# ប្រជុំរឿងប្រេត

## ភាគទី ២ ( បញ្ចប់ )

# បេតវត្ថុ

## និង

# បរមត្ថទីបនី

រៀបរៀងដោយខ្ញុំព្រះករុណា

ភិក្ខុ សុន្ទរប្បញ្ញោ អ៊ុល សាជាំ

ព.ស.២៥៥៨

# ប្រជុំរឿងប្រេត



## បេតវត្ថុ និង បរមត្ថទីបនី

រៀបរៀងដោយខ្ញុំព្រះករុណា
ភិក្ខុ សុន្ទរប្បញ្ញោ អ៊ុល សាដាំ

ព.ស.២៥៥៨


ជីវិតក្រោមម្លប់ធម៌វិន័យ

# អារម្ភកថា

ព្រះសម្មាសម្ពុទ្ធជាសាស្តាចារ្យនៃទេវតា និងមនុស្សទាំងឡាយ ព្រះអង្គទ្រង់ជ្រាបច្បាស់នូវរឿងរ៉ាវទាំងអស់ក្នុងលោក ឥតមានចន្លោះ ទោះបីរឿងនោះអាថ៌កំបាំងប៉ុណ្ណាក៏ដោយ ក៏ពុំអាចកន្លងរំលងនូវសព្វញ្ញុតញ្ញាណបានឡើយ ចំណែកបុគ្គលអ្នកមានសទ្ធា គឺពិតជាជឿនូវសព្វញ្ញុតញ្ញាណនោះ ដោយឥតសង្ស័យ ។ កម្មនិងវិបាករបស់កម្មជាលទ្ធផលនៃទង្វើរបស់សត្វលោក ពុំមានព្រះឥន្ទ ព្រះព្រហ្មព្រះអាទិទេពណា អ្នកបង្កើតនូវសុខ និងទុក្ខឱ្យសត្វលោកណាមួយ-ឡើយ, ស្បែខ្មៅផ្ទាំងងងឹតបានរួបរឹតបិទបាំងសត្វលោក ធ្វើឱ្យចិត្តខ្វាក់មិនឃើញសភាវធម៌ទៅតាមសេចក្តីពិត, ឃើញអំពើទុច្ចរិត ថាជា-ទឹកឃ្មុំ ដ៏មានឱជារស គួរត្រេកអរ គួរបរិភោគ គួរទទួលទាន, ដូចព្រះពុទ្ធដីកាបានត្រាស់សម្តែងថា **“ម្នាលភិក្ខុទាំងឡាយ បុគ្គល-ពាល កាលដែលធ្វើបាប ពុំដែលដឹងឡើយ ប៉ុន្តែក្រោយមក រមែងក្តៅក្រហាយព្រោះកម្មដែលខ្លួនធ្វើហើយនោះ ដូចជាភ្លើងឆេះព្រៃ”**។

សេចក្តីនៃព្រះពុទ្ធដីកា ត្រង់ពាក្យថា មិនដឹង គឺមានន័យថា

កាលដែលបុគ្គលធ្វើបាប មិនមែនមិនដឹងទេ គឺ ដឹង ៗ ថាខ្លួនធ្វើបាប យ៉ាងពិតប្រាកដ ប៉ុន្តែ អ្វីដែលថាមិនដឹងនោះ គឺមិនដឹងថាផល របស់កម្មនេះ មានសភាពយ៉ាងនេះ មានសភាពបែបនេះ ដែលខ្លួន ត្រូវទទួលទារុណកម្ម ឆេះក្នុងភ្លើងនរក ទារុណកម្មក្នុងកំណើតប្រេត ទារុណកម្មក្នុងកំណើតអបាយភូមិទាំងអស់ ប្រសិនបើសត្វលោកបាន ដឹងពីផលរបស់បាបកម្ម ដូចអ្វីដែលព្រះអង្គទ្រង់សម្តែងនោះ ម្ល៉េះសម សត្វលោកទាំងឡាយ រមែងខ្លាចក្រែងរអា ញញើត ខ្ពើមចំពោះបាប មិនចេះតែធ្វើតាមតែអំណាចនៃចិត្ត ដោយងាយ ៗ នោះឡើយ ។

បន្ទាប់ពីប្រជុំរឿងប្រេតភាគទី ១ ត្រូវបានបញ្ចប់មក នៅក្នុង-សៀវភៅប្រជុំរឿងប្រេតភាគទី ២ ដែលជាភាគបញ្ចប់នេះ ខ្ញុំក៏បាន ប្រមូល និងចងក្រងបន្តក្នុងគម្ពីរបេតវត្ថុ និងក្នុងគម្ពីរផ្សេង ៗ ទៀត មានក្នុងព្រះវិន័យជាដើម ដើម្បីជាប្រយោជន៍សម្រាប់កុលបុត្រ និង ពុទ្ធបរិស័ទទាំងឡាយ អ្នកដែលមានសទ្ធាជឿនូវកម្ម និងផលរបស់កម្ម ទុកគ្រាន់ជាទីរលឹកនៅក្នុងព្រះសាសនា ។

នៅក្នុងការរៀបរៀងសៀវភៅនេះ ខ្ញុំព្រះករុណា គឺគ្រាន់តែ ជាការចូលរួមចំណែកនូវធម្មទានតែប៉ុណ្ណោះ មិនមានបំណងដើម្បី នឹងបាននូវកិត្តិយសកេរ្តិ៍ឈ្មោះអ្វីនោះទេ ក៏សូមសារភាពនូវការ ចេះដឹងដ៏តិចតួចស្តួចស្តើង អំពីសម្នាក់លោកអ្នកសប្បុរសទាំងឡាយ

ក្រែងការចងក្រងនូវសៀវភៅនេះ មានកំហុសដោយប្រការណា ក៏សូមមេត្តាអនុគ្រោះអភ័យទោសដល់ខ្ញុំដែលជាអ្នករៀបរៀងផងចុះ ។

ជាទីបញ្ចប់ ដោយអំណាចនៃធម្មទាននេះ និងបុញ្ញរាសីទាំងឡាយ ដែលបានសន្សំហើយក្នុងព្រះសាសនា សូមលើកឡើងនូវមហាកុសលនេះ ឧទ្ទិសប្រគេននិងជូនចំពោះអតីតក្រុមជំនុំព្រះត្រៃបិដកទាំងអស់ មានសម្តេចព្រះសង្ឃរាជ ជួន ណាត **ជោតញ្ញាណោ** ជាដើម ព្រមទាំងព្រះគ្រូឧបជ្ឈាយាចារ្យ និងញាតិកាក្នុងសង្សារវដ្តទាំងអស់ មួយអន្លើដោយសព្វសត្វក្នុងត្រៃភព សូមបានចំណែកនៃបុណ្យនេះ ឧបត្ថម្ភគាំពារ បង្គ្រប់នូវហេតុឯណានីមួយ សម្រេចនូវព្រះនិព្វាន គ្រប់ព្រះអង្គ គ្រប់គ្នា កុំបីក្លាយជាបការៈដទៃឡើយ ។

សូមអនុមោទនា !!!

១៥
បាត់ដំបង វត្តភ្នំអណ្តើក ថ្ងៃ ៤ ។ ៤ ព.ស. ២៥៥៨

( គ.ស. 2015 )

**ភិក្ខុសុន្ទរបញ្ញោ** អ៊ុល សាដាំ

# អ្នកជួយប្រែនិងពិនិត្យអក្ខរាវិរុទ្ធ

-ព្រះភិក្ខុ **ញាណសារោ** យ៉ាវ សំអឿន ( ជួយបកប្រែ )

-វាយអត្ថបទដោយ ភិក្ខុ **សុន្ទរប្បញ្ញោ** អ៊ុល សាដាំ ( រ៉ាដូ )

# មាតិការឿង

ល.រ. ទំព័រ


~ ពន្យល់ពាក្យនិងវចនត្ថៈ អធិប្បាយភូមិប្រេត ..... ១
~ យមរាជ គឺ វេមានិកប្រេត ................................ ៨
~ ឈ្មោះរបស់ប្រេតផ្សេងៗ ................................ ៩
~ គន្ធារម្ភកថា ................................................... ១៥


## ចូឡវគ្គទី ៣ មាន ១០ រឿង


១. រឿងអភិជ្ឈមានប្រេត ............................................ ២០
២. រឿងសានុវាសិប្រេត ............................................. ៣៨
៣. រឿងរថការីប្រេត ................................................ ៥៦
៤. រឿងភុសប្រេត .................................................. ៦៥
៥. រឿងកុមារប្រេត ................................................. ៧២
៦. រឿងសេរិនីប្រេត ................................................. ៨៤
៧. រឿងមិគលុទ្ទប្រេត ............................................... ៩២
៨. រឿងទុតិយមិគលុទ្ទប្រេត ........................................ ៩៩
៩. រឿងកូដវិនិច្ឆយប្រេត ........................................... ១០៣

១០. រឿងធាតុវិវណ្ណប្រេត ........................................... ១០៩

## មហាវគ្គទី ៤ មាន ១៦ រឿង

១. រឿងអម្ពសក្ខរប្រេត ........................................... ១១៧
២. រឿងសេរីសកប្រេត ........................................... ១៦៧
៣. រឿងនន្ទិកាប្រេត ........................................... ២០៧
៤. រឿងរេវតីប្រេត ........................................... ២៣២
៥. រឿងឧច្ឆុប្រេត ........................................... ២៥១
៦. រឿងកុមារប្រេត ........................................... ២៥៨
៧. រឿងរាជបុត្តប្រេត ........................................... ២៦៤
៨. រឿងគូថខាទកប្រេត ........................................... ២៧១
៩. រឿងគូថខាទកប្រេត ........................................... ២៧៧
១០. រឿងគណប្រេត ........................................... ២៨០
១១. រឿងបាដលិបុត្តប្រេត ........................................... ២៨៤
១២. រឿងអម្ពវនប្រេត ........................................... ២៨៩
១៣. រឿងអក្ខរុក្ខប្រេត ........................................... ២៩៧
១៤. រឿងភោគសំហប្រេត ........................................... ៣០១
១៥. រឿងសេដ្ឋិបុត្តប្រេត ........................................... ៣០៤

- រឿងបុរសម្នាក់ ........................................ ៣១១
- មតកភត្តជាតកទី ៨ ........................................ ៣៤៤
១៦. រឿងសដ្ឋីកូដសហស្សប្រេត ........................................ ៣៥១

## បកិណ្ណកប្រេត

## ក្នុងព្រះធម្មបទមាន ៥ រឿង

១. រឿងអហិប្រេត ........................................ ៣៦២
២. រឿងកាកប្រេត ........................................ ៣៦៤
៣. រឿងសដ្ឋីកូដប្រេត ........................................ ៣៧២
៤. រឿងអជគរប្រេត ........................................ ៣៨២
៥. រឿងសូករប្រេត ........................................ ៣៩០

## ក្នុងវិន័យភាគ ១ និងក្នុងលក្ខណសំយុត្តភាគ ៣២

## អដ្ឋិសង្ខលិកវគ្គមាន ១០ រឿង

១. រឿងអដ្ឋិសង្ខលិកប្រេត ........................................ ៤០២
២. រឿងមំសបេសិប្រេត ........................................ ៤១៣

៣. រឿងមំសបិណ្ឌប្រេត ........................................ ៤១៤
៤. រឿងនិច្ឆវិប្រេត ........................................ ៤១៥
៥. រឿងអសិលោមប្រេត ........................................ ៤១៦
៦. រឿងសត្តិលោមប្រេត ........................................ ៤១៧
៧. រឿងឧសុលោមប្រេត ........................................ ៤១៨
៨. រឿងសូចិលោមប្រេតទី ១ ........................................ ៤១៩
៩. រឿងសូចិលោមប្រេតទី ២ ........................................ ៤២០
១០. រឿងកុម្ភណ្ឌប្រេត ........................................ ៤២២

## បរទារិកវគ្គមាន ១១ រឿង

១. រឿងបរទារិកប្រេត ........................................ ៤២៥
២. រឿងព្រាហ្មណ៍កំណាច ( គូថខាទិប្រេត ) ................ ៤២៧
៣. រឿងនិច្ឆវិស្រីប្រេត ........................................ ៤២៨
៤. រឿងមង្គុឡីស្រីប្រេត ........................................ ៤២៩
៥. រឿងឱកិលិនីស្រីប្រេត ........................................ ៤៣១
៦. រឿងអសីសកពន្ធប្រេត ( ចោរឃាតប្រេតឬសីសច្ឆិន្នប្រេត ).៤៣៣
៧. រឿងភិក្ខុប្រេត ........................................ ៤៣៤

៨. រឿងភិក្ខុនីប្រេត ............................................... ៤៣៥

៩. រឿងសិក្ខមានាប្រេត ........................................... ៤៣៦

១០. រឿងសាមណេរប្រេត ........................................ ៤៣៧

១១. រឿងសាមណេរីប្រេត ........................................ ៤៣៨


## ចប់លក្ខណសំយុត្ត


- ប្រេតក្នុងរឿងព្រះសោណកុដិកណ្ណៈ ...................... ៤៤១
- កាលកញ្ជិកអសុរ ................................................ ៤៥៤
- បាដិកសូត្រទី ១ .................................................. ៤៥៦
- រឿងមិត្តវិន្ទុកៈ ..................................................... ៤៧១
- រឿងមិត្តវិន្ទុកៈក្នុងលោសកជាតក........................... ៤៧៩
- រឿងបុរោហិត ...................................................... ៤៩៨

# សុត្តន្តបិដក

# ខុទ្ទកនិកាយ បេតវត្ថុ និង បរមត្ថទីបនី

# បញ្ចមភាគ

**នមោ តស្ស ភគវតោ អរហតោ សម្មាសម្ពុទ្ធស្ស ។**

សូមនមស្ការ ព្រះមានព្រះភាគ អរហន្តសម្មាសម្ពុទ្ធ ព្រះអង្គនោះ ។

## ពន្យល់ពាក្យ និងវចនត្ថៈ អបាយភូមិឬប្រេត

**-អបាយភូមិ** = អបាយ + ភូមិ ។

**-អបាយ** ( នាម ) ( ស. ),( បា. ) = ទីដែលប្រាសចាកសេចក្ដីចម្រើន, ទីវេទនាមានឋាននរកជាដើម ), សេចក្ដីសាបសូន្យ, សេចក្ដីវិនាស, ដំណើរលិចលង់ក្នុងសេចក្ដីវិនាស ។

**-ភូមិ** ( នាម ) ( ស. ),( បា. ) ( ភូម ) ( ភូមិ ) = ផែនដី, ទីដី, តំបន់, ផ្ទៃ, ទី, ជាន់, ថ្នាក់ ។

**-អបាយភូមិ** ( ភូម ) = ជាន់ឬឋានអបាយ, កំណើតសត្វដែល-

ប្រាសចាកសេចក្តីចម្រើន : នរក, តិរច្ឆាន, ប្រេត, អសុរកាយ, ទាំង ៤ នេះ ជាអបាយភូមិ ។

-**ប្រេត** ( នាម )( ស. ),( បា. )( ត.ទ.អ.ថ.ប្រែត )( បេត ) = សត្វកើតក្នុងអបាយភូមិពួកមួយ : ពួកប្រេត ។ គុណនាម = អ្នកដែលធ្វើមរណកាលទៅកាន់បរលោកហើយ[១] ។

-**អបាយភូមិ**[២] មានវចនត្ថៈថា **បុញ្ញសម្មតា អយា យេភុយ្យេន អបគតោតិ** = **អបាយោ** ដែលឈ្មោះថា **អបាយ** ព្រោះអត្ថថា គេចចេញពីសេចក្តីចម្រើន ដែលហៅថា បុណ្យដោយច្រើន ។

-**សោយេវ ភូមិ ភវន្តិ ឯត្ថ សត្តាតិ** = **អបាយភូមិ** អបាយនោះឯង ជាភូមិ, សត្វទាំងឡាយ រមែងកើតក្នុងអបាយនេះ ព្រោះហេតុនោះ អបាយនេះ ទើបឈ្មោះថា **អបាយភូមិ** ។

-សត្វទាំងឡាយ ឈ្មោះថា **ប្រេត** ព្រោះអត្ថថា ទៅ គឺកន្លងហួសទៅចាកសេចក្តីសុខដ៏ប្រសើរ ។

-**បេត្តិ** មានវចនត្ថៈថា ពួកនៃប្រេតទាំងឡាយ ឈ្មោះថា **បេត្តិ** ។

---

១=ចាកវចនានុក្រមសម្តេចព្រះសង្ឃរាជ **ជួន ណាត ជោតញ្ញាណោ** ។

២= ចាកអភិធម្មត្ថសង្គហៈ បរិច្ឆេទទី ៥ វិថីមុត្តសង្គហវិភាគ ។

-**បេត្តិវិសយ** មានវចនត្ថៈថា ដែននៃប្រេតទាំងឡាយ ដោយប្រភេទ មាននិជ្ឈាមតណ្ហិកប្រេតជាដើម ឈ្មោះថា **បេត្តិវិស័យ** ។

-**អសុរ** មានវចនត្ថៈថា សត្វពួកណា រមែងមិនលេង គឺ មិនលេងរីករាយដោយការលេងទាំងឡាយ មានឥស្សរិយកីឡាជាដើម ព្រោះហេតុនោះ សត្វទាំងឡាយ ទើបឈ្មោះថា **អសុរ** បានដល់ ពួក**ប្រេតអសុរ** ។

ចំណែក**ស្តេចវេបចិត្តិអសុរ** ក្រៅពីនេះ ឈ្មោះថា **អសុរ** ព្រោះអត្ថថា ជាសត្រូវរបស់ទេវតា ។ អាចារ្យទាំងឡាយ ពោលថា ពួកវេបចិត្តិអសុរ ជាទេវតាក្នុងជាន់តាវត្តិង្ស ។

## អសុរ ៣ ពួក

១- **ទេវអសុរ** បានដល់ អសុរដែលជាទេវតា

២- **បេត្តិអសុរ** បានដល់ អសុរដែលជាប្រេត

៣- **និរយអសុរ** បានដល់ អសុរដែលជាសត្វនរក

## អធិប្បាយ

១-**ទេវអសុរ** បានដល់ អសុរដែលជាប្រធាន ជាស្តេចអសុរ, **<u>ក្នុងមនោរថបូរណី អដ្ឋកនិបាត</u>** ពោលថា :

ស្តេចអសុរ មាន ៣[1] គឺ ស្តេចវេបចិត្តិ ១, អសុរិន្ទរាហូ ១, និងស្តេចមហារាទៈ ១ ។

-**ស្តេចវេបចិត្តិ** ពីដើមឈ្មោះថា **ស្តេចសម្ពរអសុរ** ជាសត្រូវនឹងពួកឥសី ទើបត្រូវឥសីប្រទេចផ្តាសា តាំងពីនោះ ស្តេចសម្ពរអសុរក៏មានចិត្តរវើរវាយ រសាប់រសល់ ដេកមិនលក់ ទើបបានឈ្មោះថ្មីថា ស្តេចវេបចិត្តិ ។

-**អសុរិន្ទរាហូ** មានរាងកាយធំ និងខ្ពស់ណាស់ ក្នុងអដ្ឋកថាពោលថា អសុរិន្ទរាហូ មានកំពស់ តាំងពីជើងដល់ក្បាល ៤.៨០០ យោជន៍, រវាងស្មាទាំងពីរ ១១២ យោជន៍, មានផ្ទៃមុខ ៦០០ យោជន៍, ផ្ទៃបាតដៃ និងបាតជើង ៣០០ យោជន៍, មាត់ ៣០០ យោជន៍, អង្គុលី ( ម្រាម ) មួយថ្នាំង ៗ ៥០ យោជន៍, ចន្លោះចិញ្ចើម ៥០ យោជន៍, ថ្ងាស ៣០០ យោជន៍, ក្បាល ៩០០ យោជន៍, កាលរាហូនោះ ចុះក្នុងទឹកមហាសមុទ្រដែលជ្រៅ ១.២០០ យោជន៍ មានប្រមាណត្រឹមជង្គង់ ។

-**ស្តេចមហារាទៈ**នោះ រាប់តាំងពីថ្ងៃដែលព្រះមានព្រះភាគត្រាស់ដឹងហើយ ក៏គិតថា :

---

***១- ក្នុងបរមត្ថជោតិកៈ និងមហាអភិធម្មត្ថសង្គហៈដីកាប្រែ ថាមាន ៦ គឺ :*** *១-វេបចិត្តិអសុរា ២-សុពលិអសុរា, ៣-រាហុអសុរា, ៤-បហារអសុរា, ៥-សម្ពរតីអសុរា, ៦-វិនិបាតអសុរា ។*

ថ្ងៃនេះ យើងនឹងទៅគាល់ ព្រឹកស្អែកយើងនឹងទៅគាល់ ដរាបដល់វេលា ១១ ឆ្នាំ ក្នុងឆ្នាំទី ១២ ទើបបានទៅគាល់ទូលសួរបញ្ហា ។ ពួកអសុរទាំងនេះ មានពិភពដែលអាស្រ័យនោះក្រៅភ្នំ-សិនេរុ ដែលមានផ្ទៃដីទំហំ ១ ម៉ឺនយោជន៍ ប៉ុនឋានតាវត្តិង្ស ។

២-**បេត្តិអសុរា**[១] ជាទេវតាមួយពួក មានអានុភាពច្រើន ហៅថា **វិនិបាតអសុរា** ( អសុរដែលមិនផុត ចាកអបាយ ) បានដល់ បិយង្ករមាតាយក្ខិនី, ឧត្តរមាតាយក្ខិនី, ផុស្សមិត្តាមាតាយក្ខិនី, ធម្មគុត្តមាតាយក្ខិនី, និងវេមានិកប្រេត ទេវតាទាំងនោះ អាស្រ័យនៅតាមព្រៃភ្នំ និងតាមដើមឈើជាដើម ជាបរិវាររបស់ភុម្មដ្ឋទេវតា សង្គ្រោះចូលក្នុងពួកទេវតាជាន់ចាតុម្មហារាជិកា ។ មួយទៀត ពាក្យថា **បេត្តិអសុរ** នេះ លោកពោលថា សត្វដែលកើតក្នុងពួកអសុរ មាន**កាលកញ្ជិកាសុរ**ជាដើម ។

៣-**និរយអសុរ** បានដល់ សត្វដែលកើតក្នុងលោកន្តរនរក ។

**ក្នុងអដ្ឋកថា អង្គុត្តរ-ចតុក្ក.** ពោលថា អសុរនេះ កាលនៅជាមនុស្ស បានធ្វើកម្មធ្ងន់ គឺ ទារុណកម្មដល់មាតាបិតា ប្រទូស្តចំពោះ-

---

***១- ក្នុងបរមត្ថជោតិកៈ និងមហាអភិធម្មត្ថសង្គហៈដីកាប្រែ ថាមាន ៣ គឺ :***
*១-កាលកញ្ជិកប្រេតអសុរា, ២-វេមានិកប្រេតអសុរា, ៣-អាវុធិកប្រេតអសុរា ( បានដល់ពួកប្រេត ដែលវាយប្រហារគ្នា និង គ្នាដោយអាវុធផ្សេង ៗ ) ។*

សមណព្រាហ្មណ៍ដែលទ្រទ្រង់ធម៌ និងការសម្លាប់សត្វរាល់ ៧ ថ្ងៃ ជាដើម ដូចអភ័យចោរ និងនាគចោរ ក្នុងតម្ពបណ្ណិទ្វីប ក៏អសុរនេះ មានអត្តភាពកំពស់ ៣ គាវុត មានក្រចកវែង តោងនៅត្រង់ជើងភ្នំ ចក្រវាឡ ដូចសត្វប្រចៀវ ( ឬជ្រឹង ) នៅក្នុងទីងងឹត ដូច្នោះ ។

## ក្នុងបរមត្ថជោតិកៈ និងមហាអភិធម្មត្ថសង្គហដីកា បានពន្យល់ថា :

១-**សុខសមុស្សយតោ បាកដ្ឋំ ឯតីតិ - បេតា** សត្វដែលឈ្មោះថា **បេតៈ** ព្រោះរមែងដល់នូវឋានៈ ដែលឃ្លាតឆ្ងាយពីសេចក្ដីសុខទាំងឡាយ ។

២-**បេតានំ សមូហោ - បេត្តិ** ពួកប្រេតទាំងឡាយ ឈ្មោះថា **បេត្តិ** ។

៣-**បេត្តិយា វិសយោ - បេត្តិវិសយោ** ទីនៅទីកើតនៃប្រេតទាំងឡាយ ឈ្មោះថា **បេត្តិវិសយៈ** ពាក្យសព្ទដែលពោលថា បេតៈនេះ សត្វទាំងឡាយស្លាប់ទៅហើយ ហៅថា **បេតៈ** ដូចគ្នាទាំងអស់ តែចំពោះក្នុងទីនេះសំដៅយកសត្វដែលកើតជាប្រេត ពោលតាមន័យវេយ្យាករណ៍ ក្នុងពាក្យថា **បេតា** ញែកសព្ទដូច្នេះ **ប** + **ឥ** + **ត**. **ប** ជាឧបសគ្គបទ. **ឥ** ជាធាតុ. **ត** ជាបច្ច័យ

ធម្មតាប្រេតទាំងឡាយ រមែងមិនមានទីលំនៅអាស្រ័យចំពោះខ្លួន ដូច្នោះប្រេតទាំងនោះ ទើបមាននៅរាត់រាយទូទៅ ដូចតាមព្រៃ, តាមភ្នំ ជ្រោះ កោះ ទន្លេ សមុទ្រ ព្រៃស្មសាន ហេតុនោះ ព្រះអនុរុទ្ធាចារ្យ ទើបសម្តែងថា **បេត្តិវិសយោ** ។

***ពាក្យថា*** **ប្រេតនោះ** បានដល់ ខ្មោច យក្ស និងប្រេតជាដើម ដែលមនុស្សទាំងឡាយប្រើពាក្យនេះ និយាយគ្នាជាទូទៅ ឯប្រេត មានច្រើនពួក ប្រេតពួកខ្លះមានខ្លួនតូច ប្រេតពួកខ្លះមានខ្លួនធំ ប្រេតនេះអាចនិម្មិតខ្លួនឱ្យជាឥដ្ឋារម្មណ៍ ឬអនិដ្ឋារម្មណ៍បាន ចំណែក ឥដ្ឋារម្មណ៍ឱ្យឃើញជាទេវតា ជាមនុស្សប្រុស មនុស្សស្រី ជាតាបស ជាព្រះថេរៈ ជាភិក្ខុ ជាដូនជី, បើចំណែកអនិដ្ឋារម្មណ៍ឱ្យឃើញជាគោ ក្របី ដំរី សេះ សុនខ រូបរាងសណ្ឋានគួរឱ្យខ្លាច មានក្បាលធំ ភ្នែកលៀនប៉ោង ជួនកាលមិនប្រាកដច្បាស់ គ្រាន់តែឱ្យឃើញស្នុង ១ ជាពណ៌ខ្មៅ ក្រហម ស , បណ្តាប្រេតទាំងឡាយនេះ ពួកខ្លះត្រូវ សោយទុក្ខវេទនាយូរយារ អត់បាយ អត់ទឹក, ពួកខ្លះ ចូលទៅរកស៊ី កាកសំណល់អាហារ ដែលអ្នកស្រុកចាក់ចោលក្នុងគំនរសំរាម, ពួក-ខ្លះ ក៏ស៊ីកំហាក ស្លេស្ម ទឹកមាត់ ទឹកសំបោរ និងឧច្ចារៈ ( លាមក ) ចំណែកប្រេតដែលអាស្រ័យនៅតាមភ្នំ មានភ្នំគិជ្ឈកូដជាដើមនោះ

មិនត្រឹមតែអត់អាហារប៉ុណ្ណោះទេ ថែមទាំងត្រូវសោយទុក្ខវេទនា ដូចសត្វនរកថែមទៀតផង ។

# យមរាជ គឺ វេមានិកប្រេត

( អដ្ឋកថា ទេវទូតសូត្រទី ៦ តិកនិបាត ភាគ ៤១, ទំព័រ ១៥៣ )

បទថា **យមស្ស រញ្ញោ** ( ដល់យមរាជ ) សេចក្ដីថា ស្ដេចវេមានិកប្រេត ឈ្មោះថា យមរាជ វេលាមួយ សោយសម្បត្តិ មានដើមកប្បព្រឹក្សទិព្វ ឧទ្យានទិព្វ និងពួកនាងទេពអប្សរជាដើម ក្នុងវិមានទិព្វ ។ វេលាមួយ សោយផលរបស់កម្ម ។ យមរាជអ្នកតាំងនៅក្នុងធម៌ជាធម្មរាជា មានហើយ, និងយមរាជនោះ ក៏មិនមែនមានតែមួយព្រះអង្គឯង ប៉ុន្តែថា មានដល់ ៤ អង្គ ត្រង់ ៤ ទ្វារ ។

# ឈ្មោះរបស់ប្រេតផ្សេង ៗ

-**ប្រេត ១២ ពួក** ដែលមានមកក្នុងបញ្ញត្តិបករណ៍និងឆគតិទី-បនីបករណ៍គឺ :

១- **វន្តាសាប្រេត** ប្រេតដែលស៊ីខេឡ: ( ទឹកមាត់ ) ស្លេស្ម កំអួតជាអាហារ ។

២- **កុណបខាទប្រេត** ប្រេតស៊ីសាកសពមនុស្ស សត្វ ជា-អាហារ ។

៣- **គូថខាទកប្រេត** ប្រេតស៊ីលាមកផ្សេង ៗ ជាអាហារ ។

៤- **អគ្គិជាលមុខប្រេត** ប្រេតមានអណ្តាតភ្លើងឆេះនៅក្នុង-មាត់ ។

៥- **សូចិមុខប្រេត** ប្រេតមានមាត់ប៉ុនរន្ធម្ជុល ។

៦- **តណ្ហដ្ដិតប្រេត** ប្រេតត្រូវតណ្ហាបៀតបៀន គឺស្រេក-ឃ្លានជានិច្ច ។

៧- **សុនិជ្ឈាមកប្រេត** ប្រេតមានដងខ្លួនខ្មៅដូចដង្គត់ឈើភ្លើងរោល ។

៨.**សត្តុទ្ធប្រេត** ប្រេតមានក្រចកដៃក្រចកជើងវែង មុតដូចកាំបិត ។

៩. **បព្វតង្គប្រេត** ប្រេតដែលមានរាងកាយខ្ពស់ធំប៉ុនភ្នំ ។

១០. **អជគរង្គប្រេត** ប្រេតដែលមានរាងកាយដូចពស់ថ្លាន់ ។

១១. **វេមានិកប្រេត** ប្រេតដែលសោយទុក្ខពេលថ្ងៃ តែដល់យប់ទៅសោយសុខក្នុងវិមាន ។

១២. **មហិទ្ធិកប្រេត** ប្រេតដែលមានឫទ្ធិច្រើន ។

## វចនត្ថៈ របស់ប្រេតទាំង ១២ ពួក តាមលំដាប់

១. **វន្តំ អសតិ ភក្ខតីតិ** = **វន្តាសោ** ប្រេតដែលឈ្មោះថា **វន្តាសះ** ព្រោះស៊ីទឹកមាត់ ស្លេស្ម កំអួត កំហាក ។

២. **កុណបំ អសតិ ភក្ខតីតិ** = **កុណបាសោ** ប្រេតដែលឈ្មោះថា **កុណបាសះ** ព្រោះស៊ីសាកសពមនុស្ស ឬសត្វ ។

៣. **គូថំ ខាទតីតិ** = **គូថខាទកោ** ប្រេតដែលឈ្មោះថា **គូថខាទកះ** ព្រោះស៊ីឧច្ចារៈ ( លាមក ) ។

៤. **អគ្គិជាលា មុខតោ ឯតស្សាតិ** = **អគ្គិជាលមុខោ** ប្រេតដែលឈ្មោះថា **អគ្គិជាលមុខះ** ព្រោះមានអណ្តាតភ្លើងឆេះនៅក្នុងមាត់ ។

៥. **សូចិបមាណំ មុខំ ឯតស្សាតិ = សូចិមុខោ** ប្រេតដែលឈ្មោះថា **សូចិមុខះ** ព្រោះមានមាត់ប៉ុនរន្ធម្ជុល ។

៦. **តណ្ហាយ អដ្ដិតោ បីឡិតោតិ = តណ្ហដ្ដិតោ** ប្រេតដែលឈ្មោះថា **តណ្ហដ្ដិតះ** ព្រោះត្រូវបៀតបៀនដោយតណ្ហា គឺឃ្លានបាយស្រេកទឹក ។

៧. **សុដ្ឋុ និស្សេសេន ឈាមោ = សុនិជ្ឈាមោ សុនិជ្ឈាមោ វិយាតិ = សុនិជ្ឈាមកោ** ដើមឈើដែលត្រូវភ្លើងឆេះ រោលមែក ស្លឹកនិងដើម ដោយមិនមានសល់ហើយនៅសល់តែដង្គត់ ឈ្មោះថា **សុនិជ្ឈមកះ** បានដល់ ដង្គត់ ដែលត្រូវភ្លើងឆេះ, ប្រេតដែលឈ្មោះថា **សុនិជ្ឈាមកះ** ព្រោះ ខ្មៅ ដូចដង្គត់ឈើត្រូវភ្លើងឆេះ ។

៨. **សត្តសទិសំ អង្គំ ឯតស្សាតិ = សត្តង្គោ** ប្រេតដែលឈ្មោះថា **សត្តង្គះ** ព្រោះមានក្រចកដៃ ក្រចកជើងវែង ហើយមុតដូចមុខកាំបិត ។

៩. **បព្វតប្បមាណោ អង្គោ ឯតស្សាតិ = បព្វតង្គោ** ប្រេតដែលឈ្មោះថា **បព្វតង្គះ** ព្រោះមានរាងកាយប៉ុនភ្នំ ។

១០. **អជគរសទិសោ អង្គោ ឯតស្សាតិ = អជគរង្គោ** ប្រេតដែលឈ្មោះថា **អជគរង្គះ** ព្រោះមានរាងកាយ ដូចពស់ថ្លាន់ ។

១១. **វិមានេ និព្វត្តោតិ = វេមានិកោ** ប្រេតដែលឈ្មោះថា

**វេមានិកៈ** ព្រោះកើតក្នុងវិមាន តែថ្ងៃត្រូវសោយទុក្ខ ពេលយប់ត្រូវសោយសុខ ។

១២. **មហិទ្ធិយា ឥទ្ធិយា សមន្នាគតោតិ - មហិទ្ធិកោ** ប្រេតដែលឈ្មោះថា **មហិទ្ធិកៈ** ព្រោះមានឫទ្ធិច្រើន ។

## ទីលំនៅរបស់ប្រេត ១២ ពួក និងស្ដេចនៃប្រេត

នៅជើងភ្នំហិមាល័យ មានព្រៃមួយកន្លែងឈ្មោះព្រៃវិជ្ឈាដវីជានគរនៃប្រេត ១២ ពួក ដែលបានពោលមកហើយនោះ អាស្រ័យនៅ បណ្ដាប្រេត ១២ ពួកនេះ មហិទ្ធិប្រេត ជាស្ដេចនៃប្រេតទាំងឡាយ ដូចមានបាលីសម្ដែងទុកក្នុងលោកបញ្ញត្តិបករណ៍ថា "**យត្ថ បេតនគរេ បេតមហិទ្ធិកោ សព្វបេតានំ ឥស្សរិយាធិបច្ចំ ករោតិ** " នគរនៃប្រេតនេះ នៅក្នុងព្រៃវិជ្ឈាដវី ឯព្រៃវិជ្ឈាដវីនេះ តាំងនៅបរិវេណ ភ្នំហិមាល័យនោះឯង នគរគឺព្រៃវិជ្ឈាដវីមាន **មហិទ្ធិកប្រេត** ជាស្ដេចគ្រប់គ្រងថែរក្សាពួកប្រេតទាំងឡាយ ។

## ប្រេត ៤ ពួកដែលមានមកក្នុងអដ្ឋកថា និងដីកា

១. **បរទត្តូបជីវិកប្រេត** ប្រេតដែលចិញ្ចឹមជីវិត ដោយអាស្រ័យអាហារ ដែលអ្នកដទៃឱ្យ ។

២. **ខុប្បិបាសិកប្រេត** ប្រេតដែលត្រូវបៀតបៀនដោយសេចក្ដីស្រេកឃ្លាន ។

៣. **និជ្ឈាមតណ្ហិកប្រេត** ប្រេតដែលត្រូវឆេះដុតរោលឱ្យក្ដៅជាប់ជានិច្ច ។

៤. **កាលកញ្ជិកប្រេត** ជាឈ្មោះរបស់អសុរា ដែលជាប្រេត, កាលកញ្ជិកប្រេតនេះ មានរាងកាយខ្ពស់ ៣ គាវុត មិនសូវមានកម្លាំងទេ ព្រោះមានឈាមនិងសាច់តិច មានសម្បុរ សណ្ឋានដូចស្លឹកឈើក្រៀមស្វិត ភ្នែកលៀនចេញមកដូចភ្នែកក្ដាម ហើយមានមាត់ទំហំ ប៉ុនរន្ធគូថម្ជុល តាំងនៅចំកណ្ដាលក្បាល ។

## វចនត្ថៈរបស់ប្រេត ៤ ពួក ដែលបានសម្ដែងមក

១.**បរេហិ ទត្តំ ឧបនិស្សាយ ជីវតីតិ - បរទត្តូបជីវិកោ** ប្រេតដែលមានឈ្មោះថា **បរទត្តូបជីវិកៈ** ព្រោះមានការចិញ្ចឹមជីវិតដោយអាស្រ័យអាហារដែលអ្នកដទៃឱ្យ ។

២.**ខុទ្ទា ច បិបាសា ច = ខុប្បិបាសា,ខុប្បិបាសាហិ បិឡិតោ = ខុប្បិបាសិកោ** ការឃ្លានបាយផង ការស្រេកទឹកផង ឈ្មោះថា **ខុប្បិបាសៈ** ប្រេតដែលឈ្មោះថា **ខុប្បិបាសៈ** ព្រោះត្រូវបៀតបៀនដោយការឃ្លានបាយ និងស្រេកទឹក ។

៣-**និជ្ឈាមេន តណ្ហា ឯតស្សាតិ = និជ្ឈាមតណ្ហិកោ** ប្រេត ដែលឈ្មោះថា **និជ្ឈាមតណ្ហិកៈ** ព្រោះមានតួតណ្ហា គឺឃ្លានចាយ ស្រេកទឹក ជាប់ជានិច្ច បណ្តាលមកពីភ្លើងឆេះចេញពីក្នុងមាត់ នោះឯង ។

៤-**កាលកញ្ជិកប្រេត** មិនមានសម្តែងវចនត្ថៈ ព្រោះជាឈ្មោះ របស់អសុរា មានសម្តែងទុកក្នុងបាថេយ្យវគ្គអដ្ឋកថា ថា " **កាលកញ្ជិ-កាតិ តេសំ អសុរានំ នាមំ** " ពាក្យថា " **កាលកញ្ជិកៈ** " នេះ ជា-ឈ្មោះរបស់អសុរាទាំងឡាយ ដែលកើតជាប្រេតនោះឯង ។

# គន្ថារម្ភកថា

ខ្ញុំសូមនមស្ការ នូវព្រះលោកនាថជាម្ចាស់ ទ្រង់ប្រកបដោយព្រះមហាករុណាគុណ ទ្រង់ដល់នូវត្រើយនៃសាគរ គឺញេយ្យធម៌ ទ្រង់មានទេសនាន័យ ដ៏ល្អិតជ្រាលជ្រៅ និងវិចិត្រ ។

ខ្ញុំសូមនមស្ការ នូវព្រះធម៌ ដ៏ប្រសើរបំផុត ដែលព្រះសម្មាសម្ពុទ្ធ ទ្រង់បូជាហើយ ដែលជា-គ្រឿងនាំសត្វអ្នកបរិបូណ៌ដោយវិជ្ជា និងចរណៈឱ្យចេញចាកលោក ។

ខ្ញុំសូមនមស្ការ នូវព្រះអរិយសង្ឃ ដែលបរិ-បូណ៌ដោយគុណមានសីលជាដើម ដែលតាំងនៅក្នុងមគ្គ និងផលដែលជាបុញ្ញក្ខេត្តដ៏ប្រសើរ ។

ដោយតេជៈនៃបុណ្យ ដែលកើតអំពីការនមស្ការព្រះរតនត្រ័យ ដូចពោលមកហើយនេះ សូមឱ្យខ្ញុំចូរជាអ្នកមានអន្តរាយដែលគំនរបុណ្យនោះ កម្ចាត់-បង់ហើយក្នុងទីគ្រប់ស្ថាន ក៏ទេសនាណា របស់ព្រះ-

ពុទ្ធទាំងឡាយ ប្រកាសដល់កម្មដែលប្រេតទាំងឡាយ
ធ្វើទុកក្នុងជាតិមុន ដែលជាហេតុនាំមកនូវភាពជា-
ប្រេត ដោយសេចក្តីផ្សេងគ្នានៃផលកម្មរបស់ប្រេត
ទាំងនោះដែលនាំសេចក្តីសង្វេគឱ្យកើតដ៏ពិសេស ធ្វើ
កម្ម និងផលរបស់កម្មឱ្យប្រចក្ស ទេសនានោះមាន
រឿងដែលជ្រាបច្បាស់ហើយ មានឈ្មោះថា **បេតវត្ថុ**
ដែលលោកអ្នកស្វែងរកនូវគុណដ៏ធំបានសង្គាយនាទុក
ហើយក្នុងខុទ្ទកនិកាយ ។ ខ្ញុំនឹងកាន់យកន័យនៃអដ្ឋ-
កថាចាស់របស់បេតវត្ថុនោះមកពន្យល់ដល់ហេតុ ក្នុង
រឿងនោះ ៗ ឱ្យជាក់ច្បាស់ដ៏ពិសេស នឹងធ្វើនូវ-
អត្ថសំវណ្ណនាដ៏ស្អាតបរិសុទ្ធដោយល្អ មិនសាំញ៉ាំ
មានអត្ថ និងវិនិច្ឆ័យដ៏ល្អិត មិនជំទាស់នឹងលទ្ធិរបស់
ព្រះមហាថេរៈ អ្នកនៅក្នុងមហាវិហារតាមកម្លាំង
សូមសាធុជនទាំងឡាយ ចូរតាំងចិត្តស្តាប់ នូវអត្ថសំ-
វណ្ណនានោះរបស់ខ្ញុំ អ្នកពោលដោយគោរព ហោង ។

បណ្តាបទទាំងនោះ បទថា **បេតវត្ថុ** បានដល់ កម្មដែល
ជាហេតុឱ្យសត្វនោះ ៗ មានបុត្តនៃសេដ្ឋីជាដើម កើតជាប្រេត ។ ក៏
ព្រះបរិយត្តិធម៌ ដែលប្រព្រឹត្តទៅដោយប្រកាសដល់កម្មនោះ មាន-

ជាដើមថា ព្រះអរហន្តទាំងឡាយ ប្រៀបដូចស្រែ លោកសំដៅយក បេតវត្ថុក្នុងទីនេះ ។

សួរថា បេតវត្ថុនេះនោះ នរណាពោល ពោលនៅទីណា ពោលកាលណា និងព្រោះហេតុអ្វីទើបពោល ? ខ្ញុំនឹងឆ្លើយ : មែនពិត បេតវត្ថុនេះកើតដោយហេតុ ២ យ៉ាង គឺដោយហេតុដែលកើតឡើងនៃរឿង ១ ដោយអំណាចនៃពាក្យសួរ និងពាក្យឆ្លើយ ១ ។ ក្នុងបណ្ដាហេតុទាំងពីរយ៉ាងនោះ ដែលកើតដោយអត្ថុប្បត្តិហេតុ ព្រះដ៏មានព្រះភាគត្រាស់ ក្រៅពីនោះ ព្រះនារទត្ថេរជាដើម ជាអ្នកសួរ ពួកប្រេតនោះៗ ជាអ្នកឆ្លើយ ។ ក៏ព្រោះហេតុដែលកាលព្រះនារទត្ថេរជាដើម ក្រាបទូលដល់ពាក្យសួរ និងពាក្យឆ្លើយទាំងនោះ ព្រះសាស្ដាទើបធ្វើនូវរឿងនោះៗ ឱ្យជាអត្ថុប្បត្តិហេតុហើយ សម្ដែងធម៌ដល់បរិស័ទដែលមកប្រជុំគ្នាហើយ ។ ព្រោះហេតុនោះ បេតវត្ថុទាំងអស់នោះ ទើបឈ្មោះថា ព្រះសាស្ដាត្រាស់ទាំងអស់ ។ មែនពិត កាលព្រះសាស្ដា ទ្រង់ប្រកាសនូវព្រះធម្មចក្កដ៏ប្រសើរ គង់ប្រថាប់នៅក្នុងទីនោះៗ មានក្រុងរាជគ្រឹះជាដើម បេតវត្ថុនោះៗ ទើបឡើងកាន់ទេសនា ដោយធ្វើនូវកម្មនិងផលរបស់កម្ម នៃសត្វទាំងឡាយឱ្យប្រចក្ស ដោយការសួរនិងដោះស្រាយនូវអត្ថុប្បត្តិហេតុនោះ ៗ ដោយច្រើន ដូច្នោះ ក្នុងទីនេះទេសនានេះ ទើបជាការឆ្លើយដោយទូទៅ

នៃបទទាំងឡាយថា **តេន ភាសិតំ** ដូច្នេះជាដើម ជាលំដាប់ដំបូង ។ ប៉ុន្តែកាលបើពោលដោយមិនទូទៅ ទេសនានេះ នឹងមកក្នុងអដ្ឋ-វណ្ណនានៃរឿងនោះ ៗ ឯង ។

ក៏បេតវត្ថុនេះនោះ រាប់បញ្ចូលក្នុងសុត្តន្តបិដក ក្នុងបណ្តា-បិដកទាំង ៣ គឺ **វិន័យបិដក សុត្តន្តបិដក** និង**អភិធម្មបិដក** រាប់បញ្ចូលក្នុង**ខុទ្ទកនិកាយ** ក្នុងបណ្តានិកាយទាំង ៥ គឺ **ទីឃនិកាយ មជ្ឈិមនិកាយ សំយុត្តនិកាយ អង្គុត្តរនិកាយ** និង**ខុទ្ទកនិកាយ** សង្គ្រោះចូលក្នុងគាថា ក្នុងបណ្តាសាសនាមានអង្គ ៩ គឺ **សុត្តៈ គេយ្យៈ វេយ្យាករណៈ គាថា ឧទ្ទាន ឥតិវុត្តកៈ ជាតក អព្ភុតធម្មៈ** និង **វេទល្លៈ** ។ សង្គ្រោះចូលក្នុងធម្មក្ខន្ធតិចតួច ក្នុងបណ្តាធម្មក្ខន្ធ ៨៤,០០០ ព្រះធម្មក្ខន្ធ ដែលព្រះអានន្ទជាធម្មភណ្ឌាគារិកៈ បានប្តេជ្ញាទុកយ៉ាងនេះថា :

**ទ្វាសីតិ ពុទ្ធតោ គណ្ហិ　　ទ្វេ សហស្សានិ ភិក្ខុតោ**
**ចតុរាសីតិសហស្សានិ　　យេ មេ ធម្មា បវត្តិនោ ។**

ធម៌ទាំងឡាយណា ដែលប្រព្រឹត្តទៅក្នុងហឫទ័យ របស់ខ្ញុំ ខ្ញុំបានរៀនអំពីព្រះពុទ្ធ ៨២,០០០ ធម្មក្ខន្ធ រៀនមកអំពីពួកភិក្ខុ ២,០០០ ធម្មក្ខន្ធ រួមជា ៨៤,០០០ ព្រះធម្មក្ខន្ធ ។

ពោលដោយភាណវារៈ មានត្រឹមតែ ៤ ភាណវារៈ ពោល-

ដោយវគ្គ សង្គ្រោះជា ៤ វគ្គ គឺ **ឧរគវគ្គ ឧព្វីវគ្គ ចូឡវគ្គ** និង **មហាវគ្គ** ។ ក្នុង ៤ វគ្គនោះ **វគ្គទី ១** មាន **១២ រឿង វគ្គទី ២** មាន **១៣ រឿង វគ្គទី ៣** មាន **១០ រឿង វគ្គទី ៤** មាន **១៦ រឿង** រួមសេចក្តីថា កាលបើពោលដោយរឿង ប្រជាប់ដោយរឿង **៥១ រឿង** ។ ក្នុងបណ្តាវគ្គរបស់រឿងនោះ ឧរគវគ្គ ជាវគ្គខាងដើម ។ ក្នុងបណ្តារឿង មាន**រឿងខេត្តូបមាប្រេត**ជារឿងខាងដើម គាថារបស់រឿងខាងដើមនោះ មានពាក្យថា **ខេត្តូបមា អរហន្តោ** ជាដើម ជាគាថាដំបូង ។

# ចុឡវគ្គទី ៣

## រឿងអតិជ្ជមានប្រេត

" ប្រេតអាក្រាតពាក់កណ្តាលកាយខាងលើ "

( បិដកលេខ ៥៦, ទំព័រ ៦៦ និងអដ្ឋកថា )

កាលព្រះសាស្តាស្តេចគង់ប្រថាប់នៅក្នុងវត្តជេតពនមហាវិហារ ទ្រង់ប្រារព្ធប្រេតព្រានម្នាក់ ទើបត្រាស់នូវព្រះគាថានេះ មានពាក្យផ្តើមថា **អតិជ្ជមានេ ទារិម្ហិ** ដូច្នេះ ។

បានឮមកថា ក្នុង**ក្រុងពារាណសី** មានព្រានម្នាក់នៅក្នុងស្រុក ឈ្មោះថា **ចុន្ទដ្ឋិលៈ** ហួស**វាសភគ្រាម** នៅត្រើយម្ខាងនៃ-**ទន្លេគង្គា** គាត់បានទៅបរបាញ់សត្វក្នុងព្រៃ ហើយបានយកសាច់ដែលល្អៗ មកអាំងបរិភោគ សាច់ដ៏សេសគាត់ខ្ចប់ស្លឹកឈើរែកមកផ្ទះ ពួកក្មេងតូចៗ ឃើញគាត់ត្រង់ទ្វារស្រុក ទើបរត់លាដៃស្រែកសុំថា ចូរឱ្យសាច់ខ្ញុំ ចូរឱ្យសាច់ខ្ញុំ គាត់បានឱ្យសាច់ដល់ក្មេងទាំងនោះម្នាក់បន្តិចៗ ។ ក្រោយមកថ្ងៃមួយ ពួកក្មេងឃើញគាត់ត្រង់ទ្វារស្រុក

ដែលពុំបានសាច់ ប្រដាប់ផ្ការាជព្រឹក្សនិងត្រកងយកទៅផ្ទះមានចំនួនជាច្រើន ទើបរត់លាដៃ ស្រែកសុំថា ចូរឱ្យសាច់ខ្ញុំ ចូរឱ្យសាច់ខ្ញុំ គាត់បានឱ្យផ្កាក្រវាន់ដល់ក្មេងទាំងនោះម្នាក់ ១ ផ្កា ។

លុះកាលជាខាងក្រោយមក គាត់ធ្វើកាលកិរិយាហើយក៏បានទៅកើតក្នុងកំណើតប្រេត ជាប្រេតអាក្រាតកាយមានរូបអាក្រក់ក្រៃ-ពេក ឃើញគួរខ្លាច មិនដែលស្គាល់បាយនិងទឹកសូម្បីតែក្នុងយល់សប្តិ ទ្រទ្រង់កម្រងផ្ការាជព្រឹក្សនិងផ្កាឈើ ( ដទៃទៀត ) លើក្បាល គិតថា យើងនឹងបានអ្វី ៗ ក្នុងសម្នាក់នៃពួកញាតិក្នុង**ចុន្ទដ្ឋិលគ្រាម** កាលទឹកក្នុងទន្លេគង្គាហូរជាប់ជានិច្ច ទើបដើរច្រាសខ្សែទឹកទៅ ។ ក៏-សម័យនោះ **អាមាត្យរបស់ព្រះបាទពិម្ពិសារ** ឈ្មោះថា **កោលិយៈ** បានទៅបង្ក្រាបបច្ចន្តនគរ ដែលងើបបះបោរឱ្យស្ងប់ហើយ ក៏ត្រឡប់មកវិញ ទើបបញ្ជូនពលបរិវារ មានពលដំរីនិងពលសេះជាដើមទៅតាមផ្លូវគោក ចំណែកខ្លួនឯងមកតាមផ្លូវទូក តាមទន្លេគង្គា ឃើញប្រេតនោះកំពុងដើរទៅយ៉ាងនោះ កាលនឹងសួរទើបពោលគាថាថា :

*អ្នកឯងជាប្រេតអាក្រាត តែពាក់កណ្តាលកាយខាងលើ ជា-អ្នកទ្រទ្រង់នូវកម្រងផ្កា គាត់តែងក្បាល ដើរលើទឹកទន្លេគង្គា មិនបែកខ្ញែក ក្នុងទីនេះ ម្នាលប្រេត តើអ្នកនឹងទៅក្នុងទីណា*

*ទីនៅរបស់អ្នកនឹងមានក្នុងទីណា ។*

បណ្ដាបទទាំងនោះ បទថា **អភិជ្ជមានេ** បានដល់ មិនបែកគ្នា គឺនៅជាប់គ្នាដោយការឈានជើង ។ បទថា **វារិម្ហិ គង្គាយ** បានដល់ ទឹកក្នុងទន្លេគង្គា ។ បទថា **ឥធ** គឺក្នុងទីនេះ ។ បទថា **បុព្វឌ្ឍបេតោវ** សេចក្ដីថា មានរាងកាយពាក់កណ្ដាលខាងលើ មិនដូចប្រេត គឺដូចទេវបុត្រ មិនជាប់ទាក់ទងក្នុងកំណើតប្រេត ។ ដើម្បីជៀសវាងពាក្យសួរថា តើដូចម្ដេច ? លោកទើបពោលថា ជាអ្នកទ្រទ្រង់នូវកម្រងផ្កា អធិប្បាយថា ប្រដាប់ដោយកម្រងផ្កា ពាក់លើក្បាល ។ បទថា **កស្ស វាសោ ភវិស្សតិ** ( បិដកថា **កត្ថ វាសោ ភវិស្សតិ** ) សេចក្ដីថា ទីនៅរបស់អ្នក នៅក្នុងស្រុកណា ឬក្នុងប្រទេសណា អ្នកចូរប្រាប់រឿងនោះ ។

ឥឡូវនេះ ដើម្បីនឹងសម្ដែងពាក្យដែលប្រេតនោះនិងកោលិយ-មហាមាត្យពោលក្នុងកាលណា ព្រះសង្គីតិកាចារ្យទាំងឡាយទើបពោលគាថាថា :

*ប្រេតនោះ បាននិយាយថា ខ្ញុំនឹងទៅស្រុកចុន្ទដ្ឋិលៈ ត្រង់-ចន្លោះជិតស្រុកវាសភៈ និងក្រុងពារាណសី ។*

*ឯមហាមាត្យ ដែលល្បីឈ្មោះថា កោលិយៈ បានឃើញប្រេតនោះហើយ ក៏ឱ្យសដូវនិងបាយផង ឱ្យសំពត់លឿងមួយគូផង*

*ដល់ប្រេត ។ កាលដែលទូកឈេប់ ( កោលិយមហាមាត្យ ) បាន ប្រើខ្ញាន់ឱ្យ ( សំពត់មួយគូដល់ស្ងួម ) កាលដែលសំពត់មួយគូ ដែលខ្ញាន់ព្រះកេសឱ្យហើយ សំពត់នោះ ក៏ប្រាកដ ដល់ប្រេតមួយ-រំពេច ។ លំដាប់នោះ ប្រេតក៏ស្លៀកពាក់សំពត់ដ៏ល្អ ទ្រទ្រង់កម្រងផ្កា ស្អិតស្អាងខ្លួន ទក្ខិណាទានក៏សម្រេចដល់ប្រេតដែលឋិតនៅក្នុងទីគួរ សម្រេច ព្រោះហេតុនោះ បុគ្គលគួរឱ្យទក្ខិណាទានរឿយ ៗ ដើម្បី-អនុគ្រោះដល់ប្រេតទាំងឡាយ ។*

បណ្ដាបទទាំងនោះ បទថា **ចុន្ទដ្ឋិលំ** បានដល់ ស្រុកដែល មានឈ្មោះយ៉ាងនោះ ។ បទថា **អន្តរេ វាសភគាមំ ពារាណសឹ ច សន្តិកេ** ( បិដកថា **អន្តរេ វាសភគាមំ ពារាណសិយាវ សន្តិកេ** ) បានដល់ ក្នុងចន្លោះ**វាសភគ្រាម** និង **ក្រុងពារាណសី** ។ មែនពិត បទថា **អន្តរេ វាសភគាមំ ពារាណសឹ ច សន្តិកេ** នេះ ជាទុតិយាវិភត្តិ ប្រើក្នុងអត្ថនៃឆដ្ឋីវិភត្តិ ព្រោះប្រកបដោយ **អន្តរា** សព្ទ ។ មែនពិត ស្រុកនោះនៅជិតក្រុងពារាណសី ។ ក៏ក្នុង-សេចក្ដីនោះ មានអធិប្បាយដូច្នេះថា ក្នុងចន្លោះវាសភគ្រាម និង ក្រុងពារាណសី ខ្ញុំនឹងទៅស្រុកឈ្មោះថា **ចុន្ទដ្ឋិលគ្រាម** មិនឆ្ងាយពី ក្រុងពារាណសី ។

បទថា **កោលិយោ ឥតិ វិស្សុតោ** បានដល់ មានឈ្មោះ

ប្រាកដយ៉ាងនេះថា **កោលិយ:** ។ បទថា **សត្តុំ ភត្តញ្ច** ( បិដកថា **សត្តុភត្តញ្ច** ) បានដល់ សដូវនិងភត្ត ។ បទថា **បីតកញ្ច យុគំ អទា** សេចក្ដីថា បានឱ្យសំពត់ពណ៌លឿងមួយគូ គឺពណ៌ដូចមាស ។ ប្រសិនបើគេសួរថា បានឱ្យកាលណា ? ទើបពោលតបថា បានឱ្យកាលទូកឈប់ ។ បទថា **គច្ឆតស្ស អទាបយិ** មានសេចក្ដីថា បានឈប់ទូកដែលកំពុងធ្វើដំណើរទៅ បានឱ្យដល់ឧបាសកខ្មាន់ព្រះ-កេសម្នាក់ក្នុងទីនោះ កាលកោលិយមហាមាត្យឱ្យសំពត់មួយគូនោះ ។ បទថា **ឋានេ** គឺមួយរំពេច បានដល់ក្នុងខណៈនោះឯង ។ បទថា **បេតស្ស ទិស្សថ** សេចក្ដីថា បានប្រាកដក្នុងរាងកាយរបស់ប្រេត គឺសំពត់ស្លៀកនិងសំពត់ដណ្ដប់បានសម្រេចដល់ប្រេតនោះ ។ ព្រោះហេតុនោះលោកទើបពោលថា ក្រោយមកប្រេតនោះស្លៀកដណ្ដប់ល្អហើយ ទ្រទ្រង់កម្រងផ្កា តាក់តែងរាងកាយដោយគ្រឿងអាភរណៈ អធិប្បាយថា ស្លៀកដណ្ដប់សំពត់ល្អហើយ ប្រដាប់តាក់តែងដោយអាភរណៈ គឺកម្រងផ្កា ។ បទថា **ឋានេ ឋិតស្ស បេតស្ស** ទក្ខិណា **ឧបកប្បថ** សេចក្ដីថា ក៏ព្រោះទក្ខិណាទាននោះតាំងនៅក្នុងខណៈដែលគួរដល់ព្រះទក្ខិណេយ្យបុគ្គល រមែងសម្រេច គឺ បានដល់ការប្រកបជាពិសេស ដល់ប្រេតនោះ ។ បទថា **តស្មា ទជ្ជេថ បេតានំ អនុកម្បាយ បុនប្បុនំ** សេចក្ដីថា គប្បីឱ្យទក្ខិណាទានរឿយៗ ដើម្បី-

អនុគ្រោះដល់ប្រេត គឺ ដើម្បីឧទ្ទិសដល់ប្រេត ។

លំដាប់នោះ **កោលិយមហាមាត្យ**នោះ កាលនឹងអនុគ្រោះដល់ប្រេតនោះ ទើបឱ្យសម្រេចទានវិធីមកតាមខ្សែទឹក កាលព្រះ-អាទិត្យរះឡើងក៏បានមកដល់ក្រុងពារាណសី ។ ចំណែកព្រះដ៏មាន-ព្រះភាគស្តេចមកតាមផ្លូវអាកាស ដើម្បីអនុគ្រោះដល់ប្រេតទាំងនោះ បានប្រថាប់ឈរត្រង់ច្រាំងទន្លេគង្គា រីឯកោលិយមហាមាត្យ ចុះអំពីទូកហើយ ក៏មានចិត្តត្រេកអររីករាយ ហើយបាននិមន្តព្រះដ៏មាន-ព្រះភាគថា បពិត្រព្រះដ៏មានព្រះភាគដ៏ចម្រើន សូមព្រះអង្គទ្រង់ព្រះមេត្តាទទួលនូវភត្តាហាររបស់ខ្ញុំព្រះអង្គក្នុងថ្ងៃស្អែកនេះ ដើម្បី-អនុគ្រោះដល់ខ្ញុំព្រះអង្គ ។ ព្រះសាស្តាទ្រង់ទទួលដោយតុណ្ហីភាព ។ កោលិយមហាមាត្យនោះ បានជ្រាបថា ព្រះដ៏មានព្រះភាគទ្រង់ទទួលហើយ ទើបឱ្យសាងសាខាមណ្ឌបធំក្នុងភូមិភាគដ៏ជាទីមនោរម្យក្នុងខណៈនោះឯង ឱ្យប្រដាប់ដោយសំពត់ដ៏វិចិត្រដោយពណ៌ផ្សេង ៗ ទាំងខាងលើ និងផ្នែកខាង ៗ ទាំង ៤ ទិស បានឱ្យក្រាលអាសនៈថ្វាយចំពោះព្រះដ៏មានព្រះភាគក្នុងទីនោះ ។ ព្រះដ៏មានព្រះភាគទ្រង់គង់ប្រថាប់លើអាសនៈដែលគេតាក់តែងទុក ។

លំដាប់នោះ មហាមាត្យនោះ ទើបចូលទៅគាល់ព្រះដ៏មាន-ព្រះភាគ រួចហើយបូជាដោយសក្ការៈមានគ្រឿងក្រអូប និងផ្កាកម្រង

ជាដើម ថ្វាយបង្គំហើយក៏បានអង្គុយនៅក្នុងទីដ៏សមគួរ បន្ទាប់-
មកក៏បានក្រាបទូលពាក្យដែលខ្លួនពោលនិងពាក្យឆ្លើយឆ្លងរបស់ប្រេត
ក្នុងគ្រាមុន ចំពោះព្រះដ៏មានព្រះភាគ ។ ព្រះដ៏មានព្រះភាគ ទ្រង់
ព្រះតម្រិះថា សូមសង្ឃចូរមក ។ ព្រមគ្នាជាមួយនឹងព្រះអង្គទ្រង់ព្រះ-
តម្រិះនោះឯង ភិក្ខុសង្ឃដែលពុទ្ធានុភាពដាស់តឿនហើយ ទើបនាំគ្នា
មកចោមរោមព្រះធម្មរាជា ដូចហ្វូងហង្សមាសនាំគ្នាចោមរោម
ស្តេចហង្សធតរដ្ឋ ។ ក្នុងខណៈនោះឯង មហាជននាំគ្នាប្រជុំដោយ
ពោលពាក្យថា នឹងមានព្រះធម្មទេសនាដ៏ប្រសើរក្រៃលែង ។ មហា-
មាត្យឃើញដូច្នោះក៏មានចិត្តរីករាយជ្រះថ្លា ទើបអង្គាសភិក្ខុសង្ឃ
មានព្រះពុទ្ធជាម្ចាស់ជាប្រធាន ឱ្យឆ្អែតស្កប់ស្កល់ដោយខាទនីយៈនិង
ភោជនីយៈដ៏ប្រណីត ។ ព្រះដ៏មានព្រះភាគទ្រង់សោយស្រេចហើយ
ដើម្បីអនុគ្រោះដល់មហាជនទើបទ្រង់អធិដ្ឋានថា សូមអ្នកស្រុកជិត
ក្រុងពារាណសីចូរប្រជុំគ្នាចុះ ។ ក៏មហាជនទាំងអស់នោះបានប្រជុំគ្នា
ដោយកម្លាំងព្រះឫទ្ធិ ។ ហើយព្រះអង្គទ្រង់បានញុំាងប្រេតជាច្រើនឱ្យ
ប្រាកដដល់មហាមាត្យ ។ បណ្តាប្រេតទាំងនោះ ពួកខ្លះស្លៀកកំណាត់
សំពត់ចាស់ដាច់រយីរយ៉ៃ ពួកខ្លះយកសក់របស់ខ្លួនឯងបិទបាំងកេរ្តិ៍-
ខ្មាស ពួកខ្លះអាក្រាតកាយមានរូបដូចពេលកើត ត្រូវសេចក្តីស្រេក
ឃ្លានបៀតបៀន មានរាងកាយត្រឹមតែស្បែកដណ្តប់ឆ្អឹង ត្រេចទៅ

វិលវល់ឆ្វេឆ្វាគ្រប់ច្រកល្ហក ប្រាកដដល់មហាជនដោយប្រចក្ស ។

លំដាប់នោះ ព្រះដ៏មានព្រះភាគទ្រង់តាក់តែងនូវឥទ្ធាភិសង្ខារ គឺបណ្តាលដោយព្រះឫទ្ធិ ដោយប្រការដែលប្រេតទាំងនោះប្រជុំព្រម គ្នាប្រកាសអំពើអាក្រក់ដែលខ្លួនបានធ្វើដល់មហាជន ។ ព្រះសង្គីតិ-កាចារ្យកាលនឹងសម្តែងនូវសេចក្តីនោះ ទើបបានពោលគាថាទាំង-ឡាយថា :

*ពួកប្រេតខ្លះស្លៀកពាក់កំណាត់សំពត់ចាស់ ដាច់ដាចផ្ទុះធ្លាយ ពួកប្រេតដទៃបិទបាំង ( កេរ្តិ៍ខ្មាស ) ដោយសក់ ពួកប្រេតរមែងទៅដើម្បីបាយ ចៀសចេញទៅអំពីទិសទៅកាន់ទិស ។ ពួកប្រេតខ្លះក៏ទៅក្នុងទីឆ្ងាយ ( ដើម្បីនឹងស៊ី ) លុះមិនបាន ក៏ត្រឡប់មកវិញស្រេកឃ្លាន ដើរទៅជ្រុលជ្រក ដួលស្រូសលើផែនដី ពួកសត្វមិនបានធ្វើអំពើល្អ ក្នុងភពមុន ( រមែងក្តៅក្រហាយ ) ដូចត្រូវភ្លើងឆេះ ក្នុងទីដ៏ក្តៅថា ក្នុងកាលពីដើម ពួកយើងមានធម៌ដ៏លាមកជាម្ចាស់ផ្ទះ ជាមាតានៃទារកក្នុងត្រកូល ទេយ្យធម៌ទាំងឡាយមានគ្រប់គ្រាន់ តែពួកយើងមិនបានធ្វើទីពឹងដល់ខ្លួន ។ ព្រោះថា ពួកយើងចាក់ចោលគ្រឿងស៊ីនិងគ្រឿងផឹកដ៏ច្រើន កាលដែលមានបព្វជិតប្រតិបត្តិត្រឹមត្រូវ ពួកយើងមិនបានប្រគេនវត្ថុបន្តិចបន្តួចសោះ-ឡើយ ។ ពួកយើងស្រឡាញ់តែអកុសលកម្ម ជាអ្នកខ្ជិលច្រអូស*

ចំណូលតែវត្ថុឆ្ងាញ់ ជាអ្នកស៊ីច្រើន ឱ្យដុំភោជនត្រឹមតែមួយពំនូត តែងតិះដៀលចំពោះពួកជនអ្នកទទួល ។ ផ្ទះទាំងនោះ ទាសីទាំងនោះ គ្រឿងអាភរណៈទាំងនោះ ជារបស់យើង ( ឥឡូវនេះ ) បានទៅពួកអ្នកដទៃប្រើប្រាស់របស់នោះ ឯពួកយើងបានតែចំណែកនៃសេចក្ដី-ទុក្ខម្យ៉ាង ពួកជនដែលត្រូវគេមើលងាយរឿយ ៗ គឺជាងផែង ១ ជាងរថ១ អ្នកទ្រុស្ដមិត្រ១ ចណ្ឌាល១ ជនកំព្រា១ អ្នកកាត់កោរ១ ។ ត្រកូលទាំងឡាយណាៗ ថោកទាបផង កំព្រាផង ( ពួកសត្វមិនបាន-ធ្វើបុណ្យ )តែងទៅកើតក្នុងត្រកូលទាំងឡាយនោះៗ នេះជាគតិនៃ-ជនអ្នកកំណាញ់ ។ ពួកជន បានធ្វើអំពើល្អក្នុងកាលមុន ជាទាយកអ្នកប្រាសចាកសេចក្ដីកំណាញ់ ពួកជននោះ ឈ្មោះថា ញ៉ាំងឋានសួគ៌ឱ្យពេញលេញផង ឈ្មោះថា ញ៉ាំងព្រៃនន្ទនៈឱ្យរុងរឿងផង ។ ពួកជនទាំងនោះ ជាអ្នកបរិភោគកាមតាមប្រាថ្នា ត្រេកអរក្នុងប្រាសាទឈ្មោះវេជយន្ត លុះច្យុតចាកទេវលោកនោះហើយ ក៏បានមកកើតក្នុងត្រកូលខ្ពង់ខ្ពស់ទាំងឡាយដែលមានភោគៈ ។ ពួកជនទាំងនោះបានកើតក្នុងត្រកូលមានយស មានខ្លួនគេបក់ដោយផ្លិតស្លាបក្ងោកទាំង-ឡាយ លើបល្ល័ង្កដែលគេក្រាលដោយសំពត់គោណកៈ ក្នុងផ្ទះមានកំពូលនិងប្រាសាទ ។ ជាអ្នកទ្រទ្រង់នូវកម្រងផ្កា មានខ្លួនប្រដាប់-ហើយ ទៅអំពីខ្លួនមួយទៅកាន់ខ្លួនមួយ ( នៃញាតិនិងភីលៀង-

*ទាំងឡាយ ) ភីលៀងទាំងឡាយ ជាអ្នកស្វែងរកសេចក្តីសុខឱ្យ តែង បម្រើទាំងល្ងាចទាំងព្រឹក ។ នន្ទនមហាវ័នរបស់ពួកទេវតានៅក្នុង-ឋានត្រៃត្រិង្ស មិនមានសោក ជាទីត្រេកអរ នេះមិនមែនរបស់ពួកជន មិនបានធ្វើបុណ្យឡើយ នេះជារបស់ពួកជនដែលបានធ្វើបុណ្យ ពួកជនដែលមិនបានធ្វើបុណ្យ មិនមានសេចក្តីសុខក្នុងលោកនេះ និង លោកខាងមុខឡើយ ឯពួកជនដែលបានធ្វើបុណ្យ រមែងមានសេចក្តី សុខក្នុងលោកនេះ និងលោកខាងមុខពិតប្រាកដ ។ ពួកជនដែលចង់ កើតជាមួយនឹងពួកទេវតានោះ ត្រូវធ្វើបុណ្យឱ្យច្រើន ព្រោះពួកជន ដែលបានធ្វើបុណ្យហើយ តែងបរិបូណ៌ដោយភោគៈ រមែងរីករាយ ក្នុងឋានសួគ៌ ។*

បណ្តាបទទាំងនោះ បទថា **សាតុន្នវសនា** ( បិដកថា **សាហុន្នវាសិនោ** ) ប្រែថា ស្លៀកសំពត់ដាច់រយីរយ៉ៃ ។ បទថា **ឯកេ** ប្រែថា ពួកខ្លះ ។ បទថា **កេសនិវាសនា** ( បិដកថា **កេសនិវាសិនោ** ) ប្រែថា យកសក់នោះឯងបិទបាំងកេរ្តិ៍ខ្មាស ។ *បទថា **គន្ត្វាយ គច្ឆន្តិ** សេចក្តីថា **ឈប់នៅចំពោះទីណា ៗ មិនបាន រមែងដើរទៅដើម្បី ត្រូវការអាហារ ដោយសង្ឃឹមក្នុងចិត្តថា ពួកយើងទៅអំពីទីនេះ ហើយនឹងគប្បីបានអ្វីមួយ ទោះជាអាហារ ដែលគេចោលក៏ដោយ កំអួតក៏ដោយ មន្ទិលគភ៌ជាដើមក៏ដោយ***

***ក្នុងទីណាមួយ***[១] ។ បទថា **បក្កមន្តិ ទិសោ ទិសំ** សេចក្តីថា ចៀសចេញអំពីទិសទៅកាន់ទិស អស់រយៈចំងាយជាច្រើនយោជន៍ ។

បទថា **ទូរេ** ប្រែថា ក្នុងទីឆ្ងាយណាស់ ។ បទថា **ឯកេ** បានដល់ ប្រេតពួកខ្លះ ។ បទថា **បធាវិត្វា** បានដល់ រត់ចូលទៅ ដើម្បីត្រូវការអាហារ ។ បទថា **អលទ្ធាវ និវត្តរេ** ( បិដកថា **អលទ្ធា ច និវត្តរេ** ) សេចក្តីថា កាលមិនបានបាយឬទឹកផឹកណាមួយ ហើយ ក៏នាំគ្នាត្រឡប់មកវិញ ។ បទថា **បមុច្ឆិតា** សេចក្តីថា សន្លប់ ព្រោះសេចក្តីទុក្ខដែលកើតអំពីសេចក្តីឃ្លាននិងសេចក្តីស្រេក។ បទថា **ភន្តា** ប្រែថា បម្រះនទៀល ។ បទថា **ភូមិយំ បដិសម្ភិតា** សេចក្តីថា កាលការសន្លប់នោះឯងកើតឡើង ក៏ស្ទេកស្ទាំងដួលចុះលើផែនដីដូច បុគ្គលឈរចោលដុំដីចុះទៅដូច្នោះ ។

បទថា **តត្ថ** គឺក្នុងទីដែលខ្លួនដើរទៅ ។ បទថា **ភូមិយំ បដិសម្ភិតា** សេចក្តីថា ដួលចុះលើផែនដី ព្រោះមិនអាចនឹងទប់ខ្លួនបាន ដោយសេចក្តីទុក្ខដែលកើតអំពីសេចក្តីឃ្លានជាដើម ដូចធ្លាក់ទៅក្នុងជ្រោះដូច្នោះ ឬក្នុងទីដែលទៅនោះ ជាអ្នកអស់សង្ឃឹមព្រោះមិនបានអាហារជាដើម ក៏ដួលចុះលើផែនដី ដូចត្រូវនរណាម្នាក់

***១- ( សូមពិចារណានៅក្នុងបទនេះ ទាក់ទងនឹងរឿងបោះបាយបិណ្ឌ តាមប្រពៃណីខ្មែរ តើមានប្រយោជន៍ ឬអត់ប្រយោជន៍ ? សូមពិចារណាឱ្យបានច្បាស់លាស់ផង ) ។***

វាយចំកណ្តាលមុខ ។ បទថា **បុព្វេ អកតកល្យាណា** ប្រែថា អ្នកមិនបានធ្វើអំពើល្អណាមួយទុកក្នុងភពមុន ។ បទថា **អគ្គិឧឡារ អាតបេ** សេចក្តីថា ត្រូវភ្លើងគឺសេចក្តីស្រេកឃ្លានដុតរោល រមែងសោយនូវសេចក្តីទុក្ខយ៉ាងខ្លាំងក្រៃលែង ដូចត្រូវភ្លើងឆេះក្នុងទីដ៏ក្តៅក្នុងរដូវប្រាំង ។

បទថា **បុព្វេ** គឺក្នុងអតីតភព ។ បទថា **បាបធម្មា** បានដល់ឈ្មោះថា អ្នកមានសភាវៈដ៏លាមក ព្រោះមានសេចក្តីប្រស្យានិងសេចក្តីកំណាញ់ជាដើម ។ បទថា **ឃរណី** បានដល់ ស្ត្រីមេផ្ទះ ។ បទថា **កុលមាតរោ** បានដល់ ស្ត្រីជាមាតានៃទារកក្នុងត្រកូល ឬជាមាតារបស់បុរសក្នុងត្រកូល ។ បទថា **ទីបំ** ប្រែថា ទីពឹង អធិប្បាយ-ថា បុណ្យ ។ មែនពិត បុណ្យនោះលោកហៅថា **បតិដ្ឋា** ព្រោះជាទីពឹងរបស់សត្វទាំងឡាយក្នុងសុគតិ ។ បទថា **នាកម្ហ** ប្រែថា មិនបានធ្វើទុក ។

បទថា **បហូតំ** ប្រែថា ច្រើន ។ បទថា **អន្នបានម្បិ** ( បិដកថា **អន្នបានំ ហិ** ) បានដល់ បាយនិងទឹក ។ សព្ទថា **សុ** ក្នុងបទថា **អបិស្សុ អវកិរីយតិ** ត្រឹមតែជានិបាត ។ ក៏បាយនិងទឹកយើងមិនបានធ្វើ គឺចាក់ចោល ។ បទថា **សម្មគ្គតេ** បានដល់ កាលយើងប្រព្រឹត្តត្រឹមត្រូវគឺបដិបត្តិត្រឹមត្រូវ ។ បទថា **បព្វជិតេ** ប្រែថា ដល់

អ្នកបួស ។ មែនពិត បទថា **បព្វជិតេ** នេះ ជាសត្តមីវិភត្តិ ប្រើក្នុងអត្ថចតុត្ថីវិភត្តិ ។ ម្យ៉ាងទៀត អធិប្បាយថា កាលបព្វជិតអ្នកប្រតិបត្តិត្រឹមត្រូវមាននៅ គឺកាលបានបព្វជិត ។ បទថា **ន ច កិញ្ចិ អទម្ហសេ** សេចក្តីថា ពួកប្រេតដែលត្រូវសេចក្តីក្តៅក្រហាយបៀតបៀន ពោល-ថា យើងមិនបានឱ្យទេយ្យធម៌ សូម្បីតែបន្តិចបន្តួច ។

បទថា **អកម្មកាមា** សេចក្តីថា ឈ្មោះថា **អកម្មកាមះ** ព្រោះប្រាថ្នាអកុសលកម្ម ដែលមនុស្សល្អទាំងឡាយមិនគប្បីធ្វើ ឬឈ្មោះថាកម្មកាមៈ ព្រោះប្រាថ្នាកុសលកម្ម ដែលមនុស្សល្អគប្បីធ្វើ ឈ្មោះថាអកម្មកាមៈ ព្រោះមិនប្រាថ្នាកុសលកម្ម អធិប្បាយថា មិនមានឆន្ទៈក្នុងកុសលកម្ម ។ បទថា **អលសា** បានដល់ ជាមនុស្សខ្ជិលច្រអូសគឺមិនមានសេចក្តីព្យាយាមក្នុងការធ្វើកុសល ។ បទថា **សាទុកាមា** បានដល់ ប្រាថ្នានូវវត្ថុដែលសុខស្រួលនិងឆ្ងាញ់ ។ បទថា **មហគ្ឃសា** ប្រែថា អ្នកស៊ីច្រើន ។ សូម្បីដោយបទទាំងពីរ លោកសម្តែងទុកថាបានភោជនដែលល្អនិងឆ្ងាញ់ហើយ មិនបានឱ្យរបស់ណាមួយដល់អ្នកត្រូវការបរិភោគខ្លួនឯងតែប៉ុណ្ណោះ ។ បទថា **អាលោបបិណ្ឌទា-តារោ** បានដល់ ឱ្យដុំបាយត្រឹមតែមួយពំនូត ។ បទថា **បដិគ្គហោ** បានដល់ អ្នកទទួលដុំបាយនោះ ។ បទថា **បរិភាសិម្ហសេ** បានដល់ពោលសង្កត់សង្កិន, អធិប្បាយថា មើលងាយនិងចំអកឡកឡឺយ ។

បទថា **តេ ឃរា** មានអធិប្បាយថា ក្នុងកាលមុន ពួកយើងបានធ្វើនូវសេចក្តីស្រឡាញ់ថា ផ្ទះរបស់យើង ផ្ទះទាំងនោះតាំងនៅដូចដើម ឥឡូវនេះ វត្ថុណាមួយក៏មិនសម្រេចដល់ពួកយើងឡើយ ។ សូម្បីក្នុងបទថា **តា ច ទាសិយោ តានេវាភរណានិ នោ** ( បិដកថា **តាច ទាសិយោ តានេវាភរណានិ នោ** ) នេះ ក៏ន័យនេះដូចគ្នា ។ បណ្តាបទទាំងនោះ បទថា **នោ** ប្រែថា ដល់ពួកយើង ។ បទថា **តេ** បានដល់ មានផ្ទះជាដើមទាំងនោះ ។ បទថា **អញ្ញេ បរិចារេន្តិ** សេចក្តីថា ធ្វើការប្រកបឱ្យពិសេសដោយការបរិភោគជាដើម ។ បទថា **មយំ ទុក្ខស្ស ភាគិនោ** សេចក្តីថា ពួកប្រេតពោលតិះដៀលខ្លួនថា ក៏កាលមុន ពួកយើងខ្វល់ខ្វាយតែការលេងតែម្យ៉ាង លះបង់សម្បត្តិមិនដឹងទីធ្វើឱ្យសម្បត្តិនោះជាប់ទៅតាមខ្លួន ប៉ុន្តែឥឡូវនេះ យើងជាអ្នកមានចំណែកនៃទុក្ខដែលកើតអំពីសេចក្តីឃ្លាន និងសេចក្តីស្រេកជាដើម ។

ឥឡូវនេះ ព្រោះហេតុដែលសត្វទាំងឡាយចុតិចាកកំណើតប្រេតហើយ សូម្បីនឹងកើតក្នុងកំណើតមនុស្ស ក៏ជាមនុស្សមានជាតិថោកទាប មានការប្រព្រឹត្តដូចមនុស្សកំព្រាតែម្តង ដោយសំណល់នៃវិបាករបស់កម្មនោះឯង ព្រោះហេតុនោះ ដើម្បីនឹងសម្តែងនូវសេចក្តីនោះ លោកទើបពោលពីរគាថា ដោយន័យមានជាដើមថា

**វេណឹ វា** ដូច្នេះ ។ បណ្ដាបទទាំងនោះ បទថា **វេណឹ វា** បានដល់ កើតក្នុងត្រកូលជាងផែង, អធិប្បាយថា ជាជាងផែងឫស្សី ជាងផែង បបុស ។ **វា** សព្ទ មានអត្ថមិនពិតប្រាកដ ។ បទថា **អវញ្ញា** ប្រែថា មើលងាយ អធិប្បាយថា មើលស្រាល ។ បាលីថា **វម្ភនា** មើលងាយ ដូច្នេះក៏មាន, អធិប្បាយថា ត្រូវអ្នកដទៃបៀតបៀន ។ បទថា **រថការី** បានដល់ ជាងរថ ។ បទថា **ទុព្ភិកា** អ្នកប្រទូសរ៉ាយមិត្ត គឺអ្នកបៀតបៀនមិត្ត ។ បទថា **ចណ្ឌាលី** ប្រែថា ជាមនុស្សជាតិ ចណ្ឌាល ។ បទថា **កបណា** បានដល់ វណិព្វកៈ គឺអ្នកបានទទួល នូវសេចក្ដីអាណិតអាសូរយ៉ាងក្រៃលែង ។ បទថា **កប្បកា** បានដល់ កើតក្នុងត្រកូលជាងកាត់កោរ ។ ក្នុងបទទាំងពួង មានសេចក្ដីថា មានរឿយ ៗ, អធិប្បាយថា រមែងកើតក្នុងត្រកូលថោកទាបទាំងនេះ ម្ដងហើយម្ដងទៀត ។

បទថា **តេសុ តេស្វេវ ជាយន្តិ** សេចក្ដីថា កើតក្នុងកំណើត ប្រេតទាំងឡាយ ព្រោះមន្ទិល គឺសេចក្ដីកំណាញ់ ចុតិចាកកំណើត ប្រេតហើយកើតក្នុងត្រកូលជនកំព្រាស្ទូម្បីពួកដទៃ មានត្រកូលនាយ-ព្រាននិងត្រកូលអ្នកចោលសំរាម ដែលត្រូវគេមើលងាយយ៉ាងខ្លាំង និងកំសត់យ៉ាងក្រៃលែងដែលជាត្រកូលថោកទាប ។ ព្រោះហេតុ នោះលោកទើបពោលថា នេះជាគតិរបស់មនុស្សកំណាញ់ ដូច្នេះ ។

ព្រះសង្គីតិការចារ្យ លុះសម្ដែងគតិរបស់សត្វអ្នកមិនបានធ្វើបុណ្យទុកយ៉ាងនេះហើយ ឥឡូវនេះដើម្បីនឹងសម្ដែងនូវគតិរបស់ជនអ្នកធ្វើបុណ្យទុក ទើបពោលគាថា ៧ គាថាថា ក៏បុគ្គលអ្នកបានធ្វើអំពើល្អទុកក្នុងកាលមុន ដូច្នេះជាដើម ។ បណ្ដាបទទាំងនោះ បទថា **សគ្គន្តេ បរិបូរេន្តិ** សេចក្ដីថា ទាយកទាំងឡាយ បានធ្វើអំពើល្អទុកក្នុងជាតិមុន ត្រេកអរក្រៃលែងក្នុងបុណ្យដែលពោលអំពីការឱ្យទានប្រាសចាកសេចក្ដីកំណាញ់ដែលជាមន្ទិល រមែងញ៉ាំងឋានសួគ៌ គឺទេវលោក ឱ្យពេញលេញផង ដោយរូបសម្បត្តិរបស់ខ្លួននិងដោយបរិវារសម្បត្តិ ។ បទថា **ឱភាសេន្តិ ច នន្ទនំ** សេចក្ដីថា មិនមែនញ៉ាំងនន្ទនវ័នឱ្យរុងរឿងតែម្យ៉ាងប៉ុណ្ណោះទេ តាមពិត មែងគ្របសង្កត់នន្ទនវ័នសូម្បីមានពន្លឺភ្លឺស្វាងស្វៃ នៅតាមសភាវៈដោយរស្មីនៃដើម-កប្បព្រឹក្សជាដើម និងឱ្យភ្លឺស្វាងស្វៃរុងរឿង ដោយរស្មីនៃសំពត់និងអាភរណៈ និង ដោយរស្មីនៃរាងកាយរបស់ខ្លួន ។

បទថា **កាមកាមិនោ** សេចក្ដីថា មានគ្រឿងប្រើប្រាស់តាមប្រាថ្នាក្នុងកាមគុណតាមដែលត្រូវការ ។ បទថា **ឧច្ចាកុលេសុ** បានដល់ ត្រកូលខ្ពង់ខ្ពស់ មានត្រកូលក្សត្រជាដើម ។ បទថា **សភោគេសុ** បានដល់ មានសម្បត្តិច្រើន ។ បទថា **តតោ ចុតា** សេចក្ដីថា លុះចុតិចាកទេវលោកនោះហើយ ។

បទថា **កូដាគារេ ច បាសាទេ** បានដល់ ក្នុងគោដាគារនិងប្រាសាទ ។ បទថា **ទិជិតង្គា** បានដល់ មានរាងកាយដែលត្រូវគេបក់ដោយផ្លិត ។ បទថា **មោរហត្ថេហិ** បានដល់ កាន់ផ្លិតវីជនីប្រដាប់ដោយស្លាបក្ងោក ។ បទថា **យសស្សិនោ** អធិប្បាយថា មានបរិវារជាទីរីករាយ ។

បទថា **អង្កតោ អង្កំ គច្ឆន្តិ** សេចក្តីថា សូម្បីក្នុងវេលាជាទារក ពួកញាតិនិងមេនំនាំគ្នាបីពទៅ អធិប្បាយថា មិនដែលដើរផ្ទាល់លើផែនដីទេ ។ បទថា **ឧបតិដ្ឋន្តិ** ប្រែថា ចាំបម្រើ ។ បទថា **សុខេសិនោ** បានដល់ អ្នកប្រាថ្នាសេចក្តីសុខ, អធិប្បាយថា ចាំបំបាត់ទុក្ខ សូម្បីមានប្រមាណតិចថា ភាពត្រជាក់ឬភាពក្តៅកុំគប្បីមានឡើយ ។

បទថា **នយិទំ អកតបុញ្ញានំ** សេចក្តីថា ឧទ្យានធំរបស់ពួកទេវតាថានត្រៃត្រិង្ស ឈ្មោះថា នន្ទនវ័ន ជិតព្រៃធំនេះមិនមានសេចក្តីសោក គួរជាទីរីករាយចិត្ត មិនមានដល់អ្នកមិនបានធ្វើបុណ្យទុក, អធិប្បាយថា អ្នកដែលមិនបានធ្វើបុណ្យទុកមិនអាចបានឡើយ ។

ដោយបទថា **ឥធ** នេះ លោកពោលសំដៅយកអ្នកដែលបានធ្វើបុណ្យទុក ជាពិសេសក្នុងមនុស្សលោកនេះ ។ ម្យ៉ាងទៀត បទថា **ឥធ** គឺ ក្នុងបច្ចុប្បន្ន ។ បទថា **បរត្ថ** គឺ ក្នុងសម្បរាយភព ។

បទថា **សេតំ** បានដល់ ទេវតាទាំងឡាយតាមដែលពោលហើយនោះ ។ បទថា **សហព្យតាមានំ** បានដល់ ប្រាថ្នានូវភាពជាសម្លាញ់ ។ បទថា **ភោគសង្គិនោ** បានដល់ អ្នកប្រកបដោយភោគៈទាំងឡាយ, អធិប្បាយថា អ្នកបរិបូណ៌ដោយកាមគុណ ៥ ដ៏ជាទិព្វជាទីរីករាយចិត្ត ។ ពាក្យដ៏សេសមានសេចក្តីងាយយល់ទាំងអស់ ។

ព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់សម្តែងនូវធម៌ដោយពិស្តារតាមសមគួរដល់អធ្យាស្រ័យរបស់មហាជន ដែលប្រជុំគ្នាក្នុងទីនោះមានកោលិយមហាមាត្យជាប្រធាន ដែលមានចិត្តតក់ស្លុត ក្នុងកាលដែលប្រេតទាំងនោះប្រកាសអំពីគតិរបស់កម្ម ដែលខ្លួនបានធ្វើទុកដោយទូទៅ និង គតិរបស់បុញ្ញកម្មដោយប្រការយ៉ាងនេះ ។ ក្នុង-វេលាចប់ព្រះធម៌ទេសនា សត្វប្រមាណ **៨៤,000** បានត្រាស់ដឹងធម៌ដោយប្រការដូច្នេះ ។

## ( ចប់រឿងអភិជ្ជមានប្រេតទី ១ )

# ២-រឿងសានុវាសិប្រេត

" ព្រះថេរៈធ្វើទានឧទ្ទិសដល់ប្រេត "

( បិដកលេខ ៥៦, ទំព័រ ៦៩ និងអដ្ឋកថា )

កាលព្រះសាស្ដាគង់ប្រថាប់នៅក្នុងវត្តវេឡុវ័នមហាវិហារ ទ្រង់ប្រារព្ធប្រេតដែលជាញាតិរបស់ព្រះសានុវាសិត្ថេរ ទើបត្រាស់នូវព្រះ-ធម៌ទេសនានេះ មានពាក្យផ្ដើមថា **កុណ្ឌិនគរិយោ ថេរោ** ដូច្នេះ ។

បានឮថា ក្នុងអតីតកាល ក្នុងក្រុងពារាណសី ព្រះរាជឱរសរបស់ព្រះរាជាទ្រង់ព្រះនាម **កិតវៈ** ទ្រង់ក្រសាលក្នុងព្រះរាជឧទ្យាន កាលស្ដេចត្រឡប់មកវិញទ្រង់ទតឃើញព្រះបច្ចេកពុទ្ធមួយព្រះអង្គនាមថា **សុនេត្តៈ** កំពុងត្រេចបិណ្ឌបាត ចេញអំពីព្រះនគរជាអ្នកស្រវឹងដោយសេចក្ដីស្រវឹង ព្រោះភាពជាធំ មានចិត្តគិតប្រទូសរ៉ាយថា សមណៈត្រងោលនេះ មិនធ្វើអញ្ជលីយ៉ាងណាមួយដល់យើងដើរទៅ ( ធ្វើព្រងើយ ) ស្ដេចចុះអំពីក-ដំរីហើយសួរថា តើលោកបានបិណ្ឌបាតខ្លះដែរឬទេ ? ទើបទទួលបាត្រអំពីដៃហើយ ក៏បោកចោលលើផែនដី ។ លំដាប់នោះ ព្រះរាជឱរសនោះ មានសេចក្ដីអាឃាតក្នុងឋានៈដែលមិនសមគួរ មានចិត្តគិតប្រទូសរ៉ាយចំពោះព្រះបច្ចេក-

ពុទ្ធនោះ ដែលជាអ្នកមិនសម្តែងនូវវិការៈ ព្រោះលោកជាតាទិបុគ្គល ជាអ្នកមានចិត្តផូរផង់ ដែលតាក់តែង ( ប្រកប ) ដោយសោមនស្ស-វេទនា ផ្សាយទៅដោយអំណាចនៃសេចក្តីករុណា ព្រះរាជឱរសនោះ ពិនិត្យមើលនៅក្នុងទីគ្រប់ស្ថាន ទើបត្រាស់ថា លោកមិនស្គាល់យើង ដែលជាព្រះរាជឱរសរបស់ព្រះបាទកិតវៈទេឬ ? លោកសម្លឹងមើល យើង តើនឹងធ្វើអ្វីយើងកើត ? កាលមិនអាចទើបចៀសចេញទៅ ។ កាលដែលព្រះរាជឱរសចៀសចេញទៅប៉ុណ្ណោះ ក៏កើតនូវសេចក្តីក្តៅ អន្ទះអន្ទែងក្នុងរាងកាយយ៉ាងខ្លាំង ប្រៀបដូចជាកំដៅនៃភ្លើងក្នុង នរក ។ ព្រោះវិបាកនៃកម្មនោះ ព្រះរាជឱរសនោះ ទើបមានកាយ ត្រូវសេចក្តីក្តៅអន្ទះអន្ទែងយ៉ាងខ្លាំងគ្របសង្កត់ ត្រូវទុក្ខវេទនាយ៉ាង ខ្លាំងក្លាចាក់ដោត ធ្វើកាលកិរិយាហើយ ក៏បានទៅកើតក្នុងអវីចិ-មហានរក ។

ព្រះរាជឱរសនោះ ដេកម្តងផ្ងារម្តងផ្កាប់ បម្រះនទៀល ម្តងប្រែទៅឆ្វេង ម្តងប្រែទៅស្តាំ ដោយអាការៈមានសភាពយ៉ាងនេះ ជារឿយ ៗ ក្នុងទីនោះ ឆេះក្នុងមហានរកនោះអស់កាល **៨៤,០០០ ឆ្នាំ** ចុតិចាកអត្តភាពនោះហើយ ក៏បានសោយនូវសេចក្តីទុក្ខដែល កើតអំពីសេចក្តីស្រេកឃ្លាន ក្នុងកំណើតប្រេតអស់កាលរាប់ប្រមាណ មិនបាន ចុតិចាកអត្តភាពនោះហើយ ក្នុងពុទ្ធុប្បាទនេះ ក៏បានមក-

កើតក្នុង**កេវដ្តគ្រាម ជិតកុណ្ឌិនគរ** ។ គេមានញាណអាចរលឹកជាតិបាន ។ ព្រោះហេតុនោះ ពេលដែលគេនឹករលឹកដល់នូវសេចក្ដីទុក្ខដែលខ្លួនធ្លាប់សោយក្នុងកាលមុន សូម្បីចម្រើនវ័យហើយ ក៏មិនព្រមទៅចាប់**ត្រី**ជាមួយនឹងពួកញាតិឡើយ ព្រោះខ្លាចបាប ។ កាលពួកញាតិទាំងនោះនាំគ្នាទៅ គេក៏គេចខ្លួនពួនសម្ងំ មិនមានបំណងប្រាថ្នានឹងសម្លាប់ត្រី ហើយគេទៅបំផ្លាញគ្រឿងឧបករណ៍សម្រាប់ចាប់ត្រី ឬចាប់ត្រីដែលនៅរស់យកមកប្រលែងក្នុងទឹក ពួកញាតិកាលមិនពេញចិត្តនូវទង្វើបែបនោះរបស់គេ ទើបបណ្ដេញគេចេញពីផ្ទះ ។ ប៉ុន្តែ គេមានបងប្រុសម្នាក់ ដែលមានសេចក្ដីស្រឡាញ់គេខ្លាំង ។

សម័យនោះ **ព្រះអានន្ទ** អាស្រ័យ**កុណ្ឌិនគរ** នៅក្នុង**សានុបពិត** ។ លំដាប់នោះ បុត្រអ្នកនេសាទនោះ ត្រូវពួកញាតិបោះបង់ចោល ដើរត្រាច់រង្គាត់ទៅគ្រប់ទីកន្លែង ក៏បានទៅដល់ទីកន្លែងនោះហើយ ក៏បានចូលទៅរកព្រះថេរៈក្នុងវេលាធ្វើភត្តកិច្ច ព្រះថេរៈសួរគេហើយ ដឹងថាគេត្រូវការអាហារ ទើបឱ្យភត្តាហារដល់គេ គេបរិភោគភត្តាហាររួចហើយ ដឹងរឿងនោះហើយ ដឹងដល់សេចក្ដីជ្រះថ្លាក្នុងធម្មកថា ទើបពោលថា អ្នកចង់បួសទេ ? គេពិតថាចង់បួសលោកម្ចាស់ ។ ព្រះថេរៈលុះឱ្យគេបព្វជ្ជារួចហើយ ក៏បាននាំ

គេទៅគាល់ព្រះដ៏មានព្រះភាគជាម្ចាស់ ។ លំដាប់នោះ ព្រះសាស្ដា ទ្រង់បានត្រាស់ជាមួយនឹងព្រះថេរៈថា អានន្ទ អ្នកគប្បីជួយអនុគ្រោះដល់សាមណេរនេះចុះ ។ ប៉ុន្តែ ព្រោះសាមណេរធ្វើកុសលទុក លោកទើបមានលាភតិច ។ លំដាប់នោះ ព្រះសាស្ដា កាលទ្រង់នឹងអនុគ្រោះដល់លោក ទើបណែនាំឱ្យលោកដងទឹក សម្រាប់ឆាន់ដាក់ឱ្យពេញឆ្នាំង ដើម្បីឱ្យភិក្ខុបរិភោគប្រើប្រាស់ ឧបាសក និងឧបាសិកាទាំងឡាយ ឃើញដូច្នោះ ទើបចាប់ផ្ដើមតាំងនិច្ចភត្តយ៉ាង-ច្រើនដល់លោក ។

សម័យក្រោយមក លោកបានឧបសម្បទាហើយ ក៏បានសម្រេចព្រះអរហត្ត ជាព្រះថេរៈមួយអន្លើដោយភិក្ខុ ១២ រូប បានគង់អាស្រ័យនៅឯសានុបពឹត ។ ចំណែកឯពួកញាតិរបស់លោក ប្រមាណជា ៥០០ នាក់ មិនបានកសាងកុសលកម្មទុក សាងតែបាបធម៌មានមច្ឆរិយៈជាដើម ធ្វើកាលកិរិយាហើយ ក៏បានទៅកើតក្នុងកំណើតប្រេត ។ រីឯមាតាបិតារបស់លោក ក៏បាននឹករលឹកថា ក្នុងកាលមុន អ្នកនេះត្រូវពួកយើងបណ្ដេញចេញពីផ្ទះ ទើបមិនហ៊ានចូលទៅរកលោក បានបញ្ជូនបងប្រុសជាទីស្រឡាញ់ពេញចិត្តចំពោះលោកទៅ ។ ក្នុងវេលាដែលព្រះថេរៈចូលទៅបិណ្ឌបាតក្នុងស្រុក គេក៏បានលុតជង្គង់ខាងស្ដាំលើផែនដី ធ្វើអញ្ជលី បង្ហាញខ្លួន បានពោល

គាថាជាដើមថា **មាតា បិតា ច តេ ភន្តេ** បពិត្រលោកដ៏ចម្រើន មាតានិងបិតារបស់លោក ។ ដើម្បីនឹងសម្តែងនូវសេចក្តីជាប់ទាក់ទង-គ្នានៃគាថា ៥ ខាងដើម មានជាដើមថា **កុណ្ឌិនគរិយោ ថេរោ** ដូច្នេះ ព្រះធម្មសង្គាហកាចារ្យទើបលើកឡើងតាំងទុកថា :

*ព្រះថេរៈឈ្មោះបោដ្ឋបាទៈ អ្នកកើតក្នុងក្រុងកុណ្ឌី បានទៅអាស្រ័យលើភ្នំឈ្មោះសានុវាសី ជាអ្នករម្ងាប់បាប មានឥន្ទ្រិយចម្រើនហើយ ( ដោយអរិយមគ្គភាវនា ) ។ មាតា បិតា និងបងប្រុសរបស់ព្រះថេរៈនោះ ជាអ្នកដល់នូវសេចក្តីលំបាក បានកើតក្នុងយមលោក ( នរក ) លុះច្យុត អំពីមនុស្សលោកនេះហើយ ក៏ទៅកាន់បេតលោក ព្រោះប្រេតទាំងនេះ ជាអ្នកដល់នូវសេចក្តីលំបាក មានទ្វារមាត់ប៉ុនរន្ធម្ជុល ត្រដាបត្រដូស មានកាយអាក្រាត ស្គមកំព្រឹង ស្លុតរន្ធត់ភ័យឡឺនឡង់ ជាអ្នកមានផលកម្មអាក្រក់ មិនហ៊ានបង្ហាញខ្លួនឱ្យគេឃើញឡើយ ។ បងប្រុសរបស់ព្រះថេរៈនោះ ជាអ្នកអាក្រាត តែម្នាក់ឯងក្នុងផ្លូវចុះតែជើងមួយ ញុំាងអត្តភាពឱ្យប្រព្រឹត្តទៅ ដោយអវយវៈ៤ គឺវារប្រញាប់ប្រញាល់ទៅបង្ហាញខ្លួនដល់ព្រះថេរៈ ។ ព្រះ-ថេរៈមិនបានធ្វើទុកក្នុងចិត្តថា អ្នកនោះឈ្មោះនេះ ហើយក៏នៅស្ងៀមដើរហួសទៅ ឯប្រេតនោះទូលព្រះថេរៈឱ្យដឹងច្បាស់ថា បពិត្រព្រះថេរៈ ខ្ញុំព្រះករុណាត្រូវជាបង បានទៅកាន់បេតលោកហើយ ។*

*បពិត្រលោកដ៏ចម្រើន មាតានិងបិតារបស់លោក ដល់នូវសេចក្តីលំបាក កើតក្នុងយមលោក លុះច្យុតអំពីមនុស្សលោកនេះហើយ ក៏ទៅកាន់-បេតលោក ព្រោះធ្វើកម្មដ៏អាក្រក់ មាតានិងបិតាទាំងនោះ ជាអ្នកដល់សេចក្តីលំបាក មានទ្វារមាត់ប៉ុនរន្ធម្ជុល ត្រដាបត្រដួស មានកាយអាក្រាត ស្គមកំព្រឹង ស្គុតរន្ធត់ ភ័យឡើនឡង់ ជាអ្នកមានផលកម្មអាក្រក់ មិនហ៊ានបង្ហាញខ្លួនឱ្យគេឃើញឡើយ ។ លោកជាអ្នកមានសេចក្តីអាណិតអាសូរ សូមអនុគ្រោះឱ្យទានឧទ្ទិសទៅឱ្យយើងទាំង-ឡាយផង មាតានិងបិតាទាំងនោះ ដែលមានកម្មអាក្រក់ នឹងញុំាងអត្តភាពឱ្យប្រព្រឹត្តទៅ ដោយទានដែលលោកម្ចាស់ឱ្យហើយ ។*

បណ្តាបទទាំងនោះ បទថា **កុណ្ឌិនគរិយោ ថេរោ** បានដល់ព្រះថេរៈអ្នកកើតចម្រើនវ័យឡើងក្នុងនគរមានឈ្មោះយ៉ាងនេះ បាលីថា **កុណ្ឌិកនគរោ** ដូច្នេះក៏មាន បាលីនោះ សេចក្តីក៏យ៉ាងនេះ ។ បទថា **សានុវាសិនិវាសិកោ** បានដល់ អ្នកមានប្រក្រតីអាស្រ័យនៅឯសានុបព៌ត ។ បទថា **បោដ្ឋបាទោតិ នាមេន** បានដល់ លោកមានឈ្មោះថា បោដ្ឋបាទៈ ។ បទថា **សមណោ** ប្រែថា ជាអ្នកស្ងប់ចាកបាប ។ បទថា **ភាវិតិន្ទ្រិយោ** សេចក្តីថា អ្នកអប់រំសទ្ធិន្ទ្រិយជាដើមហើយ ដោយអរិយមគ្គភាវនា គឺជាព្រះអរហន្ត ។ បទថា **តស្ស** បានដល់ ព្រះសានុវាសិត្ថេរនោះ ។ បទថា **ទុគ្គតា** បានដល់

អ្នកទៅកាន់ទុគ្គតិ ។ បទថា **សូចិភដ្ឋា** បានដល់ អ្នកមានទ្វារមាត់ប៉ុនរន្ធម្ជុល ព្រោះជាអ្នកសៅហ្មងដោយរបស់ស្អុយរលួយ គឺតានតឹងចង្អៀតចង្អល់ក្នុងចិត្ត បានដល់ ត្រូវសេចក្តីស្រេកឃ្លាន ដែលមានឈ្មោះថា **សូចិកា** បៀតបៀនហើយ អាចារ្យពួកខ្លះពោលថា **សូចិភណ្ឌា** ដូច្នេះក៏មាន អធិប្បាយថា អ្នកមានទ្វារមាត់ ដូចជារន្ធ-ម្ជុល ។ បទថា **កិលន្តា** បានដល់ អ្នកមានកាយនិងចិត្តលំបាក ។ បទ-ថា **នគ្គិនោ** បានដល់ ជាអ្នកមានកាយអាក្រាត គឺមិនមានសំពត់ ។ បទថា **កិសា** បានដល់ អ្នកមានរាងកាយស្គមកំព្រឹង ព្រោះមានរាងកាយនៅសល់ត្រឹមតែស្បែកដណ្តប់ឆ្អឹង ។ បទថា **ឧត្តសន្តា** បានដល់ ដល់នូវភាពស្លុតរន្ធត់ ព្រោះសេចក្តីភ័យខ្លាចថា សមណៈនេះជាបុត្ររបស់យើង ។ បទថា **មហត្តាសា** បានដល់ កើតមហា-ភ័យឡើង ព្រោះអាស្រ័យកម្មដែលខ្លួនបានធ្វើទុកក្នុងកាលមុន ។ បទថា **ន ទេសេន្តិ** សេចក្តីថា មិនបង្ហាញខ្លួន គឺមិនព្រមប្រឈមមុខដាក់គ្នា ។ បទថា **ករូរិនោ** ប្រែថា អ្នកមានការងារឃោរឃៅ ។

បទថា **តស្ស ភាតា** បានដល់ ប្រេតដែលត្រូវជាបងប្រុសរបស់សានុវាសិត្ថេរ ។ បទថា **វិតរិត្វា** បានដល់ ជាអ្នកប្រញាប់ឆ្លងទៅហើយ, អធិប្បាយថា មានភ័យកើតអំពីសេចក្តីស្លុតរន្ធត់ព្រោះភ័យខ្លាច ។ ម្យ៉ាងទៀត បាលីថា **វិតុរិត្វា** ដូច្នេះក៏មាន,

អធិប្បាយថា ជាអ្នកប្រញាប់ប្រញាល់ គឺ ប្រញាប់ទៅ ។ បទថា **ឯកបថេ** គឺ ក្នុងផ្លូវសម្រាប់ដើរបានតែម្នាក់ឯង ។ បទថា **ឯកកោ** គឺ ទៅតែម្នាក់ឯង មិនមានគ្នាទេ ។ បទថា **ចតុក្កុណ្ឌិកោ ភវិត្វាន** សេចក្តីថា ឈ្មោះថា **ចតុណ្ឌិកោ** ព្រោះសោយនូវទុក្ខវេទនា គឺ ញុំាងអត្តភាព ឱ្យប្រព្រឹត្តទៅដោយអង្គ ៤ អធិប្បាយថា ប្រើជង្គង់ទាំង ២ ដៃទាំង ២ ដើរនិងឈរ ( វារទៅ ), អធិប្បាយថា គឺ យ៉ាងនោះឯង ។ មែនពិត ប្រេតនោះ បានធ្វើយ៉ាងនោះថា ការបិទបាំងអវយវៈដែលញុំាងសេចក្តីខ្មាសឱ្យកម្រើក រមែងមានអំពីនេះ ។ បទថា **ថេរស្ស ទស្សយីតុមំ** ( បិដកថា **ថេរស្ស ទស្សយីតុម** ) សេចក្តីថា សម្តែងខ្លួន គឺបង្ហាញខ្លួនដល់ព្រះថេរៈ ។

បទថា **អមនសិកត្វា** បានដល់ មិនធ្វើទុកក្នុងចិត្ត គឺមិននឹកដល់ យ៉ាងនេះថា អ្នកនេះឈ្មោះយ៉ាងនេះ ។ បទថា **សោ ច** បានដល់ ប្រេតនោះ ។ បទថា **ភាតា បេតាគតោ អហំ** មានសេចក្តីថា ប្រេតនោះ ពោលយ៉ាងនេះថា ខ្ញុំព្រះករុណាត្រូវជាបងប្រុស ក្នុងអត្តភាពដែលជាអតីតៈ, ឥឡូវនេះ ខ្ញុំព្រះករុណាជាប្រេត មកក្នុងទីនេះ ដូច្នេះហើយទើបឱ្យព្រះថេរៈជ្រាប ។

ដើម្បីនឹងសម្តែងនូវប្រការដែលនឹងឱ្យព្រះថេរៈជ្រាបបាន ទើបបានពោលគាថា ៣ គាថា ដោយន័យមានជាដើមថា **មាតា បិតា ច**

ដូច្នេះ ។ បណ្ដាបទទាំងនោះ បទថា **មាតា បិតា ច តេ** ប្រែថា មាតា និងបិតារបស់លោក ។ បទថា **អនុកម្បស្សុ** សេចក្ដីថា សូម-អនុគ្រោះ គឺសូមធ្វើនូវសេចក្ដីអាណិតអាសូរ ។ បទថា **អន្វាធិសាហិ** ប្រែថា ចំពោះ ។ បទថា **នោ** បានដល់ពួកយើង ។ បទថា **តវ ទិន្នេន** បានដល់ ដោយទានដែលលោកឱ្យហើយ ។

ព្រះថេរៈ លុះបានស្ដាប់ដូច្នោះហើយ ដើម្បីនឹងសម្ដែងនូវ-សេចក្ដីដែលប្រេតនោះបដិបត្តិ ទើបពោលគាថាទាំងឡាយថា :

*ព្រះថេរៈផង ភិក្ខុទាំងឡាយដទៃ ១២ អង្គផង ដើរទៅ-បិណ្ឌបាត ហើយប្រជុំក្នុងទីជាមួយគ្នា ព្រោះហេតុនៃភត្តកិច្ច ។ ព្រះថេរៈ បាននិយាយនឹងពួកភិក្ខុទាំងអស់នោះថា លោកទាំងឡាយ សូមឱ្យនូវភត្ត ដែលលោកទាំងឡាយបានហើយយ៉ាងណាដល់ខ្ញុំ ខ្ញុំ-នឹងធ្វើសង្ឃភត្ត ដើម្បីអនុគ្រោះ ដល់ពួកញាតិ ។*

*ភិក្ខុទាំងនោះ បានប្រគេន ( ភត្តទាំងនោះ ) ដល់ព្រះថេរៈ ព្រះថេរៈបាននិមន្តសង្ឃ លុះព្រះថេរៈ បានឱ្យទានហើយ ក៏ឧទ្ទិស ចំពោះបិតាមាតានិងបងថា :* ***ឥទំ មេ ញាតីនំ ហោតុ សុខិតា ហោន្តុ ញាតយោ*** *សូមឱ្យទាននេះសម្រេចដល់ពួកញាតិ របស់ខ្ញុំ សូមឱ្យពួកញាតិ បានដល់នូវសេចក្ដីសុខ ។*

*ភោជនក៏សម្រេច ( ដល់ប្រេតទាំងនោះ ) ក្នុងលំដាប់ដែល-*

ឧទ្ទិស ( ភោជននោះ ) ជាភោជនដ៏ស្អាត ថ្លៃថ្លា ឆ្ងាញ់ ជាម្ហូបមាន ឱជារសច្រើន ក្នុងកាលខាងក្រោយ អំពីកាលជាទីបានទូវភោជន នោះមក ប្រេតជាបង មានសម្បុរល្អ មានកម្លាំង មានសេចក្ដីសុខ បានបង្ហាញខ្លួន ( ដល់ព្រះថេរៈហើយពោលថា ) បពិត្រលោក ដ៏ចម្រើន សូមលោករមិលមើលនូវភោជនដ៏ច្រើន ( ដែលពួកយើង-បានហើយ ដោយអានុភាពនៃទានរបស់លោក ) ប៉ុន្តែពួកយើង អាក្រាតនៅឡើយ បពិត្រលោកដ៏ចម្រើន ពួកយើងគួរបាននូវសំពត់ ដោយប្រការណា សូមលោកព្យាយាម ដោយប្រការនោះចុះ ។

ព្រះថេរៈ បានរើសកំណាត់សំពត់រេចជាយទាំងឡាយ អំពី គំនរនៃសម្រាម ហើយធ្វើកំណាត់សំពត់ឱ្យជាផ្ទាំង គឺធ្វើជាចីវរ បានប្រគេនដល់ព្រះសង្ឃ ដែលមកអំពីទិសទាំង ៤ ។ ព្រះថេរៈ បានឱ្យទានហើយឧទ្ទិសដល់បិតាមាតា និងបងថា : **ឥទំ មេ ញាតីនំ ហោតុ សុខិតា ហោន្តុ ញាតយោ** ទាននេះចូរសម្រេច ដល់ពួកញាតិរបស់ខ្ញុំ សូមពួកញាតិ បានដល់នូវសេចក្ដីសុខ ។

សំពត់ទាំងឡាយ ក៏សម្រេច ( ដល់ប្រេតទាំងនោះ ) ក្នុងលំដាប់ដែលឧទ្ទិស លំដាប់នោះ ( ប្រេតជាបង ) ក៏ស្លៀក-ដណ្ដប់សំពត់ដ៏ល្អបានបង្ហាញខ្លួនដល់ព្រះថេរៈ ។ ( ប្រេតនោះ ) មានសម្បុរល្អ មានកម្លាំងមានសេចក្ដីសុខ ( បាននិយាយថា )

បពិត្រលោកដ៏ចម្រើន សំពត់ជាគ្រឿងបិទបាំងកាយ ក្នុងដែនរបស់ព្រះបាទនន្ទៈទាំងប៉ុន្មាន ( សំពត់ជាគ្រឿងបិទបាំងរបស់ពួកយើង ) ច្រើនលើសជាងសំពត់ជាគ្រឿងបិទបាំងកាយទាំងនោះ ។

សំពត់ទាំងឡាយ ជាគ្រឿងស្លៀកពាក់របស់ពួកយើង គឺ កោសេយ្យពស្ត្រ កម្ពលីយពស្ត្រ ខោមពស្ត្រ កប្បាសិកពស្ត្រ ជាសំពត់ធំទូលាយមានថ្លៃច្រើន ឯសំពត់ទាំងនោះ ក៏សំយុងចុះ ឰដ៏អាកាស ពួកយើងនឹងស្លៀកពាក់សំពត់ទាំងនោះ តាមចិត្តស្រឡាញ់ បពិត្រលោកដ៏ចម្រើន ពួកយើងគួរបានផ្ទះដោយប្រការណា សូមលោកព្យាយាមដោយប្រការនោះចុះ ។

ព្រះថេរៈបានធ្វើកុដិប្រក់ដោយស្លឹកហើយប្រគេនដល់ព្រះសង្ឃ ដែលមកអំពីទិសទាំង ៤ លុះព្រះថេរៈ បានប្រគេនហើយឧទ្ទិសដល់បិតាមាតានិងបងថា : **ឥទំ មេ ញាតីនំ ហោតុ សុខិតា ហោន្តុ ញាតយោ** សូមទាននេះសម្រេច ដល់ពួកញាតិរបស់ខ្ញុំ សូម-ពួកញាតិ បានដល់នូវសេចក្តីសុខចុះ ។

ផ្ទះទាំងឡាយ ផ្ទះកំពូលទាំងឡាយ ជាទីនៅ ដែលញែកចែក ដែលចែកដោយប្រមាណស្មើគ្នា ក៏សម្រេច ( ដល់ពួកប្រេតទាំងនោះ ) ក្នុងលំដាប់ដែលឧទ្ទិស ។ ( ប្រេតទាំងនោះពោលថា ) ផ្ទះទាំងឡាយរបស់ពួកយើងក្នុងបេតលោកនេះ យ៉ាងណា ផ្ទះទាំងឡាយ ក្នុង-

មនុស្សលោកមិនដូច្នោះទេ តែផ្ទះទាំងឡាយ ក្នុងឋានទិព្វទាំងឡាយ យ៉ាងណា ផ្ទះទាំងឡាយ របស់ពួកយើងក្នុងបេតលោកនេះ យ៉ាង-នោះដែរ ជាផ្ទះដ៏រុងរឿង អាចញុំាងទិសទាំង ៤ ឱ្យភ្លឺជុំវិញបាន ។ បពិត្រលោកដ៏ចម្រើន ពួកយើងគួរបានទឹកផឹក ដោយប្រការណា សូមលោកព្យាយាមដោយប្រការនោះចុះ ។

ព្រះថេរៈបានចាក់ទឹកបំពេញធម្មក្រក ហើយប្រគេនដល់ព្រះ-សង្ឃ ដែលមកអំពីទិសទាំង៤ ។ លុះព្រះថេរៈបានប្រគេនហើយ ក៏-ឧទ្ទិសចំពោះ បិតាមាតានិងបងថា : **ឥទំ មេ ញាតីនំ ហោតុ សុខិតា ហោន្តុ ញាតយោ** សូមទាននេះសម្រេច ដល់ពួកញាតិរបស់ខ្ញុំ សូមពួកញាតិ បានដល់នូវសេចក្តីសុខ ។

ទឹកក៏សម្រេច ( ដល់ប្រេតទាំងនោះ ) ក្នុងលំដាប់ដែលឧទ្ទិសស្រះពោក្ខរណីទាំងឡាយ ដែលបុញ្ញកម្មនិម្មិតល្អហើយ ជ្រៅ មាន-ជ្រុង ៤ មានទឹកដ៏ត្រជាក់ មានកំពង់ល្អ ជាស្រះត្រជាក់ មានក្លិនក្រអូប ប្រៀបមិនបាន ដេរដាស ដោយផ្កាឈូកនិងផ្កាឧប្បល ពេញដោយលំអងលើទឹក ។ ប្រេតទាំងនោះងូត ផឹក ក្នុងស្រះពោក្ខរណីនោះហើយ បង្ហាញខ្លួនដល់ព្រះថេរៈថា បពិត្រលោកដ៏ចម្រើន ( ពួក-យើងបាន ) ទឹកច្រើនហើយ តែជើងទាំងឡាយរបស់ពួកយើងឈឺពុរពង ពួកយើងកាលដើរជាន់លើក្រួស-រវាន លើស្បូវភ្លាំង និងបន្លា

*រមែងខ្មើច ១ បពិត្រលោកដ៏ចម្រើន ពួកយើងគួរបាន នូវយាន ដោយប្រការណា សូមលោកខំព្យាយាមដោយប្រការនោះចុះ ។*

*ព្រះថេរៈ បានស្បែកជើងមានជាន់មួយ ហើយបានប្រគេន ដល់ព្រះសង្ឃដែលមកអំពីទិសទាំង៤ ។ លុះព្រះថេរៈបានប្រគេន ហើយក៏ឧទ្ទិស ចំពោះបិតាមាតានិងបងថា : **ឥទំ មេ ញាតីនំ ហោតុ សុខិតា ហោន្តុ ញាតយោ** សូមទាននេះសម្រេចដល់-ពួកញាតិរបស់ខ្ញុំ សូមពួកញាតិ បានដល់នូវសេចក្តីសុខ ។*

*ពួកប្រេតបានមកដោយរថ ក្នុងលំដាប់ដែលឧទ្ទិស ហើយ ( និយាយថា ) បពិត្រលោកដ៏ចម្រើន ពួកយើងលោកបានអនុគ្រោះ ហើយ ដោយបាយផង ដោយគ្រឿងបិទបាំងផង ដោយផ្ទះផង ដោយទានទាំងពីរ គឺបានីយទាននិងយានទានផង បពិត្រលោក-ដ៏ចម្រើន ពួកយើងមកដើម្បីថ្វាយបង្គំលោក ជាអ្នកប្រាជ្ញ ប្រកប ដោយសេចក្តីករុណាក្នុងលោក ។*

បណ្តាបទទាំងនោះ បទថា **ថេរោ ចរិត្វា បិណ្ឌាយ** សេចក្តីថា ព្រះថេរៈត្រាច់ទៅបិណ្ឌបាត ។ បទថា **ភិក្ខូ អញ្ញេ ច ទ្វាទស** សេចក្តីថា ភិក្ខុទាំងឡាយដទៃ ១២ អង្គទៀត ប្រជុំ-គ្នាក្នុងទីជាមួយគ្នា ។ ប្រសិនបើមានពាក្យសួរជ្រៀតចូលមកថា ព្រោះហេតុអ្វី ? តបថា ព្រោះចំណែកពិសេសនៃភត្តជាហេតុ,

អធិប្បាយថា ព្រោះភត្តកិច្ចជាហេតុ គឺ ព្រោះការឆាន់ជាហេតុ ។ បទថា **តេ** ដោយភិក្ខុទាំងនោះ ។ បទថា **យថា លទ្ធំ** ប្រែថា តាម-ដែលបាន ។ បទថា **ទេថ** ប្រែថា ចូរឱ្យ ។

បទថា **និយ្យាទយឹសុ** ប្រែថា បានឱ្យហើយ ។ បទថា **សង្ឃំ និមន្តយិ** សេចក្តីថា និមន្តភិក្ខុ ១២ អង្គនោះឯង ដើម្បីឆាន់ភត្តាហារនោះ ដោយសង្ឃុទ្ទេស ឧទ្ទិសចំពោះសង្ឃ ។ បទថា **អន្វាទិសិ** បានដល់ ឧទ្ទិសឱ្យ ។ បណ្តាញាតិទាំងនោះ ដើម្បីនឹងសម្តែងនូវ-ញាតិដែលខ្លួនឧទ្ទិសចំពោះទាំងនោះ ទើបពោលពាក្យថា សូមផលនៃទាននេះ ចូរសម្រេចដល់មាតា បិតា និងបងប្រុស សូមផលនៃ-ទាននេះ ចូរសម្រេចដល់ពួកញាតិរបស់ខ្ញុំ សូមឱ្យពួកញាតិ បានដល់នូវសេចក្តីសុខចុះ ។

បទថា **សមនន្តរានុទិដ្ឋេ** ប្រែថា ដំណាលគ្នានឹងការឧទ្ទិសនោះឯង ។ បទថា **ភោជនំ ឧបបជ្ជថ** សេចក្តីថា ភោជនរមែងកើតដល់ប្រេតទាំងនោះ ។ ដើម្បីចៀសវាងពាក្យសួរថា តើភោជនដូចម្តេច ? ទើបពោលថា ភោជនដ៏ស្អាត ។ បណ្តាបទទាំងនោះ បទថា **អនេករសព្យញ្ជនំ** បានដល់ ប្រកបដោយម្ហូបមានរសផ្សេងៗ ឬថា មានរសច្រើនយ៉ាង និងមានម្ហូបច្រើនយ៉ាង ។ បទថា **តតោ** បានដល់ ក្រោយអំពីការបានភោជន ។

បទថា **ឧទ្ទិស្សតិ ភាតា** សេចក្តីថា ប្រេតជាបងប្រុស បង្ហាញខ្លួនដល់ព្រះថេរៈ ។ បទថា **វណ្ណវា ពលវា សុខី** សេចក្តីថា ព្រោះការបានភោជននោះ ក្នុងខណៈនោះឯង ប្រេតនោះបរិបូណ៌ ដោយរូប បរិបូណ៌ដោយកម្លាំង មានសេចក្តីសុខយ៉ាងក្រៃលែង ។ បទថា **បហូតំ ភោជនំ ភន្តេ** សេចក្តីថា បពិត្រលោកដ៏ចម្រើន ភោជនច្រើនសន្ធឹកសន្ធាប់ គឺ មិនមែនតិច ដែលពួកយើងបានហើយ ព្រោះអានុភាពនៃទានរបស់លោក ។ បទថា **បស្ស នគ្គម្ហសេ** សេចក្តីថា លោកចូរមើល, ប៉ុន្តែពួកយើងជាអ្នកអាក្រាតកាយ ( នៅឡើយ ) ព្រោះដូច្នោះ សូមលោកខិតខំធ្វើនូវសេចក្តីព្យាយាម យ៉ាងនោះចុះ ។ បទថា **យថា វត្ថំ លភាម្ហសេ** សេចក្តីថា សូមលោកទាំងឡាយព្យាយាមដោយប្រការ គឺដោយសេចក្តីព្យាយាម ដែលពួកយើងទាំងអស់គ្នា គប្បីបានសំពត់ចុះ ។

បទថា **សង្ការកូដម្ហា** ( បិដកថា **សង្ការកូដតោ** ) បានដល់ អំពីគំនរសម្រាមក្នុងទីនោះ ៗ ។ បទថា **ឧច្ចិនិត្វាន** បានដល់ កាន់យកដោយការស្វែងរក ។ បទថា **នន្តកេ** បានដល់ កំណាត់-សំពត់ដែលគេចោល មានជាយរេច ។ ក៏ព្រោះសំពត់ទាំងនោះ ឈ្មោះថា ជាសំពត់ចាស់ដាច់រយីរយៃ ព្រះថេរៈយកសំពត់ទាំងនោះ ធ្វើជាចីវរថ្វាយសង្ឃ ព្រោះហេតុនោះ លោកទើបពោលថា ធ្វើសំពត់

ចាស់ឱ្យជាផ្ទាំងសំពត់ហើយឧទ្ទិសចំពោះសង្ឃ ដែលមកអំពីទិសទាំង-៤ ។ បណ្តាបទទាំងនោះ បទថា **សង្ឃេ ចាតុទ្ទិសេ អទា** សេចក្តីថា បានថ្វាយដល់សង្ឃ ដែលមកអំពីទិសទាំង ៤ ។ ក៏បទថា **សង្ឃេ ចាតុទ្ទិសេ** នេះ ជាសត្តមីវិភត្តិ ចុះក្នុងអត្ថនៃចតុត្ថីវិភត្ត ។ បទថា **សុវត្ថវសនោ** ប្រែថា ជាអ្នកស្លៀកដណ្តប់សំពត់ដ៏ល្អ ។ បទថា **ថេរស្ស ឧស្សយិត្វាមំ** សេចក្តីថា សម្តែងខ្លួន គឺបង្ហាញខ្លួន បានដល់ប្រាកដខ្លួនដល់ព្រះថេរៈ ។ សំពត់ឈ្មោះថា **បដិប្ផទា** ព្រោះជាទីបិទបាំង ។

បទថា **គោជាគារនិវេសនា** ( បិដកថា **គោជាគារា និវេ-សនា** ) បានដល់ ផ្ទះដែលជាប្រាសាទ និងទីនៅអាស្រ័យដទៃអំពីប្រាសាទនោះ ។ មែនពិត បទថា **គោជាគារនិវេសនា** នេះ លោកពោលដោយលិង្គវិបល្លាស ។ បទថា **វិភត្តា** បានដល់ ដែលគេរៀបចំបែងចែកដោយសណ្ឋាន ៤ ជ្រុងស្មើគ្នា វែងនិងមូល ។ បទថា **ភាគសោ មិតា** ប្រែថា កំណត់ជាចំណែក ។ ។ បទថា **នោ** បានដល់ យើងទាំងឡាយ ។ បទថា **ឥធ** បានដល់ បេតលោកនេះ ។ សព្ទថា **អបិ** ក្នុងបទថា **អបិ ទិព្វេសុ** នេះ ត្រឹមតែជានិបាត, អធិប្បាយថា ក្នុងទេវលោក ។

បទថា **ភរកំ** បានដល់ ធម្មក្រក ។ បទថា **បូរេត្វា** ប្រែថា

ពេញដោយទឹក ។ បទថា **ទារុកិញ្ជកូប្បរិតា** បានដល់ លើទឹកក្នុងទីនោះ ៗ ពេញដេរដាសដោយលំអងបទុម និងឧប្បលជាដើម ។ បទថា **ផលន្តិ** ប្រែថា រមែងរីក, អធិប្បាយថា បែកត្រង់កែងជើង និងកៀន ៗ នៃបាតជើងជាដើម ។

បទថា **អាហិណ្ឌមានា** បានដល់ ត្រាច់ទៅ ។ បទថា **ខញ្ជោម** ប្រែថា ខ្ញើចៗ ។ បទថា **សក្ខរេ កុសកណ្ដកេ** បានដល់ ក្នុងភូមិភាគដែលមានដុំក្រួស និងពន្លកស្បូវភ្លាំង អធិប្បាយថា ជាន់លើដុំក្រួស និងពន្លកស្បូវភ្លាំង ។ បទថា **យានំ** បានដល់ យានប្រភេទណាមួយមានរថ និងយានជំនិះជាដើម ។ បទថា **សិវាជិកំ** បានដល់ ស្បែកជើងមួយជាន់ ។

**ម** អក្សរក្នុងបទថា **រថេន មាគមុំ** នេះ ធ្វើការត_បទ គឺមកដោយរថ ។ បទថា **ឧភយំ** ប្រែថា ដោយការឱ្យទាំងពីរ គឺ ដោយការឱ្យយាន និងដោយការឱ្យបច្ច័យ ៤ មានភត្តជាដើម ។ មែនពិតក្នុងការឱ្យពីរយ៉ាងនោះ សូម្បីការឱ្យភេសជ្ជៈ លោកក៏សង្គ្រោះដោយការឱ្យទឹកផឹក ។ ពាក្យដ៏សេសងាយយល់ទាំងអស់ ព្រោះមានន័យដូចពោលហើយ ក្នុងខាងដើមនោះឯង ។

ព្រះថេរៈក្រាបទូលរឿងនោះចំពោះព្រះដ៏មានព្រះភាគជាម្ចាស់ ព្រះដ៏មានព្រះភាគជាម្ចាស់ទ្រង់ធ្វើរឿងនោះឱ្យជា**អត្ថុប្បត្តិហេតុ**-

( **ហេតុដែលកើតឡើងនៃរឿង** ) ទើបត្រាស់ថា ប្រេតទាំងនេះ រមែងសោយនូវទុក្ខយ៉ាងខ្លាំងក្លា ក្នុងកាលឥឡូវនេះ យ៉ាងណាមិញ សូម្បីអ្នកក៏ដូច្នោះដែរ ជាប្រេតក្នុងអត្តភាពដែលជាអតីតៈ អំពីអត្តភាពនេះ រមែងសោយនូវទុក្ខយ៉ាងខ្លាំងក្លា ដូច្នេះហើយ ព្រះថេរៈទូលអារាធនា ទើបទ្រង់សម្តែងនូវរឿង**សុត្តប្រេត**[១]ហើយ ទ្រង់សម្តែងធម៌ដល់បរិស័ទ ដែលមកជួបជុំគ្នាហើយក្នុងទីនោះ មហាជនបានស្តាប់រឿងនោះហើយ ក៏កើតនូវសេចក្តីតក់ស្លុត រួចហើយក៏ជាអ្នកត្រេកអររីករាយក្នុងបុញ្ញកម្ម មានទាន និងសីលជាដើម ។

## ( ចប់រឿងសានុវាសិប្រេតទី ២ )

១= មានមកហើយក្នុង **ឧព្វរីវគ្គទី ២ រឿងទី ១១** ( បិដកលេខ ៥៦, ត្រង់ទំព័រ ៥៧ ) ។

# ៣. រឿងរថការីប្រេត

" មាណពចង់នៅរួមរស់ជាមួយនឹងនាងប្រេតក្នុងសួនឧទ្យាន "

( បិដកលេខ ៥៦, ទំព័រ ៧៤ និងអដ្ឋកថា )

ព្រះសាស្តាកាលស្តេចគង់ប្រថាប់នៅនគរសាវត្ថី ទ្រង់ប្រារព្ធនាងប្រេតម្នាក់ ទើបត្រាស់នូវព្រះគាថានេះ មានពាក្យផ្តើមថា **វេឡុរិយត្ថម្ភំ រុចិរំ បភស្សរំ** ដូច្នេះ ។

បានឮថា ក្នុងអតីតកាល ក្នុងកាលនៃព្រះដ៏មានព្រះភាគទ្រង់ព្រះនាមថា **កស្សបៈ** មានស្រីម្នាក់បរិបូណ៌ដោយសីល និងអាចារៈ មានកល្យាណមិត្តជាទីពឹងពាក់ពំនាក់អាស្រ័យ ជ្រះថ្លាក្រៃ-លែងក្នុងព្រះសាសនា បានសាងអាវាសមួយកន្លែង គួររមិលមើលយ៉ាងក្រៃលែង មានជញ្ជាំង សសរ ជណ្តើរ និងផ្ទៃផែនដីដ៏វិចិត្រដែលចែកទុកដោយល្អ និមន្តភិក្ខុទាំងឡាយឱ្យគង់ក្នុងអាវាសនោះ អង្គាសដោយអាហារដ៏ប្រណីត រួចហើយក៏បានវេរប្រគេនចំពោះភិក្ខុសង្ឃ ។ ក្នុងកាលជាខាងក្រោយមក នាងធ្វើកាលកិរិយាហើយ ក៏បានទៅកើតជា**នាងវិមានប្រេត** អាស្រ័យស្រះឈ្មោះ **រថការៈ** នៅឯ**ភ្នំហេមពាន្ត** ដោយអំណាចនៃបាបកម្មឯណានីមួយ ។ ដោយអានុភាពនៃបុណ្យ

ដែលនាងថ្វាយអាវាសដល់សង្ឃ វិមានដែលសម្រេចដោយរតនៈគ្រប់យ៉ាងធំទូលាយ ដោយជុំវិញគួរឱ្យជ្រះថ្លា គួរឱ្យមនោរម្យយ៉ាងក្រៃលែង ស្រស់ស្អាតដូចនន្ទនវ័ននៅឯស្រះបោក្ខរណី រមែងកើតឡើងដល់នាង ចំណែកឯរូបនាងក៏មានពណ៌សម្បុរដូចមាស ស្រស់ស្អាតគួរឱ្យគយគន់ គួរឱ្យជ្រះថ្លា ។

នាងវៀរចាកពួកបុរស សោយទិព្វសម្បត្តិនៅក្នុងទីនោះ កាលនាងមិនមានបុរសនៅក្នុងទីនោះអស់កាលដ៏យូរ ក៏កើតនូវសេចក្តីអផ្សុកឡើង នាងក៏គិតត្រិះរិះក្នុងចិត្តថា ឧបាយនេះប្រើបាន ទើបទម្លាក់ស្វាយទុំដ៏ជាទិព្វទៅក្នុងស្ទឹង ។ ពាក្យទាំងអស់គប្បីជ្រាប ដោយន័យដូចដែលបានពោលរួចមកហើយ ក្នុងរឿងកណ្ណមុណ្ឌប្រេត[១] នោះឯង ។ ក៏ក្នុងរឿងនេះ មានមាណពម្នាក់ ជាអ្នកក្រុងពារាណសី បានឃើញផ្លែស្វាយមួយផ្លែ ក្នុងបណ្តាផ្លែស្វាយទុំទាំងនោះ ក្នុងទន្លេគង្គា ទើបទៅកាន់ទីលំនៅរបស់នាងដោយទំនងនោះ នាងបានឃើញមាណពនោះហើយ ទើបនាំគេទៅកាន់ទីលំនៅរបស់ខ្លួន ហើយក៏បានធ្វើនូវបដិសណ្ឋារកិច្ចរួចហើយក៏បានអង្គុយចុះ ។ គេបានឃើញភាពបរិបូណ៌នៃទីលំនៅរបស់នាង កាលនឹងសួរទើបពោលនូវគាថាទាំងនេះថា :

១= មានមកហើយក្នុង**ឧព្វិរិវគ្គទី ២ រឿងទី ១២** ត្រង់ទំព័រ ៥៩

បពិត្រនាងទេវី មានអានុភាពច្រើន នាងឡើងកាន់វិមាន មានសសរកែវពិទូរ្យដ៏រុងរឿងភ្លឺផ្លេក ៗ វិចិត្រដោយរតនៈច្រើនយ៉ាង ហើយនៅក្នុងវិមាននោះដូចព្រះចន្ទ្រក្នុងថ្ងៃ ១៥ កើត នៅក្នុងផ្លូវជាគន្លង ( របស់ខ្លួន ) ទាំងសម្បុររបស់នាងសោតប្រាកដស្មើដោយមាស មានសភាពខ្ពង់ខ្ពស់ គួរឱ្យរមិលមើលក្រៃពេក បពិត្រនាង មិនមានគេផ្ទឹមបាន នាងគង់លើបល្ល័ង្កដ៏ប្រសើរបំផុត នាងនៅតែម្នាក់ឯង នាងមិនមានប្ដីសោះ ។ ឯស្រះបោក្ខរណីទាំងឡាយ របស់នាងនេះ មានកម្រងផ្កាច្រើនយ៉ាង មានផ្កាឈូកសច្រើនដោយជុំវិញ រោយ-រាយជុំវិញ ដោយកំទេចនៃមាសទាំងឡាយ ភក់និងចក ក៏មិនមាន ក្នុងស្រះបោក្ខរណីទាំងនោះ ។ សូម្បីហង្សទាំងនេះ គួររមិលមើល គួររីករាយនៃចិត្ត ក៏ហែលក្រឡឹង លើទឹកសព្វៗកាល ហង្សទាំងអស់ មានសំឡេងមូល ដូចជាសំឡេងគឹកកង នៃស្គរទាំងឡាយប្រជុំគ្នា បន្លឺឡើងនូវសំឡេងដ៏ពីរោះ ។ នាងជាអ្នកមានយស រុងរឿងដោយយស ឈរផ្អែកលើទូក បពិត្រនាងមានរោមភ្នែកខ្មៅ វែង-ង នាងសើច នាងពោល នូវពាក្យជាទីស្រឡាញ់ មានលំអ-សព្វអវយវៈ រុងរឿងក្រៃពេក ។ វិមាននេះ ប្រាសចាកធូលី តាំងនៅលើផែនដីរាប ជាឧទ្យាន ញុំាងតម្រេកនិងសេចក្ដីរីករាយឱ្យចម្រើន បពិត្រនារី គួររមិលមើល មិនថោកទាប ខ្ញុំប្រាថ្នា ដើម្បីរីករាយក្នុងវិមានជាទី-

*វិករាយនេះរបស់នាង ជាមួយនឹងនាង ។*

បណ្ដាបទទាំងនោះ បទថា **តត្ថ** យោគៈថា ក្នុងវិមាននោះ ។ បទថា **អច្ឆសិ** បានដល់ អ្នកអង្គុយនៅក្នុងវេលាដែលប្រាថ្នា-ហើយ ៗ ។ មាណពហៅនាងប្រេតនោះថា **ទេវិ** ។ បទថា **មហានុភាវេ** បានដល់ អ្នកប្រកបដោយអានុភាពទិព្វដ៏ធំ ។ បទថា **បថទ្ធនិ** បានដល់ ផ្លូវឆ្ងាយដែលជាផ្លូវរបស់ខ្លួន, អធិប្បាយថា ផ្លូវអាកាស ។ បទថា **បណ្ណរសេវ ចន្ទោ** សេចក្ដីថា រុងរឿងដូចព្រះចន្ទពេញវង់ ក្នុងថ្ងៃពេញបូណ៌មី ។

បទថា **វណ្ណោ ច តេ កនកស្ស សន្និភោ** សេចក្ដីថា ក៏ពណ៌សម្បុររបស់អ្នកដូចមាសសិង្គីដ៏ឆ្អិនឆ្អៅ គួរឱ្យមនោរម្យយ៉ាងក្រៃលែង ។ ព្រោះហេតុនោះ មាណពទើបពោលថា មានសភាពខ្ពង់ខ្ពស់ គួរឱ្យរមិលមើលក្រៃពេក ។ បទថា **អតុលេ** បានដល់ ដែលមានតម្លៃច្រើន ។ម្យ៉ាងទៀតពាក្យថា **អតុលេ** ជាពាក្យហៅទេវតា, អធិប្បាយថា មានរូបមិនមាននរណាដូច ។ បទថា **នត្ថិ ច តុយ្ហ សាមិកោ** ( បិដកថា **នត្ថិ តុយ្ហំ សាមិកោ** ) សេចក្ដីថា ក៏ស្វាមីរបស់អ្នកមិនមានទេឬ ?

បទថា **បហូតមល្យា** ( បិដកថា **បហូតមាលា** ឬ **បហុត្តម-ល្យា** ) បានដល់ មានកម្រងផ្កាច្រើនប្រភេទ មានផ្កាឈូកជាដើម ។

បទថា **សោវណ្ណចុណ្ណេហិ** ប្រែថា ដោយខ្សាច់មាស ។ បទថា **សមន្តមោតតា** ប្រែថា ដេរដាសដោយជុំវិញ ។ បទថា **ឥត្ថ** បានដល់ ក្នុងស្រះបោក្ខរណីទាំងឡាយនោះ ។ បទថា **បង្កោ បណ្ណកោ ច** សេចក្តីថា មិនមានភក់ឬចកក្នុងទឹក ។

បទថា **ហំសាចិមេ ឧស្សនីយា មនោរមា** ( បិដកថា **ហំសាបិមេ ឧស្សនីយា មនោរមា** ) សេចក្តីថា ហង្សទាំងនេះគួរឱ្យរមិលមើល គួរឱ្យរីករាយនៃចិត្ត ។ បទថា **អនុបរិយន្តិ** បានដល់ ត្រាច់ទៅ ។ បទថា **សព្វទា** បានដល់ ក្នុងគ្រប់រដូវកាល ។ បទថា **សមយ្យ** ប្រែថា ប្រជុំគ្នា ។ បទថា **វគ្គូ** ប្រែថា ពីរោះ ។ បទថា **ឱបនទន្តិ** ( បិដកថា **បនទន្តិ** ) ប្រែថា យំខ្សៀវខ្សារ ។ បទថា **ពិន្ទុស្សរា** បានដល់ មានសំឡេងមិនបែក គឺ មានសំឡេងក្រអួន ។ បទថា **ទុន្ទុភីនំ វ ឃោសោ** សេចក្តីថា សំឡេងយំរបស់ពួកហង្សក្នុងស្រះបោក្ខរណីរបស់អ្នក ដូចសំឡេងស្គរ ព្រោះជាសំឡេងពីរោះនិងក្រអួន ។

បទថា **ឧទ្ទល្លមានា** បានដល់ រុងរឿងយ៉ាងក្រៃលែង ។ បទថា **យសសា** បានដល់ អ្នកមានទេវឫទ្ធិ ។ បទថា **នាវាយ** បានដល់ ក្នុងទូក ។ មែនពិត មាណពឃើញនាងប្រេតអង្គុយនៅលើបល្ល័ង្កដែលមានតម្លៃច្រើនក្នុងទូកមាស កំពុងលេងកីឡាក្នុងទឹកនៅ

ក្នុងស្រះបោក្ខរណីដែលមានគុម្ពបទុម ទើបបានពោលយ៉ាងនោះ ។ បទថា **អទលម្ព** សេចក្តីថា អង្គុយមិនផ្អែកនូវបង្អែក ។ ពាក្យថា **តិដ្ឋសិ** នេះ ជាពាក្យហាមការទៅ ព្រោះថានៈសព្ទ មានការហាមការទៅជាអត្ថ ។ បាលីថា **និសជ្ជសិ** ដូច្នេះក៏មាន, គប្បីជ្រាបសេចក្តីនៃបទថា **និសជ្ជសិ** ជា **និសីទសិ** នោះឯង ។ បទថា **អាឡារបម្ហេ** បានដល់ មានរោមភ្នែកខ្មៅ វែង-ង ។ បទថា **ហសិតេ** ប្រែថា មានមុខញញឹមញញែមរីករាយក្រៃលែង ។ បទថា **បិយំ វទេ** ប្រែថា និយាយស្តីគួរឱ្យស្រឡាញ់ ។ បទថា **សព្វង្គ-កល្យាណិ** ប្រែថា ល្អដោយអវយវៈទាំងពួង គឺ មានអវយវៈគ្រប់ផ្នែកស្រស់ស្អាត ។ បទថា **វិរោចសិ** ប្រែថា រុងរឿងក្រៃលែង ។

បទថា **វិរជំ** ប្រែថា ប្រាសចាកធូលី គឺ មិនមានទោស ។ បទថា **សមេដ្ឋិតំ** បានដល់ តាំងនៅលើផែនដីដ៏រាប ឬតាំងនៅលើផែនដីដ៏ស្មើ ព្រោះស្រស់ស្អាតទាំង ៤ ផ្នែក, អធិប្បាយថា ស្អាតដោយជុំវិញ ។ បទថា **ឧយ្យានវន្តំ** បានដល់ ប្រកបដោយសួននន្ទនវ័ន ។ បទថា **រតិនន្ទិវឌ្ឍនំ** ( បិដកថា **រតិនន្ទវឌ្ឍនំ** ) សេចក្តីថា ឈ្មោះថា **រតិនន្ទិវឌ្ឍនៈ** ព្រោះញ៉ាំងសេចក្តីត្រេកអរនិងសេចក្តីភ្លើតភ្លើនឱ្យចម្រើន, អធិប្បាយថា ញ៉ាំងសុខនិងបីតិឱ្យ-ចម្រើន ។ ពាក្យថា **នារិ** ជាពាក្យហៅនាងប្រេតនោះ ។ បទថា

**អនោមនស្សេ** បានដល់ ឃើញហើយមិនគួរតិះដៀល ព្រោះមាន-អវយវៈតូចធំបរិបូណ៌ ។ បទថា **នន្ទេ** បានដល់ អ្នកធ្វើនូវសេចក្ដីរីករាយចិត្ត ។ បទថា **ឥធ** ប្រែថា ក្នុងសួននន្ទនវ័ននេះ ឬក្នុងវិមាននេះ ។ បទថា **មោទិតុំ** មានសេចក្ដីថា ខ្ញុំប្រាថ្នាដើម្បីនឹងអភិរម្យ ។

កាលមាណពនោះពោលយ៉ាងនោះហើយ នាងវិមានប្រេតនោះ កាលនឹងឆ្លើយតបចំពោះមាណពនោះ ទើបពោលគាថាថា :

*អ្នកចូរធ្វើនូវកម្មដែលឱ្យផល ក្នុងឋានទិព្វនេះ ទាំងចិត្តរបស់អ្នកសោតក៏ចូរឱនទៅក្នុងឋានទិព្វនេះ លុះអ្នកធ្វើនូវកម្មដែលគួររីករាយក្នុងឋានទិព្វនេះហើយ ទើបអ្នកបាននូវខ្ញុំជាស្រីមានកាមតាមប្រាថ្នា ដោយប្រការយ៉ាងនេះ ។*

បណ្ដាបទទាំងនោះ បទថា **ករោហិ កម្មំ ឥធ វេទនីយំ** សេចក្ដីថា អ្នកចូរធ្វើ គឺ គប្បីបានជួបប្រសព្វនូវកុសលកម្មដែល សម្រេចផល គឺ ឱ្យផលក្នុងឋានទិព្វនេះ ។ បទថា **ឥធ និហិតំ** ( បិដកថា **ឥធ និតញ្ច** ) បានដល់ បង្អោនចិត្តចូលទៅក្នុងវិមាននេះ, បាលីថា **ឥធនិន្នំ** ដូច្នេះក៏មាន, អធិប្បាយថា ចិត្តរបស់អ្នកចូរបង្អោន ៗ ទៅក្នុងទីនេះ ។ បទថា **មមំ** ប្រែថា នូវខ្ញុំ ។ បទថា **លច្ឆសិ** ប្រែថា នឹងបាន ។

មាណពនោះ បានស្ដាប់នូវពាក្យរបស់នាងវិមានប្រេតនោះ

ហើយ ក៏បានចៀសចេញអំពីទីនោះទៅកាន់លំនៅមនុស្ស តាំងចិត្ត-នោះទុកក្នុងទីនោះ ហើយក៏បានធ្វើនូវបុញ្ញកម្មដែលកើតអំពីចិត្តនោះ មិនយូរប៉ុន្មាន ក៏បានធ្វើកាលកិរិយាទៅ ហើយក៏បានទៅកើតក្នុង វិមាននោះ គឺ បានកើតជាមួយនឹងនាងវិមានប្រេតនោះ ព្រះសង្គីតិ-កាចារ្យទាំងឡាយ ទើបពោលនូវគាថាចុងក្រោយថា :

*មាណពនោះ បានទទួលស្តាប់ពាក្យនាងវិមានប្រេតនោះ ថា អើនាង ស្រួលហើយ ហើយក៏បានធ្វើកម្មដែលឱ្យផលក្នុងឋានទិព្វ-នោះ លុះមាណពបានធ្វើកម្មដែលឱ្យផលក្នុងឋានទិព្វនោះហើយ ក៏បានទៅកើតជាមួយនឹងនាងវិមានប្រេតនោះ ។*

បណ្តាបទទាំងនោះ បទថា **សាធុ** ជានិបាត ប្រើក្នុងអត្ថសម្បដិច្ឆនត្ថៈ ។ បទថា **តស្សា** បានដល់ នាងវិមានប្រេតនោះ ។ បទថា **បដិសុណិត្វា** បានដល់ ទទួលពាក្យរបស់នាងវិមានប្រេតនោះ ។ បទថា **តហឹ វេទនីយំ** បានដល់ កុសលកម្មដែលមានផលជាសុខ ដែលនឹងគប្បីបានទទួលជាមួយនឹងនាងវិមានប្រេតនោះ ក្នុងវិមាននោះ ។ បទថា **សហព្យតំ** គឺ នូវការនៅរួមគ្នា, អធិប្បាយថា មាណពនោះបានទៅកើតជាមួយនឹងនាងវិមានប្រេតនោះ ។ ពាក្យ-ដ៏សេសងាយយល់ទាំងអស់ ។

កាលជនទាំងនោះសោយនូវទិព្វសម្បត្តិក្នុងវិមាននោះ អស់-

កាលដ៏យូរយ៉ាងនេះ ព្រោះអស់កម្ម បុរសទើបធ្វើនូវកាលកិរិយា ប៉ុន្តែស្ត្រីព្រោះបុញ្ញកម្មរបស់ខ្លួនដល់នូវដែនសម្បត្តិ ទើបឋិតនៅរហូតដល់គ្រប់អាយុក្នុងវិមាននោះ អស់មួយចន្លោះព្រះពុទ្ធ ។ កាលដែលព្រះដ៏មានព្រះភាគជាម្ចាស់នៃយើងទាំងឡាយ ស្តេចឧប្បត្តិឡើងក្នុងលោក ទ្រង់ប្រកាសនូវធម្មចក្កដ៏ប្រសើរ គង់ប្រថាប់នៅក្នុងវត្ត-ជេតពនមហាវិហារដោយលំដាប់ ថ្ងៃមួយ**ព្រះមហាមោគ្គល្លាន**ចារិក-ទៅលើភ្នំ ក៏បានឃើញវិមាននិងនាងវិមានប្រេតនោះ ទើបសួរដោយគាថាមានជាដើមថា : *វិមានមានសសរ សម្រេចហើយដោយកែវពិទូរ្យដ៏ស្រស់ស្អាតផូរផង់,* ហើយនាងវិមានប្រេតនោះ បានពោលរៀបរាប់នូវប្រវត្តិរបស់ខ្លួនទាំងអស់ដល់ព្រះមហាមោគ្គល្លាន តាំងពីដើមរហូតដល់ចប់ ។ ព្រះថេរៈបានស្តាប់ដូច្នោះហើយ ក៏បានមកកាន់ក្រុងសាវត្ថី ក្រាបទូលរឿងនោះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះដ៏-មានព្រះភាគ ទ្រង់ធ្វើនូវរឿងនោះឱ្យជាអត្ថុប្បត្តិហេតុ ទ្រង់សម្តែងធម៌ដល់បរិស័ទ ដែលមកប្រជុំគ្នាហើយក្នុងទីនោះ មហាជនបានស្តាប់ដូច្នោះហើយ ជាអ្នកត្រេកអររីករាយក្នុងបុញ្ញកម្ម មានទានជាដើមដោយប្រការដូច្នេះ ។

## ( ចប់រឿងរថការីប្រេតទី ៣ )

# ៤~រឿងភុសប្រេត

## " បុព្វកម្មរបស់ប្រេតទាំង ៤ "

( បិដកលេខ ៥៦, ទំព័រ ៧៦ និងអដ្ឋកថា )

កាលព្រះសាស្តា គង់ប្រថាប់នៅក្នុងក្រុងសាវត្ថី ទ្រង់ប្រារព្ធ-ប្រេត ៤ នាក់ ទើបត្រាស់នូវព្រះធម្មទេសនានេះ មានពាក្យផ្តើមថា **ភុសានិ ឯកោ សាលឹ បុនាបរោ** ដូច្នេះ ។

បានឮថា ក្នុងស្រុកមួយដែលស្ថិតនៅមិនឆ្ងាយពីក្រុងសាវត្ថី មានពាណិជបោកប្រាស់ម្នាក់ ចិញ្ចឹមជីវិតដោយ**អនេសនាកម្ម**មានការបោកប្រាស់ដោយការបំបាត់ភ្នែកជញ្ជីងជាដើម ។ គាត់កាន់យកអង្កាមស្រូវសាលីច្របល់ជាមួយនឹងដីក្រហម ធ្វើឱ្យធ្ងន់ជាងមុន លាយជា-មួយនឹងស្រូវសាលីក្រហមហើយលក់ ។ បុត្ររបស់គាត់ខឹងថា លោកឪពុកមិនព្រមផ្តល់កិត្តិយសលើកតម្កើងមិត្តសម្លាញ់របស់យើង ដែលមកកាន់ផ្ទះសោះឡើយ ហើយក៏បានកាន់យកខ្សែស្បែកពីរសរសៃវាយក្បាលមាតា ។ ស្ត្រីជាកូនប្រសាររបស់គាត់ លួចស៊ីសាច់ដែលរក្សាទុកសម្រាប់ជនទាំងពួងហើយ កាលត្រូវជនទាំងនោះ សួរដេញដោលទើបស្បថថា ប្រសិនបើខ្ញុំបរិភោគសាច់នោះមែន សូម-

ឱ្យខ្ញុំខ្វេះសាច់ខ្នងរបស់ខ្លួនហើយបរិភោគគ្រប់ ៧ ភពទៅចុះ ។ ចំណែកឯភរិយារបស់គាត់ កាលជនទាំងឡាយនាំគ្នាសូមគ្រឿង-ឧបករណ៍ណាមួយ ក៏តបថា មិនមានទេ កាលត្រូវជនទាំងនោះរំអុក ទើបបានស្បថ ដោយមុសាវាទថា ប្រសិនបើខ្ញុំពោលនូវវត្ថុដែលមាន ថាមិនមានសោត សូមឱ្យខ្ញុំគប្បីជាអ្នកមានលាមកជា-អាហារ ក្នុងទីដែលកើតហើយចុះ ។

លុះកាលជាខាងក្រោយមក ជនទាំង ៤ នាក់នោះ ធ្វើកាលកិរិយាហើយ ក៏បានទៅកើតជាប្រេតក្នុងព្រៃភ្លើងឆេះ ក្នុងបណ្ដា-ជនទាំង ៤ នាក់នោះ ពាណិជបោកប្រាស់ ប្រើដៃទាំងសងខាងកើបយកអង្គារមដែលកំពុងតែឆេះសន្ធោសន្ធៅដោយផលនៃកម្មហើយរោយលើក្បាលរបស់ខ្លួនឯង សោយនូវទុក្ខយ៉ាងខ្លាំងក្លា ។ បុត្ររបស់គាត់ក៏ប្រើដំបងដែកវាយសំពងក្បាលខ្លួនឯង សោយនូវទុក្ខយ៉ាងខ្លាំងក្លា ។ ស្ត្រីជាកូនប្រសាររបស់គាត់ ដោយផលនៃកម្ម ទើបប្រើក្រចកទាំងឡាយដែលធំហើយវែងនិងមុតយ៉ាងក្រៃលែង ខ្វាចសាច់ខ្នងរបស់ខ្លួនឯងស៊ី សោយនូវទុក្ខប្រមាណមិនបាន ។ ពេលដែលភរិយារបស់គាត់បង្ហោននូវស្រូវសាលីដែលមានក្លិនក្រអូបបរិសុទ្ធល្អប្រាសចាកនូវភាពសៅហ្មង ចូលទៅប៉ុណ្ណោះក៏ក្លាយជាលាមកពោរពេញ ទៅដោយពួកសត្វដង្កូវនានា មានក្លិនស្អុយ និងគួរឱ្យខ្ពើម

យ៉ាងក្រៃលែង ។ ភរិយានោះ យកដៃទាំងសងខាង កើបលាមក នោះស៊ី សោយនូវទុក្ខយ៉ាងខ្លាំងក្លា ។

កាលជនទាំង ៤ នាក់នោះ កើតក្នុងកំណើតប្រេតសោយនូវ-ទុក្ខយ៉ាងខ្លាំក្លាដោយអាការយ៉ាងនេះ **ព្រះមហាមោគ្គល្លាន** កាលចារិកទៅលើភ្នំ ថ្ងៃមួយបានទៅដល់ទីនោះ ហើយក៏បានឃើញប្រេតទាំងនោះ ទើបសួរអំពីបុព្វកម្មដែលប្រេតទាំងនោះបានធ្វើ ដោយគាថានេះថា :

*ប្រេតម្នាក់ ( រោយរាយ ) អង្កាមនៃស្រូវសាលី ( លើក្បាល-ខ្លួន ) ប្រេតម្នាក់ទៀត ( សំពងបំបែកក្បាលរបស់ខ្លួន ដោយដំបងដែក ) ឯស្រីនេះ ( ស៊ីតែ ) សាច់ និងឈាមរបស់ខ្លួន ទាំងអ្នកសោតក៏ស៊ីអាចម៍ មិនស្អាត មិនគួរឱ្យប្រាថ្នា នេះតើជាផលនៃកម្មដូចម្តេច ។*

បណ្តាបទទាំងនោះ បទថា **តុសានិ** បានដល់ អង្កាម ។ បទថា **ឯកោ** ប្រែថា ម្នាក់ ។ បទថា **សាលឹ** ប្រែថា ស្រូវសាលី ។ មែនពិត បទថា **សាលឹ** នេះ ជាទុតិយាវិភត្តិ ចុះក្នុងអត្ថនៃឆដ្ឋីវិភត្តិ, អធិប្បាយថា រោយអង្កាមនៃស្រូវសាលី ដែលភ្លើងឆេះសន្ធោសន្ធៅលើក្បាលរបស់ខ្លួន ។ បទថា **បុនាបរោ** កាត់បទជា **បុន អបរោ** ប្រែថា ម្នាក់ទៀត ។ មែនពិត លោកពោលសំដៅដល់ អ្នកវាយក្បាលមាតាហើយ យកដំបងដែកវាយក្បាលខ្លួនឯងរហូតដល់បែក ។ បទថា

**សកមំសលោហិតំ** មានសេចក្តីថា រមែងស៊ីសាច់ខ្នង និងឈាមរបស់ខ្លួនឯង ។ បទថា **អភន្តំ** ប្រែថា មិនគួរឱ្យពេញចិត្ត គឺគួរឱ្យខ្ពើម ។ បទថា **កិស្ស អយំ វិបាកោ** សេចក្តីថា តើនេះជាផលនៃបាបកម្មដូចម្តេច ដែលពួកអ្នកកំពុងសោយក្នុងកាលឥឡូវនេះ ។

កាលព្រះថេរៈសួរនូវបុព្វកម្មដែលជនទាំងនោះបានធ្វើយ៉ាងនេះហើយ ភរិយារបស់ពាណិជបោកប្រាស់ កាលនឹងទូលនូវបុព្វកម្មដែលជនទាំងអស់នោះបានធ្វើទុក ទើបបានពោលនូវគាថាថា :

*ក្នុងកាលមុន ប្រេតម្នាក់នេះ បានប្រហារមាតា ( ដោយ-ព្រនង់ ) ឯប្រេតម្នាក់នេះ ជាពាណិជបោកប្រាស់ ប្រេតនេះ រមែងស៊ីសាច់ទាំងឡាយ ហើយបញ្ឆោតដោយពាក្យមុសាវាទ ។*

*ខ្ញុំបានកើត ជាមនុស្ស ក្នុងពួកមនុស្ស ជាអ្នក*
*គ្រប់គ្រងផ្ទះ ជាឥស្សរៈនៃត្រកូលទាំងពួង ។*

*កាលដែលគ្រឿងឧបករណ៍មានគ្រប់គ្រាន់ ខ្ញុំក៏បានលាក់-លៀមទុក មិនបានឱ្យវត្ថុតិចតួច អំពីគ្រឿងឧបកណ៍នេះ ( ដល់អ្នក-ដទៃ ) ខ្ញុំបិទបាំងដោយពាក្យមុសាវាទថា វត្ថុនេះក្នុងផ្ទះខ្ញុំមិនមានទេ ប្រសិនបើខ្ញុំលាក់វត្ថុដែលមាន សូមឱ្យអាចម៍មកជាភោជនរបស់ខ្ញុំចុះ ។ បាយនៃស្រូវសាលី មានក្លិនក្រអូបឈ្ងុយ ក៏ក្លាយទៅជាអាចម៍ដើម្បីខ្ញុំ ដោយវិបាកនៃកម្មទាំងពីរគឺ ( ការលាក់លៀមទុកវត្ថុដែល-*

*មាន ១ ) និងមុសាវាទ ១ ។ ឯកម្មទាំងឡាយ មិនមែនសោះ-សូន្យឡើយ ព្រោះថា កម្មមិនចេះវិនាសទៅ ខ្ញុំស៊ីផឹកនូវអាចម៍មានក្លិនអាក្រក់ ( ជាលាមកដាប់ ) នៃពួកជង្គូវ ។*

នាងប្រេតកាលនឹងសម្តែងដល់បុត្រទើបបានពោលថា **អយំ** ក្នុងគាថានោះ ។ បទថា **ហឹសតិ** ប្រែថា ប្រើកម្លាំងបៀតបៀន, អធិប្បាយថា ប្រើព្រនង់វាយ ។ បទថា **កូដវាណិជោ** ប្រែថា ពាណិជអាក្រក់, អធិប្បាយថា ធ្វើជំនួញដោយការបោកប្រាស់ ។ បទថា **មំសានិ ខាទិត្វា** សេចក្តីថា បរិភោគសាច់ដែលទូទៅដល់ជនពួកដទៃ ហើយបោកបញ្ឆោតជនទាំងនោះដោយមុសាវាទថា ខ្ញុំមិនបានបរិភោគទេ ។

បទថា **អគារិនី** បានដល់ ស្រ្តីមេផ្ទះ ។ បទថា **សន្តេសុ** សេចក្តីថា កាលដែលគ្រឿងឧបករណ៍ដែលជនពួកដទៃសូមមាននៅនោះឯង ។ បទថា **បរិគុហាមិ** ( បិដកថា **បរិគូយ្ហាមិ** ) ប្រែថា លាក់លៀម ។ មែនពិត **បរិគុហាមិ** នេះ លោកពោលដោយកាលវិបល្លាស ។ បទថា **មា ច កិញ្ចិ ឥតោ អទំ** សេចក្តីថា ខ្ញុំមិនបានឱ្យសូម្បីតែវត្ថុតិចតួច អំពីវត្ថុដែលជារបស់ខ្ញុំនេះ ដល់ជនពួកដទៃដែលត្រូវការឡើយ ។ បទថា **ឆាទេមិ** សេចក្តីថា បិទបាំងដោយមុសាវាទថា វត្ថុនេះមិនមាននៅក្នុងផ្ទះរបស់ខ្ញុំទេ ។

បទថា **គូថំ មេ បរិវត្តតិ** សេចក្តីថា ស្រូវសាលីមានក្លិនក្រអូបរមែងប្រែប្រួលទៅ គឺក្លាយទៅជាលាមក ដោយអំណាចកម្មរបស់ខ្ញុំ ។ បទថា **អវញ្ឈានិ** ( បិដកថា **អនវជ្ជានិ** ) ប្រែថា មិនសោះសូន្យ គឺ មិនឥតផល ។ បទថា **ន ហិ កម្មំ វិនស្សតិ** សេចក្តីថា កម្មតាមដែលខ្លួនបានសន្សំទុក នៅមិនទាន់ឱ្យផល នឹងមិនសោះសូន្យទៅណាឡើយ ។ បទថា **កិមីនំ** បានដល់ មានដង្កូវ គឺកើតជាពួកដង្កូវឡើង ។ បទថា **មីឡ្ហំ** ប្រែថា លាមក ។ ពាក្យដ៏សេសងាយយល់ទាំងអស់ ព្រោះមានន័យដូចពោលរួចមកហើយក្នុងខាងដើម ។

ព្រះថេរៈ លុះបានស្តាប់នូវពាក្យរបស់នាងប្រេតនោះយ៉ាងនេះហើយ ទើបបានក្រាបទូលរឿងនោះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះដ៏មានព្រះភាគ ទ្រង់ធ្វើនូវរឿងនោះឱ្យជាអត្ថុប្បត្តិហេតុហើយ ទើបទ្រង់សម្តែងធម៌ដល់បរិស័ទដែលមកប្រជុំគ្នាហើយក្នុងទីនោះ ។ ព្រះធម្មទេសនានោះ បានសម្រេចជាប្រយោជន៍ដល់មហាជន ដោយប្រការដូច្នេះ ។

**( ចប់រឿងគូថខាទកប្រេតទី ៤ )**

# ៥-រឿងកុមារប្រេត

" ក្មេងពោលវាចាអាក្រក់រមែងបានបាប "

( បិដកលេខ ៥៦, ទំព័រ ៧៨ និងអដ្ឋកថា )

រឿងនៃកុមារប្រេតនេះ មានពាក្យផ្ដើមថា **អច្ឆេររូបំ សុគតស្ស ញាណំ** ដូច្នេះ ។ រឿងនោះមានឧប្បត្តិហេតុដូចម្ដេច ?

បានឮថា ក្នុងក្រុងសាវត្ថី ឧបាសក និងឧបាសិកាជាច្រើន ដែលជាក្រុមអ្នកធមីអាថ៌ បានសាងមណ្ឌបធំក្នុងព្រះនគរ តាក់តែងមណ្ឌបនោះដោយសំពត់មានពណ៌ផ្សេង ៗ រួចហើយក៏បាននិមន្តព្រះ-សាស្ដា និងព្រះភិក្ខុសង្ឃមកពីព្រឹកព្រលឹម អារាធនាភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធានឱ្យគង់លើអាសនៈ ដែលក្រាលដោយកម្រាលយ៉ាង-ល្អដ៏មានតម្លៃច្រើន បូជាដោយសក្ការៈមានគ្រឿងក្រអូបនិងផ្កាកម្រងជាដើមហើយ ឱ្យមហាទានប្រព្រឹត្តទៅ ។ បុរសម្នាក់ មានចិត្តត្រូវមន្ទិល គឺសេចក្ដីកំណាញ់រួបរឹត លុះឃើញដូច្នោះហើយ អត់ទ្រាំនឹងសក្ការៈនោះមិនបាន ទើបពោលយ៉ាងនេះថា វត្ថុទាំងអស់នេះចាក់ចោលលើគំនរសំរាមប្រសើរជាង ជាជាងការថ្វាយដល់សមណៈត្រងោលទាំងនេះ ដែលរកសេចក្ដីល្អគ្មាន ។ ពួកឧបាសកឧបាសិកា

បានឮដូច្នោះ កើតនូវសេចក្តីសង្វេគ នាំគ្នាគិតថា ការដែលបុរសនេះខ្វល់ខ្វាយសាងកម្មអាក្រក់ ដែលជាហេតុឱ្យខុសក្នុងភិក្ខុសង្ឃ មាន-ព្រះពុទ្ធជាប្រធានដល់ថ្នាក់នេះ ចាត់ថាជាកម្មដ៏ធ្ងន់ហ្ន៎ ដូច្នេះហើយទើបបានប្រាប់នូវរឿងនោះ ដល់មាតារបស់គេ ហើយពោលថា ទៅអ្នកចូរទៅសូមខមាទោសព្រះដ៏មានព្រះភាគ មួយអន្លើដោយព្រះ-សង្ឃសាវ័ក ។ មាតាទទួលពាក្យហើយ កាលនឹងសម្លុតបុត្រឱ្យយល់ព្រម ទើបចូលទៅគាល់ព្រះដ៏មានព្រះភាគ និងភិក្ខុសង្ឃ ហើយបានសម្តែងទោសដែលបុត្របានធ្វើ ឱ្យបុត្រសូមខមាទោសរួចហើយ ក៏បានធ្វើនូវការបូជា ដោយការថ្វាយយាគូអស់ ៧ ថ្ងៃ ចំពោះព្រះដ៏-មានព្រះភាគ និងភិក្ខុសង្ឃ ។ ព្រោះដូច្នោះ មិនយូរប៉ុន្មានបុត្រក៏ធ្វើកាលកិរិយាទៅ ហើយក៏បានទៅកើតក្នុងផ្ទៃនៃ**ស្ត្រីពេស្យា** ដែលជាអ្នកចិញ្ចឹមជីវិតដោយកម្មដ៏សៅហ្មង ។ លុះបុត្រកើតមកភ្លាម មាតាដឹងថា ជាក្មេងប្រុស ក៏បានឱ្យគេយកទៅបោះចោលក្នុងព្រៃស្មសាន។ បុត្រនោះ ដែលកម្លាំងនៃបុណ្យរបស់ខ្លួនឃុំគ្រងរក្សាទុកក្នុងទីនោះ មិនត្រូវអ្វីមួយបៀតបៀនឡើយ ទើបដេកលក់ជាសុខដូចដេកលក់នៅលើភ្លៅរបស់មាតា ។ ចំណែកអាចារ្យពួកខ្លះពោលថា ទេវតានាំគ្នាទទួលឃុំគ្រងរក្សាបុត្រនោះទុក ។

លុះវេលាទៀបភ្លឺ ព្រះដ៏មានព្រះភាគស្តេចចេញអំពីមហា-

ករុណាសមាបត្តិ ទ្រង់ប្រមើលមើលសត្វលោកដោយពុទ្ធចក្ខុ ក៏-បានឃើញក្មេងនោះដែលត្រូវគេនាំយកទៅបោះចោលក្នុងព្រៃស្មសាន ទើបទ្រង់យាងទៅកាន់ព្រៃស្មសាន ក្នុងវេលាព្រះអាទិត្យរះឡើង ។ មហាជនប្រជុំគ្នាថា ព្រះសាស្តាស្តេចមកក្នុងទីនេះ ទំនងជាមានហេតុអ្វីមួយក្នុងទីនេះ ។ ព្រះដ៏មានព្រះភាគត្រាស់ដល់បរិស័ទដែលបានមកជួបជុំគ្នាហើយថា ក្មេងនេះមិនមាននរណាស្គាល់ទេ ឥឡូវនេះត្រូវគេនាំយកមកបោះចោលក្នុងព្រៃស្មសាន ឥតទីពឹងក៏ពិតមែន ទោះបីជាយ៉ាងនោះក៏ដោយ ក្មេងនោះក៏នឹងបានទទួលសម្បត្តិដ៏ប្រសើរ ក្នុងអនាគត បច្ចុប្បន្ន និងអភិសម្បរាយភព ហើយត្រូវពួកមនុស្សទាំង-នោះ ទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន ក្នុងជាតិមុន តើក្មេងនេះបានធ្វើកម្មអ្វីទុក ព្រះអង្គ ? ដូច្នេះហើយ ទើបទ្រង់ប្រកាសនូវកម្មដែលក្មេងនោះបានធ្វើទុក និងសម្បត្តិដែលក្មេងនោះគប្បីបានទទួលក្នុងអនាគត ដោយន័យជាដើមថា :

*ពួកជនបានធ្វើនូវការបូជាដ៏ឧឡារិក ចំពោះព្រះសង្ឃ មានព្រះពុទ្ធជាប្រធាន ប៉ុន្តែចិត្តរបស់ក្មេងនោះ ប្រែត្រឡប់ជាយ៉ាងដទៃ ទើបបានពោលវាចាអាក្រក់ មិនមែនជារបស់សប្បុរស ។*

ដូច្នេះហើយ ទើបទ្រង់សម្តែងធម៌ដ៏សមគួរដល់អធ្យាស្រ័យរបស់បរិស័ទដែលមកជួបជុំគ្នាហើយ ទើបទ្រង់ត្រាស់នូវព្រះធម្ម-

ទេសនា ដែលព្រះអង្គទ្រង់លើកឡើងសម្ដែងដោយព្រះអង្គឯង ។ ក្នុងវេលាចប់អរិយសច្ចៈ **សត្វ ៨៤.០០០** បានត្រាស់ដឹងធម៌ ។ កំកុដុម្ពិកៈម្នាក់ ដែលមានទ្រព្យ **៨០ កោដិ** បានទទួលក្មេងនោះចំពោះព្រះភក្ត្រព្រះដ៏មានព្រះភាគថា ជាបុត្ររបស់ខ្ញុំ ។ ព្រះដ៏មានព្រះភាគទ្រង់ព្រះតម្រិះថា ក្មេងនេះ ដែលបុញ្ញកម្មមានប្រមាណប៉ុណ្ណេះរក្សាទុកហើយ និងមហាជននាំគ្នាធ្វើនូវការអនុគ្រោះ ដូច្នេះហើយ ទើបស្ដេចយាងទៅកាន់ព្រះវិហារវិញ ។

លុះកាលជាខាងក្រោយមក កាលកុដុម្ពិកៈនោះ ធ្វើកាលកិរិយាហើយ គេក៏គ្រប់គ្រងទ្រព្យ ដែលកុដុម្ពិកៈនោះបានប្រគល់ទុកឱ្យ បានជាគហបតី មានសម្បត្តិច្រើនក្នុងព្រះនគរនោះឯង ជាអ្នកត្រេកអរក្នុងការឱ្យទានជាដើម ។ ក្រោយមកថ្ងៃមួយ ភិក្ខុទាំងឡាយ សន្ទនាក្នុងធម្មសភាថា គួរឱ្យអស្ចារ្យណាស់ ព្រះសាស្ដាជាអ្នកអនុគ្រោះសត្វទាំងឡាយ សូម្បីក្មេងនោះ ក្នុងកាលនោះ ជាមនុស្សអនាថា ប៉ុន្តែឥឡូវនេះសោយសម្បត្តិច្រើន និងធ្វើ(ទាន)យ៉ាងឧឡារិក ព្រះសាស្ដា ទ្រង់ព្រះសណ្ដាប់ដូច្នោះហើយ ទ្រង់ព្យាករថា ម្នាលភិក្ខុទាំងឡាយ គេមិនមែនមានសម្បត្តិត្រឹមតែប៉ុណ្ណេះទេ តាមពិតក្នុងវេលាអស់អាយុគេនឹងបានទៅកើតជាឱរសរបស់ស្ដេចសក្កទេវរាជក្នុងជាន់តាវត្តិង្ស ហើយនឹងបានសម្បត្តិដ៏ជាទិព្វ ។ ភិក្ខុទាំងឡាយ

និងមហាជន បានស្តាប់ដូច្នោះហើយ គិតថា ព្រះដ៏មានព្រះភាគ ទ្រង់ព្រះនាមថា អ្នកឃើញកាលវែង, ទ្រង់ស្តាប់នូវហេតុនោះហើយ យាងទៅ កាលគេកើតមកប៉ុណ្ណោះ ក៏ត្រូវគេនាំយកមកបោះចោល ក្នុងព្រៃស្មសាន ទ្រង់យាងទៅក្នុងទីនោះ ធ្វើនូវការសង្គ្រោះគេ ដូច្នេះហើយ ទើបនាំគ្នាសរសើរព្រះញាណពិសេសរបស់ព្រះសាស្តា ហើយ បានក្រាបទូលប្រវត្តិក្មេងនោះក្នុងអត្តភាពនោះ ។ ព្រះសង្គីតិកាចារ្យទាំងឡាយ កាលនឹងសម្តែងនូវសេចក្តីនោះ ទើបបានពោលគាថា ៦ គាថាថា :

*ញាណរបស់ព្រះសុគត មានសភាពអស្ចារ្យ ដូចព្រះសាស្តាទ្រង់ព្យាករនូវបុគ្គលថា បុគ្គលពួកខ្លះ ជាអ្នកមានបុណ្យក្រាស់ បុគ្គលពួកខ្លះ ជាអ្នកមានបុណ្យស្តើង ។ កុមារនេះ ដែលគេបោះចោលក្នុងព្រៃស្មសាន បានញុំាងអត្តភាពឱ្យប្រព្រឹត្តទៅ ដោយទឹកដោះដែលហូរចេញអំពីមេដៃ ( នៃទេវតា ) អស់មួយរាត្រី ។ យក្ស និងភូតទាំងឡាយក្តី ពស់ទាំងឡាយក្តី មិនបៀតបៀនកុមារ អ្នកមានបុណ្យធ្វើហើយទេ សូម្បីតែពួកឆ្កែ ក៏មកលិទ្ធជើងទាំងគូ របស់កុមារនេះដែរ ពួកបក្សីក្អែក ពួកចចក ក៏មកចោមជុំវិញ ( កុមារនោះ ) ។ ហ្វូងសត្វស្លាបទាំងឡាយ ក៏នាំយកមន្ទិលគភ៌ចេញ ឯក្អែកទាំងឡាយក៏នាំយកអាចម៍ភ្នែកចេញ មនុស្សនិងអមនុស្សពួកខ្លះ មិនបាន-*

*ចាត់ចែងការរក្សានូវកុមារនេះទេ មិនបានចាត់ចែងនូវឱសថ និងការអប់ដោយគ្រាប់ស្ពៃ ( ដល់កុមារនេះទេ ) ។ សូម្បីតែពួកមនុស្ស ក៏មិនរៀនទូវការប្រកបនូវនក្ខត្តឫក្ស ទាំងមិនបានរោយរាយ នូវធញ្ញជាតិគ្រប់មុខ លើកុមារដែលមានសភាពដូច្នោះ ដែលដល់នូវសេចក្ដីលំបាកយ៉ាងក្រៃលែង គេនាំមកក្នុងពេលយប់ ហើយបោះចោលក្នុងព្រៃស្មសាន ព្រះពុទ្ធដែលទេវតានិងមនុស្សបូជា បានឃើញកុមារនោះ ដូចជាដុំនៃទឹកដោះខាប់ កំពុងតែញាប់ញ័រប្រកបដោយសេចក្ដី-សង្ស័យ នៅសល់តែជីវិត លុះព្រះពុទ្ធមានប្រាជ្ញាស្មើដោយផែនដីបានឃើញហើយ ទើបទ្រង់ព្យាករថា កុមារនេះ នឹងបានជាអ្នកមានត្រកូលដ៏ប្រសើរផង នឹងមានភោគៈផង ក្នុងនគរនេះ ។*

ពួកឧបាសកដែលឈរនៅក្នុងទីជិតព្រះសាស្ដាទូលសួរថា :

*វ័តដូចម្ដេច ព្រហ្មចរិយៈដូចម្ដេច នេះជាផលនៃវ័ត ឬព្រហ្មចរិយៈដូចម្ដេច ដែលកុមារនេះបានសន្សំល្អហើយ បានជាកុមារនេះដល់នូវសេចក្ដីវិនាសដល់ម្ល៉េះ ហើយត្រឡប់បាននូវឫទ្ធិ គឺទិព្វសម្បត្តិដល់ម្ល៉ោះនោះវិញ ។*

បណ្ដាបទទាំងនោះ បទថា **អច្ឆេររូបំ** បានដល់ មានសភាពគួរឱ្យអស្ចារ្យ ។ បទថា **សុគតស្ស ញាណំ** បានដល់ ព្រះញាណនៃព្រះសម្មាសម្ពុទ្ធដែលមិនទូទៅដល់សាវ័កដទៃ ដែលលោកពោល

សំដៅយកព្រះសព្វញ្ញុតញ្ញាណ មានអាសយានុសយញ្ញាណជាដើម ប៉ុណ្ណោះ ។ ដើម្បីចៀសវាងពាក្យសួរថា ព្រះញាណនេះនោះ មិនជាវិស័យរបស់សាវ័កដទៃ តើដូចម្តេច ? ទើបពោលថា ព្រះសាស្តាទ្រង់ព្យាករតាមជាន់ថ្នាក់របស់បុគ្គល ។ ដោយពាក្យនោះ លោកសម្តែងថា ភាពដែលព្រះញាណជាភាវៈគួរអស្ចារ្យ រមែងដឹងបានដោយទេសនារបស់ព្រះសាស្តាប៉ុណ្ណោះ ។

ឥឡូវនេះ កាលទ្រង់នឹងព្យាករ ព្រះអង្គទើបត្រាស់ថា បុគ្គលខ្លះមានបុណ្យច្រើន បុគ្គលខ្លះមានបុណ្យតិច ដូច្នេះ ។ សេចក្តីនៃពាក្យនោះ មានអធិប្បាយដូច្នេះថា បុគ្គលពួកខ្លះក្នុងលោកនេះមានកុសលធម៌ច្រើន ជាអ្នកវិនាសចាកជាតិជាដើម ដោយអំណាចអកុសលដែលខ្លួនបានធ្វើហើយជាបច្ច័យក៏មាន, បុគ្គលពួកខ្លះមានបុណ្យតិចក៏មាន, បុគ្គលពួកខ្លះមានបុញ្ញធម៌តិចជាងក៏មាន ជាអ្នករុងរឿង ព្រោះភាពជាបុណ្យរុងរឿងច្រើន ដោយហេតុមានខេត្ត-សម្បត្តិជាដើម ក៏មាន ។

បទថា **សីវថិកាយ** ប្រែថា ក្នុងព្រៃស្មសាន ។ បទថា **អច្ឆុដ្ឋស្នេហេន** បានដល់ ដោយទឹកដោះដែលហូរចេញអំពីម្រាមដៃ អធិប្បាយថា ដោយទឹកដោះដែលហូរចេញអំពីម្រាមដៃរបស់ទេវតា ។ បទថា **ន យក្ខភូតា ន សិរីសបា វា** សេចក្តីថា សត្វណាមួយ

ទោះជាភូតបិសាច យក្ខភូត ឬពស់តូចធំ ដែលត្រាច់ទៅ ឬដើរទៅ មិនគប្បីបៀតបៀន គឺមិនគប្បីប្រទូសរ៉ាយ ។

បទថា **ចលហិំសុ ឃាតេ** សេចក្តីថា លិទ្ធជើងទាំងពីរដោយអណ្តាតរបស់ខ្លួន ។ បទថា **ឆន្ទា** ប្រែថា ពួកក្អែក ។ បទថា **បរិវត្តយន្តិ** សេចក្តីថា ដើររក្សាជុំវិញទៅមក ៗ ដើម្បីឱ្យដឹងថា មិនមានរោគ ថានរណា ៗ កុំគប្បីបៀតបៀនកុមារនោះឡើយ ។ បទថា **គព្ភាសយំ** ប្រែថា មន្ទិលគភ៌ ។ បទថា **បក្ខិគណា** បានដល់ហ្វូងសត្វស្លាប មានត្មាត និងខ្លែងជាដើម ។ បទថា **ហរន្តិ** ប្រែថា កម្ចាត់ចេញ ។ បទថា **អក្ខិមូលំ** បានដល់ អាចម៍ភ្នែក ។

បទថា **កេចិ** បានដល់ ពួកជាមនុស្ស ប៉ុន្តែអមនុស្សចាត់ចែងរក្សា ។ បទថា **ឱសធំ** បានដល់ ថ្នាំដែលបំបាត់រោគក្នុងកាលនោះ និងកាលតទៅ ។ ដោយបទថា **សាសបធូបនំ វា** លោកសម្តែងថា អ្នកដែលនឹងធ្វើថ្នាំដោយគ្រាប់ស្ពៃ ដើម្បីនឹងរក្សាក្មេងដែលទើបនឹងកើតនោះ មិនមានឡើយ ។ បទថា **នក្ខត្តយោគំបិ ន អគ្គហេសុំ** ( បិដកថា **ន ឧគ្គហេសុំ** ) សេចក្តីថា មិនកាន់យកសូម្បីដោយការប្រកបឫក្ស, អធិប្បាយថា នរណា ៗ មិនធ្វើនូវកម្មដែលទើបនឹងកើតឱ្យដល់គេយ៉ាងនេះថា ក្មេងនេះកើតក្នុងឫក្សនោះ តិថីនោះ វំពេចនោះ ។ បទថា **ន សព្វធញ្ញានិបំ អាកិរីសុ** សេចក្តីថា កាលនឹង

ធ្វើមង្គល មិនបានធ្វើស្រូវ មានស្រូវសាលីជាដើម ដែលលាយជាមួយប្រេងគ្រាប់ស្ពៃ ដែលគេប្រកបឱ្យជាថ្នាំដល់ក្មេងនោះ ។ បទថា **ឯកានិសំ** ប្រែថា មានសភាពដូច្នោះ ។ បទថា **ឧត្តមកិច្ឆបត្តំ** សេចក្ដីថា បានទទួលសេចក្ដីលំបាកយ៉ាងក្រៃលែង គឺបានទទួលទុក្ខយ៉ាងក្រៃលែង ។ បទថា **រត្តាភតំ** បានដល់ ដែលគេនាំមកក្នុងរាត្រី។ បទថា **នវនីតបិណ្ឌំ វិយ** បានដល់ ដូចជាដុំទឹកដោះខាប់, លោកពោលយ៉ាងនោះ ព្រោះត្រឹមតែដុំសាច់ ។ បទថា **វេធមានំ** បានដល់ ញាប់ញ័រដោយភាវៈដែលមានកម្លាំងតិច ។ បទថា **សសំសយំ** សេចក្ដីថា ឈ្មោះថាមានសេចក្ដីសង្ស័យ ព្រោះមានសេចក្ដីសង្ស័យថា គេនៅមានជីវិត ឬ មិនមានទេហ្ន៎ ។ បទថា **ជីវិតសាវសេសំ** បានដល់ នៅសល់ត្រឹមតែជីវិតតែម្យ៉ាង ។ ព្រោះមិនមានទ្រព្យដែលជាហេតុទ្រទ្រង់ជីវិត ។

បទថា **អគ្គកុលិកោ ភវិស្សតិ ភោគវា ច** សេចក្ដីថា នឹងជាអ្នកមានត្រកូលខ្ពង់ខ្ពស់ គឺមានត្រកូលខ្ពស់បំផុតដែលមានភោគៈជាហេតុ គឺដោយអំណាចភោគៈ ។

គាថាថា **កិស្ស វតំ** ជាដើមនេះ គប្បីជ្រាបថា ឧបាសកអ្នកនៅក្នុងសម្នាក់របស់ព្រះសាស្ដា ក្រាបទូលដោយអំណាចពាក្យសួរដល់កម្មដែលគេបានធ្វើទុក និងគាថានោះឯង ឧបាសកដែលមក-

ជួបជុំគ្នានៅក្នុងព្រៃស្មសានបានពោលទុកហើយ ។ បណ្ដាបទ-ទាំងនោះ បទថា **កិស្ស** ប្រែថា ជាកម្មដូចម្ដេច ។ បទថា **វតំ** បានដល់ ការសមាទានវ័ត ។ បទថា **កិស្ស** មានសេចក្ដីប្រកប ការផ្លាស់វិភត្តិទៀតថា **វ័ត** និងព្រហ្មចរិយៈ ដែលគេបានសន្សំទុក ហើយល្អដូចម្ដេច ។ បទថា **ឯតាទិសំ** សេចក្ដីថា ឈ្មោះថា មាន សភាពដូច្នោះ ព្រោះ កើតក្នុងផ្ទៃស្រីពេស្យា ត្រូវគេនាំយកទៅបោះ ចោលក្នុងព្រៃស្មសាន ។ បទថា **ព្យសនំ** ប្រែថា សេចក្ដីវិនាស ។ បទថា **តាទិសំ** ប្រែថា ដូច្នោះ, អធិប្បាយថា មានប្រការដូច ពោលហើយ ដោយន័យមានជាដើមថា រស់នៅអស់មួយរាត្រី ដោយទឹកដោះដែលហូរចេញអំពីម្រាមដៃ និងដោយន័យមានជាដើម ថា ក្មេងនេះនឹងមានត្រកូលខ្ពង់ខ្ពស់នៃនគរនេះ ។ បទថា **ឥទ្ធី** បានដល់ទេវឫទ្ធិ , អធិប្បាយថា ទិព្វសម្បត្តិ ។

ឥឡូវនេះ ព្រះដ៏មានព្រះភាគ ត្រូវឧបាសកទាំងនោះទូលសួរ ហើយ ទ្រង់បានព្យាករក្នុងវេលានោះ ដោយប្រការដែលព្រះសង្គីតិ-កាចារ្យទាំងឡាយ កាលនឹងសម្ដែងបានពោលគាថា ៤ គាថាថា :

*ពួកជនបានធ្វើនូវការបូជា ដ៏ឧឡារិកចំពោះព្រះសង្ឃ មាន-ព្រះពុទ្ធជាប្រធាន ទារកនោះមានចិត្តរវើរវាយក្នុងការបូជានោះ ទារកនោះបានពោលវាចាអាក្រក់ ជាវាចាមិនគួរចង់ឮ ក្នុងទីប្រជុំ*

*នៃសប្បុរស ទារកនោះ បន្ទោបង់សេចក្តីត្រិះរិះនោះចេញហើយ ក៏ត្រឡប់បាននូវសេចក្តីត្រេកអរ និងសេចក្តីជ្រះថ្លា ក្នុងកាលជាខាងក្រោយ ទារកនោះ បានបម្រើព្រះតថាគត ព្រះអង្គគង់នៅក្នុងវត្តជេតពន ដោយយាគូអស់៧ថ្ងៃ ។ នោះជាវ័ត នោះជាព្រហ្មចរិយៈរបស់កុមារនោះ នេះជាផលនៃវ័តឬព្រហ្មចរិយៈនោះ ដែលកុមារនេះសន្សំល្អហើយ បានជាកុមារនេះដល់នូវសេចក្តីវិនាសដល់ម្ល៉េះ ហើយត្រឡប់បាននូវឫទ្ធិ គឺទិព្វសម្បត្តិដល់ម្ល៉ោះនោះវិញ ។ លុះកុមារនោះឋិតនៅក្នុងមនុស្សលោកនេះ អស់មួយរយឆ្នាំ ជាអ្នកបរិបូណ៌ដោយកាមទាំងពួង ដល់បែកធ្លាយរាងកាយទៅកាន់ភពថ្មី ក៏បានជាកូននៃសក្កទេវរាជ ។*

បណ្តាបទទាំងនោះ បទថា **ជនតា** បានដល់ ពួកជន, អធិប្បាយថា គណៈនៃឧបាសក ។ បទថា **តត្រ** បានដល់ ក្នុងការបូជានោះ ។ បទថា **អស្ស** បានដល់ របស់ទារកនោះ ។ បទថា **ចិត្តស្សាហុ អញ្ញថត្តំ** ( បិដកថា **ចិត្តស្ស អហុ អញ្ញថត្តំ** ) សេចក្តីថា ក្នុងភពមុន ចិត្តរបស់គេមានភាវៈជាយ៉ាងដទៃ គឺមិនអើពើ មិនគោរព មិនមានបីតិ ។ បទថា **អសព្ភិ** បានដល់ បានពោលវាចាអាក្រក់ដែលមិនគួរនឹងស្តាប់ក្នុងទីប្រជុំនៃសាធុជន ។

បទថា **សោ** បានដល់ ក្មេងនោះ ។ បទថា **តំ ទិតត្ថំ**

បានដល់ វិតក្កៈដ៏លាមកនោះ ។ បទថា **បវិនោទយិត្វា** ( បិដកថា **បដិវិនោទយិត្វា** ) បានដល់ ស្ងប់រម្ងាប់ដោយសញ្ញត្តិ ( ការប្រកាស-ឱ្យដឹង ) ដែលមាតាធ្វើ ។ បទថា **បីតី បសាទំ បដិលទ្ធា** ( បិដកថា **បីតិបសាទំ បដិលទ្ធា** ) បានដល់ ត្រឡប់បាន គឺធ្វើបីតិ និងសេចក្តីជ្រះថ្លាឱ្យកើត ។ បទថា **យាគុយា ឧបដ្ឋាសិ** បានដល់ បានបម្រើដោយការថ្វាយយាគូ ។ បទថា **សត្តាហំ** ប្រែថា អស់ ៧ ថ្ងៃ ។

បទថា **តស្ស ឧតំ តំ បន ព្រហ្មចរិយំ** សេចក្តីថា សេចក្តីជ្រះថ្លា និងការឱ្យនៃចិត្តរបស់ខ្លួនដែលមានប្រការដូចយើងពោលហើយ ក្នុងខាងដើមនោះ ជារ័ត និងជាព្រហ្មចរិយៈរបស់បុគ្គលនេះ, អធិប្បាយថា មិនមានអ្វីដទៃ ។ បទថា **ឋត្វាន** សេចក្តីថា ស្ថិតនៅក្នុងមនុស្សលោកនេះឯងរហូតដល់អស់អាយុ ។ បទថា **អភិសម្ប-រាយំ** បានដល់ ក្នុងភពថ្មី ។ បទថា **សហព្យតំ គច្ឆតិ វាសវស្ស** ( បិដកថា **វាសវយ** ) បានដល់ នឹងចូលដល់ភាពជាសម្លាញ់ ដោយភាពជាបុត្រនៃស្តេចសក្កទេវរាជ ។ ក៏ពាក្យថា **សហព្យតំ គច្ឆតិ វាសវស្ស** នេះ ជាពាក្យបច្ចុប្បន្នកាល ប្រើក្នុងអត្ថដែលជាអនាគត ។ ពាក្យដ៏សេសក្នុងបទទាំងពួងងាយយល់ទាំងអស់ ដូច្នេះឯង ។

**( ចប់រឿងកុមារប្រេតទី ៥ )**

# ៦-រឿងសេរិនីប្រេត

" មនុស្សកំណាញ់ស្លាប់ទៅកើតជាប្រេត "

( បិដកលេខ ៥៦, ទំព័រ ៨០ និងអដ្ឋកថា )

ព្រះសាស្តា កាលស្តេចគង់ប្រថាប់នៅក្នុងវត្តជេតពនមហា-វិហារ ទ្រង់ប្រារព្ធនាងសេរិនីប្រេត ទើបត្រាស់នូវព្រះគាថាមានពាក្យផ្តើមថា **នគ្គា ទុព្វណ្ណរូបាសិ** ដូច្នេះ ។

បានឮថា ក្នុង**ហត្ថិនីបុរី** ក្នុង**ដែនកុរុរដ្ឋ** មានស្ត្រីម្នាក់ឈ្មោះថា **សេរិនី** ជាអ្នកអាស្រ័យរូបចិញ្ចឹមជីវិត ។ ក៏ភិក្ខុទាំងឡាយ អំពីទីនោះ ៗ បានមកជួបជុំគ្នាក្នុងហត្ថិនីបុរីនោះ ដើម្បីធ្វើឧបោសថ ។ មានភិក្ខុចំនួនជាច្រើនមកប្រជុំគ្នាទៀត ។ មនុស្សទាំងឡាយឃើញដូច្នោះ ទើបចាត់ចែងត្រៀមនូវគ្រឿងឧបករណ៍ ក្នុងការបំពេញទានជាច្រើន មានគ្រាប់ល្ង និងអង្ករជាដើម និងមានទឹកដោះរាវ ទឹកដោះខាប់ និងទឹកឃ្មុំជាដើម បំពេញមហាទាន ។ ក៏សម័យនោះ **នាងគណិកា** ( ស្រីផ្កាមាស ) នោះ មិនមានសទ្ធា មិនមានសេចក្តីជ្រះថ្លា ចិត្តត្រូវរួបរឹតដោយមន្ទិល គឺសេចក្តីកំណាញ់ សូម្បីត្រូវពួកមនុស្សទាំងនោះ ផ្តល់កម្លាំងចិត្តថា មកនាង ជាដំបូងចូរអនុមោទនា

នូវទាននេះ ក៏អះអាងនូវសេចក្ដីមិនជ្រះថ្លាដល់មនុស្សទាំងនោះថា តើមានប្រយោជន៍អ្វីដោយទានដែលឱ្យដល់ពួកសមណៈត្រងោល ការបរិច្ចាគនូវវត្ថុមានប្រមាណតិចតួច នឹងមានមកពីណា ។

សម័យជាខាងក្រោយមក នាងធ្វើកាលកិរិយាហើយ ក៏បានទៅកើតជាប្រេត នៅត្រង់ខ្នងគូ [១] នៃបច្ចន្តនគរមួយ ។ លំដាប់នោះឧបាសកអ្នកក្រុងហត្ថិនីបុរីម្នាក់ ទៅកាន់នគរនោះដើម្បីធ្វើជំនួញ ក្នុងវេលាទៀបភ្លឺនៃរាត្រី បានទៅកាន់ខ្នងគូ ដោយប្រយោជន៍ដូច្នោះ ។ នាងឃើញគាត់ទីនោះ ក៏ចាំបាន ( នាង ) ជាប្រេតអាក្រាតកាយ មានរាងកាយសល់ត្រឹមតែស្បែកដណ្ដប់ឆ្អឹង ឃើញហើយគួរឱ្យខ្លាចក្រៃលែង បានឈរបង្ហាញខ្លួនក្នុងទីមិនឆ្ងាយ ។ ឧបាសកនោះ ឃើញនាងនោះហើយ សួរជាគាថាថា :

*ម្នាលនាងស្គម មានឆ្អឹងជំនីរគាម នាងជាស្រីអាក្រាត មានរូបមានសម្បុរអាក្រក់ ជាស្រីស្គមរីងរៃដោយសរសៃ នាងជាអ្វី មកឈរក្នុងទីនេះ ។*

ចំណែកនាងប្រេត ទើបប្រកាសខ្លួនដល់ឧបាសកនោះដោយគាថាថា :

---

១= គូ ( ន. ) ស្នាមភ្លោះព័ទ្ធបន្ទាយ ឬ វាំង, ពាក្យបុរាណហៅ កសិណ ដូចយ៉ាងកសិណព័ទ្ធជុំវិញនគរវត្តជាដើម .. ( វចនានុក្រមសម្ដេចព្រះសង្ឃរាជជួន ណាត ) ។

*បពិត្រអ្នកដ៏ចម្រើន ខ្ញុំជាស្រីប្រេត ដល់នូវសេចក្តីលំបាក កើតក្នុងយមលោក បានធ្វើនូវកម្មដ៏លាមក ( លុះច្យុត ) អំពីមនុស្សលោកនេះហើយ បានទៅកាន់បេតលោក ។*

នាងត្រូវឧបាសកនោះ សួរដល់កម្មដែលខ្លួនបានធ្វើដោយគាថាទៀតថា :

*អំពើអាក្រក់ដូចម្តេច ដែលនាងបានធ្វើហើយដោយកាយ វាចា ចិត្ត នាង ( ច្យុត ) អំពីមនុស្សលោកនេះ បានទៅកាន់បេតលោក ដោយផលនៃកម្មដូចម្តេច ។*

( នាងប្រេតនោះ ) ទើបប្រាប់នូវកម្មដែលខ្លួនបានធ្វើ និងប្រយោជន៍ដែលគេគប្បីធ្វើឱ្យដល់ខ្លួនទៀត ដោយគាថា ៦ គាថានេះថា :

*ខ្ញុំបានរើសទ្រព្យគេកន្លះមាសកៈ ត្រង់កំពង់ទាំងឡាយ ដែលមិនមានទោស គឺមិនមានអ្នកណាមួយឃាត់ខាំង កាលដែលទេយ្យធម៌ទាំងឡាយ កំពុងមានគ្រប់គ្រាន់ ខ្ញុំមិនបានធ្វើនូវទីពឹងចំពោះខ្លួនសោះ ។ ខ្ញុំស្រេកទឹក ចូលទៅរកស្ទឹង ស្ទឹងក៏បែរទៅជាទទេ ខ្ញុំចូលទៅជ្រកម្លប់ ក្នុងកាលកំពុងក្តៅ ស្រមោលក៏បែរទៅជាក្តៅ ។ ឯខ្យល់ដែលដូចភ្លើងសោត ក៏ក្តៅភាយមកដល់ខ្ញុំ បពិត្រអ្នកដ៏ចម្រើន ខ្ញុំគួរ ( វង ) ទុក្ខមានសម្រេកជាដើមនេះ និងបាបកម្មដទៃ ដ៏លាមក*

*លើសលុបជាងសេចក្តីទុក្ខមានសម្រេកជាដើមនោះ ។ អ្នកគួរទៅកាន់ហត្ថិនីបុរី ហើយជម្រាបមាតារបស់ខ្ញុំថា ខ្ញុំបានឃើញកូនស្រីរបស់នាងដល់នូវសេចក្តីលំបាក កើតក្នុងយមលោក បានធ្វើនូវ-កម្មដ៏លាមក ( ច្យុត )អំពីមនុស្សលោកនេះ បានទៅកាន់បេតលោក ។ ទ្រព្យដែលខ្ញុំទុកក្នុងទីនុ៎ះមាន តែខ្ញុំមិនបានប្រាប់ទ្រព្យនោះ ( ឯទ្រព្យ-ទាំងនោះ ) ចំនួន ៤ សែនកហាបណៈ ក្រោមបល្ល័ង្គ ( របស់ខ្ញុំ ) ។ មាតារបស់ខ្ញុំនោះ ចូរឱ្យទានដើម្បីខ្ញុំផង ចូរចិញ្ចឹមជីវិតផង ដោយទ្រព្យនោះចុះ មាតារបស់ខ្ញុំលុះឱ្យទានហើយ ចូរឧទ្ទិសទក្ខិណាទានដល់ខ្ញុំផង ខ្ញុំនឹងជាអ្នកដល់នូវសេចក្តីសុខ បានសម្រេចសេចក្តីប្រាថ្នាគ្រប់យ៉ាង ក្នុងកាលនោះ ។*

បណ្តាបទទាំងនោះ បទថា **អនាវដេសុ តិត្ថេសុ** ( បិដកថា **អនវជ្ជេសុ តិត្ថេសុ** ) សេចក្តីថា ក្នុងតំបន់ដែលជាកំពង់របស់ស្ទឹងនិងស្រះទឹកជាដើម ដែលនរណា ៗ មិនហាមឃាត់ គឺក្នុងទីដែលពួកមនុស្សងូត និងធ្វើកិច្ចដោយទឹកដូច្នោះ ។ បទថា **វិចិនឹ អឌ្ឍមាសកំ** ( បិដកថា **វិចិនិ** ) សេចក្តីថា ខ្ញុំត្រូវសេចក្តីលោភគ្របសង្កត់ រាវរកគឺស្វែងរក បានទ្រព្យត្រឹមតែកន្លះមាសកៈ ដោយគិតថា ធ្វើដូចម្តេចហ្ន៎ យើងគប្បីបាន នូវរបស់អ្វីម្យ៉ាងក្នុងទីនេះ ដែលពួកមនុស្សភ្លេច ។ ម្យ៉ាងទៀត បទថា **អនាវដេសុ តិត្ថេសុ** សេចក្តីថា កាលសមណ-

ព្រាហណ៍ ដែលជាទីពឹងរបស់សត្វទាំងឡាយ ដោយភាពជាហេតុនៃសេចក្តីបរិសុទ្ធ ដែលជាប់ទាក់ទងដោយសេចក្តីព្យាយាមរបស់ពួក-សត្វ ដែលមិនមាននរណាហាមឃាត់ ដោយការចូលទៅរកមាន ។ បទថា **វិចិនិំ អគ្ឃមាសកំ** សេចក្តីថា ខ្ញុំមានចិត្តត្រូវមន្ទិល គឺសេចក្តីកំណាញ់រួបរឹត ទើបមិនឱ្យនូវវត្ថុអ្វីមួយដល់នរណាម្នាក់ឡើយ ទើបរក្សាទ្រព្យ ទុកជាពិសេសកន្លះមាសកៈ ទើបមិនបានសន្សំបុណ្យទុក ។ ព្រោះហេតុនោះ លោកទើបពោលថា កាលទេយ្យធម៌មាន ខ្ញុំមិនបានធ្វើទីពឹងដល់ខ្លួនឡើយ ដូច្នេះជាដើម ។

បទថា **តសិតា** បានដល់ អ្នកស្រេកហើយ ។ បទថា **រិត្តកា** សេចក្តីថា ស្ទឹងដែលក្អែកល្មមនឹងផឹកបាន ដែលកំពុងតែហូរទៅ ក៏ប្រែទៅជាស្ទឹងទទេគ្មានទឹក មានត្រឹមតែខ្សាច់ ព្រោះអំពើអាក្រក់របស់ខ្ញុំ ។ បទថា **ឧណ្ហេសុ** បានដល់ ក្នុងរដូវក្តៅ ។ បទថា **អាតបោ បរិវត្តតិ** សេចក្តីថា ទីដែលមានម្លប់ កាលខ្ញុំចូលទៅ ក៏ប្រែទៅជាក្តៅ ។

បទថា **អគ្គិវណ្ណោ** ( បិដកថា **អគិវណ្ណោ** ) បានដល់ មានសម្ផស្សដូចជាភ្លើង ។ ព្រោះហេតុនោះ លោកទើបពោលថា ក្តៅភាយដូច្នេះជាដើម នាងប្រេតហៅឧបាសកនោះ ដោយសេចក្តីគោរពថា **ភន្តេ** ក្នុងបទថា **ឯតញ្ច ភន្តេ អរហាមិ** នេះ, អធិប្បាយថា

បពិត្រអ្នកដ៏ចម្រើន ក៏ខ្ញុំសមគួរសោយនូវសេចក្ដីទុក្ខ ដែលកើតអំពីសម្រេកជាដើម ដូចដែលបានពោលរួចមកហើយនេះ និងទុក្ខដទៃ-ដ៏លាមកទារុណជាងនោះ ព្រោះខ្ញុំបានធ្វើនូវកម្មអាក្រក់ ដែលកើតពីអំពើនោះ ។ បទថា **ខជ្ជេសិ** ប្រែថា គប្បីពោល ។ បទថា **ឯត្ថ និក្ខិត្តំ អនក្ខាតំ** សេចក្ដីថា ខ្ញុំមិនបានប្រាប់ថា ទ្រព្យមានប្រមាណប៉ុណ្ណេះ ទុកក្នុងទីនេះឡើយ ។ ឥឡូវនេះ នាងប្រេតកាលនឹងសម្ដែងនូវបរិមាណរបស់ទ្រព្យនោះ ទើបពោលថា ទ្រព្យ ៤០០.០០០ ( បួន-សែន ) ខ្ញុំបានលាក់ទុកនៅខាងក្រោមគ្រែដូច្នេះជាដើម ។ បណ្ដា-បទទាំងនោះ បទថា **បល្លង្កស្ស** បានដល់ បល្ល័ង្កដែលជាទីដេករបស់ខ្ញុំក្នុងកាលមុន ។ បទថា **តតោ** សេចក្ដីថា សូមមាតា ចូរកាន់យកទ្រព្យមួយចំណែកពីទ្រព្យដែលខ្ញុំកប់ទុក ហើយចូរឱ្យទានឧទ្ទិសដល់ខ្ញុំ ។ បទថា **តស្សា** បានដល់ មាតារបស់ខ្ញុំ ។

កាលនាងប្រេតនោះ ពោលយ៉ាងនេះ ឧបាសកនោះទទួលពាក្យរបស់នាងប្រេតនោះហើយ ពិចារណាករណីកិច្ចរបស់ខ្លួនក្នុងទីនោះ ទើបទៅកាន់ហត្ថិនីនគរ ក៏បានប្រាប់នូវរឿងនោះដល់មាតារបស់នាង ។ ដើម្បីនឹងសម្ដែងនូវរឿងនោះ ព្រះសង្គីតិកាចារ្យទាំងឡាយ ទើបពោលថា :

*ឧបាសកនោះ ទទួលស្ដាប់ពាក្យប្រេតនោះថា ប្រពៃហើយ*

រួចក៏ទៅកាន់ហត្ថិនីបុរី បានប្រាប់ដល់មាតារបស់ស្រីប្រេតនោះថា ខ្ញុំបានឃើញកូនស្រីរបស់នាង ដល់នូវសេចក្តីលំបាក កើតក្នុងយមៈ-លោក បានធ្វើនូវកម្មដ៏លាមក ( ច្យុត ) អំពីមនុស្សលោកនេះទៅកាន់បេតលោក កូនស្រីរបស់នាងនោះ បានផ្តាំនឹងខ្ញុំក្នុងបេត-លោកនោះថា អ្នកអញ្ជើញទៅកាន់ហត្ថិនីបុរី ហើយជម្រាបដល់មាតារបស់ខ្ញុំថា ខ្ញុំបានឃើញកូនស្រីរបស់នាង ដល់នូវសេចក្តីលំបាកកើតក្នុងយមលោក បានធ្វើកម្មដ៏លាមក ( ច្យុត ) អំពីមនុស្សលោក-នេះ ទៅកាន់បេតលោក ។ ទ្រព្យដែលខ្ញុំទុកក្នុងទីនុ៎ះមាន តែខ្ញុំមិនបានប្រាប់នូវទ្រព្យនោះ ( ឯទ្រព្យទាំងនោះ ) ចំនួន ៤ សែនកហាបណៈនៅខាងក្រោមបល្ល័ង្ក ( របស់ខ្ញុំ ) ។ សូមមាតាឱ្យទានដើម្បីខ្ញុំផង ចូរចិញ្ចឹមជីវិតផង ដោយទ្រព្យនោះចុះ មាតារបស់ខ្ញុំលុះឱ្យទានហើយសូមឧទ្ទិសនូវទក្ខិណាទានដល់ខ្ញុំផង ខ្ញុំនឹងជាអ្នកដល់នូវសេចក្តីសុខ បានសម្រេចសេចក្តីប្រាថ្នាគ្រប់យ៉ាង ក្នុងកាលនោះ ។

ក៏ក្នុងលំដាប់នោះ មាតានោះបានឱ្យទាន លុះឱ្យហើយបានឧទ្ទិសនូវទក្ខិណាទានដល់ស្រីប្រេតនោះ ស្រីប្រេតក៏បានដល់នូវ-សេចក្តីសុខផង មាតានោះចិញ្ចឹមជីវិត ដោយងាយផង ។

គាថាទាំងនោះ ងាយយល់ទាំងអស់ ។

មាតារបស់នាងបានស្តាប់ដូច្នោះហើយ ក៏បានថ្វាយទានចំពោះភិក្ខុសង្ឃ រួចហើយក៏បានឧទ្ទិសដល់នាង ។ ព្រោះហេតុនោះនាងតាំងនៅក្នុងភាពបរិបូណ៌ ដោយគ្រឿងឧបករណ៍ដែលបានមកហើយក៏បានបង្ហាញខ្លួនដល់មាតា ប្រាប់នូវហេតុនោះឱ្យជ្រាប មាតាក៏បានពិតដល់ភិក្ខុទាំងឡាយ ។ ភិក្ខុទាំងឡាយ ក្រាបទូលរឿងនោះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះដ៏មានព្រះភាគ ទ្រង់ធ្វើនូវរឿងនោះឱ្យជាអត្ថុប្បត្តិហេតុ ទើបទ្រង់សម្តែងធម៌ដល់បរិស័ទដែលមកជួបជុំគ្នាហើយ ព្រះធម៌ទេសនានោះ បានជាប្រយោជន៍ដល់មហាជនដោយប្រការ ដូច្នេះ ។

## ( ចប់រឿងសេរិនីប្រេតទី ៦ )

# ៧.រឿងមិគលុទ្ទប្រេត

" ព្រានម្រឹគចិត្តអាក្រក់ស្លាប់ទៅកើតជាប្រេត "

( បិដកលេខ ៥៦, ទំព័រ ៨៣ និងអដ្ឋកថា )

កាលព្រះដ៏មានព្រះភាគជាម្ចាស់ គង់ប្រថាប់នៅក្នុងវត្តវេឡុវ័នមហាវិហារ ទ្រង់ប្រារព្ធមិគលុទ្ទកប្រេត ទើបត្រាស់នូវព្រះគាថានេះ មានពាក្យផ្ដើមថា **នរនារីបុរក្ខតោ យុវា** ដូច្នេះ ។

បានឮថា ក្នុងក្រុងរាជគ្រឹះ មានព្រានម្នាក់ ដើរបរបាញ់សត្វចិញ្ចឹមជីវិតទាំងថ្ងៃទាំងយប់ ។ ព្រាននោះ មានសម្លាញ់ជាឧបាសកម្នាក់ ។ ឧបាសកនោះ កាលមិនអាចនឹងឱ្យព្រាននោះ ត្រឡប់ចាកអំពើអាក្រក់គ្រប់កាលបាន ទើបណែនាំឱ្យធ្វើនូវបុញ្ញកម្មក្នុងវេលារាត្រីថា នែសម្លាញ់ អ្នកចូរវៀរចាកបាណាតិបាតក្នុងពេលយប់ចុះ ។ គាត់វៀរចាកក្នុងពេលយប់ ធ្វើបាណាតិបាតក្នុងពេលថ្ងៃប៉ុណ្ណោះ ។

សម័យខាងក្រោយមក គាត់ធ្វើកាលកិរិយាហើយ ក៏បានកើតជាវេមានិកប្រេត ជិតក្រុងរាជគ្រឹះ សោយនូវសេចក្ដីទុក្ខយ៉ាងក្រៃលែង ក្នុងពេលថ្ងៃ, បរិបូណ៌ក្នុងការបម្រើដោយកាមគុណ ៥ ក្នុងវេលាយប់ ។ ព្រះនារទៈឃើញដូច្នោះ ទើបសួរដោយគាថានេះថា:

*អ្នកនៅក្មេង មាននរនារីចោមរោម រុងរឿងដោយកាមគុណទាំងឡាយ គួរឱ្យត្រេកត្រអាល ( ក្នុងពេលយប់ វេទនា ) ក្នុងពេលថ្ងៃ អ្នកបានធ្វើនូវកម្មអ្វី ក្នុងជាតិមុន ។*

បណ្ដាបទទាំងនោះ បទថា **នរនារិបុរក្ខតោ** សេចក្ដីថា ទេវបុត្រ ទេវធីតា ជាអ្នកបម្រើ នាំគ្នាចោមរោមចូលអង្គុយជិត ។ បទថា **យុវា** ប្រែថា នៅក្មេង ។ បទថា **រជនីយេហិ** ប្រែថា ដែលជាហេតុឱ្យប្រាថ្នា គឺ ជាហេតុឱ្យកើតសេចក្ដីត្រេកត្រអាល ។ បទថា **កាមគុណេហិ** បានដល់ ដោយចំណែកនៃកាម ។ បទថា **សោភសិ** អធិប្បាយថា រមែងរុងរឿងដោយភាពបរិបូណ៌ក្នុងពេលយប់ ។ ព្រោះហេតុនោះ ព្រះនារទៈទើបពោលថា សោយនូវសេចក្ដីទុក្ខក្នុងពេលថ្ងៃដូច្នេះ, អធិប្បាយថា សោយនូវហេតុ គឺសេចក្ដីចង្អៀតចង្អល់ ក្នុងពេលថ្ងៃ ។ ម្យ៉ាងទៀត បទថា **រជនី** បានដល់ក្នុងពេលយប់ ។ បទថា **យេហិ** គ្រាន់តែជានិបាត ។ បទថា **កិម-កាសិ បុរិមាយ ជាតិយា** ( បិដកថា **អកាសិ បុរិមាយ ជាតិយា** ) សេចក្ដីថា ក្នុងជាតិមុនអំពីជាតិនេះ អ្នកបានធ្វើនូវកម្មអ្វី ដែលជាផ្លូវឱ្យសោយនូវសេចក្ដីសុខ និងសេចក្ដីទុក្ខយ៉ាងនេះ សូមអ្នកចូរប្រាប់នូវកម្មនោះចុះ ។

ប្រេតបានស្ដាប់ដូច្នោះហើយ កាលនឹងប្រាប់នូវកម្មដែលខ្លួន-

បានធ្វើ ទើបបានពោលគាថាទាំងនេះថា :

*កាលពីដើមខ្ញុំជាព្រានម្រឹគ មានដៃប្រឡាក់ដោយឈាម ជាអ្នកអាក្រក់ នៅក្នុងក្រុងរាជគ្រឹះ មានភ្នំដូចជាក្រោល ជាទីគួរត្រេកអររីករាយ ។ ខ្ញុំមានចិត្តប្រទូស្តចំពោះពួកសត្វច្រើន ជាសត្វមិនធ្វើកំហុស ( នឹងនរណាមួយ ) អាក្រក់ក្រៃពេក ត្រេកអរតែក្នុងការបៀតបៀនចំពោះសត្វដទៃ មិនសង្រួម គ្រប់កាលទាំងពួង ។ សម្លាញ់របស់ខ្ញុំនោះ អ្នកមានហឫទ័យល្អ ជាឧបាសកមានសទ្ធា គាត់អនុគ្រោះ បានឃាត់ខ្ញុំរឿយ ៗ ថា អ្នកកុំធ្វើអំពើអាក្រក់ឡើយ នែអ្នក អ្នកកុំទៅកាន់ទុគ្គតិឡើយ បើអ្នកប្រាថ្នាសេចក្ដីសុខក្នុងលោក អ្នកចូរវៀរបង់ការមិនសង្រួមគឺការសម្លាប់សត្វ ។ ខ្ញុំបានស្ដាប់ពាក្យ-សម្លាញ់នោះ ជាអ្នកប្រាថ្នានូវសេចក្ដីសុខ អ្នកអនុគ្រោះដោយ-ប្រយោជន៍ តែខ្ញុំជាអ្នកត្រេកអរក្នុងបាបយូរយារ មិនមានប្រាជ្ញា មិនបានធ្វើតាមពាក្យប្រៀនប្រដៅ ( របស់គាត់ ) ទាំងអស់ ។ សម្លាញ់នោះ ជាអ្នកមានប្រាជ្ញាល្អ ស្មើដោយផែនដី បានតម្កល់ខ្ញុំក្នុងសេចក្ដីសង្រួមម្ដងទៀត ដោយសេចក្ដីអនុគ្រោះថា បើអ្នកសម្លាប់ពួកសត្វក្នុងវេលាថ្ងៃ ត្រូវអ្នកសង្រួមក្នុងវេលាយប់ចុះ ។ ខ្ញុំនោះសម្លាប់ពួកសត្វ តែក្នុងវេលាថ្ងៃ ជាអ្នកសង្រួមវៀរចាកការសម្លាប់សត្វក្នុងវេលាយប់ ខ្ញុំរក្សាខ្លួនបានតែក្នុងវេលាយប់ វេលាថ្ងៃទៅកាន់ទុគ្គតិ*

*( ផ្ដៃទាំងឡាយ ) ខាំស៊ី ។ ខ្ញុំបានសោយសម្បត្តិ មិនមែនជារបស់ មនុស្សក្នុងវេលាយប់ ( ដោយអំណាច ) កុសលកម្មនោះ វេលាថ្ងៃ ពួកផ្កៃមានចិត្តខ្វាញ់ស្អុះមកចោមខាំ ដោយជុំវិញ ពួកសត្វណា មានការប្រកបរឿយ ៗ ប្រកបជានិច្ច ក្នុងសាសនារបស់ព្រះសុគត ខ្ញុំសម្គាល់ថា ពួកសត្វនោះតែងបានទូវព្រះនិព្វាន ឈ្មោះអមតៈ ជាធម្មជាតសុទ្ធ គឺមិនលាយឡំ ដោយលោកិយសុខ ជាបទមិនមាន បច្ច័យ ប្រជុំតាក់តែងបានឡើយ ។*

បណ្ដាបទទាំងនោះ បទថា **លុទ្ទោ** បានដល់ ឃោរឃៅ ។ បទថា **លោហិតបាណិ** បានដល់ អ្នកមានបាតដៃដែលប្រឡាក់ឈាម ដោយការសម្លាប់សត្វជារឿយ ៗ ។ បទថា **ទារុណោ** ប្រែថា ខ្លាំងក្លា, អធិប្បាយថា បៀតបៀនខ្លួនឯង ។ បទថា **អទិរោធកភេសុ** បានដល់ ក្នុងម្រឹគ និងសត្វស្លាបជាដើម ជាអ្នកមិនធ្វើនូវសេចក្ដី ក្រោធដោយអាការណាមួយ ។

បទថា **អសំយមា** ( បិដកថា **អសញ្ញតោ** ) ប្រែថា អ្នកមិន សង្រួម គឺជាអ្នកទ្រុស្តសីល ។ បទថា **សកលានុសាសនី** សេចក្ដីថា នូវអនុសាសនីទាំងពួង គឺការវៀរចាកបាណាតិបាតគ្រប់កាល ។ បទថា **ចិរបាបាភិរតោ** បានដល់ អ្នកត្រេកអរក្រៃលែងក្នុងបាប អស់កាលដ៏យូរ ។

បទថា **សំយមេ** គឺ ក្នុងសុចរិត ។ បទថា **និវេសយិ** ប្រែថា តាំងនៅហើយ ។ ពាក្យថា បើអ្នកសម្លាប់សត្វក្នុងវេលាថ្ងៃ ចំណែកឯពេលយប់ ចូរវៀរចាក នេះ ជាពាក្យសម្តែងអាការនៃសេចក្តីតាំងមាំ ។ បានឮថា នាយព្រាននោះ ជាអ្នកប្រកបនូវការសម្លាប់សត្វជារឿយ ៗ ក្នុងវេលាយប់ ដោយការដាក់អន្ទាក់ គឺ កូនសរជាដើម ។

បទថា **ទិវា ខជ្ជាមិ ទុគ្គតោ** សេចក្តីថា ឥឡូវនេះ ខ្ញុំបានដល់នូវទុគ្គតិ សោយនូវសេចក្តីទុក្ខយ៉ាងក្រៃលែង ( ត្រូវឆ្កែ ) ខាំស៊ីក្នុងវេលាថ្ងៃ ។ បានឮថា ក្នុងពេលថ្ងៃ គាត់បានសោយនូវផលដែលគប្បីឃើញស្មើដោយកម្ម ព្រោះឱ្យសុនខខាំម្រឹគ ក្នុងពេលថ្ងៃ សុនខធំ ៗ ស្ទុះទៅ ធ្វើសរីរៈឱ្យនៅសល់ត្រឹមតែរាងឆ្អឹង ប៉ុន្តែកាលបើឈានចូលដល់វេលាយប់ រាងកាយនោះទើបត្រឡប់ជាប្រក្រតីដូចដើមវិញ ហើយក៏បានសោយនូវទិព្វសម្បត្តិ ។ ព្រោះហេតុនោះ លោកទើបពោលថា :

*ខ្ញុំបានសោយសម្បត្តិ មិនមែនជារបស់មនុស្សក្នុងវេលាយប់ ( ដោយអំណាច ) កុសលកម្មនោះ វេលាថ្ងៃ ពួកឆ្កែមានចិត្តខ្ញាញ់ស្ទុះមកចោមខាំ ដោយជុំវិញ ។*

បណ្តាបទទាំងនោះ បទថា **បជិហតា** សេចក្តីថា ជាអ្នកមាន

ចិត្តកាចសាហាវ គឺដូចជាត្រូវសេចក្ដីចង្អៀតចង្អល់រួបរឹត ។ បទថា **សមន្តា ខាទិតុំ** បានដល់ ស្ទុះទៅ ដើម្បីខាំស៊ីរាងកាយរបស់ខ្ញុំ ដោយជុំវិញ ។ ក៏សេចក្ដីនេះ លោកពោលសំដៅយកវេលាដែលពួកសុនខទាំងនោះ ចូលទៅជិតនាំយកនូវសេចក្ដីខ្លាចមកឱ្យដល់ខ្លួនយ៉ាងក្រៃលែង ក៏សុនខទាំងនោះ ស្ទុះទៅធ្វើនូវរាងកាយឱ្យនៅសល់ត្រឹមតែឆ្អឹងហើយ ទើបចៀសចេញទៅ ។

ក្នុងគាថាចុងក្រោយថា **យេ ច តេ សតតានុយោគិនោ** មានសេចក្ដីសង្ខេបដូចតទៅនេះ ដែលឈ្មោះថា ខ្ញុំ ក៏ជាអ្នកវៀរចាកហេតុត្រឹមតែការសម្លាប់សត្វតែក្នុងវេលាយប់ បានសោយនូវទិព្វ-សម្បត្តិដល់ម្ល៉េះ ក៏ពួកជនណាជាអ្នកខ្វល់ខ្វាយមាំទាំ គឺព្យាយាមប្រកបរឿយ ៗ គឺគ្រប់កាល ក្នុងអធិសីលជាដើម ក្នុងព្រះសាសនារបស់ព្រះដ៏មានព្រះភាគជាម្ចាស់ ពួកជននោះ ជាអ្នកមានបុណ្យប្រាកដជាសម្រេចនូវអមតធម៌ ដែលមាននាមថា អសង្ខតបទដែលមិនលាយឡំ ដោយលោកិយសុខតែម្យ៉ាងប៉ុណ្ណោះ គឺពួកជននោះ រមែងមិនមានការហាមឃាត់ណាមួយក្នុងការសម្រេចនូវអមត-បទនោះ ។

កាលប្រេតនោះ ពោលយ៉ាងនេះហើយ ព្រះថេរៈទើបក្រាបទូលនូវរឿងនោះចំពោះព្រះសាស្ដា ។ ព្រះសាស្ដាទ្រង់ធ្វើនូវ-

រឿងនោះ ឱ្យជាអត្ថុប្បត្តិហេតុ ទ្រង់សម្តែងធម៌ដល់បរិស័ទដែលមកជួបជុំគ្នាហើយ, ពាក្យទាំងអស់នោះ មានន័យដូចបានពោលរួចមកហើយនោះឯង ។

## ( ចប់រឿងមិគលុទ្ទប្រេតទី ៧ )

**បាបញ្ចេ បុរិសោ កយិរា ន នំ កយិរា បុនប្បុនំ**
**ន តម្ហិ ឆន្ទំ កយិរាថ ទុក្ខោ បាបស្ស ឧច្ចយោ ។**

បើបុរសធ្វើបាប កុំធ្វើបាបនោះរឿយ ៗ ឡើយ កុំគប្បីធ្វើសេចក្តីពេញចិត្ត ក្នុងបាបនោះ ( ព្រោះថា ) ការសន្សំបាបតែងនាំសេចក្តីទុក្ខមកឱ្យ ។

( បិដកលេខ ៥២ ទំព័រ ៤៦ )

# ៨-រឿងទុតិយមិគលុទ្ទប្រេត

" កម្មញុំាងឱ្យព្រានម្រឹគសោយទុក្ខក្នុងព្រៃស្មសាន "

( បិដកលេខ ៥៦, ទំព័រ ៨៥ និងអដ្ឋកថា )

កាលព្រះដ៏មានព្រះភាគ គង់ប្រថាប់នៅវត្តវេឡុវ័នមហាវិហារ ទ្រង់ប្រារព្ធមិគលុទ្ទកប្រេតម្នាក់ទៀត ទើបត្រាស់នូវពាក្យផ្ដើមថា **កូដាគារេ ច បាសាទេ** ដូច្នេះ ។

បានឮថា ក្នុងក្រុងរាជគ្រឹះ មាណព ឈ្មោះថា **មាគវិកៈ**ម្នាក់ សូម្បីជាអ្នកបរិបូណ៌ដោយសម្បត្តិ ក៏លះបង់នូវភោគសុខ ចេញទៅបរបាញ់សត្វទាំងយប់ទាំងថ្ងៃ ។ ឧបាសកម្នាក់ ដែលជាសម្លាញ់របស់គេ អាស្រ័យនូវសេចក្ដីអនុគ្រោះទើបឱ្យឱវាទថា នែសម្លាញ់ អ្នកចូរវៀរចាកបាណាតិបាត អ្នកកុំគប្បីបាននូវវត្ថុដែលមិនមែនជា-ប្រយោជន៍ និងសេចក្ដីទុក្ខអស់កាលដ៏យូរអង្វែងឡើយ ។ គេមិនបានអើពើនូវឱវាទនោះឡើយ ។ លំដាប់នោះ ឧបាសកនោះ ទើបសូមអង្វរ ព្រះថេរៈដែលជាព្រះខីណាស្រព ដែលជាទីចម្រើនចិត្តនៃខ្លួនមួយរូបថា បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់សម្ដែងនូវ-ធម៌ដល់បុរសឈ្មោះឯណោះ ដោយប្រការដែលគេនឹងគប្បីវៀរចាក-

បាណាតិបាត ។

ក្រោយមកថ្ងៃមួយ ព្រះថេរៈនោះ ត្រាច់បិណ្ឌបាតក្នុងក្រុងរាជគ្រឹះ បានឈប់ឈរនៅត្រង់ទ្វារផ្ទះរបស់គេ ។ មាគវិកៈនោះឃើញលោកហើយ ក៏កើតនូវសេចក្តីគោរពកោតក្រែងជាខ្លាំង បានចេញមកទទួលនិមន្តឱ្យចូលទៅកាន់ផ្ទះ រួចហើយក៏បានតាក់តែងនូវអាសនៈប្រគេន ។ ព្រះថេរៈក៏បានគង់លើអាសនៈដែលគេបានតាក់តែងទុកហើយ ។ ចំណែកមាណពនោះ ក៏បានចូលទៅរកព្រះថេរៈ ( ថ្វាយបង្គំ ) ហើយអង្គុយក្នុងទីដ៏សមគួរ ។ ព្រះថេរៈប្រកាសនូវទោសក្នុងបាណាតិបាត និងអានិសង្សក្នុងការវៀរចាកបាណាតិបាតនោះដល់គេ ។ គេសូម្បីបានស្តាប់ដូច្នោះហើយ ក៏មិនប្រាថ្នានឹងវៀរចាកបាណាតិបាតនោះឡើយ ។ លំដាប់នោះ ព្រះថេរៈទើបពោលនឹងគេថា នែអ្នក បើអ្នកមិនអាចនឹងវៀរចាកដោយប្រការទាំងពួងបានសោត ជាដំបូងអ្នកចូរវៀរចាកក្នុងវេលាយប់ចុះ ។ គេទទួលពាក្យហើយពោលថា នឹងវៀរចាកក្នុងវេលាយប់ ហើយទើបវៀរចាកនូវបាណាតិបាតនោះ ។ ពាក្យដ៏សេស ដូចគ្នានឹងរឿងដែលជាប់គ្នានោះឯង ។ ក៏ក្នុងបណ្តាគាថា ព្រះនារទត្ថេរ បានសួរគេដោយគាថា ៣ គាថាថា :

*អ្នកត្រេកអរលើបល្ល័ង្ក ដែលក្រាលដោយសំពត់គោណកៈ*

*ប្រាសាទ ដែលជាផ្ទះកំពូល គេប្រគំហើយ ដោយតូរ្យតន្ត្រីប្រកប-ដោយអង្គ ៥ ។ កាលជិតព្រះអាទិត្យរះឡើង ក្នុងទីបំផុតនៃរាត្រីនោះ អ្នកត្រូវគេបោះបង់ចោលក្នុងព្រៃស្មសាន ដល់នូវសេចក្ដីទុក្ខច្រើន ។ អំពើអាក្រក់ ដូចម្ដេច ដែលអ្នកបានធ្វើហើយ ដោយកាយ វាចា ចិត្ត អ្នកដល់នូវសេចក្ដីទុក្ខនេះ តើដោយផលនៃកម្ម ដូចម្ដេច ។*

លំដាប់នោះ ប្រេតទើបប្រាប់នូវសេចក្ដីនោះដល់លោកដោយគាថាថា :

*កាលពីដើម ខ្ញុំជាព្រានម្រឹគ ជាអ្នកអាក្រក់ មិនសង្រួម នៅក្នុងក្រុងរាជគ្រឹះ មានភ្នំដូចជាក្រោល គួរត្រេកអរីករាយ ។ សម្លាញ់របស់ខ្ញុំនោះ អ្នកមានហឫទ័យល្អ ជាឧបាសកមានសទ្ធា មានភិក្ខុមួយអង្គជាជីតុន(១) របស់សម្លាញ់ខ្ញុំនោះជាសាវ័ក របស់-ព្រះគោតម ។ ភិក្ខុនោះ អនុគ្រោះ បានឃាត់ខ្ញុំរឿយ ៗ ថា អ្នកកុំធ្វើអំពើអាក្រក់ឡើយ នែអ្នកកុំទៅកាន់ទុគ្គតិឡើយ បើអ្នកប្រាថ្នាសេចក្ដីសុខក្នុងបរលោក អ្នកចូរវៀរបង់នូវការមិនសង្រួម គឺការសម្លាប់សត្វ ។ ខ្ញុំបានស្ដាប់ពាក្យរបស់ភិក្ខុនោះ លោកប្រាថ្នាសេចក្ដីសុខ អនុគ្រោះដោយប្រយោជន៍ តែខ្ញុំជាអ្នកត្រេកអរក្នុងបាបយូរយារមិនមានប្រាជ្ញា មិនបានធ្វើតាមពាក្យប្រៀនប្រដៅ (របស់លោក) ទាំងអស់ ។ ភិក្ខុនោះ លោកមានប្រាជ្ញាល្អ ស្មើដោយផែនដី*

*បានកម្កល់ខ្ញុំក្នុងសេចក្ដីសង្រួមទៀត ដោយសេចក្ដីអនុគ្រោះថា បើអ្នកសម្លាប់ពួកសត្វក្នុងវេលាថ្ងៃ ត្រូវអ្នកសង្រួមក្នុងវេលាយប់ចុះ ។ ខ្ញុំនោះ សម្លាប់ពួកសត្វតែក្នុងវេលាថ្ងៃ ជាអ្នកសង្រួម វៀរចាកការសម្លាប់សត្វក្នុងវេលាយប់ ខ្ញុំរក្សាខ្លួនបានតែក្នុងវេលាយប់ វេលាថ្ងៃទៅកាន់ទុគ្គតិ ( ឆ្កែទាំងឡាយ ) ខាំស៊ី ។ ខ្ញុំសោយសម្បត្តិទិព្វ ( ដោយអំណាច ) នៃកុសលកម្មនោះ ក្នុងវេលាយប់ វេលាថ្ងៃពួកឆ្កែមានចិត្តខ្នាញ់ ស្ទុះមកចោមខាំដោយជុំវិញ ពួកសត្វណាមានការប្រកបរឿយ ៗ ប្រកបជានិច្ច ក្នុងសាសនារបស់ព្រះសុគត ខ្ញុំសំគាល់ថា ពួកសត្វនោះ តែងបាននូវព្រះនិព្វានឈ្មោះអមតៈ ជាធម្មជាតសុទ្ធ គឺមិនលាយឡំដោយលោកិយសុខ ជាបទមិនមានបច្ច័យប្រជុំតាក់តែងបានឡើយ ។*

សេចក្ដីនៃគាថានោះ មានន័យដូចបានពោលរួចមកហើយក្នុងខាងដើមនោះឯង ។

## ( ចប់រឿងទុតិយមិគលុទ្ទប្រេតទី ៨ )

# ៩. រឿងក្ដីវិនិច្ឆ័យក្តីប្រេត

" ប្រេតខ្វារសាច់ខ្នងរបស់ខ្លួនឯងស៊ី "

( បិដកលេខ ៥៦, ទំព័រ ៨៦ និងអដ្ឋកថា )

កាលព្រះសាស្ដា គង់ប្រថាប់នៅក្នុងវត្តវេឡុវ័នមហាវិហារ ទ្រង់ប្រារព្ធប្រេតជាអ្នកវិនិច្ឆ័យក្ដីកោង ទើបត្រាស់នូវពាក្យផ្ដើមថា **មាលី កិរិដី កាយូរី** ដូច្នេះ ។

ក្នុងកាលនោះ ព្រះបាទពិម្ពិសារ ទ្រង់ចូលចាំ**ឧបោសថមួយ-ខែ ៦ ថ្ងៃ** មនុស្សជាច្រើនបានបដិបត្តិតាមទ្រង់ ទើបនាំគ្នាចូលចាំឧបោសថ ។ ព្រះរាជាត្រាស់ថា ពួកមនុស្សដែលមកកាន់សម្នាក់របស់ព្រះអង្គថា ពួកអ្នកចូលចាំឧបោសថឬ ឬថាមិនចូលចាំទេ ? ក្នុងបណ្ដាមនុស្សទាំងនោះ អ្នកវិនិច្ឆ័យក្ដីម្នាក់ ជាអ្នកមានវាចាញុះញង់ ជាអ្នកបោកប្រាស់ ជាអ្នកទទួលយកសំណូក មិនអាចអត់ទ្រាំដើម្បីនឹងពោលថា ទូលព្រះបង្គំ មិនបានចូលចាំឧបោសថទេ តែក្រាបទូលថា ទូលព្រះបង្គំចូលចាំឧបោសថ ថ្ងៃវិសេស ។ លំដាប់នោះ សម្លាញ់ទើបពោលនឹងគាត់ ដែលចេញអំពីទីជិតនៃព្រះរាជាថា សម្លាញ់ថ្ងៃនេះអ្នកចូលចាំឧបោសថឬ ? គាត់តបថា សម្លាញ់អើយ ព្រោះសេចក្ដី-

ខ្លាច ខ្ញុំទើបក្រាបទូលយ៉ាងនោះ ចំពោះព្រះភក្ត្រព្រះរាជា ប៉ុន្តែខ្ញុំមិនបានចូលចាំឧបោសថឡើយ ។

លំដាប់នោះ សម្លាញ់ទើបពោលនឹងគាត់ថា បើដូច្នោះជាដំបូង អ្នកចូររក្សាឧបោសថ កន្លះថ្ងៃ ក្នុងថ្ងៃនេះ អ្នកចូរសមាទានអង្គឧបោសថចុះ ។ គាត់ទទួលពាក្យរបស់សម្លាញ់នោះហើយក៏បានទៅកាន់ផ្ទះវិញ មិនបរិភោគឡើយ ខ្ពុរមាត់ហើយក៏បានអធិដ្ឋានឧបោសថ ចូលចាំក្នុងវេលាយប់ ត្រូវសេចក្ដីចុកសៀតដែលមានកម្លាំងខ្យល់ ហេតុដែលកើតឡើងបណ្ដាលមកពីពោះទំនេរ ចូលទៅកាត់ផ្ដាច់នូវអាយុសង្ខារ បន្ទាប់ពីចុតិក៏បានទៅកើតជា**វេមានិកប្រេត**នៅត្រង់ផ្ទៃភ្នំ ។ មែនពិត គេបានវិមានដែលមាន**ស្រីទេពអប្សរ ១០.០០០ នាក់** ជាបរិវារ និងទិព្វសម្បត្តិជាច្រើន ដោយហេតុគ្រាន់តែការរក្សានូវឧបោសថ ត្រឹមតែមួយរាត្រី ( ប៉ុណ្ណោះ ) ។ ប៉ុន្តែព្រោះខ្លួនជាអ្នកវិនិច្ឆ័យក្ដីកោង និងនិយាយពាក្យញុះញង់ ខ្លួនឯងទើបខ្វារសាច់ខ្នងរបស់ខ្លួនឯងស៊ី ។ **ព្រះនារទៈ** ចុះពីភ្នំគិជ្ឈកូដ បានឃើញគេហើយ ទើបសួរដោយគាថា ៤ គាថាថា :

*អ្នកពាក់នូវកម្រងផ្កា ជូតក្បាល ពាក់សង្វារ ខ្លួនរបស់អ្នកប្រស់ព្រំ ដោយខ្លឹមចន្ទន៍ អ្នកមានសម្បុរមុខថ្លា ល្អដូចជាសម្បុរនៃព្រះអាទិត្យ ។ បរិវារទាំងឡាយរបស់អ្នក ដែលរាប់បញ្ចូលក្នុង-*

*បរិស័ទ មិនមែនជាមនុស្ស គឺនាងកញ្ញាមួយម៉ឺន ជាស្រីបម្រើរបស់អ្នក ។ នាងកញ្ញាទាំងនោះ ទ្រទ្រង់នូវសង្វារមាស ស្ថិតស្ពាងដោយសំពត់មាស អ្នកជាបុគ្គលមានអានុភាពច្រើន មានរូបអាចញ៉ាំងពួកជនអ្នកមើលឱ្យព្រឺរោម ។ អ្នកខ្វារសាច់ខ្នងរបស់ខ្លួន ស៊ីដោយខ្លួនឯង តើអំពើអាក្រក់ដូចម្តេច ដែលអ្នកបានធ្វើដោយកាយវាចា ចិត្ត អ្នកខ្វារសាច់ខ្នងខ្លួនស៊ីដោយខ្លួនឯង តើដោយផលនៃកម្មដូចម្តេច ។*

ប្រេតនោះបានឆ្លើយថា ៖

*ខ្ញុំបានប្រព្រឹត្ត ដើម្បីសេចក្តីវិនាសខ្លួន ដោយការញុះញង់និងមុសាវាទផង ដោយការបន្លំ នឹងបោកប្រាស់ផង ក្នុងជីវលោក ។ ខ្ញុំបានទៅកាន់បរិស័ទ មិនធ្វើនូវហេតុមានប្រយោជន៍ ក្នុងកាលពិតដែលតាំងឡើងប្រាកដ បែរជាប្រព្រឹត្តតាមនូវហេតុ ដែលមិនមានប្រយោជន៍វិញ ក្នុងជីវលោកនោះ ។ ប្រេតណា ស៊ីសាច់ខ្នងប្រេតនោះឈ្មោះថាស៊ីខ្លួនឯង ដូចជាខ្ញុំស៊ីសាច់ខ្នងរបស់ខ្លួន ក្នុងថ្ងៃនេះដែរ ។*

**តយិទំ តយា នារទ សាមំ ទិដ្ឋំ**
**អនុកម្បកា យេ កុសលា វទេយ្យុំ**
**មា បេសុណំ មា ច មុសា ភណិ**

## **មា ខោសិ មិដ្ឋិមំសិកោ ត្តុទំ ២**

*បពិត្រព្រះនារទ: រឿងនេះ លោកម្ចាស់ បានឃើញដោយព្រះអង្គឯងស្រាប់ហើយ ជនទាំងឡាយណា ជាអ្នកអនុគ្រោះ ជនទាំងនោះ ជាអ្នកឈ្លាសវៃ គប្បីពោលថា អ្នកកុំនិយាយពាក្យញុះញង់ផង កុំនិយាយពាក្យកុហកផង អ្នកកុំស៊ីនូវសាច់ខ្នងឡើយ ។*

ចំណែកប្រេតនោះ បានឆ្លើយនូវសេចក្តីនោះ ដោយគាថា ៣ គាថា ចំពោះព្រះនារទត្ថេរនោះហើយ ។

បណ្តាបទទាំងនោះ បទថា **មាលី** បានដល់ អ្នកពាក់នូវកម្រងផ្កា, អធិប្បាយថា អ្នកប្រដាប់ដោយកម្រងផ្កាទិព្វ ។ បទថា **កិរីដី** ប្រែថា អ្នកពាក់នូវមកុដ ។ បទថា **កាយូរី** ប្រែថា អ្នកពាក់នូវ-កងមាស, អធិប្បាយថា អ្នកប្រដាប់ដោយគ្រឿងប្រដាប់ដៃ ។ បទថា **គត្តា** ប្រែថា អវយវៈ គឺ សរីរៈ ។ បទថា **ចន្ទនុស្សទា** ប្រែថា អ្នកប្រោះព្រំដោយលំអិតខ្លឹមចន្ទន៍ ។ បទថា **សុរិយវណ្ណោវ សោភសិ** សេចក្តីថា អ្នកជាអ្នកមានសម្បុរមុខស្រស់ថ្លា ដូចព្រះ-សុរិយោទ័យ បញ្ចេញរស្មីដ៏ស្រទន់ ។ បាលីថា **អរុណវណ្ណី បភាសតិ** ដូច្នេះ ក៏មាន ។ បទថា **អរុណំ** សេចក្តីថា មានសម្បុរស្មើនឹងទេវតាដែលមិនមានភាពសៅហ្មង គឺ ជាដែនដ៏ប្រសើរ ។

បទថា **បរិសដ្ឋា** ប្រែថា អ្នករាប់បញ្ចូលក្នុងបរិស័ទ,

អធិប្បាយថា អ្នកឧបដ្ឋាក ។ បទថា **តុវំ** ប្រែថា អ្នក ។ បទថា **លោមហំសនរូបវា** បានដល់ អ្នកប្រកបដោយរូប ដែលនាំឱ្យកើតការព្រឺរោមដល់អ្នកដែលបានឃើញ ។ មែនពិត ពាក្យថា **លោមហំសនរូបវា** នេះ លោកពោលទុក ព្រោះភាវៈជាអ្នកបរិបូណ៌ដោយភាពជាអ្នកមានអានុភាពច្រើន ។ បទថា **ឧក្កច្ច** ប្រែថា កាត់, អធិប្បាយថា អារ ។

បទថា **អចារិសំ** ( បិដកថា **អចារិស្សំ** ) ប្រែថា បានត្រាច់ទៅហើយ គឺ បានប្រព្រឹត្តទៅហើយ ។ បទថា **បេសុញ្ញមុសាវាទេន** ប្រែថា ដោយភាពជាអ្នកនិយាយញុះញង់ និងពោលពាក្យកុហក ។ បទថា **និកតិវញ្ចនាយ ច** បានដល់ ដោយការបន្លំនិងបោកប្រាស់ គឺ ដោយការបោកប្រាស់ ដោយធ្វើឱ្យប្លែកដល់ពួកជនដទៃ ដោយសម្ដែងនូវរបស់មិនពិត ។

បទថា **សច្ចកាលេ** គឺ ក្នុងកាលដ៏សមគួរដើម្បីនឹងពោលនូវពាក្យពិត ។ បទថា **អត្ថំ** បានដល់ ប្រយោជន៍ មានប្រយោជន៍ក្នុងបច្ចុប្បន្នជាដើម ។ បទថា **ធម្មំ** បានដល់ ហេតុ គឺ វត្ថុដែលគួរ ។ បទថា **និរាកត្វា** បានដល់ ចោល គឺ លះបង់ចោល ។ បទថា **សោ** បានដល់ សត្វអ្នកប្រព្រឹត្តនូវវចីទុច្ចរិត មានការនិយាយញុះញង់ជាដើម ។ ពាក្យដ៏សេសទាំងអស់ មានន័យដូចបានពោល

រួចមកហើយនោះឯង

# ( ចប់រឿងកុដវិនិច្ឆយកប្រេតទី ៩ )

**អភិត្ថរេថ កល្យាណេ បាបា ចិត្តំ និវារយេ**
**ទន្ធំ ហិ ករតោ បុញ្ញំ បាបស្មឹ រមតី មនោ ។**

បុគ្គលគួរប្រញាប់ប្រញាល់ធ្វើអំពើល្អ គួរឃាត់ចិត្តចាកបាប ព្រោះថា កាលបើបុគ្គលធ្វើបុណ្យយឺតយូរ ចិត្តរមែងត្រេកអរក្នុងបាប ។

( បិដកលេខ ៥២ ទំព័រ ៤៦ )

# ១០~រឿងធាតុវិវណ្ណប្រេត

" ប្រេតត្រូវនិរយបាលស្រោចទឹកដ៏ផ្សានិងវះមាត់ "

" ព្រោះតិះដៀលព្រះធាតុ "

( បិដកលេខ ៥៦, ទំព័រ ៨៨ និងអដ្ឋកថា )

រឿងនៃប្រេតដែលតិះដៀលព្រះធាតុនេះ មានពាក្យផ្ដើមថា **អន្តលិក្ខស្មឹ តិដ្ឋន្តោ** ដូច្នេះ ។

កាលព្រះដ៏មានព្រះភាគជាម្ចាស់ស្ដេចបរិនិព្វាន ( ទៅហើយ ) ក្នុងចន្លោះដើមសាលព្រឹក្សទាំងគូ នៅនា សាលវ័នឧទ្យាននៃ-មល្លក្សត្រ ដែលជាទីចូលទៅក្នុងក្រុងកុសិនារា និងជាទីបែងចែកព្រះធាតុ ។ ព្រះបាទអជាតសត្តុ ទ្រង់កាន់យកនូវចំណែកព្រះធាតុដែលព្រះអង្គបាន ទ្រង់រលឹកដល់ព្រះពុទ្ធគុណ **៧ ឆ្នាំ ៧ ខែ ៧ ថ្ងៃ** ហើយបានញ៉ាំងឱ្យការបូជាដ៏ឱឡារិក ប្រព្រឹត្តទៅ ។

ពួកមនុស្សក្នុងទីនោះ រាប់មិនបានប្រមាណមិនអស់ នាំគ្នាធ្វើចិត្តឱ្យជ្រះថ្លា ហើយក៏បានទៅកើតក្នុងឋានសួគ៌ ។ ក៏បុរសប្រមាណ **៨៦.០០០ នាក់** ក្នុងទីនោះ មានចិត្តវិបល្លាស ព្រោះភាពជាអ្នកមិនមានសទ្ធា និងព្រោះសេចក្ដីយល់ឃើញខុស ដែលខ្លួនបានសន្សំ

មកអស់កាលដ៏យូរ ក៏បានប្រទូសរ៉ាយចិត្តរបស់ខ្លួន សូម្បីក្នុងឋានៈដែលជាទីតាំងនៃសេចក្តីជ្រះថ្លា ហើយក៏បានទៅកើតក្នុងកំណើតប្រេត ។ ភរិយា ធីតា កូនប្រសាស្រីរបស់កុដុម្ពិកៈ ជាអ្នកបរិបូណ៌ដោយសម្បត្តិម្នាក់ ក្នុងក្រុងរាជគ្រឹះនោះ មានចិត្តជ្រះថ្លា នាំគ្នាគិតថានឹងបូជាព្រះធាតុ ទើបកាន់យកនូវសក្ការៈ មានគ្រឿងក្រអូប និងកម្រងផ្កាជាដើម ចាប់ផ្តើមទៅកាន់ទីបញ្ចុះព្រះធាតុ ។ កុដុម្ពិកៈនោះគិតថា នឹងមានប្រយោជន៍អ្វីដោយការបូជាឆ្អឹង ទើបប្រមាថព្រះធាតុទាំងនោះ តិះដៀលនូវការបូជាព្រះធាតុ ។ ស្ត្រីទាំងនោះ មិនជឿនូវពាក្យរបស់កុដុម្ពិកៈនោះឡើយ ក៏បាននាំគ្នាទៅក្នុងទីនោះ ធ្វើនូវការបូជាព្រះធាតុរួចហើយ ក៏បានត្រឡប់មកកាន់ផ្ទះវិញ ត្រូវរោគដូច្នោះបៀតបៀន មិនយូរប៉ុន្មានក៏ធ្វើកាលកិរិយាទៅ ហើយក៏បានទៅកើតក្នុងទេវលោក ។ ចំណែកកុដុម្ពិកៈនោះ ត្រូវសេចក្តីក្រោធគ្របសង្កត់ មិនយូរប៉ុន្មានក៏ធ្វើកាលកិរិយាទៅ ហើយក៏បានទៅកើតក្នុងកំណើតប្រេត ព្រោះបាបកម្មនោះ ។

ក្រោយមកថ្ងៃមួយ ព្រះមហាកស្សបៈ តាក់តែងឥទ្ធាភិសង្ខារដោយប្រការដែលពួកមនុស្សឃើញនូវប្រេតទាំងនោះ និងទេវតាទាំងនោះ លុះធ្វើយ៉ាងនោះហើយ ក៏បានឈរនៅត្រង់ទីលាននៃព្រះចេតិយ ហើយក៏បានសួរនូវប្រេតដែលតិះដៀលព្រះធាតុនោះ

ដោយគាថា ៣ គាថា ប្រេតនោះបានព្យាករដល់លោកហើយ ។

**ព្រះថេរៈសួរថា :**

*អ្នកឋិតនៅឰដ៏អាកាស មានក្លិនអាក្រក់ ស្អុយផ្សាយទៅផង ពួកដង្កូវរុកស៊ីមាត់ របស់អ្នក ដែលមានក្លិនស្អុយផង តើអ្នកបានធ្វើអំពើដូចម្តេច ក្នុងកាលមុន ។ ព្រោះតែផ្សាយក្លិនអាក្រក់ និងមាត់ដែលមានដង្កូវរុកស៊ីនោះ ( បានជាពួកសត្វដែលកម្មដាស់តឿន ) កាន់គ្រឿងសស្ត្រាមកវះ ( មាត់អ្នក ) រឿយ ៗ ហើយស្រោចដោយទឹកខារ ( ទឹកក្រូត ) រួចវះញយ ៗ ថែមទៀត ។ អំពើអាក្រក់ដូចម្តេច ដែលអ្នកបានធ្វើដោយកាយ វាចា ចិត្ត អ្នករងទុក្ខនេះ តើដោយផលនៃកម្ម ដូចម្តេច ។*

**ប្រេតនោះឆ្លើយថា :**

*បពិត្រលោក អ្នកនិរទុក្ខ ខ្ញុំជាឥស្សរៈលើទ្រព្យនិងធញ្ញជាតិ ដ៏ច្រើនក្រៃលែង ( នៅ ) ក្នុងក្រុងរាជគ្រឹះ មានភ្នំដូចជាក្រោល គួរត្រេកអររីករាយ ។ ( កាលពីជាតិមុន ) ស្រីនេះជាប្រពន្ធរបស់ខ្ញុំផង ស្រីនេះជាធីតារបស់ខ្ញុំផង ស្រីនេះជាកូនប្រសាររបស់ខ្ញុំផង ខ្ញុំបានឃាត់ ( ស្រីនោះ ) ដែលនាំផ្កាពុំសែន ផ្កាឧប្បល និងគ្រឿងលាបមានតម្លៃ ទៅកាន់ព្រះស្តូប បាបនោះឯង ដែលខ្ញុំបានធ្វើហើយ ។ ពួកយើងចំនួន ៨៦.០០០ នាក់ រងទុក្ខវេទនាចំពោះខ្លួន ៗ ឆេះនៅ*

*ក្នុងនរកយ៉ាងខ្លាំង ព្រោះតិះដៀល នូវការបូជាចំពោះព្រះស្តូប ពួកជនណាប្រកាសនូវទោសក្នុងការបូជា ចំពោះព្រះអរហន្តសម្មា-សម្ពុទ្ធ ដែលប្រព្រឹត្តទៅដោយការបូជានូវព្រះស្តូប ( ដូចជាខ្ញុំ ) សូមលោកម្ចាស់ញុំាងពួកជននោះ កុំឱ្យងាកចេញចាកបុណ្យនោះឡើយ សូមលោកម្ចាស់មើលពួកស្រីទាំងនេះ ដែលទ្រទ្រង់កម្រងផ្កាមានខ្លួនប្រដាប់ហើយ កំពុងមកតាមអាកាសផង ។ ពួកស្រីទាំងនោះបានសម្រេច ( សម្បត្តិទិព្វ ) មានយសបរិវារ កំពុងសោយផលនៃការបូជាដោយកម្រងផ្កា សេចក្តីព្រីរោមក៏កើតឡើង ព្រោះឃើញហេតុជាអស្ចារ្យចំឡែកនោះ ។*

**នមោ ករោន្តិ សប្បញ្ញា វទន្តិ តំ មហាមុនឹ**
**សោហំ នូន ឥតោ គន្ត្វា យោនឹ លទ្ធាន មានុសឹ**
**ថូបបូជំ ករិស្សាមិ អប្បមត្តោ បុនប្បុនំ ។**

*ពួកអ្នកមានប្រាជ្ញា តែងធ្វើនមស្ការថ្វាយបង្គំសរសើរព្រះ-មហាមុនីនោះ ខ្ញុំនោះ លុះទៅអំពីបេតលោកនេះ ហើយបាននូវកំណើតជាមនុស្ស ជាអ្នកលែងធ្វេសប្រហែស នឹងធ្វើការបូជាចំពោះព្រះស្តូបរឿយ ៗ ដោយពិត ។*

បណ្តាបទទាំងនោះ **បទថា ទុគ្គន្ធោ** បានដល់ អ្នកមានក្លិនមិនគួរឱ្យប្រាថ្នា, អធិប្បាយថា មានក្លិនដូចក្លិនសាកសព ។ ព្រោះ-

ហេតុនោះ លោកទើបពោលថា មានក្លិនស្អុយផ្សាយទៅ ។ បទថា **តតោ** សេចក្តីថា ក្រៅពីក្លិនស្អុយផ្សាយទៅ និងត្រូវពួកដង្កូវនាំគ្នារុកស៊ី ។ បទថា **សត្ថំ គហេត្វាន ឱក្កន្តន្តិ បុនប្បុនំ** សេចក្តីថា សត្វទាំងឡាយត្រូវកម្មដាស់តឿន ទើបយកសស្ត្រាដ៏មុត វះមុខរបួសនោះរឿយ ៗ ។ បទថា **ខារេន បរិប្ផោសិត្វា** សេចក្តីថា ត្រូវស្រោចដោយទឹកដ៏ផ្សាក្នុងទីដែលត្រូវវះហើយបណ្តើរអាសាច់បណ្តើរ ។

បទថា **ឥស្សរោ ធនធញ្ញស្ស សុបហូតស្ស** សេចក្តីថា ជាធំគឺជាម្ចាស់របស់ទ្រព្យ និងធញ្ញាហារដ៏ច្រើនក្រៃលែង, អធិប្បាយថា ជាអ្នកស្តុកស្តម្ភមានទ្រព្យច្រើន ។

បទថា **តស្សាយំ មេ ភរិយា ច ធីតា ច សុណិសា ច** សេចក្តីថា ក្នុងអត្តភាពមុន អ្នកនេះជាភរិយា ជាធីតា ជាកូនប្រសាស្រីរបស់ខ្ញុំនោះ ។ ប្រេតពោលបង្ហាញថា ស្ត្រីទាំងនោះ ជាទេវតាឋិតនៅឰដ៏អាកាស ។ បទថា **បច្ចគ្ឃញ្ច** ប្រែថា ថ្មី ។ បទថា **ថូបំ ហរន្តិយោ វារេសឹ** សេចក្តីថា ខ្ញុំតិះដៀលព្រះធាតុហាមឃាត់ស្ត្រីទាំងនោះ ដែលបង្អោនចូលទៅដើម្បីបូជាព្រះស្តូប ។ ដោយពាក្យថា **តំ បាបំ បកតំ មយា** នេះ ប្រេតដល់នូវសេចក្តីក្តៅក្រហាយពោលថា អំពើអាក្រក់ក្នុងការតិះដៀលព្រះធាតុនោះ ខ្ញុំបានធ្វើ គឺប្រព្រឹត្តជារឿយ ៗ ។

បទថា **ឆឡាសីតិសហស្សានិ** បានដល់ ប្រមាណ ៨៦.០០០ នាក់ ។ ប្រេតពោលរួមនូវប្រេតទាំងនោះនិងខ្លួនថា **មយំ** ប្រែថា ពួកយើង ។ បទថា **បច្ចត្តវេទនា** បានដល់ ទុក្ខវេទនាដែលកំពុងគ្របសង្កត់ចំពោះខ្លួន ៗ ។ ដោយបទថា **និរយេ** ប្រេតពោលនូវ-បេតវិស័យ ឱ្យដូចគ្នានឹងនរក ព្រោះមានទុក្ខធ្ងន់ ។

បទថា **យេ ច ខោ ថូបបូជាយ វត្តន្តេ អរហតោ មហេ** សេចក្តីថា កាលការឆ្លង ការបូជា ឧទ្ទិសចំពោះព្រះស្តូបរបស់ព្រះអរហន្តសម្មាសម្ពុទ្ធជាម្ចាស់កំពុងប្រព្រឹត្តទៅ ពួកជនណាប្រកាសនូវ**អាទីនវ** គឺ ទោស ក្នុងការបូជានូវព្រះស្តូបដូចជាខ្ញុំ លោកម្ចាស់ទាំងឡាយ គប្បីញាំងនូវបុគ្គលទាំងនោះកុំឱ្យងាកចេញចាកបុណ្យនោះឡើយ ។ ប្រេតប្រកាសនូវភាពដែលខ្លួនជាអ្នកវិនាសធំ ដោយអាងអ្នកដទៃថា គប្បីញាំងបុគ្គលដែលនៅឆ្ងាយពីបុណ្យឱ្យកើតឡើង។

បទថា **អាយន្តិយោ** ប្រែថា អ្នកមកតាមអាកាស ។ បទថា **មាលាវិបាកំ** បានដល់ វិបាក គឺផលនៃការបូជាដោយកម្រងផ្កាដែលបានធ្វើទុកក្នុងព្រះស្តូប ។ បទថា **សមិទ្ធា** បានដល់ សម្រេចដោយទិព្វសម្បត្តិ ។ បទថា **តា យសស្សិនោ** (បិដកថា **តា យសស្សិយោ**) ស្ត្រីទាំងនោះមានបរិវារ ។

បទថា **តញ្ច ទិស្វាន** សេចក្តីថា ឃើញផលវិសេសដ៏ប្រសើរ

ក្រៃលែង ដែលគួរឱ្យអស្ចារ្យមិនធ្លាប់មាន ឱ្យកើតនូវការព្រឺរោមព្រឺ-ស្បែក របស់បុណ្យដែលកើតអំពីការបូជាដ៏តិចតួចនោះ ។ បទថា **នមោ ករោន្តិ សប្បញ្ញា វទន្តិ តំ មហាមុនឹ** សេចក្តីថា បពិត្រព្រះកស្សបៈដ៏ចម្រើន ស្ត្រីទាំងនេះ រមែងថ្វាយបង្គំ រមែងអភិវាទ, អធិប្បាយថា ធ្វើនូវការគោរពឱនលំទោន និងធ្វើនូវការនមស្ការចំពោះលោកអ្នកជាបុញ្ញក្ខេត្តដ៏ប្រសើរខ្ពង់ខ្ពស់ ។

លំដាប់នោះ ប្រេតនោះមានចិត្តសង្វេគ កាលនឹងសម្តែងនូវកម្មដែលខ្លួនគប្បីធ្វើតទៅ ដែលគួរដល់សេចក្តីសង្វេគ ទើបពោលនូវគាថាថា **សោហំ នូន** ដូច្នេះជាដើម ពាក្យនោះ មានអត្ថងាយយល់ទាំងអស់ ។

ព្រះមហាកស្សបៈ លុះបានស្តាប់នូវពាក្យដែលប្រេតពោលយ៉ាងនេះហើយ ទើបធ្វើនូវរឿងនោះឱ្យជាអត្ថុប្បត្តិហេតុ សម្តែងធម៌ដល់បរិស័ទដែលបានមកជួបជុំគ្នាហើយ ។

## ( ចប់រឿងធាតុវិវណ្ណប្រេតទី ១០ )

# ឧទ្ទាន

និយាយអំពីរឿងអភិជ្ឍមានប្រេត ១ រឿងសានុវាសិប្រេត ១ រឿងរថការីប្រេត ១ រឿងភុសប្រេត ១ រឿងកុមារប្រេត ១ រឿងសេរិនីប្រេត ១ រឿងមិគលុទ្ទប្រេត ២ លើក រឿងកូដវិនិច្ឆយក-ប្រេតដែលស៊ីសាច់ខ្នងរបស់ខ្លួន ១ រឿងធាតុវិវណ្ណប្រេតឃាត់ការបូជា ១ ព្រោះហេតុនោះទើបចាត់ជាវគ្គ ។

## ( ចប់ចូឡវគ្គទី ៣ )

# មហាវគ្គទី ៤

## ១-រឿងអម្ពសក្ខរប្រេត

" ប្រេតត្រូវគេដោតនៅលើឈើអណ្ដាត "

( បិដកលេខ ៥៦, ទំព័រ ៩០ និងអដ្ឋកថា )

រឿងអម្ពសក្ខរប្រេតនេះ មានពាក្យផ្ដើមថា **វេសាលី នាម នគរត្ថិ វជ្ជីនំ** ដូច្នេះ ។ រឿងនោះកើតឡើងដូចម្ដេច ? កាលព្រះដ៏មានព្រះភាគ គង់ប្រថាប់នៅក្នុងវត្តជេតពនមហាវិហារ ស្ដេចលិច្ឆវីព្រះនាមថា **អម្ពសក្ខរៈ** ជាបុគ្គលមិច្ឆាទិដ្ឋិ ជា**នត្ថិកវាទៈ** គ្រងរាជក្នុងក្រុងវេសាលី ។

ក៏សម័យនោះ ក្នុងនគរវេសាលី មានភក់នៅក្នុងទីជិតរានផ្សារ របស់ពាណិជម្នាក់ ។ ជនជាច្រើនក្នុងទីនោះ លោតកន្លងលំបាក អ្នកខ្លះប្រឡាក់ភក់ ។ ពាណិជនោះឃើញដូច្នោះ ទើបគិតថា មនុស្សទាំងនេះកុំជាន់ភក់ឡើយ ទើបឱ្យគេនាំយកលលាដ៏ក្បាលគោ ដែលមានចំណែកប្រៀបដូចជាពណ៌ស័ង្ខ ប្រាសចាកក្លិនស្អុយ មកដាក់ធ្វើជាស្ពាន ។ តាមប្រក្រតី គាត់ជាអ្នកមានសីល មិនមានសេចក្ដីខឹង-

ក្រោធ មានវាចាទន់ភ្លន់ និងពោលសរសើរដល់គុណតាមសេចក្ដីពិតរបស់បុគ្គលដទៃ ។

ថ្ងៃមួយ កាលសម្លាញ់របស់ខ្លួនងូតទឹក មិនបានក្រឡេកមើលដោយសេចក្ដីធ្វេសប្រហែស គាត់ទើបយកសំពត់ស្លៀកលាក់ដោយបំណងនឹងលេងសើច ធ្វើឱ្យគេលំបាកជាមុនសិនទើបឱ្យវិញ ។ ក៏ក្មួយរបស់គាត់បានលួចភណ្ឌៈអំពីផ្ទះរបស់អ្នកដទៃ ហើយយកមកទុកនៅហាងរបស់គាត់នោះឯង ។ ម្ចាស់របស់ភណ្ឌៈ កាលពិនិត្យមើល ទើបបង្ហាញក្មួយរបស់គាត់ និងខ្លួនរបស់គាត់ព្រមទាំងភណ្ឌៈដល់ព្រះរាជា ។ ព្រះរាជាទ្រង់បញ្ជាថា ពួកអ្នកចូរកាត់ក្បាលបុរសនេះ ចំណែកក្មួយរបស់គេ ចូរដោតលើឈើអណ្ដោត ។ ពួករាជបុរសក៏បានធ្វើដូច្នោះ ។ គាត់ធ្វើកាលកិរិយាហើយ ក៏បានទៅកើតក្នុងភុម្មទេវតា បាននូវសេះអាជានេយ្យដ៏ជាទិព្វ មានពណ៌ស មានល្បឿនលឿនរហ័សទាន់ចិត្ត ព្រោះយកក្បាលគោធ្វើជាស្ពាន និងព្រោះការពោលសរសើរគុណរបស់អ្នកមានគុណ ក្លិនទិព្វទើបផ្សាយចេញអំពីកាយរបស់គេ ប៉ុន្តែគេជាអ្នកអាក្រាតកាយ ព្រោះយកសំពត់សាដកលាក់ គេពិចារណាមើលនូវកម្មដែលខ្លួនបានធ្វើក្នុងកាលមុន ក៏បានឃើញក្មួយរបស់ខ្លួនត្រូវគេដោតលើឈើអណ្ដោតដោយទំនងនោះ ត្រូវសេចក្ដីករុណាដាស់តឿន ទើបឡើងជិះសេះ ដែលមានល្បឿន-

លឿនរហ័សទាន់ចិត្ត ក្នុងវេលាពាក់កណ្តាលអធ្រាត្រ ក៏បានទៅដល់ទីកន្លែងដែលក្អួយនោះត្រូវគេដោតលើឈើអណ្តោត ទើបឈរនៅក្នុងទីមិនឆ្ងាយ ពោលរាល់ ៧ ថ្ងៃថា " ***នែអ្នកដ៏ចម្រើន អ្នកចូររស់នៅចុះ ព្រោះការរស់នៅជាការប្រសើរ*** " ។

ក៏សម័យនោះ ព្រះបាទអម្ពសក្ខរៈទ្រង់គង់លើ-កដរីដ៏ប្រសើរ ប្រទក្សិណព្រះនគរ ទ្រង់បានឃើញស្ត្រីម្នាក់បើកបង្អួចក្នុងផ្ទះមួយដែលកំពុងមើលសម្បត្តិរបស់ព្រះរាជា ទ្រង់ក៏មានចិត្តប្រតិព័ទ្ធ ទើបឱ្យសញ្ញាដល់បុរសដែលអង្គុយនៅក្រោយអាសនៈថា អ្នកចូរពិនិត្យមើលផ្ទះនេះ និងស្ត្រីនេះ ដូច្នេះហើយ ទ្រង់ក៏បានយាងចូលព្រះរាជនិ-វេសន៍របស់ព្រះអង្គវិញដោយលំដាប់ ទ្រង់បានបញ្ជូនបុរសនោះទៅដោយឱ្យដឹងថា អ្នកទៅចុះ អ្នកចូរដឹងថា ស្ត្រីនោះមានស្វាមីឬអត់ ។ គេក៏បានទៅ ដឹងថាស្ត្រីនោះមានស្វាមីហើយ ទើបក្រាបទូលដល់ព្រះរាជា ។ ព្រះរាជាកាលទ្រង់គិតដល់ឧបាយដើម្បីនឹងគ្រប់គ្រងនូវស្ត្រីនោះ ទើបបញ្ជាឱ្យហៅស្វាមីរបស់នាងមក ហើយត្រាស់ថា មកចុះ អ្នកចូរឧបដ្ឋាកយើង ។ គេសូម្បីមិនប្រាថ្នាក៏ទទួលដើម្បី-ឧបដ្ឋាកព្រះរាជា ព្រោះខ្លាចថា កាលបើយើងមិនធ្វើតាមព្រះតម្រាស់របស់ព្រះអង្គទេ ព្រះរាជាក៏នឹងដាក់នូវរាជទណ្ឌ ទើបបានទៅឧបដ្ឋាកព្រះរាជាជារៀងរាល់ថ្ងៃ ។ ចំណែកព្រះរាជា ក៏បានប្រទាននូវប្រាក់-

បំណាច់ដល់គេ ដោយកន្លងទៅ ២-៣ ថ្ងៃ ក៏បានត្រាស់នឹងគេ ដែលមកកាន់ទីឧបដ្ឋាកពីព្រឹកព្រលឹម យ៉ាងនេះថា អ្នកចូរទៅក្នុងទីឯណោះ មានស្រះបោក្ខរណីមួយ អ្នកចូរនាំដីពណ៌អរុណ និងផ្កាឧប្បលក្រហម អំពីស្រះបោក្ខរណីនោះមក ប្រសិនបើអ្នកមកមិនទាន់ក្នុងថ្ងៃនេះទេ ជីវិតរបស់អ្នកនឹងត្រូវអស់ ។ ក៏កាលគេទៅហើយ ទើបត្រាស់នឹងអ្នករក្សាទ្វារថា ថ្ងៃនេះ កាលព្រះអាទិត្យនៅមិនទាន់អស្តង្គត អ្នកចូរបិទទ្វារគ្រប់ទិស ។

ក៏ស្រះបោក្ខរណីនោះស្ថិតនៅចំងាយ ៣០០ យោជន៍ អំពី-ក្រុងវេសាលី ម្យ៉ាងទៀត បុរសនោះត្រូវមរណភ័យគ្របសង្កត់ ទើបទៅដល់ស្រះបោក្ខរណីនោះពីព្រឹកតែម្តង ព្រោះកម្លាំងលឿនរបស់ខ្យល់ ព្រោះបានស្តាប់មកពីមុនថា ស្រះបោក្ខរណីនោះ អមនុស្សហួងហែង ព្រោះសេចក្តីខ្លាច គេទើបដើរក្រវែលជុំវិញ ដោយគិតថាក្នុងទីនេះ តើនឹងមានអន្តរាយដែរឬទេហ្ន៎ ? អមនុស្សដែលរក្សាស្រះបោក្ខរណីឃើញគេហើយ កើតសេចក្តីអាណិត ក៏ក្លែងភេទជាមនុស្សចូលទៅរកហើយពោលថា បុរសដ៏ចម្រើន អ្នកមកទីនេះដើម្បីប្រយោជន៍អ្វី គេក៏បាននិយាយនូវរឿងនោះឱ្យអមនុស្សនោះស្តាប់ ។ អមនុស្សនោះទើបពោលថា កាលបើដូច្នោះ អ្នកចូរកាន់យកតាមសេចក្តីត្រូវការចុះ ដូច្នេះហើយ ទើបសម្តែងរូបទិព្វរបស់ខ្លួន

ហើយក៏បាត់ទៅ ។

គេបានកាន់យកដីពណ៌អរុណ និងផ្កាឧប្បលក្រហមក្នុងស្រះ-
-បោក្ខរណីនោះហើយ ក៏បានមកដល់ទ្វារព្រះនគរក្នុងកាលព្រះអាទិត្យនៅមិនទាន់អស្តង្គតនៅឡើយ ។ អ្នករក្សាទ្វារបានឃើញគេហើយកាលគេកំពុងស្រែកប្រាប់នោះឯង ក៏បានបិទទ្វារ ។ កាលបើទ្វារត្រូវបានគេបិទហើយ គេចូលទៅមិនបាន ឃើញបុរសដែលឋិតនៅលើឈើអណ្តោតជិតទ្វារ ទើបបានឱ្យធ្វើជាសាក្សីថា មនុស្សទាំងនេះកាលយើងមកដល់ក្នុងកាលព្រះអាទិត្យនៅមិនទាន់អស្តង្គត កំពុងស្រែកប្រាប់នោះឯង ក៏បានបិទទ្វារ ទោះបីអ្នកក៏ចូរដឹងចុះថា ខ្ញុំមកទាន់ពេល ខ្ញុំពុំមានទោសទេ ។ បុរសដែលឋិតនៅឈើអណ្តោតបានស្តាប់ដូច្នោះហើយទើបពោលថា ខ្ញុំត្រូវគេដោតដោយឈើអណ្តោត គេនឹងសម្លាប់ ឆ្ពោះមុខទៅរកសេចក្តីស្លាប់ និងធ្វើជាសាក្សីឱ្យអ្នកដូចម្តេចបាន ។ ក៏ក្នុងទីនេះ ប្រេតម្នាក់មានឫទ្ធិច្រើននឹងមកទីជិតខ្ញុំ អ្នកចូរញុំាងប្រេតនោះឱ្យធ្វើជាសាក្សីចុះ ។ បុរសនោះសួរថាខ្ញុំនឹងឃើញប្រេតដែលមានឫទ្ធិច្រើននោះ ដូចម្តេចបាន ? បុរសដែលឋិតនៅលើឈើអណ្តោតនោះពោលថា អ្នកចូររង់ចាំនៅទីនេះហើយ អ្នកនឹងឃើញដោយខ្លួនឯង ។ គេក៏បានឈរនៅក្នុងទីនោះឃើញប្រេតនោះមកក្នុងមជ្ឈិមយាម ទើបបានឱ្យធ្វើជាសាក្សី ។ លុះ-

ព្រឹកឡើង កាលព្រះរាជាត្រាស់ថា អ្នកប្រព្រឹត្តកន្លងអាជ្ញារបស់យើង ព្រោះដូច្នោះ យើងនឹងដាក់នូវ**រាជទណ្ឌ**ដល់អ្នក បុរសនោះទើបទូលថា បពិត្រព្រះសម្មតិទេព ខ្ញុំព្រះអង្គមិនបានប្រព្រឹត្តកន្លងអាជ្ញាព្រះ-អង្គទេ ខ្ញុំព្រះអង្គមកក្នុងទីនេះ ក្នុងកាលព្រះអាទិត្យនៅមិនទាន់អស្តង្គតនៅឡើយ ព្រះរាជាត្រាស់សួរថា ក្នុងរឿងនោះនរណាធ្វើជាសាក្សីឱ្យអ្នក ? បុរសនោះ ទើបអាងដល់ប្រេតអាក្រាត ដែលមកកាន់សម្នាក់របស់បុរសដែលត្រូវឈើអណ្តោតដោតនោះថា ជាសាក្សី កាលព្រះរាជាត្រាស់សួរថា រឿងនោះយើងនឹងជឿដូចម្តេចបាន ទើបទូលថា ថ្ងៃនេះ ក្នុងវេលារាត្រី ព្រះអង្គចូរបញ្ជូនបុរសដែលគួរជឿបានទៅជាមួយខ្ញុំព្រះអង្គ ។ ព្រះរាជាបានស្តាប់ដូច្នោះហើយ ទើបយាងទៅក្នុងទីនោះ មួយអន្លើដោយបុរសនោះដោយព្រះអង្គឯងហើយក៏បានប្រថាប់ឈរ កាលប្រេតមកក្នុងទីនោះពោលថា "***នៃអ្នកដ៏ចម្រើន អ្នកចូររស់នៅចុះ ព្រោះការរស់នៅជាការប្រសើរ***" ទើបទ្រង់សួរប្រេតនោះដោយគាថា ៥ គាថា ដោយន័យមានជាដើមថា ការដេក ការអង្គុយ មិនមានដល់បុគ្គលនេះ ដូច្នេះ ។ ក៏ចាប់តាំងពីនេះជាដើមទៅ ដើម្បីនឹងសម្តែងនូវសេចក្តីសម្ពន្ធនៃគាថាទាំងនោះ ព្រះសង្គីតិកាចារ្យ ទើបបានតាំងគាថាថា **វេសាលិ នាម នគរត្ថិ វជ្ជីនំ** សេចក្តីថា :

មាននគរ ១ ឈ្មោះវេសាលី របស់អ្នកដែនវជ្ជី ក្នុងក្រុង-វេសាលីនោះ មានស្ដេចលិច្ឆវី ព្រះនាមអម្ពសក្ខរៈ បានទតឃើញប្រេតនៅខាងក្រៅក្រុង ស្ដេចមានព្រះហឫទ័យចង់ដឹងហេតុ បានត្រាស់សួរប្រេតនោះ ក្នុងទីនោះឯងថា បុគ្គល ( ដែលគេចាក់ស្លួយ-ឡើង លើដែកអណ្ដោត ) នេះ ដេក ឬអង្គុយ ក៏មិនបាន ការឈានទៅមុខ និងការឈានថយក្រោយ ក៏មិនបាន ការស៊ីផឹក លិទ្ធភក្ស សំពត់ ភោគៈ ទាំងស្រីជាអ្នកបម្រើរបស់បុគ្គលនេះ ក៏មិនមានទៀត ។ ពួកជនណា ដែលជាញាតិសម្លាញ់ ដែលឃើញហើយ ឮហើយ ជាអ្នកមានចិត្តល្អអនុគ្រោះ នៃបុគ្គលណា ដែលមានក្នុងកាលពីដើម ឥឡូវនេះ ពួកញាតិជាដើមនោះ ក៏មិនបានឃើញបុគ្គលនោះដែរ ព្រោះខ្លួនឃ្លាតឆ្ងាយពីបុគ្គលនោះ បុគ្គលទុគ៌ត រមែងមិនមានពួកមិត្ត ពួកមិត្តតែងលះបង់ចោល ព្រោះដឹងថាខ្វះខាត ពួកមិត្តរមែងចោម-រោម ព្រោះឃើញប្រយោជន៍ ឯបុគ្គលខ្ពង់ខ្ពស់ ( ដោយភោគសម្បត្តិ ) តែងមានមិត្តច្រើន ។ បុគ្គលសាបសូន្យចាកប្រយោជន៍ លំបាកដោយភោគៈទាំងអស់ មានខ្លួនប្រឡាក់ដោយឈាម មានខ្លួនធ្លុះធ្លាយ រលត់ជីវិតទៅក្នុងថ្ងៃនេះ ឬក្នុងថ្ងៃស្អែក ដូចដំណក់ទឹកសន្សើម ( ដែលជាប់នៅលើចុងស្មៅ ) ។ សរីរៈប្រាកដដូច្នេះ ដល់នូវសេចក្ដីលំបាកដ៏ក្រៃលែង គេដោតស្លួយឡើងលើឈើអណ្ដោត ដែលគេធ្វើ

*ដោយមែកស្តៅ កាលបើយ៉ាងហ្នឹងហើយ ម្នាលយក្ស ចុះហេតុអ្វីបាន ជាអ្នកពោលថា* ***នៃអ្នកដ៏ចម្រើន អ្នកចូររស់នៅចុះ ( ព្រោះ ) ការរស់ នៅជាការប្រសើរ ។***

បណ្តាបទទាំងនោះ បទថា **តត្ថ** បានដល់ ក្នុងក្រុង-វេសាលីនោះ ។ បទថា **នគរស្ស ពាហិរំ** បានដល់ មាននៅខាងក្រៅព្រះនគរ គឺប្រព្រឹត្តទៅ ជាប់គ្នាខាងក្រៅនៃនគរវេសាលីនោះឯង ។ បទថា **តត្ថេវ** គឺ ក្នុងទីដែលខ្លួនឃើញប្រេតនោះឯង ។ បទថា **តំ** យោគ: **តំ បេតំ** ប្រែថា នូវប្រេតនោះ ។ បទថា **ការណត្ថិកោ** បានដល់ ជាអ្នកមានសេចក្តីត្រូវការដោយហេតុដើម្បី-ផលដូចពោលថា " ***នៃអ្នកដ៏ចម្រើន អ្នកចូររស់នៅចុះ ព្រោះការរស់នៅជាការប្រសើរ*** " ។

បទថា **សេយ្យា និសជ្ជា នយិមស្ស អត្ថិ** សេចក្តីថា ការដេកមានលក្ខណ: មានការដេកសណ្តូកខ្នងជាលក្ខណ: និងការអង្គុយមានការអង្គុយពែនភ្នែនជាលក្ខណ: រមែងមិនមានដល់បុគ្គលដែលត្រូវឈើអណ្តោតដោតនេះបានទេ ។ បទថា **អភិក្កមោ នត្ថិ បដិក្កមោ ច** សេចក្តីថា ការទៅ មានការឈានទៅមុខ សូម្បីត្រឹមតែបន្តិចបន្តួច ក៏មិនមានដល់បុគ្គលនេះឡើយ ។ បទថា **បរិចារិកា សាចិ** សេចក្តីថា សូម្បីស្រីដែលជាអ្នកបម្រើនូវឥន្ទ្រិយ ដែលមាន

លក្ខណៈដូចជា ការស៊ី ការផឹក ការលិទ្ធភ្លក្ស ការស្លៀក ដណ្ដប់ និងការប្រើប្រាស់ជាដើម សូម្បីវត្ថុនោះ ក៏មិនមានដល់បុគ្គលនេះឡើយ ។ ម្យ៉ាងទៀត បាលីថា **បរិហរណា សាបិ** ដូច្នេះក៏មាន, អធិប្បាយថា សូម្បីស្រីជាអ្នកថែរក្សានូវឥន្ទ្រិយ ដោយអំណាចនៃការបរិភោគ មានរបស់គួរបរិភោគជាដើម ក៏មិនមានដល់បុគ្គលនេះឡើយ ព្រោះជាអ្នកប្រាសចាកជីវិត, អាចារ្យពួកខ្លះពោលថា **បរិចារណា សាបិ** ដូច្នេះ ក៏មាន ។

បទថា **ទិដ្ឋសុតា សុហជ្ជា អនុកម្បកា យស្ស អហេសុំ បុព្វេ** សេចក្ដីថា អ្នកដែលមានជនជាសម្លាញ់ធ្លាប់ឃើញគ្នា និងមិនធ្លាប់ឃើញគ្នាជាមិត្ត មានសេចក្ដីអនុគ្រោះ ក្នុងកាលមុន ។ បទថា **ឧដ្ឋំបិ** សេចក្ដីថា បុគ្គលទាំងនោះ សូម្បីនឹងមកសួរសុខទុក្ខក៏មិនបាន គឺការនៅរួមគ្នា នឹងមានមកពីណា ។ បទថា **វិរាជិតត្តោ** បានដល់អ្នកមានសភាវៈ ដែលញាតិជាដើមលះបង់ហើយ ។ បទថា **ជនេន តេន** បានដល់ ដែលជន មានជនដែលជាញាតិជាដើមនោះ ។

បទថា **ន ឱគ្គត្តស្ស ភវន្តិ មិត្តា** សេចក្ដីថា ដែលឈ្មោះថាមិត្ត រមែងមិនមានដល់បុគ្គលដែលប្រាសចាកវិញ្ញាណ ទៅហើយ គឺដែលស្លាប់ទៅហើយ ព្រោះអ្នកនោះឆ្លងផុតអំពីកិច្ច ដែលមិត្តនឹងគប្បីធ្វើចំពោះមិត្ត ។ បទថា **ជហន្តិ មិត្តា វិកលំ វិទិត្វា** សេចក្ដីថា

អ្នកដែលស្លាប់ហើយ ចូរលើកទុកសិន ។ ពួកមិត្តសម្លាញ់ កាលដែលជ្រាបនូវបុរស សូម្បីនៅមានជីវិត ប៉ុន្តែខ្វះខាតនូវភោគសម្បត្តិ ក៏បោះបង់គេចោលដោយគិតថា វត្ថុណាមួយដែលគួរកាន់យកបានអំពីបុរសនេះ រមែងមិនមានឡើយ ។ បទថា **អត្ថញ្ច ទិស្វា បរិវារយន្តិ** សេចក្តីថា ឃើញទ្រព្យដែលជាប្រយោជន៍ ដែលជារបស់អ្នកនោះហើយ ពោលវាចាពីរោះគួរឱ្យស្រឡាញ់ នាំគ្នាចោមរោមអ្នកដែលស្តុកស្តម្ភដោយភោគសម្បត្តិនោះ ។ បទថា **ពហូ ច មិត្តា ឧគ្គតត្តស្ស ហោន្តិ** សេចក្តីថា បុគ្គលដែលមានសេចក្តីសម្រេច មានសភាពស្តុកស្តម្ភដោយទ្រព្យសម្បត្តិ រមែងមានមិត្តច្រើននេះ ជាសភាវៈផ្លូវលោក ។

បទថា **និហីនត្តោ សព្វភោគេហិ** បុគ្គលដែលមានខ្លួនសាបសូន្យចាកវត្ថុដែលជាគ្រឿងឧបភោគ និងបរិភោគទាំងអស់ ។ បទថា **កិច្ឆោ** បានដល់ ជាអ្នកធ្លាក់ខ្លួនក្រលំបាក ។ បទថា **សម្មក្ខិត្តោ** បានដល់ អ្នកមានរាងកាយប្រឡាក់ដោយឈាម ។ បទថា **សម្បរិភិន្នគត្តោ** ( បិដកថា **សំបរិភិន្នគត្តោ** ) បានដល់ អ្នកមានខ្លួនត្រូវឈើអណ្តោតដោតខាងក្នុង ។ បទថា **ឧស្សាវពិន្ទុវ បលិម្ប-មានោ** បានដល់ ដូចដំណក់ទឹកសន្សើមដែលជាប់នៅលើចុងស្មៅ ។ បទថា **អជ្ជ សុវេ** សេចក្តីថា ជីវិតរបស់បុរសនេះនឹងរលត់សូន្យ-

ក្នុងថ្ងៃនេះ ឬក្នុងថ្ងៃស្អែក បន្ទាប់ពីនោះទៅ ក៏ប្រព្រឹត្តទៅមិនបាន ។

បទថា **ឱតាសិតំ** បានដល់ ត្រូវឈើអណ្តោតដោត គឺដោតជាប់ ។ បទថា **បុចិមន្ទស្ស សូលេ** ( បិដកថា **បិចុមន្ទស្ស** ) បានដល់ លើឈើអណ្តោត ដែលគេធ្វើដោយមែកស្តៅ ។ បទថា **កេន វណ្ណេន** ប្រែថា ព្រោះហេតុអ្វី ។ បទថា **ជីវ ភោ ជីវិតមេវ សេយ្យោ** សេចក្តីថា **នែអ្នកដ៏ចម្រើន អ្នកចូររស់នៅចុះ ព្រោះការរស់នៅ ជាការប្រសើរ** ។ សួរថា ព្រោះហេតុអ្វី ? ឆ្លើយថា ព្រោះអ្នកត្រូវឈើអណ្តោតដោត នៅមានជីវិតរស់នៅក្នុងទីនេះ ប្រសើរជាង គឺល្អជាងជីវិតរបស់បុគ្គលដែលចុតិចាកលោកនេះ រាប់រយពាន់ដង ។

ប្រេតនោះត្រូវព្រះរាជានោះត្រាស់សួរយ៉ាងនេះហើយ កាលនឹងប្រកាសនូវបំណងរបស់ខ្លួន ទើបពោលគាថា ៤ គាថាថា :

*បុរសនុ៎ះ ( កាលពីជាតិមុន ) ជាសាលោហិតរបស់ខ្ញុំ ខ្ញុំរលឹកឃើញជាតិក្នុងភពមុន បពិត្រព្រះរាជា បុរសមានធម៌ដ៏លាមកនេះ កុំធ្លាក់ចុះក្នុងនរកឡើយ ។ បពិត្រលិច្ឆវិរាជ បុរសនោះជាអ្នកធ្វើអំពើអាក្រក់ កាលច្យុតចាកអត្តភាពនេះហើយនឹងកើតក្នុងនរក ដែលសម្បូរដោយសត្វមានសភាពគួរឱ្យស្ញើប មានកំដៅភ្លើងដ៏ខ្លាំង មានទុក្ខក្តៅផ្សា ជាគ្រឿងធ្វើភ័យឱ្យកើត ។ ដែកអណ្តោតនេះឯង ប្រសើរ*

*ជាងនរកនោះ ដោយគុណមានចំណែកដ៏ច្រើន បុរសនេះ កុំធ្លាក់ក្នុងនរក មានទុក្ខតែម្យ៉ាង មានទុក្ខដ៏ក្តៅផ្សា ជាគ្រឿងធ្វើភ័យឱ្យកើតមានទុក្ខដ៏ក្លៀវក្លាតែម្យ៉ាង បុរសអ្នកដល់នូវសេចក្តីទុក្ខនោះ ស្តាប់ពាក្យខ្ញុំនេះបានហើយ គប្បីវៀរបង់នូវអំពើលាមកចេញ ហេតុដូច្នោះបានជាខ្ញុំ មិននិយាយក្នុងសម្នាក់នៃ ( បុគ្គលនេះ ) ថា ការរលត់ទៅនៃជីវិតនេះ ចូរកុំមានដល់ខ្ញុំ ក្នុងទីជាមួយគ្នាឡើយ ។*

បណ្តាបទទាំងនោះ បទថា **សាលោហិតោ** បានដល់ មានលោហិតស្មើគ្នា គឺ ជាប់ទាក់ទងគ្នាដោយកំណើត, អធិប្បាយថា ជាញាតិនិងគ្នា ។ បទថា **បុរិមាយ ជាតិយា** គឺក្នុងអត្តភាពមុន ។ បទថា **មា បាបធម្មោ និរយំ បតាយំ** មានសេចក្តីថា ខ្ញុំព្រះអង្គបានឃើញបុរសនេះហើយមានសេចក្តីករុណាថា សូមកុំឱ្យបុរសដែលមានធម៌ដ៏លាមក ធ្លាក់នរកឡើយ គឺ កុំចូលដល់នរកឡើយ ។

បទថា **សត្តុស្សទំ** សេចក្តីថា កកកុញដោយសត្វដែលធ្វើនូវអំពើអាក្រក់, ម្យ៉ាងទៀត ពោរពេញដោយការធ្វើទោសដ៏ខ្លាំងក្លា ៧ យ៉ាងនេះ គឺ បញ្ចពិធពន្ធន៍ ( ចំណង ៥ ប្រការ[១] ) ១, ចាក់ទឹក-

*[១]= ចំណង ៥ ប្រការនោះគឺ ផ្តេក ( បុរសនោះ ) ហើយបោះដែកគោលដ៏ក្តៅត្រង់ដៃ ( ខាងស្តាំ ) ១ បោះដែកគោលដ៏ក្តៅ ត្រង់ដៃខាងឆ្វេង ១ បោះដែកគោលដ៏ក្តៅ ត្រង់ជើង ( ខាងស្តាំង ) ១ បោះដែកគោលដ៏ក្តៅ ត្រង់ជើងខាងឆ្វេង ១ បោះដែកគោលដ៏ក្តៅចំកណ្តាលទ្រូង ១ ។ ( បិដកលេខ ២៧, ទំព័រ ២២២ )*

ទង់ដែងដ៏ក្ដៅចូលទៅក្នុងមាត់ ១ , ឱ្យឡើងភ្នំដែលពេញដោយរងើកភ្លើង ១, ចាប់ទម្លាក់ចូលទៅក្នុងខ្ទះទង់ដែង ១, ឱ្យចូលទៅកាន់ព្រៃសសិត ១, ឱ្យចុះក្នុងស្ទឹងវេតរណីក្នុងនរក ១, ចាប់បោះទម្លាប់ទៅក្នុងមហានរក ១ , អធិប្បាយថា សន្សំកាន់តែច្រើនឡើង ៧ ។ បទថា **មហាភិតាបំ** បានដល់ ទុក្ខធំ ឬ សេចក្ដីក្ដៅរោលរាលដែលកើតអំពីគំនរភ្លើងដ៏ធំ ។ បទថា **អកន្តំ** ប្រែថា មិនគួរប្រាថ្នា ។ បទថា **ភយានកំ** ប្រែថា ឱ្យកើតសេចក្ដីខ្លាច ។

បទថា **អនេកភាគេន គុណេន** បានដល់ ដោយអានិសង្សច្រើនផ្នែក ។ បទថា **អយមេវ សុលោ និរយេន តេន** សេចក្ដីថា ឈើអណ្ដោតនេះឯង ប្រសើរជាងនរក ដែលជាទីកើតរបស់បុរសនេះនោះ ។ មែនពិត បទថា **និរយេន** នេះ ជាតតិយាវិភត្តិប្រើក្នុងអត្ថនៃបញ្ចមីវិភត្តិ ។ បទថា **ឯកន្តតិព្វំ** សេចក្ដីថា មានសេចក្ដីទុក្ខដ៏ខ្លាំងក្លាតែម្យ៉ាងដោយពិត គឺ ជាទុក្ខដ៏ធំយ៉ាងពិតប្រាកដ ។

បទថា **ឥទញ្ច សុត្វា វចនំ មមេសោ** សេចក្ដីថា បុរសនេះ ស្ដាប់ពាក្យរបស់ខ្ញុំនេះ ដែលពោលដោយន័យ មានជាដើមថា **ឥតោ ចុតោ** ឃ្លាតចាកអត្តភាពនេះហើយជាដើម ជាអ្នកចូលដល់ទុក្ខ ដូចជាចូលដល់ទុក្ខក្នុងនរក តាមពាក្យរបស់ខ្ញុំ ។ បទថា

**ទិដហេយ្យ ធារណំ** សេចក្តីថា គប្បីលះបង់ជីវិតរបស់ខ្លួន ។ បទថា **តស្មា** ប្រែថា ព្រោះហេតុនោះ ។ បទថា **មា មេតតោ** អធិប្បាយថា ខ្ញុំមិនបាននិយាយពាក្យនេះ ក្នុងទីជិតនៃបុរសនេះថា សូមជីវិតរបស់បុរសនេះ ចូរកុំរលត់ព្រមគ្នាជាមួយនឹងខ្ញុំឡើយ ។ តាមពិត ខ្ញុំនិយាយត្រឹមតែប៉ុណ្ណេះថា " **នែអ្នកដ៏ចម្រើន អ្នកចូររស់នៅចុះ ព្រោះការរស់នៅជាការប្រសើរ** " ។

កាលប្រេតប្រកាសនូវបំណងរបស់ខ្លួនយ៉ាងនេះហើយ ព្រះ-រាជា កាលទ្រង់សូមឱកាសដើម្បីនឹងសួរប្រវត្តិរបស់ប្រេតនោះទៀត ទើបត្រាស់នូវគាថានេះថា :

*ប្រយោជន៍របស់បុរសនេះ ខ្ញុំដឹងហើយ យើងចង់សួរប្រយោជន៍ដទៃទៀត ចំពោះអ្នក បើអ្នកមិនបើកឱកាសឱ្យយើងទេ យើងក៏មិនហ៊ានសួរអ្នកដែរ អ្នកកុំគប្បីខឹងនឹងយើង ។*

**ប្រេតនោះក្រាបទូលថា** :

*សេចក្តីប្តេជ្ញារបស់យើង មានហើយក្នុងកាលនោះដោយពិតថា មិនប្រាប់ដល់បុគ្គលដែលមិនជ្រះថ្លា ( នឹងគ្នា ) អ្នកចូរធ្វើទុកក្នុងចិត្តថា យើងមិនចង់ប្រាប់ទេ តែជាមនុស្សមានពាក្យគួរជឿបានដូច្នេះ ហើយសួរខ្ញុំចុះ តាមសេចក្តីពិតដែលអាច ( នឹងប្រាប់បាន ) ។*

នេះជាព្រះគាថាដែលឆ្លើយឆ្លងគ្នារវាងព្រះរាជា និង ប្រេត ។

បណ្ដាបទទាំងនោះ បទថា **អញ្ញាតោ** ( បិដកថា **អញ្ញាតោ** ) ប្រែថា ដែលខ្ញុំដឹងហើយ ។ បទថា **ឥច្ឆាមសេ** ប្រែថា ខ្ញុំរមែងប្រាថ្នា ។ បទថា **នោ** ប្រែថា ដល់ពួកយើង ។ បទថា **ន ច កុជ្ឈិតព្វំ** សេចក្ដីថា មិនគួរធ្វើសេចក្ដីក្រោធថា អ្នកទាំងនេះ បានសួរនូវរឿងណាមួយឡើយ ។

បទថា **អទ្ធា** ប្រែថា ពិតប្រាកដ ។ បទថា **បដិញ្ញា មេ** សេចក្ដីថា កាលពោលដោយចំណេះដឹង យើងបានប្ដេជ្ញា គឺ បើកឱកាសថា អ្នកចូរសួរ ។ បទថា **តទា អហុ** គឺ មានហើយក្នុងកាលនោះ គឺ ក្នុងការឃើញគ្រាដំបូង ។ បទថា **នាចិក្ខនា អប្បសន្នស្ស ហោតិ** ( បិដកថា **អចិក្ខនា អប្បសន្នស្ស ហោតិ** ) សេចក្ដីថា មិនបាននិយាយដល់អ្នកដែលមិនជ្រះថ្លា ។ មែនពិតអ្នកជ្រះថ្លាប៉ុណ្ណោះ រមែងពោលនូវរឿងអ្វីមួយដល់អ្នកជ្រះថ្លា តែក្នុងវេលានោះ អ្នកមិនមានសេចក្ដីជ្រះថ្លាចំពោះយើង ហើយយើងក៏មិនមានសេចក្ដីជ្រះថ្លាចំពោះអ្នក ព្រោះដូច្នោះ អ្នកទើបមិនមានសេចក្ដីប្រាថ្នាដើម្បីនឹងពោលប្ដេជ្ញា ។ ប៉ុន្តែឥឡូវនេះ យើងមានវាចាដែលនឹងឱ្យអ្នកលួមជឿជាក់បាន ព្រោះដូច្នោះ យើងទើបជាអ្នកឈ្មោះថាមានវាចាលួមជឿជាក់បាន ។ បទថា **បុច្ឆស្សុ មំ ភាមំ យថាវិសយ្ហំ** សេចក្ដីថា សូមព្រះអង្គចូរសួរនូវរឿងតាមដែលព្រះអង្គទ្រង់-

ប្រាថ្នានឹងខ្ញុំព្រះអង្គចុះ ។ តែខ្ញុំព្រះអង្គនឹងក្រាបទូលតាមសមគួរដល់កម្លាំងចំណេះដឹងរបស់ខ្លួន ដោយប្រការដែលខ្ញុំព្រះអង្គអាចនឹងក្រាបទូលបាន ។

កាលប្រេតបើកឱកាសដល់ការសួរយ៉ាងនេះហើយ ព្រះរាជាទើបត្រាស់នូវគាថាថា :

*យើងឃើញនូវហេតុណាមួយដោយចក្ខុ យើងត្រូវជឿហេតុ-នោះទាំងអស់ ប្រសិនបើយើងឃើញហើយ យើងមិនជឿហេតុ-នោះទេ ម្នាលយក្ខ អ្នកត្រូវធ្វើនិយស្សកម្ម ( ការបន្ថយយស ) ដល់យើងចុះ ។*

ពាក្យនៃគាថានោះ មានសេចក្តីអធិប្បាយដូចតទៅនេះ : យើងឃើញនូវហេតុណាមួយដោយចក្ខុ យើងត្រូវជឿនូវហេតុនោះទាំងអស់ ដោយប្រការនោះឯង ប្រសិនបើយើងឃើញនូវហេតុនោះហើយ មិនជឿទេ ម្នាលយក្ខ សូមអ្នកធ្វើនូវនិយស្សកម្ម ( ការដកយស ) និងនិគ្គហកម្ម ( ការដាក់ទោស.. ) ។ ម្យ៉ាងទៀត បទថា **យំកិញ្ចាហំ ចក្ខុនា បស្សិស្សាមិ** សេចក្តីថា យើងនឹងឃើញនូវហេតុណាមួយដោយចក្ខុ ព្រោះមិនជាអារម្មណ៍នៃចក្ខុទើបមិនឃើញ ។ បទថា **សព្វំបិ តាហំ អភិសទ្ទហេយ្យំ** សេចក្តីថា យើងគួរជឿនូវហេតុដែលអ្នកបានឃើញ បានឮ ឬហេតុដទៃ , អធិប្បាយថា

មែនពិតយើងមានជំនឿដូច្នោះចំពោះអ្នក ។ ចំណែកសេចក្ដីនៃបទក្រោយ ក៏មានអត្ថដូចដែលបានពោលរួចមកហើយនោះឯង ។

ប្រេតបានស្ដាប់ដូច្នោះហើយបានពោលគាថាថា :

*ពាក្យប្ដេជ្ញានុ៎ះ ជាពាក្យដ៏ពិតរបស់ព្រះអង្គចុះ បើព្រះអង្គត្រូវការចង់ដឹង មានហឫទ័យមិនប្រទូស្ដ ស្ដាប់ធម៌ណា ជាធម៌ដែលព្រះអង្គធ្លាប់ស្ដាប់ហើយក្ដី មិនធ្លាប់ស្ដាប់ហើយក្ដី លុះព្រះអង្គស្ដាប់ធម៌នោះហើយ ចូរបាននូវសេចក្ដីជ្រះថ្លា កាលបើខ្ញុំដឹងយ៉ាងណា នឹងក្រាបទូលនូវហេតុនោះទាំងអស់ ។*

បន្ទាប់ពីនោះ ព្រះរាជា និងប្រេតទាំងពីរនោះ ទើបមានគាថាជាគ្រឿងត្រាស់ឆ្លើយឆ្លងគ្នាដូច្នេះថា :

**ព្រះបាទអម្ពសក្ខរៈត្រាស់ថា :**

*អ្នកមានសេះ-សប្រដាប់ហើយ ហើយចូលទៅក្នុងទីជិតនៃ-បុរសដែលគេដោតដោយឈើអណ្ដោត ឯយានជំនិះ ជារបស់អស្ចារ្យគួររមិលមើល នេះជាផលនៃកម្មអ្វី ។*

**ប្រេតក្រាបទូលថា :**

*មានជង្ហុក ១ ត្រង់ផ្លូវរអិលនៅកណ្ដាលក្រុងវេសាលីនោះ ថ្ងៃមួយខ្ញុំមានចិត្តជ្រះថ្លា បានយកក្បាលគោធ្វើជាស្ពាន ដាក់ត្រង់ជង្ហុកនោះ ។ យើងក្ដី ពួកមនុស្សឯទៀត ១ ក្ដី បានដាក់ជើងលើស្ពាននោះ*

*ហើយ ទើបដើរទៅបាន យានជំនិះដ៏អស្ចារ្យ គួររមិលមើល នេះជាផលនៃកម្មនោះឯង ។*

**ព្រះបាទអម្ពសក្ខរៈត្រាស់សួរថា :**

*ចុះអ្នកមានសម្បុរភ្លឺទៅសព្វទិស អ្នកមានក្លិនផ្សព្វផ្សាយទៅសព្វទិសបាន អ្នកបានទ្ធវឫទ្ធិជាយក្ស មានអានុភាពច្រើន តែជាអ្នកអាក្រាត នេះជាវិបាកនៃកម្មអ្វី ។*

**ប្រេតនោះក្រាបទូលថា :**

*ខ្ញុំជាមនុស្សមិនក្រោធ មានចិត្តជ្រះថ្លាជានិច្ច និយាយទៅនឹងជនដោយពាក្យពីរោះផ្អែមល្ហែម នេះជាផលនៃកម្មនោះឯង បានជាសម្បុររបស់ខ្ញុំ ភ្លឺជានិច្ចដូចជាទិព្វ ។ ខ្ញុំបានឃើញយសស័ក្តិ និងកេរ្តិ៍ឈ្មោះ របស់ពួកជនអ្នកតាំងនៅក្នុងធម៌ ក៏មានចិត្តជ្រះថ្លា ហើយប្រឹក្សា នេះជាផលនៃកម្មនោះឯង បានជាខ្ញុំមានក្លិនដូចជាទិព្វផ្សព្វផ្សាយទៅជានិច្ចបាន ។ ខ្ញុំបានយកសំពត់ពួកសម្លាញ់ កំពុងងូតទឹកក្នុងកំពង់ លាក់លើគោក ខ្ញុំត្រូវការនឹងសើចលេង មិនមានចិត្តប្រទូស្តទេ ព្រោះតែកម្មនោះ បានជាខ្ញុំអាក្រាត ទាំងការចិញ្ចឹមជីវិតក៏លំបាកពន់ពេក ។*

**ព្រះបាទអម្ពសក្ខរៈត្រាស់សួរថា :**

*បើបុគ្គលណា លែងធ្វើបាប អ្នកប្រាជ្ញទាំងឡាយបានសម្តែង*

*នូវផលនៃកម្មរបស់បុគ្គលនោះប្រាកដដូច្នេះ ចុះបើបុគ្គលណា មិន-លែងធ្វើបាបទេ អ្នកប្រាជ្ញទាំងឡាយ បានសម្តែងនូវផលនៃកម្មនោះដូចម្តេច ។*

**ប្រែតក្រាបទូលថា :**

*បើពួកមនុស្សណា មានតម្រិះក្នុងចិត្តប្រទូស្តហើយ សៅហ្មងដោយកាយនិងវាចា មនុស្សទាំងនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ ក្នុងបរលោក រមែងទៅកើតក្នុងនរកឥតមានសង្ស័យឡើយ ។ ចំណែកពួកមនុស្សដទៃប្រាថ្នានូវសុគតិ ត្រេកអរក្នុងទានមានអត្តភាពជាអ្នកសង្គ្រោះមនុស្សទាំងនោះ លុះបែកធ្លាយរាងកាយស្លាប់ទៅក្នុងបរលោក រមែងទៅកើតក្នុងសុគតិ ឥតមានសង្ស័យឡើយ ។*

បណ្តាបទទាំងនោះ បទថា **សច្ចប្បដិញ្ញា តវ មេសា ហោតុ** សេចក្តីថា សូមសេចក្តីប្តេជ្ញារបស់ព្រះអង្គនេះ ចូរជាសេចក្តីពិតរបស់ព្រះអង្គចុះ ខ្ញុំគប្បីជឿនូវហេតុនោះទាំងអស់ ។ បទថា **សុត្វាន ធម្មំ លភស្សុ បសាទំ** សេចក្តីថា ព្រះអង្គស្តាប់ពាក្យដែលខ្ញុំពោលហើយ ចូរបាននូវសេចក្តីជ្រះថ្លាដ៏ល្អ ។ បទថា **អញ្ញត្ថិកោ** បានដល់ ព្រះអង្គមានបំណងចង់ដឹង ។ បទថា **យថា បជានំ** បានដល់ តាមដែលអ្នកដទៃដឹង, អធិប្បាយថា តាមដែលព្រះអង្គដឹង-

ហើយ ឬថាតាមដែលខ្ញុំព្រះអង្គដឹងហើយ ។

បទថា **កិស្សេតំ កម្មស្ស អយំ វិបាកោ** សេចក្តីថា នោះជាផលនៃកម្មអ្វី គឺ នេះជាវិបាកនៃកម្មអ្វី ។ ម្យ៉ាងទៀត បទថា **ឯតំ** គ្រាន់តែជានិបាត ក៏អាចារ្យមួយពួកទៀតពោលថា ជាផលនៃ-កម្មអ្វីរបស់អ្នក ។

បទថា **ចិក្ខលមគ្គេ** ប្រែថា ក្នុងផ្លូវមានភក់ ។ បទថា **នរកំ** បានដល់ ជង្ហុក ។ បទថា **ឯកាហំ** កាត់បទជា **ឯកំ អហំ** ។ បទថា **នរកស្មិំ និក្ខិបឹ** ( បិដកថា **នរកស្មិំ និក្ខិបិ** ) សេចក្តីថា ខ្ញុំបានដាក់ក្បាលគោមួយ ក្នុងជង្ហុកដែលមានភក់ដោយប្រការដែលអ្នកដើរនឹងមិនជាន់ភក់ ។ បទថា **តស្ស** បានដល់ យកក្បាលគោធ្វើជាស្ពាននោះ ។

បទថា **ធម្មេ ឋិតានំ** បានដល់ អ្នកប្រព្រឹត្តធម៌ ប្រព្រឹត្តជានិច្ច ។ បទថា **មន្តេមិ** បានដល់ ពោល គឺ ប្រាប់ដល់ ។ បទថា **វិឌ្ឍត្ថិកោ** ( **កិញ្ចត្ថិកោ** ) បានដល់ បំណងនឹងសើចលេង ។ បទថា **នោ ច បទុដ្ឋចិត្តោ** បានដល់ មិនមានចិត្តគិតប្រទូសរ៉ាយម្ចាស់សំពត់ទេ, អធិប្បាយថា មិនមានបំណងនឹងលួច ទាំងមិនមានបំណងនឹងធ្វើឱ្យបាត់បង់ឡើយ ។ បទថា **អភិឡមានោ** បានដល់ មិន គឺមានចិត្តប្រទូសរ៉ាយ ព្រោះសេចក្តីលោភជាដើម ។ បទថា **ភឹ តស្ស**

**កម្មស្ស វិបាកមាហុ** សេចក្តីថា បណ្ឌិតទាំងឡាយពោលនូវវិបាកទុក្ខដ៏ក្តៅផ្សាររបស់កម្មអាក្រក់នោះ គឺដែលធ្វើទុកយ៉ាងនោះ ដូចម្តេច ។

បទថា **ទុដ្ឋសង្កប្បមនា** បានដល់ អ្នកមានវិតក្កៈតាមផ្លូវចិត្តដែលប្រទូសរ៉ាយ ដោយអំណាចសេចក្តីត្រិះរិះក្នុងកាមជាដើម ។ ដោយពាក្យថា **ទុដ្ឋសង្កប្បមនា** នោះ លោកពោលដល់មនោ-ទុច្ចរិត ។ បទថា **កាយេន វាចាយ ច សន្ថិលិដ្ឋា** បានដល់ មានសេចក្តីសៅហ្មង ដោយកាយ និងវាចា ដោយអំណាចបាណា-តិបាតជាដើម ។ បទថា **អាសមានា** ( បិដកថា **អាសិសមានា** ) បានដល់ សង្ឃឹម គឺ ប្រាថ្នា ។

កាលប្រេតសម្តែងនូវការចែកកម្ម និងផលនៃកម្មដោយសង្ខេបយ៉ាងនេះហើយ ព្រះរាជាទ្រង់មិនជឿនូវពាក្យនោះ ទើបត្រាស់គាថាថា :

*យើងបានពិចារណាហើយ គប្បីដឹងពាក្យនោះដូចម្តេច នេះជាផលនៃកល្យាណកម្ម និងបាបកម្ម កាលបើកល្យាណកម្ម និងបាបកម្មទេតើ យើងឃើញដូចម្តេច គប្បីជឿ នរណាគប្បីធ្វើខ្ញុំឱ្យជឿពាក្យនោះបាន ។*

បណ្តាបទទាំងនោះ បទថា **តំ កិន្តិ ជានេយ្យំ អហំ អវេច្ច** សេចក្តីថា យើងនឹងគប្បីជឿដោយមិនមានអ្នកដទៃជាបច្ច័យ ចំពោះ-

វិបាករបស់កម្មល្អ និងកម្មអាក្រក់ដែលអ្នកពោលចែកទុក ដោយន័យមានជាដើមថា អ្នកដែលមានសេចក្តីត្រិះរិះអាក្រក់ រមែងសៅហ្មងដោយកាយ និងវាចា និងដោយន័យមានជាដើមថា ក៏ពួកជនដទៃរមែងប្រាថ្នាសុគតិ ដូច្នេះនោះបានដូចម្តេច គឺ ដោយហេតុដូចម្តេច ។ បទថា **កឹ ទាហំ ឥស្វា អភិសទ្ទហេយ្យំ** សេចក្តីថា យើងឃើញដូចម្តេច ដែលជាតួយ៉ាងដ៏ប្រចក្សនឹងគប្បីជឿបាន ។ បទថា **កោ ទាបិ មំ សទ្ទហាបេយ្យ ឯតំ** សេចក្តីថា ឬនរណាជាវិញ្ញូជនគឺជាបណ្ឌិត និងគប្បីឱ្យយើងជឿនូវពាក្យនោះ អ្នកចូរណែនាំនូវបុគ្គលនោះ ។

ប្រេតបានស្តាប់ដូច្នោះហើយ កាលនឹងប្រកាសនូវរឿងនោះដល់ព្រះរាជានោះដោយហេតុ ទើបបានពោលនូវគាថាថា :

*ព្រះអង្គទតឃើញហើយ ឮហើយ សូមជឿទៅចុះ នេះជាផលនៃកល្យាណកម្ម និងបាបកម្ម កាលបើកល្យាណកម្ម និងបាបកម្មទាំងពីរមិនមានទេ ពួកសត្វគប្បីមានសុគតិ ឬ ទុគ្គតិ ដូចម្តេចបាន ។ ប្រសិនបើពួកសត្វមិនគប្បីធ្វើកល្យាណកម្ម និងបាបកម្ម ក្នុងមនុស្សលោកនេះទេ ពួកសត្វក៏មិនបានសុគតិ ឬទុគ្គតិ ទាំងមិនបានថោកទាប ឬខ្ពង់ខ្ពស់ក្នុងមនុស្សលោកឡើយ ។ ពួកសត្វធ្វើកល្យាណកម្ម និងបាបកម្ម ក្នុងមនុស្សលោកនេះ ព្រោះហេតុណា ហេតុនោះបានជា*

*ពួកសត្វ ទៅសុគតិខ្លះ ទុគ្គតិខ្លះ ថោកទាបខ្លះ ខ្ពង់ខ្ពស់ខ្លះ ក្នុងមនុស្សលោក ។ ពួកអ្នកប្រាជ្ញ បានសម្ដែងនូវផលទាំងពីរនៃកម្ម ទាំងឡាយ ដែលជាគ្រឿងសោយនូវសុខ និងទុក្ខ ពួកទេវតាតែង ចោមរោមដោយពិត ពួកពាលជាអ្នកមិនបានឃើញនូវផលទាំងពីរ ហើយ រមែងឆេះនៅ( ក្នុងអបាយទាំងឡាយមាននរកជាដើម ) ។*

បណ្ដាបទទាំងនោះ បទថា **ទិស្វា ច** ប្រែថា ទាំងទ្រង់បាន ឃើញដោយប្រចក្ស ។ បទថា **សុត្វា** បានដល់ ទ្រង់ស្ដាប់ធម៌ហើយ ទ្រង់ដឹង គឺ ទ្រង់ដឹងតាមន័យតាមក្រសែនៃធម៌នោះ ។ បទថា **កល្យាណបាបស្ស** សេចក្ដីថា សូមទ្រង់ជឿចុះថា សុខនេះជាវិបាក នៃកុសលកម្ម និងទុក្ខនេះជាវិបាកនៃអកុសលកម្ម ។ បទថា **ឧភយេ អសន្តេ** សេចក្ដីថា កាលបើកម្មទាំងពីរ គឺ កម្មល្អ និងកម្មអាក្រក់ មិនមាន ។ បទថា **សិយា នុ សត្តា សុគតា ទុគ្គតា វា** សេចក្ដីថា សេចក្ដីដូច្នេះថា សត្វទាំងនេះ ទៅសុគតិ ឬទុគ្គតិ ឬថា ជាអ្នក បរិបូណ៌ដោយភោគៈក្នុងសុគតិ ឬជាអ្នកមានសេចក្ដីទុក្ខលំបាកក្នុង ទុគ្គតិ ដូច្នេះ នឹងគប្បីមានឬ គឺ នឹងគប្បីកើតបានដូចម្ដេច ។

ឥឡូវនេះ ប្រេតនឹងប្រកាសនូវសេចក្ដីតាមដែលបានពោលរួច មកហើយ ដោយខុសប្លែកគ្នា និងដោយស្របគ្នា ដោយគាថា ២ គាថាថា **នោ ចេត្ត កម្មានិ** និង **យស្មា ច កម្មានិ** ដូច្នេះ ។

បណ្ដាបទទាំងនោះ បទថា **ហីនា បណីតា** បានដល់ ដែល-ថោកទាប និងខ្ពង់ខ្ពស់ដោយត្រកូល រូបរាង សេចក្ដីមិនមានរោគ និងបរិវារជាដើម ។

បទថា **ទ្វយញ្ច កម្មានំ វិបាកមាហុ** ( បិដកថា **ទ្វយញ្ច កម្មានំ វិបាកមាហុ** ) សេចក្ដីថា សត្វទាំងឡាយ រមែងពោល គឺសម្ដែងវិបាកនៃសុចរិត និងទុច្ចរិតនៃកម្មទាំងពីរយ៉ាង ក្នុងថ្ងៃនេះ គឺក្នុងឥឡូវនេះ ។ ដើម្បីចៀសវាង ពាក្យសួរថា សេចក្ដីនោះ គឺដូចម្ដេច ? ទើបពោលថា ការសោយនូវសុខ និងទុក្ខ, អធិប្បាយថា គួរនឹងសោយនូវឥដ្ឋារម្មាណ៍ និងអនិដ្ឋារម្មណ៍ ។ បទថា **តា ទេវតា-យោ បរិចារយន្តិ** ( បិដកថា **តាវ ទេវតា បរិវារយន្តិ** ) សេចក្ដីថា ពួកជនដែលបានទទួលនូវវិបាកជាសុខតែម្យ៉ាង រមែងជាទេវតាក្នុងទេវលោក បរិបូណ៌ដោយទិព្វសុខ បម្រើនូវឥន្ទ្រិយ-ទាំងឡាយ ។ បទថា **បច្ចេន្តិ ពាលា ទ្វយតំ អបស្សិនោ** សេចក្ដីថា ជនទាំងឡាយណា ជាបុគ្គលពាល មិនឃើញ គឺមិនជឿនូវកម្ម និងផលនៃកម្មទាំងពីរ ជនទាំងនោះ ជាអ្នកខ្វល់ខ្វាយក្នុងបាបកាលសោយនូវវិបាកជាទុក្ខ រមែងឆេះ គឺរមែងបានទទួលនូវសេចក្ដីទុក្ខ ព្រោះកម្មក្នុងនរកជាដើម ។

ប្រេតសំដៅយកការសួរត្រឡប់ទៅវិញថា ក៏អ្នកជឿនូវកម្ម

និងផលនៃកម្មយ៉ាងនេះហើយ ព្រោះហេតុដូចម្តេច ទើបសោយនូវ-ទុក្ខមានសភាពដូច្នេះ ទើបពោលនូវគាថាថា :

*បុញ្ញកម្មដែលធ្វើដោយខ្លួនឯង មិនមានអ្នកឱ្យគ្រឿងស្លៀក-ពាក់ ទីដេក ទីអង្គុយ បាយ និងទឹក ហើយឧទ្ទិសចំពោះខ្ញុំ ក៏មិនមានដែរ ហេតុនោះ បានជាខ្ញុំមានកាយអាក្រាតទាំងការប្រព្រឹត្តចិញ្ចឹមជីវិតក៏លំបាក ។*

បណ្តាបទទាំងនោះ បទថា **ន មត្ថិ កម្មានិ សយំ កតានិ** សេចក្តីថា ព្រោះហេតុដែលបុញ្ញកម្មដែលខ្លួនឯងធ្វើទុកក្នុងកាលមុន ដែលជាហេតុឱ្យបានទទួលនូវគ្រឿងស្លៀកដណ្តប់ជាដើមក្នុងកាលឥឡូវនេះ មិនមានប្រាកដដល់ខ្ញុំព្រះអង្គទេ ។ បទថា **ទត្វាបិ មេ នត្ថិ សោ អាទិសេយ្យ** សេចក្តីថា អ្នកណាគប្បីឱ្យទានដល់សមណ-ព្រាហ្មណ៍ហើយ គប្បីឧទ្ទិសនូវចំណែកបុណ្យដល់ខ្ញុំព្រះអង្គថា សូមបុណ្យនេះ ចូរសម្រេចដល់ប្រេតឯណោះ រមែងមិនមានឡើយ ។ បទថា **តេនម្ហិ នគ្គោ កសិរា ច វុត្តិ** ( បិដកថា **តេនម្ហិ នគ្គោ កសិរា បវុត្តិ** ) សេចក្តីថា ព្រោះហេតុទាំងពីរនោះ ខ្ញុំព្រះអង្គទើបជាអ្នកអាក្រាតកាយ មិនមានសំលៀកបំពាក់ក្នុងកាលឥឡូវនេះ ទាំង-ការរស់នៅក៏លំបាក ។

ព្រះរាជាទ្រង់បានស្តាប់ដូច្នោះហើយ កាលប្រាថ្នានឹងឱ្យប្រេត

នោះបាននូវគ្រឿងស្លៀកដណ្តប់ជាដើម ទើបពោលនូវគាថាថា :

*ម្នាលយក្ស ហេតុតិចតួចដែលអ្នកគួរបាន នូវគ្រឿងស្លៀកពាក់មានដែរឬ អ្នកចូរប្រាប់ដល់យើង ហេតុណាដែលនាំឱ្យយើងជឿបាន យើងនឹងស្តាប់នូវពាក្យ តាមហេតុនោះ ។*

បណ្តាបទទាំងនោះ បទថា **យេន** សេចក្តីថា ហេតុណាមួយដែលជាហេតុឱ្យអ្នកបាននូវគ្រឿងស្លៀកដណ្តប់ តើមានដែរឬទេហ្ន៎ ។ បទថា **យទត្ថិ** កាត់បទជា **យទិ អត្ថិ** ប្រែថា បើមាន ។

លំដាប់នោះ ប្រេតកាលនឹងទូលនូវហេតុនោះដល់ព្រះរាជា ទើបបានពោលនូវគាថាថា :

*ក្នុងក្រុងវេសាលីនេះ មានភិក្ខុ ១ រូប ឈ្មោះ**កប្បិតកៈ** មានឈាន មានសីលធម៌ល្អ ជាព្រះអរហន្ត មានចិត្តផុតស្រឡះចាកអកុសល មានឥន្ទ្រិយស្រគត់ស្រគំ សង្រួមក្នុងបាតិមោក្ខ ត្រជាក់ត្រជំ សម្រេចនូវការយល់ដ៏ខ្ពង់ខ្ពស់ មានសំដីទន់ភ្លន់ ដឹងនូវពាក្យពោល មានសំដីផ្អែមល្ហែម មានព្រះភក្ត្រផូរផង់ ចេះចាំធម៌អាចីដោយប្រពៃ ផុតស្រឡះហើយដោយល្អ ជាបុញ្ញក្ខេត្ត ស្ងប់ស្ងាត់ចាកកិលេស ជាទក្ខិណេយ្យបុគ្គល របស់ទេវតា និងមនុស្សទាំងឡាយ ជាសប្បុរសប្រាសចាកផ្សែង គឺ វិតក្កៈ វិចារៈ មិនមានទុក្ខ មិនមានសេចក្តីប្រាថ្នា ផុតស្រឡះចាកភពទាំងពួង មានសរ គឺរាគៈទៅប្រាសហើយ មិនមាន*

*សេចក្តីសំគាល់ថាអញ មិនវៀចវេរ មិនមានឧបធិក្កិលេស អស់ធម៌ជាគ្រឿងឃឹតយូរគ្រប់យ៉ាង បានសម្រេចវិជ្ជា ៣ មានសេចក្តីរុងរឿង ។ លោកនោះ មិនល្បីទាមប្រាកដទេ ទុកជាឃើញក៏មិនងាយនឹងស្គាល់ ពួកមនុស្សអ្នកនៅក្នុងដែនវជ្ជី តែងនាំគ្នាហៅថា មុនី ដូច្នេះទាំងដឹងថា លោកជាបុគ្គលគួរបូជា មិនមានសេចក្តីញាប់ញ័រគឺកិលេស មានកល្យាណធម៌ ប្រព្រឹត្តនៅក្នុងលោក ។ បើព្រះអង្គ ឱ្យសំពត់ ១ គូក្តី ២ គូក្តី ដល់ព្រះថេរៈនោះឧទ្ទិសដល់ខ្ញុំ ខ្ញុំនឹងគប្បីបានសំពត់ ដែលលោកទទួលហើយនោះផង ព្រះអង្គនឹងទតឃើញខ្ញុំដែលស្លៀកសំពត់ហើយផង ។*

បណ្តាបទទាំងនោះ បទថា **កប្បិតកោ នាម** ប្រែតពោលសំដៅយក**ព្រះឧបជ្ឈាយ៍**របស់**ព្រះឧបាលិត្ថេរ**ក្នុងបណ្តាជដិល **១.០០០ អង្គ** ។ បទថា **ឥធ** បានដល់ ក្នុងទីជិតនគរវេសាលីនេះ ។ បទថា **ឈាយី** បានដល់ អ្នកបានឈាន ដោយឈានដែលសម្បយុត្តដោយអរហត្តផល ។ បទថា **សីតិភូតោ** បានដល់ អ្នកដល់នូវភាពត្រជាក់ត្រជុំ ដោយការចូលទៅស្ងប់សេចក្តីក្រវល់ក្រវាយ និងសេចក្តីក្តៅរោលរាលនៃកិលេសទាំងពួង ។ បទថា **ឧត្តមទិដ្ឋិបត្តោ** បានដល់ អ្នកសម្រេចនូវសម្មាទិដ្ឋិដែលជាផលដ៏ខ្ពង់ខ្ពស់ គឺ អរហត្តផល ។

បទថា **សភិយោ** ប្រែថា អ្នកមានវាចាទន់ភ្លន់ ។ បទថា

**សុវចោ** ប្រែថា អ្នកប្រដៅងាយ ។ បទថា **ស្វាគមោ** ប្រែថា អ្នកមកល្អទៅល្អ ។ បទថា **សុប្បដិមុត្តកោ** ប្រែថា អ្នកមានវាចារួចផុតដោយល្អ, អធិប្បាយថា អ្នកមានប្រក្រតីពោលនូវការរួចផុត ។ បទថា **អរណវិហារី** ប្រែថា អ្នកមានប្រក្រតី នៅដោយមេត្តាវិហារៈធម៌ ។

បទថា **សន្តោ** ប្រែថា អ្នកស្ងប់កិលេស ។ បទថា **វិធូមោ** បានដល់ អ្នកប្រាសចាកផ្សែង គឺ មិច្ឆាវិតក្កៈ ។ បទថា **អនីឃោ** ប្រែថា អ្នកមិនមានទុក្ខ ។ បទថា **និរាសោ** ប្រែថា អ្នកមិនមានតណ្ហា ។ បទថា **មុត្តោ** ប្រែថា អ្នករួចផុតចាកភពទាំងពួង ។ បទថា **វិសល្លោ** ប្រែថា អ្នកប្រាសចាក-សរ មានរាគៈជាដើម ។ បទថា **អមមោ** ប្រែថា អ្នកប្រាសចាកការប្រកាន់ថាយើងថាគេ ។ បទថា **អវង្កោ** បានដល់ អ្នកប្រាសចាកការវៀចវេរ មានវៀចវេរកាយជាដើម ។ បទថា **និរូបធិ** ប្រែថា អ្នកលះឧបធិមានកិលេសជាគ្រឿងតាក់តែងជាដើម ។ បទថា **សព្វបបញ្ចខីណោ** ប្រែថា អ្នកអស់ធម៌ជាគ្រឿងយឺតយូរ មានតណ្ហាជាដើម ។ បទថា **ជុតិមា** បានដល់ អ្នករុងរឿងដោយញាណដ៏ប្រសើរបំផុត ។ បទថា **អប្បញ្ញាតោ** បានដល់ ឈ្មោះថាអ្នកមិនប្រាកដ ព្រោះជាអ្នកប្រាថ្នាតិចយ៉ាងក្រៃលែង និងព្រោះជាអ្នកបិទបាំងនូវគុណ ។

បទថា **ទិស្វាបិ ន ច សុជានោ** ( បិដកថា **ទិស្វាបិ ន សុជានោ** ) សេចក្តីថា សូម្បីឃើញក៏មិនអាចដឹងបានច្បាស់ថា មានសីលយ៉ាងនេះ មានធម៌យ៉ាងនេះ មានបញ្ញាយ៉ាងនេះ ។ បទថា **ជានន្តិ តំ យក្ខភូតំ អនេជំ** សេចក្តីថា ក៏អ្នកដែលប្រសើរ រមែងស្គាល់លោកជាអ្នកមាំទាំ គឺអ្នកប្រាសចាកតណ្ហាថា ជាព្រះអរហន្ត ។ បទថា **កល្យាណធម្មំ** បានដល់ អ្នកមានគុណ មានសីលល្អជាដើម ។

បទថា **តស្ស** យោគៈថា ដល់ព្រះកប្បិតកៈមហាថេរៈនោះ ។ បទថា **ឯកយុគំ** បានដល់ សំពត់ ១ គូ ។ បទថា **ទុវេ វា** បានដល់ ឬថា សំពត់ ២ គូ ។ បទថា **មមុទ្ទិសិត្វាន** បានដល់ ឧទ្ទិសដល់ខ្ញុំព្រះអង្គ ។ បទថា **បដិគ្គហិតានិ ច តានិ អស្សុ** សេចក្តីថា និងសំពត់ទាំងនោះ គប្បីជារបស់ដែលព្រះថេរៈនោះទទួលហើយ ។ បទថា **សន្នទ្ធានុស្សំ** បានដល់ អ្នកធ្វើនូវការស្លៀកដណ្តប់សំពត់, អធិប្បាយថា បានសំពត់ហើយ គឺ ស្លៀកដណ្តប់សំពត់ហើយ ។

លំដាប់នោះ ព្រះរាជាទើបត្រាស់សួរដល់ទីលំនៅរបស់ព្រះថេរៈថា :

*ឥឡូវនេះ យើងនឹងទៅជួបព្រះសមណៈនៅក្នុងប្រទេសណា សមណៈនោះគប្បីបន្ទោបង់នូវសេចក្តីសង្ស័យផង នូវសេចក្តីងឿងឆ្ងល់ផង នូវសេចក្តីយល់ខុស ដែលជាសត្រូវរបស់យើងផង ក្នុងថ្ងៃ-*

*នេះបានឬទេ ។*

បណ្តាបទទាំងនោះ បទថា **ភស្មឹ បទេសេ** ប្រែថា ក្នុង-ប្រទេសណា ។ បទថា **យោ មជ្ជ** កាត់បទជា **យោ អជ្ជ** , **ម** អក្សរធ្វើការតបទ ។

លំដាប់នោះ ប្រេតទើបពោលនូវគាថាថា :

*សមណៈនុំះគង់នៅឯប្រទេសឈ្មោះ* ***កបិនច្ចនា*** *មានពួក-ទេវតាច្រើនចោមរោម លោកមាននាមថា* ***សច្ចៈ*** *ជាអ្នកមិនប្រមាទក្នុងធម៌ជាគ្រឿងអស្ចារ្យរបស់ខ្លួន សម្តែងធម្មិកថា ។*

បណ្តាបទទាំងនោះ បទថា **កបិនច្ចនាយំ** បានដល់ ក្នុង-ប្រទេសដែលមានឈ្មោះថា **កបិនច្ចនា** ព្រោះជាទីរាំរបស់ពួកស្វា ។ បទថា **សច្ចនាមោ** បានដល់ អ្នកមាននាមតាមសេចក្តីពិត គឺ អ្នកមាននាមមិនខុសប្លែកដោយគុណនាម មានជាដើមថា អ្នកបានឈានអ្នកមានសីលបរិសុទ្ធ ជាព្រះអរហន្ត ជាអ្នកផុតស្រឡះ ។

កាលប្រេតពោលយ៉ាងនោះហើយ ព្រះរាជាមានព្រះរាជ-បំណង ចង់យាងទៅកាន់សម្នាក់របស់ព្រះថេរៈក្នុងខណៈនោះតែម្តងទើបត្រាស់នូវគាថាថា :

*បើដូច្នោះ ឥឡូវនេះ យើងនឹងទៅធ្វើ ឱ្យសមណៈស្លៀក-ដណ្តប់ ដោយគូសំពត់ អ្នកចូរមើលសំពត់ទាំងនោះ ដែលលោកបាន*

*ទទួលហើយ ឯយើងគប្បីមើលនូវអ្នកស្មៀកសំពត់ ។*

បណ្ដាបទទាំងនោះ បទថា **ករិស្សាមិ** ប្រែថា នឹងធ្វើ ។

លំដាប់នោះ ប្រេតកាលនឹងសម្ដែងថា ព្រះថេរៈរមែងសម្ដែងធម៌ដល់ទេវតាទាំងឡាយ ព្រោះដូច្នេះ វេលានេះ មិនមែនជាវេលាដើម្បីនឹងចូលទៅរកទេ ទើបពោលនូវព្រះគាថាថា :

*ព្រះអង្គកុំចូលទៅរកបព្វជិត ក្នុងកាលមិនគួរឡើយ ខ្ញុំសូម-អង្វរ ធម៌នោះ មិនមែនជាធម៌របស់ព្រះអង្គ ជាស្ដេចលិច្ឆវីទេ ខ្ញុំចូលទៅក្នុងកាលគួរនោះ ទើបឃើញលោកគង់នៅ ក្នុងទីស្ងាត់នោះឯង ។*

បណ្ដាបទទាំងនោះ បទថា **សាធុ** ជានិបាតប្រើក្នុងអត្ថទូលអង្វរ ។ បទថា **ទេវ លិច្ឆវិនេស ធម្មោ** សេចក្ដីថា បពិត្រ-ព្រះបាទលិច្ឆវី ការយាងចូលទៅរកបព្វជិត ក្នុងវេលាដ៏មិនសមគួរនេះ មិនមែនជាទំនៀមរបស់ព្រះអង្គដែលជាព្រះរាជាទេ ។ បទថា **តត្ថេវ** គឺ ក្នុងទីនោះឯង ។

កាលប្រេតពោលយ៉ាងនេះ ព្រះរាជាទ្រង់ទទួលពាក្យហើយ ទ្រង់ក៏បានយាងទៅព្រះរាជនិវេសន៍របស់ព្រះអង្គ បានឱ្យពួកទាសៈកាន់យកសំពត់ ៨ គូ ក្នុងវេលាដ៏សមគួរ ហើយចូលទៅរកព្រះថេរៈក៏បានគង់ប្រថាប់ក្នុងទីដ៏សមគួរ ទ្រង់ធ្វើនូវបដិសណ្ឋារៈហើយត្រាស់ថា បពិត្រលោកដ៏ចម្រើន សូមលោកទទួលនូវសំពត់ ៨ គូនេះ ។

ព្រះថេរៈបានស្តាប់ដូច្នោះហើយ ដើម្បីនឹងសន្ទនាជាមួយ ទើបទូលថា បពិត្រមហារាជ កាលមុនព្រះអង្គទ្រង់មិនបំពេញទាន មានតែបៀត-បៀនពួកសមណព្រាហ្មណ៍ប៉ុណ្ណោះ មានព្រះរាជបំណងនឹងប្រគេននូវសំពត់ដ៏ប្រណីតដូចម្តេចបាន ។ ព្រះរាជាលុះទ្រង់ស្តាប់ដូច្នោះហើយ កាលនឹងត្រាស់ប្រាប់នូវហេតុដល់លោក ទើបបានត្រាស់ប្រាប់ដល់ការដែលប្រេតមក និងរឿងដែលប្រេតជាមួយនឹងព្រះអង្គពោលដល់ព្រះថេរៈ ទើបបានប្រគេននូវសំពត់ហើយឧទ្ទិសដល់ប្រេត ។ ព្រោះហេតុនោះ ប្រេតទើបស្លៀកដណ្តប់សំពត់ដ៏ជាទិព្វ ប្រដាប់តាក់-តែងរាងកាយ ឡើងជិះសេះ ហើយក៏បានមកបង្ហាញខ្លួនក្នុងទីចំពោះមុខព្រះថេរៈ និងព្រះរាជា ។ ព្រះរាជា លុះទ្រង់ឃើញដូច្នោះហើយ ទ្រង់សព្វព្រះរាជហឫទ័យ ។ កើតបីតិសោមនស្សត្រាស់ថា យើងបានឃើញនូវផលនៃកម្មដោយប្រចក្សហើយ ឥឡូវនេះ យើងនឹងមិនធ្វើនូវអំពើអាក្រក់ទៀតឡើយ នឹងធ្វើតែបុណ្យប៉ុណ្ណោះ ដូច្នេះហើយទ្រង់បានធ្វើសាក្សីជាមួយនឹងប្រេតនោះ ។ ហើយប្រេតនោះក្រាបទូលថា បពិត្រស្តេចលិច្ឆវី ចាប់តាំងពីថ្ងៃនេះទៅ ប្រសិនបើព្រះ-អង្គលះបង់នូវអធម៌ ប្រព្រឹត្តនូវធម៌សោត កាលបើដូច្នេះ ខ្ញុំព្រះអង្គនឹងធ្វើជាសាក្សីដល់ព្រះអង្គ ហើយខ្ញុំព្រះអង្គនឹងមកកាន់សម្នាក់របស់ព្រះអង្គ ហើយសូមព្រះអង្គចូរឱ្យបុរសដែលត្រូវឈើអណ្តោតដោត

រួចផុតអំពីឈើអណ្តោត ឱ្យធ្លាប់ទៅ កាលបើដូច្នេះ បុរសនោះក៏នឹងរួចជីវិត ប្រព្រឹត្តនូវធម៌រួចផុតចាកទុក្ខ ហើយព្រះអង្គចូរចូលទៅរកព្រះថេរៈតាមកាលដ៏សមគួរ ស្តាប់ធម៌ បំពេញនូវបុណ្យដូច្នេះ ហើយក៏បានត្រឡប់ទៅវិញ ។

លំដាប់នោះ ព្រះរាជាថ្វាយបង្គំព្រះថេរៈហើយ ក៏បានយាងទៅកាន់ព្រះនគរវិញ ប្រញាប់ឱ្យកោះប្រជុំបរិស័ទលិច្ឆវី ឱ្យអ្នកទាំងអស់នោះអនុញ្ញាត ឱ្យបុរសនោះរួចផុតពីឈើអណ្តោត ហើយបានបញ្ជាពួកពេទ្យថា ចូរព្យាបាលបុរសនេះឱ្យជារោគ ។ ( ក្រោយ-មកព្រះរាជា ) លុះទ្រង់ចូលទៅរកព្រះថេរៈហើយ ទើបត្រាស់សួរថា បពិត្រលោកដ៏ចម្រើន អ្នកដែលធ្វើនូវកម្មដែលជាហេតុទៅកាន់នរកហើយ កំពុងមានជីវិតរស់នៅ តើអាចរួចផុតពីនរកបានដែរឬទេ ? ព្រះថេរៈទូលថា អាចរួចផុតបាន មហាបពិត្រ ប្រសិនបើអ្នកនោះធ្វើបុណ្យឱ្យច្រើន ក៏អាចរួចផុតបាន ទើបឱ្យព្រះរាជាតាំងនៅក្នុងសរណៈ និងសីល ។ ព្រះរាជាតាំងនៅក្នុងសរណៈ និងសីលនោះហើយ តាំងនៅក្នុងឱវាទរបស់ព្រះថេរៈ ក៏បានជាព្រះសោតាបន្ន ។ ចំណែកឯបុរស ដែលត្រូវឈើអណ្តោតដោតនោះ ជាចាករោគហើយ កើតសេចក្តីសង្វេគ ក៏បានបួសក្នុងសម្នាក់ភិក្ខុទាំងឡាយ មិនយូរប៉ុន្មាន ក៏បានសម្រេចព្រះអរហត្ត ។ ព្រះសង្គីតិកាចារ្យទាំងឡាយ

កាលនឹងសម្ដែងនូវរឿងនោះ ទើបបានពោលនូវគាថាទាំងឡាយថា :

*ស្ដេចលិច្ឆវីនោះពោលពាក្យផ្លូវច្នោះហើយ ក៏មានពួកទាសៈចោមរោម យាងចូលទៅក្នុងទីនោះ លុះចូលទៅក្រុងនោះហើយ ទ្រង់យាងចូលទៅក្នុងព្រះរាជនិវេសន៍របស់ព្រះអង្គវិញ ។ លំដាប់នោះ ស្ដេចលិច្ឆវី ធ្វើនូវកិច្ចទាំងឡាយជារបស់គ្រហស្ថ ក្នុងវេលាព្រឹកហើយ ក៏ស្រង់ផង សោយនូវសុគន្ធរសផង រួចបាននូវឱកាស ក៏ជ្រើសរើសនូវគូសំពត់បាន ៨ គូ អំពីហិប ហើយក៏ឱ្យពួកទាសៈកាន់យកតាមទៅ ។ ស្ដេចលិច្ឆវីនោះ ចូលទៅឯប្រទេសនោះ បានឃើញសមណៈនោះ អ្នកមានចិត្តស្ងប់រម្ងាប់ កំពុងវិលត្រឡប់ពីគោចរជាបុគ្គលត្រជាក់ត្រជំ គង់នៅក្រោមម្លប់ឈើ ។ លុះស្ដេចលិច្ឆវីចូលទៅដល់ហើយ ក៏ពោលទៅនឹងសមណៈនោះ រួចហើយក៏សួរនូវការមិនមានអាពាធ និងការនៅជាសុខសប្បាយ ( ហើយទូល ) ថាបពិត្រលោកដ៏ចម្រើន ខ្ញុំជាស្ដេចលិច្ឆវីក្នុងក្រុងវេសាលី អ្នកផងតែងស្គាល់ខ្ញុំថាជាស្ដេចលិច្ឆវីឈ្មោះ* ***អម្ពសក្ខរៈ*** *។ បពិត្រលោកដ៏ចម្រើនសូមលោកទទួលសំពត់ទាំង ៨ គូ របស់ខ្ញុំនេះចុះ បពិត្រលោកដ៏-ចម្រើន ខ្ញុំសូមប្រគេនដល់លោក ខ្ញុំមកក្នុងទីនេះ ព្រោះប្រយោជន៍នោះឯង គួរឱ្យខ្ញុំមានចិត្តត្រេកអរ ។*

**ព្រះថេរៈទូលសួរថា** :

*ពួកសមណព្រាហ្មណ៍ ដែលមកអំពីទីឆ្ងាយ តែងចៀសវាង នូវនិវេសន៍ របស់ព្រះអង្គ បាត្រទាំងឡាយ តែងធ្លាក់បែក សង្ឃាដី ទាំងឡាយ តែងតែរហែកដាច់ដាច ក្នុងនិវេសន៍របស់ព្រះអង្គ ។ ម្យ៉ាងទៀត ពួកសមណៈដទៃ មានក្បាលសំយុងចុះ រមែងធ្លាក់ចុះ ដោយជើងទាំងឡាយ ពោលគឺជើង ( របស់ព្រះអង្គ ) កាលបើ ព្រះអង្គ បៀតបៀននូវបព្វជិតប្រាកដដូច្នោះហើយ ពួកសមណៈរមែង ដល់នូវអំពើដែលព្រះអង្គធ្វើ ។ ព្រះអង្គមិនដែលឱ្យប្រេង សូម្បីដោយ ចុងស្បូវផង មិនប្រាប់ផ្លូវ ដល់អ្នកវង្វេងផ្លូវផង ព្រះអង្គសមាទាន កាន់យកតែអាជ្ញា របស់មនុស្សអន្ធពាល ដោយព្រះអង្គឯង បុគ្គល បែបហ្នឹងឈ្មោះថា កំណាញ់ស្វិតស្វាញ ជាអ្នកមិនសង្រួម ។ កាល បើយ៉ាងហ្នឹង តើព្រះអង្គឃើញហេតុអ្វី តាមដោយហេតុអ្វី បានជា ព្រះអង្គធ្វើនូវការចែករំលែកជាមួយនឹងអាត្មាភាព ។*

**ព្រះរាជាត្រាស់ថា :**

*បពិត្រលោកដ៏ចម្រើន លោកពោលពាក្យណា ខ្ញុំក៏ទទួលស្តាប់ នូវពាក្យនោះ ។*

**ព្រះថេរៈទូលថា :**

*ព្រះអង្គធ្វើពួកសមណព្រាហ្មណ៍ឱ្យវង្វេងហើយ ។*

**ព្រះរាជាត្រាស់ថា :**

*បពិត្រលោកដ៏ចម្រើន ខ្ញុំជាបុគ្គលត្រូវការនឹងលេង មិនមានចិត្តប្រទូស្តឡើយ ខ្ញុំធ្វើអំពើអាក្រក់នេះមែនហើយ បុគ្គលក្មេងក្តីកម្លោះក្តី ដែលមានទ្រព្យតិច តែងទទួលទុក្ខ ព្រោះតែសទ្ធាបដោយការលេង ជាបុគ្គលមានចំណែកនៃភាពជាអ្នកអាក្រាត អ្វីដែលដល់នូវទុក្ខយ៉ាងធ្ងន់ ជាងភាពអាក្រាតនោះ របស់ប្រេតនោះ ។ បពិត្រលោកដ៏ចម្រើន ខ្ញុំឃើញប្រេតនោះគួរឱ្យកើតសង្វេគទើបឱ្យទាន ព្រោះសង្វេគនោះជាបច្ច័យ បពិត្រលោកដ៏ចម្រើន សូមលោកទទួលសំពត់ទាំង ៨ គូ ចុះ ទក្ខិណាទាន ( ដែលខ្ញុំប្រគេនហើយ ) នេះ សូមឱ្យបានសម្រេចដល់យក្សចុះ ។*

**ព្រះថេរៈទូលថា :**

*ការមិនចេះអស់ ចូរមានដល់ព្រះអង្គ កាលឱ្យទាន ដែលអ្នកប្រាជ្ញ មានព្រះពុទ្ធជាដើម ទ្រង់សរសើរហើយ ដោយប្រការដ៏ច្រើនដោយពិត ឯអាត្មានឹងទទួលសំពត់របស់ព្រះអង្គទាំង ៨ គូ សូមទក្ខិណាទានសម្រេចដល់យក្សចុះ ។*

*លំដាប់នោះឯង ស្តេចលិច្ឆវីនោះ ក៏ជម្រះសំអាត ហើយប្រគេនសំពត់ ៨ គូ ដល់ព្រះថេរៈ ព្រះថេរៈបានទទួលសំពត់ ៨ គូនោះហើយ ស្តេចលិច្ឆវី បានឃើញនូវយក្សស្លៀកដណ្តប់សំពត់ ។ ស្តេចលិច្ឆវី បានទតឃើញប្រេតនោះ មានខ្លួនប្រស់ព្រំដោយខ្លឹមចន្ទន៍*

*ហើយ ឡើយជិះសេះអាជានេយ្យ មានរូបដ៏ប្រសើរ មានគ្រឿងប្រដាប់គ្រប់គ្រាន់ មានសំពត់ស្លៀកដណ្តប់ដ៏ស្អាត មានបរិស័ទចោមរោម ដល់នូវឫទ្ធិជាយក្សយ៉ាងធំ ។ លុះស្តេចលិច្ឆវីនោះទតឃើញប្រេតនោះហើយ ក៏មានព្រះហឫទ័យសោមនស្ស ខ្ពស់-អណ្តែតឡើង មានព្រះហឫទ័យត្រេកអរ មានសភាពដ៏ប្រសើរល្អមានចក្ខុ ព្រោះបានឃើញនូវកម្មមានផលដ៏ធំផង ធ្វើឱ្យជាក់ច្បាស់នូវប្រេតដែលខ្លួន បានឃើញដោយខ្លួនឯង ។ ស្តេចលិច្ឆវី បានចូលទៅរកប្រេតនោះហើយ មានព្រះបន្ទូលថា យើងនឹងឱ្យទាន ដល់ពួកសមណព្រាហ្មណ៍ ឯវត្ថុបន្តិចបន្តួច ដែលយើងមិនត្រូវឱ្យ មិនមានទេម្នាលយក្ស អ្នកមានឧបការៈដល់យើងច្រើនណាស់ ។*

**ប្រេតនោះក្រាបទូលថា :**

*បពិត្រស្តេចលិច្ឆវី ព្រះអង្គបានឱ្យទានទាំងឡាយចំពោះតែបច្ច័យ ១ ការឱ្យទាននេះ មិនមែនសោះសូន្យឡើយ ខ្ញុំជាអមនុស្សធ្វើជាសក្សីជាមួយព្រះអង្គជាមនុស្ស ។*

**ព្រះរាជាត្រាស់ថា :**

*អ្នកជាគតិ ជាផៅពង្ស ជាការនាំមុខ និងជាមិត្តសម្លាញ់ និងជាទេវតារបស់យើង យើងសូមប្រណម្យអញ្ជលីចំពោះអ្នក ម្នាលយក្ស យើងចង់ឃើញអ្នកម្តងទៀត ។*

**ប្រេតក្រាបទូលថា :**

*បើព្រះអង្គជាអ្នកមិនមានសទ្ធា ជាបុគ្គលកំណាញ់ មានចិត្តវិបត្តិហើយ ព្រះអង្គបានឃើញខ្ញុំដោយហេតុនោះឯង ទុកជាខ្ញុំឃើញក៏មិននិយាយរកចំពោះព្រះអង្គដែរ ។ បើព្រះអង្គជាអ្នកគោរពក្នុងធម៌ត្រេកអរក្នុងទាន មានអត្តភាពជាអ្នកសង្គ្រោះ ជាអណ្តូងរបស់ពួកសមណព្រាហ្មណ៍ យ៉ាងនេះ ទើបព្រះអង្គអាចឃើញខ្ញុំបាន ។ បពិត្រ-ព្រះអង្គដ៏ចម្រើន ខ្ញុំឃើញហើយនិយាយ ចំពោះព្រះអង្គថា ព្រះអង្គចូរដោះបុរសនេះ អំពីឈើអណ្តោតឱ្យឆាប់ទៅ យើងបានធ្វើជាសាក្សីព្រោះហេតុតែបុរសណា យើងរមែងដឹង ព្រោះហេតុតែបុរស ដែលគេដោតដោយឈើអណ្តោត យើងទាំងនោះបានធ្វើជាសាក្សីដល់គ្នានិងគ្នា ។ បើបុរសដែលដោតលើឈើអណ្តោតនេះ បានរួចឆាប់គប្បីប្រព្រឹត្តធម៌ដោយគោរព ទើបបុរសនោះ រួចអំពីនរកបានកម្មនោះនឹងទៅជាកម្មដែលបុរសនោះគប្បីទទួលក្នុងភពដទៃ ។ សូម-ព្រះអង្គ ស្តេចចូលទៅរក* ***កប្បិតកភិក្ខុ*** *ហើយចាត់ចែងភោជនាហារក្នុងកាលដ៏គួរ ជាមួយនឹងលោក ហើយអង្គុយចំពោះមុខលោកដោយព្រះអង្គឯង ហើយចូរសួរលោកចុះ លោកគង់នឹងប្រាប់សេចក្តីនោះដល់ព្រះអង្គ ។ សូមព្រះអង្គ ចូលទៅរកភិក្ខុនោះហើយសួរចុះព្រោះភិក្ខុនោះត្រូវការបុណ្យ មិនមានចិត្តប្រទូស្តទេ ភិក្ខុនោះដឹង*

*យ៉ាងណា ក៏នឹងប្រាប់នូវធម៌ទាំងអស់យ៉ាងនោះ ដែលព្រះអង្គស្ដាប់ហើយក្ដី មិនដែលស្ដាប់ហើយក្ដី កាលបើព្រះអង្គស្ដាប់ លោកនឹងសម្ដែងប្រាប់នូវធម៌ផង នូវសុគតិផង ។*

*ស្ដេចលិច្ឆវីនោះ ចរចានឹងគ្នាក្នុងទីស្ងាត់ ក្នុងទីនោះហើយធ្វើឱ្យជាសាក្សី ជាមួយនឹងអមនុស្ស ហើយចៀសចេញទៅ កាន់សម្នាក់នៃស្ដេចលិច្ឆវីទាំងឡាយ លំដាប់នោះ ស្ដេចបានពោលចំពោះបរិស័ទដែលមកប្រជុំគ្នា ។*

**ព្រះរាជាត្រាស់ថា :**

*អ្នកដ៏ចម្រើនទាំឡាយ ចូរស្ដាប់ពាក្យយើងមួយម៉ាត់ យើងនឹងបានទូវពរ យើងបានទូវប្រយោជន៍ បុរសដែលត្រូវដោតដោយឈើអណ្ដោត ជាអ្នកមានកម្មអាក្រក់ មានអាជ្ញាតាំងទុកហើយ មានសភាពជាមនុស្សជាប់ដោយអាជ្ញា ។ បុរសដែលត្រូវឈើអណ្ដោតដោតហើយ មិនរស់ មិនស្លាប់ អស់ ២០ រាត្រីប៉ុណ្ណោះ ឥឡូវនេះយើងនឹងដោះបុរសនោះ សូមសង្ឃ[១] យល់តាមសេចក្ដីគាប់ចិត្ត ( របស់យើង ) ចុះ ។*

**ប្រេតក្រាបទូលថា :**

១= សំដៅយកពួកក្រុមស្ដេចលិច្ឆវី

សូមព្រះអង្គដោះលែងបុរសដែលជាប់ដោយឈើអណ្តោតនោះផង បុរសដទៃផងឱ្យចាប់ទៅ នរណាពោលនឹងព្រះអង្គដែលកំពុងធ្វើដូច្នោះ ព្រះអង្គយល់យ៉ាងណា ចូរធ្វើយ៉ាងនោះចុះ ឥឡូវសង្ឃ-យល់ព្រមតាមសព្វព្រះទ័យហើយ ។

ស្តេចនោះបានចូលទៅប្រទេសនោះ ហើយបានដោះលែងបុរសដែលគេដោត ដោយឈើអណ្តោតមួយរំពេច ហើយប្រាប់ទៅបុរសនោះថា នែសម្លាញ់មានធុរៈស្មើ ចូរអ្នកកុំភ័យឡើយ ហើយក៏ប្រគល់ឱ្យទៅពួកពេទ្យអ្នកថែរក្សា ។ ទើបស្តេចលិច្ឆវីយាងចូលទៅរក **កប្បិតកភិក្ខុ** ហើយចាត់ចែងភោជនាហារ ក្នុងកាលដ៏គួរ មួយអន្លើ-និង**កប្បិតកភិក្ខុ**នោះ ស្តេចលិច្ឆវីអ្នកត្រូវការដោយហេតុ ទើបចូលទៅគង់ជិតហើយ សួរ**កប្បិតកភិក្ខុ**នោះ ដែលអង្គុយនៅទីនោះដោយព្រះឱស្ឋព្រះអង្គឯងថា បុរសដែលគេដោតដោយឈើអណ្តោត ( ហ្នឹង ) ជាអ្នកធ្វើកម្មអាក្រក់ ត្រូវគេដាក់អាជ្ញាហើយ មានសភាពជាអ្នកជាប់ដោយអាជ្ញា បុរសដែលត្រូវឈើអណ្តោតដោតហើយមិនរស់ មិនស្លាប់ អស់ **២០** រាត្រីប៉ុណ្ណោះ ។ បពិត្រលោកដ៏ចម្រើន ឥឡូវនេះ បុរសនោះ ខ្ញុំបានដោះលែងតាមពាក្យយក្សនុ៎ះហើយ ហេតុតិចតួច ដែលបុរសនោះ មិនគប្បីទៅនរកមានដែរឬ ។ បពិត្រ-លោកដ៏ចម្រើន បើមានហេតុ គឺហេតុដែលគួរជឿបាន សូមលោក-

ប្រាប់ដល់យើង យើងស្តាប់ហើយ យើង ( នឹងជឿតាមពាក្យរបស់-លោក ) ការវិនាសនៃកម្មទាំងនោះ ក៏មិនមាន សេចក្តីវិនាសរបស់បុរសនោះ ក៏មិនមាន ក្នុងទីនេះ ព្រោះមិនបានទទួលនូវផល ។ បើបុរសនោះ គប្បីប្រព្រឹត្តនូវធម៌ទាំងឡាយ មិនប្រមាទ ទាំងយប់ទាំងថ្ងៃ ដោយគោរព ទើបបុរសនោះ គប្បីរួចចាកនរកនោះបាន កម្មនោះនឹងជាកម្មដែលត្រូវទទួលក្នុងភពដទៃ ។ ប្រយោជន៍របស់បុរសនុ៎ះ ខ្ញុំបានដឹងហើយ បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោក-ម្ចាស់អនុគ្រោះខ្ញុំ ក្នុងកាលឥឡូវនេះ បពិត្រលោកមានប្រាជ្ញាដ៏ក្រាស់ សូមលោកម្ចាស់ ទូន្មានប្រៀនប្រដៅខ្ញុំ គួរកុំឱ្យខ្ញុំទៅនរកបាន ។

**កប្បិតកភិក្ខុទូលថា :**

ព្រះអង្គមានព្រះហឫទ័យជ្រះថ្លា ចូរដល់នូវព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជាសរណៈ ក្នុងថ្ងៃនេះឯង មួយទៀត ព្រះអង្គចូរសមាទាននូវសិក្ខាបទទាំង ៥ កុំឱ្យដាច់ធ្លុះធ្លាយឡើយ ។ ចូរព្រះអង្គវៀរចាកបាណាតិបាតឱ្យឆាប់ ចូរវៀរចាកទ្រព្យដែលគេមិនឱ្យក្នុងលោកចេញ កុំសោយនូវទឹកស្រវឹងផង កុំកុហកផង ចូរត្រេកអរនឹងមហេសីរបស់ព្រះអង្គផង ។ សូមព្រះអង្គសមាទាននូវឧបោសថសីលដ៏ប្រសើរ ប្រកបដោយអង្គ ៨ នេះ ជាកុសល ឱ្យផលជាសុខចុះ ។

សូមព្រះអង្គប្រទាននូវចីវរប្បច្ច័យ បិណ្ឌបាតប្បច្ច័យ សេនា-

សនប្បច្ច័យ បាយនិងទឹក បង្អែម សំពត់ សេនាសនៈទាំងឡាយ ចំពោះពួកបុគ្គលអ្នកមានចិត្តត្រង់ បុណ្យរមែងចម្រើន សព្វ ៗ កាល មួយទៀត សូមព្រះអង្គញ៉ាំងពួកភិក្ខុអ្នកបរិបូណ៌ដោយសីល ប្រាស-ចាករាគៈ ជាពហុស្សូត ឱ្យឆ្អែតដោយបាយនិងទឹក បុណ្យរមែងចម្រើនសព្វ ៗ កាល ។ កាលបើបុរសនោះ ប្រព្រឹត្តនូវធម៌ទាំងឡាយ មិនប្រមាទទាំងយប់ទាំងថ្ងៃ ដោយគោរពយ៉ាងនេះហើយ ទើបរួចចាកនរកបាន កម្មនោះនឹងទៅជាកម្មដែលត្រូវទទួលក្នុងភពដទៃ ។

**( ស្ដេចលិច្ឆវីមានព្រះឱង្ការថា ) :**

ខ្ញុំមានចិត្តជ្រះថ្លា ដល់នូវព្រះពុទ្ធ ព្រះធម៌ ព្រះសង្ឃ ជាសរណៈក្នុងថ្ងៃនេះឯង មួយទៀត ខ្ញុំសមាទាននូវសិក្ខាបទទាំង ៥ មិនឱ្យដាច់ធ្លុះធ្លាយ ខ្ញុំវៀរចាកបាណាតិបាតយ៉ាងឆាប់ ខ្ញុំវៀរចាកអទិន្នាទានក្នុងលោក ខ្ញុំមិនផឹកទឹកស្រវឹង មិននិយាយពាក្យមុសា ខ្ញុំត្រេកអរចំពោះតែប្រពន្ធរបស់ខ្លួន ។ ខ្ញុំសមាទាននូវឧបោសថសីលដ៏ឧត្តមប្រកបដោយអង្គ ៨ ប្រការដ៏ប្រសើរនេះ ជាកុសល ឱ្យផលជាសុខ ។

ខ្ញុំឱ្យនូវចីវរប្បច្ច័យ បិណ្ឌបាតប្បច្ច័យ ទីដេក ទីអង្គុយ បាយទឹក បង្អែម សំពត់ សេនាសនៈទាំងឡាយ ចំពោះពួកភិក្ខុ អ្នកបរិបូណ៌ដោយសីល ប្រាសចាករាគៈ ជាពហុស្សូត ខ្ញុំជាអ្នកត្រេកអរក្នុង-សាសនា របស់ព្រះពុទ្ធទាំងឡាយ មិនកម្រើកឡើយ ។

*( បណ្ដាពួកឧបាសក ) ក្នុងក្រុងវេសាលី ស្ដេចលិច្ឆវីព្រះនាម* ***អម្ពសក្ខរៈ*** *ជាឧបាសកម្នាក់ ប្រាកដដូច្នោះ ក្នុងក្រុងវេសាលី ជាអ្នកមានសទ្ធាផង មានចិត្តទន់ភ្លន់ផង ជាអ្នកធ្វើនូវឧបការៈ ទំនុកបម្រុងភិក្ខុសង្ឃដោយគោរព ក្នុងកាលនោះផង ។ បុរសដែលត្រូវគេដោតដោយឈើអណ្ដោត ឥតមានរោគ មានតែសិរីនិងសុខ បានចូលទៅកាន់ផ្នួស ជនទាំងពីរនាក់ ក៏បានសម្រេចនូវសាមញ្ញផលទាំងឡាយ ( តាមសមគួរ ) ព្រោះអាស្រ័យនឹងព្រះថេរៈឈ្មោះ* ***កប្បិតកៈ*** *ដ៏ឧត្តម ។ ការសេពគប់នឹងពួកសប្បុរស អ្នកស្ងប់ អ្នកដឹងដូច្នេះ រមែងមានផលច្រើន* ***បុរសដែលដេកលើឈើអណ្ដោត*** *បានសម្រេចនូវផលដ៏ប្រសើរ* ***ឯស្ដេចលិច្ឆវីអម្ពសក្ខរៈ*** *បានសម្រេចផលតូច ( សោតាបត្តិផល ) ។*

បណ្ដាបទទាំងនោះ បទថា **ខាសុបគច្ឆិត្ត** ( បិដកថា **ខាសុ-បគញ្ឆិត្ត** ) ប្រែថា ចូលទៅកាន់ទីប្រថាប់ ។ បទថា **គិហិកិច្ចានិ** បានដល់ កិច្ចនៃកំណប់ទ្រព្យដែលអ្នកគ្រប់គ្រងផ្ទះគប្បីធ្វើ ។ បទថា **វិចេយ្យ** បានដល់ គប្បីជ្រើសរើសកាន់យកសំពត់ល្អ ៗ ។ បទថា **បដិក្កន្តំ** ប្រែថា ត្រឡប់ពីមកបិណ្ឌបាត ។ ព្រោះហេតុនោះ លោកទើបពោលថា ត្រឡប់មកពីគោចរ ។ បទថា **អវោច** សេចក្ដីថា បានត្រាស់នូវពាក្យជាដើមថា បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំជា-

ស្តេចលិច្ឆវីក្នុងក្រុងវេសាលី ។

បទថា **វិនាលយន្តិ** ប្រែថា រមែងរហែកដាច់ដាច ។ បទថា **បានក្ខរាវិកាហិ** ( បិដកថា **បានក្ខរាវិកាហិ** ) បានដល់ ដោយជ្រញ់ គឺជើង ។ បទថា **បាតយន្តិ** ( បិដកថា **បាដិយន្តិ** ) ប្រែថា រមែងធ្លាក់ចុះ ។

បទថា **តិណេន** ប្រែថា សូម្បីដោយចុងស្មៅ ។ បទថា **មូឡ្ហស្ស មគ្គំបិ ន បាវទាសិ** សេចក្តីថា ព្រះអង្គមិនបានប្រាប់សូម្បីនូវផ្លូវដល់អ្នកវង្វេងផ្លូវ ដោយគិតថា បុរសនេះ ចូរវិលវល់ដើរត្រឡប់ទៅមក ដោយអាការយ៉ាងនេះ ។ មែនពិត ព្រះរាជានេះជាអ្នកចូលចិត្តលេង ។ បទថា **សយមាទិយាសិ** សេចក្តីថា ខ្លួនឯងដណ្តើមយកឈើច្រត់អំពីដៃរបស់មនុស្សខ្វាក់ភ្នែក ។ បទថា **សំវិភាគំ ករោសិ** សេចក្តីថា ទ្រង់បែងចែកនូវចំណែកអំពីវត្ថុដែលខ្លួនបរិភោគឱ្យទៅ ។

បទថា **បច្ចេមិ ភន្តេ យំ ត្វំ វទេសិ** នេះ ព្រះរាជាទ្រង់សម្តែងថា បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំដឹងចំពោះពាក្យដែលលោកពោលដោយន័យជាដើមថា បាត្របែក ទង្វើទាំងអស់ហ្នឹង ខ្ញុំបានធ្វើ និងឱ្យអ្នកដទៃធ្វើ ។ បទថា **ឯតម្បិ** ទង្វើនេះ សូម្បីខ្ញុំធ្វើក៏ដោយបំណងដើម្បីនឹងលេង ( តែប៉ុណ្ណោះ ) ។

បទថា **ខិឌ្ឌា** ប្រែថា ដោយការលេង ។ បទថា **បសវិត្វា** ប្រែថា សន្សំហើយ ។ បទថា **ទេវេតិ** ប្រែថា រមែងសោយ ។ បទថា **អសមត្ថភោគី** ( បិដកថា **អប្បមត្ថភោគី** ) ប្រែថា អ្នកមានភោគៈមិនបរិបូណ៌ ។ ដើម្បីនឹងសម្តែងថា ប្រេតជាអ្នកមានភោគៈមិនបរិបូណ៌នោះឯង ទើបត្រាស់ថា ក្មេងកំលោះជាដើម ។ បទថា **នគ្គនិយស្ស** ប្រែថា ជាអ្នកអាក្រាត ។ បទថា **កឹសុ តតោ ទុក្ខតរស្ស ហោតិ** សេចក្តីថា ក៏ទុក្ខអ្វីដែលជាទុក្ខជាងភាពអាក្រាតរបស់ប្រេតនោះ ។ បទថា **យក្ខស្សិមាគច្ឆន្តុ ទក្ខិណាយោ** សេចក្តីថា សូមទក្ខិណាទាន គឺសំពត់ដែលខ្ញុំប្រគេននេះ ចូរសម្រេចដល់ប្រេត ។

បទថា **ពហុធា បសដ្ឋំ** សេចក្តីថា ដែលបណ្ឌិតទាំងឡាយមានព្រះពុទ្ធជាដើម ពណ៌នាទុកដោយប្រការជាច្រើន ។ បទថា **អក្ខយធម្មមត្ថុ** ប្រែថា សូមទានវត្ថុនេះ ចូរកុំឱ្យមានការអស់ទៅ ។ បទថា **អាចមយិត្វា** បានដល់ ខ្ពុរមាត់មុនលាងដៃ និងលាងជើង ។

បទថា **ចន្ទនសារលិត្តំ** ប្រែថា ប្រោះព្រំដោយខ្លឹមចន្ទន៍ ។ បទថា **ឧឡារវណ្ណំ** ប្រែថា មានរូបដ៏ប្រសើរ ។ បទថា **បរិវារិតំ** ប្រែថា ចោមរោមដោយបរិវារដែលមានការប្រព្រឹត្តតាម ។ បទថា **យក្ខមហិទ្ធិបត្តំ** បានដល់ អ្នកមានយក្ខឫទ្ធិ គឺ ទេវឫទ្ធិដ៏ធំ ។ បទថា

**តមេនមទោច** កាត់បទជា **តមេនំ អទោច** បានត្រាស់ពាក្យនេះនោះ ។

បទថា **ឯកទេសំ អទាសិ** លោកពោលសំដៅដល់ ការឱ្យសំពត់ដែលជាផ្នែកមួយក្នុងបណ្ដាបច្ច័យទាំង ៤ ។ បទថា **សក្ខី** បានដល់ ភាពជាសាក្សី ។

បទថា **នមាសិ** កាត់បទជា **មេ អសិ** ។ បទថា **ទេវតា មេ** ( បិដកថា **ទេវតាសិ** ) មានសេចក្ដីថា អ្នកជាទេវតារបស់យើង ។

បទថា **វិប្បដិបន្នចិត្តោ** បានដល់ អ្នកមានចិត្តប្រព្រឹត្តតាមមិច្ឆាទិដ្ឋិ, អធិប្បាយថា អ្នកលះបង់នូវបដិបទាដ៏ត្រឹមត្រូវ ហើយប្រព្រឹត្តនូវបដិបទាដែលមិនត្រឹមត្រូវ ។ បទថា **យតោ និទានំ** បានដល់ មានអ្វីជានិមិត្ត គឺ មកកាន់សម្នាក់របស់អ្នកណាជាហេតុ ។

បទថា **សំវិភជិត្វា** ( បិដកថា **សំវិភជិត្វាន** ) ប្រែថា ធ្វើការចែកទាន ។ បទថា **សយំ មុខេន ឧបនិសជ្ជ បុច្ឆ** សេចក្ដីថា ព្រះអង្គចូរកុំបញ្ជូនអ្នកដទៃទៅ ចូរចូលទៅអង្គុយសួរចំពោះមុខតែ-ម្ដង ។

បទថា **សន្និសសិន្នំ** ប្រែថា អង្គុយប្រជុំគ្នា ។ បទថា **លភិស្សាមិ អត្ថំ** សេចក្ដីថា យើងនឹងបាននូវប្រយោជន៍ដែលយើងប្រាថ្នា ។ បទថា **បណិហិតទណ្ឌោ** ( បិដកថា **បណិតទណ្ឌោ** )

ប្រែថា បានតាំងអាជ្ញាក្នុងខ្លួនទុក ។ បទថា **អនុសត្តរូបោ** បានដល់ មានសភាពជាប់ទាក់ទងនឹងព្រះរាជា ។ បទថា **វីសតិរត្តិមត្តា** សេចក្តីថា កន្លងទៅប្រមាណ ២០ រាត្រី ។ បទថា **តាហំ** កាត់បទជា **តំ អហំ** ។ បទថា **យថា មតី** ប្រែថា តាមសេចក្តីគាប់ចិត្ត របស់យើង ។

បទថា **ឯតញ្ច អញ្ញញ្ច** សេចក្តីថា បុរសនេះដែលត្រូវគេ ដោតដោយឈើអណ្តោត និងបុរសដទៃដែលត្រូវគេដាក់រាជអាជ្ញា ។ បទថា **លាហុំ បមុញ្ច** ប្រែថា ដោះលែងឱ្យឆាប់ទៅ ។ បទថា **កោ តំ វទេថ ច តថា ករោន្តំ** សេចក្តីថា នរណាក្នុងដែនវជ្ជីនេះ គប្បី-ប្រាប់អ្នកធ្វើនូវកម្មដ៏ត្រឹមត្រូវនោះថា ចូរកុំដោះលែង, អធិប្បាយថា ទោះបីនរណាម្នាក់ ក៏មិនបានដើម្បីពោលយ៉ាងនោះ ។

បទថា **តិកិច្ឆកានញ្ច** បានដល់ អ្នកព្យាបាល ។

បទថា **យក្ខស្ស វចោ** បានដល់ ពាក្យរបស់ប្រេត, លោក-សម្តែងថា បពិត្រលោកម្ចាស់ដ៏ចម្រើនខ្ញុំបានធ្វើយ៉ាងនោះ តាមពាក្យ របស់ប្រេតនោះ ។

បទថា **ធម្មានិ** បានដល់ ធម៌ គឺ បុណ្យដែលអាចគ្របសង្កត់ នូវកម្មអាក្រក់ ដែលបានធ្វើទុកក្នុងកាលមុន ។ បទថា **កម្មំ សិយា អញ្ញត្រ វេទនីយំ** បានដល់ កម្មដែលឱ្យផលឱ្យកើតក្នុងកម្មអាក្រក់

នោះ ឈ្មោះថា ជាអហោសិកម្ម ចំណែកឯកម្មដែលឱ្យផល ឱ្យកើត ក្នុងភពត ៗ ទៅ រមែងជាផលដែលនឹងគប្បីសោយក្នុងភពដទៃ គឺ ភពត ៗ ទៅ កាលបើនៅប្រព្រឹត្តទៅក្នុងសង្សារវដ្ត ។

បទថា **ឥមញ្ច** ព្រះថេរៈពោលព្រោះធ្វើនូវសេចក្ដីអធិប្បាយ-ថា ពាក្យដែលខ្លួនពោល ជិតឬប្រចក្សដល់សិក្ខានោះ ។ បទថា **អរិយំ អដ្ឋង្គវរេនុបេតំ** ( បិដកថា **អដ្ឋង្គវរំ ឧបេតំ** ) សេចក្ដីថា ឧបោសថសីលដ៏ឧត្ដម ដែលចូលដល់ គឺ ប្រកបដោយអង្គ ៨ មាន-ចេតនាវៀរចាកបាណាតិបាតជាដើម ឈ្មោះថាប្រសើរ ពោះអត្ថថា បរិសុទ្ធ ។ បទថា **កុសលំ** បានដល់ មិនមានទោស ។ បទថា **សុខិន្ទ្រិយំ** ប្រែថា មានសុខជាផល ។

បទថា **សតា បុញ្ញំ បវឌ្ឍតិ** សេចក្ដីថា កាលបុគ្គលធ្វើបុណ្យម្ដងហើយគិតថា បុណ្យប៉ុណ្ណេះមិនទាន់គ្រប់គ្រាន់ទេ ហើយទើបបំពេញនូវសុចរិតត ៗ ទៅទៀត បុណ្យរបស់គេ រមែងចម្រើនសព្វ-កាល ឬកាលគេបំពេញនូវសុចរិតត ៗ មកទៀត ផលបុណ្យ គឺ បុណ្យរមែងចម្រើន គឺ រីតតែពេញបរិបូណ៌ឡើង ៗ ។

កាលព្រះថេរៈពោលយ៉ាងនេះហើយ ព្រះរាជាមានព្រះ-ហឫទ័យតក់ស្លុតអំពីទុក្ខ ក្នុងអបាយ មានសេចក្ដីជ្រះថ្លាចំពោះព្រះរតនត្រ័យនិងបុញ្ញកម្មកាន់តែក្រៃលែងឡើង, បន្ទាប់ពីនោះ ទើប-

សមាទាន សរណៈនិងសីល ទើបត្រាស់នូវពាក្យជាដើមថា ខ្ញុំសូមដល់នូវព្រះពុទ្ធជាសរណៈក្នុងថ្ងៃនេះឯង ។

បណ្ដាបទទាំងនោះ បទថា **ឯតេនិសោ** បានដល់ មានសភាពដូចដែលបានពោលរួចមកហើយនេះ ។ បទថា **វេសាលិយំ អញ្ញ-តរោ ឧបាសកោ** សេចក្ដីថា ជាឧបាសកម្នាក់ ក្នុងបណ្ដាឧបាសកជាច្រើនពាន់នាក់ក្នុងក្រុងវេសាលី ។ បទថា **សទ្ធោ** ជាដើម លោកពោលដើម្បីនឹងសម្ដែងនូវសេចក្ដីដែលព្រះបាទអម្ពសក្ខរៈនោះមានដោយប្រការដទៃចាកភាវៈដែលមានក្នុងកាលមុន ព្រោះអាស្រ័យកល្យាណមិត្ត ។ មែនពិតក្នុងកាលមុន ព្រះបាទអម្ពសក្ខរៈនោះជាអ្នកមិនមានសទ្ធា ជាមនុស្សអាក្រក់ ជេរប្រទេចពួកភិក្ខុទាំងឡាយនិងមិនមែនជាឧបដ្ឋាករបស់សង្ឃទេ ប៉ុន្តែឥឡូវនេះ ជាអ្នកមានសទ្ធា ទន់ភ្លន់ និងឧបដ្ឋាកភិក្ខុសង្ឃក្នុងកាលនោះ ដោយគោរព ។ បណ្ដាបទទាំងនោះ បទថា **ការការោ** បានដល់ អ្នកធ្វើនូវឧបការៈ ។

បទថា **ឧភោបិ** បានដល់ ជនទាំងពីរនាក់ គឺ បុរសដែលត្រូវឈើអណ្ដោតដោត និងព្រះរាជា ។ បទថា **សាមញ្ញផលានិ អជ្ឈគុំ** បានដល់ អ្នកសម្រេចនូវសាមញ្ញផលតាមសមគួរ ។ ដើម្បីនឹងសម្ដែងតាមសមគួរ លោកទើបពោលនូវពាក្យនេះទុកថា បុរសដែលត្រូវឈើអណ្ដោតដោត បានសម្រេចព្រះអរហត្តផល, ចំណែកឯព្រះបាទ-

អម្ពសក្ខរៈបានសម្រេចផលតូចជាង ដូច្នេះ ។ បណ្ដាបទទាំងនោះ បទថា **ផលំ កនិដ្ឋំ** លោកពោលសំដៅដល់សោតាបត្តិផល តែ-ក្នុងទីនេះ កាលពោលដោយអត្ថ ពាក្យដែលលោកមិនបានចែកទុក អាចយល់បានដោយងាយ ។

**ព្រះកប្បិតកៈ** បានទៅដល់ក្រុងសាវត្ថី ដើម្បីថ្វាយបង្គំព្រះសាស្ដា ទើបបានក្រាបទូលនូវសេចក្ដីដែលព្រះរាជា ប្រេត, និងខ្លួន បានពោលហើយយ៉ាងនេះ ចំពោះព្រះដ៏មានព្រះភាគ ។ ព្រះសាស្ដា ទ្រង់ប្រារព្ធនូវរឿងនោះ ឱ្យជាអត្ថុប្បត្តិហេតុហើយ សម្ដែងធម៌ដល់បរិស័ទដែលបានមកជួបជុំគ្នាហើយ ទេសនានោះ បានជាប្រយោជន៍ដល់មហាជនដោយប្រការ ដូច្នេះ ។

## ( ចប់រឿងអម្ពសក្ខរប្រេតទី ១ )

# ២-រឿងសេរីសកប្រេត

( បិដកលេខ ៥៦, ទំ. ១១១ + បិដក ៥៥, ទំ. ១៧៦ និងអដ្ឋកថា )

ការប្រជុំនៃយក្ខ និងពាណិជទាំងឡាយ អ្នកទាំងឡាយចូរ-ស្តាប់ ។ បេ ។

រឿង**សេរីសកប្រេត**នេះ មានពាក្យផ្តើមថា **សុណោថ យក្ខស្ស ច វណិជាន ច** ដូច្នេះ ។ ព្រោះហេតុដែលរឿងនោះ មិនវិសេសជាងរឿងសេរីសកវិមាន ព្រោះដូច្នោះ ពាក្យដែលគួរនឹងពោលក្នុងអត្ថុប្បត្តិហេតុ និងក្នុងគាថានោះ ព្រះអដ្ឋកថាចារ្យ បានពោលទុកហើយក្នុង **អដ្ឋកថាវិមានវត្ថុ** ឈ្មោះ **បរមត្ថទីបនី** ព្រោះដូច្នោះ គប្បីជ្រាបតាមន័យ ដែលបានពោលទុកហើយ ក្នុងអដ្ឋកថា-វិមានវត្ថុនោះចុះ ។

សេចក្តីក្នុង **អដ្ឋកថាបេតវត្ថុ**មានប្រមាណប៉ុណ្ណេះ ។

## ចំណែកសេចក្តីពិស្តារនៃរឿងនេះ
## គប្បីជ្រាបតាមន័យអដ្ឋកថាវិមានវត្ថុ ដូចតទៅនេះ :

សេរីសកវិមាន មានគាថាថា **សុណោថ យក្ខស្ស ច**

**ទារណិជាន ៥** ជាដើម ។ សេរីសកវិមាននោះ តើកើតឡើងដូចម្ដេច ?

កាលព្រះដ៏មានព្រះភាគ ទ្រង់រំលត់ខន្ធបរិនិព្វានហើយ **ព្រះ-កុមារកស្សបៈ** មួយអន្លើដោយ**ភិក្ខុប្រមាណ ៥០០ រូប** ទៅដល់**សេតព្យនគរ** បានដោះព្រះបាទបាយាសិដែលចូលទៅរកខ្លួនក្នុងនគរនោះ រួចផុតពីមិច្ឆាទិដ្ឋិ ឱ្យតាំងនៅក្នុងសម្មាទិដ្ឋិ ចាប់តាំងពីពេលនោះមក ព្រះបាទបាយាសិជាអ្នកខ្វល់ខ្វាយក្នុងបុណ្យ កាលថ្វាយទានដល់សមណព្រាហ្មណ៍ទាំងឡាយ បានថ្វាយទានដោយមិនគោរព ព្រោះ-មិនធ្លាប់សន្សំក្នុងទាននោះ លុះក្រោយមក ធ្វើកាលកិរិយាហើយក៏បានទៅកើតក្នុងសេរីសកវិមាន ( ជិតដើមច្រេស ) ក្នុងឋានសួគ៌ជាន់ចាតុម្មហារាជ ។

បានឮមកថា ក្នុងអតីតកាល ក្នុងសម័យកាលនៃព្រះដ៏មាន-ព្រះភាគ ព្រះនាមថា **កស្សបៈ** ព្រះថេរៈខីណាសវៈមួយអង្គ ត្រាច់បិណ្ឌបាតក្នុងស្រុកមួយ ហើយបានធ្វើភត្តកិច្ចនៅត្រង់សួនមួយកន្លែងខាងក្រៅស្រុករាល់ថ្ងៃ, អ្នកឃ្វាលគោម្នាក់ឃើញដូច្នោះហើយ គិតថាលោកម្ចាស់លំបាកព្រោះកំដៅថ្ងៃ មានចិត្តជ្រះថ្លាក៏បានយកបង្គោលដើមច្រេស ៤ ដើម ធ្វើជាមណ្ឌបមែកឈើប្រគេន អាចារ្យពួកខ្លះពោលថា ដាំដើមច្រេសជិតមណ្ឌប ដូច្នេះក៏មាន គេធ្វើកាលកិរិយា-

ហើយ ក៏បានទៅកើតក្នុងឋានសួគ៌ជាន់ចាតុម្មហារាជ ដោយបុញ្ញកម្ម នោះឯង នៅត្រង់ទ្វារវិមានបានកើតនូវសួនច្រេសដែលមានផ្កា បរិបូណ៌ដោយពណ៌ និងក្លិនស្រស់ស្អាតគ្រប់ពេលវេលា ឆ្លុះបញ្ជាំង ដល់កម្មចាស់របស់គេ ព្រោះហេតុនោះ វិមាននោះទើបមានឈ្មោះ ថា **សេរីសកៈ** ម្យ៉ាងទៀត ទេវបុត្រនោះ អន្ទោលទៅមកក្នុងទេវតា និងមនុស្សទាំងឡាយអស់មួយពុទ្ធន្តរៈ ( មួយចន្លោះព្រះពុទ្ធ ) ក្នុង ពុទ្ធុប្បាទនេះ ក៏បានមកកើតជា **ព្រះគវម្បតិ** ក្នុងបណ្ដាគ្រហស្ថ ៤ នាក់[១] មាន**វិមល**ជាដើម ដែលជាសម្លាញ់របស់**ព្រះយសត្ថេរ** តាំង នៅក្នុងព្រះអរហត្ត ដោយព្រះធម្មទេសនារបស់ព្រះដ៏មានព្រះភាគ ឃើញវិមានទំនេរនោះ ទើបទៅសម្រាកពេលថ្ងៃជារឿយ ៗ ដោយ អំណាចបុញ្ញកម្មដែលបានសន្សំទុកក្នុងកាលមុន[២] ។

---

១= គឺ : **វិមល សុពាហុ បុណ្ណជិ គវម្បតិ** ។ ២= **ក្នុងអដ្ឋកថាបាយាសិរាជញ្ញសូត្រ បិដកលេខ ១៧** បានសម្ដែងប្រវត្តិរបស់លោកដែលមានសេចក្ដីប្លែកគ្នាខ្លះថា : ***ព្រះថេរៈ*** *ជាប្រធានក្មេងចិញ្ចឹមគោ ក្នុងមនុស្សលោក ក្នុងជាតិមុន បោសច្រាសសម្អាតគល់ឈើដើមធំ ចាក់រោយដីខ្សាច់ និមន្ត ព្រះថេរៈ អ្នកកាន់បិណ្ឌបាតិកធុតង្គមួយរូប ឱ្យគង់ត្រង់គល់ឈើ ថ្វាយអាហារដែលខ្លួនបានមក ចុតិចាកមនុស្សលោកនោះ ទៅកើតក្នុងវិមានប្រាក់នោះ ដោយអានុភាពរបស់បុណ្យនោះ ។ ដើមឈើតាំងនៅជិតទ្វារវិមាន ។ ៥០ ឆ្នាំ ដើមឈើនោះទើបមានផ្លែ ។ តពីនោះ ទេវបុត្រក៏ ដល់សេចក្ដីតក់ស្លុតថា កន្លងទៅ ៥០ ឆ្នាំហើយ ។ សម័យតមក ទេវបុត្រនោះទៅកើតក្នុង ពួកមនុស្ស ក្នុងសម័យនៃព្រះមានព្រះភាគរបស់យើង ស្ដាប់ធម្មកថារបស់ព្រះសាស្ដា ក៏សម្រេច ព្រះអរហត្ត ។ តែដោយអំណាចការធ្លាប់នៅ ព្រះថេរៈក៏ទៅកាន់វិមាននោះឯងនៅរឿយ ៗ ដើម្បីសម្រាកពេលថ្ងៃ ។*

ក្រោយមក **ព្រះគវម្បតិត្ថេរ**ជួប**បាយាសិទេវបុត្រ**ក្នុងទីនោះ ក៏បានសួរថា អ្នកមានអាយុ តើអ្នកជានរណា ? កាលបាយាសិទេវបុត្រតបថា បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំគឺព្រះបាទបាយាសិ មកកើតក្នុងទីនេះ ទើបពោលថា អ្នកជាមិច្ឆាទិដ្ឋិមានទស្សនៈវិបរិតមិនមែនឬ មកកើតក្នុងទីនេះដូចម្តេចបាន ? គ្រានោះ បាយាសិទេវបុត្រពោលនឹងព្រះថេរៈថា លោកម្ចាស់កុមារកស្សបត្ថេរបានដោះខ្ញុំឱ្យរួចផុតពីមិច្ឆាទិដ្ឋិ ប៉ុន្តែខ្ញុំកើតក្នុងវិមានទំនេរ ក៏ដោយសារបុញ្ញកិរិយាដែលធ្វើដោយមិនគោរព ប្រពៃហើយលោកម្ចាស់ វេលាលោកម្ចាស់ត្រឡប់ទៅមនុស្សលោកវិញ សូមលោកម្ចាស់ប្រាប់ដល់ជនជាបរិវាររបស់ខ្ញុំថា ព្រះបាទបាយាសិថ្វាយទានដោយមិនគោរព មកកើតក្នុងវិមានដើមច្រេសដែលជាវិមានទំនេរ អ្នកទាំងឡាយចូរធ្វើបុណ្យដោយគោរព ចូរតាំងចិត្តឱ្យនឹងធឹង ដើម្បីមកកើតក្នុងវិមាននោះ ព្រះថេរៈក៏បានធ្វើតាមពាក្យនោះ ដើម្បីអនុគ្រោះទេវបុត្រនោះ សូម្បីពួកជនជាបរិវារទាំងនោះ ស្តាប់ពាក្យរបស់ព្រះថេរៈហើយ ក៏បានតាំងចិត្តធ្វើបុណ្យយ៉ាងនោះ ហើយក៏បានទៅកើតក្នុងសេរីសកវិមាននោះ **ស្តេចមហារាជវេស្សវ័ណ**បានតែងតាំងសេរីសកទេវបុត្រឱ្យជាអ្នកថែរក្សានូវមាគ៌ា ដើម្បីនឹងការពារអន្តរាយអំពីអមនុស្សដល់ពួកមនុស្សដែលធ្វើដំណើរក្នុងផ្លូវដែលគ្មានម្លប់ និង ទឹក នៅនាតំបន់-

សមុទ្រខ្សាច់ ។

សម័យក្រោយមក ពួកពាណិជអ្នកដែនអង្គៈ និងមគធៈ បាន យកទំនិញផ្ទុកពេញរទេះចំនួន ១.០០០ រទេះ ធ្វើដំណើរទៅកាន់**សិន្ធុ-ប្រទេស** និង**សោវីរៈប្រទេស** កាត់តាមសមុទ្រខ្សាច់ មិនធ្វើដំណើរក្នុងពេលថ្ងៃទេ ព្រោះខ្លាចក្តៅ ធ្វើដំណើរក្នុងពេលយប់ ព្រោះប្រើផ្កាយជាគ្រឿងសំគាល់ ពួកគេបាននាំគ្នាធ្វើដំណើរវង្វេងផ្លូវទៅទិសផ្សេង ក្នុងរវាងពាណិជទាំងនោះ មានឧបាសកម្នាក់ជាអ្នកមានសទ្ធា-ជ្រះថ្លា បរិបូណ៌ដោយសីល បរិបូណ៌ដោយឧបនិស្ស័យដែលនឹងបានសម្រេចនូវព្រះអរហត្ត ទៅធ្វើជំនួញដើម្បីទំនុកបម្រុងចិញ្ចឹមមាតា-បិតា កាលនឹងអនុគ្រោះឧបាសកនោះ សេរីសកទេវបុត្រទើបបង្ហាញខ្លួនព្រមទាំងវិមាន លុះបង្ហាញខ្លួនហើយ បានសួរថា ហេតុដូចម្តេចបានជាពួកអ្នកទើបធ្វើដំណើរតាមផ្លូវនេះ ដែលគ្មានម្លប់និងទឹក ថែម-ទាំងជាសមុទ្រខ្សាច់ដូច្នេះ ? ពួកគេបានប្រាប់នូវរឿងដែលពួកខ្លួនមកក្នុងទីនោះដល់ទេវបុត្រនោះ ការសម្តែងនូវសេចក្តីនោះ ជាគាថារួបរួមពាក្យពោលឆ្លើយឆ្លងរបស់ទេវបុត្រនិងរបស់ពាណិជទាំងឡាយ-ទុក ។ ដើម្បីសម្តែងនូវសេចក្តីសម្ពន្ធនៃគាថាទាំងនោះ ព្រះធម្មសង្គា-ហកាចារ្យទាំងឡាយបានចាប់ផ្តើមតាំងគាថាខាងដើមទុក២គាថាថា :

*ការប្រជុំនៃទេវតានិងពាណិជទាំងឡាយ ឮដ៏ផ្លូវព្រៃណា ក្នុង-*

*កាលណា កាលនោះ អ្នកទាំងឡាយ ចូរស្តាប់ ( នូវការប្រជុំពួដ៏ផ្លូវក្នុងព្រៃនោះចុះ ) អ្នកទាំងឡាយ ចូរស្តាប់នូវសុភាសិតនោះ ដោយប្រការដូចម្តេចផង ដោយប្រការដទៃផង ស្តេចណាព្រះនាម-* ***ជាយាសិ*** *បានទៅកើតជាមួយនឹងកុម្ភទេវតាទាំងឡាយ ជាអ្នកមានយស ស្តេចនោះ រីករាយក្នុងវិមានរបស់ខ្លួន លោកមិនមែនជាមនុស្សទេ តែបានពោល នឹងពួកមនុស្ស ។*

បណ្តាបទទាំងនោះ បទថា **សុណោថ** ជាពាក្យបង្គាប់ឱ្យស្តាប់ សេចក្តីថា អ្នកទាំងឡាយចូរស្តាប់នូវពាក្យដែលពួកយើងពោលក្នុងកាលឥឡូវនេះ ។ បទថា **យក្ខស្ស** បានដល់ **ទេវតា** ព្រោះថា **ទេវតា** លោកហៅថា **យក្ស** ព្រោះជាអ្នកគួរបូជារបស់ពួកមនុស្ស និងរបស់ទេវតាពួកខ្លះ, ម្យ៉ាងទៀត **ស្តេចសក្កៈក្តី ស្តេចចាតុម្មហារាជក្តី បរិស័ទរបស់ស្តេចវេស្សវ័ណក្តី បុរសក្តី** លោកក៏ហៅថា **យក្ស** ។

មែនពិត **ស្តេចសក្កៈ** លោកហៅថា **យក្ស** បាន ក្នុងប្រយោគជាដើមថា **អតិពាឡ្ហំ ខោ អយំ យក្ខោ បមត្តោ វិហរតិ យន្នូនាហំ ឥមំ យក្ខំ សំវេជេយ្យំ**[១] ស្តេចសក្កៈនេះរស់នៅដោយសេចក្តីប្រមាទយ៉ាងក្រៃលែង បើដូច្នេះ យើងគប្បីញ៉ាំងស្តេចសក្កៈ

១= មានក្នុងចូឡតណ្ហាសង្ខយសូត្រ បិដកលេខ ២២ ទំព័រ ១៤២ ។

នេះឱ្យសង្វេគ ។

**ស្តេចមហារាជទាំងឡាយ** លោកហៅថា **យក្ស** បាន-ក្នុងប្រយោគជាដើមថា **ចត្តារោ យក្ខា ខគ្គហត្ថា** ស្តេចមហារាជទាំង ៤ កាន់ព្រះខាន់ ។

**បរិស័ទរបស់ស្តេចវេស្សវ័ណ** លោកហៅថា **យក្ស** បាន-ក្នុងប្រយោគជាដើមថា **សន្តិ ហិ ភន្តេ ឧឡារោ យក្ខា ភគវតោ អប្បសន្នា**(១) បពិត្រព្រះអង្គដ៏ចម្រើន មានបរិស័ទរបស់ស្តេចវេស្ស-វ័ណជាច្រើន មិនជ្រះថ្លានឹងព្រះដ៏មានព្រះភាគ ។

**បុរស** លោកហៅថា **យក្ស** បាន ក្នុងប្រយោគជាដើមថា **ឯត្តាវតា យក្ខស្ស សុទ្ធិ** ត្រឹមតែប៉ុណ្ណោះក៏ជាសេចក្តីបរិសុទ្ធិរបស់បុរស ។

តែក្នុងទីនេះ លោកសំដៅយកបរិស័ទរបស់ស្តេចវេស្សវ័ណ ។

បទថា **ទារណិជាន ច** លោកពោលលុបនិគ្គហិត ដើម្បីស្រួលក្នុងការចងនូវគាថា ។

បទថា **សមាគមោ** ប្រែថា មកជួបគ្នា ។ បទថា **យត្ថ** បានដល់ ក្នុងសមុទ្រខ្សាច់ណា ។ បទថា **តទា** បានដល់ ក្នុងវេលាដែលវង្វេងផ្លូវនោះ ។ បទថា **ឥតរីតរេន ចាបិ** បានដល់ គ្នា និង គ្នា

១= មានក្នុង**អាដានាដិយសូត្រ** បិដកលេខ ១៩, ទំព័រ ៩៥ ។ ( ទី. និ.៣. ២៧៦ ឆដ្ឋ )

បទនេះ គប្បីប្រកបជាមួយនឹងបទ **យថា** ក្នុងចំណុចនេះមានសេចក្ដីដូចតទៅនេះ **សេរីសកទេវបុត្រ** និងពួកពាណិជបានជួបគ្នាក្នុងទីណា ( ផ្លូវសមុទ្រខ្សាច់ ) ក្នុងគ្រានោះ អ្នកទាំងឡាយចូរស្ដាប់នូវរឿងនោះម្យ៉ាងទៀត ដោយពាក្យដែលនិយាយគ្នាល្អ ចរចាគ្នាពីរោះដែលសេរីសកទេវបុត្រ និងពួកពាណិជទាំងនោះឱ្យប្រព្រឹត្តទៅហើយរឿងណា សូមអ្នកទាំងពួងចូរតាំងចិត្តស្ដាប់នូវរឿងនោះ ។ បទថា **ភុម្មានំ** បានដល់ ពួកភុម្មទេវតា ។

ឥឡូវនេះ ជាគាថាសួររបស់ទេវបុត្រថា :

*នែមនុស្សទាំងឡាយ អ្នកភ័យចំពោះផ្លូវវៀច អ្នកមានចិត្តខូចហើយ ( វង្វេងផ្លូវ ) ក្នុងព្រៃជាទីរង្កៀស ជាកន្លែងគ្រាច់ទៅនៃ-មនុស្ស ជាផ្លូវកន្ដារ ឥតមានទឹក ឥតមានចាយ ពាក់កណ្ដាលនៃព្រៃធំដែលបុគ្គលដើរទៅបានដោយកម្រណាស់ ផ្លែឈើនិងមើមឈើទាំង-ឡាយ ក្នុងផ្លូវកន្ដារនេះ មិនមានទេ វត្ថុសម្រាប់ដុតឱ្យឆេះ ក៏មិនមានភិក្ខាហារ តើនឹងមានមកពីណា ក្នុងផ្លូវខ្សាច់នេះ វៀរលែងតែអាចម៍-ដី និងដីខ្សាច់ទាំងឡាយ ដ៏ក្ដៅក្រហាយ កាចអាក្រក់ចេញ ទីនេះជាទីទួលក្ដៅ មិនមានសេចក្ដីចម្រើន ស្មើដោយបរលោក គឺនរកផែនដីនេះ ជាទីនៅនៃពួកបិសាចអាក្រក់ ជារបស់ចាស់ ប្រទេសនៃផែនដី ប្រាកដស្មើដោយប្រទេស ដែលពួកឥសីផ្ដាសាហើយ*

*ក៏អ្នកទាំងឡាយ ប្រាថ្នារបស់អ្វី ដោយហេតុដូចម្តេច បានជាចូលមកកាន់ប្រទេសនេះ មិនពិចារណា ( រកទោសនិងអានិសង្ស ) ដោយរហ័សសិន ឬមួយអ្នកទាំងឡាយ ចូលមកកាន់ប្រទេសនេះ ព្រោះលោភ ឬ ព្រោះភ័យ ឬ ព្រោះវង្វេងផ្លូវ ។*

បណ្តាបទទាំងនោះ បទថា **ឧង្កេ** ( បិដកថា **សង្កេ** ) បានដល់ទីគួរសង្ស័យ ដែលអ្នកចូលទៅហើយ មានសេចក្តីសង្ស័យក្នុងជីវិតថា នឹងរស់ នឹងស្លាប់ហ្ន៎ ក្នុងព្រៃដូច្នោះ ។ បទថា **អមនុស្សដ្ឋានេ** ( បិដកថា **អមនុស្សឋានេ** ) បានដល់ ជាទីសព្ចររបស់ពួកអមនុស្ស មានបិសាចជាដើម ឬមិនមែនជាផ្លូវគោចររបស់ពួកមនុស្ស ។ បទថា **កន្តារេ** បានដល់ វាលដែលគ្មានទឹក ភូមិប្រទេសឈ្មោះថា កន្តារ ព្រោះអត្ថថា ជាទីឱ្យឆ្លងទឹក នាំទឹកទៅជាមួយ បានដល់ ទីដែលត្រូវកាន់យកទឹកឆ្លងទៅ ព្រោះហេតុនោះ ទេវបុត្រទើបពោលថា **អប្បោទកេ** ឥតមានទឹក ។ **អប្ប** សព្ទក្នុងទីនេះ មានសេចក្តីថា ឥតមាន ដូចក្នុងប្រយោគជាដើមថា **អប្បិច្ឆោ** មានសេចក្តីប្រាថ្នាតិច **អប្បនិគ្ឃោសោ** ឥតមានសំឡេងអ៊ូអរ ។ បទថា **ឧណ្ណវបថស្ស មជ្ឈេ** ( បិដកថា **ឧនបថស្ស មជ្ឈេ** ) សេចក្តីថា កណ្តាលសមុទ្រខ្សាច់ ។ បទថា **ឧង្កម្ភយា** ប្រែថា ភ័យចំពោះផ្លូវវៀច កាលគួរនឹងពោលថា **ឧង្កភយា** ព្រោះអត្ថថា ពួកគេមានតែសេចក្តីខ្លាចចំពោះផ្លូវវៀច,

ពោលថា **ទង្គម្ពយា** ចុះនិគ្គហិត ( ហើយផ្លាស់ជា ម ) ដើម្បីងាយស្រួលក្នុងការចងគាថា និងបទនេះ លោកពោលសំដៅដល់ភ័យដែលកើតឡើងដល់ពួកគេ មុននឹងចូលទៅក្នុងសមុទ្រខ្សាច់ ។ បទថា **នដ្ឋមនា** បានដល់ មានចិត្តខូច ព្រោះចាំផ្លូវមិនបាន, អធិប្បាយថា វង្វេងផ្លូវ ។ បទថា **មនុស្សា** ជាពាក្យហៅពាណិជទាំងនោះ ( អាលបនៈ ) ។

បទថា **ឥធ** បានដល់ ក្នុងសមុទ្រខ្សាច់នេះ ។ បទថា **ផលា** សេចក្ដីថា មិនមានផ្លែឈើទាំងឡាយ មានស្វាយ ជំពូ ត្នោត និងដូងជាដើម ។ បទថា **មូលមយា ច** សេចក្ដីថា មើមនោះឯងឈ្មោះថា សម្រេចពីមើម លោកពោលសំដៅយក មើមដែលកើតពីវល្លិ៍ជាដើម ។ បទថា **ឧបាទានំ នត្ថិ** សេចក្ដីថា មិនមានអាហារណាមួយ, មយ៉ាងទៀត វត្ថុសម្រាប់ដុតឱ្យឆេះ ឈ្មោះថា ឧបាទាន សូម្បីត្រឹមតែវត្ថុសម្រាប់ដុតឱ្យឆេះក៏មិនមានឡើយ តើនឹងមានអាហារក្នុងសមុទ្រខ្សាច់នេះមកពីណា គឺព្រោះហេតុអ្វី ដូច្នេះក៏ពិតទោះបីយ៉ាងនោះ លោកពោលពាក្យជាដើមថា **អញ្ញត្រ បំសុហិ** ដូច្នេះ ក៏ដើម្បីសម្ដែងនូវវត្ថុដែលមាននៅក្នុងសមុទ្រខ្សាច់នោះ ។

បទថា **ឧជ្ជង្គលំ** សេចក្ដីថា ភូមិប្រទេសសៅហ្មងពណ៌ប្រផេះ ៗ មិនមានទឹក ហៅថា ជង្គលៈ ទីទូល ក៏ទីត្រង់នោះជាទីទូល

ខ្ពស់ជាងទីទូលទូទៅ ដូច្នោះទេវបុត្រទើបពោលថា **ឧដ្ឌត្ថលំ** ។ ព្រោះហេតុនោះ ទេវបុត្រទើបពោលថា **តត្តមិទំ កបាលំ** ( បិដកថា **តត្តមិធំ កបាលំ** ) សេចក្តីថា ដូចបន្ទះដែកត្រូវភ្លើងឆេះ និងក្នុងទីនេះ លោកពោលចុះនិគ្គហិត ដើម្បីងាយស្រួលក្នុងការចងគាថា គប្បីជ្រាបថា **តត្តមិទ** នោះឯង ។ បទថា **អនាយសំ** សេចក្តីថា ឈ្មោះថា **អនាយ** ព្រោះអត្ថថា ជាទីមិនមានអាយៈគឺសេចក្តីសុខ ឈ្មោះថា **អនាយស** ព្រោះអត្ថថា សាបសូន្យជីវិត គឺធ្វើឱ្យជីវិតវិនាស ព្រោះមិនមានសេចក្តីសុខនោះឯង ម្យ៉ាងទៀត ឈ្មោះថា **អនាយសៈ** ព្រោះមិនជាសុខ ។ បទថា **បរលោកេន** បានដល់ប្រៀបដូចនរក មែនពិត នរកជាលោកបរបក្ស គឺជាសត្រូវរបស់សត្វទាំងឡាយ ព្រោះធ្វើនូវសេចក្តីវិនាសឱ្យតែម្យ៉ាង ដូច្នោះ លោកទើបហៅថា **បរលោក** ជាពិសេស ម្យ៉ាងទៀត នរកនេះ ឈ្មោះថា **អាយសៈ** ព្រោះធ្វើដោយដែកដោយជុំវិញ ចំណែកទីទូលនេះ ឈ្មោះថា **អនាយស** ព្រោះមិនមានដែកនោះ ទេវបុត្រសម្តែងថា ស្រដៀងនរក ព្រោះជាទីកើតទុក្ខខ្លាំង, អាចារ្យពួកខ្លះពោលថា **អនស្សយំ** សេចក្តីថា មិនជាទីតាំងនៃសេចក្តីសុខ ។ បទថា **លុទ្ធានមាវាសមិធំ បុរាណំ** សេចក្តីថា ទីនេះ តាំងពីយូរណាស់មកហើយជាទីនៅរបស់ពួកអមនុស្សកាច ៗ មានបិសាចជាដើម ។

បទថា **អភិសត្ថរូបោ** សេចក្ដីថា ដូចត្រូវផ្ដាសា ដែលពួកឥសីពីបុរាណផ្ដាសាថា ចូរសៅហ្មង មានអាការអាក្រក់យ៉ាងនេះ ។

បទថា **កេន នុ វណ្ណេន** បានដល់ ព្រោះហេតុដូចម្ដេច ។ បទថា **កិមាសមានា** ប្រែថា ប្រាថ្នាអ្វី ។ បទថា **ហិ** គ្រាន់តែជានិបាត លោកខ្លះពោល **បទេសម្បិ** សេចក្ដីថា សូម្បីប្រទេសឈ្មោះនេះ ។ បទថា **សហសា សមេច្ច** សេចក្ដីថា មិនពិចារណាដល់ទោសនិងគុណតាមគ្នាចូលទៅ គឺចូលទៅព្រមគ្នា ។ បទថា **លោភា ភយា** សេចក្ដីថា ត្រូវអ្នកមិនមានបំណងល្អខ្លះ បោកបញ្ឆោតចូលទៅ ព្រោះសេចក្ដីលោភ ឬត្រូវអមនុស្សជាដើមខ្លះ ធ្វើឱ្យភិតភ័យ ចូលទៅព្រោះសេចក្ដីខ្លាច ។ បទថា **អថ វា សម្បមូឡ្ហា** បានដល់ ព្រោះទៅខុសផ្លូវ សេចក្ដីថា ចូលទៅរឿយ ៗ ដល់ប្រទេសនេះ ។

ឥឡូវនេះ ពួកពាណិជពោលថា :

*យើងទាំងឡាយ ជាពួកឈ្មួញរទេះក្នុង**ដែនមគធៈ**និង**ដែនអង្គៈ** បានផ្ទុកទ្រព្យសម្បត្តិជាច្រើន ពួកយើងទាំងនោះ ទៅកាន់ប្រទេសឈ្មោះ **សិន្ធុ** និងប្រទេសឈ្មោះ **សោវីរៈ** ត្រូវការដោយទ្រព្យ ប្រាថ្នានូវការចំណេញ មិនអាចនឹងអត់ទ្រាំ សម្រេកគំលានក្នុងវេលាថ្ងៃបានក៏រំពឹងរកសេចក្ដីអនុគ្រោះដល់សត្វសម្រាប់ទឹមទាំងឡាយ ( មានគោ-ជាដើម ) យើងទាំងអស់គ្នា មកដោយប្រញាប់ទុំ ពួកយើងទាំងនោះ*

*ដើរទៅកាន់ផ្លូវក្នុងវេលាយប់ ក្នុងកាលមិនគួរ ពួកយើងទាំងនោះ ដើរទៅខុសផ្លូវ ក៏វង្វេងផ្លូវ វិលវល់ដូចមនុស្សខ្វាក់ វិលវល់នៅត្រង់ពាក់កណ្តាលនៃព្រៃធំ ជាព្រៃដែលគេកម្រឆ្លងបានដោយងាយ មានចិត្ត វង្វេងមិនដឹងទិស ( ដែលគួរនឹងទៅបាននោះ ) ម្នាលយក្ស ពួកយើង បានឃើញនូវវិមានដ៏ប្រសើរ ដែលមិនធ្លាប់បានឃើញមក នេះផង ឃើញបុគ្គលអ្នកប្រាថ្នានូវការរស់នៅ ឱ្យក្រៃលែងជាងនោះទៅទៀតផង ឃើញហើយ ក៏មានចិត្តរីករាយ មានចិត្តសោមនស្ស មានចិត្តអណ្តែតខ្ពស់ ( ដោយអំណាចបីតិ ) ។*

បណ្តាបទទាំងនោះ បទថា **មគធេសុ អង្គេសុ ច សត្ថវាហា** សេចក្តីថា ទាំងជានាយឈ្មួញរទេះ ទាំងជាម្ចាស់ឈ្មួញរទេះ នាំទំនិញមកដោះដូរទំនិញ ជាអ្នកកើតធំធាត់ក្នុងដែនមគធៈនិងក្នុងដែនអង្គៈ ជាអ្នកដែននោះ ។ បទថា **បណិយំ** ប្រែថា ទំនិញ ។ បទថា **តេ** បានដល់ ពួកយើងនោះ ។ បទថា **យាមសេ** ប្រែថា នាំគ្នាទៅ ។ បទថា **សិន្ធុសោវីរភូមឹ** បានដល់ សិន្ធុប្រទេសនិងសោវីរៈប្រទេស ។ បទថា **ឧទយំ** បានដល់ ផលប្រយោជន៍ជាប្រាក់ចំណូលដែលកើនលើស ( ចំណេញ ) ។ បទថា **អនធិវាសយន្តា** ប្រែថា ទ្រាំមិនបាន ។ បទថា **យោគ្គានុកម្បំ** បានដល់ អនុគ្រោះសត្វ-ទាំងឡាយមានគោជាដើម ។ បទថា **ឯតេន វេគេន** បានដល់

ដោយប្រញាប់ ដែលជាហេតុឱ្យពួកយើងនាំគ្នាមក គឺជាអ្នកមកមុន ជួបអ្នក ។ បទថា **រត្តឹ មគ្គំ បដិបន្នា** សេចក្តីថា ធ្វើដំណើរ ពេលយប់ ។ បទថា **វិកាលេ** បានដល់ មិនត្រូវកាលមិនត្រូវវេលា ។

បទថា **ឧប្បថយាតា** បានដល់ ទៅបានដោយកម្រ គឺទៅមិន ត្រូវផ្លូវ ព្រោះទៅមិនត្រូវផ្លូវនោះឯង ទើបឈ្មោះថា ខុសផ្លូវ ។ បទថា **អន្ធាកុលា** សេចក្តីថា ឈ្មោះថា ខ្វាក់ ព្រោះមិនមានចក្ខុ គឺបញ្ញាដែលអាចដឹងផ្លូវ ទើបវិលវល់ដូចមនុស្សខ្វាក់ ព្រោះខ្វាក់នោះ ឯង ទើបឈ្មោះថា វិលវល់ និងដែលឈ្មោះថា ទៅខុសផ្លូវព្រោះជា អ្នកវង្វេងផ្លូវ ។ បទថា **ទិសំ** បានដល់ ទិសដែលគួរនឹងទៅ គឺទិស ដែលសិន្ធុប្រទេសនិងសោវីរៈប្រទេសតាំងនៅ ។ បទថា **បមូឡ្ហចិត្តា** បានដល់ មានចិត្តវង្វេងដោយមិនសង្ស័យទិស ។ បទថា **តុវញ្ច** ប្រែថា នូវអ្នកផង ។ បទថា **យក្ខ** ជាពាក្យហៅ ( អាលបនៈ ) ។ បទថា **តត្ថេវ ជីវិតមាសមានា** ( បិដកថា **ជីវិតមាសីសនា** ) សេចក្តីថា សេចក្តីសង្ស័យក្នុងជីវិតណាកើតឡើងថា តពីនេះ ពួក យើងប្រាកដជាមិនរួចជីវិតឡើយ ឥឡូវនេះ ពួកយើងក៏ប្រាថ្នានឹងរួច ជីវិតក្រៃលែងជាងសេចក្តីសង្ស័យក្នុងជីវិតនោះ ។ បទថា **ទិស្វា** ប្រែថា ព្រោះហេតុដែលឃើញ ។ បទថា **បតីតា** ប្រែថា រីករាយ ។ បទថា **សុមនា** ប្រែថា ដល់នូវសោមនស្ស ( ត្រេកអរ ) ។ បទថា

**ឧទគ្គា** ប្រែថា សប្បាយចិត្ត ដោយអំណាចបីតិដែលកើតឡើង ។

កាលពួកពាណិជពោលរៀបរាប់នូវរឿងរ៉ាវដែលបានប្រព្រឹត្ត-ទៅរបស់ខ្លួនយ៉ាងនេះហើយ ទេវបុត្របានសួរដោយគាថា ២ គាថាទៀតថា :

*អ្នកទាំងឡាយឆ្លងបានដោយក្រ ទៅកាន់ត្រើយសមុទ្រខាងនាយផង កាន់ព្រៃនេះផង កាន់ផ្លូវស្នូរ ដែលគេចងដោយវល្លិ និងផ្តៅផង កាន់ផ្លូវប្រកបដោយសេចក្តីរង្កៀសផង កាន់ស្ទឹងទាំងឡាយរបស់ភ្នំទាំងឡាយដែលទៅបានដោយកម្រផង កាន់ទិសទាំងឡាយដ៏-ច្រើន ( យ៉ាងនេះ ) ព្រោះហេតុតែភោគៈ កាលអ្នកចេញទៅកាន់ដែនរបស់ស្តេចទាំងឡាយដទៃ អ្នកទាំងឡាយឃើញពួកមនុស្សអ្នកនៅក្នុងប្រទេសផ្សេងគ្នា នៃអ្នកទាំងឡាយ ហេតុអស្ចារ្យណា ដែលអ្នកទាំងឡាយឮហើយ ឬឃើញហើយ ពួកយើងឮនូវហេតុអស្ចារ្យនោះ ( ក្នុងសម្នាក់ ) នៃអ្នកទាំងឡាយ ។*

សេចក្តីនៃគាថាទាំង ២ នោះ ដូចតទៅនេះ បទថា **ឃារំ សមុទ្ទស្ស** ជាដើម សេចក្តីថា ទៅសមុទ្រខ្សាច់ គឺផ្លូវដែលប្រកបដោយខ្សាច់ទាំងត្រើយអាយនិងត្រើយនាយ, ឈ្មោះថា ផ្លូវស្នូរ ព្រោះដើមផ្តៅវ័ណ្ឌគ្នានឹងត្រូវទៅឱ្យល្អ កាន់ផ្លូវដែលមានជង្គត់ ព្រោះត្រូវគាស់ជង្គត់ទាំងឡាយហើយទើបទៅបាន ទិសជាច្រើនដែលទៅបាន

ដោយកម្រ យ៉ាងនេះគឺស្ទឹងមានស្ទឹងចន្ទភាគាជាដើម និងប្រទេស ដែលមិនរាបស្មើនៃភ្នំទាំងឡាយ ព្រោះភោគទ្រព្យជាហេតុ និងពួក អ្នកកាលទៅយ៉ាងនេះ ក៏ស្រូតចូលទៅដល់ដែនរបស់ព្រះរាជាដទៃ ៗ ឃើញពួកមនុស្សអ្នកនៅក្នុងប្រទេសផ្សេងគ្នា គឺអ្នកនៅតំបន់ផ្សេង-គ្នា ក្នុងដែននោះ ហេតុអស្ចារ្យ គឺគួរឱ្យស្ងើចសរសើរណា ដែល ពួកអ្នក គឺអ្នកទាំងឡាយ បានឮ ឬបានឃើញ នៃពាណិជទាំង-ឡាយ យើងសូមស្តាប់នូវហេតុអស្ចារ្យនោះ ក្នុងសម្នាក់របស់ពួកអ្នក ទេវបុត្រមានបំណងចង់ឱ្យពាណិជទាំងនោះពោលដល់ភាពអស្ចារ្យ-នៃវិមានរបស់ខ្លួន ទើបសួរដោយប្រការដូច្នេះ ។

ត្រូវទេវបុត្រសួយ៉ោងនេះហើយ ពួកពាណិជពោលថា :

*នែទេវកុមារ ហេតុអស្ចារ្យជាងនេះទៅទៀត ពួកយើងមិន ដែលឮទេ ទាំងមិនដែលឃើញឡើយ ពួកយើងឃើញនូវអ្នក និងវិមាន ទាំងអស់ដែលកន្លងនូវសម្បត្តិជារបស់មនុស្ស មិនមែនជាមនុស្ស មានវណ្ណៈមិនថោកទាប ក៏រីករាយ រមែងឆ្អែតចិត្ត ស្រះបោក្ខរណី ទាំងឡាយ ឮដ៏អាកាស រមែងហូរចេញ ឈូកសទាំងឡាយជាច្រើន មានផ្កាច្រើន ទាំងពួកឈើទាំងនោះ ក៏ប្រកបដោយផ្លែជានិច្ច ក្លិន ក្រអូបក្រៃលែង តែងផ្សាយចេញទៅ សសរទាំងឡាយជាវិការៈនៃ កែវពិទូរ្យ មានកំពស់ ១០០ ហត្ថ មានបណ្តោយដ៏វែង ជាវិការៈនៃ-*

*ថ្មកែវពពាឡ និងថ្មកែវផលិក ព្រមទាំងកែវពព្រុះ និងកែវមណី មានពណ៌ក្រហម សសរទាំងនេះ ជាវិការៈនៃ**កែវមណីជាតិរស** វិមាន ( របស់អ្នក )នេះល្អ មានសសររាប់ពាន់ មានអានុភាពថ្លឹងមិនបាន ក្នុងខាងលើនៃសសរទាំងនោះ ជាវិមាន ប្រកបដោយកែវ ( ផ្សេងៗ) លាយដោយផែនមាសស្រួយ ប្រក់ដោយផ្ទាំងកែវ មានរស្មី ( ផ្សេងៗ ) ដ៏ល្អ វិមាន ( របស់អ្នក )នេះ វិសេសដូចដុំមាស**ជម្ពូនទ** ប្រទេសនៃ ( វិមាននោះ ) ក៏រលីងស្អាត ប្រកបដោយប្រាសាទនិងកាំជណ្ដើរដ៏មាំមួនផង ល្អផង មានលំនាំស្រដៀង ៗ គ្នា គួរក្រឡេក-មើលក្រៃពេក ជាទីគាប់ចិត្ត បាយនិងទឹកដ៏ច្រើន ( តែងមាន ) ក្នុងខាងក្នុងនៃវិមានជាវិការៈនៃកែវ អ្នកមានពួកស្រីអប្សរហែហម កងរំពងដោយសម្ភោរ ស្គរធំនិងតូរ្យតន្ត្រី អ្នកផង រមែងថ្វាយបង្គំដោយការថ្វាយបង្គំជាទីសរសើរអ្នកនោះ ជាអ្នកភ្ញាក់រឭកដោយពួកនាងនារី មានអានុភាពដែលបុគ្គលមិនគប្បីគិត ប្រកបដោយគុណទាំងពួង រមែងរីករាយក្នុងវិមាន ប្រាសាទដ៏ប្រសើរជាទីរីករាយចិត្តដូចជាស្ដេចវេស្សវ័ណ ក្នុងកីឡាស្ថានឈ្មោះ**នលិន្យា**ដែរ អ្នកជាទេវតា ឬជាយក្ខ ឬជាព្រះឥន្ទ្រ ឬក៏ជាមនុស្ស ពួកពាណិជសួរអ្នក អ្នកចូរ-ប្រាប់មក អ្នកជាយក្ខឈ្មោះអ្វី ។*

បណ្ដាបទទាំងនោះ លោកហៅទេវបុត្រដោយបទថា **កុមារ**

ព្រោះនៅក្នុងបឋមវ័យ ។ បទថា **សព្វំ** លោកពោលសំដៅយក ទេវបុត្រ និងវត្ថុដែលជាប់ទាក់ទងនឹងវិមានរបស់ទេវបុត្រនោះ ។ បទថា **បោក្ខរញ្ញោ** ប្រែថា ស្រះបោក្ខរណី ។ បទថា **សតមុស្សិតាសេ** ប្រែថា កំពស់ ១០០ ហត្ថ ។ បទថា **សិលប្បវាឡស្ស** ប្រែថា ដោយសិលានិងកែវពពាឡ សេចក្ដីថា សម្រេចដោយសិលា សម្រេចដោយកែវពពាឡ ។ បទថា **អាយតំសា** ប្រែថា បណ្ដោយ, ម្យ៉ាងទៀត សេចក្ដីថា ទំហំរីកចេញទៅ ៨ ភាគ ១៦ ភាគ និង ៣២ ភាគ ជាដើម ។

បទថា **តេសូបរិ** ( បិដកថា **តេសុបរិ** ) បានដល់ ខាងលើ សសរទាំងនោះ ។ បទថា **សាធុមិទំ** សេចក្ដីថា វិមានរបស់អ្នកនេះ ស្អាត ។ បទថា **រតនន្តរំ** បានដល់ មានរតនៈខាងក្នុងខាងក្រៅ ប្រកបដោយរតនៈដទៃទៀតមានច្រើនយ៉ាង ត្រង់ជញ្ជាំងសសរ និង ជណ្ដើរជាដើម ។ បទថា **កញ្ចនវេទិមិស្សំ** សេចក្ដីថា ប្រកប គឺព័ទ្ធ ជុំវិញដោយភ្លើងជាវិការៈនៃមាស ។ បទថា **តបនីយបដ្ឋេហិ ច សាធុ ឆន្នំ** សេចក្ដីថា ប្រក់យ៉ាងល្អក្នុងទីនោះ ៗ ដោយគ្រឿង-ប្រក់ ដែលសម្រេចដោយមាស និងដែលសម្រេចដោយរតនៈដ៏ច្រើន ក្រៃលែង ។

បទថា **ជម្ពោនទុត្តត្តមិទំ** ( បិដកថា **ជម្ពោនទុត្តមិទំ** )

សេចក្ដីថា វិមានរបស់អ្នកនេះ មានរស្មីពណ៌មាសជម្ពោនទចែងចាំង យ៉ាងច្រើន ។ បទថា **សុមជ្ជោ ចាសាទសោចាណផលុបបន្ទោ** សេចក្ដីថា ប្រទេសនោះ ៗ នៃវិមាននោះ រលីងស្អាត គឺ ខាត់ទុក យ៉ាងល្អ និងប្រកបដោយប្រាសាទជាប់ ៗ គ្នានោះ ៗ មានជណ្ដើរ វិសេសនិងផែនក្ដារដែលគួរឱ្យមនោរម្យ ។ បទថា **ឧឡោ្ហ** ប្រែថា មាំមួន ។ បទថា **ទគ្គូ** ប្រែថា ស្អាតខ្ពស់ត្រដែត ។ បទថា **សុសន្ធតោ** បានដល់ មានគ្រឿងប្រកបចូលគ្នាបានល្អ មានគ្រឿងប្រកបប្រាសាទ សមគ្នានិងគ្នា ។ បទថា **អតីទ និជ្ឈានខមោ** សេចក្ដីថា ទ្រាំនឹងការ ក្រឡេកមើលបានដោយកម្រ ព្រោះភាពជារបស់ផូរផង់ ។ បទថា **មនុញ្ញោ** ប្រែថា ជាទីរីករាយចិត្ត ។

បទថា **រតនន្តរស្មឹ** សេចក្ដីថា សម្រេចដោយរតនៈ គឺ ខាងក្នុងវិមាន ជារតនៈ ឬជាសារៈ ។ បទថា **ពហុ អន្នបានំ** សេចក្ដីថា បាយ និងទឹកគួរជាទីគាប់ចិត្តដ៏ច្រើន ក៏មាន គឺ រកបាន ។ បទថា **មុរជអាលម្ពរតុរិយសង្ឃុដ្ឋោ** សេចក្ដីថា កងរំពងជានិច្ច ដោយសម្លេងសម្ភោរ ស្គរធំ និងតូរ្យតន្ត្រីដទៃ ៗ ទៀត ។ បទថា **អភិវន្ទិតោសិ** សេចក្ដីថា ជាអ្នកដែលពួកទេវតានមស្ការហើយ ឬ សរសើរហើយ ព្រោះហេតុនោះ លោកទើបពោលថា **ថុតិវន្ទនាយ** ដូច្នេះ ។

បទថា **អចិន្តិយោ** បានដល់ មានអានុភាពជាអចិន្តេយ្យមិនគួរគិត ។ បទថា **នលិន្យា** សេចក្ដីថា អ្នករីករាយដូចស្ដេចវេស្សវ័ណមហារាជរីករាយក្នុងកីឡាស្ថាន ដែលមានឈ្មោះយ៉ាងនេះថា **នលិនី**។

បទថា **អាសិ** បានដល់ **អសិ ភវសិ** ប្រែថា អ្នកជា ។ បទថា **ទេវិន្ទោ** បានដល់ ស្ដេចសក្កទេវរាជ ។ បទថា **មនុស្សភូតោ** បានដល់ កើតក្នុងពួកមនុស្ស គឺជាជាតិមនុស្ស ពាណិជទាំងឡាយសូម្បីនឹងសួរនូវភាពជាទេវៈជាដើម តែនៅសង្ស័យភាពជាយក្ខ ទើបពោលថា **យក្ខោ** ។

ឥឡូវនេះ កាលនឹងឱ្យពួកពាណិជស្គាល់ខ្លួន ទើបពោលនូវគាថាថា :

*ខ្ញុំជាយក្ខឈ្មោះ**សេរីសកៈ** ធ្វើតាមពាក្យរបស់ស្ដេចវេស្សវ័ណជាអ្នកនៅចាំ ក្នុងផ្លូវកន្ដារ គ្រប់គ្រង ក្នុងព្រៃធំ ថែរក្សាប្រទេសនេះ។*

បណ្ដាបទទាំងនោះ បទថា **អហម្ហិ យក្ខោ** សេចក្ដីថា ខ្ញុំជាទេវតា ។ បទថា **កន្តារិយោ** បានដល់ ជាអ្នកមានតួនាទីចាំរក្សាក្នុងផ្លូវកន្ដារ ។ បទថា **គុត្តោ** បានដល់ ឃុំគ្រង ព្រោះដូច្នោះលោកទើបពោលថា **អភិបាលយាមិ** ថែរក្សា ។

ឥឡូវនេះ ពួកពាណិជកាលសួរដល់កម្មជាដើមរបស់ទេវបុត្រនោះ ទើបពោលថា :

*វិមានដែលអ្នកបាន តាមសេចក្តីប្រាថ្នា ប្រែប្រួលទៅតាមកាល អ្នកធ្វើខ្លួនឯង ឬក៏ពួកទេវតាឱ្យវិមានជាទីគាប់ចិត្តនេះ អ្នកបានដោយប្រការដូចម្តេច ។*

បណ្តាបទទាំងនោះ បទថា **អធិច្ចលទ្ធំ** បានដល់ កើតឡើងឯង, អធិប្បាយថា បានតាមសេចក្តីប្រាថ្នា ។ បទថា **បរិណាមជន្តេ** បានដល់ ប្រែប្រួលដោយភ័ព្វសំណាងនិងសេចក្តីជាប់ទាក់ទំនងនៃ-សង្គម ឬប្រែប្រួលទៅតាមកាល ។ បទថា **សយំ កតំ** សេចក្តីថា អ្នកធ្វើខ្លួនឯង, អធិប្បាយថា អ្នកប្រើទេវឫទ្ធិឱ្យកើតឡើងដោយខ្លួនឯង ។ បទថា **ទេវេហិ ទិន្នំ** សេចក្តីថា ទេវតាទាំងឡាយដែលអ្នកធ្វើឱ្យត្រេកអរ លះបង់ឱ្យដោយអំណាចនៃសេចក្តីជ្រះថ្លា ។

ឥឡូវនេះ ទេវបុត្រកាលនឹងបដិសេធនូវប្រការទាំង ៤ ( ដែលសួរ ) ហើយអាងបុណ្យប៉ុណ្ណោះ បាននពោលនូវគាថាថា :

*វិមាននេះ មិនមែនខ្ញុំបានតាមសេចក្តីប្រាថ្នាទេ ទាំងមិនមែនប្រែប្រួលទៅ តាមកាលទេ មិនមែនធ្វើខ្លួនឯងទេ មិនមែនពួកទេវតាឱ្យទេ វិមាន ជាទីគាប់ចិត្តនេះ ខ្ញុំបានដោយកម្មមិនលាមក ដោយបុណ្យរបស់ខ្លួនទេតើ ។*

ពួកពាណិជបានស្តាប់ដូច្នោះហើយ លើកនូវគោលទាំង ៤ ប្រការនោះ ក្នុងគាថាថា **នាធិច្ចលទ្ធំ** ជាដើម ថាជាបុញ្ញាធិការតែ-

ម្តង និងសួរសរុបនូវបុណ្យទៀតថា :

*វតរបស់អ្នក តើដូចម្តេច មួយទៀត ព្រហ្មចរិយៈរបស់អ្នក តើដូចម្តេច នេះជាផលនៃកម្មដូចម្តេច ដែលអ្នកសន្សំល្អហើយ វិមាននេះ អ្នកបានដោយប្រការដូចម្តេច ។*

បណ្តាបទទាំងនោះ បទថា **វតំ** បានដល់ សមាទានវត ។ បទថា **ព្រហ្មចរិយំ** បានដល់ សេចក្តីប្រព្រឹត្តដ៏ប្រសើរបំផុត ។

ទេវបុត្របដិសេធនូវពាក្យសួរទាំងនោះទៀត កាលនឹងសម្តែងនូវខ្លួននិងបុណ្យតាមដែលបានសន្សំទុក ទើបពោលថា :

*ដើមឡើយ ខ្ញុំឈ្មោះ **បាយាសិ** សោយរាជ្យ ក្នុងដែនកោសល ក្នុងកាលណា ខ្ញុំជាអ្នកមាននត្ថិកទិដ្ឋិផង មានសេចក្តីកំណាញ់ស្វិតស្វាញផង មានបាបធម៌ផង ជាឧច្ឆេទវាទីផង ក្នុងកាលនោះ មានសមណៈ ឈ្មោះ **កុមារកស្សបៈ** ជាពហុស្សូត មានសំដីវិចិត្តលើសលុប ក្នុងកាលនោះ ព្រះថេរៈនោះ បានសម្តែងធម្មកថា ចំពោះខ្ញុំ បានដកភើចចោលនូវចំរូង គឺទិដ្ឋិរបស់ខ្ញុំ លុះខ្ញុំស្តាប់ធម្មកថារបស់លោកហើយ បានប្តេជ្ញាខ្លួនជាឧបាសក វៀរចាកបាណាតិបាតផង វៀរបង់ការកាន់យកទ្រព្យ ដែលគេមិនបានឱ្យ ក្នុងលោកផង មិនផឹកទឹកស្រវឹងផង មិនពោលពាក្យកុហកផង ជាអ្នកត្រេកអរ ត្រឹមតែប្រពន្ធរបស់ខ្លួនផង នោះជាវតរបស់ខ្ញុំ ជាព្រហ្មចរិយៈរបស់ខ្ញុំ*

*នេះជាផលនៃកម្មនោះ ដែលខ្ញុំសន្សំល្អហើយ វិមានដែលខ្ញុំបាន ហើយនេះ ដោយបុញ្ញកម្មនេះឯង ជាអំពើមិនលាមក ។*

សេចក្តីនោះ ងាយយល់ទាំងអស់ ។

លំដាប់នោះ ពួកពាណិជបានឃើញទេវបុត្រនិងវិមានរបស់ទេវបុត្រនោះ យ៉ាងជាក់ច្បាស់ ទើបជឿនូវផលនៃកម្ម កាលប្រកាសនូវជំនឿក្នុងផលនៃកម្មរបស់ខ្លួន បានពោល ២ គាថាថា :

*បានឮមកថា ពួកនរជន អ្នកប្រកបដោយបញ្ញា តែងពោលពាក្យពិត ពាក្យរបស់បណ្ឌិតទាំងឡាយ មិនឃ្លៀងឃ្លាត បុគ្គលអ្នកមានបុញ្ញកម្ម ទៅក្នុងទីណា ៗ ប្រាថ្នាបានតាមចំណង់ រមែងរីករាយក្នុងទីនោះៗ សេចក្តីសោក និងសេចក្តីខ្សឹកខ្សួល ការសម្លាប់ ការចង និងសេចក្តីសៅហ្មងគ្រប់យ៉ាង មាននៅក្នុងទីណា ៗ បុគ្គលមានកម្មដ៏លាមក ទៅក្នុងទីនោះ ៗ រមែងមិនរួចចាកទុគ្គតិ ក្នុងកាលម្តងឡើយ ។*

បណ្តាបទទាំងនោះ បទថា **សោចបរិទ្ទេវោ** ប្រែថា សេចក្តីសោក និងសេចក្តីខ្សឹកខ្សួល, ហេតុដែលនាំឱ្យកើតនូវសេចក្តីវិនាស ហៅថា **បរិក្កិលេស** ។

កាលពួកគេកំពុងនិយាយគ្នាយ៉ាងនេះ សម្បកផ្លែច្រេស ដែល-ចាស់ជោរណាស់ហើយ របេះទង ព្រោះភាពចាស់ជោរ ( នោះ ) ក៏

ជ្រុះចាកដើម ជិតទ្វារវិមាន ព្រោះហេតុនោះ ទេវបុត្រព្រមទាំងទេវបរិវារក៏កើតនូវសេចក្ដីទោមនស្ស ពួកពាណិជឃើញដូច្នោះ ទើបពោលនូវគាថាថា :

*ទេវជន ( របស់អ្នក ) មានសភាពងេងងោង ដូចជាទឹកល្អក់ ដែលកើតអំពីភក់ ក្នុងមួយស្របក់នេះ នៃទេវកុមារ សេចក្ដី-ទោមនស្ស កើតមានដល់ជន ជាបរិស័ទនេះផង ដល់អ្នកផង តើព្រោះហេតុ ដូចម្ដេចហ្ន៎ ។*

បណ្ដាបទទាំងនោះ បទថា **សម្ភន្តរូបោវ** សេចក្ដីថា ដូចអ្នកមានសភាពវង្វេងអស់ ព្រោះសេចក្ដីសោក ។ បទថា **ជនោ** បានដល់ ជន គឺទេវតា ។ បទថា **អស្មិំ មុហុត្តេ** បានដល់ ក្នុងមួយរំពេចនេះ ។ បទថា **កលលីកតោ** បានដល់ ត្រូវធ្វើឱ្យដូចជាភក់, អធិប្បាយថា ល្អក់ដូចទឹកដែលនៅជាមួយភក់ ។ បទថា **ជនស្សិមស្ស តុយ្ហញ្ច** បានដល់ ដល់ទេវតាដែលជាបរិវាររបស់អ្នកនេះ និងដល់ខ្លួនអ្នក ។ បទថា **អបច្ចយោ** បានដល់ សេចក្ដី-ទោមនស្ស ។

ទេវបុត្របានស្ដាប់ដូច្នោះហើយ ទើបពោលថា :

*នៃអ្នកទាំងឡាយ ក្លិនទាំងឡាយ ក្លិនទិព្វទាំងឡាយ ក្រអូប-ឈ្ងុយឈ្ងប់ រមែងផ្សាយចេញអំពីព្រៃប្រេស ក្លិនទាំងនោះ តែងអប់*

*វិមាននេះ កំចាត់បង់នូវងងឹត ទាំងថ្ងៃទាំងយប់ ផ្កាក្រពុំមួយ ៗ នៃដើម-ព្រៃសទាំងនេះ តែងលៀនចេញអំពីទង ដោយកាលកន្លងទៅ ១០០ ឆ្នាំ ចំនួន ១០០ ឆ្នាំ របស់មនុស្ស កន្លងទៅហើយ ខ្ញុំមកកើត ក្នុងទេវវិមាននេះ ក្នុងទេវនិកាយ នៃអ្នកទាំងឡាយ លុះខ្ញុំឋិតនៅក្នុងវិមាននេះ អស់កំណត់ ៥០០ ឆ្នាំទិព្វហើយ នឹងច្យុតដោយអស់អាយុផង ដោយអស់បុណ្យផង ទើបខ្ញុំជ្រប់ស្រពោន ដោយសេចក្ដីសោកស្ដាយនោះឯង ។*

បណ្ដាបទទាំងនោះ បទថា **សិរីសវនា** បានដល់ អំពីព្រៃព្រៃស ទេវបុត្រហៅពួកពាណិជថា **តាតា** ក្លិនក្រអូបដ៏ជាទិព្វទាំងនេះ គឺដែលប្រចក្ស ដល់ពួកអ្នកនិងខ្ញុំ មានក្លិនក្រអូបក្រៃពេក រមែងផ្សាយ គឺផ្សាយទៅដោយជុំវិញ ក្លិនទិព្វទាំងនោះ កាលផ្សាយទៅយ៉ាងនេះ រមែងក្រអូបឈ្ងុយឈ្ងប់ពាសពេញវិមាននេះ ឱ្យទទួលក្លិនបានយ៉ាងល្អតែម្ដង មិនមែនក្រអូបឈ្ងុយឈ្ងប់តែម្យ៉ាងប៉ុណ្ណោះទេ តាមពិតថែមទាំងកម្ចាត់បង់នូវភាពងងឹតដោយរស្មីរបស់ខ្លួនទៀតផង ព្រោះហេតុនោះ ទេវបុត្រទើបពោលថា **ទិវា ច រត្តោ ច តមំ និហន្ត្វា** ដូច្នេះ ។

បទថា **ឥមេសំ** បានដល់ ដើមព្រៃសទាំងឡាយ ។ បទថា **សិបាដិកា** បានដល់ សម្បកផ្លែព្រៃស ។ បទថា **ផលន្តិ** សេចក្ដីថា ទុំហើយជ្រុះចាកទង ឬថា ផ្លែបែកហើយ ក៏ជ្រុះ ។ បទថា

**មានុស្សកំ វស្សសតំ អតីតំ** សេចក្តីថា ព្រោះកន្លងទៅ ១០០ ឆ្នាំ សម្បកផ្លែដើមច្រេសនេះនឹងបែក និងដែលបែកហើយក៏មាន ដូច្នោះ ១០០ ឆ្នាំមនុស្សរបស់ខ្ញុំទើបកន្លងទៅហើយ ចាប់តាំងពី គឺផ្តើមពីខ្ញុំចូលដល់ គឺកើតក្នុងពួកនេះ គឺក្នុងទេវតាពួកនេះ ខ្ញុំមានអាយុ ៥០០ ឆ្នាំទិព្វ ព្រោះដូច្នោះ អាយុរបស់ខ្ញុំកំពុងអស់ ដូច្នោះខ្ញុំទើបជ្រប់ស្រពោនព្រោះសេចក្តីសោកដូច្នេះ ទេវបុត្រពន្យល់ដូចពោលមកនេះ ព្រោះហេតុនោះ ទេវបុត្រទើបពោលថា **ទិព្វានហំ វស្សសតានិ បញ្ច ។ បេ ។ តេនេវ សោកេន បមុច្ឆិតោស្មិ** ដូច្នេះ ។

លំដាប់នោះ ពួកពាណិជនាំគ្នានិយាយលួងលោមទេវបុត្រនោះថា :

*ទេវបុត្រនោះ ប៉ុនអម្បាល បានទូវវិមាន ( ដ៏ល្អ ) មិនអាចថ្ងឹងបាន អស់កាលយូរហើយ ម្តេចក៏នៅសោកស្តាយ ចំណង់បើពួកទេវបុត្រណា ដែលកើតក្នុងវិមានក្រៅនេះ ពួកទេវបុត្រនោះ ជាអ្នកមានបុណ្យតិច ទើបគួរសោកស្តាយពិតមែន ។*

ក្នុងគាថានោះ អធិប្បាយថា នរណា ៗ ក៏ដោយដែលមានអាយុតិចមានបុណ្យតិច គួរសោកស្តាយព្រោះអាស្រ័យសេចក្តីស្លាប់ តែទេវបុត្រដូចជាអ្នកបរិបូណ៌ដោយអានុភាពទិព្វ មានអាយុដល់ទៅ ៩ លានឆ្នាំយ៉ាងនេះ នឹងសោកស្តាយធ្វើអ្វី គឺមិនគួរសោកស្តាយ

ឡើយ ទេវបុត្រសប្បាយចិត្តដោយពាក្យលួងលោមត្រឹមតែប៉ុណ្ណោះឯង ក៏បានទទួលពាក្យពាណិជទាំងនោះ ហើយកាលនឹងពន្យល់ដល់ពាណិជទាំងនោះ ទើបពោលនូវគាថាថា :

*អ្នកទាំងឡាយ ពោលពាក្យជាទីស្រឡាញ់ណា ចំពោះខ្ញុំ ពាក្យនោះ ជាពាក្យសមគួរដល់ខ្ញុំផង ជាពាក្យដែលអ្នកទាំងឡាយគប្បីទូន្មានដល់ខ្ញុំផង នែអ្នកទាំងឡាយ ឯពួកអ្នកសោត ខ្ញុំក៏បានតាមគ្រប់គ្រងហើយ អ្នកទាំងឡាយ ចូរទៅរកទីមានសួស្តី គួរតាមប្រាថ្នាចុះ ។*

បណ្តាបទទាំងនោះ បទថា **អនុច្ឆវី** បានដល់ សមគួរ គឺការពោលដាស់តឿនរបស់ពួកអ្នកនោះឯង សមគួរ ។ បទថា **ឱវទិយញ្ច មេ តំ** សេចក្តីថា ពាក្យនោះដែលពួកអ្នកពោល គឺគប្បីពោលជាឱវាទដល់ខ្ញុំ, សេចក្តីថា ព្រោះអ្នកទាំងឡាយពោលវាចាជាទីស្រឡាញ់ គឺពាក្យជាទីស្រឡាញ់ ដោយពាក្យថា **ភទ្ទំ នុ សោវចេយ្យំ** ជាដើម នឹងខ្ញុំ គឺដល់ខ្ញុំណា ម្យ៉ាងទៀត ការនិយាយ ការពោលដោយវាចាជាទីស្រឡាញ់ណា ការពោលនោះរបស់ពួកអ្នកនោះឯងសមគួរ មួយវិញទៀត ព្រោះអ្នកទាំងឡាយពោលវាចាជាទីស្រឡាញ់ណា ដូច្នោះ ការពោលវាចាជាទីស្រឡាញ់របស់អ្នកទាំងឡាយនោះ ជា-ការដែលអ្នកទាំងឡាយដាស់តឿន គឺគប្បីពោលទូន្មានផង ខ្ញុំគួរធ្វើឱ្យ

សមគួរដល់ឱវាទផង សមគួរដល់ខ្ញុំ ដែលខ្ញុំធ្វើហើយ ដើម្បីនឹងឆ្លើយនូវសំនួរដែលនឹងកើតមានឡើងថា ធ្វើនូវសេចក្តីនោះ ដូចម្តេច ? ដូច្នោះទេវបុត្រទើបពោលថា **ត្វម្ហេ ខោ តាតា** ជាដើម ។ បណ្តាបទទាំងនោះ បទថា **មយានុគុត្តា** សេចក្តីថា ខ្ញុំនឹងតាមគ្រប់គ្រងរក្សាពួកអ្នក រហូតដល់ពួកអ្នកឆ្លងផុតផ្លូវកន្តារ ក្នុងសមុទ្រ-ខ្សាច់ដែលពួកអមនុស្សគ្រប់គ្រងនេះទៅ គឺដល់ទីដែលប្រាថ្នា គឺតាមសេចក្តីគាប់ចិត្ត កាន់ទីដែលមានសួស្តី គឺដោយសុវត្ថិភាព ។

លំដាប់នោះ ពួកពាណិជកាលនឹងប្រកាសនូវភាពជាអ្នកកតញ្ញូ បានពោលនូវគាថាថា :

*ពួកខ្ញុំជាអ្នកត្រូវការដោយទ្រព្យ កំពុងប្រាថ្នានូវការចំណេញ ទើបដើរទៅកាន់ប្រទេស ឈ្មោះ **សិន្ធុ** និង ប្រទេសឈ្មោះ **សោវីរៈ** ក៏ប្រកបការងារតាមសមគួរ បានបរិច្ចាគបរិបូណ៌ហើយ នឹងធ្វើនូវ-ការឆ្លងចំពោះសេរិស្សកវិមានដ៏ឱឡារិក ។*

បណ្តាបទទាំងនោះ បទថា **យថា បយោគា** បានដល់ ប្រកបកម្មតាមសមគួរដល់បដិញ្ញា ( សេចក្តីប្តេជ្ញា ) ដែលបានធ្វើទុកក្នុងកាលឥឡូវនេះ ។ បទថា **បរិបុណ្ណចាគា** ប្រែថា មានចាគៈបរិបូណ៌ គឺបរិច្ចាគរបស់ដែលគួរជាទីប្រាថ្នាដើម្បីធ្វើបុណ្យឆ្លងយ៉ាងឱឡារិក ។ បទថា **មហំ** បានដល់ ការឆ្លងជាការបូជា ( បូជាដោយការឆ្លង ) ។

ទេវបុត្របដិសេធនូវបុណ្យឆ្លង និងណែនាំពាណិជទាំងនោះ ក្នុងវត្ថុដែលគួរធ្វើទៀត ទើបពោលថា :

*អ្នកទាំងឡាយ កុំធ្វើនូវការឆ្លង ចំពោះសេរិស្សកវិមានឡើយ អ្នកទាំងឡាយ ពោលពាក្យណា ពាក្យទាំងអស់នោះ នឹងមានដល់អ្នកទាំងឡាយ ៗ គប្បីវៀរបង់កម្មលាមកទាំងឡាយផង ចូរអធិដ្ឋានការប្រកបរឿយ ៗ នូវកុសលធម៌ផង ។*

បណ្ដាបទទាំងនោះ បទថា **យំ វទេថ** សេចក្ដីថា អ្នក-ទាំងឡាយ ប្រាថ្នាធ្វើដំណើរឱ្យដល់សិន្ធុប្រទេសនិងសោវីរៈប្រទេស ដោយសុវត្ថិភាព និងប្រាថ្នានូវការចំណេញដ៏ច្រើនក្នុងប្រទេសនោះ ពោលពាក្យជាដើមថា **គន្ត្វាមយំ** ដូច្នេះ ណា ពាក្យទាំងអស់នោះ នឹងមានដល់ពួកអ្នក គឺដល់អ្នកទាំងឡាយយ៉ាងនោះតែម្ដង អ្នក-ទាំងឡាយ ចូរកុំសង្ស័យក្នុងរឿងនោះឡើយ តែចាប់តាំងពីនេះទៅ អ្នកទាំងឡាយ ត្រូវវៀរចាកការធ្វើនូវអំពើបាប មានបាណាតិបាតជាដើម ។ បទថា **ធម្មានុយោគំ** បានដល់ ប្រកបរឿយ ៗ នូវ-កុសលធម៌មានឱ្យទានជាដើម ។ បទថា **អធិដ្ឋហាថ** បានដល់ ចូរតាមសិក្សា នេះជាការឆ្លងនៃសេរីសកទេវបុត្រ សេរីសកទេវបុត្រពន្យល់ដូចបានពោលមកនេះ ។

ទេវបុត្រកាលនឹងអនុគ្រោះឧបាសកណា ក៏ប្រាថ្នានឹងរក្សា

និងការពារពាណិជទាំងនោះទុក កាលទេវបុត្រសរសើរនូវកិត្តិគុណរបស់ឧបាសកនោះហើយ ក៏ណែនាំឧបាសកនោះដល់ពាណិជទាំងនោះ រួចហើយក៏បានពោលនូវគាថាទាំងនេះថា :

*ក្នុងពួកនេះ មានឧបាសកម្នាក់ ជាពហុស្សូត បរិបូណ៌ដោយសីលនិងវត្ត ជាអ្នកមានសទ្ធាផង មានការបរិច្ចាគផង មានសីល ជាទីស្រឡាញ់ផង ជាអ្នកឈ្លាសវៃ មានសេចក្តីសន្តោស មានប្រាជ្ញា ជាអ្នកដឹងច្បាស់ មិនពោលនូវពាក្យកុហក មិនគិតបៀតបៀន នូវអ្នកដទៃ មិនពោលពាក្យញុះញង់ ដែលជាពាក្យមិនពិត គប្បីពោលវាចាដ៏ពីរោះ ជាវាចាមិនរឹរុះ ប្រកបសេចក្តីគោរព សេចក្តីកោតក្រែង មានខ្លួនទូន្មានហើយ មិនមែនជាអ្នកលាមកអាក្រក់ ជាអ្នកបរិសុទ្ធក្នុងអធិសីល មួយទៀត ឧបាសកនោះ ជាបុរសចិញ្ចឹមមាតាបិតា តាមធម៌ ប្រព្រឹត្តស្អាត ឧបាសកនោះ ទំនងជាស្វែងរកភោគៈទាំងឡាយ ព្រោះហេតុតែមាតាបិតាពិត មិនមែនដើម្បីខ្លួនទេ មួយទៀត បុរសណា អំណើះអំពីមាតាបិតាទៅ ជាអ្នកមានចិត្តទោរទន់ ទៅរកព្រះនិព្វាន ទាំងប្រព្រឹត្តនូវសាសនព្រហ្មចរិយៈ ជាអ្នកមានកាយ វាចា ចិត្ត មិនវៀច មិនអួតអាង មិនមានពុតត្បុត មិនគប្បីជួញ ដោយលេសកប្ប គឺមិនគប្បីបញ្ចេញពាក្យ ដោយអំណាចកលមាយា និងការអួតអាង បុរសប្រាកដដូច្នោះនោះ ឈ្មោះថា អ្នកធ្វើនូវកម្មល្អ ឋិតនៅ*

*ក្នុងធម៌ ម្ដេចនឹងបាននូវទុក្ខ ខ្ញុំធ្វើឱ្យប្រាកដដោយខ្លួនឯង ព្រោះករុណាចំពោះឧបាសកនោះ ម្នាលពាណិជទាំងឡាយ ហេតុនោះ អ្នកទាំងឡាយ ចូររមិលមើលខ្ញុំចុះ ប្រសិនបើអ្នកទាំងឡាយ វៀរចាកឧបាសកនោះ នឹងទៅជាបុគ្គលវិលវល់ ដូចជាមនុស្សខ្វាក់ ភាន់ភាំងនៅក្នុងព្រៃគប្បីដល់នូវភាពជាផេះ ការគប់រកមនុស្សផ្ដេសផ្ដាស ជាអ្នកបៀតបៀនគេ ជាការងាយ ការគប់រកសប្បុរស ជាគុណនាំមកនូវសេចក្ដីសុខ ។*

បណ្ដាបទទាំងនោះ បទថា **សឡេ** បានដល់ ពួកឈ្មួញរទេះ ។ បទថា **វិចក្ខណោ** បានដល់ ជាអ្នកឈ្លាសក្នុងវត្ថុដែលនឹងគប្បីធ្វើនោះ ៗ ។ បទថា **សន្តសិតោ** បានដល់ ជាអ្នកសន្តោស ។ បទថា **មតីមា** សេចក្ដីថា ជាអ្នកមានចំណេះដឹង ព្រោះដឹងនូវប្រយោជន៍លោកនេះ និងប្រយោជន៍លោកខាងមុខ ។ ដោយ-**កម្មស្សកតាញាណ** ជាដើម ។

បទថា **សញ្ញានមានោ ន មុសា ភណេយ្យ** សេចក្ដីថា មិននិយាយកុហកទាំងដឹងខ្លួន ។ បទថា **វេភូតិកំ** ( បិដកថា **វិភូតិកំ** ) សេចក្ដីថា មិនគប្បីធ្វើ គឺមិនគប្បីពោលពាក្យញុះញង់ ដែលមានឈ្មោះថា ***វេភូតិកៈ*** ព្រោះធ្វើអ្នកដែលធ្លាប់អនុគ្រោះគ្នាឱ្យបែកចាក-គ្នា ។

បទថា **សប្បតិស្សោ** សេចក្តីថា មានសេចក្តីកោតក្រែង គឺមានសេចក្តីស្ងប់ស្ងៀម ព្រោះមានសេចក្តីប្រព្រឹត្តទន់ភ្លន់បន្ទាបខ្លួន ក្នុងបុគ្គលដែលនៅក្នុងឋានៈជាគ្រូ , ឈ្មោះថា **សប្បតិស្ស** ព្រោះ អត្ថថា ប្រព្រឹត្តទៅដោយសេចក្តីកោតក្រែង ។ បទថា **អធិសីលេ** បានដល់ ក្នុងអធិសីលសិក្ខាដែលឧបាសកគប្បីរក្សា ។ បទថា **អរិយវុត្តិ** បានដល់ មានសេចក្តីប្រព្រឹត្តបរិសុទ្ធ ។

បទថា **នេក្ខម្មគោណោ** បានដល់ បង្អោនទៅក្នុងព្រះ-និព្វាន ។ បទថា **ចរិស្សតិ ព្រហ្មចរិយំ** សេចក្តីថា នឹងបួស ប្រព្រឹត្តនូវសាសនព្រហ្មចរិយៈ ។

បទថា **លេសកប្បេន** បានដល់ ប្រើលេសដ៏សមរម្យ ។ បទថា **ន ច វោហរេយ្យ** សេចក្តីថា មិនគប្បីបញ្ចេញពាក្យសម្តី ដោយអំណាចមាយាសាថេយ្យៈ ។ បទថា **ធម្មេ ឋិតោ កិន្តិ លភេថ ទុក្ខំ** សេចក្តីថា អ្នកឋិតនៅក្នុងធម៌ គឺអ្នកប្រព្រឹត្តធម៌ ប្រព្រឹត្តស្មើ ដោយន័យដូចដែលបានពោលរួចមកហើយយ៉ាងនេះ នឹងគប្បីបាន គឺ គប្បីដល់នូវសេចក្តីទុក្ខ ដូចម្តេច គឺដោយប្រការដូចម្តេច ។

បទថា **តំ ការណា** ( បិដកថា **តំ ការុណា** ) បានដល់ ឧបាសកនោះជានិមិត្ត គឺ ព្រោះហេតុនៃឧបាសកនោះ ។ បទថា **ឃាតុកាមោម្ហិ អត្តនា** សេចក្តីថា ខ្ញុំនេះឯង បានបង្ហាញខ្លួនដល់អ្នក

ទាំងឡាយ បាឋៈថា **អត្តានំ** ក៏មាន សេចក្តីថា ខ្ញុំបានធ្វើខ្លួនរបស់ខ្ញុំឱ្យប្រាកដដល់អ្នកទាំងឡាយ ។ បទថា **តស្មា** សេចក្តីថា ព្រោះហេតុដែលខ្ញុំប្រព្រឹត្តគោរពកោតក្រែងចំពោះព្រះធម៌ កាលរក្សានូវព្រះធម៌នោះ ក៏ឈ្មោះថា រក្សានូវពួកអ្នកផងដែរ ដូច្នោះ ពួកអ្នកចូរឃើញនូវព្រះធម៌ គឺចូរពិនិត្យមើលនូវព្រះធម៌ប៉ុណ្ណោះថា គួរប្រព្រឹត្ត ។ បទថា **អញ្ញត្រ តេន ហិ តស្មិ ភវេថ** សេចក្តីថា ប្រសិនបើអ្នកទាំងឡាយ វៀរចាកឧបាសកនោះនាំគ្នាមកក៏នឹងក្លាយជាអ្នកមិនមានទីពឹង មិនមានទីអាស្រ័យ ដល់នូវភាពជាផេះផង់ក្នុងសមុទ្រខ្សាច់នេះ ។ បទថា **ខិប្បមានេន** បានដល់ លះបង់ចំអកឡកឡឺយ បៀតបៀនយ៉ាងនេះ ។ បទថា **លហុំ** ធ្វើបានដោយងាយ ។ បទថា **បរេន** ប្រែថា ក្រៃលែង, ម្យ៉ាងទៀត ប្រែថា អ្នកដទៃព្រោះហេតុនោះ ការសេពគប់សប្បុរសទើបជាសុខពិត អធិប្បាយថា អ្នកដែលតាំងមាំនៅក្នុងខន្តិ និងសោរច្ចៈ ទោះបីត្រូវនរណាស្តីថានូវរឿងអ្វីមួយក៏ដោយ ក៏មិនតបតឡើយ ។

ពួកពាណិជចង់ដឹងថា ឧបាសកដែលទេវបុត្រពោលដល់នោះ (តើជានរណា) ទើបពោលនូវគាថាថា :

*បុរសនោះឈ្មោះអ្វី ធ្វើការងារដូចម្តេច នាមដែលមាតាបិតាឱ្យ តើដូចម្តេច មួយទៀត គោត្ររបស់គាត់តើដូចម្តេច នែយក្ខ*

*អ្នកមកក្នុងទីនេះ ដើម្បីសេចក្ដីអនុគ្រោះបុរសណា ពួកយើងចង់ឃើញ បុរសនោះដែរ ព្រោះថា អ្នកពេញចិត្តបុរសណា បុរសនោះចំជាមានលាភ ។*

បណ្ដាបទទាំងនោះ បទថា **កិន្នាម សោ** សេចក្ដីថា ដោយឈ្មោះសត្វកើត គឺសត្វនោះ ជានរណា ។ បទថា **កិញ្ច ករោតិ កម្មំ** សេចក្ដីថា បណ្ដាការងារទាំងឡាយ មានកសិកម្ម និងពាណិជកម្មជាដើម គេធ្វើការងារដូចម្ដេច ។ បទថា **កឹ នាមធេយ្យំ** សេចក្ដីថា បណ្ដាឈ្មោះមាន តិស្ស: ផុស្ស: ជាដើម ឈ្មោះដែលមាតាបិតាដាក់ឱ្យគេ ឈ្មោះអ្វី ឬបណ្ដាគោត្រមាន ភគវ: ភារទ្វាជ: ជាដើម គេជាគោត្រអ្វី ។ បទថា **យស្ស តុវំ បិហេសិ** សេចក្ដីថា អ្នកស្រឡាញ់ឧបាសកណា ។

ឥឡូវនេះ ទេវបុត្រកាលនឹងបង្ហាញនូវឧបាសកនោះដោយឈ្មោះ និងគោត្រជាដើម ទើបពោលថា :

*បុរសណា ជាជាងកាត់កោរ ឈ្មោះ* ***សម្ភវ:*** *ជាឧបាសក អ្នកចិញ្ចឹមជីវិតអាស្រ័យនូវស្នាតសក់និងក្រាស ឧបាសកនោះ ជាអ្នកបម្រើរបស់អ្នក ចូរអ្នកស្គាល់បុរសនោះចុះ អ្នកទាំងឡាយ កុំបៀតបៀនឧបាសកនោះឡើយ ឧបាសកនោះ មានសីល ជាទីស្រឡាញ់ល្អណាស់ ។*

បណ្ដាបទទាំងនោះ បទថា **គហ្បគោ** ប្រែថា ជាងកាត់កោរ ។ បទថា **សម្ពុទនាមធេយ្យោ** ប្រែថា មានឈ្មោះយ៉ាងនេះថា សម្ពុវៈ ។ បទថា **គោច្ឆផលូបជីវី** ( បិដកថា **គោច្ឆគណ្ឌូបជីវី** ) ប្រែថា អ្នកអាស្រ័យកៅអីផ្តៅ និងផ្លែចិញ្ចឹមជីវិត ( ជាងកាត់កោរ ) ដែលឈ្មោះថា **គោច្ឆៈ** ក្នុងបទថា **គោច្ឆផលូបជីវី** នោះ បានដល់គ្រឿងសម្រេចនូវការសិតសក់ជាដើម ដើម្បីចាត់របៀបម៉ូដសក់ជាដើម ។ បទថា **បេសិយោ** ( បិដកថា **បេសសិយោ** ) បានដល់អ្នកបម្រើ គឺ អ្នកជួយខ្នះខ្នែង ។

ឥឡូវនេះ ពាណិជទាំងឡាយស្គាល់ឧបាសកនោះហើយពោលថា :

*នែយក្ខ អ្នកពោលពាក្យណា យើងទាំងឡាយ រមែងដឹងពាក្យនោះ តែយើងទាំងឡាយមិនដឹងបុរសនោះថា ជាអ្នកប្រាកដដូច្នេះឡើយ នែយក្ខ លុះពួកយើងបានឮពាក្យរបស់អ្នកលើសលុប នឹងបូជាបុរសនោះដែរ ។*

បណ្ដាបទទាំងនោះ បទថា **ជានាមសេ** សេចក្តីថា ពួកយើងស្គាល់អ្នកដែលអ្នកពោលដល់នោះ ដោយចំពោះហើយ ។ បទថា **ឯតំសោ** អធិប្បាយថា ពួកយើងមិនដឹងឡើយថា ឧបាសកនោះប្រាកដដូច្នេះ ដូចដែលអ្នកប្រកាសនូវកិត្តិគុណ គឺមិនបានដឹងដូចដែល-

អ្នកប្រកាសទេ ។

ឥឡូវនេះ ដើម្បីនឹងលើកពាណិជទាំងនោះឡើងកាន់វិមានរបស់ខ្លួនហើយដាស់តឿន ទើបពោលគាថាថា :

*ពួកមនុស្សឯណានីមួយ ទាំងអស់ក្នុងទីប្រជុំនេះ ទោះក្មេងក្តី ចាស់ក្តី កណ្តាលក្តី មនុស្សទាំងអស់នោះ ចូរឡើងកាន់វិមាន ពួកមនុស្សអ្នកមានសេចក្តីកំណាញ់ ចូរមើលនូវផលនៃបុណ្យទាំង-ឡាយចុះ ។*

បណ្តាបទទាំងនោះ បទថា **មហត្តា** ប្រែថា មនុស្សចាស់ ។ បទថា **អលម្ពន្តុ** ( បិដកថា **អាលភន្តុ** ) ប្រែថា ចូរឡើង ។ បទថា **កទរិយា** ប្រែថា មនុស្សកំណាញ់ គឺមនុស្សមានប្រក្រតីមិនបរិច្ចាគ ។

ឥឡូវនេះ ព្រះធម្មសង្គាហកាចារ្យទាំងឡាយពោលគាថាទុក ៦ គាថា នៅចុងបញ្ចប់រឿងថា :

*ពាណិជទាំងអស់នោះ ក្នុងទីនោះពោលថា ខ្ញុំមុនគេ ៗ ហើយក៏ធ្វើនូវជាងកាត់កោរនោះឱ្យដើរមុខ ក្នុងទីនោះ ពាណិជទាំងអស់នោះ បានឡើងកាន់វិមាន ដូចជាភពនៃទេវរាជ ឈ្មោះ**វាសវៈ**ដែរ ពាណិជទាំងអស់នោះក្នុងទីនោះពោលថា ខ្ញុំមុនគេ ៗ ប្តេជ្ញានូវភាពនៃខ្លួន ជាឧបាសក ជាអ្នកវៀរចាកបាណាតិបាតផង វៀរចាកការកាន់យកទ្រព្យ ដែលគេមិនបានឱ្យក្នុងលោកផង មិនផឹកទឹកស្រវឹងផង*

*មិននិយាយពាក្យកុហកផង ជាអ្នកសន្តោសដោយប្រពន្ធរបស់ខ្លួនផង ពួកពាណិជទាំងអស់នោះ ក្នុងទីនោះពោលថា ខ្ញុំមុនគេ ៗ ប្តូផ្ទានូវ-ភាពនៃខ្លួនជាឧបាសក ឈ្មួញរទេះ មានសេចក្តីត្រេកអររឿយ ៗ ដោយឫទ្ធិនៃទេវតា ( លុះទេវតា ) អនុម័តហើយ ក៏ដើរចេញទៅ ពាណិជទាំងនោះទៅកាន់ប្រទេសឈ្មោះ សិន្ធុ និងប្រទេសឈ្មោះ សោវីរៈ ជាអ្នកត្រូវការដោយទ្រព្យ ប្រាថ្នានូវការចំណេញ ប្រកប ព្យាយាមគួរតាមអធ្យាស្រ័យ មានលាភបរិបូណ៌ ត្រឡប់មកកាន់* ***ក្រុងបាតលិបុត្ត****វិញ មិនមានអន្តរាយ លុះបុរសទាំងនោះ ទៅផ្ទះរបស់ ខ្លួនហើយ ក៏មានសួស្តី ជួបជុំនឹងបុត្តភរិយា មានចិត្តរីករាយ ត្រេកអរ ព្រីព្រួច ទើបនាំគ្នាធ្វើការឆ្លងដ៏ឱឡារិក ចំពោះ****សេរីសកវិមាន*** *ពួក ពាណិជទាំងនោះ បានសាងបរិវេណ ១ ឈ្មោះ* ***សេរីសកៈ*** *ការសេព-គប់នឹងសប្បុរសទាំងឡាយ ជាគុណញុំាងប្រយោជន៍ ឱ្យសម្រេច ការសេពគប់នឹងបុគ្គលអ្នកមានធម្មគុណទាំងឡាយ រមែងមានឫទ្ធិ-ច្រើន ពួកសត្វ គឺនាយពាណិជ ទាំងអស់នោះ បានដល់នូវសេចក្តីសុខ ព្រោះអាស្រ័យសេចក្តីចម្រើន របស់ឧបាសកម្នាក់ ។*

បណ្តាបទទាំងនោះ បទថា **អហំ បុរេ** សេចក្តីថា ម្នាក់ ៗ ដណ្តើមគ្នានិយាយថា ខ្ញុំមុនគេ ៗ ។ ព្រះធម្មសង្គាហកាចារ្យពោលថា **តេ តត្ថ សព្វេវ** ពាណិជទាំងអស់នោះក្នុងទីនោះ ដូច្នេះហើយ-

ពោលថា **សព្វេ តេ** ពាណិជទាំងអស់នោះ ដូច្នេះទៀត ក៏ដើម្បី-សម្តែងថា ពាណិជទាំងអស់នោះ មានសេចក្តីខ្ពឹឃ្នាតក្នុងការឡើង ដោយប្រការណា ពាណិជទាំងអស់បានឡើងវិមាននោះ ដោយប្រការនោះ មិនមានអន្តរាយក្នុងការឡើងដល់នរណាម្នាក់ឡើយ ។ បទថា **មសក្កសារំ** ក្នុងបាទគាថាថា **មសក្កសារំ វិយ វាសវស្ស** លោកពោលសំដៅដល់ស្ថានសួគ៌ជាន់តាវត្តិង្ស ម្យ៉ាងទៀត សំដៅដល់ស្ថានសួគ៌ទាំងអស់ តែក្នុងទីនេះ គប្បីជ្រាបថា ភពនៃស្តេចសក្កទេវ-រាជ ព្រោះហេតុនោះ លោកទើបពោលថា **មសក្កសារំ វិយ វាសវស្ស** ដូច្នេះ ។

គ្រានោះ ពាណិជទាំងនោះឃើញវិមានហើយមានចិត្តជ្រះថ្លា តាំងនៅក្នុងឱវាទរបស់ទេវបុត្រនោះ តាំងនៅក្នុងសរណគមន៍ និងសីល ៥ បានទៅដល់ប្រទេសដែលខ្លួនប្រាថ្នា ដោយសួស្តី ដោយអានុភាពរបស់ទេវបុត្រនោះ ព្រោះហេតុនោះ លោកទើបពោលថា **តេ តត្ថ សព្វេ** ជាដើម ក្នុងគាថានោះមានសេចក្តីថា ឈ្មួញរទេះវិករាយដោយទេវឫទ្ធិជារឿយ ៗ បានទទួលអនុញ្ញាតហើយ ក៏ចៀស-ចេញទៅ សួរថា នរណាជាអ្នកអនុញ្ញាត ? ឆ្លើយថា ទេវបុត្រ សេចក្តីប្រាកដដូច្នេះ ។

បទថា **យថាបយោគា** ប្រែថា ធ្វើនូវសេចក្តីព្យាយាម

តាមសេចក្តីប្រាថ្នា ។ បទថា **បរិបុណ្ណលាភា** ប្រែថា មានលាភ-សម្រេចហើយ ។ បទថា **អក្ខតំ** ( បិដកថា **មក្ខតំ** ) បានដល់ ដល់ក្រុងបាតលិបុត្រដោយមិនលំបាក,ម្យ៉ាងទៀត បទថា **អក្ខតំ** ប្រែថា មិនឈឺថ្កាត់ មិនត្រូវគេបៀតបៀន សេចក្តីថា ដោយមិនមាន អន្តរាយ ។

បទថា **សឃរំ** ប្រែថា ផ្ទះរបស់ខ្លួន ។ បទថា **សោត្ថិវន្តោ** បានដល់ ប្រកបដោយសេចក្តីសួស្តី គឺមានសុវត្ថិភាព ដោយបទ ទាំង ៤ បទថា **អានន្ទី** ជាដើម , លោកពោលដល់ភាពជាអ្នកមាន សេចក្តីសប្បាយចិត្តទាំងអស់ ។ បទថា **សេរីសកំ តេ បរិវេណំ មាបយឹសុ** សេចក្តីថា ដើម្បីតាំងនៅក្នុងភាពជាអ្នកកតញ្ញូ រួចផុត ពីពាក្យសន្យា ពួកពាណិជបានសាងទេវាល័យ គឺទីលំនៅឈ្មោះ **សេរីសកៈ** តាមឈ្មោះរបស់ទេវបុត្រ ពេញត្រៀបត្រាដោយប្រាសាទ ផ្ទះកំពូល និងទីសម្រាកពេលថ្ងៃជាដើម ព័ទ្ធជុំវិញដោយកំពែង ប្រកបដោយខ្លោងទ្វារ មានបរិវេណដោយមានការពិនិត្យពិចារណា តាមបែបផែនដែលបានកំណត់ទុកនោះឯង ។

បទថា **ឯតានិសា** ប្រែថា ប្រាកដដូច្នេះ គឺការពារនូវវត្ថុ ដែលមិនជាប្រយោជន៍ និងឱ្យសម្រេចប្រយោជន៍បានយ៉ាងនេះ ។ បទថា **មហត្ថិកា** ប្រែថា មានប្រយោជន៍ធំ មានអានិសង្សច្រើន ។

បទថា **ធម្មគុណានំ** ប្រែថា មានគុណសេចក្តីល្អមិនឃៀងឃ្លាត ព្រោះដើម្បីសត្វតែម្នាក់ សត្វទាំងអស់ គឺសត្វដែលរាប់បញ្ចូលក្នុងឈ្មួញរទេះទាំងអស់នោះតែម្តង ក្នុងទីនោះ ក៏មានសេចក្តីសុខជួបប្រសព្វនូវសេចក្តីសុខដល់នូវសេចក្តីក្សេមក្សាន្ត ។

ចំណែកសម្តវឧបាសករៀននូវគាថាព័ន្ធដែលប្រព្រឹត្តទៅដោយពាក្យពោលពាក្យឆ្លើយឆ្លងរបស់**បាយាសិទេវបុត្រ** និងពាណិជទាំងនោះ ដោយទំនងដែលបានស្តាប់នោះឯង និងប្រាប់ដល់ព្រះថេរៈទាំងឡាយ, អាចារ្យពួកខ្លះពោលថា បាយាសិទេវបុត្រ ពោលចំពោះ **ព្រះសម្តវត្ថេរ** ។ ព្រះមហាថេរៈទាំងឡាយ មាន**ព្រះយសត្ថេរ** ជាប្រធាន បានលើកនូវរឿងនោះកាន់សង្គាយនា ក្នុងគ្រាសង្គាយនាលើកទី ២ ចំណែក**សម្តវឧបាសក**បានបួស ពេលដែលមាតាបិតាចែកឋានទៅហើយ បានតាំងនៅក្នុងព្រះអរហត្ត ។

**(ចប់រឿងសេរីសកប្រេតឬសេរីសកវិមាន)**

# ៣-រឿងនន្ទិកាប្រេត(១)

" ហាមឃាត់ការឱ្យទានស្លាប់ទៅកើតជាប្រេត "

( បិដកលេខ ៥៦, ទំព័រ ១១១ និងអដ្ឋកថា )

រឿងនន្ទិកាប្រេតនេះ មានពាក្យផ្ដើមថា **រាជា បិង្គលកោ នាម** ដូច្នេះ ។ ការកើតឡើងនៃរឿងនោះ តើដូចម្ដេច ?

រាប់ចាប់តាំងពីព្រះសាស្ដាទ្រង់បរិព្វាន កន្លងទៅបាន ២០០ ឆ្នាំ ក្នុង**សុរដ្ឋប្រទេស** មានព្រះរាជាមួយព្រះអង្គ ទ្រង់ព្រះនាមថា **បិង្គលៈ** ។ សេនាបតីរបស់ព្រះរាជានោះ ឈ្មោះថា **នន្ទកៈ** ជាមិច្ឆាទិដ្ឋិ មានសេចក្ដីយល់ខុស ដើរសរសើរនូវការប្រកាន់ខុស ដោយន័យជាដើមថា ទានដែលឱ្យហើយមិនមានផលឡើយ ដូច្នេះ, ធីតារបស់នាយនន្ទកៈនោះ ជាឧបាសិកា ឈ្មោះថា **ឧត្តរា**, គាត់បានរៀបចំឱ្យមានគូគ្រងក្នុងត្រកូលដែលស្មើគ្នា ។ ចំណែកនន្ទកសេនា-បតី ធ្វើកាលកិរិយាហើយ ក៏បានទៅកើតជាវិមានិកប្រេត នៅត្រង់ដើមជ្រៃធំ ក្នុងព្រៃភ្លើងឆេះ ។ កាលនន្ទកសេនាបតីនោះ ធ្វើកាលកិរិយាហើយ នាងឧត្តរា បានប្រគេននូវក្អមដែលពេញដោយទឹកក្រអូបស្អាត និង ត្រជាក់ និងភាជន៍ដែលពេញដោយនំ បរិបូណ៌-

១ = អដ្ឋកថាថា **នន្ទកប្រេត** ។

ដោយពណ៌ ក្លិន និងរស ដែលផ្សំដោយនំកុម្មាស ដល់ព្រះថេរៈជាព្រះខីណាស្រពមួយរូប ហើយឧទ្ទិសថា **សូមទក្ខិណាទាន សម្រេចដល់បិតារបស់ខ្ញុំចុះ** ។ ទឹកដ៏ជាទិព្វ និងនំប្រមាណមិនបាន ក៏បានកើតឡើងដល់ប្រេតនោះ ព្រោះទាននោះ ។ គេឃើញដូច្នោះ ទើបគិតយ៉ាងនេះថា យើងធ្វើកម្មដ៏លាមកហ្ន៎ ដែលឱ្យមហាជនកាន់យកខុស ដោយន័យជាដើមថា ទានដែលទាយកឱ្យហើយ រមែងមិនមានផលឡើយ ដូច្នេះ, ក៏ឥឡូវនេះ **ព្រះបាទបិង្គលៈ** ស្តេចយាងទៅប្រទានឱវាទដល់**ព្រះបាទធម្មាសោក**, ព្រះអង្គប្រទានឱវាទហើយ នឹងយាងត្រឡប់មកវិញ ណ្ហើយចុះ បើដូច្នេះយើងនឹងបន្ទោបង់នូវ**នត្ថិកទិដ្ឋិ** ។ មិនយូរប៉ុន្មានព្រះបាទបិង្គលៈ បានឱ្យឱវាទដល់ព្រះបាទធម្មាសោក កាលនឹងយាងត្រឡប់មកវិញ ទើបទ្រង់ធ្វើដំណើរទៅតាមផ្លូវនោះ ។

លំដាប់នោះ ប្រេតនោះ និម្មិតផ្លូវនោះ ឱ្យឆ្ពោះមុខទៅកាន់ទីលំនៅរបស់ខ្លួន ។ ក្នុងវេលាថ្ងៃត្រង់ ព្រះរាជា ស្តេចយាងទៅតាមផ្លូវនោះ ។ កាលព្រះអង្គយាងទៅ ផ្លូវខាងមុខប្រាកដ តែផ្លូវខាងក្រោយមិនប្រាកដដល់ព្រះអង្គឡើយ ។ បុរសដែលទៅក្រោយគេបង្អស់ ឃើញផ្លូវបាត់ទៅ ទើបខ្លាច ក៏បានស្រែកឡើង រត់ទៅក្រាបទូលដល់ព្រះរាជា, ព្រះរាជាទ្រង់ព្វដូច្នោះ ទើបភិតភ័យ មានព្រះទ័យតក់ស្លុត គង់ប្រថាប់នៅលើ-កដំរី ទតមើលទិសទាំង ៤ ក៏បានឃើញ

ដើមជ្រៃដែលជាទីលំនៅរបស់ប្រេត ទើបទ្រង់យាងឆ្ពោះព្រះភក្ត្រទៅកាន់ដើមជ្រៃនោះ មួយអន្លើដោយ**ចតុរង្គិនីសេនា** ( សេនាប្រកប-ដោយអង្គ ៤ ) ។ លុះព្រះរាជាយាងដល់ទីនោះដោយលំដាប់ ប្រេតប្រដាប់ដោយអាភរណៈទាំងពួង ក៏បានចូលទៅគាល់ព្រះរាជា ធ្វើនូវ-បដិសណ្ឋារៈរួចហើយ ក៏បានថ្វាយនំ និងទឹក ។ ព្រះរាជា មួយអន្លើដោយបរិវារ ទ្រង់លុបលាងរួចហើយ ក៏បានសោយនំនិងទឹក បំបាត់នូវសេចក្តីនឿយហត់ក្នុងដំណើរផ្លូវហើយ ទើបត្រាស់សួរប្រេតដោយន័យជាដើមថា អ្នកជាទេវតា ឬជាគន្ធព្វ ? ប្រេតបានក្រាបទូលនូវរឿងរបស់ខ្លួនតាំងពីដើម រហូតដល់ចប់ហើយ ទើបដោះព្រះរាជាចាកភាពជាមិច្ឆាទិដ្ឋិ ឱ្យតាំងនៅក្នុងសរណៈ និងសីល ។ ដើម្បីនឹងសម្តែងនូវរឿងនោះ ព្រះសង្គីតិកាចារ្យទាំងឡាយ ទើបពោលនូវ-គាថាទាំងឡាយថា :

***ព្រះរាជាព្រះនាមបិង្គលកៈ*** *ជាធំក្នុងសុរដ្ឋប្រទេស ស្តេចទៅកាន់ គំនាល់នៃព្រះបាទមោរិយៈ ( ព្រះបាទធម្មាសោក ) ហើយស្តេចត្រឡប់មក****សុរដ្ឋប្រទេស****វិញ ។ ព្រះរាជាស្តេចយាងកាត់ភក់ ក្នុងវេលាថ្ងៃត្រង់ដ៏ក្តៅ ក៏បានទតឃើញផ្លូវគួរជាទីត្រេកអរ ជាផ្លូវដែលប្រេតទាំងឡាយនិម្មិតហើយ ទើបព្រះរាជាទ្រង់ត្រាស់នឹងនាយសារថីថា ផ្លូវនេះគួរជាទីត្រេកអរ ជាផ្លូវដ៏ក្សេមក្សាន្ត ប្រកបដោយសួស្តី*

ជាផ្លូវមិនមានឧបទ្រពឡើយ ម្នាលសារថី ចូរអ្នកទៅតាមផ្លូវនេះវិញ ( ព្រោះយើង ) ទៅតាមផ្លូវនេះ ជិតដល់សុរដ្ឋប្រទេសហើយ ដូច្នេះ រូប**ព្រះពោធិសត្វ**ក្នុងសុរដ្ឋប្រទេស ក៏បានទៅតាមផ្លូវនោះជាមួយនឹងសេនាប្រកបដោយអង្គ ៤ ។

**បុរស** មានសភាពតក់ស្លុត បានក្រាបទូលស្តេចក្នុងសុរដ្ឋប្រទេស ដូច្នេះថា យើងដើរទៅតាមផ្លូវមិនស្រួល ជាទីស្ញប់ស្ញែងព្រឺព្រួចរោម ។ ផ្លូវខាងមុខប្រាកដ ផ្លូវខាងក្រោយមិនប្រាកដទេ យើងដើរទៅតាមផ្លូវមិនស្រួល ក្នុងទីជិតនៃពួកយមបុរសប្រេត ឯក្លិនអមនុស្សបក់មក ទាំងមានសំឡេងគឹកកងដ៏ខ្លាំង ដ៏អាក្រក់ ក៏ឮមក ។

**ព្រះរាជាក្នុងសុរដ្ឋប្រទេស** ទ្រង់មានសេចក្តីតក់ស្លុត ទើបត្រាស់ទៅនឹងនាយសារថីដូច្នេះថា យើងដើរទៅពារផ្លូវមិនស្រួល នាំឱ្យស្ញប់ស្ញែង នាំឱ្យព្រឺព្រួចរោម ផ្លូវខាងមុខប្រាកដ ផ្លូវខាងក្រោយមិនប្រាកដទេ ។ យើងដើរទៅពារផ្លូវមិនស្រួល ក្នុងទីជិតនៃពួកយមបុរសហើយ ឯក្លិនសរីរៈអមនុស្សក៏បក់មក ទាំងសំឡេងគឹកកងរំពងអាក្រក់ ក៏ឮមក ។ ( ទ្រង់ត្រាស់ដូច្នេះហើយ ) ក៏ឡើងគង់លើដំរី ហើយទតមើលទៅទិសទាំង ៤ បានឃើញដើមជ្រៃមួយដើម ជារុក្ខជាតផឹកនូវទឹក ដោយជើង បរិបូណ៌ដោយម្លប់ប្រហែលមេឃមានពណ៌ខៀវ ជាឈើមានសម្បុរដូចផ្ទៃមេឃ ព្រះរាជាត្រាស់

ទៅនឹងនាយសារថីថា ដើមឈើធំប្រហែលមេឃមានពណ៌ខៀវ ជាឈើមានសម្បុរដូចផ្ទៃមេឃនុ៎ះ ជាឈើអ្វី ។

**សារថី**ក្រាបទូលថា បពិត្រមហារាជ នោះជាដើមជ្រៃ ជារុក្ខ-ជាតផឹកទឹកដោយជើង បរិបូណ៌ដោយម្លប់ ប្រហែលមេឃមានពណ៌ខៀវ ជាឈើមានសម្បុរដូចផ្ទៃមេឃ ។

**ព្រះរាជាក្នុងសុវណ្ណប្រទេស** ស្តេចទៅត្រង់ដើមឈើធំ ប្រហែលមេឃមានពណ៌ខៀវ ជាឈើមានសម្បុរដូចផ្ទៃមេឃ ។ ព្រះរាជាស្តេចចុះពីកជ្ជីរ ហើយចូលទៅរកដើមឈើ ទ្រង់គង់ក្រោមម្លប់ឈើជាមួយនឹងអាមាត្យ និងជនជាបរិស័ទ ក៏បានទតឃើញបំពង់ទឹកដ៏ពេញ និងនំទាំងឡាយដ៏វិចិត្រ ។

( **ប្រេតនោះ** ) ក្លែងខ្លួនជាបុរសមានភេទដូចជាទេវតាស្អិតស្អាងគ្រឿងអាភរណៈទាំងពួង ហើយចូលទៅនិយាយនឹងព្រះ-រាជា ជាធំក្នុងសុវណ្ណប្រទេស ដូច្នេះថា បពិត្រមហារាជ ព្រះអង្គស្តេចមកល្អហើយ មួយទៀត ដំណើរព្រះអង្គស្តេចមក ឈ្មោះថា មកអំពីទីមិនឆ្ងាយ បពិត្រព្រះអរិន្ទមរាជ សូមព្រះសម្មតិទេពទ្រង់សោយនូវ-វិសុទ្ធិរស ទ្រង់សោយនូវនំទាំងឡាយ ។

**ព្រះរាជក្នុងសុវណ្ណប្រទេស** ព្រមទាំងអាមាត្យនិងជនជាបរិស័ទបានសោយនូវព្រះវិសុទ្ធិរសផង សោយនូវនំទាំងឡាយផង លុះ-

សោយរួចហើយ ទ្រង់ត្រាស់សួរដូច្នេះថា អ្នកជាទេវតា ឬជាគន្ធព្វ ឬមួយជាសក្កបុរិន្ទទៈ យើងមិនស្គាល់ បានជាសួរអ្នក យើងស្គាល់អ្នកដូចម្ដេចបាន ។

( **ប្រេតតបថា** ) ខ្ញុំមិនមែនជាទេវតា មិនមែនជាគន្ធព្វ មិនមែនជាសក្កបុរិន្ទទៈទេ បពិត្រមហារាជ ជាស្ដេចក្នុងសុរដ្ឋប្រទេស ខ្ញុំជាប្រេតទេតើ មកនៅក្នុងទីនេះ ។

**ព្រះរាជាត្រាស់ថា** ចុះអ្នកឯង មានសីលធម៌ ដូចម្ដេច មាន-សមាចារ ដូចម្ដេច ក្នុងសុរដ្ឋបុរី អ្នកឯងនេះ មានអានុភាពច្រើន ព្រោះអ្នកប្រព្រឹត្តនូវធម៌ដ៏ប្រសើរ ដូចម្ដេចខ្លះ ។

( **ប្រេតតបថា** ) បពិត្រព្រះអរិន្ទមមហារាជ ជាស្ដេចចម្រើនក្នុងដែន សូមព្រះអង្គ ព្រមទាំងពួកអាមាត្យ និងព្រាហ្មណ៍បុរោហិត ទ្រង់ព្រះសណ្ដាប់ពាក្យខ្ញុំនោះ ។ បពិត្រព្រះទេព ខ្ញុំនៅក្នុងសុរដ្ឋ-ប្រទេស ជាបុរសមានចិត្តអាក្រក់ មានសេចក្ដីយល់ខុស ទ្រុស្តសីល កំណាញ់ ជេរប្រទេចផ្ដាសាពួកជនដែលកំពុងឱ្យ កំពុងធ្វើ ហាមឃាត់ពួកជនច្រើន ធ្វើអន្តរាយដល់ពួកជនដទៃ ដែលកំពុងឱ្យ ( ខ្ញុំរមែង-និយាយរឿយៗ ថា ) ផលរបស់ទានមិនមានទេ តើផលនៃការសង្រួម គឺសីលនឹងមានមកពីណា អាចារ្យមិនមាន អ្នកណានឹងទូន្មានបុគ្គលដែលគេមិនទាន់ទូន្មាននោះបាន ។ ពួកសត្វសឹងតែស្មើ ៗ គ្នាទេ

ចាំបាច់មានបុគ្គលជាអ្នកគោរពកោតក្រែងត្រកូលរៀមច្បង ( ធ្វើអ្វី-ទៀត ) កម្លាំងក្ដី សេចក្ដីព្យាយាមក្ដី មិនមានហើយ តើការប្រឹងប្រែងរបស់បុរសមានមកអំពីណា ។ ផលរបស់ទានមិនមានទេ បុគ្គលមិនអាចធ្វើសត្វដែលមានពៀរឱ្យស្អាតបាន សត្វបានសេចក្ដីសុខទុក្ខដែលត្រូវបានកើតពីសេចក្ដីប្រែប្រួលតែងដឹកនាំទៅ ( មិន-មែនព្រោះកម្មដែលខ្លួនធ្វើទេ ) ។ មាតាបិតាបងប្អូនមិនមាន លោកដទៃក្រៅពីលោកនេះមិនមាន ការឱ្យទានមិនមាន ការបូជាមិនមាន ការតម្កល់ទាន ( ចំពោះសមណព្រាហ្មណ៍ ) ក៏មិនមាន ។ អ្នកណាកាត់ក្បាលបុរស មិនឈ្មោះថា សម្លាប់បុរសទេ ( ព្រោះ ) គ្មានអ្នកណាសម្លាប់ ( អ្នកណា ) តិចតួចទេ ទុកដូចជាបៀតបៀន ក្នុងចន្លោះនៃកាយទាំង ៧ ( មានផែនដីជាដើម ) ដែរ ។ ជីវៈជាសភាវៈផ្ដាច់មិនបាន ទម្លាយមិនបាន ( ព្រោះ ) ជួនកាលមានជ្រុង ៨ ជួនកាលមូលជាដុំ ( មានកំពស់ ) ៥០០ យោជន៍ អ្នកណាក៏មិនអាចនឹងផ្ដាច់បង់ជីវៈបានឡើយ ។ កាលបើអម្បោះហុងគេបោះចោលទៅ អម្បោះហុងនោះ រមែងរលាយយ៉ាងណាមិញ ជីវៈនោះ ក៏រលាយយ៉ាងនោះដែរ ។ បុរសបុគ្គល ចេញពីស្រុក ចូលទៅកាន់ស្រុកដទៃទៀតយ៉ាងណាមិញ ជីវៈនោះ ( ចេញពីកាយនេះ ) ចូលទៅកាន់កាយដទៃយ៉ាងនោះដែរ ។ បុរសបុគ្គល ចេញពីផ្ទះ ចូលទៅកាន់ផ្ទះដទៃ

យ៉ាងណាមិញ ជីវៈនោះ ចូលទៅកាន់កាយដទៃទៀត ក៏យ៉ាងនោះដែរ ។ ពួកពាល ពួកបណ្ឌិត នឹងធ្វើសង្សារវដ្តឱ្យអស់ទៅ ធ្វើទុក្ខឱ្យផុតបាន ទាល់តែអស់មហាកប្បទាំងឡាយ ៨ លាន ៤ សែន ។ សុខនិងទុក្ខទាំងឡាយ វាល់បានដោយទោណៈទាំងឡាយផង ដោយកញ្ឆើទាំងឡាយផង ជិនបុរស រមែងជ្រាបសព្វ ពួកសត្វក្រៅនេះប្រកបដោយសេចក្តីវង្វេង ។ កាលមុន ខ្ញុំជាអ្នកយល់យ៉ាងនេះ ជាអ្នកប្រកបដោយសេចក្តីវង្វេង មានសេចក្តីវង្វេងគ្របសង្កត់ មានសេចក្តីយល់ខុស ទ្រុស្តសីល កំណាញ់ ប្រទេចផ្តាសា ( សមណៈ និងព្រាហ្មណ៍ ) ។ ខាងអាយ ៦ ខែទៀត ខ្ញុំនឹងធ្វើកាលកិរិយា ។ ខ្ញុំមុខជានឹងធ្លាក់នរក មានការក្តៅក្រហាយដ៏ពន្លឹកដោយពិត ជានរកមានជ្រុង ៤ មានទ្វារ ៤ ដូចជាវាស់ដោយចំណែកដែលចែកស្មើគ្នា ជានរកមានកំពែងដែកព័ទ្ធជុំវិញ គ្របដោយដែក ។ ភូមិនៃនរកនោះជាវិការៈនៃដែក រន្ទាលច្រាលឆ្អៅ ប្រកបដោយភ្លើង ផ្សព្វផ្សាយទៅ ១០០ យោជន៍ជុំវិញ សព្វកាល ។ កន្លងទៅ ១ សែនឆ្នាំ ឮសូរសំឡេងកងរំពង ក្នុងកាលនោះ ។ បពិត្រមហារាជ ចំណែកមួយសែនកោដិឆ្នាំ ជាគ្រឿងកំណត់ ( អាយុរបស់សត្វដែលឆេះនៅក្នុងនរក ) ទុំះ ពួកជនដែលជាមិច្ឆាទិដ្ឋិ ទ្រុស្តសីល តិះដៀលព្រះអរិយៈតែងឆេះនៅក្នុងនរក អស់ ១ សែនកោដិឆ្នាំ ។ ខ្ញុំនឹងរងទុក្ខក្នុងនរក

នោះ អស់កាលជាយូរអង្វែង ( ព្រោះ ) ផលនៃបាបកម្ម ហេតុនោះ បានជាខ្ញុំសោកសៅដ៏ក្រៃលែង ។ បពិត្រអវិន្ទមមហារាជ អ្នកចម្រើន ក្នុងដែន ព្រះអង្គចូរស្ដាប់ដំណើរនោះ បពិត្រមហារាជ ធីតារបស់ខ្ញុំ ឈ្មោះ**នាងឧត្តរា** សេចក្ដីចម្រើន ចូរមានដល់ព្រះអង្គ ។ នាងឧត្តរា តែងធ្វើនូវកម្មដ៏ចម្រើន ជាអ្នកត្រេកអរក្នុងនិច្ចសីល និងឧបោសថ-សីល ត្រេកអរក្នុងទាន ជាអ្នកចែករលែកទាន ជាអ្នកដឹងនូវពាក្យ ( នៃសូម ) មិនមានកំណាញ់ ធ្វើមិនឱ្យដាច់ក្នុងសិក្ខាបទ ជាកូនប្រសា ក្នុងត្រកូលដទៃ ជាឧបាសិកានៃព្រះសក្យមុនីសម្ពុទ្ធដ៏មានសិរី ។ ភិក្ខុ-បរិបូណ៌ដោយសីល ចូលទៅកាន់ស្រុក ដើម្បីបិណ្ឌបាត ជាអ្នកសង្រួម ចក្ខុ មានស្មារតីគ្រប់គ្រងទ្វារ បិទបាំងកាយដោយប្រពៃ ត្រាច់ទៅ តាមលំដាប់ច្រក បានទៅកាន់លំនៅរបស់នាងនោះ ។ បពិត្រមហា-រាជ សេចក្ដីចម្រើន ចូរមានដល់ព្រះអង្គ **នាងឧត្តរា** បានឃើញភិក្ខុ ហើយ បានប្រគេននូវ**បានីយករក:** ( តម្រងទឹក ) ដ៏ពេញផង នូវនំ ទាំងឡាយដ៏វិចិត្រផង ( ហើយឧទ្ទិសផលមកឱ្យខ្ញុំយ៉ាងនេះថា ) **បពិត្រលោកដ៏ចម្រើន បិតារបស់ខ្ញុំចែកឋានទៅហើយ ទាននេះ សូមសម្រេចដល់បិតារបស់ខ្ញុំនោះ ។** ផលក៏សម្រេច ក្នុងពេលជា-លំដាប់ ដែលឧទ្ទិសហើយ ខ្ញុំជាអ្នកបានកាមតាមប្រាថ្នា បរិភោគដូច ជាស្ដេចវេស្សវ័ណ ។ បពិត្រអវិន្ទមមហារាជ ព្រះអង្គអ្នកចម្រើនក្នុង-

ដែន សូមព្រះអង្គស្តាប់នូវដំណើរនោះ ព្រះពុទ្ធគេហៅថា បុគ្គលប្រសើរជាងសត្វលោកព្រមទាំងទេវលោក បពិត្រព្រះបាទអរិន្ទមៈ សូមព្រះអង្គព្រមទាំងព្រះរាជបុត្រាបុត្រី ព្រះអគ្គជាយា ដល់នូវ-ព្រះពុទ្ធនោះជាសរណៈចុះ ។ ពួកបុរសបុគ្គលបានដល់ព្រះនិព្វានដោយសារតែមគ្គប្រកបដោយអង្គ ៨ ប្រការ បពិត្រព្រះបាទអរិន្ទមៈ សូមព្រះអង្គ ព្រមទាំងព្រះរាជបុត្រាបុត្រី ព្រះអគ្គជាយា ដល់នូវធម៌ ( អដ្ឋង្គិកមគ្គ ) នោះជាសរណៈចុះ ។ ព្រះអរិយបុគ្គល ៤ ពួក ប្រតិបត្តិក្នុងមគ្គ ព្រះអរិយបុគ្គល ៤ ពួក ឋិតនៅក្នុងផល ព្រះសង្ឃទាំងនុ៎ះ លោកជាអ្នកស្លូតត្រង់ តាំងនៅមាំក្នុងបញ្ញានិងសីល បពិត្រព្រះបាទអរិន្ទមៈ សូមព្រះអង្គ ព្រមទាំងព្រះរាជបុត្រាបុត្រី ព្រះអគ្គ-ជាយា ដល់នូវព្រះសង្ឃនោះជាសរណៈចុះ ។

សូមព្រះអង្គ វៀរចាកបាណាតិបាត ឱ្យឆាប់ ៗ សូមព្រះអង្គ
វៀរចាកការកាន់យកទ្រព្យ ដែលគេមិនបានឱ្យ ក្នុងលោក
សូមព្រះអង្គ កុំសោយនូវទឹកស្រវឹង កុំមានព្រះឱង្ការកុហក
សូមព្រះអង្គត្រេកអរ តែនឹងព្រះអគ្គមហេសីរបស់ព្រះអង្គ ។

( **ព្រះរាជាត្រាស់ថា** ) ម្នាលយក្ស អ្នកជាអ្នកប្រាថ្នាសេចក្តីចម្រើនដល់យើង ម្នាលទេវតា អ្នកជាអ្នកប្រាថ្នាប្រយោជន៍ដល់យើង យើងធ្វើតាមពាក្យរបស់អ្នកហើយ អ្នកជាអាចារ្យរបស់យើង ។ យើង

*សូមដល់ព្រះពុទ្ធជាសរណៈផង ដល់ព្រះធម៌ជាសរណៈផង ដល់ព្រះ-សង្ឃដ៏ប្រសើរ ជាងមនុស្ស និងទេវតា ជាសរណៈផង ។*

*យើងវៀរចាកបាណាតិបាត យ៉ាងឆាប់រហ័ស យើងលះបង់ការកាន់យកទ្រព្យ ដែលគេមិនបានឱ្យ ក្នុងលោក យើងលែងផឹកទឹកស្រវឹង លែងនិយាយកុហក យើងជាអ្នកត្រេកអរ តែនឹងប្រពន្ធរបស់ខ្លួន ។*

*ម្នាលប្រេត យើងត្រេកអរក្នុងសាសនា របស់ព្រះពុទ្ធទាំងឡាយ បាច ( នូវទិដ្ឋិដ៏អាក្រក់ចោលដូចជាអង្កាម ) ក្នុងទីមានខ្យល់ធំផង បន្សាត់-ចោលនូវទិដ្ឋិអាក្រក់ ( ដូចជាសម្រាម ) ក្នុងទន្លេ មានខ្សែទឹករហ័សផង ។ លុះព្រះបាទបិង្គលៈ ជាស្តេចក្នុងដែនសុរដ្ឋ មានព្រះឱង្ការដូច្នេះហើយ ក៏បានវៀរចាកការយល់ដ៏លាមកចោលចេញ ធ្វើនូវ-កិរិយាថ្វាយបង្គំព្រះមានព្រះភាគ រួចក៏បែរព្រះភក្ត្រចំទៅទិសខាងកើតឡើងគង់លើរថទៅ ។*

បណ្ដាបទទាំងនោះ បទថា **រាជា បិង្គលកោ នាម សុរដ្ឋានំ អធិបតិ អហុ** សេចក្ដីថា មានព្រះរាជាមួយព្រះអង្គ ជាឥស្សរៈនៃ-សុរដ្ឋប្រទេស មានព្រះនាមថា **បិង្គលៈ** ព្រោះមានចក្ខុពណ៌លឿង ។ បទថា **មោរិយានំ** លោកពោលសំដៅដល់**ព្រះបាទមោរិយ-ធម្មាសោក** ។ បទថា **សុរដ្ឋំ បុនរាគមា** សេចក្ដីថា បានយាងត្រឡប់

មកតាមផ្លូវ ជាទីទៅកាន់សុរដ្ឋប្រទេស ឆ្ពោះទៅកាន់ទីលំនៅនៃសុរដ្ឋប្រទេស ។ បទថា **បត្តំ** បានដល់ ភូមិភាគដ៏ទន់ ។ បទថា **វណ្ណុបថំ** ( បិដកថា **វណ្ណុនាបថំ** ) ផ្លូវមានខ្សាច់ ដែលប្រេតនិម្មិតទុក ។

បទថា **ខេមោ** ប្រែថា ក្សេមក្សាន្ត ។ បទថា **សោវត្ថិកោ** ប្រែថា នាំមកនូវសេចក្តីសួស្តី ។ បទថា **សិវោ** ប្រែថា មិនមានឧបទ្រវន្តរាយ ។ បទថា **សុរដ្ឋានំ សន្តិកេ ឥតោ** បានដល់ ពួកយើងកាលទៅតាមផ្លូវនេះ និងដល់ទីជិតក្រុងសុរដ្ឋតែម្តង ។

បទថា **សោរដ្ឋោ** បានដល់ អ្នកជាធំក្នុងសុរដ្ឋប្រទេស ។ បទថា **ឧព្វិគ្គរូបោ** បានដល់ អ្នកមានសេចក្តីតក់ស្លុតជាសភាវៈ ។ បទថា **ភីសនំ** បានដល់ កើតនូវសេចក្តីខ្លាចឡើង ។ បទថា **លោមហំសនំ** បានដល់ កើតនូវការព្រឺរោម ព្រោះជាផ្លូវគួរខ្លាច ។

បទថា **យមបុរិសានំ សន្តិកេ** បានដល់ នៅក្នុងទីជិតពួកប្រេត ។ បទថា **អមានុសោ វាយតិគន្ធោ** សេចក្តីថា ក្លិនសរីរៈរបស់ពួកប្រេតរមែងផ្សាយទៅ ។ បទថា **ឃោសោ សុយតិ ទារុណោ** សេចក្តីថា ខ្ញុំព្រះអង្គបានឮសម្លេងដ៏ចម្លែកគួរឱ្យខ្លាចរបស់ពួកសត្វ អ្នកធ្វើនូវហេតុក្នុងនរកដោយចំពោះ ។

បទថា **ធានបំ** បានដល់ ដើមឈើដែលមានឈ្មោះថា **ធាទបៈ**

ព្រោះជារុក្ខជាតិដែលស្រូបទឹកដោយឫស ។ បទថា **ឆាយាសម្បន្នំ** ( បិដកថា **ឆាយសម្បន្នំ** ) ប្រែថា មានម្លប់ជិតល្អ ។ បទថា **នីលព្ភវណ្ណសន្និភំ** បានដល់ មានពណ៌ខៀវស្រងាត់ ដូចពណ៌ផ្ទៃមេឃ ។ បទថា **មេឃវណ្ណសិរន្និភំ** បានដល់ មានពណ៌និងសណ្ឋានដូចផ្ទៃមេឃ ។

បទថា **ចូរំ បានីយភរិតំ** បានដល់ ភាជនៈទឹកដ៏ពេញដោយទឹក ។ បទថា **ចូវេ** បានដល់ របស់គួរទំពាស៊ី ។ បទថា **ចិត្តេ** ( បិដកថា **ចិត្តេ** ) សេចក្តីថា នាយសារថីបានឃើញនំដែលដាក់ពេញភាជន៍នោះ ៗ ដែលឱ្យកើតសេចក្តីត្រេកអរ មានរសឆ្ងាញ់ជាទីរីករាយចិត្ត ។

សព្ទ **អថោ** ក្នុងបទថា **អថោ តេ អទុរាគតំ** នេះ គ្រាន់តែជានិបាត ឬថា បទថា **អថោ** ប្រើក្នុងអត្ថនៃអវធារណៈ , អធិប្បាយថា ពួកយើងទទួលដោយបំណងថា បពិត្រមហារាជ ព្រះអង្គយាងមកល្អ មិនមែនយាងមកអាក្រក់ទេ តាមពិត ព្រះអង្គយាងមកល្អហើយ ។ បទថា **អរិន្ទម** បានដល់ អ្នកកម្ចាត់នូវសត្រូវ ។

បទថា **អមច្ចា បារិសជ្ជា** មានសេចក្តីថា ពួកអាមាត្យនិងបុរោហិតចូរស្តាប់ពាក្យ និងព្រាហ្មណ៍ដែលជាបុរោហិតរបស់អ្នកចូរស្តាប់ពាក្យនោះចុះ ។

បទថា **សុរដ្ឋស្មឹ អហំ** កែជា **សុរដ្ឋេឥសេ អហំ** ខ្ញុំនៅក្នុងសុរដ្ឋប្រទេស ។ វេមានិកប្រេត ហៅព្រះរាជាថា **ទេវ** ។ បទថា **មិច្ឆាទិដ្ឋិ** ប្រែថា អ្នកយល់ខុសដោយនត្ថិកទិដ្ឋិ ។ បទថា **ទុស្សីលោ** បានដល់ អ្នកមិនមានសីល ។ បទថា **កទរិយោ** ប្រែថា អ្នកមានសេចក្តីស្វិតស្វាញ ។ បទថា **បរិភាសកោ** បានដល់ អ្នកជេរប្រទេចផ្តាសាសមណព្រាហ្មណ៍ ។

បទថា **វារយិស្សំ** ប្រែថា បានហាមហើយ ។ បទថា **អន្តរាយករោ អហំ** ( បិដកថា **អន្តរាយំ ករោមហំ** ) មានសេចក្តីថា ខ្ញុំជាអ្នកធ្វើអន្តរាយ ចំពោះជនដែលកំពុងឱ្យទាន អ្នកធ្វើនូវឧបការៈ និងខ្ញុំហាមឃាត់ជនជាច្រើន ចាកបុណ្យដែលសម្រេចដោយទានរបស់ពួកជនដទៃ ដែលកំពុងឱ្យទាន ។

បទថា **វិបាកោ នត្ថិ ទានស្ស** ជាដើម ជាបទសម្តែងនូវ-អាការៈ ដែលខ្ញុំហាមហើយ ។ បណ្តាបទទាំងនោះ បទថា **វិបាកោ នត្ថិ ទានស្ស** ព្រះអង្គទ្រង់ហាមនូវវិបាកថា កាលបុគ្គលនោះឱ្យទានវិបាក គឺ ផល ដែលនឹងគប្បីបានទទួលតទៅ រមែងមិនមាន ។ បទថា **សំយមស្ស កុតោ ផលំ** សេចក្តីថា ក៏ផលនៃសីលនឹងមានមកពីណា, អធិប្បាយថា ផលនៃសីលនោះរមែងមិនមានដោយប្រការទាំងពួង ។ បទថា **នត្ថិ អាចរិយោ នាម** សេចក្តីថា នរណាមួយ ដែលឈ្មោះថា

ជាអាចារ្យ អ្នកឱ្យសិក្សានូវអាចារៈ និងសមាចារៈ រមែងមិនមាន, អធិប្បាយថា បើពោលដោយសភាវៈ សត្វទាំងឡាយ អ្នកទូន្មានខ្លួន ហើយ ឬនៅមិនទាន់បានទូន្មានខ្លួន រមែងមាន ។ ព្រោះហេតុនោះ លោកទើបពោលថា នរណានឹងទូន្មានអ្នកដែលនៅមិនទាន់បានទូន្មាន ដូច្នេះ ។

បទថា **សមតុល្យានិ** សេចក្តីថា សត្វទាំងអស់នេះ ជាអ្នកស្មើ ៗ គ្នា, អធិប្បាយថា អ្នកមានសេចក្តីគោរពកោតក្រែងចំពោះត្រកូលរៀមច្បង នឹងមានមកអំពីណា គឺដែលឈ្មោះថា បុណ្យដែលជាហេតុឱ្យប្រព្រឹត្តគោរពកោតក្រែងចំពោះត្រកូលរៀមច្បង រមែងមិនមានទេ ។ បទថា **នត្ថិ ពលំ** សេចក្តីថា សត្វទាំងឡាយ អ្នកតាំងនៅក្នុងកម្លាំងរបស់ខ្លួនណា ធ្វើនូវសេចក្តីព្យាយាម រមែងសម្រេចនូវសម្បត្តិទាំងឡាយ ចាប់ផ្តើមពីភាពជាអ្នកប្រសើរដោយភាពស្រស់ស្អាតក្នុងពួកមនុស្ស រហូតដល់ភាពជាព្រះអរហន្ត ព្រះអង្គរមែងហាមឃាត់នូវកម្លាំងនៃសេចក្តីព្យាយាមនោះ ។ បទថា **វីរិយំ វា នត្ថិ កុតោ ឧដ្ឋានបោរិសំ** នេះ លោកពោលបានដោយអំណាចការបដិសេធវាទៈ ដែលប្រព្រឹត្តទៅហើយយ៉ាងនេះថា នេះប្រព្រឹត្តទៅដោយសេចក្តីព្យាយាមរបស់បុរស ដោយសេចក្តីប្រឹងប្រែងរបស់បុរស ក៏ទេ ។ បទថា **នត្ថិ ទានផលំ នាម** សេចក្តីថា ដែលឈ្មោះថា

ផលនៃទានណាមួយរមែងមិនមានទេ, អធិប្បាយថា ការបរិច្ចាគទេយ្យធម៌រមែងឥតផលតែម្តង ដូចផេះដែលគេទុកចោល ។ បទថា **ទេវនំ** ក្នុងបទថា **ន វិសោធេតិ ទេវនំ** សេចក្តីថា រមែងមិនធ្វើនូវបុគ្គលអ្នកមានពៀរ គឺអ្នកធ្វើបាបទុក ដោយអំណាចនៃពៀរ និងដោយអំណាចនៃអកុសលធម៌ មានបាណាតិបាតជាដើម ឱ្យបរិសុទ្ធចាកវត្ត មានទាននិងសីលជាដើម គឺសូម្បីក្នុងគ្រាខ្លះ ក៏មិនធ្វើឱ្យបរិសុទ្ធបានឡើយ ។ បទថា **វិបាកោ នត្ថិ ទានស្ស** ជាដើម ជាបទសម្តែងនូវអាការៈដែលខ្លួនហាមពួកជនដទៃ ចាកទានជាដើមក្នុងកាលមុន តែបទថា ឈ្មោះថា ផលនៃទានរមែងមិនមានទេ ជាដើម គប្បីជ្រាបថា ជាបទសម្តែងនូវការប្រកាន់ខុសនៃខ្លួន ។ បទថា **លព្ភេយ្យំ** ប្រែថា គប្បីបាន ។ ដើម្បីចៀសវាងពាក្យសួរថា តើគប្បីបានដូចម្តេច ? លោកទើបឆ្លើយថា កើតពីវត្ថុដែលបង្អោនមកឯង ។ យ៉ាងពិតប្រាកដ, អធិប្បាយថា សត្វនេះ កាលបានទទួលនូវសេចក្តីសុខ ឬសេចក្តីទុក្ខ រមែងបានដោយអំណាចនៃសេចក្តីប្រែប្រួលទៅយ៉ាងពិតប្រាកដតែម្តង មិនមែនព្រោះកម្មដែលខ្លួនធ្វើទុកឡើយ និងមិនមែនព្រោះព្រះឥស្សរ និម្មិតឡើងឡើយ ។ បទថា **នត្ថិ មាតា បិតា ភាតា** លោកពោលសំដៅដល់ការមិនមានផលនៃការបដិបត្តិត្រូវ និងការបដិបត្តិខុសក្នុងមាតាជាដើម ។ បទថា

បទថា **លោកោ នត្ថិ ឥតោ បរំ** សេចក្តីថា ឈ្មោះថាបរលោកណា ៗ ក្រៅពីឥធលោកនេះ រមែងមិនមាន, អធិប្បាយថា សត្វរមែងដាច់សូន្យទៅក្នុងទីនោះ ៗ ឯង ។ បទថា **ទិន្នំ** បានដល់ មហាទាន ។ បទថា **ហុតំ** បានដល់ សក្ការៈដើម្បីភ្ញៀវ, លោកសំដៅដល់ការមិនមានផលទាំងពីរនោះ ទើបហាមថា **នត្ថិ** ។ បទថា **សុនិហិតំ** ប្រែថា តម្កល់ទុកល្អហើយ ។ បទថា **ន វិជ្ជតិ** សេចក្តីថា ជនទាំងឡាយ រមែងពោលនូវការឱ្យទានដល់សមណព្រាហ្មណ៍ថា ជាកំណប់ទ្រព្យ ដែលជាគ្រឿងជាប់តាមនោះ រមែងមិនមាន, អធិប្បាយថា ទានដែលឱ្យដល់សមណព្រាហ្មណ៍នោះ គ្រាន់តែជាវត្ថុនៃពាក្យសំដីប៉ុណ្ណោះ ។

បទថា **ន កោចិ កិញ្ចិ ហនតិ** សេចក្តីថា បុរសណាគប្បីសម្លាប់នូវបុរសដទៃ គឺគប្បីកាត់ក្បាលរបស់បុរសដទៃ ក្នុងសេចក្តីនោះ កាលបើពោលដោយបរមត្ថ គ្មាននរណាសម្លាប់នរណាទេ គឺរមែងដូចជាអ្នកសម្លាប់ ព្រោះផ្តាច់កាយរបស់សត្វទាំងឡាយ ។ ដើម្បីចៀសវាងពាក្យសួរថា ការប្រហារដោយសស្ត្រាតើដូចម្តេច ? លោកទើបឆ្លើយថា ប្រើសស្ត្រាចូលទៅក្នុងចន្លោះ ដែលជាចន្លោះកាយទាំង ៧,[១] អធិប្បាយថា សូកសស្ត្រាចូលទៅក្នុងចន្លោះ គឺក្នុង-

***១- កាយទាំង ៧ គឺ*** *ដី ១ ទឹក ១ ភ្លើង ១ ខ្យល់ ១ សុខ ១ ទុក្ខ ១ ជីវិត ១ ។( បិដកលេខ ៣៤ ទំព័រ ១២៣ ) ។*

ចន្លោះដែលជាចន្លោះរបស់កាយទាំង ៧ មានបឋវីជាដើម ព្រោះ-ដូច្នោះ សត្វទាំងឡាយ ទើបដូចជាត្រូវសស្ត្រា មានដាវជាដើម កាប់ចិញ្ច្រាំ ប៉ុន្តែសូម្បីកាយដ៏សេស រមែងមិនដាច់ទៅទេ ព្រោះមានសភាវៈទៀង ដូចមានជីវៈដូច្នោះ ។

បទថា **អច្ឆេជ្ជាភេជ្ជោ ហិ ជីវោ** ( បិដកថា **អច្ឆេជ្ជោ អភេជ្ជោ ជីវោ** ) សេចក្ដីថា ជីវៈរបស់ពួកសត្វនេះ មិនអាចផ្ដាច់ មិនអាចទម្លាយដោយសស្ត្រាជាដើមបានឡើយ ព្រោះជាសភាវៈទៀង ។ បទថា **អដ្ឋំសោ គុឡបរិមណ្ឌលោ** សេចក្ដីថា ក៏ជីវៈនោះជួនកាលមានជ្រុង ៨ ជួនកាលមូលដូចដុំស្ករផែន ។ បទថា **យោជនានំ សតំ បញ្ច** ( បិដកថា **យោជនានិ សតា បញ្ច** ) សេចក្ដីថា ជីវៈនោះដល់នូវភាវៈសុទ្ធ កំពស់ប្រមាណ ៥០០ យោជន៍ ។ បទថា **កោ ជីវំ ឆេត្តុមរហតិ** នេះ លោកពោលថា នរណាទៅគួរដើម្បីនឹងផ្ដាច់បង់ជីវៈដ៏ទៀង គឺឥតមានពិការ ដោយសស្ត្រា-ជាដើម គឺ ជីវៈនោះ គ្មាននរណាម្នាក់ ធ្វើឱ្យកម្រើកបានឡើយ ។

បទថា **សុត្តគុឡេ** បានដល់ អំបោះហុង ដែលគេមូរទុក ។ បទថា **ខិត្តេ** បានដល់ បោះចោលទៅ ដោយអំណាចមិនបានរលាចេញ ។ បទថា **និព្វេឋេន្តោ បលាយតិ** សេចក្ដីថា អំបោះហុងដែលអំបោះរលា ដែលគេបោះចោលទៅលើភ្នំ ឬលើដើមឈើ

រមែងរមៀលទៅបាន តែកាលបើអស់អំបោះក៏រមៀលទៅមិនបាន ។ បទថា **ឯវមេវំ** សេចក្តីថា អំបោះហុងនោះ ដែលអំបោះរលាទើបរមៀលទៅបាន កាលបើអស់អំបោះរមៀលទៅមិនបាន យ៉ាង-ណាមិញ ជីវៈនោះក៏យ៉ាងនោះដែរ កាលបើរលាហុង គឺភាវៈរបស់សត្វ រមែងគេចទៅបាន គឺរមែងប្រព្រឹត្តទៅបាន អស់រយៈកាលដែលអាចពោលបានថាអស់កំណត់ ៨,៤០០,០០០ ( ប្រាំបីលានបួនសែន ) មហាកប្ប ផុតពីនោះប្រព្រឹត្តទៅមិនបានទេ ។

បទថា **ឯវមេវ ច សោ ជីវោ** ( បិដកថា **ឯវមេវំបិ សោ ជីវោ** ) សេចក្តីថា អ្នកខ្លះចេញអំពីស្រុកដែលជាទីលំនៅរបស់ខ្លួន ហើយចូលទៅកាន់ស្រុកដទៃ ចេញពីផ្ទះនោះ ដោយកិច្ចណាមួយ យ៉ាងណាមិញជីវៈនោះក៏យ៉ាងនោះដែរ ចេញពីកាយនេះហើយ ក៏ចូលទៅកាន់កាយដទៃទៀត ដោយអំណាចកំណត់កាល ។ បទថា **ពោន្ទិ** បានដល់ រាងកាយ ។

បទថា **ចុឡាសីតិ** ប្រែថា ៨៤ ។ បទថា **មហាកប្បិនោ** បានដល់ មហាកប្ប ។ ក្នុងមហាកប្បនោះ អាចារ្យទាំងឡាយពោលថា កាលទេវតាអ្នកមានឫទ្ធិ នាំយកដំណក់ទឹកដោយចុងស្បូវម្តងមួយដំណក់ ក្នុង ១០០ ឆ្នាំម្តង ៗ អំពីស្រះធំ មានស្រះអនោតត្តចេញទៅ ដោយសេចក្តីព្យាយាមនេះ កាលស្រះនោះរីងស្ងួតដល់ទៅ

៧ ដង ឈ្មោះថា ត្រូវជា ១ មហាកប្ប ទើបពោលថា ៨,៤០០,០០០ មហាកប្ប ជាប្រមាណនៃសង្សារ ។ បទថា **យេ ពាលា យេ ច បណ្ឌិតា** សេចក្ដីថា សត្វទាំងឡាយ ទាំងជាអន្ធពាល ទាំងជាបណ្ឌិតទាំងអស់នោះ ។ បទថា **សំសារំ ខេបយិត្វាន** សេចក្ដីថា ញ៉ាំងសង្សារ ដែលកំណត់ដោយកាល តាមដែលពោលហើយឱ្យអស់ទៅ ដោយអំណាចនៃការកើតរឿយ ៗ ។ បទថា **ទុក្ខស្សន្តំ ករិស្សរេ** សេចក្ដីថា នឹងធ្វើនូវទីបំផុតនៃវដ្តទុក្ខ ។ សង្សារនោះ មានការកំណត់ថា ទាំងបណ្ឌិត ក៏មិនអាចនឹងជម្រះខ្លួនឱ្យបរិសុទ្ធក្នុងចន្លោះបាន បន្ទាប់ពីនោះ ទោះបីពួកជនពាល ក៏ប្រព្រឹត្តទៅមិនបានឡើយ ។

បទថា **មិតានិ សុខទុក្ខានិ ទោណេហិ បិដកេហិ ច** សេចក្ដីថា ឈ្មោះថា សុខនិងទុក្ខរបស់សត្វទាំងឡាយ ដូចវាល់បានដោយទោណៈ ដោយកញ្ជើ បានដល់ ដោយភាជនៈជាគ្រឿងវាល់ និងសុខទុក្ខរបស់ពួកសត្វនោះ ៗ កើតពីការបង្កើនទៅយ៉ាងពិត-ប្រាកដ ជាការប្រមាណបានដោយចំពោះ ព្រោះប្រមាណបានដោយកំណត់តាមកាលដែលពោលហើយនោះឯង ។ ព្រះជិនបុរស រមែងជ្រាបនូវរឿងនេះទាំងអស់ គឺ លោកអ្នកតាំងនៅក្នុងជិនភូមិ រមែង-ដឹងច្បាស់តែម្ដង ព្រោះបានឆ្លងផុតនូវសង្សារវដ្ត ចំណែកពួកសត្វក្រៅពីនោះ ជាអ្នកវង្វេង រមែងវិលវល់នៅក្នុងសង្សារវដ្ត ។

បទថា **ឯវំ ទិដ្ឋិ បុរេ អាសិ** សេចក្តីថា កាលមុនខ្ញុំព្រះអង្គជានត្ថិកទិដ្ឋិបុគ្គល ដូចដែលបានពោលរួចមកហើយ ។ បទថា **សម្មូឡ្ហោ មោហបារុតោ** បានដល់ ជាអ្នកវង្វេង ព្រោះសម្មោហៈដែលជាហេតុនៃទិដ្ឋិ ដូចដែលបានរួចមកហើយ, អធិប្បាយថា ក៏មនុស្សអ្នកត្រូវមោហៈដែលកើតព្រមដោយទិដ្ឋិនោះគ្របសង្កត់ គឺដូចជាចម្រូងនៃស្បូវភ្លាំងដែលបិទបាំងទុក ។

**ននេ្ទកប្រេត** លុះសម្តែងនូវបាបកម្មដែលខ្លួនបានធ្វើដោយអំណាចនៃសេចក្តីយល់ខុស ដែលកើតឡើងដល់ខ្លួនក្នុងកាលមុនយ៉ាងនេះហើយ ឥឡូវនេះ កាលនឹងសម្តែងនូវផលនៃបាបកម្មនោះ ដែលខ្លួននឹងត្រូវសោយក្នុងអនាគត ទើបពោលនូវពាក្យជាដើមថា ខាងអាយ ៦ ខែទៀត ខ្ញុំនឹងធ្វើកាលកិរិយា ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **វស្សានិ សតសហស្សានិ** ( បិកដថា **វស្សសតសហស្សានិ** ) បានដល់ ១ សែនឆ្នាំ, បាលីដ៏សេសថា **អតិក្កមិត្វា** ប្រែថា កន្លង បណ្ឌិតគប្បីនាំមកភ្ជាប់ ។ ម្យ៉ាងទៀត បទថា **វស្សានិ សតសហស្សានិ** នេះ ជាបឋមាវិភត្តិប្រើក្នុងអត្ថសត្តមីវិភត្តិ, អធិប្បាយថា កាល ១ សែនឆ្នាំកន្លងទៅហើយ ។ បទថា **ឃោសោ សុយ្យតិ តាវទេ** ( បិដកថា **ឃោសោ សូយតិ តាវទេ** ) សេចក្តីថា ក្នុងខណៈដែលវេលាមានប្រមាណ

ប៉ុណ្ណោះកន្លងទៅនោះឯង ខ្ញុំបានឮសម្លេងក្នុងនរកនោះ យ៉ាងនេះថា ម្នាលអ្នកនិរទុក្ខទាំងឡាយ វេលារបស់ពួកអ្នកដែលឆេះ នៅក្នុងនរកនេះ កន្លងទៅប្រមាណ ១ សែនឆ្នាំហើយ ។ បទថា **លក្ខោ ឯសោ មហារាជ សតភាគាទស្សកោដិយោ** សេចក្ដីថា បពិត្រមហារាជ ១00 ភាគកោដិឆ្នាំ ចាត់ជាកំណត់ គឺជាដែនកំណត់ អាយុរបស់សត្វទាំងឡាយ ដែលឆេះនៅក្នុងនរក ។ លោកពោល នូវពាក្យអធិប្បាយនេះទុកថា ១0 ទសកៈ ត្រូវជា ១00 , ១0 រយ ត្រូវជា ១,000 ដប់ពាន់ ១0 ដង ត្រូវជា ១00,000 , មួយរយសែន ត្រូវជា ១ កោដិ, មួយសែនកោដិឆ្នាំដោយអំណាចនៃកោដិទាំងនោះ ចាត់ជាមួយរយកោដិឆ្នាំ ។ ក៏មួយរយកោដិឆ្នាំនោះឯង គប្បីជ្រាប ដោយការគណនាឆ្នាំចំពោះសត្វនរក មិនមែនសម្រាប់មនុស្ស ឬ ទេវតាឡើយ ។ មួយសែនកោដិឆ្នាំដ៏ច្រើនដូច្នេះ ជាអាយុរបស់ សត្វនរក ព្រោះហេតុនោះ លោកទើបពោលថា ជនដែលឆេះនៅក្នុងនរក អស់មួយសែនកោដិឆ្នាំ ដូច្នេះ ។ សត្វទាំងឡាយដែលឆេះនៅក្នុងនរកដូច្នេះ ព្រោះកម្មដូចម្ដេច ? ដើម្បីនឹងសម្ដែងនូវបាបកម្មដូច្នោះ ដោយពាក្យចុងក្រោយ លោកទើបពោលថា ជាមិច្ឆាទិដ្ឋិ ជាអ្នក-ទ្រុស្តសីល និងជាអ្នកតិះដៀលព្រះអរិយៈដូច្នេះ ។ បទថា **ចេតិស្សំ** ប្រែថា នឹងបានសោយហើយ ។

**នន្ទកប្រេត** លុះសម្តែងនូវផលនៃអំពើអាក្រក់ដែលខ្លួននឹងគប្បីសោយក្នុងអនាគតយ៉ាងនេះហើយ ឥឡូវនេះ មានបំណងនឹងទូលនូវរឿងដែលព្រះរាជាត្រាស់សួរថា អ្នកមានអានុភាពយ៉ាងនេះព្រោះព្រហ្មចរិយដូចម្តេច ដូច្នេះហើយ នឹងឱ្យព្រះរាជានោះតាំងនៅក្នុងសរណៈ និងសីល ទើបពោលពាក្យជាដើមថា បពិត្រមហារាជសូមព្រះអង្គទ្រង់ព្រះសណ្តាប់ ។ បណ្តាបទទាំងនោះ បទថា **សីលេសុ បោសថា រតោ** ( បិដកថា **សីលេសូបោសថេ រតោ** ) បានដល់ ត្រេកអរហើយក្នុងនិច្ចសីល និងឧបោសថសីល ។ បទថា **អទាសិ** ប្រែថា បានឱ្យហើយ ។ បទថា **តំ ធម្មំ** បានដល់ មគ្គ-មានអង្គ ៨ និង អមតបទនោះ ។

ព្រះរាជាដែលប្រេតណែនាំឱ្យសមាទានសីល និងសរណៈយ៉ាងនេះហើយ មានព្រះទ័យជ្រះថ្លា ជាដំបូងទើបប្រកាសដល់ឧបការៈដែលប្រេតនោះធ្វើដល់ព្រះអង្គ កាលនឹងតាំងនៅក្នុងសរណៈជាដើម ទើបពោលនូវគាថា ៣ គាថាជាដើមថា អ្នកជាអ្នកប្រាថ្នាសេចក្តីចម្រើនដល់យើងដូច្នេះ កាលទ្រង់នឹងប្រកាសដល់សេចក្តីដែលទ្រង់លះបង់នូវទិដ្ឋិអាក្រក់ ដែលព្រះអង្គប្រកាន់ក្នុងកាលមុន ទើបត្រាស់នូវគាថាថា យើងបាច ( អង្កាមក្នុងទីមានខ្យល់ខ្លាំង ) ជាដើម។

បណ្តាបទទាំងនោះ បទថា **ឱផុនាមិ មហាវាតេ** សេចក្តីថា

ម្នាលទេវតា យើងនឹងបាច គឺកម្ចាត់បង់នូវទិដ្ឋិអាក្រក់នោះ ក្នុងទីមានខ្យល់ គឺធម្មទេសនារបស់អ្នក ដូចជាបាចអង្កាមទៅក្នុងទីមានខ្យល់ខ្លាំងដែលកំពុងតែបក់ ។ បទថា **នទិយា វា សីឃគាមិយា** អធិប្បាយថា ឬថាយើងនឹងបន្សាត់ចោលនូវទិដ្ឋិអាក្រក់ដូចជាបណ្តែត ស្មៅ ឈើ ស្លឹកឈើ និងក្រមរឈើ ក្នុងទន្លេដែលមានខ្សែទឹកដ៏ត្របាញ់ ។ បទថា **វមាមិ បាបកំ ទិដ្ឋឹ** សេចក្តីថា យើងនឹងលះចោលនូវទិដ្ឋិអាក្រក់ដែលនៅក្នុងចិត្តរបស់យើង ។ ព្រះរាជាពោលនូវហេតុក្នុងសេចក្តីនោះថា ត្រេកអរហើយក្នុងព្រះសាសនាដូច្នេះ, មានសេចក្តីថា ព្រោះហេតុដែលយើងត្រេកអរ គឺត្រេកអរក្រៃលែងក្នុងព្រះសាសនារបស់ព្រះដ៏មានព្រះភាគជាម្ចាស់ទាំងឡាយ ដែលនាំមកនូវអមតៈតែម្យ៉ាង ដូច្នោះ យើងនឹងខ្ជាក់ចោលនូវពិស គឺទិដ្ឋិនោះ ។

គាថាចុងក្រោយថា **ឥទំ វត្វាន** ដូច្នេះ ព្រះសង្គីតិកាចារ្យទាំងឡាយ បានតាំងទុកហើយ ។ បណ្តាបទទាំងនោះ បទថា **បាចីនមុខោ** បានដល់ ផ្តោះមុខទៅទិសខាងកើត ។ បទថា **រថមារុយ្ហ** (**រថមារុយ្ហិ**) សេចក្តីថា ព្រះរាជាស្តេចឡើងកាន់រាជរថរបស់ព្រះអង្គដែលជាព្រះទីនាំង លុះស្តេចឡើងគង់ប្រថាប់ហើយ ក៏បានទៅដល់ព្រះនគររបស់ព្រះអង្គថ្ងៃនោះឯង ដោយអានុភាពរបស់ទេវតា ហើយ

ទ្រង់ក៏បានយាងចូលព្រះរាជវាំង ។ សម័យជាក្រោយមក ទ្រង់ក៏បាន ត្រាស់ប្រាប់នូវរឿងនោះដល់ភិក្ខុទាំងឡាយ ភិក្ខុទាំងឡាយ ទើបប្រាប់ នូវរឿងនោះ ដល់ព្រះថេរៈទាំងឡាយ ។ ព្រះថេរៈទាំងឡាយ ទើបលើកឡើងកាន់សង្គាយនាក្នុងតតិយសង្គីតិ ។

## ( ចប់រឿងនន្ទិកាប្រេតទី ៣ )

**បាបោបិ បស្សតី ភទ្រំ យាវ បាបំ ន បច្ចតិ**
**យទា ច បច្ចតី បាបំ អថ (បាបោ) បាបានិ បស្សតិ ។**

បាបមិនទាន់ឱ្យផលត្រឹមណា មនុស្សបាប ក៏នៅឃើញតែ សេចក្តីចំរើនត្រឹមណោះ លុះកាលណា បាបឱ្យផល មនុស្សបាប ទើបឃើញបាប ក្នុងកាលនោះ ។

( បិដកលេខ ៥២, ទំព័រ ៤៧ )

# ៤-រេវតីប្រេត

( បិដកលេខ ៥៦, ទំព័រ ១១៩ + បិ. ៥៥, ទំ. ១១១ និងអដ្ឋកថា )

រឿងនាងរេវតីប្រេតនេះ មានពាក្យផ្ដើមថា **ឧដ្ឋេហិ រេវតេ សុបាបធម្មេ** ដូច្នេះ ។ ព្រោះហេតុដែលរឿងនោះ មិនវិសេសជាងរេវតីវិមានវត្ថុ ព្រោះដូច្នោះ ពាក្យណាដែលគួរពោលក្នុងអត្ថុប្បត្តិហេតុ និងក្នុងគាថានោះ ពាក្យនោះគប្បីជ្រាបដោយន័យដូចពោលក្នុងអដ្ឋកថាវិមានវត្ថុ ឈ្មោះបរមត្ថទីបនីនោះឯង ។ ក៏រឿងនេះ សូម្បីព្រះសង្គីតិកាចារ្យនឹងលើកឡើងកាន់សង្គាយនាក្នុងបាលីវិមានវត្ថុ ដោយអំណាចនន្ទិយទេវបុត្រ ក៏គប្បីជ្រាបថា លើកឡើងកាន់សង្គាយនា សូម្បីក្នុងបាលីបេតវត្ថុថា រេវតីបេតវត្ថុ ដោយអំណាចគាថាដែលជាប់ទាក់ទងដោយនាងរេវតី ។

( សេចក្ដីនៃបេតវត្ថុមានប្រមាណប៉ុណ្ណោះ តទៅនឹងរៀបរាប់-សេចក្ដីពិស្ដារក្នុងវិមានវត្ថុជាបន្ត ) :

រេវតីវិមាន មានសេចក្ដីថា **ឧដ្ឋេហិ រេវតេ សុបាបធម្មេ** ជាដើម រេវតីវិមាននោះ កើតឡើងដូចម្ដេច ?

ព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់គង់ប្រថាប់នៅក្នុងព្រៃឥសិ-បតនមិគទាយវ័ន ជិតក្រុងពារាណសី សម័យនោះ ត្រកូលដែលបរិបូណ៌ដោយសទ្ធាក្នុងក្រុងពារាណសី មានបុត្រឈ្មោះនន្ទិយៈ ជាឧបាសក ដល់ព្រមដោយសទ្ធា ជាទាយក ជាទានបតី ជាអ្នកទំនុក-បម្រុងព្រះសង្ឃ គ្រានោះ មាតាបិតារបស់គាត់មានបំណងនឹងនាំនាងកញ្ញាឈ្មោះ **រេវតី** ជាធីតារបស់អ៊ំប្រុសមកពីផ្ទះដែលពួកញាតិនៅជួបជុំគ្នា ប៉ុន្តែនាងជាមនុស្សមិនមានសទ្ធា មានប្រក្រតីមិនឱ្យទានឡើយ នន្ទិយៈទើបមិនត្រូវការនាង មាតារបស់នន្ទិយៈនិយាយជាមួយនឹងនាងរេវតីថា នែនាងដ៏ចម្រើន នាងមកនៅផ្ទះនេះហើយ ចូរយកអាចម៍គោស្រស់លាបទីអង្គុយរបស់ភិក្ខុសង្ឃ ក្រាលអាសនៈ តាំងជើងទ្របាត្រ វេលាភិក្ខុទាំងឡាយនិមន្តមក ចូរថ្វាយបង្គំ ទទួលបាត្រនិមន្តឱ្យគង់ យកតម្រងទឹកត្រងទឹកសម្រាប់ឆាន់ ហើយលាងបាត្រពេលដែលលោកឆាន់រួចហើយ ធ្វើយ៉ាងនេះទើបជាទីត្រេកអររបស់កូនប្រុសយើង នាងក៏បានធ្វើតាមពាក្យដំបូន្មាននោះ លំដាប់នោះមាតាបិតាប្រាប់នន្ទិយៈថា រេវតីជាស្រីដែលអាចទូន្មានបាន កាលនន្ទិយៈទទួលថា ប្រពៃហើយ ទើបកំណត់ថ្ងៃហើយធ្វើនូវពិធីអាវា-ហមង្គល ។

គ្រានោះ នន្ទិយៈពោលជាមួយនឹងនាងថា ប្រសិនបើនាង

ទំនុកបម្រុងភិក្ខុសង្ឃ និងមាតាបិតារបស់ខ្ញុំ កាលបើដូច្នេះ នាងក៏នៅក្នុងផ្ទះនេះបាន ចូរកុំប្រមាទណា នាងទទួលពាក្យថា ប្រពៃហើយ ហើយធ្វើដូចជាមានសទ្ធាគ្រប់ពេលវេលា បដិបត្តិតាមស្វាមី, ហើយប្រសូតបុត្របាន ២ នាក់ កាលមាតាបិតារបស់នន្ទិយៈ បានធ្វើកាលកិរិយាហើយ ភាពជាធំគ្រប់យ៉ាងក្នុងផ្ទះ ក៏បានធ្លាក់មកលើនាងតែម្នាក់ឯង សូម្បីនន្ទិយៈក៏បានជា **មហាទានបតី** ( ជាម្ចាស់នៃទាន ) ហើយក៏បានចាប់ផ្តើមតម្កល់នូវទានថ្វាយចំពោះភិក្ខុសង្ឃ ចាប់ផ្តើមនូវ**បាកវត្ត** ( ដាំបាយជាប្រចាំ ) នៅក្បែរទ្វារផ្ទះសម្រាប់ជនក្រខ្សត់និងអ្នកដំណើរជាដើម គាត់បានសាងសាលា ៤ ខ្នង ប្រដាប់ដោយបន្ទប់ ៤ បន្ទប់ នៅនាឥសិបតនមហាវិហារ បានរៀបចំតម្កល់នូវគ្រែនិងតាំងជាដើម ថ្វាយមហាទានចំពោះភិក្ខុសង្ឃមានព្រះពុទ្ធជាធាន ហើយប្រួចនូវទឹកទក្ខិណោទកលើព្រះហស្តរបស់ព្រះតថាគត វេរថ្វាយដំណាលគ្នានឹងការថ្វាយទឹកទក្ខិណោទកនោះឯង មានប្រាសាទទិព្វដែលសម្រេចដោយរតនៈ ៧ ប្រការ ទំហំ ១២ យោជន៍ដោយជុំវិញ កំពស់ ១០០ យោជន៍ កុះករទៅដោយពួកស្រីទេពអប្សរ ១,០០០ បានកើតឡើង នៅនា ឋានសួគ៌ជាន់តាវត្តិង្ស ។

គ្រានោះ ព្រះមហាមោគ្គល្លានត្រាច់ទៅកាន់ទេវចារិកឃើញប្រាសាទនោះ ក៏បានសួរពួកទេវបុត្រដែលមកថ្វាយបង្គំថា នេះជា-

ប្រាសាទរបស់អ្នកណា ?

ទេវបុត្រទាំងឡាយពោលថា បពិត្រលោកដ៏ចម្រើន ម្ចាស់របស់ប្រាសាទនេះ ឈ្មោះនន្ទិយៈ ជាបុត្ររបស់កុដុម្ពិកៈ ក្រុងពារាណសី ក្នុងមនុស្សលោក បានសាងសាលា ៤ ខ្នង នៅនាឥសិបតនមហាវិហារ ថ្វាយចំពោះសង្ឃ ប្រាសាទនេះកើតឡើង សម្រាប់នន្ទិយៈនោះ សូម្បីពួកទេពអប្សរដែលកើតក្នុងប្រាសាទក៏ថ្វាយបង្គំព្រះថេរៈ ពោលថា បពិត្រលោកម្ចាស់ដ៏ចម្រើន ពួកខ្ញុំកើតក្នុងប្រាសាទនេះ ដើម្បីធ្វើជា**បរិចារិកា** ( ស្រីអ្នកបម្រើ ) របស់ឧបាសកឈ្មោះនន្ទិយៈ ក្រុងពារាណសី សូមលោកម្ចាស់ប្រាប់ដល់គេយ៉ាងនេះថា ពួកទេពធីតាដែលកើតដើម្បីធ្វើជាបរិចារិការបស់អ្នក កាលបើអ្នកនៅបង្អែបង្អង់ ក៏ក្រវល់ក្រវាយក្នុងចិត្ត ឈ្មោះថាសម្បត្តិក្នុងទេវលោករមែងជាទីពេញចិត្តយ៉ាងក្រៃលែង ដូចទម្លាយនូវភាជនៈដីហើយទទួលយកនូវភាជនៈមាសដូច្នោះ ហើយពោលថា សូមលោកម្ចាស់ប្រាប់ដល់គេ ដើម្បីឱ្យគេមកក្នុងទីនេះ ព្រះថេរៈទទួលពាក្យថា ប្រពៃហើយ រួចក៏បានប្រញាប់ត្រឡប់មកពីទេវលោកវិញ ទូលសួរព្រះដ៏មានព្រះភាគ ក្នុងកណ្តាលបរិស័ទថា បពិត្រព្រះអង្គដ៏ចម្រើន ទិព្វសម្បត្តិ រមែងកើតចាំអ្នកដែលបានធ្វើបុណ្យហើយ ដែលឋិតនៅក្នុងមនុស្សលោកនេះនៅឡើយដែរឬហ្ន៎ ព្រះអង្គ ? ព្រះដ៏មានព្រះ-

ភាគត្រាស់ថា ម្នាលមោគ្គល្លាន ទិព្វសម្បត្តិដែលកើតចាំ នន្ទិយៈ ក្នុងទេវលោកនោះ ក្រែងអ្នកបានឃើញដោយខ្លួនឯងស្រាប់ហើយ មិនមែនឬ ? ហេតុដូចម្ដេច អ្នកទើបសួរតថាគតទៀត ? ព្រះមហា-មោគ្គល្លានត្លេរក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន ទិព្វសម្បត្តិកើតឡើងចាំយ៉ាងនោះបានឬ ? គ្រានោះ ព្រះសាស្ដា កាលទ្រង់សម្ដែងដល់ព្រះថេរៈនោះថា ពួកញាតិនិងមិត្តទាំងឡាយ រមែងត្រេកអរសាទរ ចំពោះអ្នកដែលព្រាត់គ្នាទៅយូរហើយត្រឡប់មកវិញយ៉ាងណាមិញ បុណ្យទាំងឡាយរបស់ខ្លួន ៗ រមែងទទួលបុគ្គលដែលបានធ្វើបុណ្យទុកហើយ ដែលបានលះលោកនេះទៅកាន់បរលោកក៏យ៉ាងនោះដែរ ហើយទ្រង់ក៏បានត្រាស់នូវព្រះគាថាទាំងឡាយនេះថា :

*ពួកញាតិមិត្តនិងសម្លាញ់ តែងត្រេកអរសាទរ ចំពោះបុរសដែលព្រាត់គ្នាអស់កាលយូរ ហើយវិលមកអំពីទីឆ្ងាយ ដោយសួស្ដីថាមកហើយ ដូច្នោះយ៉ាងណា បុណ្យទាំងឡាយ រមែងទទួលបុគ្គលដែលបានធ្វើបុណ្យហើយ ចេញចាកលោកនេះ ទៅកាន់លោកខាងមុខ ដូចពួកញាតិទទួលញាតិ ជាទីស្រឡាញ់មកដល់ យ៉ាងនោះដែរ ។*

នន្ទិយៈបានស្ដាប់ដូច្នោះហើយ ក៏បានថ្វាយទានទាំងឡាយ ធ្វើនូវបុណ្យទាំងឡាយ កាន់តែក្រៃលែងឡើង កាលគាត់ទៅប្រកប-

ជំនួញ បានផ្តាំនាងរេវតីថា នាងដ៏ចម្រើន សង្ឃទានក្តី បាកវត្តដើម្បី-ជនអនាថាក្តី ដែលខ្ញុំបានតាំងទុកហើយ នាងកុំធ្វេសប្រហែសឡើយ ចូរឱ្យប្រព្រឹត្តទៅកុំឱ្យដាច់ឱ្យសោះ នាងទទួលពាក្យថា ប្រពៃហើយ ។

សូម្បីគាត់ធ្វើដំណើរទៅស្នាក់នៅក្នុងទីណា ៗ ក៏ដោយ ក៏នៅតែថ្វាយទានដល់ភិក្ខុទាំងឡាយ និងឱ្យទានដល់ជនអនាថាតាមសមគួរដល់ទ្រព្យ ក្នុងទីនោះ ៗ ដូចក្នុងកាលមុនដែរ ព្រះខីណាស្រពទាំងឡាយ ក៏មកទទួលទានសូម្បីក្នុងទីឆ្ងាយ ដើម្បីអនុគ្រោះដល់គាត់ ។

ចំណែកនាងរេវតី កាលនន្ទិយៈទៅហើយ នាងឱ្យទានពីរបីថ្ងៃប៉ុណ្ណោះ ហើយក៏បានបញ្ឈប់នូវការឱ្យអាហារសម្រាប់ជនអនាថាសម្រាប់ភិក្ខុទាំងឡាយ នាងបានប្រគេននូវបបរលាយស្តុរជាភត្តា-ហារ មានទឹកជ្រក់ជាគម្រប់ពីរ, នាងបានពង្រាយគ្រាប់បាយដែលសល់ពីខ្លួនបរិភោគ មានលាយឡំដោយដុំត្រីនិងសាច់ មានឆ្អឹងរាត់រាយក្នុងកន្លែងឆាន់ចង្ហាន់របស់ភិក្ខុទាំងឡាយ ហើយបង្ហាញដល់មនុស្សទាំងឡាយថា អ្នកទាំងឡាយចូរមើលនូវការប្រព្រឹត្តរបស់ពួកសមណៈពួកសមណៈបោះចោលនូវវត្ថុដែលគេប្រគេនដោយសទ្ធាយ៉ាងនេះ ។

លំដាប់នោះ នន្ទិយៈនៅពេលដែលសម្រេចនូវការប្រកបជំនួញបានផលកម្រៃហើយក៏ត្រឡប់មកវិញ បានជ្រាបនូវរឿងនោះ

ហើយ ទើបបណ្តេញនាងរេវតីចេញពីផ្ទះ, ហើយខ្លួនឯងក៏បានចូល-ក្នុងផ្ទះ ក្នុងថ្ងៃទីពីរ នន្ទិយៈបានថ្វាយនូវទានជាច្រើនចំពោះភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន បានឱ្យនិច្ចភត្ត និងអនាថភត្តប្រព្រឹត្តទៅដោយប្រពៃដូចក្នុងកាលមុន គាត់បានតាំងនាងរេវតីដែលពួកសម្លាញ់របស់គាត់នាំត្រឡប់មកវិញ ឱ្យជាធំក្នុងការមើលខុសត្រូវចំពោះអាហារសម័យជាខាងក្រោយមក គាត់ធ្វើកាលកិរិយាហើយ ក៏បានទៅកើតក្នុងវិមានរបស់ខ្លួននោះឯង ក្នុងឋានសួគ៌ជាន់តាវត្តិង្សនោះ ។

ចំណែកនាងរេវតីក៏បានបញ្ឈប់នូវការឱ្យទានគ្រប់យ៉ាង ហើយក៏បានដើរជេរប្រទេចភិក្ខុសង្ឃដោយសម្គាល់ថា ព្រោះសមណៈទាំងនេះ អញទើបសាបសូន្យចាកលាភសក្ការៈ, គ្រានោះស្តេច-វេស្សវ័ណ បានបញ្ជាយក្ខពីរនាក់ថា ម្នាលយក្ខ អ្នកទាំងពីរចូរទៅប្រកាស ក្នុងក្រុងពារាណសីថា ចាប់តាំងពីថ្ងៃនេះទៅនៅសល់ប្រាំពីរថ្ងៃទៀត នាងរេវតីនឹងត្រូវពួកនិរយបាលបោះទៅក្នុងនរកទាំងរស់ មហាជន បានស្តាប់ដូច្នោះហើយក៏កើតនូវសេចក្តីតក់ស្លុត ទាំងខ្លាចនិងភិតភ័យ ។

គ្រានោះ នាងរេវតីក៏បានឡើងទៅលើប្រាសាទ បិទទ្វារហើយក៏បានអង្គុយ ក្នុងថ្ងៃទី ៧ ស្តេចវេស្សវ័ណដែលត្រូវចាបរបស់នាងរេវតីដាស់តឿន ហើយក៏បានបញ្ជាយក្ខពីរនាក់ ដែលមានសក់

និងពុកមាត់ពណ៌ដាំដែង ( ពណ៌ខ្មៅលាយក្រហម ) មានច្រមុះវៀច ខុសប្រក្រតី មានចង្កូម-ង ភ្នែកក្រហម មានសម្បុរដូចជ័រស្រល់ មានរូបរាងគួរឱ្យខ្លាចក្រៃលែង បានចូលទៅពោលនូវពាក្យជាដើមថា នែនាងរេវតី មានធម៌ដ៏លាមកពន់ពេក នាងចូរក្រោកឡើង រួច ក៏បានចាប់ត្រង់ដើមដៃទាំងពីរប្រកាសថា មហាជនចូរមើល ហើយ ក៏បានធ្វើឱ្យនាងដួលបម្រះននៀល ចេញពីថ្នល់មួយទៅថ្នល់មួយទៀត ទូទាំងព្រះនគរ បន្ទាប់មកក៏បាននាំនាងហោះឡើងទៅកាន់ឋាន-តាវត្តិង្ស បង្ហាញវិមាន និងសម្បត្តិរបស់នន្ទិយៈឱ្យនាងបានឃើញ ហើយក៏បានបញ្ជូននាងដែលកំពុងតែយំខ្សឹកខ្សួលនោះឯងទៅជិត ឧស្សទនរក ទូតរបស់យមរាជ ក៏បានបោះនាងទៅក្នុងឧស្សទនរក ។ ព្រោះហេតុនោះ លោកទើបពោលថា :

*នែនាងរេវតី មានធម៌ដ៏លាមកពន់ពេក ជាស្រីឥតទាន ឥតសីល នាងចូរក្រោកឡើង ទ្វារនរករបើកហើយ ពួកសត្វនរក ជាសត្វទុគ៌តប្រកបដោយទុក្ខ យំថ្ងូរនៅ ក្នុងទីណា ពួកយើងនឹងនាំនាងទៅក្នុងទីនោះ ។*

បណ្តាបទទាំងនោះ បទថា **ឧដ្ឋេហិ** ប្រែថា ចូរក្រោកឡើង សេចក្តីថា ឥឡូវនេះ ប្រាសាទនេះការពាររក្សានាងឱ្យរួចផុតពីភ័យ ក្នុងនរកមិនបានទេ ព្រោះដូច្នោះ នាងចូរប្រញាប់ក្រោកឡើងមក

ហៅនាងដោយឈ្មោះថា **រេវតី** ពោលនូវហេតុនៃការក្រោកឡើង ដោយបទថា **សុចាបធម្មេ** ជាដើម សេចក្តីថា ព្រោះនាងមានបាបធម៌ដ៏លាមកក្រៃលែង ដោយការជេរការប្រទេចព្រះអរិយៈទាំងឡាយ និងព្រោះមិនបិទទ្វារនរកដើម្បីនាងនឹងបានចូលទៅ ដូច្នោះ ចូរក្រោកឡើង ។ បទថា **អទានសីលេ** បានដល់ មានប្រក្រតីមិនឱ្យនូវវត្ថុណាមួយដល់នរណាម្នាក់ឡើយ ជាមនុស្សកំណាញ់ស្វិតស្វាញ សូម្បីបទនេះ ក៏ជាពាក្យធ្វើនូវការក្រោកឡើងនោះឯង, អធិប្បាយថា ព្រោះអ្នកដែលមានប្រក្រតីឱ្យនូវទាន មិនកំណាញ់ ដូចជាស្វាមីរបស់នាងនៅក្នុងសុគតិ ចំណែកអ្នកមានប្រក្រតីមិនឱ្យនូវទាន មានសេចក្តីកំណាញ់ ដូចជានាងនៅក្នុងនរក ដូច្នោះ ចូរក្រោកឡើង យើងនឹងមិនឱ្យនាងនៅក្នុងទីនេះសូម្បីត្រឹមតែមួយស្របក់ ។ បទថា **យត្ថ ថុនន្តិ ទុគ្គតា** សេចក្តីថា ឈ្មោះថាដល់នូវសេចក្តីលំបាក ព្រោះដល់នូវសេចក្តីទុក្ខ ។ បទថា **នេរយិកា** សេចក្តីថា ពួកសត្វនរក ពេញព្រៀប គឺដល់ព្រមដោយសេចក្តីទុក្ខក្នុងនរក យំថ្ងូរនៅក្នុងនរកណា សេចក្តីថា បាបកម្មនៅមិនទាន់អស់ត្រឹមណា សត្វនរកទាំងឡាយកាលចេញទៅមិនបាន រមែងយំថ្ងូរត្រឹមនោះ យើងនឹងនាំ គឺ យក គឺបោះនាងចូលទៅក្នុងនរកនោះ ។ តទៅនេះ ជាពាក្យរបស់សង្គីតិកាចារ្យថា :

*លុះយក្ខមានភ្នែកក្រហម ធំសម្បើមទាំងពីរ ជាទូតនៃ-យមរាជបានពោលយ៉ាងនេះហើយ ក៏ចាប់នាងរេវតី ត្រង់ដើមដៃម្ខាងម្នាក់ ហើយនាំចូលទៅក្នុងសម្នាក់នៃ-ពួកទេវតា ។*

បណ្តាបទទាំងនោះ បទថា **ឥច្ចេវំ វត្វាន** សេចក្តីថា ពោលដូច្នេះហើយ គឺដោយពាក្យថា ចូរក្រោកឡើងជាដើម, អធិប្បាយថា បន្តអំពីការនិយាយនោះឯង ។ បទថា **យមស្ស ទូតា** សេចក្តីថា ជាទូតនៃយមរាជ ជាអ្នកប្រកដោយភាពយុត្តិធម៌ ដែលគ្មាននរណាម្នាក់អាចជំទាស់បានឡើយ ។ តាមពិត ស្តេចវេស្សវ័ណបញ្ជូនពួកគេទាំងនោះទៅ ពិតដូច្នោះ ពួកគេនាំនាងទៅកាន់ឋានតាវត្តិង្ស , អាចារ្យពួកខ្លះ ភ្ជាប់ **ន** អក្សរ ក្នុងបទថា **ន យមស្ស ទូតា** ជាមួយនឹងបទថា **យមស្ស** មានសេចក្តីថា ជាទូតរបស់ស្តេច-វេស្សវ័ណសេចក្តីនោះមិនត្រឹមត្រូវទេ ព្រោះមិនសម្រេចសេចក្តីថា មិនមែនជាទូតរបស់ស្តេចវេស្សវ័ណទេ ព្រោះជាទូតរបស់យមរាជ ឈ្មោះថា **យក្ខ** ព្រោះជាទីបូជា គឺនាំចូលទៅនូវពលី ។ បទថា **លោហិតក្ខា** ប្រែថា មានភ្នែកក្រហម មែនពិត យក្ខទាំងឡាយរមែងមានភ្នែកក្រហមឯទាំង ។ បទថា **ព្រហន្តា** ប្រែថា ធំ ។ បទថា **បច្ចេកពាហាសុ** សេចក្តីថា ត្រង់ដើមដៃម្ខាងម្នាក់ គឺម្នាក់ត្រង់ដើម-

ដៃម្ខាង ម្នាក់ទៀតត្រង់ដើមដៃម្ខាងទៀត ។ បទថា **រេវតី** ប្រែថា នាងរេវតី ឈ្មោះរបស់នាងថា **រេវតា**ក៏មាន សមដូចដែលបានពោលទុកថា **រេវតេ** ដូច្នេះ ។ បទថា **បក្កាមយិំសុ** ប្រែថា ចៀសចេញទៅហើយ សេចក្ដីថា នាំចូលទៅហើយ ។ បទថា **ទេវគណស្ស** បានដល់ ពួកទេវតាជាន់តាវត្តិង្ស កាលយក្ខទាំងនោះនាំទៅកាន់ឋានតាវត្តិង្សហើយក៏បានដាក់នាងចុះ ក្បែរវិមានរបស់នន្ទិយៈយ៉ាងនេះហើយ **នាងរេវតី**ក៏បានឃើញវិមាននោះ ភ្លឺរុងរឿងក្រៃលែង ដូចព្រះអាទិត្យ ទើបសួរយក្ខទាំងនោះថា :

*វិមានដែលមានសម្បុរ ដូចព្រះអាទិត្យ ដ៏រុងរឿង ភ្លឺផ្លេកសម្បើមល្អ បិទបាំង ដោយបណ្ដាញមាស មានជនកុះករភ្លឺដូចរស្មីព្រះអាទិត្យនុ៎ះ តើជាវិមានអ្នកណា ពួកនារីទាំងឡាយ មានខ្លួនលាបដោយខ្លឹមចន្ទន៍ ហើយចូលទៅញ៉ាំងវិមាននោះឱ្យល្អរុងរឿងទាំងពីរខាង វិមាននោះមានសម្បុរប្រាកដស្មើ ដោយសម្បុរព្រះអាទិត្យ បុគ្គល-ណាហ្ន៎ បានដល់នូវឋានសួគ៌ ហើយរីករាយ ក្នុងវិមាន ។*

សូម្បីយក្ខទាំងនោះក៏បានប្រាប់ដល់នាងរេវតីថា :

*ក្នុងក្រុងពារាណសី មានឧបាសកម្នាក់ឈ្មោះនន្ទិយៈ ជា-អ្នកមិនកំណាញ់ ជាម្ចាស់ទាន អ្នកដឹងនូវពាក្យពេចន៍*

*វិមានដែលមានជនកុះករ ដ៏រុងរឿងដូចរស្មីព្រះអាទិត្យ-ន៍ុះ ជាវិមានរបស់ឧបាសកឈ្មោះនន្ទិយៈនោះ ពួកនារីទាំងឡាយ មានខ្លួនលាបហើយ ដោយលំអិតខ្លឹមចន្ទន៍ ហើយចូលទៅញុំាងវិមាននោះឱ្យល្អរុងរឿងទាំងពីរខាង វិមាននោះ មានសម្បុរស្មើដោយសម្បុរព្រះអាទិត្យ នន្ទិយៈ ឧបាសកនោះ បានដល់នូវឋានសួគ៌ ហើយរីករាយក្នុងវិមាន ( នោះ ) ។*

បណ្ដាបទទាំងនោះ បទថា **ចន្ទនសារានុលិត្តា** ប្រែថា មានសរីរៈលាបដោយខ្លឹមចន្ទន៍ ។ បទថា **ឧភតោ វិមានំ** សេចក្ដីថា ញុំាងវិមានឱ្យល្អរុងរឿងទាំងពីរខាង គឺទាំងខាងក្នុងទាំងខាងក្រៅ ព្រោះប្រកបដោយសង្គីត ( ការរាំច្រៀង ) ជាដើម ។

លំដាប់នោះ **នាងរេវតី**ពោលថា :

*ខ្លួនខ្ញុំ ជាប្រពន្ធរបស់នន្ទិយឧបាសក ជាម្ចាស់ផ្ទះ*
*ជាធំរបស់ត្រកូលទាំងអស់ ខ្ញុំនឹងត្រេកអរ ក្នុងវិមាន*
*របស់ប្ដីក្នុងកាលឥឡូវនេះ ខ្ញុំមិនចង់ឃើញនរក ។*

បណ្ដាបទទាំងនោះ បទថា **អគារិនី** ប្រែថា ជាម្ចាស់ផ្ទះ អាចារ្យពួកខ្លះពោលថា **ភរិយា សគាមិនី** ដូច្នេះក៏មាន សេចក្ដីថា ភរិយាអ្នករួមផ្លូវ ។ បទថា **សព្វកុលស្ស ឥស្សរា ភត្តុ** សេចក្ដីថា

ខ្ញុំជាធំ គឺជាម្ចាស់ទ្រព្យទាំងអស់ របស់នន្ទិយៈដែលជាស្វាមីរបស់ខ្ញុំ , ដូច្នោះនាងរេវតីទើបពោលថា សូម្បីក្នុងកាលឥឡូវនេះ ខ្ញុំនឹងជាធំក្នុងវិមាន ។ បទថា **វិមានេ រមិស្សាមិ ឥានិហំ** សេចក្តីថា យក្ខទាំងនោះនាំនាងរេវតីទៅទីនោះ ក៏ដើម្បីលួងលោមយ៉ាងនេះឯង ។ បទថា **ន បត្ថយេ និរយំ ទស្សនាយ** សេចក្តីថា នាងរេវតីពោលថា អ្នកទាំងឡាយមានបំណងនឹងនាំខ្ញុំទៅកាន់នរកណា ខ្ញុំមិនប្រាថ្នាសូម្បីនឹងឃើញនរកនោះទេ ចាំបាច់និយាយទៅថ្វីដល់ការចង់ចូលទៅនោះ ។

**យក្ខទាំងពីរ**បាននាំនាងដែលកំពុងតែពោលយ៉ាងនោះឯង ទៅជិតនរក ដោយពោលថា នាងនឹងប្រាថ្នា ឬមិនប្រាថ្នាក៏ដោយ មិនមានប្រយោជន៍អ្វីដោយការប្រាថ្នារបស់នាងឡើយ ហើយពោលនូវគាថាថា :

*ម្នាលស្រីមានធម៌ដ៏លាមកពន់ពេក នរកនុ៎ះ ជានរកសម្រាប់នាងហើយ នាងឯង មិនបានធ្វើបុណ្យក្នុងមនុស្សលោកសោះ ព្រោះថា បុគ្គលមានសេចក្តីកំណាញ់ ជាអ្នកជេរប្រទេចគេ មានធម៌ដ៏លាមករមែងមិនបានកើតរួម ជាមួយនឹងពួកអ្នកដែលទៅកើតក្នុងឋានសួគ៌ទេ ។*

គាថានោះមានសេចក្តីថា នេះហើយជានរកសម្រាប់នាង គឺជាទីដែលនាងនឹងគប្បីសោយនូវទុក្ខដ៏ធំអស់កាលដ៏យូរ ព្រោះហេតុអ្វី ? ព្រោះនាងមិនបានធ្វើបុណ្យទុកក្នុងមនុស្សលោក សេចក្តីថាព្រោះថាបុណ្យសូម្បីមានប្រមាណតិចតួច នាងមិនបានធ្វើទុកក្នុង-មនុស្សលោកឡើយ, ម្យ៉ាងទៀត សត្វដូចជានាង មិនបានធ្វើបុណ្យយ៉ាងនេះហើយថែមទាំងកំណាញ់ គឺប្រកបដោយសេចក្តីកំណាញ់ដែលមានលក្ខណៈហួងហែងសម្បត្តិរបស់ខ្លួន ជាអ្នកក្រោធខឹង ដោយការឱ្យសេចក្តីក្រោធខឹងកើតឡើងដល់អ្នកដទៃ ជាអ្នកមាននូវបាបធម៌ព្រោះដល់ព្រមដោយបាបធម៌ មានសេចក្តីលោភជាដើម រមែងមិនបាននូវភាពជាសម្លាញ់ គឺភាវៈរួមគ្នា របស់ទេវតាទាំងឡាយអ្នកចូលដល់ឋានសួគ៌ឡើយ ។

លុះពោលយ៉ាងនេះហើយ យក្ខទាំងពីរនោះក៏បានអន្តរធានបាត់ទៅក្នុងទីនោះឯង ចំណែកនាងរេវតីឃើញនិរយបាលពីរនាក់ស្រដៀង ៗ គ្នា កំពុងតែចាប់អូសនាង ដើម្បីបោះទៅក្នុងគូថនរកឈ្មោះ **សំសវកៈ** ទើបសួរដល់នរកនោះថា :

*អ្វីនេះហ្ន៎ ជាគូថនិងមូត្រមិនស្អាត ជាក់ស្តែងម្ល៉េះ អ្វីនេះហ្ន៎ជាលាមកមានក្លិនអាក្រក់ម្ល៉េះ អ្វីនុ៎ះហ្ន៎ ផ្សាយក្លិនមក ។*

***( ពួកនិរយបាលពោលថា )***

*នុ៎ះនរកឈ្មោះ* ***សំសវកៈ*** *ដ៏ជ្រៅចំនួនមួយរយជួរបុរស ម្នាល-នាងរេវតី នាងនឹងឆេះក្នុងនរកនោះរាប់ពាន់ឆ្នាំ ។*

***( នាងរេវតីតបថា )***

*អំពើអាក្រក់ដូចម្តេច ដែលខ្ញុំបានធ្វើដោយកាយ វាចា ចិត្ត នរកឈ្មោះ****សំសវកៈ*** *ដ៏ជ្រៅ ចំនួនមួយរយជួរបុរស ខ្ញុំបានដោយហេតុដូចម្តេច ។*

***( ពួកនិរយបាលពោលថា )***

*នាងបាននិយាយបញ្ឆោតពួកសមណៈ ពួកព្រាហ្មណ៍ និងពួកវណិព្វកៈដទៃ ៗ ដោយមុសាវាទ បាបនោះ នាងបានធ្វើហើយយ៉ាងនេះ នរកឈ្មោះសំសវកៈ ដ៏ជ្រៅចំនួនមួយរយជួរបុរស នាងបានព្រោះបាបនោះឯង ម្នាលនាងរេវតី នាងនឹងឆេះក្នុងនរកនោះរាប់ពាន់ឆ្នាំ ។*

បណ្តាបទទាំងនោះ បទថា **សំសវកោ នាម** សេចក្តីថា ឈ្មោះថា ***សំសវកៈ*** ព្រោះជារបស់មិនស្អាតមានលាមក និងមូត្រជាដើម ហូរ គឺ ហូរចេញគ្រប់កាលជានិច្ច សម្រាប់នាង មិនមែនបានសំសវកៈក្នុងទីនេះតែម្យ៉ាងប៉ុណ្ណោះឡើយ ។

លំដាប់នោះ ដើម្បីសម្តែងថា នាងឆេះក្នុងនរកនោះរាប់ពាន់ឆ្នាំមិនមែនតិចទេ ហើយរួចផុតឡើងមកបាន ថែមទាំងត្រូវកាត់ដៃជា-

ដើមទៀត **និរយបាល**ពោលដល់ហេតុការណ៍ដែលនាងនឹងត្រូវបាន-ក្នុងនរកនោះថា :

*ពួកនិរយបាល កាត់ដៃក៏មាន កាត់ជើងក៏មាន កាត់ស្លឹកត្រចៀកក៏មាន កាត់ច្រមុះក៏មាន មួយទៀត ពួកសត្វក្អែក មកប្រជុំជញ្ជែងចឹក នូវសត្វនរក ដែលកំពុងតែញាប់ញ័រ ។*

បណ្ដាបទទាំងនោះ បទថា **កាកោលគណា** ប្រែថា ហ្វូងក្អែក បានឮថា ហ្វូងក្អែកទាំងនោះនាំគ្នាចោមរោមប្រើចំពុះដែកប្រមាណប៉ុនដើមត្នោត មានចុងមុតស្រួចចឹងស៊ីត្រង់សរីរៈប្រមាណ ៣ គាវុតរបស់នាង រាប់រយពាន់ដង សាច់ត្រង់ទីដែលត្រូវក្អែកចឹកយកទៅ ក៏ពេញដូចដើមដោយកម្លាំងកម្ម ព្រោះហេតុនោះ លោកទើបពោលថា **កាកោលគណា សមេច្ច សង្គម្ម ខាទន្តិ ផន្ទមានន្តិ** ដូច្នេះ ។

**នាងរេវតី**បានយំខ្សឹកខ្សួលតទៅដល់រឿងនោះ ៗ ដូចជាសូម-ត្រឡប់ទៅមនុស្សលោកវិញជាដើម ព្រោះហេតុនោះ លោកទើបពោលថា :

*ខ្ញុំសូមអង្វរ សូមអ្នកទាំងឡាយ នាំខ្ញុំត្រឡប់ទៅវិញ ពួកសត្វជាអ្នកបានសុខ ទាំងមិនក្ដៅក្រហាយ ក្នុងកាលខាងក្រោយ ព្រោះ-*

បានធ្វើកុសលណា ខ្ញុំនឹងធ្វើកុសលនោះឱ្យច្រើនដោយការឱ្យទាន ការប្រព្រឹត្តស្មើ ការសង្រួម និងការទូន្មានឥន្ទ្រិយ ។

**( ពួកនិរយបាលពោលថា )**

ក្នុងកាលមុននាងប្រមាទហើយ ឥឡូវនេះទួញយំ នាងនឹងទទួលផលនៃកម្មទាំងឡាយ ដែលបានធ្វើដោយខ្លួនឯង ។

**( នាងរេវតីតបថា )**

បុគ្គលណា ចេញអំពីទេវលោក ទៅកាន់មនុស្សលោកហើយ ខ្ញុំសួរ គប្បីប្រាប់ខ្ញុំ យ៉ាងនេះថា អ្នកទាំងឡាយ ចូរឱ្យសំពត់សម្រាប់ស្លៀកដណ្តប់ ទីដេក ( ទីអង្គុយ ) និងបាយ ទឹក ជាទាន ចំពោះពួកជនដែលមានអាជ្ញាដាក់ចុះហើយ បើពិតថា បុគ្គលមានសេចក្តីកំណាញ់ ជាអ្នកជេរប្រទេចគេ មានធម៌ដ៏លាមក រមែងមិនបានទៅកើតជាមួយនឹងពួកអ្នកដែលទៅកើតក្នុងឋានសួគ៌មែន ។

ខ្ញុំនោះ ប្រសិនបើរួចទៅអំពីនេះ ហើយបាននូវកំណើតជារបស់មនុស្ស នឹងជាអ្នកដឹងគុណ បរិបូណ៌ដោយសីល ធ្វើនូវកុសលឱ្យច្រើន ដោយការឱ្យទាន ការប្រព្រឹត្តស្មើ ការសង្រួម និងការទូន្មាននូវឥន្ទ្រិយ មួយទៀត ខ្ញុំនឹងដាំឈើសួន សង់ស្ពានសម្រាប់ឆ្លងទៅមក

*ក្នុងទីដែលលំបាក ជីកអណ្តូង ជីកស្រះ ដោយចិត្តជ្រះថ្លា ខ្ញុំនឹងរក្សាឧបោសថប្រកបដោយអង្គ ៨ អស់ថ្ងៃទី ១៤ ទី ១៥ និងថ្ងៃទី ៨ នៃបក្ខផង អស់បាដិហារិយបក្ខផង ខ្ញុំនឹងជាបុគ្គលសង្រួមក្នុងសីលទាំងឡាយ គ្រប់កាល ខ្ញុំនឹងមិនប្រមាទ ក្នុងទាន ព្រោះខ្ញុំ បានឃើញអំពើនេះ ( ជាក់ច្បាស់ ) ដោយខ្លួនឯងហើយ ។*

***( ពួកនិរយបាល )***

*បោះនាងរេវតីដែលកំពុងយំ បម្រះនទៀលយ៉ាងនេះ ទៅក្នុងនរកដ៏ពន្លឹក ឱ្យមានជើងឡើងលើ មានក្បាលចុះក្រោម ។*

***( នាងរេវតីនិយាយថា )***

*ក្នុងកាលមុន ខ្ញុំជាអ្នកមានសេចក្តីកំណាញ់ ជាអ្នកជេរ*
*ប្រទេច នូវពួកសមណៈនិងព្រាហ្មណ៍ បោកប្រាស់*
*នូវស្វាមី ដោយពាក្យមិនពិត ទើបខ្ញុំឆេះក្នុងនរក*
*មានសភាពដ៏ពន្លឹក ។*

បណ្តាបទទាំងនោះ បទថា **អហំ បរេ មច្ឆរិនី** នេះ នាងរេវតីដែលកើតក្នុងនរកពោល ក្រៅពីនេះ គប្បីជ្រាបថា នាងនៅមិនទាន់កើតក្នុងនរកបានពោលទុក ពាក្យដ៏សេស ងាយយល់ទាំងអស់ ។

ភិក្ខុទាំងឡាយក្រាបទូលរឿងនាងរេវតីដែលត្រូវពួកយក្ខចាប់យកទៅ ចំពោះព្រះដ៏មានព្រះភាគ ព្រះដ៏មានព្រះភាគទ្រង់ព្រះ-

សណ្ដាប់ដូច្នោះហើយ ទ្រង់ត្រាស់សម្ដែងនូវរឿងនេះ តាំងពីដើមរហូតដល់ចប់ ហើយទ្រង់ក៏បានសម្ដែងនូវព្រះធម៌ឱ្យកាន់តែពិស្ដារក្រៃលែងឡើង ។ ពេលចប់នូវព្រះធម៌ទេសនា ជនជាច្រើនបានសម្រេចនូវសោតាបត្តិផលជាដើម រឿងនេះ ហៅថា រេវតីវិមាន ព្រោះដោយច្រើនជារឿងដែលជាប់ទាក់ទងនឹងនាងរេវតីក៏ពិតមែនហើយ ប៉ុន្តែព្រោះនាងរេវតីមិនមែនជាទេវតាដែលមានវិមាន ទាំងរឿងនេះក៏ប្រកបដោយសម្បត្តិវិមានរបស់នន្ទិយទេវបុត្រជាដើមដូច្នោះ ព្រះសង្គីតិកាចារ្យទើបលើកឡើងកាន់សង្គាយនាទុក ក្នុងចំណែកនៃ-បុរិសវិមាននោះឯង បណ្ឌិតគប្បីជ្រាបដោយប្រការដូច្នេះ ។

## ( ចប់រេវតីវិមានទី ២ )

# ៥-រឿងឧច្ឆុប្រេត

" ប្រេតមានចំការអំពៅតែបរិភោគមិនកើត "

( បិដកលេខ ៥៦, ទំព័រ ១១៩ និងអដ្ឋកថា )

រឿងឧច្ឆុប្រេតនេះ មានពាក្យផ្ដើមថា **ឥទំ មម ឧច្ឆុវនំ មហន្តំ** ដូច្នេះ ។ មូលហេតុដែលនាំឱ្យកើតនូវរឿងនោះ តើដូចម្ដេច ?

កាលព្រះដ៏មានព្រះភាគទ្រង់គង់ប្រថាប់នៅក្នុងវត្តវេឡុវ័ន-មហាវិហារ មានបុរសម្នាក់ចងអំពៅ ( មួយបាច់ ) ហើយក៏បានដើរបរិភោគអំពៅមួយដើម ។ លំដាប់នោះ ឧបាសកម្នាក់ ជាអ្នកមានសីលមានកល្យាណធម៌ មួយអន្ទើដោយក្មេងតូចដើរតាមពីក្រោយ ។ ក្មេងនោះឃើញអំពៅហើយក៏យំទារថា ចូរឱ្យ ( អំពៅមកខ្ញុំ ១ ), ឧបាសកឃើញក្មេងយំ កាលនឹងសង្គ្រោះនូវបុរសនោះ ទើបបាននិយាយជាមួយនឹងបុរសនោះ ចំណែកបុរសនោះ មិននិយាយអ្វីសោះជាមួយនឹងឧបាសកនោះឡើយ ហើយសូម្បីតែអំពៅមួយកំណាត់ក៏មិនបានឱ្យដល់ក្មេងនោះដែរ ឧបាសកទើបបង្ហាញនូវក្មេងនោះហើយពោលថា ក្មេងនេះយំខ្លាំងណាស់ អ្នកចូរឱ្យអំពៅដល់ក្មេងនេះ មួយកំណាត់មក បុរសនោះបានស្ដាប់ដូច្នោះហើយ ទ្រាំមិនបាន កើត-

នូវសេចក្តីចង្អៀតចង្អល់ចិត្ត ទើបបោះអំពៅមួយដើមទៅខាងក្រោយ ដោយមិនអើពើ ។

សម័យជាខាងក្រោយមក គេធ្វើកាលកិរិយាហើយក៏បានកើតក្នុងកំណើតប្រេត ដោយអំណាចនៃសេចក្តីលោភដែលគ្របសង្កត់អស់កាលដ៏យូរ ។ ឈ្មោះថាផលនៃកម្មនោះ រមែងឃើញសមគ្នានឹងកម្មរបស់ខ្លួន ព្រោះហេតុនោះ ទើបកើតជាព្រៃអំពៅដ៏ធំក្រាស់ឃ្មឹកដោយអំពៅ ប្រមាណប៉ុនអង្រែមានពណ៌ដូចផ្កាអញ្ចាន់ ពេញស្ថានទីប្រមាណ ៨ ករីសៈ[១] ។ នៅពេលដែលគេចូលទៅ ដើម្បីនឹងចាប់យកអំពៅ ព្រោះចង់បរិភោគ អំពៅក៏ប្រហារគេ ព្រោះហេតុនោះគេទើបដួលចុះ ( លើផែនដី ) ។

ក្រោយមកថ្ងៃមួយ ព្រះមហាមោគ្គល្លាន និមន្តចូលទៅកាន់ក្រុងរាជគ្រឹះដើម្បីបិណ្ឌបាត ក៏បានឃើញប្រេតនោះក្នុងចន្លោះផ្លូវ ប្រេតនោះឃើញព្រះថេរៈហើយ ទើបសួរដល់កម្មដែលខ្លួនបានធ្វើ ។ គាថាឆ្លើយឆ្លង ដែលប្រេត និងព្រះថេរៈពោល សេចក្តីថា :

***( ប្រេតទូលសួរព្រះមោគ្គល្លានថា )***

*ព្រៃអំពៅធំនេះកើតឡើងដល់ខ្ញុំ ( ហាក់ដូច ) ជាផលបុណ្យ-*

*១= **ករីសៈ** ជាមាត្រាវាស់សម័យបុរាណ គឺ **១ ករីសៈ** ស្មើនឹង **១២៥ ហត្ថ** ។ ( អភិធាន. ) ។*

ច្រើនណាស់ដែរ តែឥឡូវនេះខ្ញុំមិនបានបរិភោគអំពៅនោះសោះ បពិត្រលោកដ៏ចម្រើន សូមលោកប្រាប់ខ្ញុំ តើផលនេះ ជាផលកម្មអ្វី ។ មួយទៀត ខ្ញុំដល់នូវសេចក្តីចង្អៀតចង្អល់ ចង់បរិភោគ ( ក៏បរិភោគ-មិនកើត ) ខ្ញុំខំប្រឹងខ្នះខ្នែងដើម្បីបរិភោគនូវរសនៃអំពៅ តិចតួច ខ្ញុំនោះមានអត្តភាពដាច់ហើយ ជាបុគ្គលកំសត់ ប្រកបដោយទុក្ខ នេះជាផលនៃកម្មអ្វី ។ មួយទៀត ខ្ញុំជាបុគ្គលចង្អៀតចង្អល់ ដួលដេកបម្រះនទៀលលើផែនដី ដូចត្រីនៅលើគោកដ៏ក្តៅ ទឹកភ្នែកទាំងឡាយរបស់ខ្ញុំ ហូរចេញអំពីចម្ងាយ បពិត្រលោកដ៏ចម្រើន សូមលោកមេត្តាប្រាប់ នេះជាផលនៃកម្មអ្វី ។ ខ្ញុំឃ្លានផង លំបាកផង ស្រេកផង តក់ស្លុតផង មិនបានសេចក្តីសុខស្រួលទេ បពិត្រលោកដ៏ចម្រើន ខ្ញុំសូមសួរសេចក្តីនុ៎ះ ចំពោះនឹងលោកម្ចាស់ ធ្វើម្តេចហ្ន៎ ខ្ញុំគប្បីបានបរិភោគអំពៅ ( នេះ ) ។

**( ព្រះមោគ្គល្លានមានថេរវាចាថា )**

កាលពីដើម អ្នកកើតជាមនុស្សបានធ្វើបាបកម្មដោយខ្លួនឯង ក្នុងកាលមុន អាត្មារៀបរាប់សេចក្តីនោះប្រាប់អ្នក អ្នកស្តាប់ហើយ ត្រូវដឹងសេចក្តីនោះចុះ ។ ( កាលនោះ ) អ្នកកំពុងដើរស៊ីអំពៅ មានបុរសម្នាក់ដើរពីក្រោយខ្នងអ្នក បុរសនោះ ប្រាថ្នាចង់បានអំពៅនោះ ហើយនិយាយសូម អ្នកមិនបាននិយាយពាក្យតិចតួច នឹងបុរស

*នោះទេ ។ ឯបុរសនោះបាននិយាយសូមចំពោះអ្នកដែលមិននិយាយរក បាននិយាយនឹងអ្នកថា អ្នកចូរឱ្យអំពៅដល់ខ្ញុំ អ្នកក៏បានឱ្យអំពៅមួយដើម តាមក្រោយខ្នង ដល់បុរសនោះ នេះជាផលរបស់បាបកម្មនោះឯង ។ ហាំ បើដូច្នោះ អ្នកគប្បីទៅចាប់អំពៅពីក្រោយខ្នងចុះ លុះចាប់បានហើយ ចូរស៊ីឱ្យឆ្អែតចុះ អ្នកគង់មានចិត្តត្រេកអរ រីករាយ អណ្ដែតឡើង ស្រស់ស្រាយ ព្រោះតែបានបរិភោគអំពៅនោះ ។ បុរសនោះ ទៅចាប់យកអំពៅពីក្រោយខ្នងរបស់ខ្លួន លុះចាប់យកបានហើយ ក៏ស៊ីអំពៅនោះទាល់តែឆ្អែតឆ្អន់ រួចបុរសនោះ មានចិត្តត្រេកអរ រីករាយ អណ្ដែតឡើង ស្រស់ស្រាយ ។*

បណ្ដាបទទាំងនោះ បទថា **កិស្ស** អធិប្បាយថា នៃកម្មដូចម្ដេច ។ បទថា **ហញ្ញាមិ** ( **វិហញ្ញាមិ** ) បានដល់ ខ្ញុំរមែងក្ដៅក្រហាយ គឺដល់នូវសេចក្ដីចង្អៀតចង្អល់, ម្យ៉ាងទៀត បទថា **ហញ្ញាមិ** ប្រែថា រមែងបៀតបៀន, អធិប្បាយថា រមែងបៀតបៀនយ៉ាង-ក្រៃលែង ។ បទថា **ខជ្ជាមិ** ប្រែថា ត្រូវស្លឹកអំពៅមុត, អធិប្បាយថា ត្រូវស្លឹកអំពៅឆូត ដូចត្រូវសស្ត្រាដ៏មុតមានដាវ ( ជាដើម ) ឆូត ។ បទថា **វាយមាមិ** បានដល់ ខ្ញុំព្យាយាមដើម្បីនឹងបរិភោគអំពៅ ។ បទថា **បរិសក្កាមិ** ប្រែថា ប្រឹងប្រែង ។ បទថា **បរិភុញ្ជិតុំ** សេចក្ដីថា ដើម្បីនឹងបរិភោគទឹកអំពៅ, អធិប្បាយថា ដើម្បីនឹងទំពាស៊ីអំពៅ ។

បទថា **ឆិន្នថាមោ** ( បិដកថា **ឆិន្នាត្ថាមោ** ) ប្រែថា អស់កម្លាំង គឺកម្លាំងដាច់ទៅ, អធិប្បាយថា កម្លាំងអស់ទៅ ។ បទថា **គបណោ** បានដល់ ជាបុគ្គលកំសត់ ។ បទថា **លាលបាមិ** ( បិដកថា **សាលបាមិ** ) សេចក្តីថា ខ្ញុំត្រូវសេចក្តីទុក្ខគ្របសង្កត់ ទើបខ្សឹកខ្សួល យ៉ាងក្រៃលែង ។

បទថា **ទិឃាតោ** ប្រែថា មានសេចក្តីចង្អៀតចង្អល់ ឬត្រូវ កម្ចាត់នូវកម្លាំង ។ បទថា **បរិបតាមិ ឆមាយំ** សេចក្តីថា កាលមិន អាចទប់ខ្លួនបានទើបដួលចុះលើផែនដី ។ បទថា **បរិវត្តាមិ** ប្រែថា រមែងបម្រះនឿល ។ បទថា **ទារិចរោវ** ប្រែថា ដូចត្រី ។ បទថា **ឃម្មេ** បានដល់ លើគោកដ៏ក្តៅរោលរាលដោយកំដៅ ។

បទថា **សន្តស្សិតោ** ( បិដកថា **សំតាសិតោ** ) បានដល់ ស្រេកខ្លាំង ព្រោះបបូរមាត់ ក និងពិដានដល់នូវភាពហួតហែងទៅ ។ បទថា **សាតស្ខំ** បានដល់ សេចក្តីសុខដែលជាសេចក្តីរីករាយ ។ បទថា **ន ទិន្ទេ** ប្រែថា រមែងមិនបាន ។ បទថា **តំ** ប្រែថា ចំពោះ លោក ។ បទថា **ទិជាន** ( បិដកថា **ទិជានំ** ) ប្រែថា ចូរដឹង ។ បទថា **បយាតោ** ប្រែថា ចាប់ផ្តើមនឹងទៅ ។ បទថា **អន្វគច្ឆិ** ( បិដកថា **អនុគញ្ឆិ** ) ប្រែថា ជាប់តាម ។ បទថា **បច្ឆាសន្តោ** ប្រែថា ប្រាថ្នាចំពោះ ។ បទថា **ឯតំ** ក្នុងបទថា **តស្សេតំ កម្មស្ស**

នេះ គ្រាន់តែជានិបាត, អធិប្បាយថា នៃកម្មនោះ ។ បទថា **បិដ្ឋិតោ គណ្ហេយ្យាសិ** សេចក្តីថា គប្បីចាប់យកអំពៅពីក្រោយខ្នងរបស់ខ្លួននោះឯង ។ បទថា **បមោទិតោ** បានដល់ រីករាយចិត្ត ។

បទថា **គហេត្វាន តំ ខាទិ យាវទត្ថំ** សេចក្តីថា ប្រេតចាប់យកអំពៅតាមទំនងដែលព្រះថេរៈប្រាប់ ហើយទំពាស៊ីតាមសេចក្តីគាប់ចិត្ត រួចហើយក៏បានកាន់យកនូវអំពៅមួយបាច់ធំ បង្អោនចូលទៅប្រគេនព្រះថេរៈ ព្រះថេរៈកាលនឹងអនុគ្រោះដល់គេ ទើបឱ្យគេនោះឯង កាន់យកអំពៅមួយបាច់នោះទៅកាន់វត្តវេឡុវ័នមហាវិហារ ថ្វាយចំពោះព្រះដ៏មានព្រះភាគ ព្រះដ៏មានព្រះភាគមួយអន្លើដោយភិក្ខុសង្ឃក៏បានឆាន់នូវអំពៅនោះ រួចហើយក៏ធ្វើនូវអនុមោទនា ប្រេតមានចិត្តជ្រះថ្លា ថ្វាយបង្គំហើយក៏ចៀសចេញទៅ ចាប់តាំងពីនោះមក គេក៏បរិភោគអំពៅតាមសប្បាយ ។

សម័យក្រោយមក គេធ្វើកាលកិរិយាហើយក៏បានទៅកើតជាទេវតាក្នុងជាន់តាវត្តិង្ស ។ ក៏ប្រវត្តិរបស់ប្រេតនេះនោះបានប្រាកដក្នុងមនុស្សលោក ។ លំដាប់នោះ ពួកមនុស្សចូលទៅគាល់ព្រះសាស្តា ទូលសួរនូវរឿងនោះ ព្រះសាស្តាទ្រង់ក៏បានត្រាស់នូវរឿងនោះដល់មនុស្សទាំងនោះដោយពិស្តារ រួចហើយទ្រង់សម្តែងនូវព្រះធម៌ ។ ពួកមនុស្សបានស្តាប់នូវព្រះធម៌នោះហើយ ជាអ្នករៀរផុតស្រឡះ

ចាកសេចក្តីកំណាញ់ ដូច្នេះឯង ។

## ( ចប់រឿងឧច្ឆុប្រេតទី ៥ )

**បុញ្ញញ្ចេ បុរិសោ កយិរា កយិរាថេនំ បុនប្បុនំ**
**តម្ហិ ឆន្ទំ កយិរាថ សុខោ បុញ្ញស្ស ឧច្ចយោ ។**

បើបុរសធ្វើបុណ្យ គួរធ្វើបុណ្យនោះឱ្យរឿយ ៗ គួរធ្វើសេចក្តីពេញចិត្ត ក្នុងបុណ្យនោះ ( ព្រោះថា ) ការសន្សំបុណ្យ តែងនាំសេចក្តីសុខមកឱ្យ ។

( បិដកលេខ ៥២, ទំព័រ ៤៧ )

# ៦-រឿងកុមារប្រេត

" ប្រេតមានតែសេចក្តីស្រេកឃ្លានព្រោះកម្មអ្វី "

( បិដកលេខ ៥៦, ទំព័រ ១២២ និងអដ្ឋកថា )

ព្រះសាស្តាកាលទ្រង់គង់ប្រថាប់នៅក្នុងវត្តជេតពនមហាវិហារ ទ្រង់ប្រារព្ធប្រេត ២ នាក់ ទើបត្រាស់នូវព្រះគាថានេះ មានពាក្យផ្តើមថា **សាវត្ថី នាម នគរំ** ដូច្នេះ ។

បានឮថា ក្នុងក្រុងសាវត្ថី ព្រះបាទបសេនទិកោសលមានព្រះ-ឱរស ២ ព្រះអង្គគួរឱ្យជ្រះថ្លា កំពុងស្ថិតនៅក្នុងបឋមវ័យ ( ជាអ្នក ) ស្រវឹងក្នុងវ័យ ( របស់ខ្លួន ) ក៏បានធ្វើនូវកម្ម គឺគប់រកភរិយារបស់អ្នកដទៃ ធ្វើកាលកិរិយាហើយក៏បានទៅកើតជាប្រេតត្រង់ខ្នងនៃគូ ។ ក្នុងវេលាយប់ ប្រេតទាំងនោះបាននាំគ្នាស្រែកដោយសម្លេងដែលគួរឱ្យខ្លាច ពួកមនុស្សបានឮសម្លេងនោះហើយ នាំគ្នាភ័យខ្លាច គិតថា កាលបើពួកយើងធ្វើយ៉ាងនេះ អពមង្គលនេះរមែងស្ងប់រម្ងាប់ ទើបនាំគ្នាធ្វើមហាទានចំពោះភិក្ខុសង្ឃមានព្រះពុទ្ធជាប្រធាន ហើយក៏បានក្រាបទូលនូវរឿងនោះ ចំពោះព្រះដ៏មានព្រះភាគ ។ ព្រះដ៏មាន-ព្រះភាគត្រាស់ថា ម្នាលឧបាសក និងឧបាសិកាទាំងឡាយ អន្តរាយ

ណាមួយ ព្រោះបានឮនូវសម្លេងនោះ រមែងមិនមានដល់ពួកអ្នកឡើយ ដើម្បីនឹងត្រាស់ប្រាប់នូវហេតុនៃសម្លេងនោះ ហើយសម្តែង-ធម៌ដល់មនុស្សទាំងនោះ ទើបបានត្រាស់នូវព្រះគាថាថា :

*តថាគតឮថាក្រុងឈ្មោះសាវត្ថី នៅក្បែរព្រៃហិមពាន្ត ក្នុង-ក្រុងនោះមានកុមារពីរនាក់ ជាព្រះរាជបុត្ររបស់ ( ព្រះបាទបសេន-ទិកោសល ) ។ ព្រះរាជបុត្រទាំងពីរអង្គនោះជាអ្នកប្រមាទ ជាអ្នកមានសេចក្តីត្រេកអរ ក្នុងកាមគុណទាំងឡាយជាទីត្រេកអរ ជាប់-ជំពាក់ និងសេចក្តីសុខជាបច្ចុប្បន្ន ព្រះរាជបុត្រទាំងនោះ មិនបានឃើញសេចក្តីសុខទៅក្នុងអនាគតកាលឡើយ ។ ព្រះរាជបុត្រទាំងនោះ ទៅកាន់លោកខាងមុខ ចាកអត្តភាពជាមនុស្ស ព្រះរាជបុត្រទាំងពីរនោះ មិនប្រាកដរូប ស្រែកប្រកាស តែអំពើអាក្រក់របស់ខ្លួនក្នុងកាលមុន ។ កាលទក្ខិណេយ្យបុគ្គលទាំងឡាយមានច្រើន កាលទេយ្យធម៌មាន ពួកយើងមិនអាចដើម្បីធ្វើខ្លួនឱ្យមានសួស្តីតិចតួច ជាទីនាំមកនូវសេចក្តីសុខសោះ ។ អំពើអាក្រក់អ្វី ជាអំពើអាក្រក់ជាងអំពើរបស់យើងនោះ ពួកយើងច្យុតចាករាជត្រកូលមកកើតជាប្រេត-វិស័យ ( ក្នុងទីនេះ ) ប្រកបដោយសេចក្តីស្រេក និងការឃ្លាន ។ ពួកមនុស្សជាម្ចាស់គេក្នុងលោកនេះ ពុំមែនជាម្ចាស់ក្នុងលោកឯណោះទៀតទេ បានខ្ពស់ហើយ ត្រឡប់ទាបវិញ ( ព្រោះតណ្ហា ) តែងស្លាប់*

*ដោយសេចក្ដីស្រេកឃ្លាន ។ នរជនដឹងទោស ដែលកើតអំពីសេចក្ដីប្រកាន់ថាធំ យ៉ាងនេះហើយ គប្បីលះនូវសេចក្ដីស្រវឹងថាធំចោលចេញ ទើបទៅឋានសួគ៌ នរជននោះជាអ្នកប្រកបដោយប្រាជ្ញា ដល់បែកធ្លាយរាងកាយ រមែងកើតក្នុងឋានសួគ៌ ។*

បណ្ដាបទទាំងនោះ បទថា **ឥតិ មេ សុតំ** សេចក្ដីថា តថាគតបានឃើញដោយញាណរបស់ខ្លួនតែម្យ៉ាងប៉ុណ្ណោះ ក៏ទេ តាមពិតតថាគតបានស្ដាប់មកយ៉ាងនេះ ដូចដែលប្រាកដក្នុងលោក ។

បទថា **កាមស្សាទាភិនន្ទិនោ** បានដល់ មានប្រក្រតីត្រេកត្រអាលដោយអំណាចនៃសេចក្ដីត្រេកអរក្នុងកាមគុណ ។ បទថា **បច្ចុប្បន្នេ សុខេ គិទ្ធា** បានដល់ ជាអ្នកជាប់ជំពាក់ គឺជាប់ជំពាក់ក្នុងអារម្មណ៍ដែលជាសេចក្ដីសុខក្នុងបច្ចុប្បន្ន ។ បទថា **ន តេ បស្សិំសុនាគតំ** សេចក្ដីថា ព្រះរាជកុមារទាំង ២ នោះ លះបង់នូវសុចរិតប្រព្រឹត្តនូវទុច្ចរិត មិនគិតដល់សេចក្ដីសុខដែលនឹងគប្បីបានក្នុងទេវតា និងមនុស្ស ក្នុងអនាគត គឺក្នុងកាលតទៅឡើយ ។

បទថា **តេ ឧ ឃោសេន្តុធិស្សន្តា** ( បិដកថា **តេ ច ឃោសេន្តិ ន ទិស្សន្តា** ) សេចក្ដីថា ប្រេតទាំងនោះ ក្នុងកាលមុនជាព្រះរាជឱរស មានរូបមិនប្រាកដស្រែកកន្ទក់កន្ទេញនៅក្នុងទីជិតក្រុងសាវត្ថីនេះ ។ ដើម្បីចៀសវាងពាក្យសួរថា តើស្រែកកន្ទក់កន្ទេញ

ដូចម្ដេចខ្លះ ? លោកទើបពោលថា ខ្លួនបានធ្វើកម្មអាក្រក់ទុកក្នុងកាលមុន ។

ឥឡូវនេះ ដើម្បីនឹងសម្ដែងនូវការចែកហេតុនៃការកន្ទក់-កន្ទេញរបស់ប្រេតទាំងនោះ ដោយហេតុនិងផល លោកទើបពោលថា **កាលទក្ខិណេយ្យបុគ្គលទាំងឡាយមានច្រើន ដូច្នេះជាដើម** ។

បណ្ដាបទទាំងនោះ បទថា **ពហូសុ វត សន្តេសុ** បានដល់កាលព្រះទក្ខិណេយ្យជាច្រើនមាន ។ បទថា **ទេយ្យធម្មេ ឧបដ្ឋិតេ** សេចក្ដីថា សូម្បីកាលទេយ្យធម៌ដែលគួរឱ្យដែលជារបស់ខ្លួនដែលទុកហើយក្នុងទីជិត, អធិប្បាយថា ដែលនឹងបាន ។ បទថា **បរិត្តំ សុខាវហំ** ( បិដកថា **បរិត្តសោត្ថិ ភាគំ សុខាវហំ** ) មានសេចក្ដីថា យើងមិនអាចធ្វើនូវបុណ្យដែលជាហេតុ នាំមកនូវសេចក្ដីសុខក្នុង-អនាគតសូម្បីមានប្រមាណតិចតួច ហើយធ្វើខ្លួនឱ្យមានសេចក្ដីសួស្ដីគឺឱ្យប្រាសចាកឧបទ្ទវន្តរាយ ។

បទថា **កឹ តតោ បាបកំ អស្ស** សេចក្ដីថា ឈ្មោះថាកម្មដែលជាបាប គឺលាមកជាងនោះ នឹងគប្បីក្លាយជាយ៉ាងដទៃបានដូចម្ដេច ។ បទថា **យំ នោ រាជកុលា ចុតា** ( បិដកថា **សន្តោ រាជកុលា ចុតា** ) សេចក្ដីថា ព្រោះបាបកម្មណា ពួកយើងទើបច្យុតចាករាជត្រកូលកើតក្នុងប្រេតវិស័យនេះ គឺកើតក្នុងកំណើតប្រេត ប្រកប-

ដោយសេចក្តីស្រេកឃ្លានត្រាច់ទៅ ។

បទថា **សាមិនោ ឥធ ហុត្វាន** សេចក្តីថា កាលពីមុន រាជបុត្រជាម្ចាស់គេត្រាច់ទៅក្នុងទីណាក្នុងលោកនេះ ប៉ុន្តែ ( ឥឡូវនេះ ) មិនមែនជាម្ចាស់គេក្នុងទីនោះឯងទៀតឡើយ ។ បទថា **មនុស្សេ ឧន្នតោនតា** លោកសម្តែងថា ក្នុងវេលាជាមនុស្ស រាជកុមារទាំងនោះជាម្ចាស់គេ ធ្វើកាលកិរិយាហើយក៏វិនាសសាប-សូន្យ ដោយអំណាចនៃកម្ម ព្រោះសេចក្តីស្រេកឃ្លាន អ្នកចូរឃើញប្រក្រតីរបស់សង្សារវដ្ត ។

បទថា **ឯតមាទីនវំ ញត្វា ឥស្សរមទសម្ភវំ** ( បិដកថា **ឯវមាទីនវំ ញត្វា ឥស្សរមោនសម្ភវំ** ) សេចក្តីថា នរជនដឹងទោស ពោលគឺការកើតក្នុងអបាយដែលកើតដោយសេចក្តីស្រវឹងក្នុងភាពជាធំនេះ ហើយលះនូវសេចក្តីស្រវឹងក្នុងភាពជាធំចេញ-ហើយ ខ្វល់ខ្វាយតែក្នុងបុណ្យ ។ បទថា **ភវេ សគ្គគតោ នរោ** សេចក្តីថា គប្បីទៅឋានសួគ៌ គឺទេវលោកប៉ុណ្ណោះ ។

ព្រះសាស្តា លុះទ្រង់ត្រាស់នូវប្រវត្តិរបស់ប្រេតទាំងនោះដោយប្រការដូច្នេះហើយ ទ្រង់ឱ្យឧទ្ទិសនូវទានដែលមនុស្សទាំងឡាយនោះបានធ្វើដល់ពួកប្រេតទាំងនោះ ហើយទ្រង់សម្តែងនូវធម៌ ដែលសមគួរដល់អធ្យាស្រ័យរបស់បរិស័ទដែលបានមកជួបជុំគ្នា ព្រះធម៌-

ទេសនានោះ បានជាប្រយោជន៍ដល់មហាជន ដោយប្រការ ដូច្នេះ ។

## ( ចប់រឿងកុមារប្រេតទី ៦ )

មាវមញ្ញេថ បាបស្ស ន មន្តំ អាគមិស្សតិ
ឧទពិន្ទុនិបាតេន ឧទកុម្ភោបិ បូរតិ
អាបូរតិ ពាលោ បាបស្ស ថោកំ ថោកំបិ អាចិនំ ។

បុគ្គល មិនគួរមើលងាយបាបថា មានប្រមាណតិច នឹងមិនឱ្យផល ដូច្នេះឡើយ ប្រៀបដូចក្អមទឹក រមែងពេញបានដោយដំណក់ទឹក ដែលធ្លាក់ចុះ យ៉ាងណា បុគ្គលពាល កាលសន្សំបាបសូម្បីបន្តិចម្តង ៗ គង់ពេញបានដោយបាប យ៉ាងនោះដែរ ។

( បិដកលេខ ៥២, ទំព័រ ៤៧ )

# ៧-រឿងរាជបុត្តប្រេត

" ប្រទូស្តចំពោះឥសីធ្លាក់នរកហើយមកកើតជាប្រេត "

( បិដកលេខ ៥៦, ទំព័រ ១២៣ និងអដ្ឋកថា )

ព្រះសាស្តា កាលគង់ប្រថាប់នៅវត្តជេតពនមហាវិហារ ទ្រង់ប្រារព្ធរាជបុត្តប្រេត បានត្រាស់នូវព្រះគាថានេះ មានពាក្យ-ផ្តើមថា **បុព្វេ កតានំ កម្មានំ** ដូច្នេះ ។

ក្នុងរឿងនោះ ក្នុងអតីតកាល ឱរសរបស់ព្រះបាទ **កិតវៈ** ប្រព្រឹត្តខុសចំពោះព្រះបច្ចេកពុទ្ធក្នុងអតីតៈ បានឆេះក្នុងនរកជាច្រើនពាន់ឆ្នាំ ដោយសេសសល់នៃវិបាកកម្មនោះឯង គេទើបកើតក្នុងកំណើតប្រេត លោកប្រាថ្នាយករាជបុត្តប្រេតក្នុងទីនេះ ។ រឿង-របស់រាជបុត្តប្រេតនោះ មកដោយពិស្តារក្នុង**រឿងសានុវាសិប្រេត** ក្នុងខាងដើមនោះឯង, ព្រោះដូច្នោះ គួរកាន់យកដោយន័យដែលបានពោលរួចមកហើយក្នុងរឿងសានុវាសិប្រេតនោះឯង ។ មែនពិតក្នុងកាលនោះ កាលព្រះថេរៈ ពោលនូវប្រវត្តិរបស់ប្រេតដែលជាញាតិរបស់ខ្លួន ព្រះសាស្តាទើបត្រាស់ថា មិនមែនប្រេតដែលជាញាតិរបស់អ្នកតែម្យ៉ាងប៉ុណ្ណោះឡើយ តាមពិតសូម្បីអ្នកក៏ឃ្លាតចាកលោក-

នេះហើយ ក៏បានទៅកើតជាប្រេតដែរ សោយនូវសេចក្តីទុក្ខដ៏ខ្លាំងក្លា ក្នុងអត្តភាពដែលជាអតីតៈដោយលំដាប់ ដូច្នេះកាលដែលព្រះថេរៈនោះ ទូលអារាធនាហើយ ទើបត្រាស់នូវបេតវត្ថុនេះថា :

*ផលរបស់បាបកម្មទាំងឡាយ ដែលរាជបុត្រធ្វើហើយ ក្នុង-កាលពីដើម គប្បីញាំញីនូវចិត្ត ព្រោះរូប សំឡេង ក្លិន រស ផ្សព្វ និងធម្មារម្មណ៍ ។ រាជបុត្រ ចូលចិត្តនឹងការរាំ ការច្រៀង ការត្រេកអរ និងការសើចចំអកឡកឡឺយដ៏ច្រើន ដើរលេងក្នុងឧទ្យាន រួចចូលទៅក្រុងរាជគ្រឹះវិញ ។ រាជបុត្រនោះ បានឃើញឥសី ( ព្រះបច្ចេកពុទ្ធ ) ឈ្មោះ**សុនេត្ត** លោកមានចិត្តទូន្មានហើយ មានចិត្តតម្កល់មាំ ប្រាថ្នា-តិច ប្រកបដោយហិរិ ត្រេកអរតែនឹងចង្ហាន់ក្នុងបាត្រដោយការស្វែងរក ។*

*ក្សត្រិយ៍ចុះពី-កដំរីហើយសួរថា បពិត្រលោកដ៏ចម្រើន បានចង្ហាន់ដែរឬទេ ? ហើយទទួលយកបាត្ររបស់លោក លើកឡើងឱ្យខ្ពស់ បោកបំបែកបាត្រលោកលើដីរដិបរដុប ហើយសើចលេងដើរចេញទៅ ( និយាយថា ) ខ្ញុំជាកូនរបស់ព្រះបាទកិតវៈ នែភិក្ខុលោកនឹងធ្វើអ្វី ដល់ខ្ញុំ ។ ផលដ៏ក្តៅក្រហាយ របស់បាបកម្មដ៏អាក្រក់នោះឯង នាំរាជបុត្រឱ្យរងទុក្ខពេញពោរក្នុងនរក ។ រាជបុត្របានធ្វើអំពើអាក្រក់ ក៏ដល់នូវសេចក្តីទុក្ខក្រៃលែងក្នុងនរក ប្រាំបួនសែន*

*( ៩០០.០០០ ) ឆ្នាំ[១] ។ **ជនពាលទុកជាដេកផ្ងារក្តី ផ្កាប់ក្តី ផ្អៀងទៅខាងឆ្វេង ខាងស្តាំក្តី ជើងឡើងលើក្តី ឈរក្តី រមែងឆេះអស់កាលដ៏-យូរ ។ ជនពាលបានធ្វើអំពើអាក្រក់ ក៏ទទួលទុក្ខដ៏ក្រៃលែង ក្នុងនរកច្រើនពាន់ឆ្នាំផង ច្រើនហ្មឺនឆ្នាំផង** ។ បុគ្គលអ្នកមានបាបកម្ម តែងទទួលនូវសេចក្តីទុក្ខដ៏ក្រៃលែង ជាទុក្ខក្តៅផ្សា ប្រាកដដូច្នោះ ព្រោះតែប្រទូស្តនឹងឥសី អ្នកមិនបានប្រទូស្តមានវត្តល្អ ។ រាជបុត្រនោះទទួលនូវសេចក្តីទុក្ខដ៏ច្រើន ក្នុងនរកនោះ អស់ឆ្នាំទាំងឡាយដ៏ច្រើនច្យុតចាកនរកនោះមក មកកើតជាប្រេត មានសេចក្តីស្រេកឃ្លានបៀតបៀនហើយ ។ បុរសបុគ្គលដឹងទោស ជាដែនកើតនៃសេចក្តីស្រវឹង ព្រោះឥស្សរិយយស យ៉ាងនេះហើយ គប្បីលះបង់នូវសេចក្តីស្រវឹង ព្រោះតែឥស្សរិយយស ហើយប្រព្រឹត្តបន្ទាបបន្ទន់កាយ ។ ជនណាជាបុគ្គលដែលគេសរសើរក្នុងបច្ចុប្បន្ន ជាអ្នកគោរព ក្នុង-ព្រះពុទ្ធ ជននោះ ជាអ្នកប្រកបដោយប្រាជ្ញា លុះបែកធ្លាយរាងកាយទៅ រមែងកើតក្នុងឋានសួគ៌ ។*

បណ្តាបទទាំងនោះ បទថា **បុព្វេ កតានំ កម្មានំ វិបាកោ មថយេ មនំ** សេចក្តីថា ផលនៃអកុសលកម្មដែលព្រះរាជបុត្របានធ្វើទុកហើយក្នុងជាតិមុន កើតជាផលដ៏ក្រៃលែង ញាំញី គ្របសង្កត់ចិត្ត

១= តាមន័យអដ្ឋកថាសានុវាសិប្រេតក្តី, អដ្ឋកថារាជបុត្តប្រេតនេះក្តីថា ៨៤,០០០ ឆ្នាំ ។

របស់មនុស្សអន្ធពាល, អធិប្បាយថា ញ៉ាំងប្រយោជន៍របស់ខ្លួនឱ្យ-កើតឡើង ដោយប្រាថ្នានឹងធ្វើនូវសេចក្តីវិនាសឱ្យដល់អ្នកដទៃ ។

ឥឡូវនេះ ដើម្បីនឹងសម្តែងនូវផលនៃអកុសលកម្មនោះ ដែលជាគ្រឿងញ៉ាំញីចិត្តមួយអន្លើដោយអារម្មណ៍ លោកទើបពោលនូវ-ពាក្យជាដើមថា រូប សម្លេង ដូច្នេះ ។ បណ្តាបទទាំងនោះ បទថា **រូបេ** បានដល់ ព្រោះហេតុនៃរូប, អធិប្បាយថា ព្រោះបាននូវរូបា-រម្មណ៍ តាមប្រាថ្នា ដែលជាទីគាប់ចិត្តជានិមិត្ត ។ សូម្បីក្នុងបទថា **សទ្ទេ** ដូច្នេះជាដើម ក៏មានន័យដូចគ្នា ។

កាលទ្រង់នឹងសម្តែងកំណត់នូវសេចក្តីដែលបានពោលរួចមក-ហើយដោយទូទៅ ដោយសេចក្តីមិនទូទៅយ៉ាងនេះ ទើបត្រាស់នូវពាក្យជាដើមថា ការរាំ ការច្រៀង ដូច្នេះ ។ បណ្តាបទទាំងនោះ បទថា **រតី** បានដល់ នូវសេចក្តីត្រេកអរក្នុងកាម ។ បទថា **ខិឌ្ឌំ** បានដល់ ការលេងជាមួយសម្លាញ់ជាដើម ។ បទថា **គិរិព្វជំ** បានដល់ ក្រុងរាជគ្រឹះ ។

បទថា **ឥសឹ** សេចក្តីថា ឈ្មោះថាឥសីព្រោះអត្ថថា ស្វែងរកនូវគុណធំមានសីលក្ខន្ធជាដើម ដែលជារបស់ព្រះអសេក្ខៈ ។ បទថា **សុនេត្តំ** បានដល់ **អត្តទន្តំ** បានដល់ អ្នកមានចិត្តដែលបានទូន្មានហើយ ដោយការទូន្មានយ៉ាងខ្ពង់ខ្ពស់ ។ បទថា **សមាហិតំ** បានដល់

អ្នកមានចិត្តតម្កល់មាំហើយដោយសមាធិដែលសម្បយុត្តដោយព្រះ-អរហត្តផល ។ បទថា **ឱច្ឆេ បត្តគតេ រតំ** បានដល់ អ្នកត្រេកអរគឺសន្តោសក្នុងអាហារដែលនៅក្នុងបាត្រ គឺដែលធ្លាក់ចុះក្នុងបាត្រដែលបានមកដោយការស្វែងរក គឺដោយភិក្ខាចារ ។

បទថា **លទ្ធា ភន្តេតិ ចាព្រវិ** ( **លទ្ធា ភន្តេតិ ច ព្រវិ** ) សេចក្តីថា ត្រាស់ដើម្បីឱ្យកើតសេចក្តីស្និទ្ធស្នាលថា បពិត្រលោក-ម្ចាស់ដ៏ចម្រើន តើលោកម្ចាស់បានភិក្ខាខ្លះដែរឬទេ ។ បទថា **ឱច្ចំ បគ្គយ្ហ** បានដល់ លើកបាត្រឡើងឱ្យខ្ពស់ ។

បទថា **ថណ្ឌិលេ បត្តំ ភិន្ទិត្វា** បានដល់ បោកបំបែកបាត្រលើភូមិប្រទេសដ៏រឹង ។ បទថា **អបក្កមិ** បានដល់ ចៀសចេញទៅបានបន្តិច ។ ក៏ព្រះរាជបុត្រកាលនឹងចៀសចេញទៅបានបន្តិច ។ ក៏ព្រះ-រាជបុត្រកាលនឹងចៀសចេញទៅទើបពោលថា យើងជាបុត្ររបស់ព្រះបាទកិតវៈ នៃភិក្ខុ លោកនឹងធ្វើអ្វីដល់យើងដូច្នេះ ជាមួយនឹងព្រះ-បច្ចេកពុទ្ធដែលសម្លឹងមើលដោយសេចក្តីករុណាថា មនុស្សអន្ធពាលបានធ្វើនូវសេចក្តីវិនាសដ៏ធំសម្បើមឱ្យដល់ខ្លួន ដោយហេតុដែលមិនសមគួរឡើយ ។

បទថា **ផរុសស្ស** បានដល់ អាក្រក់ ។ បទថា **ភដុភោ** ប្រែថាមិនគួរប្រាថ្នា ។ បទថា **យំ យោគវិបាកំ** ប្រែថា វិបាកណា ។

បទថា **សមប្បិតោ** បានដល់ ជាប់នៅហើយ ។

បទថា **ឆឡេវ ចតុរាសីតិ វស្សានិ នហុតានិ ច** សេចក្តីថា ដេកផ្ងារ ដេកផ្កាប់ ដេកផ្អៀងទៅខាងឆ្វេង ដេកផ្អៀងទៅខាងស្តាំ យកជើងឡើងលើក្បាលសំយុងចុះក្រោម និងឈរតាមប្រក្រតី ( ក្នុង-ការសោយនូវទុក្ខ ) នីមួយ ៗ ៨៤,000 ឆ្នាំ រួមជា ៦ ដង, ក្នុងម្តង ៗ ៨៤,000 ឆ្នាំ ព្រោះហេតុនោះ លោកទើបពោលថា :

***ជនពាលទុកជាដេកផ្ងារក្តី ផ្កាប់ក្តី ផ្អៀងទៅខាងឆ្វេង ខាងស្តាំក្តី ជើងឡើងលើក្តី ឈរក្តី រមែងឆេះអស់កាលដ៏យូរ ។***

ក៏ព្រោះហេតុដែលមានច្រើនម៉ឺនឆ្នាំ ដូច្នោះលោកទើបហៅថា **នហុតានិ** ច្រើនម៉ឺនឆ្នាំ ។ បទថា **ទុសំ ទុក្ខំ និគច្ឆិង្សោ** សេចក្តីថា ទទួលនូវសេចក្តីទុក្ខដ៏ក្រៃលែង ។

បទថា **បូគានិ** បានដល់ ក្នុងការប្រជុំនៃឆ្នាំ តែក្នុងគាថានេះ និងក្នុងគាថាខាងដើម គប្បីជ្រាបថា ជាទុតិយាវិភត្តិចុះក្នុងអត្ថនៃ-**អច្ចន្តសំយោគ** ប្រែថា អស់ ។

បទថា **ឯតានិសំ** គឺប្រាកដដូច្នោះ ។ បទថា **ភជុតំ** បានដល់ ទុក្ខធ្ងន់នេះ ជាការសម្តែងចេញនៃ នបុំសកលិង្គ ដូចក្នុងប្រយោគថា អង្គុយនៅក្នុងទីដ៏សមគួរជាដើម, មានសេចក្តីថា បុគ្គលដែលមាន ការងារដ៏លាមក នាំគ្នាប្រទូស្ត គឺ បៀតបៀនឥសី ដែលជាអ្នកមិន-

ប្រទូស្ត ចំពោះបុគ្គលដែលប្រទូស្ត គឺអ្នកមានវត្តល្អ រមែងទទួល-នូវសេចក្ដីទុក្ខប្រាកដដូច្នេះ ដ៏ក្ដៅផ្សាក្រៃលែង ។

បទថា **សោ** បានដល់ រាជបុត្តប្រេតនោះ ។ បទថា **តត្ថ** គឺក្នុងនរក ។ បទថា **ទេនយិត្វា** ប្រែថា សោយ ។ បទថា **នាម** បានដល់ ដោយភាពជាអ្នកប្រាកដយ៉ាងជាក់ច្បាស់ ។ បទថា **តតោ ចុតោ** បានដល់ ចុតិចាកនរក ។ ពាក្យដ៏សេសមានន័យដូចពោលរួចមកហើយនោះឯង ។

ព្រះដ៏មានព្រះភាគ ទ្រង់ឱ្យមហាជនដែលបានមកប្រជុំគ្នាក្នុងទីនោះកើតនូវសេចក្ដីសង្វេគ ដោយកថាពោលអំពីរាជបុត្តប្រេតយ៉ាងនេះហើយ ទើបប្រកាសនូវអរិយសច្ចៈកាន់តែក្រៃលែងឡើង ។ ក្នុងវេលាចប់នូវអរិយសច្ចៈ ជនជាច្រើនបានសម្រេចសោតាបត្តិផលជាដើម ដោយប្រការដូច្នេះ ។

## ( ចប់រឿងរាជបុត្តប្រេតទី ៧ )

# ៨-រឿងគូថខាទកប្រេត

" ជេរប្រទេចលោកធ្លាក់នរកស៊ីរបស់មិនស្អាត "

( បិដកលេខ ៥៦, ទំព័រ ១២៥ និងអដ្ឋកថា )

កាលព្រះសាស្តា គង់ប្រថាប់នៅក្នុងវត្តជេតពនមហាវិហារ ទ្រង់ប្រារព្ធគូថខាទកប្រេតម្នាក់ ទើបត្រាស់នូវព្រះគាថានេះ មានពាក្យផ្តើមថា **គូថកូបតោ ឧគ្គន្ត្វា** ដូច្នេះ ។

បានឮថា ក្នុងស្រុកមួយមិនឆ្ងាយពីក្រុងសាវត្ថីប៉ុន្មាន មានកុដុម្ពិកៈម្នាក់ សាងវិហារ ឧទ្ទិសចំពោះភិក្ខុដែលជាជីតុន (១) របស់ខ្លួន ។ ភិក្ខុទាំងឡាយ មកពីជនបទផ្សេង ៗ ក៏បាននៅអាស្រ័យក្នុងវិហារនោះ ។ មនុស្សទាំងឡាយឃើញភិក្ខុទាំងនោះហើយ មានចិត្តជ្រះថ្លា ក៏បានឧបដ្ឋាកដោយបច្ច័យដ៏ប្រណីត ។ ភិក្ខុដែលជាជីតុននោះ អត់ទ្រាំនឹងបច្ច័យនោះមិនបាន ជាអ្នកត្រូវសេចក្តីប្ញស្សាគ្របសង្កត់ កាលនឹងពោលទោសរបស់ភិក្ខុទាំងនោះ ទើបលើកទោសនឹងកុដុម្ពិកៈ ។ កុដុម្ពិកៈក៏បានជេរប្រទេចភិក្ខុទាំងនោះ ហើយភិក្ខុដែល

---

១= ជីតុន ( ន. ) ពាក្យសម្រាប់គ្រសហ្គហៅអ្នកបួសដែលជាញាតិឬដែលស្និតស្នាលដោយបានផ្គត់ផ្គង់ចតុប្បច្ច័យផង ។

ជាជីតុន ( ក៏បានជេរប្រទេចភិក្ខុទាំងនោះដូច្នោះដែរ )។ លំដាប់នោះ ភិក្ខុដែលជាជីតុនធ្វើកាលកិរិយាហើយ ក៏បានទៅកើតជាប្រេតក្នុង-រណ្ដៅលាមក ( បង្គន់ ) ក្នុងវត្តនោះឯង ។ ចំណែកឯកុដុម្ពិកៈ ធ្វើកាលកិរិយាហើយ ក៏បានទៅកើតជាប្រេតឋិតនៅខាងលើទីបំផុតនៃ-ក្បាលរបស់ ភិក្ខុប្រេតនោះឯង ។ លំដាប់នោះ ព្រះមហាមោគ្គល្លាន លុះឃើញ ប្រេតនោះហើយ កាលនឹងសួរទើបពោលនូវគាថាថា :

*អ្នកដែលអាត្មាឃើញហើយ តើជាអ្វី ដើបអំពីរណ្ដៅអាចម៍ ហើយឋិតនៅ អ្នកឯងជាបុគ្គលមានបាបកម្មឥតសង្ស័យ ហេតុអ្វីក៏ស្រែក ។*

ប្រេតបានស្ដាប់ដូច្នោះហើយ ទើបបង្ហាញខ្លួនដោយគាថាថា :

*បពិត្រលោកដ៏ចម្រើន ខ្ញុំជាប្រេតទុគ៌ត កើតក្នុងយមលោក បានធ្វើបាបកម្ម ទៅពីមនុស្សលោកនេះ ទៅកាន់បេតលោក ។*

លំដាប់នោះ ព្រះថេរៈទើបសួរនូវកម្មដែលប្រេតនោះបានធ្វើ ដោយគាថាថា :

*អំពើអាក្រក់ដូចម្ដេច ដែលប្រេតឯងធ្វើហើយ ដោយកាយ វាចា ចិត្ត អ្នកឯងបានទទួលទុក្ខលំបាកនេះព្រោះផលបាបកម្ម ដូចម្ដេច ។*

ប្រេតនោះ បានប្រាប់នូវកម្មដែលខ្លួនធ្វើដោយគាថា ២ គាថា

ថា :

*លោកជាចៅអាវាសរបស់ខ្ញុំ ជាអ្នកប្ញស្យា ជាអ្នកកំណាញ់-ត្រកូល ស្ថិតស្ងាញ ជេរប្រទេច នៅអាស្រ័យក្នុងផ្ទះរបស់ខ្ញុំ ។ លុះខ្ញុំឮពាក្យលោកចៅអាវាសនោះហើយ ក៏ជេរប្រទេចភិក្ខុទាំងឡាយ ព្រោះហេតុតែផលកម្មនៃការជេរនោះ បានជាខ្ញុំស្លាប់ពីលោកនេះទៅ ទៅកើតជាប្រេត ។*

បណ្ដាបទទាំងនោះ បទថា **អហុ អាវាសិកោ មយ្ហំ** បានដល់ភិក្ខុមួយរូប ដែលជាចៅអាវាស បាននៅជាប្រចាំក្នុងអាវាសរបស់ខ្ញុំ គឺក្នុងវត្តដែលខ្ញុំបានសាងទុក ។ បទថា **អជ្ឈាសិតោ មយ្ហំ ឃរេ** សេចក្ដីថា លោកបាននូវអាស្រ័យក្នុងផ្ទះរបស់ខ្ញុំ ដោយភាពជាជីតុន ដោយអំណាចការនៅដោយតណ្ហា ។

បទថា **តស្ស** បានដល់ ភិក្ខុដែលជាជីតុននោះ ។ បទថា **ភិក្ខវោ** ប្រែថា នៅភិក្ខុទាំងឡាយ ។ បទថា **បរិភាសិស្សំ** ប្រែថា ជេរប្រទេចហើយ ។ បទថា **បេតលោកំ ឥតោ គតោ** សេចក្ដីថា ចូលដល់កំណើតប្រេត គឺកើតជាប្រេតដោយអាការយ៉ាងនេះ ។

ព្រះថេរៈបានស្ដាប់ដូច្នោះហើយ កាលនឹងសួរដល់គតិរបស់ប្រេតក្រៅនេះ ទើបពោលនូវគាថាថា :

*ភិក្ខុដែលមិនមែនជាមិត្តចូលទៅរកត្រកូលរបស់អ្នក ដោយ-*

*តាំងភេទខ្លួនថាជាមិត្រ ភិក្ខុអ្នកអប្បឥតប្រាជ្ញា លុះបែកធ្លាយរាងកាយស្លាប់ទៅ តើទៅកាន់គតិដូចម្តេច ក្នុងលោកខាងមុខ ។*

បណ្តាបទទាំងនោះ បទថា **មិត្តប្បតិរូបកេន** បានដល់ ដោយមិត្តប្លម គឺដោយភាពមិនមែនជាមិត្ត ។

ប្រេតកាលនឹងប្រាប់នូវរឿងនោះ ដល់ព្រះថេរៈទៀត ទើបពោលនូវគាថា ២ គាថាថា :

*ខ្ញុំឋិតនៅលើទីបំផុតនៃក្បាល នៃភិក្ខុអ្នកមានបាបកម្មនោះ ឯភិក្ខុអ្នកមានបាបកម្មនោះ ទៅកើតជាប្រេត ជាបរិវាររបស់ខ្ញុំ ( នេះឯង ) ។ បពិត្រលោកដ៏ចម្រើន ពួកជនឯទៀត បន្ទោបង់នូវឧច្ចារៈណា ឧច្ចារៈនោះឯងទៅជាភោជនរបស់ខ្ញុំ ( រាល់ ៧ ថ្ងៃ ) ខ្ញុំបន្ទោបង់ឧច្ចារៈណា ភិក្ខុចៅអាវាសនោះ ចិញ្ចឹមជីវិតនឹងឧច្ចារៈនោះ ( រាល់ ៧ ថ្ងៃ ) ។*

បណ្តាបទទាំងនោះ បទថា **តស្សេវ** បានដល់ ប្រេតភិក្ខុដែលជាជីតុន ក្នុងកាលមុន របស់ខ្ញុំនោះឯង ។ បទថា **បាបកម្មស្ស** បានដល់ មានសេចក្តីប្រព្រឹត្តលាមក ។ បទថា **សីសេ តិដ្ឋាមិ មត្ថកេ** សេចក្តីថា ខ្ញុំស្ថិតនៅលើក្បាល ហើយកាលដែលស្ថិតនៅលើក្បាលនោះឯង, អធិប្បាយថា មិនបានស្ថិតនៅលើអាកាសប្រមាណប៉ុនក្បាលឡើយ ។ បទថា **បរវិស័យំ បត្តោ** បានដល់ អាស្រ័យមនុស្ស-

លោកហើយចូលដល់បេតវិស័យដែលជាដែនដទៃ ។ បទថា **មមេទ** សេចក្តីថា បាលីដ៏សេស បណ្ឌិតគប្បីនាំមកភ្ជាប់ជាមួយនឹងពាក្យថា បានជាបរិវាររបស់ខ្ញុំ ។

បទថា **យំ ឥធន្តេ ហានន្តញ្ញោ** សេចក្តីថា បពិត្រព្រះមហា-មោគ្គល្លានដ៏ចម្រើន ពួកជនដទៃ រមែងបន្ទោបង់នូវឧច្ចារៈក្នុងរណ្តៅលាមក ( បង្គន់ ) នោះ ។ បទថា **ឯតំ មេ ហោតិ ភោជនំ** សេចក្តីថា ឧច្ចារៈនោះជាអាហាររបស់ខ្ញុំរាល់ ៧ ថ្ងៃ ។ បទថា **យំ ហនាមិ** សេចក្តីថា ក៏ខ្ញុំបន្ទោបង់នូវឧច្ចារៈដែលខ្ញុំស៊ីចូលទៅ ។ បទថា **ឯតំ សោ ឧបជីវតិ** សេចក្តីថា ប្រេតដែលជាជីតុននោះចិញ្ចឹមជីវិត គឺញ៉ាំងអត្តភាពឱ្យប្រព្រឹត្តទៅ ដោយការស៊ីនូវឧច្ចារៈរបស់ខ្ញុំនោះ រាល់ ៧ ថ្ងៃ ។

ក្នុងបណ្តាជនទាំងនោះ កុដុម្ពិកៈ ជេរប្រទេចភិក្ខុអ្នកមានសីលដែលជាទីស្រឡាញ់ថា ការស៊ីលាមក របស់ពួកលោក ប្រសើរជាងការបរិភោគអាហារយ៉ាងនេះ ។ ចំណែកភិក្ខុដែលជាជីតុន ណែនាំកុដុម្ពិកៈក្នុងការនិយាយដូច្នោះ ខ្លួនឯងក៏បានជេរប្រទេចដូច្នោះដែរ, ព្រោះហេតុនោះ ប្រេតនោះទើបមានការចិញ្ចឹមជីវិត ដែលគួរឱ្យតិះដៀលជាងកុដុម្ពិកៈនោះ ។ ព្រះមហាមោគ្គល្លាន ក្រាបទូលនូវ-រឿងនោះចំពោះព្រះដ៏មានព្រះភាគ ព្រះដ៏មានព្រះភាគ ទ្រង់ប្រារព្ធ-

នូវរឿងនោះឱ្យជាអត្ថុប្បត្តិហេតុ ហើយទ្រង់សម្ដែងនូវទោសនៃការតិះដៀលហើយ ទ្រង់សម្ដែងធម៌ដល់បរិស័ទដែលមកជួបជុំគ្នាហើយ។ ព្រះធម៌ទេសនានោះ បានជាប្រយោជន៍ដល់មហាជនដោយប្រការដូច្នេះ ។

## ( ចប់រឿងគូថខាទកប្រេតទី ៨ )

**មធុវា មញ្ញតី ពាលោ យាវ បាបំ ន បច្ចតិ**
**យទា ច បច្ចតី បាបំ អថ [ពាលោ] ទុក្ខំ និគច្ឆតិ ។**

បាបមិនទាន់ឱ្យផលត្រឹមណា ជនពាល តែងសំគាល់នូវបាបនោះថាដូចទឹកឃ្មុំ លុះតែកាលណាបាបឱ្យផល ជនពាលទើបប្រទះនូវ-សេចក្ដីទុក្ខ ក្នុងកាលណោះ ។

( បិដកលេខ ៥២, ទំព័រ ៣៥ )

# ៩-រឿងគូថខានកប្រេត

( បិដកលេខ ៥៦, ទំព័រ ១២៦ និងអដ្ឋកថា )

*( ព្រះមោគ្គល្លានបានឃើញស្រីប្រេតហើយសួរថា )*

*នាងឯងដែលអាត្មាឃើញហើយ តើជាអ្វី ដើរអំពីរណ្ដៅអាចម៍ ហើយឋិតនៅ នាងឯងមានបាបកម្មឥតមានសង្ស័យ ហេតុអ្វីចេះតែស្រែក ។*

***( នាងប្រេតនោះតបថា )***

*បពិត្រលោកដ៏ចម្រើន ខ្ញុំជាស្រីប្រេតជាអ្នកទុគ៌ត កើតក្នុងយមលោក បានធ្វើបាបកម្ម ហើយច្យុតចាកមនុស្សលោកនេះ ទៅកាន់បេតលោក ។*

*( ព្រះមោគ្គល្លានសួរថា )*

*អំពើអាក្រក់ដូចម្ដេច ដែលនាងធ្វើហើយដោយកាយ វាចា ចិត្ត បានជានាងវងទុក្ខនេះ ព្រោះផលកម្មអ្វី ។*

***( ស្រីប្រេតតបថា )***

*លោកចៅអាវាសរបស់ខ្ញុំ ជាអ្នកប្រស្សា កំណាញ់ត្រកូល ស្វិតស្វាញ ជេរប្រទេច អាស្រ័យនៅក្នុងផ្ទះរបស់ខ្ញុំ ។ លុះខ្ញុំឮពាក្យ*

*លោកចៅអាវាសនោះហើយ កំជេរប្រទេចភិក្ខុទាំងឡាយ ព្រោះហេតុតែផលកម្ម នៃការជេរនោះ បានជាខ្ញុំស្លាប់ពីលោកនេះទៅកាន់បេតលោក ។*

*( ព្រះមោគ្គល្លានសួរថា )*

*ចុះភិក្ខុដែលមិនមែនជាមិត្តអ្នកចូលទៅកាន់ត្រកូលរបស់នាង , ដោយភេទថាដូចជាមិត្ត ភិក្ខុអ្នកអប្បឥតប្រាជ្ញានោះ លុះបែកធ្លាយរាងកាយស្លាប់ទៅ តើទៅកាន់គតិដូចម្តេច ក្នុងបរលោក ។*

***( ស្រីប្រេតតបថា )***

*ខ្ញុំឋិតនៅលើទីបំផុតនៃក្បាល របស់ភិក្ខុអ្នកមានបាបកម្មនោះទៅកើតជាប្រេត ហើយជាបរិវាររបស់ខ្ញុំ ។ បពិត្រលោកដ៏ចម្រើន ពួកជនឯទៀត ៗ បន្ទោបង់នូវឧច្ចារៈណា ឧច្ចារៈនោះឯង ទៅជាភោជនរបស់ខ្ញុំ ( រាល់ ៗ ថ្ងៃ ) ខ្ញុំបន្ទោបង់នូវឧច្ចារៈណា ភិក្ខុចៅ-អាវាសនោះ ចិញ្ចឹមជីវិតនឹងឧច្ចារៈនោះ ( រាល់ ៗ ថ្ងៃ ) ។*

## ( សេចក្តីពន្យល់នៃអដ្ឋកថា )

កាលព្រះសាស្តា គង់ប្រថាប់នៅក្នុងវត្តជេតពនមហាវិហារ ទ្រង់ប្រារព្ធនាងប្រេតដែលស៊ីលាមកម្នាក់ ទើបត្រាស់នូវព្រះធម្ម-ទេសនានេះ មានពាក្យផ្តើមថា **គូថកូបតោ ឧគ្គន្ត្វា** ដូច្នេះ ។

រឿងរបស់នាងប្រេតនោះ ដូចគ្នានឹងរឿងដែលជាប់គ្នានោះ ។ ក្នុងរឿងនោះ មកដោយអំណាចឧបាសកថា ឧបាសកបានសាងវិហារ តែក្នុងរឿងនេះ មានសេចក្តីប្លែកគ្នាប៉ុណ្ណេះថា ឧបាសិកាបានសាងវិហារ ។ ពាក្យដ៏សេស ក្នុងផ្ទៃរឿងនិងក្នុងគាថា មិនខុសគ្នា ។

## ( ចប់រឿងគូថខាទកប្រេតទី ៩ )

**យាវជីវម្បិ ចេ ពាលោ  បណ្ឌិតំ បយិរុបាសតិ**
**ន សោ ធម្មំ វិជានាតិ  ទព្វី សូបរសំ យថា ។**

មនុស្សពាល បើចូលទៅអង្គុយជិតអ្នកប្រាជ្ញ សូម្បីអស់មួយជីវិតក៏ឥតមានដឹងរសធម៌អ្វី ឱ្យច្បាស់លាស់ឡើយ ដូចវែក ដែលមិនដឹងរសសម្ល ។

( បិដកលេខ ៥២, ទំព័រ ៣៥ )

# ១០-រឿងគណប្រេត

" ប្រេតស្រេកទឹកឃើញហើយផឹកមិនកើត "

( បិដកលេខ ៥៦, ទំព័រ ១២៧ និងអដ្ឋកថា )

កាលព្រះសាស្ដា គង់ប្រថាប់នៅក្នុងវត្តជេតពនមហាវិហារ ទ្រង់ប្រារព្ធប្រេតជាច្រើន ទើបបានត្រាស់នូវព្រះគាថានេះ មានពាក្យផ្ដើមថា **នគ្គា ទុព្វណ្ណរូបាថ** ដូច្នេះ ។

បានឮថា ក្នុងក្រុងសាវត្ថី មនុស្សជាច្រើន ជាគណៈ មិនមានសទ្ធា មិនមានសេចក្ដីជ្រះថ្លា មានចិត្តត្រូវមន្ទិល គឺសេចក្ដីកំណាញ់រួបរឹត ជាអ្នកមានមុខងាកចេញពីសុចរិត មានទានជាដើម មានជីវិតរស់នៅយូរ បន្ទាប់ពីបែកធ្លាយរាងកាយស្លាប់ទៅ ក៏បានទៅកើតក្នុងកំណើតប្រេត ជិតព្រះនគរ ។ ក្រោយមកថ្ងៃមួយ ព្រះមហា-មោគ្គល្លាន កំពុងនិមន្តបិណ្ឌបាតក្នុងក្រុងសាវត្ថី ក៏បានឃើញពួកប្រេតក្នុងចន្លោះផ្លូវ ទើបសួរដោយគាថាថា :

*នែអ្នករាល់គ្នា អ្នកទាំងឡាយ មានកាយអាក្រាត មានសរីរៈមានសម្បុរមិនស្អាត ស្គមរវាមដោយសរសៃ មានឆ្អឹងជម្នីរ រគាមម្ល៉េះ តើអ្នកទាំងឡាយ ជាអ្វី ។*

បណ្ដាបទទាំងនោះ បទថា **ទុព្វណ្ណរូបាថ** សេចក្ដីថា អ្នកជាបុគ្គលមានរាងកាយមានសម្បុរអាក្រក់ក្រៃពេក ។ បទថា **កេ នុ តុម្ហេថ** សេចក្ដីថា ពួកអ្នកជានរណាហ្ន៎ ។ ព្រះមហាមោគ្គលានហៅប្រេតទាំងនោះ ដោយសមគួរដល់ខ្លួនថា **មារិសា** ។

ប្រេតបានស្ដាប់ដូច្នោះហើយ ទើបនាំគ្នាប្រកាសនូវភាពដែលខ្លួនជាប្រេត ដោយគាថាថា :

*បពិត្រលោកដ៏ចម្រើន យើងខ្ញុំជាប្រេតទុគ៌ត កើតក្នុងយមលោក ព្រោះតែធ្វើបាបកម្ម ។*

ត្រូវព្រះថេរៈសួរដល់កម្មដែលគេបានធ្វើទុកទៀត ដោយគាថាថា :

*ចុះអ្នករាល់គ្នា បានធ្វើអំពើអាក្រក់ ដូចម្ដេច ដោយកាយ វាចា ចិត្ត លះលោកនេះ ទៅកាន់បេតលោក ព្រោះផលកម្មអ្វី ។*

ទើបបានពោលនូវកម្មដែលខ្លួនធ្វើដោយគាថាថា :

*ពួកយើងបានរើសទ្រព្យកន្លះមាសកៈ នៅនាកំពង់ទឹកដែលឥតទោស ( គ្មានម្ចាស់ថែរក្សា ) នាកាលទេយ្យធម៌ទាំងឡាយមានពួកយើងមិនបានធ្វើទីពឹងដល់ខ្លួន ។ ពួកយើងជាបុគ្គលស្រេកទឹក នាំគ្នាចូលទៅរកស្ទឹង ទើបឯស្ទឹងនោះក៏ខ្វែប្រែទៅជាស្ទឹងទទេ ក្នុងកាលក្ដៅ ពួកយើងនាំគ្នាចូលទៅរកម្លប់ ម្លប់នោះក៏ខ្វែប្រែទៅជាកំដៅ*

ដ៏ក្តៅវិញ ។ ខ្យល់មានសណ្ឋានដូចជាភ្លើងដ៏ក្តៅ បក់មករកពួកយើង បពិត្រលោកដ៏ចម្រើន ពួកយើងទទួលនូវបាបកម្មនោះផង ទទួលនូវ-បាបកម្មដទៃពីនោះផង ។

ទុកជាពួកយើង ដើរទៅកាន់យោជន៍ទាំងឡាយ ជាបុគ្គលឃ្លាន ចង់ស៊ីអាហារក៏រកទទួលទានមិនបាន ហើយក៏ត្រឡប់វិលវិញ ដោយគិតថា ឱហ្ន៎ ពួកយើងជាបុគ្គលឥតបុណ្យទេតើ ។ បពិត្រលោកដ៏ចម្រើន ពួកយើងជាបុគ្គលឃ្លានជ្រុលជ្រប់ ដួលដេកលើផែនដីបម្រះនឿយលផ្ការផ្កាប់ លើផែនដី ។ លុះពួកយើងដួលនៅក្នុងទីនោះហើយ ក៏ក្រោកឡើង ដួលប្រួសទៅលើផែនដីនោះវិញ ទើបទង្គិចដើមទ្រូងផង ទង្គិចក្បាលផង ឱហ្ន៎ ពួកយើងជាបុគ្គលឥតបុណ្យទេតើ ។ បពិត្រលោកដ៏ចម្រើន ពួកយើងគួរទទួល នូវបាបកម្មនោះផង ទទួលនូវបាបកម្មដទៃពីនោះផង នាកាលទេយ្យធម៌ទាំងឡាយមាន ពួកយើងមិនបានធ្វើនូវទីពឹងដល់ខ្លួនសោះ ។ បើដូច្នោះពួកយើង លុះរដោះចាកប្រេតនេះទៅ សូមបានកើតជាមនុស្ស ជាអ្នក-បរិបូណ៌ដោយសីល ធ្វើកុសលឱ្យបានច្រើន អំពីដឹងក្តីទៅ ។

បណ្តាបទទាំងនោះ បទថា **អបិ យោជនានិ គច្ឆាម** សេចក្តីថា ពួកយើងទៅបានច្រើនយោជន៍, ព្រោះហេតុអ្វី ? គឺព្រោះជាអ្នកឃ្លានចង់បរិភោគអាហារ , អធិប្បាយថា ពួកយើងត្រូវសេចក្តី-

ឃ្លានគ្របសង្កត់ជាយូរមកហើយ ចង់បរិភោគ គឺចង់លិទ្ធភក្សអាហារ សូម្បីកាលទៅយ៉ាងនេះ មិនបានអាហារអ្វីមួយឡើយ ក៏នាំគ្នាត្រឡប់មកវិញ ។ បទថា **អប្បបុញ្ញតា** បានដល់ ពួកយើង មិនមានបុណ្យ គឺមិនបានធ្វើអំពើល្អទុក ។

បទថា **ខុត្តានា បតិកិរាម** សេចក្ដីថា ជួនកាលជាអ្នកដេកផ្ងារ ប្រព្រឹត្តទៅដូចជាអវយវៈតូចធំ ខ្វាត់ខ្វាយទៅ ។ បទថា **អវកុជ្ជា បតាមសេ** សេចក្ដីថា ជួនកាលក៏ដេកផ្កាប់ដួលចុះទៅ ។

បទថា **តេ ច** បានដល់ ពួកយើងនោះ ។ បទថា **ខុរំ សីលញ្ឆយន្តេម** សេចក្ដីថា ដេកផ្កាប់ដួលចុះទៅ កាលមិនអាចនឹងក្រោកឡើងបាន ក៏ញាប់ញ័រសោយនូវវេទនា យកដើមទ្រូងនិងក្បាលទង្គិចគ្នា ។ ពាក្យដ៏សេសមានន័យដូចពោលរួចមកហើយក្នុងខាងដើមនោះឯង ។

ព្រះថេរៈក្រាបទូលនូវរឿងនោះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះដ៏មានព្រះភាគ ទ្រង់ធ្វើនូវរឿងនោះឱ្យជាអត្ថុប្បត្តិហេតុ ទ្រង់-សម្ដែងធម៌ដល់បរិស័ទដែលមកប្រជុំគ្នាហើយ ។ មហាជនស្ដាប់ធម៌នោះ ក៏បានលះបង់នូវមន្ទិល គឺសេចក្ដីកំណាញ់ ជាអ្នកត្រេកអរក្នុងសុចរិត មានទានជាដើម ដោយប្រការដូច្នេះ ។

**( ចប់រឿងគណប្រេតទី ១០ )**

# ១១-រឿងបាដលិបុត្តប្រេត

( បិដកលេខ ៥៦, ទំព័រ ១២៩ និងអដ្ឋកថា )

កាលព្រះសាស្តា ទ្រង់គង់ប្រថាប់នៅក្នុងវត្តជេតពនមហា-វិហារ ទ្រង់ប្រារព្ធវេមានិកប្រេតម្នាក់ ទើបត្រាស់នូវគាថានេះ មានពាក្យផ្តើមថា **ទិដ្ឋា តយា និរយា តិរច្ឆានយោនី** ដូច្នេះ ។

បានឮថា ពាណិជអ្នក**ក្រុងសាវត្ថី** និងអ្នក**ក្រុងបាតលីបុត្ត**ជា-ច្រើន ឡើងសំពៅទៅកាន់**សុវណ្ណភូមិ** ។ ក្នុងបណ្តាពាណិជទាំងនោះ ពាណិជម្នាក់ជា**ឧបាសក** ក៏បានកើតនូវជម្ងឺ មានចិត្តប្រតិព័ទ្ធចំពោះ**មាតុគ្រាម** ហើយក៏បានធ្វើកាលកិរិយាទៅ ។ សូម្បីគេបានធ្វើកុសលទុកហើយក៏ដោយ ក៏មិនបានទៅកាន់ទេវលោកឡើយ គេបានកើតជាវេមានិកប្រេតក្នុងកណ្តាលមហាសមុទ្រ ព្រោះជាអ្នកមានចិត្តប្រតិព័ទ្ធចំពោះស្ត្រី ។ ក៏ស្ត្រីដែលគេមានចិត្តប្រតិព័ទ្ធនោះ បានឡើងសំពៅទៅកាន់សុវណ្ណភូមិ ។ លំដាប់នោះ ប្រេតនោះ មានបំណងនឹងចាប់នូវស្ត្រីនោះ ទើបធ្វើឱ្យសំពៅគៀង ។ លំដាប់នោះ ពាណិជទាំងឡាយប្រឹក្សាគ្នាថា ព្រោះហេតុអ្វីហ្ន៎ សំពៅនេះទើបគៀងដូច្នេះ ទើបឱ្យចាប់ស្លាកមនុស្សកាឡកិណី ស្លាកបានធ្លាក់ទៅលើស្ត្រីនោះឯង

ដល់ទៅ ៣ ដង ដោយឫទ្ធិរបស់អមនុស្ស ។ ពួកពាណិជឃើញស្ត្រីដែលគេមានចិត្តប្រតិព័ទ្ធនោះហើយ ទើបឱ្យទម្លាក់ក្បូនឫស្សីក្នុង-សមុទ្រ ឱ្យស្ត្រីនោះចុះទៅនៅលើក្បូនឫស្សីនោះ ។ លុះស្ត្រីនោះចុះទៅហើយ សំពៅក៏ឈប់កៀងមានមុខឆ្ពោះទៅកាន់សុវណ្ណភូមិយ៉ាងលឿនរហ័ស ។ អមនុស្សបានលើកស្ត្រីនោះឡើងកាន់វិមានរបស់ខ្លួន រួចហើយក៏បានអភិរម្យជាមួយនឹងស្ត្រីនោះ ។

លុះកន្លងទៅបាន ១ ឆ្នាំ ស្ត្រីនោះក៏កើតនូវសេចក្តីធុញទ្រាន់កាលនឹងសួមអង្វរប្រេតនោះ ទើបពោលថា ខ្ញុំនៅក្នុងទីនេះមិនបានដើម្បីនឹងសាងនូវប្រយោជន៍ក្នុងសម្បរាយភពឡើយ បពិត្រអ្នកនិរទុក្ខសូមអ្នកនាំខ្ញុំទៅកាន់ក្រុងបាតលីបុត្តវិញទៅ ។ ប្រេតនោះ ត្រូវស្ត្រីនោះអង្វរហើយ ទើបពោលនូវគាថាថា :

*ពួកសត្វនរកក្តី ពួកកំណើតតិរច្ឆានក្តី ពួកប្រេតក្តី ពួកមនុស្សនិងទេព្តាក្តី នាងបានឃើញឬទេ នាងបានឃើញផលកម្ម ដែលខ្លួនបានធ្វើហើយដោយខ្លួនឯងដែរឬទេ ខ្ញុំនឹងនាំនាងទៅបាដលិបុត្តមិនមានអ្នកចោមព័ទ្ធបាន បើនាងទៅដល់បាដលិបុត្តនោះ ហើយចូរធ្វើកុសលកម្មចុះ ។*

បណ្តាបទទាំងនោះ បទថា **ទិដ្ឋា តយា និរយា** បានដល់សូម្បីចំពោះសត្វនរកពួកខ្លះ នាងក៏បានឃើញហើយ ។ បទថា

**តិរច្ឆានយោនី** មានសេចក្តីថា សូម្បីសត្វតិរច្ឆាន មាននាគ និងគ្រុឌ ជាដើម ដែលមានអានុភាពច្រើន នាងក៏បានឃើញហើយ ។

បទថា **បេតា** បានដល់ ប្រេតដែលមានសេចក្តីស្រេកឃ្លាន ជាដើម ។ បទថា **អសុរា** បានដល់ **អសុរៈ** មាន**កាលកញ្ជិកាសុរៈ** ជាដើម ។ បទថា **ទេវា** បានដល់ ទេវតាជាន់ចាតុម្មហារាជិកាពួកខ្លះ ។ បានឮថា ប្រេតនោះ នាំស្ត្រីនោះ ត្រាច់មើល**បច្ចេកនរក** ជាដើម ក្នុងចន្លោះ ៧ ដោយអានុភាពរបស់ខ្លួន ព្រោះហេតុនោះ លោកទើបពោលយ៉ាងនេះ ។ បទថា **សយមទ្ទស កម្មវិបាកមត្តនោ** សេចក្តីថា ស្ត្រីនោះ ទៅឃើញសត្វនរកជាដើម ដោយផ្ទាល់ ក៏បានឃើញប្រចក្សនូវវិបាករបស់កម្មដែលខ្លួនបានធ្វើទុកហើយ ដោយខ្លួនឯង ។ បទថា **នេស្សាមិ តំ បាដលិបុត្តមក្ខតំ** សេចក្តីថា ឥឡូវនេះ ខ្ញុំនឹងនាំនាងដែលគ្មាននរណាអាចរារាំងបាន ទៅកាន់ក្រុងបាតលីបុត្ត ដោយអត្តភាពជារបស់មនុស្សនោះឯង ។ ប៉ុន្តែនាង លុះទៅដល់ក្រុងបាតលីបុត្តហើយ ចូរធ្វើកុសលកម្មឱ្យច្រើន, អធិប្បាយថា នាងចូរជាអ្នកប្រកបនូវសេចក្តីខ្វល់ខ្វាយត្រេកអរក្នុងបុណ្យ ព្រោះនាងឃើញ នូវវិបាករបស់កម្មដោយប្រចក្សហើយ ។

លំដាប់នោះ ស្ត្រីនោះ លុះបានស្តាប់នូវពាក្យប្រេតនោះហើយ មានសេចក្តីត្រេកអរ ទើបពោលនូវគាថាថា :

*នាងនោះតបថា បពិត្រយក្ស អ្នកជាបុគ្គលប្រាថ្នាប្រយោជន៍ឱ្យខ្ញុំ បពិត្រទេវតា អ្នកជាបុគ្គលប្រាថ្នា សេចក្ដីចម្រើនឱ្យខ្ញុំ ខ្ញុំនឹងធ្វើតាមសំដីរបស់អ្នក អ្នកជាអាចារ្យរបស់ខ្ញុំ ។ ពួកសត្វនរកក្ដី ពួកកំណើតតិរច្ឆានក្ដី ពួកប្រេតក្ដី ពួកអសុរក្ដី ពួកមនុស្សនិងទេព្ដាក្ដី ខ្ញុំបានឃើញហើយ ខ្ញុំបានឃើញផលកម្មរបស់ខ្លួនដោយខ្លួនឯង ខ្ញុំនឹងធ្វើបុណ្យទាំងឡាយឱ្យច្រើន ។*

លំដាប់នោះ ប្រេតនោះ ទើបនាំស្ដ្រីនោះទៅតាមអាកាស ក៏បានដាក់នាងចុះត្រង់កណ្ដាល**ក្រុងបាតលីបុត្ត** ហើយក៏បានចៀសចេញទៅ ។ លំដាប់នោះ ញាតិនិងមិត្តជាដើមរបស់ស្ដ្រីនោះ ឃើញស្ដ្រីនោះហើយ ក៏មានចិត្តត្រេកអរក្រៃលែងថា កាលពីមុនពួកយើងបានឮមកថា នាងត្រូវគេបោះចូលទៅក្នុងមហាសមុទ្រស្លាប់បាត់ទៅហើយ នាងនោះ គឺស្ដ្រីនេះឯង ។ ពួកយើងឃើញហើយហ្ន៎ មកដោយសួស្ដី ហើយក៏បានមកប្រជុំគ្នា សួរអំពីប្រវត្តិរបស់នាង ។ ចាប់តាំងពីនោះមក នាងក៏បានប្រាប់នូវរឿងរ៉ាវនោះទាំងអស់ ដែលខ្លួនបានឃើញ និងដែលខ្លួនបានសោយមក ដល់ពួកញាតិនិងមិត្តជាដើមនោះ ។ ពាណិជអ្នកក្រុងសាវត្ថីទាំងនោះ ចូលទៅគាល់ព្រះសាស្ដាក្នុងវេលាដែលបានមកដល់ក្រុងសាវត្ថីវិញ ដោយលំដាប់ ថ្វាយបង្គំហើយ អង្គុយក្នុងទីដ៏សមគួរ ក៏បានក្រាបទូលនូវរឿងនោះ ចំពោះ-

ព្រះដ៏មានព្រះភាគ ព្រះដ៏មានព្រះភាគ ទ្រង់ធ្វើនូវរឿងនោះឱ្យជា-អត្ថុប្បត្តិហេតុ ទើបសម្តែងធម៌ដល់បរិស័ទទាំង ៤ មហាជនបានស្តាប់នូវធម៌នោះហើយ ក៏បានកើតនូវសេចក្តីសង្វេគ ត្រេកអរក្នុង-កុសលធម៌ មានទានជាដើម ដោយប្រការ ដូច្នេះ ។

## ( ចប់រឿងបាដលិបុត្តប្រេតទី ១១ )

**បមាទមនុយុញ្ជន្តិ ពាលា ទុម្មេធិនោ ជនា**
**អប្បមាទញ្ច មេធាវី ធនំ សេដ្ឋំវ រក្ខតិ ។**

-ពួកជនពាលអប្បឥតប្រាជ្ញា តែងប្រកបរឿយ ៗ នូវសេចក្តី-ប្រមាទ ចំណែកអ្នកប្រាជ្ញ រមែងរក្សាទុកនូវសេចក្តីមិនប្រមាទដូចទ្រព្យយ៉ាងប្រសើរ ។ ( បិដកលេខ ៥២, ទំព័រ ២៦ )

**មា បមាទមនុយុញ្ជេថ មា កាមរតិសន្ថវំ**
**អប្បមត្តោ ហិ ឈាយន្តោ បប្បោតិ វិបុលំ សុខំ ។**

-អ្នកទាំងឡាយ ចូរកុំប្រកបរឿយ ៗ នូវសេចក្តីប្រមាទ ចូរកុំប្រកបរឿយ ៗ នូវសេចក្តីរីករាយ ត្រេកអរក្នុងកាមឡើយ ដ្បិតបុគ្គលអ្នកមិនប្រមាទ ខំសង្កេតពិនិត្យ រមែងបានសេចក្តីសុខដ៏ទូលាយ ។

# ១២- រឿងអម្ពវនប្រេត

" ប្រេតផ្ញើទ្រព្យទៅឱ្យកូនសងបំណុលគេ "

( បិដកលេខ ៥៦, ទំព័រ ១៣០ និងអដ្ឋកថា )

កាលព្រះសាស្តា ទ្រង់គង់ប្រថាប់នៅក្នុងក្រុងសាវត្ថី ទ្រង់-ប្រារព្ធអម្ពវនប្រេត ទើបត្រាស់នូវព្រះគាថានេះ មានពាក្យផ្ដើមថា **អយញ្ច តេ បោក្ខរណី សុរម្មា** ដូច្នេះ ។

បានឮថា ក្នុងក្រុងសាវត្ថី មាន**គហបតីម្នាក់** ជាអ្នកវិនាសចាកភោគសម្បត្តិ ។ **ភរិយា**របស់គាត់ក៏ស្លាប់ មាន**ធីតា**តែម្នាក់ប៉ុណ្ណោះ ។ គាត់បានឱ្យធីតានោះ ទៅនៅផ្ទះសម្លាញ់របស់ខ្លួន បានយកប្រាក់ដែលខ្ចីគេមក ១០០ កហាបណៈ ទៅទិញទំនិញ ផ្ទុកក្នុងរទេះទៅធ្វើជំនួញ មិនយូរប៉ុន្មានក៏បានប្រាក់ ៥០០ កហាបណៈ ដែលជាកម្រៃព្រមទាំងដើមទុន ហើយក៏បានត្រឡប់មកវិញ មួយអន្លើដោយរទេះ ក្នុងចន្លោះផ្លូវពួកចោរបានស្ទាក់ប្លន់ពួកឈ្មួញរទេះ ។ ពួកឈ្មួញរទេះ ក៏បានបែកខ្ញែកគ្នារត់គេចអស់ទៅ ។ ចំណែកគហបតីនោះ លាក់កហាបណៈទុកត្រង់គុម្ពឈើមួយកន្លែងហើយ ក៏បានលាក់ខ្លួន នៅក្នុងទីមិនឆ្ងាយ ។ ពួកចោរក៏បានចាប់គហបតីនោះសម្លាប់ចោល ។ ព្រោះសេចក្ដីលោភ

ក្នុងទ្រព្យ គាត់ទើបកើតជាប្រេតក្នុងទីនោះ ។

ចំណែកពួកពាណិជទៅដល់ក្រុងសាវត្ថី ក៏បានប្រាប់នូវរឿងនោះ ឱ្យធីតារបស់គាត់ជ្រាប ធីតានោះក៏បានកើតនូវទោមនស្សយ៉ាងក្រៃលែង ខ្សឹកខ្សួលយ៉ាងខ្លាំង ព្រោះការស្លាប់របស់បិតា និងព្រោះភ័យនៃការចិញ្ចឹមជីវិត, លំដាប់នោះ កុដុម្ពិកៈដែលជាសម្លាញ់របស់បិតានោះ ទើបនិយាយលួងលោមនាងថា ធម្មតាភាជនៈដីទាំងអស់មានការបែកធ្លាយទៅជាទីបំផុត យ៉ាងណាមិញ ជីវិតរបស់សត្វទាំង-ឡាយ ក៏មានការបែកធ្លាយទៅក្នុងទីបំផុត ក៏យ៉ាងនោះដែរ ។ ធម្មតាសេចក្ដីស្លាប់រមែងមានទូទៅដល់សត្វទាំងពួង និងមិនមានការរារាំងបានឡើយ ព្រោះដូច្នោះ នាងកុំសោកសៅ កុំបរិទេវៈ ដល់បិតាពេកឡើយ យើងនឹងធ្វើជាបិតារបស់នាង នាងចូរជាធីតារបស់យើង យើងធ្វើតួនាទីជំនួសបិតារបស់នាង នាងកុំសោយសោកឡើយ ចូរ-ត្រេកអរនៅក្នុងផ្ទះនេះ ឱ្យដូចជាផ្ទះបិតារបស់នាងចុះ ។ នាងនោះក៏បន្ទោបង់នូវសេចក្ដីសោកបាន តាមពាក្យរបស់កុដុម្ពិកៈនោះ ហើយក៏មាននូវសេចក្ដីគោរព និងសេចក្ដីកោតក្រែងខ្លាំង ចំពោះកុដុម្ពិកៈនោះ ដូចជាបិតាបង្កើត នាងជាអ្នកមានប្រក្រតីធ្វើនូវការខ្វល់ខ្វាយប្រព្រឹត្តតាមកុដុម្ពិកៈនោះ ដោយភាវៈដែលខ្លួនជាមនុស្សកំព្រា ប្រាថ្នានឹងធ្វើនូវកិច្ចដើម្បីអ្នកស្លាប់ ឧទ្ទិសដល់បិតា ទើបដាំបបរហើយ ដាក់

ផ្លែស្វាយទុំមានរសឆ្ងាញ់ ដែលមានពណ៌ដូចជាពណ៌នៃមនោសិលា ក្នុងថាសសំរិត ឱ្យទាសីកាន់យកបបរ និងផ្លែស្វាយទៅ កាន់វិហារ ថ្វាយបង្គំព្រះសាស្តាហើយ ក៏បានក្រាបទូលយ៉ាងនេះថា បពិត្រព្រះ-ដ៏មានព្រះភាគ សូមព្រះអង្គធ្វើនូវសេចក្តីអនុគ្រោះ ទទួលទក្ខិណាទាន របស់ខ្ញុំម្ចាស់ ព្រះសាស្តា មានព្រះហឫទ័យដែលព្រះមហាករុណា ដាស់តឿនហើយ កាលទ្រង់នឹងធ្វើមនោរថរបស់នាងឱ្យពេញព្រៀប ទើបសម្តែងនូវអាការនឹងគង់ប្រថាប់ ។ នាងមានចិត្តត្រេកអររីករាយ ក៏បានក្រាលនូវសំពត់ដ៏បរិសុទ្ធស្អាត ដែលខ្លួនបង្អោនចូលទៅក្នុង ពុទ្ធាសនៈដ៏ប្រសើរ ដែលបានផ្ចិតផ្ចង់ចាត់ចែងទុកថ្វាយ ។ ព្រះដ៏-មានព្រះភាគ ទ្រង់គង់ប្រថាប់លើអាសនៈដែលគេក្រាលហើយ ។

លំដាប់នោះ ស្ត្រីនោះ ទើបបង្អោននូវបបរចូលទៅថ្វាយ-ព្រះដ៏មានព្រះភាគ ព្រះដ៏មានព្រះភាគ ទ្រង់ទទួលនូវបបរនោះហើយ បន្ទាប់មកនាងទើបប្រគេននូវបបរដល់ភិក្ខុទាំងឡាយ ឧទ្ទិសចំពោះ សង្ឃ ហើយលាងដៃ បន្ទាប់មកក៏បានបង្អោននូវផ្លែស្វាយចូលទៅ ថ្វាយព្រះដ៏មានព្រះភាគទៀត ។ ព្រះដ៏មានព្រះភាគ ទ្រង់ក៏បានសោយ នូវផ្លែស្វាយទាំងនោះ ។ នាងថ្វាយបង្គំព្រះដ៏មានព្រះភាគហើយ ក្រាបទូលយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ទក្ខិណាទានដែល ខ្ញុំម្ចាស់បានបំពេញហើយ ដោយការថ្វាយនូវកម្រាល បបរ និងផ្លែ-

ស្វាយនោះ សូមឱ្យបានសម្រេចដល់បិតារបស់ខ្ញុំម្ចាស់ចុះ ។ ព្រះដ៏-មានព្រះភាគត្រាស់ថា ចូរសម្រេចយ៉ាងនោះចុះ រួចហើយទ្រង់ក៏បានធ្វើនូវអនុមោទនា នាងថ្វាយបង្គំព្រះដ៏មានព្រះភាគហើយ ធ្វើប្រទក្សិណហើយក៏បានចៀសចេញទៅ ។ លុះនាងបានឧទ្ទិសនូវ-ចំណែកបុណ្យរួចហើយ ប្រេតនោះ ក៏ត្រឡប់បាននូវអម្ពវ័ន វិមាន, ដើមកប្បព្រឹក្ស និងស្រះបោក្ខរណី ព្រមទាំងទិព្វសម្បត្តិដ៏ច្រើនក្រៃលែង ។

លុះសម័យជាខាងក្រោយមក ពាណិជទាំងនោះ កាលនឹងទៅធ្វើជំនួញ ក៏បានធ្វើដំណើរទៅតាមផ្លូវនោះឯង បានស្នាក់នៅមួយយប់ ក្នុងទីដែលខ្លួនធ្លាប់បានស្នាក់នៅក្នុងកាលមុន ។ ប្រេត-នោះ ឃើញពាណិជទាំងនោះហើយ ទើបបង្ហាញខ្លួនដល់ពាណិជទាំងនោះ ព្រមទាំងឧទ្យាន និងវិមានជាដើម ។ ពាណិជទាំងនោះឃើញដូច្នោះហើយ កាលនឹងសួរដល់សម្បត្តិដែលប្រេតនោះបានមកទើបបានពោលនូវគាថា ២ គាថាថា :

*ស្រះបោក្ខរណីរបស់អ្នកនេះ ជាទីត្រេកអរដោយប្រពៃផង មានផ្ទៃដ៏ស្មើផង មានកំពង់ល្អផង មានទឹកច្រើនផង មានផ្កាវីកល្អផង មានហ្វូងកន្ទង់ហើរឡៀលឆ្វាត់ផង ស្រះបោក្ខ-រណី ជាទីពេញចិត្តនេះ អ្នកបានដោយហេតុដូចម្ដេច ។*

*មួយទៀត អម្ពវ័នរបស់អ្នកនេះ ជាទីត្រេកអរ ដោយប្រពៃផង កាន់ផ្លែគ្រប់រដូវផង មានផ្ការីកជានិច្ច មានហ្វូងកន្ទង់ច្រើន ចោមរោមផង តើវិមាននេះ អ្នកបានមកដោយហេតុអ្វី ។*

បណ្តាបទទាំងនោះ បទថា **សុរម្មា** ប្រែថា គួរឱ្យត្រេកអរក្រៃលែង ។ បទថា **សមា** ប្រែថា មានផ្ទៃរាបស្មើ ។ បទថា **សុប្បតិត្ថា** បានដល់ មានកំពង់ល្អ ព្រោះមានជណ្តើរដែលសម្រេចដោយកែវ ។ បទថា **មហោទកា** ប្រែថា មានទឹកច្រើន ។

បទថា **សព្វោតុកំ** បានដល់ នាំមកនូវសេចក្តីសុខគ្រប់រដូវកាល ដោយដើមឈើដេរដាសទៅដោយផ្កា និងផ្លែជាដើម ។ ព្រោះហេតុនោះ លោកទើបពោលថា រមែងកាន់ផ្លែដូច្នេះ ។ បទថា **សុបុប្ផិតំ** ប្រែថា រីករហង់ជានិច្ច ។

ប្រេតបានស្តាប់ដូច្នោះហើយ កាលនឹងប្រាប់ដល់ហេតុនៃការបានស្រះបោក្ខរណីជាដើម ទើបពោលនូវគាថាថា :

*ខ្ញុំបានស្រះបោក្ខរណីជាទីត្រេកអរ និងអម្ពវ័នវិមានជាទីត្រេក-អរនេះ ព្រោះតែធីតារបស់ខ្ញុំបានប្រគេនទឹក ស្វាយទុំនិងបបរ និងម្លប់ដ៏ត្រជាក់ ជាទីត្រេកអរ ក្នុងទីនេះ ។*

បណ្តាបទទាំងនោះ បទថា **តេន មេ ឥធ លព្ភតីតិ**

សេចក្តីថា ព្រោះទានដែលធីតារបស់ខ្ញុំថ្វាយនូវស្វាយទុំ ទឹក និងបបរ ចំពោះព្រះដ៏មានព្រះភាគ និងភិក្ខុសង្ឃ ឧទ្ទិសដល់ខ្ញុំ ស្វាយទុំដែលចេញផ្លែគ្រប់រដូវកាល ក៏បានសម្រេចជាទឹកទិព្វ ក្នុងស្រះបោក្ខរណីដែលជាទីពេញចិត្តដ៏ជាទិព្វនេះ ដោយការឱ្យនូវបបរ និងកម្រាលរមែងឱ្យសម្រេចជាស្រះបោក្ខរណី មានម្លប់ត្រជាក់ គួរឱ្យរីករាយចិត្តក្នុងសួន វិមាន និងដើមកប្បព្រឹក្ស ជាដើមក្នុងទីនេះ ។

ប្រេតនោះ លុះពោលយ៉ាងនេះហើយ ទើបនាំពាណិជទាំងនោះ ទៅមើលទ្រព្យ ៥០០ កហាបណៈនោះ ហើយពោលថាអ្នកចូរកាន់យកជាចំណែកខ្លួនពាក់កណ្តាលអំពីទ្រព្យនេះ ចូរឱ្យដល់ធីតារបស់ខ្ញុំ ឱ្យនាងសងបំណុល ដែលខ្ញុំបានខ្ចីគេមកពាក់កណ្តាលហើយចូររស់នៅជាសុខចុះ ។ ពាណិជទាំងនោះ បានត្រឡប់មកដល់ក្រុងសាវត្ថី ដោយលំដាប់ហើយ ទើបប្រាប់ដល់ធីតារបស់ប្រេតនោះ ហើយបានឱ្យនូវចំណែកដែលប្រេតនោះ បានឱ្យដល់ខ្លួនដល់នាងនោះឯង ។ នាងបានសងបំណុលចំនួន ១០០ កហាបណៈដល់ពួកម្ចាស់បំណុល ក្រៅពីនោះបានឱ្យដល់កុដុម្ពិកៈនោះ ដែលជា-សម្លាញ់របស់បិតាខ្លួន ចំណែកខ្លួនឯងធ្វើការខ្វល់ខ្វាយនៅអាស្រ័យ ។ កុដុម្ពិកៈនោះ បានឱ្យនូវទ្រព្យនោះដល់នាងវិញ ដោយនិយាយថាចូរជាទ្រព្យរបស់នាងទាំងអស់ចុះ ហើយបានផ្សំផ្គុំនាងជាមួយនឹងកូន

ប្រុសច្បងរបស់ខ្លួន ។

ក្រោយមក នាងបានបុត្រម្នាក់ កាលនឹងបំពេបុត្រ ទើបពោលនូវគាថាថា :

*ចូរអ្នកសម្លឹងមើលផលរបស់ទាន និងការទូន្មាននូវឥន្ទ្រិយ និងការសង្រួម ដែលឃើញច្បាស់ ដោយខ្លួនឯង ខ្ញុំ ( ពីដើម ) ជាទាសី ឥឡូវបានជាកូនប្រសាស្រីក្នុង-ត្រកូលរបស់លោក នឹងជាធំត្រួតត្រាផ្ទះ របស់លោក ។*

ក្រោយមកថ្ងៃមួយ ព្រះសាស្តា ទ្រង់ប្រមើលមើលឃើញថា នាងមានញាណចាស់ក្លាហើយ ទើបទ្រង់ផ្សាយព្រះរស្មីទៅបង្ហាញព្រះអង្គឱ្យប្រាកដ ហាក់ដូចជាទ្រង់ប្រថាប់ក្នុងទីចំពោះមុខ ហើយបានត្រាស់នូវគាថានេះ មានសេចក្តីថា :

**អសាតំ សាតរូបេន បិយរូបេន អប្បិយំ**
**ទុក្ខំ សុខស្ស រូបេន បមត្តំ អតិវត្តតីតិ ។**

*របស់ដែលមិនត្រេកអរ រមែងប្រព្រឹត្តកន្លងបុគ្គលអ្នកប្រមាទដោយសភាពនៃរបស់ជាទីត្រេកអរ របស់ដែលមិនស្រឡាញ់ រមែង-ប្រព្រឹត្តកន្លងបុគ្គលអ្នកប្រមាទដោយសភាពនៃរបស់ជាទីស្រឡាញ់ ទុក្ខតែងប្រព្រឹត្តកន្លងបុគ្គលអ្នកប្រមាទដោយសភាពនៃសេចក្តីសុខ ។*

ក្នុងវេលាចប់គាថា នាងក៏បានតាំងនៅក្នុងសោតាបត្តិផល ។ ក្នុងថ្ងៃទី ២ នាងបានថ្វាយទានចំពោះភិក្ខុសង្ឃ មានព្រះពុទ្ធជា-ប្រធាន បានក្រាបទូលរឿងនោះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះដ៏-មានព្រះភាគ ទ្រង់បានធ្វើរឿងនោះឱ្យជាអត្ថុប្បត្តិហេតុ ហើយសម្តែងធម៌ដល់បរិស័ទដែលមកប្រជុំគ្នាហើយ ។ ព្រះធម៌ទេសនា-នោះ បានជាប្រយោជន៍ដល់មហាជន ដោយប្រការដូច្នេះ ។

## ( ចប់រឿងអម្ពវនប្រេតទី ១២ )

**បុត្តា មត្ថិ ធនមត្ថិ ឥតិ ពាលោ វិហញ្ញតិ**
**អត្តា ហិ អត្តនោ នត្ថិ កុតោ បុត្តា កុតោ ធនំ ។**

ជនពាលតែងព្រួយលំបាក ដោយសេចក្តីសំគាល់ថា កូនទាំង-ឡាយរបស់អញមាន ទ្រព្យរបស់អញមាន តាមដែលពិត សូម្បីខ្លួនរបស់ខ្លួនក៏មិនមាន ចំណង់បើកូនទាំងឡាយ នឹងរាប់ថាមានអំពី-ណាបាន ទ្រព្យនឹងរាប់ថា មានអំពីណាបាន ។

( បិដកលេខ ៥២, ទំព័រ ៣៤ )

# ១៣-រឿងអក្ខរក្ខប្រេត

" ភុម្មទេវតាមួយអង្គបានពោលដាស់តឿនឧបាសកម្នាក់ "

( បិដកលេខ ៥៦, ទំព័រ ១៣១ និងអដ្ឋកថា )

រឿងអក្ខទាយកប្រេតនេះ មានពាក្យផ្ដើមថា **យំ ឧនាតិ ន តំ ហោតិ** ដូច្នេះ ។ តើរឿងនោះកើតឡើងដូចម្ដេច ?

កាលព្រះដ៏មានព្រះភាគ ទ្រង់គង់ប្រថាប់នៅក្នុងក្រុងសាវត្ថី មានឧបាសកអ្នកក្រុងសាវត្ថីម្នាក់ យករទេះជាច្រើនគ្រឿងផ្ទុកទំនិញទៅលក់ឯប្រទេសផ្សេង ពេលដែលលក់ទំនិញរបស់ខ្លួនក្នុងប្រទេសនោះអស់ហើយ ក៏ទិញនូវទំនិញអំពីប្រទេសនោះត្រឡប់មកវិញ ហើយក៏បានធ្វើដំណើរឆ្ពោះទៅកាន់ក្រុងសាវត្ថី ។ កាលឧបាសកនោះ កំពុងធ្វើដំណើរភ្លៅរទេះមួយក៏បានបាក់ក្នុងព្រៃ ។ លំដាប់នោះបុរសម្នាក់ បានយកដឹងនិងពូថៅ ដើម្បីនឹងកាប់ឈើ ចេញពីស្រុកខ្លួនត្រាច់ទៅក្នុងព្រៃ ទៅដល់ទីនោះ ក៏បានជួបឧបាសកនោះ ជាអ្នកដល់នូវសេចក្ដីទោមនស្ស ព្រោះភ្លៅរទេះបាក់ ទើបគិតថា ពាណិជនេះមកលំបាកក្នុងព្រៃ ព្រោះភ្លៅរទេះបាក់ អាស្រ័យសេចក្ដីអនុគ្រោះ ទើបកាប់កំណាត់ឈើ មកអបភ្លៅរទេះឱ្យរឹងមាំហើយផ្គុំរទេះ ឱ្យទៅ ។

លុះកាលជាខាងក្រោយមក បុរសនោះ ធ្វើកាលកិរិយាហើយ ក៏បានកើតជាភុម្មទេវតា នៅក្នុងព្រៃនោះឯង ពិចារណាដល់កម្មរបស់ខ្លួន ក្នុងវេលារាត្រីទើបទៅកាន់ផ្ទះរបស់ឧបាសកនោះ ឈរនៅត្រង់ទ្វារផ្ទះ ហើយពោលនូវគាថាថា :

**យំ ទទាតិ ន តំ ហោតិ ទេថេវ ទានំ ទត្វាន**
**ឧភយំ តរតិ ឧភយំ តេន ទានេន គច្ឆតិ**
**ជាគរថ មា បមជ្ជថាតិ ។**

*បុរសបុគ្គលឱ្យរបស់ណា របស់នោះ មិនមាន ( ផលត្រឹមតែ-ប៉ុណ្ណោះ ) ទេ បុគ្គលគប្បីឱ្យទាន លុះឱ្យទានហើយ រមែងឆ្លងទុក្ខទាំងពីរយ៉ាង ( ទុក្ខក្នុងបច្ចុប្បន្ននិងបរលោក ) រមែងបានប្រទះសុខទាំងពីរ ព្រោះតែទាននោះ ចូរអ្នកភ្ញាក់រឭក ចូរអ្នកកុំធ្វេសប្រហែស ( ក្នុងទាន ) ឡើយ ។*

បណ្ដាបទទាំងនោះ បទថា **យំ ទទាតិ ន តំ ហោតិ** សេចក្ដីថា ទាយករមែងឱ្យនូវទេយ្យធម៌ណា ទេយ្យធម៌នោះឯង រមែងមិនមានផល ( ត្រឹមតែប៉ុណ្ណោះទេ ) ក្នុងបរលោក, តាមពិតនាមដទៃទៀត ដែលមានផលគួរជាទីប្រាថ្នា គួរជាទីពេញចិត្ត ក៏មាន

ច្រើនក្រៃលែង ព្រោះដូច្នោះ ពួកអ្នកចូរឱ្យនូវទាននោះ គឺចូរឱ្យទានដោយប្រការណាមួយ ។ ភុម្មទេវតា ពោលនូវហេតុក្នុងសេចក្ដីនោះថា លុះឱ្យហើយ រមែងផុតចាកទុក្ខ និងសេចក្ដីវិនាសទាំងពីរ, អធិប្បាយថា លុះឱ្យទានហើយ រមែងផុតទុក្ខ និងសេចក្ដីវិនាសទាំងបច្ចុប្បន្នទាំងសម្បរាយភព ។ ក្នុងបទថា **ឧភយំ តេន ទានេន គច្ឆតិ** នេះ គប្បីប្រកបសេចក្ដីដូច្នេះថា ព្រោះការឱ្យនោះ គេរមែងចូលដល់ គឺរមែងជួបប្រទះនូវសុខទាំងពីរ គឺសុខក្នុងបច្ចុប្បន្ន និងសុខក្នុងសម្បរាយភព ទាំងរមែងជួបប្រសព្វដោយអំណាចហិត-សុខ ទាំងដល់ខ្លួន និងសង្គម ។ បទថា **ជាគរថ មា បមជ្ជថ** សេចក្ដីថា ចូរភ្ញាក់រឭកដើម្បីញុំាងទានដែលហាមនូវអនត្ថទាំងពីរ ញុំាងប្រយោជន៍ ទាំងពីរឱ្យសម្រេចយ៉ាងនេះ និងចូរចាត់ចែងរៀប-ចំនូវឧបករណ៍ ហើយចូរកុំប្រមាទក្នុងទាននោះ ។ ក៏ក្នុងទីនេះ ដើម្បីនឹងសម្ដែងដល់សេចក្ដីអើពើ លោកទើបពោលបន្ថែមទៀត ។

ពាណិជពិចារណាដល់កិច្ចរបស់ខ្លួនហើយ ក៏បានត្រឡប់មកដល់ក្រុងសាវត្ថីវិញ ដោយលំដាប់ ក្នុងថ្ងៃទី ២ ទើបចូលទៅគាល់ព្រះសាស្ដា ថ្វាយបង្គំហើយ អង្គុយក្នុងទីដ៏សមគួរ ទើបក្រាបទូលរឿងនោះចំពោះព្រះដ៏មានព្រះភាគ ។ ព្រះសាស្ដាទ្រង់ធ្វើនូវរឿងនោះឱ្យជាអត្ថុប្បត្តិហេតុ ហើយទ្រង់សម្ដែងធម៌ដល់បរិស័ទ ដែលមក

ជួបជុំគ្នាហើយ ។ ព្រះធម៌ទេសនានោះ បានជាប្រយោជន៍ដល់មហាជន ដោយប្រការដូច្នេះ ។

## ( ចប់រឿងអគ្គរក្ខប្រេតទី ១៣ )

**អចរិត្វា ព្រហ្មចរិយំ អលទ្ធា យោព្វនេ ធនំ**
**ជិណ្ណកោញ្ចាវ ឈាយន្តិ ខីណមច្ឆេវ បល្លលេ ។**

-ជនពាលទាំងឡាយ មិនប្រព្រឹត្តព្រហ្មចរិយធម៌ មិនបានទ្រព្យក្នុងកាលខ្លួននៅជាកំលោះក្រមុំ រមែងសញ្ជប់សញ្ជឹង ដូចសត្វក្រៀលចាស់ សំកុកនៅក្នុងភក់ដែលអស់ត្រីហើយ ។

**អចរិត្វា ព្រហ្មចរិយំ អលទ្ធា យោព្វនេ ធនំ**
**សេន្តិ ចាបាតិខីណាវ បុរាណានិ អនុត្ថុនំ ។**

-ជនពាលទាំងឡាយ មិនប្រព្រឹត្តព្រហ្មចរិយធម៌ មិនបានទ្រព្យក្នុងកាលខ្លួននៅជាកំលោះក្រមុំ រមែងដេកថ្ងូរ សោកស្តាយទ្រព្យចាស់ទាំងឡាយ ដូចព្រួញដែលផុតចាកខ្សែបន្ទោះដូច្នោះ ។

( បិដកលេខ ៥២, ទំព័រ ៥៤ )

# ១៤-រឿងភោគសំហរប្រេត

( បិដកលេខ ៥៦, ទំព័រ ១៣២ និងអដ្ឋកថា )

រឿង**នាងភោគសំហរណប្រេត**នេះ មានពាក្យផ្ដើមថា **មយំ ភោគេ សំហរិម្ហ** ដូច្នេះ ។ តើរឿងនោះកើតឡើងដូចម្ដេច ?

បានឮថា កាលព្រះដ៏មានព្រះភាគ ទ្រង់គង់ប្រថាប់នៅក្នុងវត្តវេឡុវ័នមហាវិហារ ស្ត្រី ៤ នាក់ ក្នុងក្រុងរាជគ្រឹះ បានប្រកបនូវការលក់ដូរ ទឹកដោះថ្លា ទឹកឃ្មុំ ប្រេង និងស្រូវជាដើម ដោយគ្រឿងវាប់កោងជាដើម ប្រមូលភោគៈចិញ្ចឹមជីវិត ដោយមិនត្រូវទំនង ។ បន្ទាប់ពីស្លាប់ទៅ ស្ត្រីទាំងនោះ ក៏បានទៅកើតជាងនាងប្រេតនៅត្រង់ខ្នងនៃគូក្រៅក្រុង ក្នុងវេលាយប់ នាងប្រេតទាំងនោះត្រូវសេចក្ដីទុក្ខគ្របសង្កត់ ក៏បានស្រែកកន្ទក់កន្ទេញដោយសំឡេងដ៏ខ្លាំងគួរឱ្យខ្លាច ដោយគាថាថា :

*ពួកយើងបានប្រមូលភោគៈទាំងឡាយដោយសមខ្លះ ដោយមិនសមខ្លះ ពួកជនឯទៀត តែងបរិភោគភោគៈទាំងនោះ ឯពួកយើងគ្រាន់តែបានចំណែកនៃសេចក្ដីទុក្ខ ។*

មនុស្សទាំងឡាយ បានឮសំឡេងនោះហើយ ក៏ភ័យតក់ស្លុត,

លុះព្រឹកឡើង ក៏បានចាត់ចែងនូវមហាទាន ដើម្បីភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធាន បាននិមន្តព្រះសាស្តានិងភិក្ខុសង្ឃ រួចហើយ ក៏បានអង្គាសដោយខាទនីយៈ និងភោជនីយៈដ៏ប្រណីត បន្ទាប់មក ក៏បានចូលទៅគាល់ព្រះដ៏មានព្រះភាគ ក្នុងវេលាដែលទ្រង់សោយស្រេចហើយ យកព្រះហស្តចេញពីបាត្រហើយ ទើបក្រាបទូលឱ្យទ្រង់ជ្រាបនូវរឿងនោះ ។ ព្រះដ៏មានព្រះភាគ បានត្រាស់ថា ឧបាសក និងឧបាសិកាទាំងឡាយ សំឡេងនោះមិនមានអន្តរាយណាមួយដល់អ្នកទាំងឡាយទេ ចំណែកប្រេតទាំង ៤ នាក់នោះ ត្រូវសេចក្តីទុក្ខគ្របសង្កត់ ក៏បានពោលដល់កម្មដែលខ្លួនបានធ្វើអាក្រក់ ស្រែកកន្ទក់កន្ទេញបណ្តើរពោលនូវគាថានេះបណ្តើរថា :

**មយំ ភោគេ សំហរិម្ហ សមេន វិសមេន ច**
**តេ អញ្ញេ បរិភុញ្ជន្តិ មយំ ទុក្ខស្ស ភាគិនីតិ ។**

*ពួកយើងបានប្រមូលភោគៈទាំងឡាយដោយសមខ្លះ ដោយមិនសមខ្លះ ពួកជនឯទៀត តែងបរិភោគភោគៈទាំងនោះ ឯពួកយើងគ្រាន់តែបានចំណែកនៃសេចក្តីទុក្ខ ។*

បណ្តាបទទាំងនោះ បទថា **ភោគេ** បានដល់ ឧបករណ៍ពិសេសនៃទ្រព្យជាទីពេញចិត្ត មានសំពត់និងអាភរណៈជាដើម ដែលឈ្មោះថា **ភោគៈ** ព្រោះអត្ថថា គឺបុគ្គលគប្បីប្រើប្រាស់ ។ បទថា

**សំហរិម្ហា** ( បិដកថា **សំហរិម្ហ** ) សេចក្ដីថា អ្នកមានចិត្តដែលមន្ទិល គឺសេចក្ដីកំណាញ់គ្របសង្កត់ ប្រមូលទុក មិនឱ្យអ្វីមួយដល់នរណាម្នាក់ឡើយ ។ បទថា **សមេន វិសមេន ច** ដោយត្រឹមត្រូវ និងមិនត្រឹមត្រូវ ម្យ៉ាងទៀត សេចក្ដីថា ឥឡូវនេះ ជនដទៃទៀត ប្រើប្រាស់នូវភោគៈទាំងនោះ ដែលយើងប្រមូលទុក ដោយមិនត្រឹមត្រូវ ដែលជារបស់ប្លមនឹងភាពត្រឹមត្រូវ ។ បទថា **មយំ ទុក្ខស្ស ភាគិនី** សេចក្ដីថា ចំណែកពួកយើង ឥឡូវនេះ ជាអ្នកមានចំណែកនៃទុក្ខធំ ដែលជាប់ទាក់ទងក្នុងកំណើតប្រេត គឺសោយទុក្ខធំ ព្រោះខ្លួនមិនបានធ្វើនូវសុចរិតណាមួយទុក ធ្វើតែទុច្ចរិត ។

ព្រះដ៏មានព្រះភាគ ត្រាស់គាថាដែលនាងប្រេតនោះ ពោលហើយយ៉ាងនេះ ទើបត្រាស់នូវប្រវត្តិរបស់នាងប្រេតទាំងនោះ ហើយទ្រង់ធ្វើនូវរឿងនោះ ឱ្យជាអត្ថុប្បត្តិហេតុហើយ ទ្រង់សម្ដែងធម៌ដល់បរិស័ទដែលមកប្រជុំគ្នាហើយ ទ្រង់ប្រកាសនូវអរិយសច្ចៈកាន់តែក្រៃលែងឡើង ក្នុងវេលាចប់នូវអរិយសច្ចៈ ជនជាច្រើនបានសម្រេចសោតាបត្តិផលជាដើម ដោយប្រការដូច្នេះ ។

**( ចប់រឿងភោគសំហរប្រេតទី ១៤ )**

# ១៥-រឿងសេដ្ឋិបុត្តប្រេត

" ទីបំផុតមិនមាន "

( បិដកលេខ ៥៦, ទំព័រ ១៣២ និងអដ្ឋកថា )

រឿងប្រេតដែលជាសេដ្ឋីបុត្រនេះ មានពាក្យផ្ដើមថា **សដ្ឋីវស្សសហស្សានិ** ដូច្នេះជាដើម ។ តើរឿងនោះកើតឡើងដូចម្ដេច ?

ព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់គង់ប្រថាប់នៅក្នុងវត្ត-ជេតពន ក្រុងសាវត្ថី ក៏សម័យនោះឯង ព្រះបាទបសេនទិកោសល ទ្រង់ប្រដាប់តាក់តែងហើយ ក៏បានឡើងគង់ប្រថាប់លើ-កដំរីស ដ៏ប្រសើរ ស្ដេចយាងប្រទក្សិណព្រះនគរ ដោយរាជឫទ្ធិដ៏ធំ ដោយរាជានុភាពដ៏ធំ ទ្រង់ក៏បានទតឃើញនូវស្ត្រីម្នាក់ ដែលប្រៀបបីដូចជាស្រីទេពអប្សរ ព្រោះបរិបូណ៌ដោយរូប បានបើកបង្អួចជាន់ខាងលើនៃប្រាសាទ ក្នុងផ្ទះមួយខ្នងក្រឡេកមើលការតុបតែងកាយព្រះរាជានោះ មានចិត្តរួបរឹតដោយការផ្សាយទៅនៃកិលេសដែលកើតឡើងដោយឆាប់រហ័ស ក្នុងអារម្មណ៍ដែលមិនធ្លាប់ឃើញ សូម្បីមានជនក្នុងព្រះរាជវាំង ដែលបរិបូណ៌ដោយគុណវិសេស មានត្រកូល រូប និង

អាចារៈ ក៏មានចិត្តប្រតិព័ទ្ធចំពោះស្ត្រីនោះ ដោយអំណាចចិត្តដែលទូន្មានបានដោយកម្រ ដែលមានការកើតរលត់យ៉ាងឆាប់រហ័សជាសភាវៈ ទើបបានឱ្យសញ្ញាដល់បុរស ដែលអង្គុយនៅខាងក្រោយអាសនៈថា អ្នកចូរត្រួតមើលប្រាសាទនេះ ហើយទ្រង់ក៏បានចូលទៅកាន់ព្រះរាជនិវេសន៍វិញ ។ ផ្ទៃរឿងដ៏សេសទាំងអស់ គប្បីជ្រាបដោយន័យដែលបានពោលរួចមកហើយ **ក្នុងរឿងអម្ពសក្ខរប្រេត** នោះឯង ។

ចំណែកសេចក្តីប្លែកគ្នា មានដូចតទៅនេះ : ក្នុងរឿងនេះ បុរសមកក្នុងពេលព្រះអាទិត្យនៅមិនទាន់អស្តង្គត កាលគេបិទទ្វារនគរ ទើបដាក់ដីពណ៌អរុណនិងផ្កាឧប្បលដែលខ្លួននាំមក ទុកត្រង់ទ្វារនគរ ហើយទៅកាន់វត្តជេតពនមហាវិហារ ដើម្បីនឹងដេក ។ ចំណែកព្រះរាជា ស្តេចយាងចូលទីប្រថាប់លើក្រឡាព្រះបន្ទំដ៏មានសិរី ក្នុងវេលាមជ្ឈិមយាម ទ្រង់បានឮនូវអក្ខរៈ ៤ តួ ទាំងនេះគឺ **ស. ន. ទុ. សោ.**(១) ដោយសំឡេងដ៏ខ្លាំងរំពង ដូចបន្លឺចេញដោយបំពង់កដ៏ធំ ។ បានឮថា ក្នុងអតីតកាល សេដ្ឋីបុត្រ ៤ នាក់ ជាអ្នកក្រុងសាវត្ថី វង្វេងដោយសេចក្តីស្រវឹងក្នុងភោគទ្រព្យ បានប្រសព្វនូវអកុសលជាច្រើន ដោយអំណាចកម្មដែលគប់រកភរិយាអ្នកដទៃ

*១- ក្នុងធម្មបទ ត្រង់ពាលវគ្គទី ៥ គាថាទី ១ ក្នុងរឿងបុរសម្នាក់ថា **ទុ. ស. ន. សោ** ។*

កាលនៅពីក្មេង ក្រោយមកធ្វើកាលកិរិយាហើយ ក៏បានទៅកើតក្នុងលោហកុម្ភី ជិតនគរនោះឯង ឆេះដល់កណ្តាប់មាត់លោហកុម្ភី មានបំណងនឹងពោលគាថាមួយម្នាក់ ទើបបានពោលត្រឹមតែអក្ខរៈខាងដើមនៃគាថាទាំងនោះ ដែលខ្លួនបន្លឺឡើង បានទទួលវេទនា ក៏លិចចុះកាន់លោហកុម្ភីវិញ ។

ចំណែកព្រះរាជា ទ្រង់ឮនូវសំឡេងនោះហើយ ក៏មានព្រះទ័យភ័តតក់ស្លុត ព្រឺរោមព្រឺស្បែក ទ្រង់ឱ្យរាត្រីដ៏សេសនោះ កន្លងទៅដោយលំបាក លុះព្រឹកឡើង ទើបត្រាស់ឱ្យហៅបុរោហិតមកហើយត្រាស់ប្រាប់នូវរឿងនោះ ។ បុរោហិតជាមនុស្សជាប់ជំពាក់នឹងលាភដឹងថាព្រះរាជាមានព្រះទ័យតក់ស្លុត ទើបគិតថា ឧបាយដែលជាហេតុឱ្យកើតលាភដល់យើងនិងដល់ពួកព្រាហ្មណ៍ បានកើតឡើងហើយទើបទូលថា បពិត្រមហារាជ ឧបទ្រព្យចង្រៃដ៏ធំនេះកើតឡើងហើយហ្ន៎ សូមព្រះអង្គ ចូរបូជាយ័ញ្ញ ដែលប្រកបដោយពួក ៤ នៃវត្ថុទាំង-ពួង ព្រះរាជាទ្រង់ព្រះសណ្តាប់នូវពាក្យរបស់បុរោហិតនោះ ហើយទើបបញ្ជាអាមាត្យទាំងឡាយថា ពួកអ្នកចូរត្រៀមឧបករណ៍យ័ញ្ញ ៤ពួក ។ ព្រះនាងមល្លិកាទេវី ទ្រង់បានឮដូច្នោះហើយ ទើបទូលព្រះរាជាយ៉ាងនេះថា បពិត្រព្រះមហារាជ ព្រោះហេតុដូចម្តេច ព្រះ-អង្គទ្រង់ព្រះសណ្តាប់នូវពាក្យបុរោហិតនោះហើយ ទើបមានបំណង

នឹងធ្វើនូវកិច្ច គឺការសម្លាប់ និងបៀតបៀនសត្វជាច្រើន ព្រះអង្គគួរទូលសួរព្រះដ៏មានព្រះភាគជាម្ចាស់ ទ្រង់មានព្រះញាណដែលប្រព្រឹត្តទៅមិនទើសទាក់ក្នុងទីទាំងពួង មិនមែនឬ ? ហើយព្រះអង្គគួរបដិបត្តិតាមដែលព្រះដ៏មានព្រះភាគទ្រង់ព្យាករដល់ព្រះអង្គ ។ ព្រះរាជាទ្រង់ព្រះសណ្ដាប់នូវពាក្យរបស់ព្រះទេវីហើយ ក៏បានយាងទៅគាល់ព្រះសាស្ដា ក្រាបទូលនូវរឿងនោះ ចំពោះព្រះដ៏មានព្រះភាគ ព្រះដ៏មានព្រះភាគត្រាស់ថា បពិត្រមហារាជ ហេតុដែលបណ្ដាលមកអំពីសំឡេងនោះ ដែលនឹងកើតមានអន្តរាយដល់ព្រះអង្គឥតមានទេ ដូច្នេះហើយ ទើបបានត្រាស់នូវប្រវត្តិរបស់សត្វដែលកើតក្នុងលោហកុម្ភីទាំងនោះ តាំងពីដើមរហូតដល់ចប់ ទើបបានត្រាស់នូវគាថាដែលប្រេតទាំងនោះ ចាប់ផ្ដើមបន្លឺឡើងមួយម្នាក់ ឱ្យពេញលេញថា :

**សដ្ឋីវស្សសហស្សានិ បរិបុណ្ណានិ សព្វសោ**
**និរយេ បច្ចមានានំ កទា អន្តោ ភវិស្សតិ ។**

*ពួកយើងឆេះនៅក្នុងនរកពេញប្រាំមួយម៉ឺន ( ៦០.០០០ ) ឆ្នាំគ្រប់គ្រាន់ តើទីបំផុតនឹងមានក្នុងវេលាណា ។*

**នត្ថិ អន្តោ កុតោ អន្តោ ន អន្តោ បដិទិស្សតិ**
**តថា ហិ បកតំ បាបំ មម តុយ្ហញ្ច មារិស[១] ។**

*១- ក្នុងច្បាប់ឆដ្ឋសង្គាយនាថា តទា ហិ បកតំ បាបំ , មម តុយ្ហញ្ច មារិសា ។*

*ពួកយើងមិនមានទីបំផុតទេ ពួកយើងនឹងមានទីបំផុតមកពីណា ទីបំផុតនឹងមិនប្រាកដដល់យើងឡើយ ម្នាលអ្នក ព្រោះតែខ្ញុំក្តី អ្នកក្តី បានធ្វើបាប ។*

**ទុជ្ជីវិតមជីវម្ហ  យេ សន្តេ ន ទទម្ហសេ**

**សន្តេសុ ទេយ្យធម្មេសុ  ទីបំ  នាកម្ហមត្តនោ[១] ។**

*ពួកយើងរស់នៅដោយលំបាក ព្រោះទេយ្យធម៌មាន យើងមិនបានឱ្យ កាលទេយ្យធម៌មាន យើងមិនបានធ្វើទីពឹងដល់ខ្លួនសោះ។*

**សោ ហិ[២] នូន ឥតោ គន្ត្វា  យោនឹ លទ្ធាន មានុសឹ**

**វទញ្ញូ សីលសម្បន្នោ  កាហាមិ កុសលំ ពហុំ ។**

*ប្រសិនបើខ្ញុំ បានរដោះរួចចាកនរកនេះទៅ បានកើតជាមនុស្ស សូមជាអ្នកបរិបូណ៌ដោយសីល ធ្វើកុសលឱ្យច្រើន អំពីកាលដឹងក្តីទៅ ។*

បណ្តាបទទាំងនោះ បទថា **សដ្ឋីវស្សសហស្សានិ** ប្រែថា ៦០,០០០ ឆ្នាំ ។ បានឮថា សត្វដែលកើតក្នុងលោហកុម្ភីនរកនោះ លិចចុះទៅក្រោម ដល់ផ្ទៃខាងក្រោម ៣០,០០០ ឆ្នាំ សូម្បីឡើងមកខាងលើ អំពីផ្ទៃខាងក្រោមនោះ ដល់កណ្តាប់មាត់ ៣០,០០០ ឆ្នាំ

*១- ក្នុងច្បាប់ឆដ្ឋសង្គាយនាថា **វិជ្ជមានេសុ ភោគេសុ, ទីបំ នាកម្ហ អត្តនោ** ។*

*២- ច្បាប់ឆដ្ឋសង្គាយនាថា **សោហំ** ។*

ដូចគ្នា, ដោយសញ្ញានោះ ប្រេតនោះ មានបំណងនឹងពោលនូវ-គាថាថា **សដ្ឋីវស្សសហស្សានិ បរិបុណ្ណានិ សព្វសោ** ពួកយើងឆេះក្នុងនរក ៦០,០០០ ឆ្នាំ ពេញបរិបូណ៌ដោយប្រការទាំងពួង ដូច្នេះទើបពោលថា **ស.** ប្រសព្វនូវវេទនាហួសប្រមាណ ដួលផ្កាប់មុខ ។ ក៏ព្រះដ៏មានព្រះភាគ បានត្រាស់នូវគាថានោះ ឱ្យពេញលេញដល់ព្រះរាជា ។ សូម្បីក្នុងគាថាដ៏សេស ក៏ន័យនេះ ។ បណ្ដាបទទាំងនោះ បទថា **ភនា អន្តោ ភវិស្សតិ** សេចក្តីថា កាលពួកយើងឆេះនៅក្នុងលោហកុម្ភីនរក តើកាលណាហ្ន៎ ទីបំផុតនៃទុក្ខនេះ នឹងអស់ទៅ ។

បទថា **តថា ហិ** សេចក្តីថា ទីបំផុតនៃទុក្ខនេះ រមែងមិនមានដល់អ្នកនិងដល់ខ្ញុំ ទីបំផុតនឹងមិនប្រាកដឡើយ យ៉ាងណាមិញគប្បីពោលផ្លាស់វិភត្តិថា អ្នកនិងខ្ញុំបានធ្វើកម្មដ៏លាមកទុក ក៏យ៉ាងនោះដែរ គឺ ដោយប្រការនោះ ។

បទថា **ទុជ្ជីវិតំ** បានដល់ ជីវិតដែលវិញ្ញូជនគប្បីតិះដៀល ។ បទថា **យេ សន្តេ** សេចក្តីថា ពួកយើងទាំងឡាយណា កាលទេយ្យធម៌មាន គឺប្រាកដ ។ បទថា **ន ទទម្ហសេ** ប្រែថា មិនបានឱ្យហើយ ។ ដើម្បីនឹងធ្វើនូវរឿងនោះ ដែលបានពោលរួចមកហើយនោះ ឱ្យប្រាកដច្បាស់ លោកទើបពោលថា កាលទេយ្យធម៌មាន យើងមិនបានធ្វើទីពឹងដល់ខ្លួនសោះ ដូច្នេះ ។

បទថា **សោហំ** កាត់បទជា **សោ អហំ** ប្រែថា ខ្ញុំនោះ ។ សព្ទថា **នូន** ជានិបាតចុះក្នុងអត្ថថា បរិវិតក្កៈ ។ បទថា **ឥតោ** បានដល់ ចាកលោហកុម្ភីនរកនេះ ។ បទថា **គន្ត្វា** ប្រែថា ទៅប្រាស-ហើយ ។ បទថា **យោនឹ លទ្ធាន មានុសឹ** បានដល់ បានកើតជាមនុស្ស គឺអត្តភាពជាមនុស្ស ។ បទថា **វទញ្ញូ** បានដល់ អ្នកមានការបរិច្ចាគជាប្រក្រតី ឬអ្នកដឹងនូវពាក្យរបស់អ្នកសូម ។ បទថា **សីលសម្បន្នោ** បានដល់ អ្នកដល់ព្រមដោយសីលនិងអាចារៈ ។ បទថា **កាហាមិ កុសលំ ពហុំ** សេចក្តីថា ខ្ញុំមិនដល់នូវសេចក្តីប្រមាទ ដូចក្នុងកាលមុនឡើយ នឹងធ្វើ គឺកសាងកុសល គឺបុញ្ញកម្មទុកឱ្យច្រើន គឺ ឱ្យគ្រប់គ្រាន់ ។

ព្រះសាស្តា លុះត្រាស់នូវព្រះគាថាទាំងនេះហើយ ទើបទ្រង់សម្តែងធម៌ដោយពិស្តារ ។ កាលចប់នូវព្រះធម៌ទេសនា បុរសដែលនាំដីឥដ្ឋ និងផ្កាឧប្បលក្រហម ក៏បានតាំងនៅក្នុងសោតាបត្តិផល ព្រះរាជាទ្រង់កើតនូវសេចក្តីសង្វេគ ទ្រង់លះបង់នូវសេចក្តីសម្លឹងរំពៃក្នុងស្រ្តីដែលអ្នកដទៃហួងហែង ជាអ្នកត្រេកអរតែនឹងភរិយារបស់ខ្លួនដោយប្រការដូច្នេះ ។

**( ចប់រឿងសេដ្ឋិបុត្តប្រេតទី ១៥ )**

( សូមលើកសេចក្តីក្នុងធម្មបទជាបន្ទត្រង់ពាលវគ្គទី ៥ គាថាទី ១ )

# ក្នុងរឿងបុរសម្នាក់

( បិដកលេខ ៥២, ទំព័រ ៣៤ និងអដ្ឋកថា )

## សេចក្តីខាងដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តជេតពន ទ្រង់ប្រារព្ធនូវព្រះ-បាទបសេនទិកោសល និងបុរសម្នាក់ ត្រាស់ព្រះធម្មទេសនានេះថា **ទីឃា ជាគរតោ រត្តិ** មានបទដូច្នេះជាដើម ។

## ព្រះរាជាប្រទក្សិណព្រះនគរ

បានឮថា នៅក្នុងថ្ងៃមហោស្រពមួយ ព្រះរាជាទ្រង់ព្រះនាមបសេនទិកោសល ស្តេចឡើងកាន់ដំរីសសុទ្ធមួយឈ្មោះ **បុណ្ឌរីកៈ** ដែលប្រដាប់តុបតែងហើយ ទ្រង់ប្រទក្សិណព្រះនគរដោយអានុភាពនៃព្រះរាជាដ៏ធំ ។

កាលអាជ្ញា ជាគ្រឿងប្រដេញឱ្យបុគ្គលចៀសចេញ កំពុង-ប្រព្រឹត្តទៅ មហាជនត្រូវរាជបុរសប្រហារដោយវត្ថុទាំងឡាយ មានដុំដី និងដំបងជាដើម រត់ទៅបណ្តើរ ងាកក.ក្រឡេកមើលព្រះរាជាបណ្តើរ ។

បានឮថា ការងាកក.ក្រឡេកមើលរបស់មហាជននោះ ជា-ផលនៃទានដែលព្រះរាជាទាំងឡាយទ្រង់ថ្វាយហើយដោយល្អ ។

## អំណាចនៃសេចក្តីស្រឡាញ់

នៅពេលនោះ ភរិយារបស់ទុគ្គតបុរសម្នាក់ឈរនៅនាផ្ទៃប្រាសាទ ៧ ជាន់ គ្រាន់តែបើកទ្វារមើលព្រះរាជាហើយ ក៏បិទទៅវិញ ។ ការគេចចេញរបស់ស្ត្រីនោះ បានប្រាកដដល់ព្រះរាជា ដូចព្រះចន្ទពេញវង់ចូលទៅកាន់ចន្លោះនៃស្រទាប់ពពក ។

ព្រះរាជាក៏ទ្រង់មានព្រះហឫទ័យប្រតិព័ទ្ធចំពោះស្ត្រីនោះ ព្រះ-រាជាមានអាការៈហាក់ដូចជាចង់ធ្លាក់ចុះអំពីកដំរី ទ្រង់ធ្វើប្រទក្សិណព្រះនគរយ៉ាងប្រញាប់ហើយ ស្តេចចូលទៅកាន់បុរី ត្រាស់សួរអា-មាត្យដែលស្និទ្ធស្នាលនឹងព្រះអង្គថា ម្នាលអ្នកដ៏ចម្រើន ប្រាសាទដែលយើងសម្លឹងមើលក្នុងទីឯណោះ តើអ្នកឯងបានឃើញដែរឬទេ ?

អាមាត្យ. ព្រះករុណាថ្លៃវិសេស ខ្ញុំព្រះអង្គបានឃើញ ។

ព្រះរាជ. តើអ្នកឯងបានឃើញស្ត្រីម្នាក់លើប្រាសាទនោះទេ ?

អាមាត្យ. ព្រះករុណាថ្លៃវិសេស ខ្ញុំព្រះអង្គបានឃើញដែរ ។

ព្រះរាជា. អ្នកឯងចូរទៅស៊ើបឱ្យបានដឹងច្បាស់ថា ស្ត្រីនោះមានស្វាមីហើយឬក៏មិនទាន់មានទេ ។

អាមាត្យនោះទៅហើយ បានដឹងច្បាស់ថាស្ត្រីនោះមានស្វាមី

ហើយ ក៏ត្រឡប់មកក្រាបទូលព្រះរាជាថា បពិត្រព្រះសម្មតិទេព ស្ត្រីនោះមានស្វាមីហើយ ។

គ្រានោះ ព្រះរាជាត្រាស់ថា បើដូច្នោះ អ្នកឯងចូរទៅហៅស្វាមីរបស់ស្ត្រីនោះមក អាមាត្យនោះក៏ទៅកាន់សម្នាក់បុរសនោះ ហើយនិយាយថា នែអ្នកដ៏ចម្រើន ! ព្រះរាជាត្រាស់ឱ្យហៅអ្នកឯង ។

ទុគ្គតបុរសគិតថា ភ័យកើតឡើងដល់យើងព្រោះអាស្រ័យភរិយារបស់យើង កាលមិនអាចទទឹងទាស់នឹងព្រះរាជអាជ្ញា ក៏ទៅថ្វាយបង្គំព្រះរាជា ហើយឈរនៅក្នុងទីដ៏សមគួរមួយ ។ គ្រានោះព្រះរាជាត្រាស់ទៅកាន់បុរសនោះថា អ្នកឯងចូរនៅបម្រើយើង ។

ទុគ្គតបុរស. បពិត្រព្រះសម្មតិទេព កុំឡើយ ខ្ញុំព្រះអង្គធ្វើការងាររបស់ខ្លួនហើយថ្វាយសួយដល់ព្រះអង្គ ការចិញ្ចឹមជីវិតនុ៎ះឯងសូមមានដល់ខ្ញុំព្រះអង្គចុះ ។

ព្រះរាជាត្រាស់ថា យើងមិនត្រូវការសួយរបស់អ្នកឯងទេចាប់តាំងអំពីថ្ងៃនេះទៅ អ្នកឯងចូរនៅបម្រើយើង ហើយបញ្ជារាជ-បុរសឱ្យព្រះរាជទានខែល និងអាវុធដល់បុរសនោះ ។

បានឮថា ព្រះរាជាទ្រង់មានព្រះតម្រិះយ៉ាងនេះថា យើងនឹងលើកនូវទោសអ្វីមួយរបស់គេឡើងហើយសម្លាប់ចោល យកប្រពន្ធ ។

គ្រានោះ ទុគ្គតបុរសភ័យខ្លាចស្លាប់ ក៏បម្រើព្រះរាជាដោយ

សេចក្តីមិនប្រមាទ ។

ព្រះរាជាមិនទ្រង់ឃើញឱកាស ( ទោស ) របស់ទុគ្គតបុរស កាលសេចក្តីក្តៅក្រហាយព្រោះ**កាម**ចម្រើនឡើងហើយ ក៏ទ្រង់ព្រះ-តម្រិះថា យើងនឹងលើកទោសអ្វីមួយរបស់បុរសនោះឡើង ដាក់រាជអាជ្ញា ទើបបញ្ជាឱ្យហៅបុរសនោះមកហើយ ត្រាស់យ៉ាងនេះថា ម្នាលអ្នកដ៏ចម្រើន អ្នកឯងចូរទៅកាន់ទីឯណោះនៃស្ទឹងចម្ងាយប្រមាណ ១ យោជន៍ នាំផ្កាកុមុទ ផ្កាឧប្បល និងដីពណ៌អរុណមក ( ឱ្យទាន់ ) ពេលយើងស្រង់ទឹកក្នុងវេលាល្ងាច, ប្រសិនបើអ្នកឯងមកមិនទាន់ក្នុងពេលនោះទេ យើងនឹងដាក់រាជអាជ្ញាដល់អ្នកឯង ។

## ការលំបាកក្នុងរាជដំណាក់

បានឮថា សេវកៈ ( អ្នកចូលគាល់ ) លំបាកជាងទាសៈរបស់ព្រះរាជាទាំង ៤ ទៅទៀត ។ ពិតណាស់ ទាសៈទាំងឡាយ មានទាសៈដែលគេលោះមកដោយទ្រព្យជាដើម រមែងបានដើម្បីនឹងពោលថា ខ្ញុំឈឺក្បាល , ខ្ញុំឈឺខ្នង ហើយសម្រាក ។

ពាក្យដែលទាសៈទាំងឡាយពោលហើយ បានសម្រាកនោះរមែងមិនមានដល់សេវកៈ, ការងារណាដែលព្រះរាជាទ្រង់បញ្ជាហើយ សេវកៈត្រូវតែធ្វើដាច់ខាត ប្រកែកមិនបាន ព្រោះហេតុនោះបុរសនោះក៏គិតថា យើងត្រូវទៅយ៉ាងដាច់ខាត ប្រកែកមិនបាន ។

ដែលឈ្មោះថា ដីពណ៌អរុណ និងផ្កាកុមុទ ព្រមទាំងផ្កាឧប្បល រមែងមានក្នុងអនាគត, យើងនឹងបានអំពីទីណា ? ខ្លាចស្លាប់ ទៅផ្ទះហើយ សួរភរិយាថា ម្នាលនាងដ៏ចម្រើន ភត្តសម្រាប់ខ្ញុំសម្រេចហើយឬនៅ ? ភរិយាឆ្លើយថា បពិត្រអ្នកជាម្ចាស់ នៅលើទីចង្ក្រាននៅឡើយ ។ ទុគ្គតបុរសមិនអាចរង់ចាំដរាបដាក់ភត្តចុះបាន ក៏ប្រាប់ឱ្យភរិយាយកវែកដួសទឹកបាយ ( លាយ ) នឹងបាយដែលមិនទាន់ឆ្អិននោះឯង ដាក់កញ្ច្រែងកាន់យកទៅ ធ្វើដំណើរទៅយ៉ាងលឿនបានចម្ងាយមួយយោជន៍ ។

កាលទុគ្គតបុរសកំពុងធ្វើដំណើរទៅនោះឯង ភត្តក៏បានឆ្អិនហើយដែរ ។ គាត់រំលែកភត្តទុកបន្តិច ធ្វើមិនឱ្យជារបស់សំណល់ហើយបរិភោគ ជួបអ្នកដំណើរម្នាក់ក៏ពោលថា បពិត្រអ្នកដ៏ចម្រើនភត្តបន្តិចនេះ ខ្ញុំរំលែកចេញ ធ្វើមិនឱ្យជារបស់សំណល់ លោកចូរកាន់យកបរិភោគ ។ អ្នកដំណើរនោះក៏ទទួលយកទៅបរិភោគ ។

ទុគ្គតបុរសបរិភោគហើយ ក៏បាចបាយទៅក្នុងទឹកមួយក្ដាប់ ខ្ពុរមាត់ហើយ ប្រកាសឡើង ៣ ដង ដោយសំឡេងដ៏លាន់ឮថា សូមពួកនាគ គ្រុឌ និងទេវតាដែលអាស្រ័យនៅក្នុងទីនេះ ស្ដាប់ពាក្យរបស់ខ្ញុំ ព្រះរាជាទ្រង់ប្រាថ្នានឹងដាក់អាជ្ញាដល់ខ្ញុំ, ទ្រង់ត្រាស់បង្គាប់ខ្ញុំថាអ្នកឯងចូរទៅនាំយកដីពណ៌អរុណ និងផ្កាកុមុទ ព្រមទាំងផ្កាឧប្បល-

មក ក៏ភត្តដែលខ្ញុំឱ្យដល់មនុស្សអ្នកដំណើរហើយ ជាទានមានអានិ-សង្សទាំងពាន់ ភត្តដែលខ្ញុំឱ្យដល់មនុស្សអ្នកដំណើរហើយ ជាទានមានអានិសង្សទាំងរយ, ខ្ញុំឱ្យចំណែកបុណ្យមានប្រមាណប៉ុណ្ណោះដល់អ្នកទាំងឡាយ, សូមអ្នកទាំងឡាយនាំដីពណ៌អរុណ និងផ្កាកុមុទព្រមទាំងផ្កាឧប្បលមកឱ្យខ្ញុំ ។

ស្តេចនាគ ដែលអាស្រ័យនៅក្នុងប្រទេសនោះ បានឮសំឡេងនោះហើយ ក៏ទៅកាន់សម្នាក់នៃបុរសនោះ ដោយភេទជាមនុស្សចាស់ ហើយសួរថា ម្នាលអ្នកដ៏ចម្រើន អ្នកឯងពោលនូវពាក្យអ្វី ? បុរសនោះក៏ពោលដូច្នេះម្តងទៀត កាលស្តេចនាគសួរថា អ្នកឱ្យ-ចំណែកបុណ្យនោះដល់យើងឬ ទើបពោលថា បពិត្រអ្នកដ៏ចម្រើនខ្ញុំឱ្យ កាលស្តេចនាគសួរបញ្ជាក់ថែមទៀតថា លោកឱ្យមែនឬ ក៏ពោលបញ្ជាក់ថា បពិត្រអ្នកដ៏ចម្រើន ខ្ញុំឱ្យពិតមែន ស្តេចនាគឱ្យនាំចំណែកមកយ៉ាងនោះអស់វារៈ ២-៣ ដងហើយ ក៏បានឱ្យដីពណ៌អរុណ និងផ្កាកុមុទ ព្រមទាំងឧប្បលដល់បុរសនោះ ។

ចំណែកព្រះរាជា ទ្រង់ព្រះតម្រិះថា ធម្មតាមនុស្សទាំងឡាយរមែងមានមន្តច្រើន បើបុរសនោះគប្បីបាន ( របស់នោះ ) ដោយឧបាយយ៉ាងណានីមួយសោត កិច្ចរបស់យើងក៏មិនសម្រេច ព្រះរាជាបញ្ជាឱ្យបិទទ្វារ ( ក្រុង ) តាំងអំពីថ្ងៃ ហើយបញ្ជាឱ្យនាំយកកូនសោ

ទៅកាន់ដំណាក់របស់ព្រះអង្គ ។

ចំណែកទុគ្គតបុរស មកទាន់ពេលព្រះរាជាទ្រង់ស្រង់ទឹកដែរ ប៉ុន្តែទ្វារបិទ កាលមិនបានទ្វារ ក៏ហៅអ្នកយាមទ្វារមកហើយពោលថា នែអ្នកដ៏ចម្រើន ! ចូរបើកទ្វារឱ្យខ្ញុំ ។ អ្នកយាមទ្វារពោលថា យើងមិនអាចបើកបានទេ ព្រោះព្រះរាជាឱ្យនាំកូនសោទៅកាន់សម្នាក់ព្រះអង្គតាំងអំពីថ្ងៃម្ល៉េះ ។ សូម្បីទុគ្គតបុរសប្រាប់ថា យើងជារាជទូត, លោកចូរបើកទ្វារឱ្យខ្ញុំ ក៏មិនបើកឱ្យ ទុគ្គតបុរសកាលអ្នកយាមមិនបើកទ្វារឱ្យ ក៏គិតថា ឥឡូវនេះ យើងនឹងមិនមានជីវិត យើងនឹងធ្វើដូចម្តេចហ្ន៎ ក៏បោះដុំដីស្អិតទៅខាងលើនៃធរណីទ្វារ ព្យួរផ្កាទុកខាងលើនៃធរណីទ្វារនោះហើយ ស្រែកដោយសំឡេងយ៉ាងខ្លាំងអស់វារៈ ៣ ដងថា ម្នាលអ្នកនគរដ៏ចម្រើនទាំងឡាយ សូមអ្នកទាំងឡាយ ចូរដឹងនូវកិច្ចដែលខ្ញុំធ្វើតាមព្រះរាជបញ្ជារបស់ព្រះរាជាហើយចុះ ព្រះ-រាជាទ្រង់ប្រាថ្នានឹងញ៉ាំងខ្ញុំឱ្យវិនាសដោយហេតុមិនសមគួរ ហើយគិតថា យើងនឹងទៅទីណាហ្ន៎ ? បានសម្រេចចិត្តថា ធម្មតាភិក្ខុ-ទាំងឡាយ រមែងជាអ្នកមានចិត្តទន់ យើងនឹងទៅកាន់វិហារហើយដេក ។ ធម្មតាសត្វទាំងឡាយ កាលបានទទួលនូវសេចក្តីសុខ មិនដែលនឹកនា មិនដឹងថា ភិក្ខុទាំងឡាយមាននៅក្នុងវិហារទេ លុះត្រូវសេចក្តីទុក្ខគ្របសង្កត់ហើយ ទើបប្រាថ្នានឹងទៅកាន់វិហារ, ព្រោះ

ហេតុនោះ សូម្បីបុរសនោះ ក៏គិតថា ទីពឹងយ៉ាងដទៃរបស់យើង មិនមាន ទើបទៅកាន់វិហារ ដេកក្នុងទីដ៏សមគួរមួយ ។ សេចក្ដីក្ដៅក្រហល់ក្រហាយព្រោះកាម កើតឡើងហើយដល់ព្រះរាជា ធ្វើឱ្យព្រះរាជាផ្ទំមិនលក់ កាលព្រះរាជាមិនបានទទួលនូវការលក់អស់មួយរាត្រី ក៏ទ្រង់រំពឹងនឹកដល់ស្ត្រីនោះ ។ ព្រះរាជាទ្រង់គិតថា កាលអរុណរះ យើងនឹងបញ្ជាឱ្យគេសម្លាប់បុរសនោះ ហើយឱ្យនាំយកស្ត្រីនោះមក ។

## រឿងរបស់សត្វនរកអ្នកពោលអក្សរ

## ទុ. ស. ន. សោ.

ក្នុងខណៈនោះឯង បុរស ៤ នាក់ ដែលកើតក្នុងនរកលោហកុម្ភី ( នរកខ្ទះដែក ) ដែលមានជម្រៅ ៦០ យោជន៍ ត្រូវភ្លើងនរកឆេះវិលត្រឡប់ត្រឡិន ននៀលទៅមក ដូចជាអង្ករក្នុងឆ្នាំងដែលភ្លើងឱ្យពុះឡើងហើយ ( លិចចុះទៅ ) ដល់ផ្ទៃខាងក្រោម ៣ មុឺនឆ្នាំ ហើយ ( អណ្ដែតឡើងមក ) ដល់កណ្ដាប់មាត់ ៣ មុឺនឆ្នាំទៀត ។

សត្វនរកទាំងនោះ ងើបក្បាលឡើងក្រឡេកមើលនូវគ្នានឹងគ្នា ហើយ ប្រាថ្នានឹងពោលនូវគាថាមួយម្នាក់ ( ប៉ុន្តែ ) មិនអាចពោលបាន ពោលបានតែម្នាក់មួយអក្សរ ក៏លិចចុះទៅកាន់ខ្ទះដែកដូចដើមវិញ ។

ព្រះរាជា កាលផ្ទំមិនលក់ ក៏បានឮសំឡេងនោះ នៅក្នុងចន្លោះ

នៃមជ្ឈិមយាម ទ្រង់ខ្លាច ទ្រង់មានព្រះទ័យតក់ស្លុត ទ្រង់ព្រះតម្រិះថា អន្តរាយនៃជីវិតនឹងមានដល់យើងឬហ្ន៎ ឬថានឹងមានដល់អគ្គមហេសី ឬថារាជសម្បត្តិរបស់យើងនឹងវិនាស ?

ព្រះរាជាមិនអាចផ្ទេចនូវព្រះនេត្រទាំងពីរបាន រហូតអស់រាត្រីទាំងមូល ។ លុះពេលអរុណរះឡើង ព្រះអង្គក៏បញ្ជាឱ្យហៅបុរោហិតមកហើយត្រាស់ថា ម្នាលអាចារ្យ សំឡេងដែលមានសភាពគួរខ្លាចយ៉ាងខ្លាំង យើងបានឮក្នុងចន្លោះនៃមជ្ឈិមយាម ។ យើងមិនដឹងថាអន្តរាយនឹងមានដល់រាជសម្បត្តិ ឬដល់អគ្គមហេសី ដល់យើង ឬក៏ដល់អ្នកណាមួយ ? ព្រោះហេតុនោះ ទើបយើងឱ្យអញ្ជើញលោកមក ។

## ព្រាហ្មណ៍លួងឱ្យព្រះរាជាបូជាយញ្ញ

បុរោហិត. បពិត្រមហារាជ សំឡេងដែលព្រះអង្គទ្រង់បានព្រះសណ្តាប់ហើយនោះ តើដូចម្តេច ?

ព្រះរាជា. ម្នាលអាចារ្យ យើងបានឮសំឡេងទាំងនេះថា **ទុ. ស. ន. សោ.** លោកចូរពិចារណាមើលនូវផលដែលនឹងសម្រេចមកអំពីសំឡេងទាំងនេះមើល ។

ដំណឹងដែលជាគ្រឿងពោលតបអ្វីមួយ រមែងមិនប្រាកដដល់ព្រាហ្មណ៍ ហាក់ដូចជាអ្នកចូលទៅកាន់ទីងងឹតដ៏ធំ ។ បុរោហិតនោះគិតថា ក៏កាលយើងក្រាបទូលព្រះរាជាថា ខ្ញុំព្រះអង្គមិនជ្រាបលាភ-

សក្ការៈរបស់យើងនឹងសាបសូន្យ ទើបក្រាបទូលថា បពិត្រមហារាជ ហេតុនេះធ្ងន់ណាស់ ។

ព្រះរាជា. ម្នាលអាចារ្យ តើមានហេតុអ្វី ?

បុរោហិត. អន្តរាយនៃជីវិត នឹងប្រាកដដល់ព្រះអង្គ ។

ព្រះរាជាទ្រង់តក់ស្លុតជាទ្វេគុណ ត្រាស់ថា ម្នាលអាចារ្យ ហេតុដែលជាគ្រឿងការពារនូវអន្តរាយនោះមានដែរឬទេ ?

បុរោហិត. បពិត្រមហារាជ មាន, សូមព្រះអង្គកុំខ្លាចឡើយ ខ្ញុំព្រះអង្គដឹងនូវវេទ ៣ [១] ។

ព្រះរាជា. អើ អាចារ្យ យើងបាននូវវត្ថុអ្វី ទើបសមគួរ ?

បុរោហិត. បពិត្រព្រះសម្មតិទេព ព្រះអង្គទ្រង់បូជាយញ្ញ ដោយមានសត្វមួយមុខ ១០០ គ្រប់សត្វហើយ នឹងរួចផុតអំពីអន្តរាយជីវិត ។

ព្រះរាជា. ម្នាលអាចារ្យ បាននូវសត្វអ្វីខ្លះ ទើបគួរ ?

បុរោហិតនោះ ក្រាបទូលថា បពិត្រមហារាជ គួរបាននូវ-បាណជាតមួយប្រភេទ ៗ ឱ្យបាន ១០០ គឺ : ដំរី ១០០ សេះ ១០០

---

១= វេទ ៣ គឺ **ឥរុវេទ** ជាគម្ពីរមានគាថាពោលដល់ឈ្មោះទេវតា និងអង្វរសូមឱ្យជួយកម្ចាត់ភ័យផ្សេង ៗ ១ **យជុវេទ** ជាគម្ពីរពោលដល់ពិធីការក្នុងការបូជាយញ្ញដូចបួងសួងផ្សេង ៗ ១ **សាមវេទ** ជាគម្ពីរពោលដល់ឱ្យបាយឈ្នះសត្រូវ ១ ។

គោឧសភៈ ១០០ មេគោដែលរីតយកទឹកដោះ ១០០ ពពែ ១០០ ចៀម ១០០ មាន់ ១០០ ជ្រូក ១០០ ក្មេងប្រុស ១០០ ក្មេងស្រី ១០០, ទើបសមគួរ ។

បុរោហិតបានគិតឃើញថា ប្រសិនបើយើង ឱ្យចាប់យកតែជំពូកម្រឹគប៉ុណ្ណោះ, ជនទាំងឡាយក៏នឹងនិយាយថា បុរោហិតឱ្យចាប់យកតែសត្វដែលជារបស់ស៊ីបានសម្រាប់ខ្លួនប៉ុណ្ណោះ ព្រោះហេតុនោះ ទើបឱ្យចាប់ជំពូកជីវី សេះ និងមនុស្ស ( ផង ) ។

ព្រះរាជា ទ្រង់ព្រះតម្រិះថា ជីវិតរបស់យើងជារបស់សំខាន់ ទើបត្រាស់ថា ម្នាលអាចារ្យ លោកចូរចាប់សត្វគ្រប់ប្រភេទឱ្យប្រញាប់ ៗ ។ បុរោហិតបានទទួលព្រះរាជបញ្ជាអំពីព្រះរាជាហើយ ក៏ចាប់មនុស្សយ៉ាងច្រើនសន្ធឹកសន្ធាប់ ។

## បាលីកោសលសំយុត្ត

ពិតណាស់ ព្រះធម្មសង្គាហកាចារ្យ បានពោលពាក្យនេះទុកក្នុង**កោសលសំយុត្ត**ថា ក្នុងសម័យនោះ ព្រះបាទបសេនទិកោសល តាំងផ្តើមធ្វើនូវមហាយញ្ញ ( ជាធំ ) ។ ពួកគោឧសភៈ ៥០០ កូនគោឈ្មោល ៥០០ កូនគោញី ៥០០ ពពែ ៥០០ ចៀម ៥០០ ត្រូវគេនាំទៅចងជាប់នឹងសសរយញ្ញដើម្បីបូជា ។ ពួកជនណា ដែលជាខ្ញុំប្រុសក្តី ជាអ្នកបម្រើការងារក្តី ជនទាំងនោះ ត្រូវអាជ្ញាគំរាម-

ហើយ ត្រូវភ័យគំរាមហើយ ក៏មានមុខទទឹកជោកដោយទឹកភ្នែក ស្រែកយំ ធ្វើនូវបរិកម្មទាំងឡាយ ( ការខ្សឹកខ្សួល ) ។

## ព្រះនាងមល្លិកាទ្រង់ដោះទុក្ខរបស់សត្វ

មហាជន ទូញយំរៀបរាប់ដល់ញាតិរបស់ខ្លួន បានធ្វើនូវ-សំឡេងដ៏លាន់ឮយ៉ាងខ្លាំង សំឡេងនោះ ដូចជាសំឡេងស្រុតផែនដី។

គ្រានោះ ព្រះនាងមល្លិកាទេវី ទ្រង់បានឮសំឡេងនោះហើយ ស្តេចទៅកាន់រាជដំណាក់ទូលសួរព្រះរាជាថា បពិត្រមហារាជ ព្រោះហេតុដូចម្តេច បានជាឥន្ទ្រិយរបស់ព្រះអង្គមិនតាំងនៅជាប្រក្រតី , ព្រះអង្គមើលទៅហាក់ដូចជាមិនស្រួលព្រះកាយ ។

ព្រះរាជា. ម្នាលនាងមល្លិកា នាងមិនបានដឹងថា អាសិរពិស ចូលមកជិតព្រះកាណ៌ ( ត្រចៀក ) របស់យើងទេឬ ?

មល្លិកា. បពិត្រមហារាជ ហេតុហ្នឹង តើដូចម្តេច ?

ព្រះរាជា. ក្នុងចំណែកនៃរាត្រី យើងបានឮសំឡេងបែបនេះ, ទើបយើងសួរបុរោហិត បុរោហិតក៏ឆ្លើយប្រាប់យើងថា អន្តរាយនៃ-ជីវិតនឹងប្រាកដដល់ព្រះអង្គ, ព្រះអង្គទ្រង់បូជាយញ្ញដោយមានសត្វ ១ ប្រភេទ ៗ ១០០ គ្រប់ប្រភេទហើយ នឹងរួចផុតអំពីអន្តរាយនៃជីវិតបាន, ម្នាលនាងមល្លិកា យើងបានគិតឃើញថា ជីវិតការរស់នៅរបស់យើងប៉ុណ្ណោះ គឺជាលាភរបស់យើង ទើបយើងបញ្ជាបុរោហិតឱ្យ

ចាប់សត្វទាំងឡាយនេះទុកដើម្បីបូជាយញ្ញ ។

ព្រះនាងមល្លិកាទេវីក្រាបទូលថា បពិត្រមហារាជ ព្រះអង្គជាមនុស្សអន្ធពាល ទ្រង់ជាអ្នកមានភិក្ខាហារដ៏ច្រើន ព្រះអង្គរមែង-សោយនូវភោជនដែលគេចម្អិនដោយអង្ករទាំងនាឡិ ៗ មានសម្ល និងម្ហូបច្រើនបែបសព្វយ៉ាង ព្រះអង្គគ្រងរាជ្យក្នុងដែនទាំងពីរក៏ពិតមែនហើយ ប៉ុន្តែបញ្ញារបស់ព្រះអង្គនៅទន់ខ្សោយណាស់ ។

ព្រះរាជាទ្រង់សួរព្រះនាងមល្លិកាថា ម្នាលនាងដ៏ចម្រើន ព្រោះហេតុដូចម្តេច ទើបនាងពោលយ៉ាងនេះ ។

ព្រះនាងមល្លិកាក្រាបទូលព្រះរាជាថា ការបានជីវិតរបស់អ្នក-ដទៃ ព្រោះការស្លាប់របស់អ្នកដទៃ ព្រះអង្គធ្លាប់ឃើញក្នុងទីណា ? ព្រោះហេតុអ្វី ទើបព្រះអង្គទ្រង់ជឿពាក្យរបស់ព្រាហ្មណ៍អន្ធពាល ហើយទ្រង់ឱ្យនូវទុក្ខទៅលើមហាជនយ៉ាងនេះ ? ព្រះសាស្តា ទ្រង់-ជាអគ្គបុគ្គលនៃលោក ព្រមទាំងទេវលោក មានព្រះញាណមិនទើសទាក់ក្នុងកាលទាំងឡាយ មានអតីតកាលជាដើម ទ្រង់គង់នៅក្នុងវិហារដ៏ជិត, ព្រះអង្គទូលសួរព្រះសាស្តាហើយ សូមទ្រង់ធ្វើតាមព្រះឱវាទ របស់ព្រះអង្គចុះ ។

គ្រានោះឯង ព្រះរាជា ស្តេចយាងទៅកាន់វិហារជាមួយនឹងព្រះនាងមល្លិកា ដោយយានដ៏ស្រាល ៗ ទ្រង់ត្រូវមរណភ័យគំរាម-

កំហែង ក៏មិនអាចត្រាស់នូវព្រះបន្ទូលអ្វី ៗ បាន ថ្វាយបង្គំព្រះសាស្តា ហើយ ទ្រង់គង់ក្នុងទីដ៏សមគួរមួយ ។

គ្រានោះ ព្រះសាស្តាទ្រង់ត្រាស់ទៅកាន់ព្រះរាជាមុនថា បពិត្រមហារាជ មានហេតុអ្វី ទើបមហាបពិត្រយាងមកកាន់សម្នាក់តថាគត ទាំងថ្ងៃ អ៊ីចឹង ?

ព្រះរាជាក៏ទ្រង់គង់នៅស្ងៀម ។ គ្រានោះ ព្រះនាងមល្លិកាក្រាបទូលព្រះមានព្រះភាគថា បពិត្រព្រះអង្គដ៏ចម្រើន បានឮថា ព្រះរាជាទ្រង់បានឮសំឡេងដ៏អាក្រក់ក្នុងចន្លោះនៃមជ្ឈិមយាម, កាលបើដូច្នោះ ព្រះរាជាក៏ទ្រង់ប្រាប់ហេតុនោះដល់បុរោហិត, បុរោហិតក៏ក្រាបទូលថា អន្តរាយនៃជីវិតនឹងមានដល់ព្រះអង្គ, កាលបើព្រះអង្គចាប់សត្វមួយប្រភេទ ៗ ១០០ គ្រប់ប្រភេទ បូជាយញ្ញដោយលោហិតក្នុងបំពង់ក.នៃសត្វទាំងនោះ ដើម្បីការពារនូវអន្តរាយនោះ, ព្រះអង្គនឹងបាននូវព្រះជន្ម, ព្រះរាជាត្រាស់បញ្ជាឱ្យចាប់សត្វជាច្រើន ព្រោះ-ហេតុនោះ ទើបខ្ញុំព្រះអង្គនាំព្រះរាជាមកកាន់សម្នាក់ព្រះអង្គ ។

ព្រះសាស្តា. បពិត្រមហារាជ យ៉ាងនោះពិតមែនឬ ?

ព្រះរាជា. បពិត្រព្រះអង្គដ៏ចម្រើន ពិតមែន ។

ព្រះសាស្តា. សំឡេងដែលមហារាជទ្រង់បានឮហើយនោះតើដូចម្តេច ?

ព្រះរាជាក្រាបទូលដោយទំនងដែលព្រះអង្គទ្រង់ឮបាន ។

ពន្លឺតែមួយបានប្រាកដដល់ព្រះតថាគត ព្រោះទ្រង់ព្រះ-សណ្ដាប់នូវសេចក្ដីនោះ ។

គ្រានោះ ព្រះសាស្ដា ទ្រង់ត្រាស់ទៅកាន់ព្រះរាជាថា បពិត្រ-មហារាជ ព្រះអង្គកុំទ្រង់ខ្លាចឡើយ អន្តរាយនៃជីវិតមិនមានដល់ព្រះអង្គទេ, សត្វទាំងឡាយដែលជាអ្នកមានកម្មដ៏លាមក កាលធ្វើទុក្ខរបស់ខ្លួនឱ្យប្រាកដច្បាស់ ទើបពោលយ៉ាងនេះ ។

ព្រះរាជាទូលសួរព្រះសាស្ដាថា បពិត្រព្រះអង្គដ៏ចម្រើន ក៏-កម្មអ្វីខ្លះ ? ដែលសត្វទាំងនោះបានធ្វើទុកហើយ ?

## ព្រះសាស្ដាទ្រង់សម្ដែងទោសបរទារិកកម្ម

ព្រះសាស្ដា កាលនឹងទ្រង់សម្ដែងកម្មរបស់សត្វនរកទាំងនោះ ក៏ទ្រង់ត្រាស់ថា បពិត្រមហារាជ បើដូច្នោះ សូមមហារាជទ្រង់ស្ដាប់ដោយសេចក្ដីគោរពចុះ ហើយទ្រង់នាំអតីតនិទានមកសម្ដែងដូចតទៅ

**ក្នុងអតីតកាល** កាលមនុស្សមានអាយុ ២ ម៉ឺនឆ្នាំ ព្រះមាន-ព្រះភាគព្រះនាម **កស្សបៈ** ទ្រង់កើតឡើងក្នុងលោក ស្ដេចត្រាច់ទៅកាន់ទីចារិក មួយអន្លើដោយព្រះខីណាស្រព ២ ម៉ឺនអង្គ បានស្ដេចទៅកាន់ក្រុងពារាណសី ។

អ្នកក្រុងពារាណសី ២ នាក់ខ្លះ ៣ នាក់ខ្លះ ច្រើននាក់ខ្លះ

រួមគ្នាជាពួក ញ៉ាំងអាគន្តុកទានឱ្យប្រព្រឹត្តទៅ ។ ក្នុងកាលនោះ ក្នុង-ក្រុងពារាណសីមានសេដ្ឋីបុត្រ ៤ នាក់ មានសម្បត្តិ ៤០ កោដិ ជាសម្លាញ់នឹងគ្នា សេដ្ឋីបុត្រទាំងនោះ ប្រឹក្សាគ្នាថា ក្នុងផ្ទះរបស់ពួក-យើង មានទ្រព្យច្រើនណាស់ ពួកយើងនឹងធ្វើនូវអ្វីដោយទ្រព្យនោះ ។

កាលព្រះពុទ្ធដ៏មានព្រះភាគ ស្ដេចត្រាច់ទៅកាន់ទីចារិក បណ្ដាសេដ្ឋីបុត្រទាំងនោះមិនបានពោលថា ពួកយើងនឹងឱ្យនូវទាន នឹងធ្វើនូវការបូជា នឹងរក្សាសីល សេដ្ឋីបុត្រម្នាក់ពោលយ៉ាងនេះមុនថា ពួកយើងផឹកសុរាដ៏ខ្លាំង ទំពាស៊ីសាច់ដ៏ឆ្ងាញ់ ការរស់នៅរបស់យើងបែបនេះ ជាការរស់នៅប្រព្រឹត្តទៅមួយអន្លើដោយផល ជាជីវិតដ៏ប្រសើរ ។

ម្នាក់ទៀតពោលយ៉ាងនេះថា ពួកយើងនឹងបរិភោគភត្តនៃ-អង្ករស្រូវសាលី មានក្លិនក្រអូបដែលគេទុកដាក់អស់ ៣ ឆ្នាំហើយ ដោយរសដ៏ប្រណីតផ្សេង ៗ ត្រាច់ទៅ ។

ម្នាក់ទៀតពោលយ៉ាងនេះថា ពួកយើងនឹងឱ្យគេចម្អិនរបស់ដែលគួរទំពាស៊ីដ៏ត្រកាលមានប្រការផ្សេង ៗ បរិភោគ ។

ម្នាក់ទៀតពោលយ៉ាងនេះថា ម្នាលសម្លាញ់ ពួកយើងមិនចាំបាច់ធ្វើនូវកិច្ចអ្វីដទៃទេ ស្ត្រីទាំងឡាយ កាលយើងពោលថា នឹងឱ្យទ្រព្យ, ដែលឈ្មោះថាមិនប្រាថ្នា រមែងមិនមាន, ព្រោះហេតុនោះ

ពួកយើងរួបរួមទ្រព្យទុកហើយ នឹងល្បួង ( ស្ត្រី ) ធ្វើបរទារិកកម្ម ( ការប្រព្រឹត្តខុសចំពោះភរិយារបស់បុរសដទៃ ) ។

សេដ្ឋីបុត្រទាំងអស់ ទទួលយល់ព្រមដោយពាក្យថា សាធុ សាធុ ប្រពៃហើយ ១ បានតាំងនៅក្នុងពាក្យរបស់សេដ្ឋីបុត្រទី ៤ នោះ ។

ចាប់ផ្តើមអំពីកាលនោះមក សេដ្ឋីបុត្រទាំងនោះបានបញ្ជូនទ្រព្យទៅឱ្យស្ត្រីដែលមានរូបស្អាត ១ ធ្វើនូវបរទារិកកម្មអស់ ២ ម៉ឺនឆ្នាំ ធ្វើកាលកិរិយាហើយ កើតក្នុងអវិចីនរក ។

សេដ្ឋីបុត្រទាំងនោះ ឆេះក្នុងនរកអវិចីអស់មួយចន្លោះព្រះពុទ្ធ រួចអំពីនរកអវិចីនោះហើយ ដោយសេសសល់កម្ម ក៏កើតក្នុងលោហ-កុម្ភីនរក ដែលមានជម្រៅ ៦០ យោជន៍ ( លិចចុះ ) ដល់ផ្ទៃខាងក្រោម ៣ ម៉ឺនឆ្នាំ ( អណ្តែតឡើងមក ) ទំរាំដល់កណ្តាប់មាត់ខ្ទះអស់រយៈពេល ៣ ម៉ឺនឆ្នាំទៀត មានសេចក្តីប្រាថ្នានឹងពោលនូវគាថាម្នាក់មួយគាថា ( ប៉ុន្តែ ) មិនអាចពោលបាន ពោលបានតែអក្សរមួយម្នាក់ ហើយក៏លិចចុះទៅកាន់ខ្ទះដែកដូចដើមវិញ ។

បពិត្រមហារាជ ព្រះអង្គត្រាស់ប្រាប់មកមើល តើសំឡេងដែលព្រះអង្គទ្រង់ឮលើកដំបូងនោះដូចម្តេច ?

ព្រះរាជា. បពិត្រព្រះអង្គដ៏ចម្រើន សំឡេងថា **ទុ.** ។

ព្រះសាស្តា កាលនឹងត្រាស់សម្តែងគាថាដែលសត្វនរកនោះមានបំណងនឹងពោល ទើបត្រាស់យ៉ាងនេះថា :

**ទុជ្ជីវិតមជីវម្ហ យេ សន្តេ ន ទទម្ហសេ**
**សន្តេសុ ទេយ្យធម្មេសុ ទីបំ នាកម្ហមត្តនោ [១] ។**

*ពួកយើងរស់នៅដោយលំបាក ព្រោះទេយ្យធម៌មាន យើងមិនបានឱ្យ កាលទេយ្យធម៌មាន យើងមិនបានធ្វើទីពឹងដល់ខ្លួនសោះ ។*

គ្រានោះ ព្រះសាស្តា លុះទ្រង់ប្រកាសនូវអត្ថនៃគាថានេះដល់ព្រះរាជាហើយ ក៏ទ្រង់ត្រាស់សួរថា មហាបពិត្រ សំឡេងទី ២, ៣, ៤ តើព្រះអង្គទ្រង់ព្រះសណ្តាប់យ៉ាងណា ? កាលព្រះរាជាទូល-ថា បពិត្រព្រះអង្គដ៏ចម្រើន ខ្ញុំព្រះអង្គបានឮយ៉ាងនេះ កាលនឹងទ្រង់ញុំាងអត្ថដ៏សេសឱ្យបរិបូណ៌ ទើបត្រាស់ ( គាថា ) ថា :

**សដ្ឋីវស្សសហស្សានិ បរិបុណ្ណានិ សព្វសោ**
**និរយេ បច្ចមានានំ កទា អន្តោ ភវិស្សតិ ។**

*ពួកយើងឆេះនៅក្នុងនរកពេញប្រាំមួយម៉ឺន ( ៦០.០០០ ) ឆ្នាំគ្រប់គ្រាន់ តើទីបំផុតនឹងមានក្នុងវេលាណា ។*

---

*១= ក្នុងច្បាប់ឆដ្ឋសង្គាយនាថា* ***វិជ្ជមានេសុ ភោគេសុ, ទីបំ នាកម្ហ អត្តនោ ។***

**នត្ថិ អន្តោ កុតោ អន្តោ ន អន្តោ បដិទិស្សតិ**

**តទា ហិ បកតំ បាបំ មម តុយ្ហញ្ច មារិស[១] ។**

*ពួកយើងមិនមានទីបំផុតទេ ពួកយើងនឹងមានទីបំផុតមកពីណា ទីបំផុតនឹងមិនប្រាកដដល់យើងឡើយ ម្នាលអ្នក ព្រោះតែខ្ញុំក្តី អ្នកក្តី បានធ្វើបាប ។*

**សោ ហិ[២] នូន ឥតោ គន្ត្វា យោនឹ លទ្ធាន មានុសឹ**

**វទញ្ញូ សីលសម្បន្នោ កាហាមិ កុសលំពហុំ ។**

*ប្រសិនបើខ្ញុំ បានរដោះរួចចាកនរកនេះទៅ បានកើតជាមនុស្ស សូមជាអ្នកបរិបូណ៌ដោយសីល ធ្វើកុសលឱ្យច្រើន អំពីកាលដឹងក្តីទៅ ។*

ព្រះសាស្តា លុះទ្រង់ត្រាស់ព្រះគាថាទាំងនេះដោយលំដាប់ហើយ ទើបទ្រង់ត្រាស់ថា ថ្វាយព្រះពរមហាបពិត្រ ជនទាំង ៤ នាក់នោះ ជាអ្នកប្រាថ្នានឹងពោលគាថាមួយម្នាក់ ប៉ុន្តែមិនអាចពោលបាន ពោលបានតែម្នាក់មួយអក្សរប៉ុណ្ណោះ ក៏លិចចូលទៅកាន់ខ្ទះដែកដូចដើមវិញទៀត ។

បានឮថា ចាប់តាំងអំពីកាលដែលព្រះរាជា **ព្រះនាមបសេន-**

---

*១. ក្នុងច្បាប់ឆដ្ឋសង្គាយនាថា **តទា ហិ បកតំ បាបំ , មម តុយ្ហញ្ច មារិសា** ។*

*២. ច្បាប់ឆដ្ឋសង្គាយនាថា **សោហំ** ។*

**ទិកោសល** ទ្រង់ព្រះសណ្ដាប់នូវសំឡេងនោះមករហូតដល់សព្វថ្ងៃនេះ ជនទាំងនោះកំពុងលិចទៅខាងក្រោម មិនទាន់ដល់បាតខ្ទះនៅឡើយ ។

សេចក្ដីតក់ស្លុតយ៉ាងខ្លាំង បានកើតឡើងដល់ព្រះរាជា ព្រោះទ្រង់ព្រះសណ្ដាប់នូវទេសនានោះ ។

ព្រះរាជាទ្រង់ព្រះចិន្ដាថា ដែលឈ្មោះថា **បរទារិកកម្ម** នេះមានទោសធ្ងន់ណាស់ហ្ន៎, បានឮថា ជនទាំង ៤ នាក់ ឆេះហើយក្នុងអវិចីនរកអស់រយៈកាលមួយចន្លោះព្រះពុទ្ធ រួចចាកអវិចីនរកនោះហើយ កើតក្នុងលោហកុម្ភីនរក ដែលមានជម្រៅ ៦០ យោជន៍ ឆេះក្នុងលោហកុម្ភីនោះអស់ ៦ ម៉ឺនឆ្នាំ សូម្បីយ៉ាងនេះហើយក៏-ដោយ កាលដែលជាទីផុតចាកទុក្ខនៃជនទាំងនោះនៅមិនទាន់ប្រាកដ, ចំណែកយើងមានសេចក្ដីស្នេហាក្នុងភរិយារបស់អ្នកដទៃ មិនបាននូវ-ការលក់អស់រាត្រីទាំងមូល, ឥឡូវនេះ ចាប់ផ្ដើមអំពីកាលនេះទៅ យើងនឹងមិនចងចិត្តក្នុងលួចស្នេហ៍នឹងស្ត្រី ដែលជាភរិយារបស់បុរសដទៃទៀតឡើយ ទើបក្រាបទូលព្រះតថាគតថា បពិត្រព្រះអង្គដ៏-ចម្រើន ខ្ញុំព្រះអង្គទើបតែបានដឹងនូវភាវៈនៃរាត្រីជាវេលាដ៏វែងក្នុងថ្ងៃនេះឯង ។

ចំណែកបុរសនោះ ក៏អង្គុយនៅក្នុងទីនោះដែរ ស្ដាប់ពាក្យ-

នោះហើយ គិតថា បច្ច័យដ៏មានកម្លាំង យើងបានហើយ ទើបក្រាប-ទូលព្រះសាស្តាថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះរាជាទ្រង់ដឹងនូវភាវៈនៃរាត្រីជាវេលាដ៏វែងក្នុងថ្ងៃនេះ ចំណែកខ្ញុំព្រះអង្គបានដឹងនូវភាវៈនៃយោជន៍មានប្រមាណដ៏វែងឆ្ងាយ អំពីថ្ងៃម្សិល ។

ព្រះសាស្តា ទ្រង់ប្រៀបផ្ទឹមនូវសម្តីនៃជនទាំងពីររូបនោះហើយ ត្រាស់ថា រាត្រីនៃបុគ្គលរូបខ្លះ ជាវេលាដ៏វែង, យោជន៍នៃ-បុគ្គលរូបខ្លះ ជាប្រមាណដ៏ឆ្ងាយ ចំណែកសង្សារវដ្តរបស់បុគ្គលពាលរមែងជាសភាពដ៏វែង កាលនឹងទ្រង់បន្តអនុសន្ធិដើម្បីសម្តែងធម៌ទើបត្រាស់ព្រះគាថានេះថា :

**ទីឃា ជាគរតោ រត្តិ ទីឃំ សន្តស្ស យោជនំ**
**ទីឃោ ពាលាន[១] សំសារោ សទ្ធម្មំ អវិជានតំ ។**

រាត្រីវែង ចំពោះតែអ្នកភ្ញាក់រឭក ( អ្នកដេកមិនលក់ ) យោជន៍វែង ចំពោះតែអ្នកនឿយហត់ សង្សារវដ្តវែង ចំពោះតែបុគ្គលពាលមិនដឹងច្បាស់នូវព្រះសទ្ធម្ម ។

## អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា **ទីឃា** ជាដើម សេចក្តីថា ដែលឈ្មោះថា **រាត្រី** មានត្រឹមតែបីយាមប៉ុណ្ណោះ, ប៉ុន្តែសម្រាប់អ្នកភ្ញាក់

១-ច្បាប់ឆដ្ឋសង្គាយនា និងអដ្ឋកថាថា **ពាលានំ** ។

( ដេកមិនលក់ ) ដូចជាវែង គឺថា រមែងប្រាកដដូចជាគុណនឹងពីរ ឬគុណនឹងបី, បុគ្គលដែលខ្ជិលច្រអូស គ្មានសេចក្ដីព្យាយាម ធ្វើខ្លួនឱ្យជាចំណីនៃពួកសង្កើច ដេកប្រែប្រួល ៗ រហូតដល់ព្រះអាទិត្យរះឡើងក្ដី បុគ្គលអ្នកសេពកាម បរិភោគភោជនដ៏ប្រណីត ហើយដេកលើទីដ៏មានសិរីក្ដី រមែងមិនដឹងនូវភាវៈនៃរាត្រីនោះជាវេលាដ៏វែង, ចំណែកព្រះយោគាវចរ អ្នកប្រារព្ធនូវសេចក្ដីព្យាយាមរហូតអស់រាត្រីទាំងមូលក្ដី អ្នកដែលត្រូវរោគទាំងឡាយ មានរោគក្នុងក្បាលជាដើមពាល់ត្រូវហើយ ឬអ្នកដល់នូវសេចក្ដីទុក្ខ មានការកាត់ដៃជើងជាដើមត្រូវវេទនាគ្របសង្កត់ក្ដី អ្នកដើរផ្លូវឆ្ងាយ ដើររហូតអស់រាត្រីទាំង-មូលក្ដី រមែងដឹងនូវភាវៈនៃរាត្រីនោះជាវេលាដ៏វែង ។

បទថា **យោជនំ** ជាដើម សេចក្ដីថា សូម្បីយោជន៍ក៏មានប្រមាណត្រឹមតែ ៤ គាវុតប៉ុណ្ណោះ ក៏ប៉ុន្តែ សម្រាប់បុគ្គលអ្នកនឿយហត់ គឺអ្នកស្បើយកម្លាំង ដូចជាវែងឆ្ងាយ គឺថា រមែងប្រាកដដល់បុគ្គលនោះដូចជាគុណនឹងពីរ ឬនឹងបី ។

ដូចយ៉ាងថា បុគ្គលអ្នកទៅកាន់ផ្លូវឆ្ងាយ ធ្វើដំណើរអស់ពេញមួយថ្ងៃ នឿយហត់ហើយ ជួបបុរសដែលធ្វើដំណើរបញ្ច្រាសទិសគ្នាក៏សួរថា ស្រុកខាងមុខនៅឆ្ងាយប៉ុន្មាន ? កាលគេប្រាប់ថា មួយ-យោជន៍ ដើរទៅបានបន្តិច ក៏សួរអ្នកដទៃទៀត សូម្បីកាលអ្នកដទៃ

នោះប្រាប់ថា មួយយោជន៍ ដើរទៅបានបន្តិចទៀត ក៏សួរអ្នកដទៃ-ទៀត, សូម្បីគេក៏ប្រាប់ថា មួយយោជន៍ បុគ្គលទាំងនោះ ត្រូវអ្នក-ដំណើរនោះសួរហើយសួរទៀត ក៏ប្រាប់ថា មួយយោជន៍ អ្នកដំណើរនោះគិតថា យោជន៍នេះពិតមែនហ្ន៎ រមែងសម្គាល់មួយយោជន៍ ដូចជា ២-៣ យោជន៍ ។

បទថា **ពាលានំ** ជាដើម សេចក្តីថា ចំណែកសង្សារវដ្តរបស់ជនពាលទាំងឡាយ ដែលជាអ្នកមិនដឹងនូវប្រយោជន៍ក្នុងលោកនេះ និងប្រយោជន៍ក្នុងលោកខាងមុខ គឺអ្នកមិនអាចធ្វើនូវទីបំផុតនៃ-សង្សារវដ្ត អ្នកមិនដឹងច្បាស់នូវព្រះសទ្ធម្ម មានពោធិបក្ខិយធម៌ ៣៧ ប្រការជាដើម ដែលព្រះអរិយទាំងឡាយដឹងច្បាស់ហើយ ធ្វើនូវទី-បំផុតនៃសង្សារវដ្តបាន រមែងឆ្ងាយ ។ ពិតណាស់ សង្សារវដ្តនោះ រមែងវែងឆ្ងាយ តាមធម្មតារបស់ខ្លួនឯង ។

សមដូចព្រះពុទ្ធវចនៈ ដែលព្រះមានព្រះភាគត្រាស់ទុកថា "**ម្នាលភិក្ខុទាំងឡាយ សង្សារវដ្តនេះ មានទីបំផុតដែលបុគ្គលណា ១ ដឹងមិនបាន ទីបំផុតខាងដើម ខាងចុង ( នៃសង្សារវដ្តនោះ ) រមែងមិនប្រាកដ** " ។ ប៉ុន្តែសម្រាប់ជនពាលទាំងឡាយ ដែលជាអ្នកមិនអាចធ្វើនូវទីបំផុតនៃសង្សារវដ្តបាន រមែងជាសភាពដ៏វែងក្រៃពេកមែន-ពិត ។

ក្នុងកាលចប់ព្រះធម្មទេសនា បុរសនោះក៏បានសម្រេចសោ-តាបត្តិផល សូម្បីជនដទៃជាច្រើន ក៏បានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ព្រះធម្មទេសនាមានប្រយោជន៍ដល់មហាជនដោយប្រការដូច្នេះឯង ។

ព្រះរាជាថ្វាយបង្គំព្រះសាស្តាហើយ ស្តេចយាងទៅកាន់ព្រះ-រាជវាំងវិញ លុះស្តេចយាងទៅដល់ព្រះរាជវាំងភ្លាម ក៏ត្រាស់ឱ្យដោះលែងសត្វទាំងនោះអំពីចំណង ។

បណ្តាមនុស្ស និងសត្វទាំងនោះ ស្ត្រី និងបុរសទាំងឡាយ ផុតអំពីចំណង ងូតទឹក កក់ក្បាលហើយ ទៅកាន់ផ្ទះរបស់ខ្លួន ៗ ពោលសរសើរព្រះគុណ**នាងមល្លិកា**ថា យើងទាំងឡាយ រួចផុតពីសេចក្តីស្លាប់ បានរស់រានមានជីវិត ព្រោះអាស្រ័យព្រះទេវីអង្គណា សូមព្រះនាងមល្លិកាទេវីអង្គនោះ ដែលជាព្រះមេម្ចាស់របស់យើងទាំងឡាយ សូមទ្រង់មានព្រះជន្មយឺនយូរចុះ ។

ក្នុងវេលាល្ងាច ភិក្ខុទាំងឡាយសន្ទនាគ្នាក្នុងរោងធម្មសភាថា ម្នាលអ្នកដ៏មានអាយុទាំងឡាយ " គួរសរសើរពិតមែន ! ព្រះនាង-មល្លិកាជាបណ្ឌិតពិតមែនហ្ន៎ ទ្រង់អាស្រ័យព្រះបញ្ញារបស់ខ្លួនហើយ បានឱ្យនូវជីវិតទានដល់មហាជនមានប្រមាណប៉ុណ្ណោះ " ។

**ព្រះនាងមល្លិកាធ្លាប់ជួយអ្នកដទៃឱ្យរួចផុត-**

# ចាកទុក្ខក្នុងជាតិមុន

ព្រះសាស្តាស្តេចមកហើយ ត្រាស់សួរថា ម្នាលភិក្ខុទាំងឡាយ ឥឡូវនេះ អ្នកទាំងឡាយអង្គុយប្រជុំនិយាយអំពីរឿងអ្វី ? កាលភិក្ខុ-ទាំងនោះក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន អំពីរឿងឈ្មោះនេះ ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ព្រះនាងមល្លិកា ទ្រង់អាស្រ័យព្រះបញ្ញារបស់ខ្លួនហើយ ឱ្យនូវជីវិតទានដល់មហាជន ក្នុងកាលឥឡូវនេះប៉ុណ្ណោះក៏ទេ, សូម្បីក្នុងកាលមុន ព្រះនាងក៏ធ្លាប់បានឱ្យហើយដែរ កាលទ្រង់ប្រកាសសេចក្តីនោះឱ្យប្រាកដច្បាស់ ទើបទ្រង់នាំអតីតនិទានមក ( ត្រាស់ ) ថា :

**ក្នុងអតីតកាល** ឱរសរបស់ព្រះរាជា**ក្រុងពារាណសី**ចូលទៅកាន់ដើមជ្រៃមួយដើមហើយ ទ្រង់បន់ស្រន់ទេវតាដែលអាស្រ័យនៅនាដើមជ្រៃនោះថា បពិត្រទេវតា ក្នុងជម្ពូទ្វីបនេះ មានព្រះរាជា ១០១ ព្រះអគ្គមហេសី ១០១, ប្រសិនបើខ្ញុំនឹងបានរាជសម្បត្តិក្នុងកាលកន្លងទៅនៃព្រះបិតាសោត, ខ្ញុំនឹងធ្វើនូវពលីកម្មដោយឈាមក្នុងបំពង់កនៃព្រះរាជា និងព្រះអគ្គមហេសីទាំងនោះ ។

ព្រះរាជកុមារនោះ កាលព្រះបិតាសោយទិវង្គតហើយ បានទទួលរាជសម្បត្តិ ( សមដូចព្រះបំណង ) ទ្រង់គិតថា យើងបានទទួលរាជសម្បត្តិដោយអានុភាពនៃទេវតា យើងនឹងធ្វើពលីដល់ទេវតានោះ

ទើបស្តេចចេញទៅដោយសេនាដ៏ធំ ញ៉ាំងព្រះរាជា ១ អង្គ ឱ្យប្រព្រឹត្ត ទៅក្នុងអំណាចរបស់ខ្លួនហើយ ធ្វើព្រះរាជាអង្គដទៃ និងអង្គដទៃ ទៀតឱ្យនៅក្នុងអំណាចរបស់ខ្លួន ធ្វើព្រះរាជាទាំងអស់ ឱ្យនៅក្នុង អំណាចរបស់ខ្លួនដោយប្រការដូច្នេះហើយ ទ្រង់នាំព្រះរាជា និងអគ្គ-មហេសីទាំងឡាយ ទ្រង់បន្សល់ទុកតែព្រះទេវីព្រះនាម **ធម្មទិន្នា** អ្នក ទ្រង់ព្រះគភ៌ចាស់ ដែលជាអគ្គមហេសីរបស់ព្រះរាជា ព្រះនាម **ឧគ្គសេន** ដែលជាព្រះរាជាអង្គតូចជាងព្រះរាជាទាំងពួងទុក ស្តេចទៅ ហើយ ទ្រង់ព្រះតម្រិះថា យើងនឹងឱ្យជនទាំងនេះ ផឹកទឹកលាយថ្នាំ ពិសឱ្យស្លាប់ ទើបបញ្ជាឱ្យជនទាំងឡាយជម្រះនូវគល់ឈើឱ្យស្អាត ។

ទេវតាគិតថា ព្រះរាជាអង្គនេះ កាលចាប់ព្រះរាជាប្រមាណ ប៉ុណ្ណេះ ទ្រង់អាស្រ័យយើងទើបចាប់, ព្រះរាជាទ្រង់ប្រាថ្នានឹងធ្វើនូវ-ពលីកម្មចំពោះយើង ដោយលោហិតក្នុងបំពង់ករបស់ព្រះរាជាទាំង នោះ, ក៏ប្រសិនបើព្រះរាជាអង្គនេះ នឹងសម្លាប់ព្រះរាជាទាំងនោះ សោត ព្រះរាជវង្សក្នុងជម្ពូទ្វីបនឹងដាច់សូន្យ, សូម្បីគល់ឈើរបស់ យើងក៏នឹងមិនស្អាត, យើងនឹងអាចហាមព្រះរាជានោះបានឬទេហ្ន៎ ? ទេវតានោះពិចារណាហើយក៏ដឹងថា យើងនឹងមិនអាចទើបចូលទៅ រកទេវតាអង្គដទៃ ប្រាប់សេចក្តីនោះហើយ ពោលថា លោកនឹង អាចឬ ? ទេវតានោះ ត្រូវទេវតា ( ដែលខ្លួនត្រូវសួរ ) នោះហាម

ហើយ, ក៏ចូលទៅរកទេវតាអង្គដទៃ និងអង្គដទៃ សូម្បីត្រូវទេវតាទាំងនោះប្រាប់ថា យើងមិនអាចហើយ ក៏ចូលទៅកាន់សម្នាក់របស់មហារាជទាំង ៤ សូម្បីមហារាជទាំង ៤ នោះ ក៏ហាមថា ពួកយើងមិនអាច, ប៉ុន្តែព្រះរាជារបស់យើងទាំងឡាយ ជាអ្នកវិសេសជាងពួកយើងដោយបុណ្យ និងបញ្ញា, អ្នកចូរទូលសួរព្រះរាជាអង្គនោះចុះ ដូច្នេះហើយ ទើបចូលទៅគាល់សក្កទេវរាជ ក្រាបទូលសេចក្តីនោះហើយ ទូលថា បពិត្រព្រះឧបបត្តិទេព កាលព្រះអង្គដល់នូវភាពជាអ្នកខ្វល់ខ្វាយតិចហើយ ខត្តិយវង្សនឹងដាច់សូន្យ, សូមព្រះអង្គទ្រង់ជាទីពឹងពំនាក់នៃខត្តិយវង្សនោះផង ។

សក្កទេវរាជត្រាស់ថា ស្ទូម្បីយើងក៏មិនអាចហាមព្រះរាជាអង្គនោះបានដែរ, ប៉ុន្តែយើងនឹងប្រាប់ឧបាយដល់អ្នក ហើយទ្រង់ប្រាប់ឧបាយថា ម្នាលអ្នកដ៏ចម្រើន អ្នកឯងទៅចុះ កាលព្រះរាជាទ្រង់ឃើញអ្នកនុ៎ះឯង អ្នកចូរស្លៀកសំពត់ពណ៌ក្រហម ហើយសម្តែងអាការដូចជាចេញចាកដើមឈើរបស់ខ្លួន, កាលអ្នកឯងធ្វើដូច្នោះព្រះរាជាអង្គនោះនឹងទ្រង់ព្រះតម្រិះថា ទេវតារបស់យើងទៅណា យើងនឹងញ៉ាំងទេវតានោះឱ្យត្រឡប់មកវិញ ហើយអង្វរអ្នកដោយប្រការផ្សេង ៗ, កាលបើដូច្នោះ អ្នកគប្បីពោលទៅកាន់ព្រះរាជាអង្គនោះថា លោកបន់ស្រន់បួងសួងចំពោះយើងថា នឹងនាំព្រះរាជា-

១០១ ព្រមទាំងអគ្គមហេសីទាំងឡាយ មកធ្វើពលីដោយលោហិតក្នុងបំពង់កនៃព្រះរាជាទាំងនោះ ( ប៉ុន្តែ ) ទ្រង់បន្សល់ទុកនូវព្រះ-ទេវីរបស់**ព្រះបាទឧគ្គសេន**ហើយស្តេចមក, យើងនឹងមិនទទួលពលីកម្មរបស់បុគ្គលអ្នកច្រើនទៅដោយការនិយាយកុហកដូចព្រះអង្គទេ, កាលអ្នកពោលយ៉ាងនេះ ព្រះរាជានឹងឱ្យនាំព្រះទេវីនោះមក, ព្រះទេវីនោះនឹងសម្តែងធម៌ដល់ព្រះរាជា ឱ្យនូវជីវិតទានដល់មហាជនមានប្រមាណប៉ុណ្ណេះ សក្កទេវរាជត្រាស់ប្រាប់ឧបាយនេះដល់ទេវតាដោយហេតុនេះ, ទេវតាបានធ្វើដូច្នោះ, សូម្បីព្រះរាជាក៏បញ្ជាឱ្យនាំព្រះរាជទេវីនោះមកដែរ ។

## ទេវតាបូជាព្រះនាងមល្លិកា

ព្រះទេវីនោះ មកហើយថ្វាយបង្គំព្រះរាជា ( ដែលជាស្វាមី ) របស់ខ្លួនប៉ុណ្ណោះ សូម្បីព្រះរាជាអង្គនោះគង់ក្នុងទីបំផុតនៃព្រះរាជាទាំងនោះក៏ដោយ ។

ព្រះរាជាទ្រង់ខ្ញាល់នឹងព្រះទេវីនោះថា កាលយើងដែលជាអ្នកប្រសើរជាងព្រះរាជាទាំងពួងឈរនៅទីនេះ នាងហ៊ានថ្វាយបង្គំស្វាមីរបស់ខ្លួន ដែលជាព្រះរាជាតូចបំផុតជាងព្រះរាជាទាំងពួង ។

គ្រានោះ ព្រះនាងធម្មទិន្នាទេវីក្រាបទូលព្រះរាជានោះថា រឿងអ្វីដែលខ្ញុំព្រះអង្គត្រូវទាក់ទងនឹងព្រះអង្គទៅ ? ក៏ព្រះរាជាអង្គ-

នេះ ជាស្វាមីអ្នកឱ្យនូវភាពជាធំដល់ខ្ញុំព្រះអង្គ, ខ្ញុំព្រះអង្គមិនថ្វាយបង្គំព្រះរាជាអង្គនេះហើយ នឹងថ្វាយបង្គំព្រះអង្គដូចម្ដេចទៅ ?

កាលព្រះរាជាទាំងនោះកំពុងឃើញនោះឯង រុក្ខទេវតាក៏-ពោលថា បពិត្រព្រះទេវីដ៏ចម្រើន យ៉ាងនោះពិតមែនហើយ បពិត្រព្រះទេវីដ៏ចម្រើន យ៉ាងនោះពិតមែនហើយ ហើយបូជាព្រះទេវីនោះដោយផ្កាឈើមួយក្ដាប់ ។ ព្រះរាជាត្រាស់ទៀតថា បើនាងមិនថ្វាយបង្គំយើងក៏ណ្ហើយទៅចុះ, ហេតុដូចម្ដេច ទើបនាងមិនថ្វាយបង្គំទេវតារបស់យើងអ្នកមានអានុភាពធំយ៉ាងនេះ អ្នកឱ្យនូវសិរី គឺភាវៈជាព្រះរាជាដល់យើងទៅ ?

ព្រះនាងធម្មទិន្នាទេវីក្រាបទូលព្រះរាជាថា បពិត្រមហារាជព្រះរាជាទាំងឡាយ ដែលព្រះអង្គទ្រង់ចាប់បាននោះ ព្រោះអាស្រ័យបុណ្យរបស់ព្រះអង្គ, មិនមែនទេវតាចាប់ថ្វាយព្រះអង្គទេ ។

ទេវតាពោលទៅកាន់ព្រះទេវីទៀតថា បពិត្រព្រះទេវីដ៏ចម្រើនយ៉ាងនោះពិតមែនហើយ បពិត្រព្រះទេវីដ៏ចម្រើន យ៉ាងនោះពិតមែនហើយ ហើយបូជាព្រះទេវីនោះដោយផ្កាឈើមួយក្ដាប់ទៀត ។

ព្រះទេវីនោះក្រាបទូលព្រះរាជាទៀតថា ព្រះអង្គត្រាស់ថាព្រះរាជាទាំងឡាយមានប្រមាណប៉ុណ្ណោះ ទេវតាទាំងឡាយចាប់ឱ្យយើង ។ ឥឡូវនេះ ដើមឈើត្រូវភ្លើងឆេះនៅខាងឆ្វេងខាងលើ

នៃទេវតារបស់ព្រះអង្គ, ព្រោះហេតុអ្វី ទើបទេវតានោះមិនអាចញ៉ាំង ភ្លើងនោះឱ្យរលត់បាន ? បើទេវតាមានអានុភាពច្រើនយ៉ាងនោះ ។

ទេវតាពោលនឹងព្រះទេវីទៀតថា បពិត្រព្រះទេវីដ៏ចម្រើន យ៉ាងនោះពិតមែនហើយ បពិត្រព្រះទេវីដ៏ចម្រើន យ៉ាងនោះពិតមែន ហើយ ហើយបូជាព្រះទេវីដោយផ្កាឈើមួយក្តាប់ទៀត ។

ព្រះទេវីទ្រង់មានព្រះសវនីយ៍ទាំងទ្រង់ព្រះកន្សែង ទាំងទ្រង់-សើច ។

គ្រានោះ ព្រះរាជាត្រាស់ទៅកាន់ព្រះទេវីនោះថា នាងជាស្ត្រីឆ្កួតឬ ?

ព្រះទេវី. បពិត្រមហារាជ ព្រោះហេតុអ្វី ទើបព្រះអង្គទ្រង់សួរយ៉ាងនេះ, ស្ត្រីទាំងឡាយប្រហែលដូចខ្ញុំម្ចាស់ មិនមែនជាស្ត្រី-ឆ្កួតទេ ។

ព្រះរាជា. បើដូច្នោះ ព្រោះហេតុអ្វី ទើបនាងយំផង សើចផង ?

ព្រះទេវីទូលថា បពិត្រមហារាជ សូមព្រះអង្គទ្រង់ព្រះ-សណ្តាប់ចុះ, **កាលពីជាតិមុន** ខ្ញុំម្ចាស់ជា**កុលធីតា** កាលទៅនៅក្នុង ត្រកូលស្វាមី ឃើញភ្ញៀវដែលជាសម្លាញ់របស់ស្វាមីមកហើយ ប្រាថ្នា នឹងដាំស្លដើម្បីភ្ញៀវនោះ ក៏ឱ្យកហាបណៈដល់នាងទាសី ដោយពាក្យ-

ថា ម្នាលនាងដ៏ចម្រើន នាងចូរទៅទិញសាច់មក កាលនាងទាសីនោះ ទៅទិញមិនបានសាច់ហើយត្រឡប់មកប្រាប់ថា បពិត្រនាង-ម្ចាស់ សាច់មិនមានទេ ក៏**កាត់ក្បាលមេពពែ**ដែលដេកនៅខាងក្រោយផ្ទះ ចាត់ចែងភត្ត ។ បពិត្រមហារាជ ខ្ញុំបានកាត់ក្បាលមេពពែមួយ ក្រោយអំពីស្លាប់ ត្រូវឆេះក្នុងនរកអស់មួយចន្លោះព្រះពុទ្ធ ដោយសេសសល់ផលនៃកម្ម ក៏ត្រូវបានគេ**កាត់ក្បាលដោយការរាប់ចំនួនរោមមេពពែនោះ** ។ ចុះបើព្រះអង្គសម្លាប់ជនមានប្រមាណប៉ុណ្ណេះ កាលណាទៅនឹងរួចផុតចាកទុក្ខបាន, ខ្ញុំម្ចាស់រឭកដល់ទុក្ខដ៏ធំរបស់ព្រះអង្គដូច្នេះ ទើបខ្ញុំព្រះអង្គយំ, ដូច្នេះហើយ ទើបត្រាស់ព្រះគាថានេះថា :

**ខ្ញុំកាត់ក្បាលមេពពែមួយ ឆេះហើយ ( ក្នុងនរក ) ដោយ**
**ការរាប់ចំនួនរោមនៃមេពពែ, បពិត្រមហារាជ ព្រះអង្គ**
**កាត់ក្បាលនៃមនុស្សដ៏ច្រើនយ៉ាងនេះ នឹងធ្វើដូចម្ដេចទៅ** ។

ព្រះរាជា. ចុះហេតុអ្វី បានជានាងសើច ?

ព្រះទេវី. បពិត្រមហារាជ ខ្ញុំម្ចាស់ត្រេកអរថា យើងរួចផុតចាកទុក្ខនោះហើយ, ទើបខ្ញុំព្រះអង្គសើច ។

ទេវតាពោលនឹងព្រះទេវីនោះទៀតថា បពិត្រព្រះទេវីដ៏ចម្រើន យ៉ាងនោះពិតមែនហើយ បពិត្រព្រះទេវីដ៏ចម្រើន យ៉ាងនោះពិតមែន

ហើយ ហើយបូជាព្រះទេវីដោយផ្កាឈើមួយក្តាប់ទៀត ។

ព្រះរាជាទ្រង់ព្រះតម្រិះថា ឱ គួរឱ្យតក់ស្លុតណាស់ ! កម្មរបស់យើងធ្ងន់ណាស់ បានឮថា ព្រះទេវីនេះ សម្លាប់មេពពែតែមួយ ត្រូវឆេះក្នុងនរកមួយចន្លោះព្រះពុទ្ធ ដោយសេសសល់ផលនៃ-កម្មត្រូវគេកាត់ក្បាលដោយការរាប់ចំនួនរោមនៃមេពពែនោះ, យើងសម្លាប់ជនមានប្រមាណប៉ុណ្ណេះ នឹងដល់នូវសិរីសួស្តីអំពីទីណា ? ដូច្នេះហើយ ទើបទ្រង់លែងព្រះរាជាទាំងអស់ថ្វាយបង្គំព្រះរាជាដែលចាស់ជាងខ្លួន ទ្រង់ផ្គងនូវអញ្ជលីចំពោះព្រះរាជាដែលក្មេងជាងខ្លួនញុំាងព្រះរាជាទាំងអស់ឱ្យអត់ទោសឱ្យហើយ ទ្រង់បញ្ជូនទៅកាន់នគររបស់ខ្លួន ៗ ដូចដើមវិញ ។

ព្រះសាស្តា លុះទ្រង់នាំព្រះធម្មទេសនានេះមកហើយ ទ្រង់-ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ព្រះនាងមល្លិកាអាស្រ័យព្រះបញ្ញារបស់ខ្លួន ប្រទាននូវជីវិតទានដល់មហាជនក្នុងកាលឥឡូវនេះក៏ទេ, សូម្បីក្នុងកាលមុន ព្រះនាងក៏ធ្លាប់បានប្រទានហើយដែរ ហើយទ្រង់ប្រជុំរឿងអតីតៈថា **ព្រះរាជាក្រុងពារាណសី** ក្នុងកាលនោះ បានមកជា**ព្រះបាទបសេនទិកោសល**, **ព្រះនាងធម្មទិន្នាទេវី** បានមកជាព្រះ-នាង**មល្លិកា**, **រុក្ខទេវតា** គឺ **តថាគត**នេះឯង ។

លុះទ្រង់ប្រជុំរឿងអតីតៈយ៉ាងនេះហើយ កាលនឹងទ្រង់សម្តែង

ធម៌តទៅទៀត ក៏ទ្រង់ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ដែលឈ្មោះថា បាណាតិបាត ជាធម៌មានទោស បុគ្គលមិនគប្បីធ្វើ, ព្រោះថា បុគ្គលអ្នកសម្លាប់សត្វជាប្រក្រតី រមែងសោកសៅអស់កាលយូរ ទើបត្រាស់ព្រះគាថានេះថា(១):

**ឯវញ្ចេ សត្តា ជានេយ្យុំ ទុក្ខាយំ ជាតិសម្ភវោ**
**ន បាណោ បាណិនំ ហញ្ញេ បាណឃាតី ហិ សោចតិ ។**

បើពួកសត្វគប្បីដឹងយ៉ាងនេះថា ការកើតនៃជាតិនេះ រមែងនាំមកនូវទុក្ខ សត្វមិនត្រូវសម្លាប់សត្វ ព្រោះថា បុគ្គលអ្នកសម្លាប់សត្វ រមែងសោយសោក ។

## ( ចប់រឿងបុរសម្នាក់ )

---

១- **មតកភត្តជាតក** ( បិដកលេខ ៥៨ ទំព័រ ៩ )

( **សូមលើកនូវមតកភត្តជាតកជាបន្ត :** )

# មតកភត្តជាតកទី ៨

( បិដកលេខ ៥៨, ទំព័រ ៩ និងអដ្ឋកថា )

ព្រះសាស្តា កាលព្រះអង្គគង់ប្រថាប់នៅក្នុងវត្តជេតពនមហា-វិហារ ទ្រង់ប្រារព្ធមតកភត្ត ទើបត្រាស់ព្រះធម្មទេសនានេះមានពាក្យផ្តើមថា **ឯវញ្ចេ សត្តា ជានេយ្យុំ** ដូច្នេះ ។

សេចក្តីពិស្តារថា ក្នុងកាលនោះមនុស្សទាំងឡាយ សម្លាប់ពពែជាដើម ជាច្រើនឱ្យមតកភត្តឧទ្ទិសដល់ពួកញាតិទាំងឡាយដែលស្លាប់ទៅហើយ ភិក្ខុទាំងឡាយ ឃើញមនុស្សពួកនោះធ្វើយ៉ាងនោះ ទើបទូលសួរព្រះសាស្តាថា បពិត្រព្រះអង្គដ៏ចម្រើន ឥឡូវនេះមនុស្ស-ទាំងឡាយធ្វើសត្វមានជីវិតជាច្រើនឱ្យដល់នូវសេចក្តីស្លាប់ ហើយឱ្យឈ្មោះថា **មតកភត្ត** សេចក្តីចម្រើនក្នុងការឱ្យមតកភត្តនេះមានដែរឬព្រះអង្គ ? ព្រះសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ឈ្មោះថាសេចក្តីចម្រើនណាមួយក្នុងបាណាតិបាត សូម្បីដែលគេធ្វើដោយគិតថា ពួកយើងនឹងឱ្យនូវមតកភត្តដូច្នេះរមែងមិនមាន សូម្បីក្នុងកាលមុន បណ្ឌិតទាំងឡាយអង្គុយក្នុងអាកាសសម្តែងធម៌ពោលទោសក្នុង-

ការធ្វើបាណាតិបាតនេះ ឱ្យជនអ្នកជម្ពូទ្វីបទាំងអស់លះកម្មនោះ ប៉ុន្តែឥឡូវនេះ កម្មនោះត្រឡប់ប្រាកដកើតឡើងទៀត ព្រោះសត្វទាំង-ឡាយ ពួកនោះជាអ្នកនៅក្នុង**សង្ខេបនៃភព** [១] ហើយទ្រង់នាំអតីតនិទាន មកត្រាស់ដូចតទៅនេះ :

ក្នុងអតីតកាល កាលព្រះបាទព្រហ្មទត្តគ្រងរាជ្យសម្បត្តិក្នុងនគរពារាណសី មានអាចារ្យទិសាបាមោក្ខ អ្នកសម្រេចត្រៃវេទម្នាក់គិតថា នឹងឱ្យមតកភត្ត ទើបឱ្យចាប់ពពែមកមួយក្បាល ពោលដល់អន្តេវាសិកទាំងឡាយថា អ្នកទាំងឡាយ ពួកអ្នកចូរនាំពពែមួយក្បាលនេះទៅកាន់ស្ទឹង យកកម្រងផ្កាឈើពាក់ក យកម្សៅមកព្រោះព្រំហើយនាំមក អន្តេវាសិកទាំងឡាយទទួលពាក្យហើយនាំពពែនោះទៅកាន់ស្ទឹងឱ្យងូតទឹកប្រដាប់ហើយ សម្រាកទុកកន្លែងមាត់ស្ទឹង ពពែនោះឃើញកម្មចាស់របស់ខ្លួនកើតសេចក្ដីសោមនស្សសប្បាយថា យើងនឹងរួចផុតចាកទុក្ខ ដែលមានសភាពបែបនេះក្នុងថ្ងៃនេះ ទើបសើចលាន់ឮដូចវាយឆ្នាំងដី ត្រឡប់គិតថា ព្រាហ្មណ៍នេះសម្លាប់យើងហើយ នឹងបានសេចក្ដីទុក្ខដែលយើងបានហើយ កើតសេចក្ដីអាណិតព្រាហ្មណ៍ ទើបស្រែកយំដោយសំឡេងដ៏ខ្លាំង លំដាប់នោះ

*១- ក្នុងអភិធម្មត្ថសង្គហៈ បរិច្ឆេទទី ៨ សម្ដែងអំពីសង្ខេបថាមាន ៤ គឺ អវិជ្ជា និង សង្ខារ ជាសង្ខេប ១, វិញ្ញាណ នាមរូប សឡាយតនៈ ផស្សៈ វេទនា ជាសង្ខេប ១, តណ្ហា ឧបាទាន ភព ជាសង្ខេប ១, ជាតិ និងជរាមរណៈ ជាវិបាកវដ្ដៈ ជាសង្ខេប ១ ។*

មាណពពួកនោះ ទើបសួរពពែនោះថា ម្នាលពពែអ្នកជាសម្លាញ់ អ្នកសើចឬស្រែកយំសំឡេងលាន់ឮខ្លាំង ព្រោះហេតុអ្វីហ្ន៎ ! អ្នកទើបសើច និងព្រោះហេតុអ្វីអ្នកទើបស្រែកយំ ? ពពែនោះពោលថា អ្នកទាំងឡាយគប្បីសួរហេតុនេះដល់យើង ក្នុងសម្នាក់នៃអាចារ្យរបស់លោក មាណពពួកនោះទើបនាំពពែទៅហើយប្រាប់ហេតុនោះដល់អាចារ្យ អាចារ្យបានស្តាប់ពាក្យរបស់មាណពពួកនោះហើយ សួរពពែថា ម្នាលពពែ ព្រោះហេតុអ្វី អ្នកទើបសើច ព្រោះហេតុអ្វីអ្នកទើបយំ ? ពពែត្រឡប់រលឹកដល់កម្ម ដែលខ្លួនធ្វើដោយញាណ គ្រឿងរលឹកជាតិបាន ពោលដល់ព្រាហ្មណ៍ ម្នាលព្រាហ្មណ៍ កាលពីមុនយើងជាព្រាហ្មណ៍អ្នកស្វាធ្យាយមន្តដូចជាលោកនេះឯង គិតថានឹងឱ្យមតកភត្ត ទើបបានសម្លាប់ពពែមួយក្បាលហើយឱ្យមតកភត្ត ព្រោះយើងសម្លាប់ពពែមួយក្បាល យើងនោះទើបត្រូវគេកាត់ក្បាលអស់ **៤៩៩** អត្តភាពហើយ នេះជាអត្តភាពទី **៥០០** របស់យើង ដែលតាំងនៅក្នុងទីបំផុត យើងនោះកើតសេចក្តីរីករាយថា ថ្ងៃនេះយើងនឹងរួចផុតចាកទុក្ខដែលមានសភាពបែបនេះ ដោយហេតុនេះ ទើបយើងសើច ប៉ុន្តែកាលយើងយំ ព្រោះសេចក្តីអាណិតលោកដោយគិតថា ខាងដើមយើងសម្លាប់ពពែមួយក្បាល ដល់នូវសេចក្តីទុក្ខគឺការត្រូវកាត់ក្បាលរហូតដល់ទៅ ៥០០ ជាតិ នឹងរួចផុតចាកទុក្ខនោះថ្ងៃ

នេះ ចំណែកព្រាហ្មណ៍សម្លាប់យើងហើយ នឹងបានទទួលទុក្ខ គឺការត្រូវកាត់ក្បាលដល់ទៅ ៥០០ ជាតិ ដូចយើងដែរ ព្រាហ្មណ៍នោះពោលថា ម្នាលពពែអ្នកកុំខ្លាចឡើយ យើងនឹងមិនសម្លាប់អ្នក ពពែពោលថា ព្រាហ្មណ៍លោកនិយាយអ្វី កាលលោកនឹងសម្លាប់ក្តី មិន-សម្លាប់ក្តី ថ្ងៃនេះ យើងមិនអាចរួចផុតចាកសេចក្តីស្លាប់បានឡើយ ព្រាហ្មណ៍ពោលថា ម្នាលពពែអ្នកកុំខ្លាច យើងនឹងកាន់យកការរក្សា-អ្នក ត្រាច់ទៅជាមួយអ្នកប៉ុណ្ណោះ ពពែពោលថា ព្រាហ្មណ៍ការរក្សារបស់លោកមានប្រមាណតិច ចំណែកបាបដែលយើងធ្វើមានកម្លាំងច្រើន ព្រាហ្មណ៍ឱ្យដោះលែងពពែហើយពោលថា យើងនឹងមិនឱ្យនរណា ៗ សម្លាប់ពពែនេះ ទើបនាំពួកអន្តេវាសិក ត្រាច់ទៅជាមួយពពែនោះឯង ពពែល្មមគេដោះលែងប៉ុណ្ណោះ ក៏អើតកផ្តើមនឹងស៊ីស្លឹកឈើ ដែលអាស្រ័យផ្ទាំងថ្មមួយកន្លែង ភ្លាមនោះឯង រន្ទះក៏បាញ់កន្លែងផ្ទាំងថ្មនោះ ចំណិតថ្មមួយដុំបែកធ្លាក់ចុះត្រូវកពពែដែលអើតនោះឯង កាត់ក្បាលដាច់ទៅ, មហាជនប្រជុំគ្នា ក្នុងកាលនោះព្រះ-ពោធិសត្វកើតជារុក្ខទេវតានៅក្នុងទីនោះ ព្រះពោធិសត្វនោះ កាលមហាជនឃើញនោះឯង អង្គុយចម្រើនសមាធិក្នុងអាកាសដោយទេវានុភាពពោលថា សត្វទាំងអស់នោះ ដឹងផលរបស់បាបយ៉ាងនេះមិនគួរធ្វើបាណាតិបាត កាលព្រះពោធិសត្វនឹងសម្តែងធម៌ដោយ-

សំឡេងយ៉ាងពីរោះ ទើបពោលគាថានេះថា :

**ឯវញ្ចេ សត្តា ជានេយ្យុំ ទុក្ខាយំ ជាតិសម្ភវោ**
**ន បាណោ បាណិនំ ហញ្ញេ បាណឃាតី ហិ សោចតិ ។**

បើពួកសត្វគប្បីដឹងយ៉ាងនេះថា ការកើតនៃជាតិនេះ រមែង-នាំមកនូវទុក្ខ សត្វមិនត្រូវសម្លាប់សត្វ ព្រោះថា បុគ្គលអ្នកសម្លាប់សត្វ រមែងសោយសោក ។

បណ្ដាបទទាំងនោះ បទថា **ឯវញ្ចេ សត្តា ជានេយ្យុំ** សេចក្ដីថា សត្វទាំងនោះគប្បីដឹងយ៉ាងនេះ គប្បីដឹងយ៉ាងណា ? គប្បីដឹងថា ជាតិការកើតនេះជាទុក្ខ, អធិប្បាយថា បើគប្បីដឹងថាសេចក្ដីកើតក្នុងភពនោះ ៗ និងសេចក្ដីកើត ពោលគឺសេចក្ដីចម្រើនរបស់អ្នកដែលកើតដោយលំដាប់នេះឈ្មោះថាជាទុក្ខ ព្រោះជាវត្ថុជាទីតាំងនៃ-ទុក្ខទាំងឡាយមានជរា ព្យាធិ មរណៈ សេចក្ដីជួបជាមួយវត្ថុមិនជាទីស្រឡាញ់ សេចក្ដីព្រាត់ប្រាសចាកវត្ថុជាទីស្រឡាញ់ និងការត្រូវកាត់ដៃកាត់ជើងជាដើម ។ បទថា **ន បាណោ បាណិនំ ហញ្ញេ** សេចក្ដីថាសត្វណា ៗ ដឹងហើយថា ជាតិការកើតឈ្មោះថា ជាទុក្ខ ព្រោះជាទីតាំងនៃសេចក្ដីទុក្ខថា អ្នកធ្វើសត្វដទៃឱ្យចម្រើន រមែងបានសេចក្ដីចម្រើនក្នុងជាតិ គឺការកើត កាលបៀតបៀនសត្វដទៃ រមែងបានទទួលការបៀតបៀនវិញ ដូច្នេះហើយទើបមិនគួរសម្លាប់សត្វដទៃ

អធិប្បាយថា សត្វមិនគួរសម្លាប់សត្វព្រោះហេតុអ្វី ? ព្រោះអ្នកមានប្រក្រតីសម្លាប់សត្វរមែងសោកសៅ, អធិប្បាយថា ព្រោះបុគ្គលអ្នកមានប្រក្រតីសម្លាប់សត្វ ដោយការចូលទៅកាត់ជីវិតិន្ទ្រិយរបស់សត្វ-ដទៃ ដោយប្រយោគណាមួយ៉ាង ក្នុងបណ្ដាប្រយោគទាំង ៦ មាន **សាហត្ថិកប្រយោគ**ជាដើម សោយសេចក្ដីទុក្ខនៅក្នុងអបាយភូមិទាំង ៤ នេះ គឺ ក្នុងមហានរកទាំង ៨ រណ្ដៅ ក្នុងឧស្សទនរក ១៦ រណ្ដៅ ក្នុងកំណើតសត្វតិរច្ឆាន មានប្រការផ្សេង ៗ ក្នុងបេតវិស័យ និងក្នុងអសុរកាយ ឈ្មោះថារមែងសោកសៅ ដោយសេចក្ដីសោកសៅដែលមានសេចក្ដីដុតឆេះ ក្នុងខាងក្នុងលក្ខណៈរហូតអស់កាលយូរម្យ៉ាងទៀតសត្វដឹងថា ពពែនេះសោកសៅហើយព្រោះមរណភ័យយ៉ាងណា ? អ្នកមានប្រក្រតីសម្លាប់សត្វ រមែងសោកសៅអស់កាលយូរ សូម្បីដូច្នោះ ដូច្នេះហើយមិនគួរសម្លាប់សត្វ, អធិប្បាយថា នរណា ៗ មិនគួរធ្វើកម្ម គឺបាណាតិបាត បុគ្គលអ្នកវង្វេងព្រោះ-មោហៈ កាល**អវិជ្ជា**ធ្វើឱ្យជាមនុស្ស**ខ្វាក់**ហើយ មិនឃើញទោសនេះរមែងធ្វើបាណាតិបាត ។

ព្រះពោធិសត្វសម្ដែងធម៌ ដោយយកភ័យក្នុងនរកមកគំរាមដោយប្រការយ៉ាងនេះ មនុស្សទាំងឡាយ ស្ដាប់ធម្មទេសនានោះហើយ ខ្លាចភ័យក្នុងនរក នាំគ្នាវៀរចាកបាណាតិបាត ចំណែក-

ព្រះពោធិសត្វ គ្រាសម្ដែងធម៌ចប់ហើយ ញុំាងមហាជនឱ្យតាំងនៅក្នុងបញ្ចសីល ( សីល ៥ ) ហើយទៅតាមយថាកម្ម ចំណែកមហាជនតាំងនៅក្នុងឱវាទរបស់ព្រះពោធិសត្វ ធ្វើបុណ្យមានទានជាដើម ធ្វើ-ទេពនគរឱ្យពេញបរិបូណ៌ហើយ ( ស្លាប់ទៅកើតជាទេវតា ) ។

ព្រះសាស្ដា គ្រាទ្រង់នាំព្រះធម្មទេសនានេះមកសម្ដែងហើយ ទ្រង់បន្តអនុសន្ធិ ទ្រង់ប្រជុំជាតកថា ម្នាលភិក្ខុទាំងឡាយ ក្នុងសម័យនោះតថាគតបានជារុក្ខទេវតានោះឯង ។

## ( ចប់មតកភត្តជាតកទី ៨ )

**អត្តនា ច កតំ បាបំ អត្តនា ច សង្កិលិស្សតិ**
**អត្តនា អកតំ បាបំ អត្តនា ច វិសុជ្ឈតិ**
**សុទ្ធិ អសុទ្ធិ បច្ចត្តំ នាញ្ញោ អញ្ញំ វិសោធយេ ។**

-អ្នកធ្វើបាបខ្លួនឯង នឹងសៅហ្មងខ្លួនឯង អ្នកមិនធ្វើបាបខ្លួនឯងតែងបរិសុទ្ធស្អាតខ្លួនឯង សេចក្ដីបរិសុទ្ធិនិងមិនបរិសុទ្ធិ មានចំពោះខ្លួន អ្នកដទៃនឹងធ្វើអ្នកដទៃ ឱ្យបរិសុទ្ធពុំបានទេ ។

( បិដកលេខ ៥២, ទំព័រ ៥៦ )

# ១៦-រឿងសង្ខិត្តសហស្សប្រេត

" ប្រេតត្រូវញញួរដែកវាយបំបែកក្បាល "

( បិដកលេខ ៥៦, ទំ. ១៣៣ និងអដ្ឋកថា )

ព្រះសាស្តា កាលស្តេចគង់ប្រថាប់នៅក្នុងវត្តជេតពនមហា-វិហារ ទ្រង់ប្រារព្ធប្រេតម្នាក់ ទើបត្រាស់នូវព្រះគាថានេះ មានពាក្យផ្តើមថា **គិន្ន ខុម្មត្ថរូបោខ** ដូច្នេះ ។

បានឮថា ក្នុងអតីតកាល ក្នុងក្រុងពារាណសី មានបុរសខ្វិនម្នាក់ ជាអ្នកឈ្លាសក្នុងការប្រកបនូវការផ្ទាត់គ្រាប់ក្រួស គេដល់នូវ-សេចក្តីសម្រេចក្នុងសិល្បៈនៃការផ្ទាត់គ្រាប់ក្រួសនោះ អង្គុយនៅត្រង់គល់ជ្រៃ ជិតទ្វារព្រះនគរ បានសម្តែងនូវរូបដំរី សេះ មនុស្ស រថ ផ្ទះកំពូល ទង់ និងក្អមទឹកពេញជាដើម នៅលើស្លឹកជ្រៃដោយការផ្ទាត់គ្រាប់ក្រួស ពួកក្មេងក្នុងព្រះនគរ បានឱ្យទ្រព្យ ១ មាសកៈ និងកន្លះមាសកៈ ដើម្បីប្រយោជន៍ដល់ការលេងរបស់ខ្លួន ឱ្យគេសម្តែងសិល្បៈទាំងនោះ តាមសេចក្តីពេញចិត្ត ។

ក្រោយមកថ្ងៃមួយ ព្រះបាទពារាណសី ទ្រង់យាងចេញពីព្រះ-នគរ ចូលទៅកាន់គល់ជ្រៃនោះ បានឃើញនូវការចែករូបផ្សេង ៗ

មានរូបដំរីជាដើម ដែលជាប់នៅលើស្លឹកជ្រៃ ទើបត្រាស់សួរពួកមនុស្សថា តើនរណាគេហ្ន៎ ធ្វើនូវការចែករូបផ្សេង ៗ យ៉ាងនេះនៅលើស្លឹកជ្រៃទាំងនេះ ពួកមនុស្សចង្អុលឱ្យទតមើលបុរសខ្វិននោះ ហើយទូលថា បុរសខ្វិននេះធ្វើ ថ្លៃវិសេស ។ ព្រះរាជា ត្រាស់ឱ្យហៅបុរសខ្វិននោះមកហើយ ត្រាស់យ៉ាងនេះថា នែនាយ អ្នកអាចដើម្បីនឹងយកអាចម៍ពពែដាក់ឱ្យពេញពោះរបស់បុរសម្នាក់ ដែលយើងចង្អុលប្រាប់ ដែលកំពុងពោលជាមួយនឹងព្រះរាជនោះឯង បានដែរឬទេ ? បុរសខ្វិនទូលថា បានថ្លៃវិសេស ។ ព្រះរាជាទើបនាំបុរសខ្វិននោះ ចូលទៅកាន់ព្រះរាជវាំងរបស់ព្រះអង្គ ទ្រង់ធុញទ្រាន់នឹងបុរោហិតដែលនិយាយច្រើន ទើបត្រាស់ឱ្យហៅបុរោហិតមកអង្គុយប្រឹក្សាគ្នា ក្នុងឱកាសដ៏ស្ងាត់ជាមួយនឹងបុរោហិតនោះ ដែលហ៊ុមព័ទ្ធដោយកំពែង គឺវាំងនន ទើបត្រាស់ឱ្យហៅបុរសខ្វិនមក ។ បុរសខ្វិនកាន់យកអាចម៍ពពែប្រមាណ ១ នាឡិមក ដឹងនូវអាការ-របស់ព្រះរាជា ក៏បានអង្គុយបែរមុខចំបុរោហិត កាលបុរោហិតនោះហាមាត់ ក៏បានផ្ទាត់អាចម៍ពពែម្តង ១ ដុំ ចូលក្នុងបំពង់ករបស់បុរោហិតនោះ តាមប្រហោងកំពែង គឺវាំងនន ។ គេមិនអាចនឹងខ្ជាក់ចេញ ព្រោះសេចក្តីខ្មាសអៀន ទើបលេបចូលទាំងអស់ ។ លំដាប់នោះ ព្រះរាជាទ្រង់ប្រាប់ឱ្យបុរោហិតនោះ ដែលមានពោះ-

ពេញដោយអាចម៍ពពែត្រឡប់ទៅវិញ ដោយត្រាស់ថា ទៅចុះព្រាហ្មណ៍ អ្នកបានផលនៃភាពជាអ្នកនិយាយច្រើនហើយ អ្នកចូរ-ផឹកទឹកដែលផ្សំដោយផ្លៃ និងសម្បកប្រយង្គ ដែលច្របាច់ជាដើម ហើយចូរបន្ទោបង់ចេញ ដោយអាការៈយ៉ាងនេះ អ្នកក៏នឹងមានសេចក្ដីសួស្ដី ។ ដោយទង្វើរបស់បុរសខ្វិននោះ ព្រះអង្គទ្រង់សព្វ-ព្រះរាជហឫទ័យ ក៏បានព្រះរាជទាននូវផ្ទះសួយ ១៤ តំបន់ ។ លុះគេបានផ្ទះសួយ ១៤ តំបន់ហើយ ក៏បានធ្វើខ្លួនឱ្យមនុស្សមានសេចក្ដីសុខសប្បាយ ទាំងឱ្យជនជាបរិវារបានទទួលនូវសេចក្ដីសុខសប្បាយ ឱ្យនូវវត្ថុដ៏សមគួរដល់សមណព្រាហ្មណ៍ជាដើម មិនធ្វើឱ្យប្រយោជន៍បច្ចុប្បន្ន និងអនាគតវិនាសទៅឡើយ ចិញ្ចឹមជីវិតដោយសេចក្ដីសុខដ៏ក្រៃលែង ថែមទាំងឱ្យនូវបំណាច់រង្វាន់ ដល់អ្នកដែលមកកាន់សម្នាក់ខ្លួនដើម្បីសិក្សាសិល្បៈ ( ទៀតផង ) ។

លំដាប់នោះ បុរសម្នាក់ចូលទៅកាន់សម្នាក់គាត់ពោលយ៉ាងនេះថា បពិត្រលោកអាចារ្យ សូមលោកអាចារ្យឱ្យខ្ញុំសិក្សាសិល្បៈនេះទៅ ខ្ញុំគ្រប់គ្រាន់ហើយ ដោយបំណាច់និងរង្វាន់ ។ បុរសខ្វិននោះ ក៏បានឱ្យបុរសនោះសិក្សានូវសិល្បៈនោះ ។ បុរសនោះសិក្សាសិល្បៈបានហើយ មានបំណងនឹងសាកល្បងនូវសិល្បៈ ទើបដើរទៅ យកគ្រឿងពិឃាត គឺដុំក្រួសផ្ទាត់ទម្លាយសីសៈរបស់ព្រះ-

បច្ចេកពុទ្ធ ព្រះនាម **សុនេត្តៈ** ដែលគង់នៅនាមាត់ច្រាំងទន្លេគង្គា ព្រះបច្ចេកពុទ្ធក៏បានបរិនិព្វាននៅនាមាត់ច្រាំងទន្លេគង្គានោះឯង ពួក-មនុស្សដឹងរឿងហើយ ទើបយកដុំដីជាដើម ប្រហារបុរសនោះ ឱ្យអស់ជីវិតក្នុងទីនោះឯង គេធ្វើកាលកិរិយាហើយ ក៏បានទៅកើតក្នុងអវិចីមហានរក ឆេះនៅក្នុងនរកច្រើនពាន់ឆ្នាំ ដោយសេសសល់នៃ-ផលកម្មនោះឯង ក្នុងពុទ្ធុប្បាទនេះ ទើបកើតជាប្រេត មិនឆ្ងាយពីក្រុងរាជគ្រឹះ វិបាកដែលគប្បីឃើញសមនឹងកម្មនោះគប្បីមាន ព្រោះ-ហេតុនោះ ញញួរដែកប្រមាណ ៦០,០០០ ដែលកម្លាំងនៃកម្មបន្សាត់ឡើង ហើយក៏បានធ្លាក់មកលើក្បាល ទាំងវេលាព្រឹក វេលាថ្ងៃត្រង់ និងវេលាល្ងាច ។ ប្រេតនោះ មានក្បាលបែកហើយ បានទទួលនូវ-ទុក្ខវេទនាដ៏សែនខ្លាំងក្លា ហើយក៏បានដួលលើផែនដី ប៉ុន្តែកាលដែលញញួរដែកប្រាសទៅ វាក៏មានក្បាលតាំងនៅដូចដើមវិញ ។

ក្រោយមកថ្ងៃមួយ ព្រះមហាមោគ្គល្លាន ចុះពីភ្នំគិជ្ឈកូដ ក៏បានឃើញប្រេតនោះ ទើបសួរដោយគាថានេះថា :

*ហេតុអ្វីអ្នកដូចមនុស្សឆ្កួត ស្ទុះចុះស្ទុះឡើង ដូចម្រឹគភ្ញាក់ផ្អើល អ្នកមានបាបកម្មមិនមានសង្ស័យ ហេតុអ្វី ក៏អ្នកស្រែក ។*

បណ្តាបទទាំងនោះ បទថា **ឧម្មត្តរូបោវ** សេចក្តីថា អ្នកដូចជាមានសភាវៈនៃមនុស្សឆ្កួត គឺដូចជាមនុស្សដល់នូវភាពឆ្កួត ។

បទថា **មិគោ ភន្តោវ ធាវសិ** សេចក្តីថា អ្នករត់ឆ្វេឆ្វាចុះឡើង ដូចម្រឹគផ្អើល ។ មែនពិត កាលញញួរដែកទាំងនោះកំពុងធ្លាក់លើ គេមិនឃើញនូវវត្ថុដែលអាចតតាំងបាន ទើបរត់ចុះឡើងដោយគិត ថា ការប្រហារដូច្នេះ នឹងមិនគប្បីមានឬហ្ន៎ ។ ក៏ញញួរដែកទាំងនោះ ត្រូវកម្លាំងកម្មបន្សាត់ទៅ ទើបធ្លាក់ចុះតែលើក្បាលរបស់ប្រេតនោះ ដែលឈរនៅក្នុងទីណាមួយ ។ បទថា **កិន្នុ សន្ទយសេ តុវំ** សេចក្តីថា អ្នកស្រែកធ្វើអ្វី គឺអ្នកត្រាច់ស្រែកកងរំពងក្រៃលែង ។

ប្រេតបានស្តាប់ដូច្នោះហើយ ទើបឆ្លើយតបដោយគាថា ២ គាថាថា :

*បពិត្រលោកដ៏ចម្រើន ខ្ញុំជាប្រេតទុគ៌ត កើតក្នុងយមលោក ទៅពីមនុស្សលោកនេះ ទៅកាន់បេតលោក ព្រោះតែធ្វើបាបកម្ម ។ មានញញួរដែកពេញចំនួនប្រាំមួយហ្មឺន ( ៦០.០០០ ) ដ៏គ្រប់គ្រាន់ តែងធ្លាក់លើក្បាលរបស់ខ្ញុំ ញញួរដែកទាំងនោះទម្លាយនូវក្បាល របស់ខ្ញុំ ។*

បណ្តាបទទាំងនោះ បទថា **សដ្ឋី កូដសហស្សានិ** ប្រែថា ញញួរដែកប្រមាណ ៦០,០០០ ។ បទថា **បរិបុណ្ណានិ** ប្រែថា មិនខ្វះ ។ បទថា **សព្វសោ** គឺ ដោយចំណែកទាំងពួង ។ បានឮថា ក្បាលរបស់ប្រេតនោះ ប៉ុនកំពូលភ្នំធំ កើតឡើងល្មមដែលនឹងឱ្យ

ញញួរដែក ៦០,០០០ ធ្លាក់លើ ។ ញញួរដែកទាំងនោះ ធ្លាក់លើក្បាលរបស់ប្រេតនោះ មិនសល់ស្លានទីត្រឹមតែចាក់នូវចុងនៃរោមទ្រាយចូលបានឡើយ ព្រោះហេតុនោះ ប្រេតនោះទើបស្រែកកងរំពងឡើង ។ ព្រោះហេតុនោះ លោកទើបពោលថា ញញួរដែកទាំង-នោះធ្លាក់លើ និងវាយទម្លាយក្បាលរបស់ខ្ញុំ ដោយប្រការទាំងពួង ។

លំដាប់នោះ ព្រះថេរៈកាលនឹងសួរនូវកម្មដែលប្រេតនោះបានធ្វើ ទើបបានពោលនូវគាថា ២ គាថាថា :

*ចុះអ្នកបានធ្វើអំពើអាក្រក់ដោយកាយ វាចា ចិត្តដូចម្ដេចបានជាអ្នកលះលោកនេះ ទៅកើតក្នុងបេតលោក ព្រោះផលកម្មអ្វី ។ ញញួរដែកពេញប្រាំមួយហ្មឺន ( ៦០.០០០ ) ដ៏គ្រប់គ្រាន់ ធ្លាក់មកលើក្បាលរបស់អ្នក ញញួរដែកទាំងនោះវាយទម្លាយក្បាល ។*

ប្រេតកាលនឹងប្រាប់នូវកម្មដែលខ្លួនបានធ្វើដល់ព្រះថេរៈនោះទើបបានពោលនូវគាថា ៣ គាថាថា :

*កាលណោះ ខ្ញុំបានឃើញព្រះបច្ចេកពុទ្ធ ព្រះនាមសុនេត្តលោកមានឥន្ទ្រិយចម្រើន ដោយអរិយមគ្គ គង់ក្រោមម្លប់ឈើ លោកមានឈាន ឥតមានភ័យមកពីទីណាទេ ។ ខ្ញុំបាញ់ទម្លាយព្រះកេស-លោក ដោយការប្រហារដោយក្រួស សេចក្ដីទុក្ខនេះ សម្រេចដល់ខ្ញុំព្រោះតែផលកម្មនៃការប្រហារនោះ ។ ( ព្រោះហេតុនោះ ) បានជា*

*ញញួរដែកពេញប្រាំមួយហ្មឺន ( ៦០.០០០ ) ដ៏គ្រប់គ្រាន់ ធ្លាក់មកលើក្បាលរបស់ខ្ញុំ ញញួរដែកទាំងនោះវាយទម្លាយក្បាលរបស់ខ្ញុំ ។*

បណ្ដាបទទាំងនោះ បទថា **សម្ពុទ្ធំ** បានដល់ ព្រះបច្ចេកសម្ពុទ្ធ ។ បទថា **សុនេត្តំ** បានដល់ អ្នកមានឈ្មោះយ៉ាងនេះ ។ បទថា **ភាវិតិន្ទ្រិយំ** បានដល់ អ្នកមានឥន្ទ្រិយ មានសទ្ធិន្ទ្រិយជាដើម ដែលអប់រំហើយដោយអរិយមគ្គភាវនា ។

បទថា **សាលិត្តកប្បហារេន** សេចក្ដីថា ប្រកបនូវការផ្ទាត់គ្រាប់ក្រួសដោយធ្នូ ឬដោយម្រាមដៃនោះឯង ដែលលោកហៅថាសាលិត្តកៈ ។ ពិតយ៉ាងនោះ បាលីថា **សត្ថរាយ បហារេន** ដូច្នេះក៏មាន ។ បទថា **ភិន្ទិសីសំ** ប្រែថា ទម្លាយហើយ ។

ព្រះថេរៈលុះបានស្ដាប់ដូច្នោះហើយ កាលនឹងសម្ដែងថា ឥឡូវនេះ អ្នកបានទទួលនូវផលនេះនៃកម្មចាស់ ដែលសមគួរដល់កម្មដែលខ្លួនបានធ្វើនោះឯង ទើបពោលនូវគាថាចុងក្រោយថា :

*ម្នាលបុរសអាក្រក់ សមតាមសេចក្ដីប្រព្រឹត្តរបស់អ្នកហើយ ត្រង់ដែលញញួរដែក ពេញប្រាំមួយហ្មឺន ( ៦០.០០០ ) ដ៏គ្រប់គ្រាន់ ធ្លាក់មកលើក្បាលរបស់អ្នក ញញួរដែកទាំងនោះ ក៏វាយទម្លាយក្បាលរបស់អ្នក ។*

បណ្ដាបទទាំងនោះ បទថា **ធម្មេន** ប្រែថា ដោយហេតុ-

ដ៏សមគួរ ។ បទថា តេ បានដល់ អ្នក ។ លោកសម្តែងទុកថា ផលនេះសមគួរពិតដល់បាបកម្ម ដែលអ្នកជាអ្នកប្រព្រឹត្តខុសក្នុងព្រះ-បច្ចេកពុទ្ធនោះ បានធ្វើហើយ ដែលបង្អោននាំចូលទៅរកអ្នក ព្រោះដូច្នោះ ផលនៃបាបកម្មនោះឯង ដែលបុគ្គលណាម្នាក់ ទោះបីជាទេវតា មារ ព្រហ្ម ឬសូម្បីតែព្រះសម្មាសម្ពុទ្ធក៏ដោយ នឹងគប្បីការពារមិនបានឡើយ ។

លុះពោលយ៉ាងនេះហើយ បន្ទាប់ពីទីនោះទើបត្រាច់ទៅបិណ្ឌបាតក្នុងព្រះនគរ ធ្វើនូវភត្តកិច្ចរួចហើយ ក្នុងវេលាល្ងាចទើបចូលទៅគាល់ព្រះសាស្តា ក្រាបទូលនូវរឿងនោះ ចំពោះព្រះដ៏មាន-ព្រះភាគ ។ ព្រះដ៏មានព្រះភាគ ទ្រង់ធ្វើនូវរឿងនោះឱ្យជាអត្ថុប្បត្តិ-ហេតុ កាលទ្រង់នឹងសម្តែងធម៌ដល់បរិស័ទ ដែលមកប្រជុំគ្នាហើយ ទើបទ្រង់ប្រកាសនូវគុណានុភាពនៃព្រះបច្ចេកពុទ្ធ និងការមិនមើលងាយនូវកម្ម មហាជនកើតនូវសេចក្តីសង្វេគលះបង់បាបកម្មហើយ ជាអ្នកត្រេកអរក្នុងបុណ្យ មានទានជាដើម ដោយប្រការ ដូច្នេះ ។

## ( ចប់រឿងសដ្ឋីកូដសហស្សប្រេតទី ១៦ )

**អដ្ឋកថាខុទ្ទកនិកាយ បេតវត្ថុ មហាវគ្គទី ៤ ប្រដាប់ដោយរឿង ១៦**

## ឧទ្ទាននៃមហាវគ្គ ទី ៤ នោះគឺ :

និយាយអំពីរឿងអម្ពសក្ខរប្រេត ១ សេរីសកប្រេត ១ នន្ទិកា-ប្រេត ១ រេវតីប្រេត ១ ឧច្ឆុខាទកប្រេត ១ កុមារប្រេត ១ រាជបុត្តប្រេត ១ គូថខាទកប្រេតពីរលើក គណប្រេត ១ បាដលិបុត្តប្រេត ១ អម្ពវនប្រេត ១ អក្ខរុក្ខប្រេត ១ ភោគសំហរប្រេត ១ សេដ្ឋិបុត្តប្រេត ១ សដ្ឋីកូដសហស្សប្រេត ១ ហេតុនោះ បានជាលោកហៅថា វគ្គ ។

## ចប់មហាវគ្គទី ៤ ។

## ចប់បេតវត្ថុ ។

# កថាសរុបចុងក្រោយ

ក៏ដោយលំដាប់ពាក្យមានប្រមាណប៉ុណ្ណោះ ។

**អត្ថសំវណ្ណនា**ដែលប្រកាសផលដ៏ក្តៅផ្សាលាមករបស់កម្ម ដែលជាហេតុឱ្យសត្វដែលធ្វើអាក្រក់ កើតជាប្រេតដោយប្រចក្ស ដោយការបុច្ឆាវិសជ្ជនា និងដោយនិយាមនៃទេសនា ញុំាងនូវសេចក្តីសង្វេគឱ្យកើតដល់សប្បុរសទាំងឡាយ ខ្ញុំអាស្រ័យន័យនៃអដ្ឋកថាចាស់ផ្តួចផ្តើមទុក ដើម្បីនឹងប្រកាសនូវសេចក្តីរបស់រឿង ដែលលោកអ្នកស្វែងរកគុណដ៏ធំ អ្នកឈ្លាសក្នុងរឿងពាក្យពេចន៍ កំណត់ដឹងរឿងបានយ៉ាងល្អចងក្រងទុក ដោយឈ្មោះថា **បេតវត្ថុ** ដែលប្រកាសនូវអត្ថយ៉ាងល្អទុកក្នុងបេតវត្ថុនោះ តាមសមគួរក្នុងរឿងនោះ ៗ ដោយឈ្មោះឈ្មោះថា **បរមត្ថទីបនី** មាននិវិនិច្ឆ័យមិនសាំញ៉ាំ ចប់បរិបូណ៌ហើយដោយព្រះបាលីប្រមាណ ១៥ ភាណវារៈ ដូច្នោះ បុណ្យនោះដែលខ្ញុំអ្នកតែងបរមត្ថទីបនីនោះ បានជួបប្រសព្វហើយ ដោយអានុភាពនៃ-បុណ្យនោះ សូមពួកសត្វទាំងពួង ចូរឈានចុះកាន់សាសនារបស់ព្រះលោកនាថ ហើយជាអ្នកមានចំណែកនៃវិមុត្តិរស ដោយសេចក្តីបដិបត្តិមានសីលជាដើមដ៏បរិសុទ្ធ សូមសាសនារបស់ព្រះសម្មាសម្ពុទ្ធ

ជាម្ចាស់ ស្ថិតនៅក្នុងលោកអស់កាលយូរ សូមឱ្យសត្វទាំងឡាយសត្វ-ទាំងពួងមានសេចក្ដីគោរពក្នុងសាសនារបស់ព្រះសម្មាសម្ពុទ្ធព្រះអង្គនោះ ជានិច្ចនិរន្តរ៍ សូម្បីភ្លៀងក៏ចូរបង្អុរចុះកាន់ផ្ទៃប្រឹថពី ត្រូវតាមរដូវកាល សូមលោកអ្នកត្រេកអរក្នុងព្រះសទ្ធម្ម គ្រប់គ្រងសត្វលោកដោយធម៌ ( ទៅ ) ហោង ។

## ចប់ សំវណ្ណនាបេតវត្ថុ

### ព្រះភទ្ទន្តាចារិយធម្មបាល
### ដែលជាអ្នកបួសដ៏ប្រសើរក្នុងពួកមុនី
### អ្នកនៅក្នុងពទរតិត្ថវិហារ រចនា

# ចប់ បរិបូណ៌

# បកិណ្ណកប្រេត

ក្នុងធម្មបទដ្ឋកថា ( អដ្ឋកថាគម្ពីរធម្មបទ ) មាន :

## ១-រឿងអហិប្រេត

" ប្រេតដូចជាពស់ "

( ពាលវគ្គទី ៥ គាថាទី ១២ បិដកលេខ ៥២, ទំ.៣៦ និងអដ្ឋកថា )

### សេចក្តីខាងដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធប្រេតដែលមានអត្តភាពដូចជាពស់មួយរូប ត្រាស់ព្រះធម្មទេសនានេះថា **ន ហិ បាបំ កតំ កម្មំ** មានបទដូច្នេះ ជាដើម ។

### ព្រះមហាមោគ្គល្លានត្ថេរញញឹម

សេចក្តីពិស្តារថា ថ្ងៃមួយព្រះលក្ខណត្ថេរ ដែលជាព្រះថេរៈមួយអង្គក្នុងចំណោមជដិល ១,០០០ និងព្រះមហាមោគ្គល្លានត្ថេរ ចុះអំពីភ្នំគិជ្ឈកូដដោយគិតថា យើងនឹងត្រាច់ទៅបិណ្ឌបាតក្នុងក្រុង-រាជគ្រឹះ ។

បណ្តាព្រះថេរៈទាំងពីររូបនោះ ព្រះមហាមោគ្គល្លានឃើញប្រេតដែលមានអត្តភាពដូចពស់មួយ បានធ្វើការញញឹមឱ្យប្រាកដ ។ គ្រានោះ ព្រះលក្ខណត្ថេរសួរព្រះមោគ្គល្លានថា ម្នាលអាវុសោ ព្រោះហេតុអ្វី ទើបលោកញញឹម ?

ព្រះមហាមោគ្គល្លានឆ្លើយថា ម្នាលអាវុសោ ពេលនេះមិនមែនជាពេលវិស្សជ្ជនាបញ្ហានេះទេ, លោកគប្បីសួរខ្ញុំក្នុងសម្នាក់ព្រះមានព្រះភាគចុះ ។

កាលព្រះថេរៈទាំងពីរអង្គនោះ និមន្តបិណ្ឌបាតក្នុងក្រុងរាជ-គ្រឹះហើយ ទៅកាន់សម្នាក់ព្រះមានព្រះភាគ អង្គុយក្នុងទីដ៏សមគួរមួយ, ព្រះលក្ខណត្ថេរសួរថា ម្នាលអាវុសោ មោគ្គល្លាន កាលលោកចុះអំពីភ្នំគិជ្ឈកូដបានធ្វើការញញឹមឱ្យប្រាកដ ខ្ញុំសួរដល់ហេតុនៃការញញឹមនោះ លោកបានពោលថា ម្នាលអាវុសោលក្ខណៈ លោកគប្បីសួរខ្ញុំ ក្នុងសម្នាក់ព្រះមានព្រះភាគចុះ, ឥឡូវនេះ លោកចូរប្រាប់ហេតុនោះចុះ ។

## ព្រះមហាមោគ្គល្លានប្រាប់ហេតុនៃការញញឹម

ព្រះថេរៈពោលថា ម្នាលអាវុសោលក្ខណៈ ខ្ញុំបានឃើញប្រេតដែលមានអត្តភាពដូចជាពស់មួយ ទើបខ្ញុំករុណាញញឹម, អត្តភាពរបស់ប្រេតនោះបែបនេះ ក្បាលរបស់វាដូចក្បាលមនុស្ស, អត្តភាព

ដ៏សេសរបស់វាដូចពស់, ប្រេតនោះឈ្មោះថា **អហិប្រេត** កំពស់ប្រមាណ ២៥ យោជន៍, អណ្តាតភ្លើងតាំងឡើងអំពីក្បាលរបស់វាឆេះរាលរហូតទៅដល់កន្ទុយ, តាំងឡើងអំពីកន្ទុយឆេះរាលរហូតដល់ក្បាល, តាំងឡើងត្រង់ពាក់កណ្តាលខ្លួន ឆេះរាលដាលទៅទាំងពីរ-ខាង តាំងឡើងអំពីខាងទាំងពីរ ឆេះរួមចូលមកត្រង់កណ្តាល ។

បានឮថា អត្តភាពរបស់ប្រេតទាំងពីរនោះ ( គឺ**អហិប្រេត** និង **កាកប្រេត** ) ប្រមាណ ២៥ យោជន៍ របស់ប្រេតដ៏សេសប្រមាណ ៣ គាវុត, បណ្តាប្រេតទាំងនោះ រឿងរបស់អហិប្រេតសូមស្ទេះទុក-សិន ។

## បុព្វកម្មរបស់កាកប្រេត

ព្រះមហាមោគ្គល្លាន ឃើញកាកប្រេត ដែលភ្លើងកំពុងឆេះនៅលើកំពូលភ្នំគិជ្ឈកូដ ក៏សួរអំពីបុព្វកម្មរបស់ប្រេតនោះ ដោយគាថានេះថា :

*អណ្តាតរបស់អ្នកមានប្រមាណ ៥ យោជន៍, ក្បាលរបស់អ្នកប្រមាណ ៩ យោជន៍, កាយរបស់អ្នកខ្ពស់ប្រមាណ ២៥ យោជន៍, ឯងធ្វើកម្មអ្វីទុក ទើបដល់នូវសេចក្តីទុក្ខដូច្នេះ ។*

គ្រានោះ កាកប្រេតក៏បានឆ្លើយប្រាប់ព្រះថេរៈនោះ ដោយព្រះ-គាថានេះថា :

*បពិត្រព្រះមោគ្គល្លានដ៏ចម្រើន ខ្ញុំស៊ីភត្តដែលគេនាំមក ចំពោះសង្ឃសាវ័ករបស់ព្រះពុទ្ធទ្រង់ព្រះនាមថា **កស្សបៈ** អ្នកស្វែងរកគុណដ៏ធំ តាមសេចក្តីប្រាថ្នា ។*

ដូច្នេះហើយ ក៏ពោលតទៅថា បពិត្រលោកម្ចាស់ដ៏ចម្រើន ក្នុងកាលនៃព្រះពុទ្ធទ្រង់ព្រះនាម កស្សបៈ ពួកភិក្ខុច្រើនរូបចូលទៅកាន់ស្រុកដើម្បីបិណ្ឌបាត ។ ពួកមនុស្សឃើញភិក្ខុទាំងឡាយហើយ មានសេចក្តីជ្រះថ្លា ស្រឡាញ់ពេញចិត្ត និមន្តគង់ក្នុងរោងឆាន់ លាងជើង លាបដោយប្រេង ប្រគេនយាគូ និងរបស់គួរទំពាស៊ីដល់ភិក្ខុ-ទាំងឡាយហើយ អង្គុយស្តាប់ធម៌ ដើម្បីរង់ចាំបិណ្ឌបាតកាល ។

ក្នុងកាលចប់ធម្មកថា ពួកមនុស្សទទួលបាត្ររបស់ភិក្ខុទាំង-ឡាយហើយ ញុំាងភោជនដែលមានរសដ៏ប្រណីត ៗ ឱ្យពេញបាត្រ ក្នុងផ្ទះរបស់ខ្លួន ៗ ហើយនាំមក ។

គ្រានោះ ខ្ញុំម្ចាស់ជាក្អែកទំនៅលើរោងឆាន់ ឃើញភោជននោះហើយ បានចឹកយកដុំបាយ ៣ ដុំ ពេញ ១ មាត់ ៣ ដង អំពីបាត្រដែលមនុស្សម្នាក់កំពុងកាន់, ប៉ុន្តែភត្តនោះ មិនមែនជាភត្តរបស់សង្ឃទេ មិនមែនជាភត្តដែលគេបង្អោនទៅដើម្បីប្រគេនសង្ឃទេ, ទាំង-មិនមែនជាភត្តដែលសល់អំពីភត្តដែលភិក្ខុទាំងឡាយឆាន់ ដែលពួកមនុស្សនាំទៅកាន់ផ្ទះរបស់ខ្លួនបរិភោគដែរ, ខ្ញុំម្ចាស់ចឹកយកដុំបាយ ៣

ជុំអំពីជុំបាយទាំងនោះ, កម្មត្រឹមតែប៉ុណ្ណេះ ជាបុព្វកម្មរបស់ខ្ញុំម្ចាស់ ខ្ញុំម្ចាស់ធ្វើកាលកិរិយាហើយកើតក្នុងអវីចី ព្រោះវិបាកនៃកម្មនោះ ក្នុងកាលឥឡូវនេះ កើតជា**កាកប្រេត** សោយទុក្ខនៅភ្នំគិជ្ឈកូដនេះ ដោយផលកម្មដ៏សេសអំពីកម្មដែលឱ្យផលឆេះក្នុងនរក ។ រឿងរបស់**កាកប្រេត**មានត្រឹមតែប៉ុណ្ណេះ ។

ប៉ុន្តែក្នុងរឿងនេះ ព្រះថេរៈពោលថា ខ្ញុំឃើញប្រេត ទើបធ្វើនូវការញញឹមឱ្យប្រាកដ ។

គ្រានោះ ព្រះសាស្តាទ្រង់ជាសាក្សីរបស់ព្រះថេរៈ ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ មោគ្គល្លាននិយាយពិត, តថាគតក៏បានឃើញប្រេតនោះក្នុងថ្ងៃដែលតថាគតសម្រេចនូវពោធិញាណ ( បញ្ញាជា-គ្រឿងត្រាស់ដឹង ) ដែរ, ប៉ុន្តែតថាគតមិនសម្តែង ព្រោះអនុគ្រោះដល់បុគ្គលដទៃ បុគ្គលណាមិនជឿពាក្យរបស់តថាគត, ការមិនជឿនោះ រមែងប្រព្រឹត្តទៅដើម្បីជាទុក្ខដល់បុគ្គលនោះ ក៏ក្នុងកាលដែលព្រះ-មហាមោគ្គល្លានឃើញហើយនោះឯង ព្រះសាស្តាទ្រង់ជាសាក្សីរបស់លោក ទ្រង់ត្រាស់រឿង ២១ រឿង ក្នុងលក្ខណសំយុត្ត ។

សូម្បីរឿងនេះ ព្រះថេរៈនោះ ក៏ពោលទុកយ៉ាងនោះដែរ ។ សូម្បីព្រះសាស្តា ក៏ត្រាស់សម្តែងប្រាប់ភិក្ខុទាំងនោះថា :

## បុព្វកម្មរបស់អហិប្រេត

បានឮថា ក្នុងអតីតកាល ពួកជនអាស្រ័យក្រុងពារាណសី សាងបណ្ណសាលាទុកដើម្បីព្រះបច្ចេកពុទ្ធ ក្បែរឆ្នេរស្ទឹង ។ ព្រះ-បច្ចេកពុទ្ធនោះ គង់នៅក្នុងបណ្ណសាលានោះ រមែងត្រាច់ទៅដើម្បីបិណ្ឌបាតក្នុងក្រុងជានិច្ច ។

សូម្បីពួកអ្នកក្រុងពារាណសី ក៏មានដៃកាន់សក្ការៈ មាន-គ្រឿងក្រអូប និងកម្រងផ្កាជាដើមទៅកាន់ទីបម្រើរបស់ព្រះបច្ចេកពុទ្ធទាំងព្រឹកទាំងល្ងាច ។ បុរសអ្នកក្រុងពារាណសីម្នាក់អាស្រ័យនូវផ្លូវនោះភ្ជួរស្រែ ។ មហាជន កាលទៅកាន់ទីបម្រើព្រះបច្ចេកពុទ្ធតែងតែជាន់ស្រែនោះ ទាំងព្រឹកទាំងល្ងាច ។ សូម្បីអ្នកស្រែនោះហាមថា សូមពួកលោកកុំជាន់ស្រែរបស់ខ្ញុំ ក៏មិនស្ដាប់ នៅតែដើរជាន់ដដែល ។

គ្រានោះ អ្នកស្រែនោះ បានគិតយ៉ាងនេះថា ប្រសិនបើបណ្ណ-សាលារបស់ព្រះបច្ចេកពុទ្ធ មិននៅទីនេះសោត, ជនទាំងឡាយ ក៏មិនបានជាន់ស្រែរបស់យើងដែរ ។

ក្នុងកាលដែលព្រះបច្ចេកពុទ្ធចូលទៅបិណ្ឌបាត អ្នកស្រែនោះវាយបំបែកភាជនៈសម្រាប់ប្រើប្រាស់ ហើយដុតនូវបណ្ណសាលាចោល ។

ព្រះបច្ចេកពុទ្ធ ឃើញបណ្ណសាលាត្រូវភ្លើងឆេះហើយ ក៏-

ចៀសចេញទៅតាមសប្បាយ ។

មហាជនកាន់គ្រឿងក្រអូប និងកម្រងផ្កាមក ឃើញបណ្ណ-សាលាត្រូវភ្លើងឆេះ ក៏ពោលថា លោកម្ចាស់ដ៏ចម្រើនរបស់ពួកយើង និមន្តទៅណាហ្ន៎ សូម្បីអ្នកស្រែនោះ ក៏មកជាមួយនឹងមហាជនដែរ ឈរនៅកណ្តាលមហាជន និយាយយ៉ាងនេះថា បណ្ណសាលារបស់ព្រះបច្ចេកពុទ្ធនេះ ខ្ញុំជាអ្នកដុត ។

គ្រានោះ មហាជនទាំងឡាយនិយាយថា ពួកលោកចូរចាប់, ពួកយើងអាស្រ័យបុរសអាក្រក់នេះ ទើបមិនបានឃើញព្រះបច្ចេកពុទ្ធដូច្នេះហើយ ក៏វាយអ្នកស្រែនោះ ដោយគ្រឿងប្រហារទាំងឡាយ មានដំបងជាដើម ឱ្យដល់នូវការអស់ជីវិត ។ ក្រោយអំពីស្លាប់អ្នកស្រែនោះ ក៏កើតក្នុងអវីចិ, ឆេះក្នុងនរកដរាបផែនដីនេះដុះក្រាស់ឡើងប្រមាណមួយយោជន៍ ក្នុងពុទ្ធុប្បាទកាលនេះ កើតជា**អហិប្រេត** នៅនាភ្នំគិជ្ឈកូដ ដោយផលកម្មដ៏សេស ។

## ព្រះសាស្តាទ្រង់ប្រៀបធៀបផលកម្ម

ព្រះសាស្តា លុះទ្រង់ត្រាស់បុព្វកម្មរបស់អហិប្រេតនោះហើយ ក៏ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ដែលឈ្មោះថាបាបកម្មនោះ ប្រៀប-ដូចជាទឹកដោះស្រស់ ទឹកដោះស្រស់ដែលបុគ្គលកំពុងរីត មិនទាន់ប្រែក្លាយទៅយ៉ាងណា កម្មដែលបុគ្គលកំពុងធ្វើ ក៏មិនទាន់ឱ្យផល

ដូច្នោះដែរ ប៉ុន្តែក្នុងកាលណាកម្មឱ្យផល ក្នុងកាលនោះ អ្នកធ្វើរមែងជួបប្រសព្វនូវសេចក្តីទុក្ខបែបនោះ ក៏ត្រាស់ព្រះគាថានេះថា :

**ន ហិ បាបំ កតំ កម្មំ សជ្ជុខីរំវ មុច្ចតិ**
**ឌហន្តំ ពាលមន្វេតិ ភស្មាច្ឆន្នោវ[១] បាវកោ ។**

កម្មលាមក ដែលបុគ្គលពាលធ្វើហើយ មិនទាន់ឱ្យផល
នោះក៏មាន ដូចទឹកដោះស្រស់ ដែលមិនទាន់ប្រែក្លាយ
( ក្នុងមួយរំពេច ) ដូច្នោះ បាបកម្មនោះ តាមដុតបុគ្គល
ពាល ដូចរងើកភ្លើងដែលបិទបាំងទុកដោយផេះដូច្នោះ ។

## អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា **សជ្ជុខីរំ** សេចក្តីថា ទឹកដោះស្រស់ ដែលហូរចេញចាកដោះមេគោក្នុងខណៈនោះ នៅក្តៅ មិន-ទាន់ប្រែក្លាយ មិនទាន់ប្រែប្រួលនៅឡើយ ។ ព្រះសាស្តា ទ្រង់ត្រាស់អធិប្បាយទុកដូច្នេះថា ទឹកដោះស្រស់ដែលគេទើបតែរីតភ្លាម ៗ នោះមិនទាន់ប្រែប្រួល គឺមិនទាន់ប្រែក្លាយ បានដល់ មិនទាន់លះបង់នូវ-ភាពប្រក្រតី ក្នុងខណៈនោះភ្លាមទេ, គឺថា កាលដែលគេរីតដាក់ក្នុងភាជនៈណាហើយ មិនទាន់ដាក់របស់ជូរចូលទៅដរាបណា វាមិនទាន់ជូរដរាបនោះ លុះដាក់របស់ជូរចូលទៅ ឬក៏ដាក់ទៅក្នុងភាជនៈ

១= ឱ. **ភស្មច្ឆន្នោ** ។

សម្រាប់ដាក់វត្ថុមានទឹកដោះគោជូរជាដើម ទើបលះបង់នូវភាពប្រ-ក្រតីរបស់ខ្លួនដរាបនោះយ៉ាងណា សូម្បីបាបកម្មដែលបុគ្គលកំពុងធ្វើ ក៏មិនទាន់ឱ្យផលក្នុងខណៈនោះដូច្នោះដែរ, ប្រសិនបើបាបកម្មឱ្យផល (ក្នុងខណៈកំពុងធ្វើសោត) គ្មាននរណាហ៊ានធ្វើបាបឡើយ ខន្ធទាំង-ឡាយដែលកើតអំពីកុសលនៅមានដរាបណា ខន្ធទាំងនោះ រមែងរក្សាបុគ្គលនោះបានដរាបនោះ, កាលខន្ធទាំងឡាយកើតក្នុងអបាយ ព្រោះការបែកធ្លាយទៅនៃខន្ធទាំងនោះ បាបរមែងឱ្យផល, ក៏កាលបាបឱ្យផល ឈ្មោះថា រមែងតាមដុតបុគ្គលពាល ។

សួថៅ ដូចអ្វី ?

ឆ្លើយថា ដូចរងើកភ្លើងបិទបាំងដោយផេះ (ផេះគ្របពីលើ) ។

**អធិប្បាយថា** ដូចយ៉ាងថា រងើកភ្លើងមានអណ្ដាតទៅប្រាស-ហើយ ដែលបិទបាំងដោយផេះ សូម្បីបុគ្គលជាន់ហើយ ក៏មិនទាន់រលាកភ្លាមទេ ព្រោះផេះបិទបាំង, ប៉ុន្តែញាំងផេះឱ្យក្ដៅហើយ រមែងធ្វើឱ្យរលាករហូតដល់ខួរក្បាល ដោយអំណាចនៃការឆេះអវយវៈមានស្បែកជាដើមយ៉ាងណា សូម្បីបាបកម្មក៏ដូច្នោះដែរ ជាបាបកម្មដែលបុគ្គលណាធ្វើទុក រមែងតាមដុតបុគ្គលនោះ ដែលជាបុគ្គលពាលកើតហើយក្នុងអបាយ មាននរកជាដើម ក្នុងអត្តភាពទី ២-៣ ។

ក្នុងកាលចប់ទេសនា ជនជាច្រើនបានសម្រេចអរិយផល

មានសោតាបត្តិផលជាដើមដូច្នេះឯង ៕

## ( ចប់រឿងអហិប្រេត )

**ហីនំ ធម្មំ ន សេវេយ្យ បមាទេន ន សំវសេ**
**មិច្ឆាទិដ្ឋឹ ន សេវេយ្យ ន សិយា លោកវឌ្ឍនោ ។**

បុគ្គលមិនគួរសេពធម៌ថោកទាប [១] មិនគួរនៅដោយសេចក្តីប្រមាទ មិនគួរសេពមិច្ឆាទិដ្ឋិ មិនគួរជាមនុស្សបង្អៀតលោក ។

**អន្ធភូតោ អយំ លោកោ តនុកេត្ថ វិបស្សតិ**
**សកុណោ ជាលមុត្តោវ អប្បោ សគ្គាយ គច្ឆតិ ។**

លោកិយមហាជននេះ ជាមនុស្សងងឹត បណ្តាជនទាំងនេះ ជនតិចគ្នាដែលឃើញច្បាស់ ( នូវខន្ធាទិលោកនេះដោយអំណាចអនិច្ចលក្ខណៈជាដើម ) ជនតិចគ្នា ដែលទៅកាន់ឋានសួគ៌ ដូចសត្វស្លាប ( ដែលជាប់សំណាញ់របស់ព្រានហើយ ) តិចណាស់ ដែលរួចអំពីសំណាញ់ ដូច្នោះ ។ ( បិដកលេខ ៥២, ទំព័រ ៥៧-៥៨ )

---

១= កាមគុណ ៥ ឈ្មោះថា ធម៌ថោកទាប ព្រោះជាធម៌សម្រាប់ជនថោកទាប រាប់តាំងអំពីឱដ្ឋនិងគោជាដើម គប្បីសេព ទាំងជាធម៌នាំសត្វទៅកើតក្នុងទីទាប មាននរកជាដើម ។

# ២-រឿងសង្ឃីក្លងប្រេត

( ពាលវគ្គទី ៥ គាថាទី ១៣ បិដកលេខ ៥២,ទំ.៣៦ និងអដ្ឋកថា )

## សេចក្តីខាងដើម

ព្រះសាស្តា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធសដ្ឋីកូដ-ប្រេត ( ប្រេតដែលញញួរ ៦ ម៉ឺនសំពងក្បាលរាល់ថ្ងៃ ) ត្រាស់ព្រះ-ធម្មទេសនានេះថា **យាវទេវ អនត្ថាយ** ដូច្នេះជាដើម ។

## ( ព្រះមោគ្គល្លានឃើញសដ្ឋីកូដប្រេត )

សេចក្តីពិស្តារថា ព្រះមហាមោគ្គល្លានត្ថេរ ចុះអំពីភ្នំគិជ្ឈកូដមួយអន្លើដោយព្រះលក្ខណត្ថេរ ធ្វើការញញឹមក្នុងប្រទេសមួយដោយន័យដូចន័យដែលមានហើយក្នុងកាលមុនដែរ ត្រូវព្រះថេរៈសួរដល់ហេតុនៃការញញឹម ក៏ពោលថា ម្នាលអាវុសោលក្ខណៈ លោកគប្បីសួរខ្ញុំករុណាក្នុងសម្នាក់ព្រះមានព្រះភាគចុះ ក្នុងកាលដែលព្រះ-មហាមោគ្គល្លានត្រាច់ទៅបិណ្ឌបាតរួចហើយ ចូលទៅគាល់ព្រះ-សាស្តា ថ្វាយបង្គំហើយគង់ក្នុងទីដ៏សមគួរ ត្រូវព្រះថេរៈសួរទៀត ក៏ពោលថា ម្នាលអាវុសោ ខ្ញុំករុណាបានឃើញប្រេតមួយ មានអត្តភាពប្រមាណ ៣ គាវុត, ញញួរដែក ៦ ម៉ឺន ដែលមានភ្លើងឆេះសន្ធោ-

សន្ទៅ ហើយធ្លាក់ចុះមកលើក្បាលរបស់ប្រេតនោះ ហើយវាយបំបែកក្បាលប្រេតនោះ, ក្បាលដែលបែកហើយ ត្រឡប់ប្រាកដដូចដើមវិញ រមែងតាំងឡើងទៀត អត្តភាពបែបនេះខ្ញុំព្រះករុណាមិនធ្លាប់បានឃើញទេ, ខ្ញុំករុណាឃើញអត្តភាពនោះ ទើបញញឹមពិតណាស់ ព្រះមហាមោគ្គល្លានត្ថេរ អាស្រ័យប្រេតនេះឯង ទើប-ពោលពាក្យជាដើមថា :

*ញញួរដែក ៦ ម៉ឺន ដ៏បរិបូណ៌គ្រប់គ្រាន់ដោយប្រការ-ទាំងពួង ធ្លាក់មកលើក្បាលរបស់អ្នក ញញួរដែកទាំងនោះ វាយទម្លាយក្បាលរបស់អ្នកជានិច្ច ។*

## ( ព្រះសាស្តាទ្រង់អះអាងថាមានប្រេត )

ព្រះសាស្តា ទ្រង់ព្រះសណ្តាប់នូវពាក្យរបស់ព្រះថេរៈហើយក៏ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សត្វនេះសូម្បីកាលតថាគតគង់នៅនាពោធិមណ្ឌប្រទេស ក៏តថាគតបានឃើញដែរ ប៉ុន្តែតថាគតមិនសម្តែងប្រាប់ ព្រោះអនុគ្រោះដល់ជនដទៃថា ជនទាំងឡាយណា មិនជឿពាក្យតថាគត, ការមិនជឿនោះ រមែងប្រព្រឹត្តទៅជាទុក្ខដល់ជនទាំងនោះ, ប៉ុន្តែឥឡូវនេះ តថាគតជាសាក្សីរបស់មោគ្គល្លាន ទើបសម្តែងប្រាប់បាន ។

ភិក្ខុទាំងឡាយស្តាប់ព្រះតម្រាស់នោះហើយ ក៏ទូលសួរដល់

បុព្វកម្មរបស់ប្រេតនោះ ។ ព្រះសាស្តា ក៏ត្រាស់បុព្វកម្មរបស់ប្រេតនោះ ប្រាប់ភិក្ខុទាំងនោះថា :

## បុព្វកម្មរបស់សដ្ឋីកូដប្រេត

បានឮថា ក្នុងអតីតកាល នៅក្នុងក្រុងពារាណសី មានបុរសខ្វិនម្នាក់ ស្ទាត់ជំនាញខាងផ្ទាត់គ្រាប់ក្រួស ។

បុរសនោះ អង្គុយនៅក្រោមដើមជ្រៃក្រឹមមួយដើម ក្បែរទ្វារនរគ ត្រូវពួកក្មេងអ្នកស្រុកពោលថា លោកចូរផ្ទាត់គ្រាប់ក្រួសទៅចោះស្លឹកជ្រៃក្រឹមនោះសម្តែងរូបដំរី រូបសេះដល់ពួកយើង, ក៏សម្តែងរូបទាំងឡាយដែលពួកក្មេងប្រាថ្នា បានទូវវត្ថុទាំងឡាយ មានរបស់ទំពាស៊ីជាដើមអំពីសម្នាក់ពួកក្មេងទាំងនោះ ។

ថ្ងៃមួយ ព្រះរាជាស្តេចយាងទៅកាន់ព្រះរាជឧទ្យាន ស្តេចយាងដល់កន្លែងនោះ ពួកក្មេងទាំងនោះក៏លាក់បុរសខ្វិនទុកក្នុងចន្លោះនៃពួរជ្រៃ ហើយនាំគ្នារត់គេចចេញទៅ ។

កាលព្រះរាជា ស្តេចចូលទៅកាន់គល់ជ្រៃ ជាវេលាថ្ងៃត្រង់ស្រមោលនៃប្រហោងនោះផ្សាយទៅកាន់ព្រះសរីរៈរបស់ព្រះរាជា ។

ព្រះរាជាទ្រង់ព្រះតម្រិះថា នេះជាអ្វីហ្ន៎ ទ្រង់ផ្ទៀងមើលខាងលើឃើញរូបទាំងឡាយ មានរូបដំរីជាដើមឰដ៏ស្លឹកឈើ ក៏ត្រាស់សួរថា នេះជាកម្មរបស់អ្នកណា ? ទ្រង់ព្រះសណ្តាប់ថា របស់បុរសខ្វិន

ក៏បញ្ជាឱ្យហៅបុរសខ្វិននោះមក ហើយត្រាស់ថា ម្នាលអ្នកដ៏ចម្រើន បុរោហិតរបស់យើងមានមាត់រឹងណាស់ កាលយើងពោលពាក្យមានប្រមាណតិច ក៏និយាយពាក្យយ៉ាងច្រើន រមែងបៀតបៀនយើងដោយពាក្យសំដី, អ្នកអាចផ្ទាត់អាចម៍ពពែប្រមាណមួយនាឡិចូលទៅក្នុងមាត់របស់បុរោហិតនោះបានទេ ? បុរសខ្វិននោះក្រាបទូលថា ព្រះករុណាថ្លៃវិសេស ខ្ញុំព្រះអង្គអាច, សូមព្រះអង្គបញ្ជាឱ្យមនុស្សនាំអាចម៍ពពែមកហើយ ទ្រង់គង់ខាងក្នុងវាំងននជាមួយនឹងបុរោហិតចុះ ខ្ញុំព្រះអង្គនឹងដឹងកម្មដែលគួរធ្វើក្នុងរឿងនេះ ។

ព្រះរាជា ក៏ទ្រង់ធ្វើតាមបុរសខ្វិននោះ ។ បុរសខ្វិនបានប្រើឱ្យគេធ្វើនូវប្រហោងឰដ៏វាំងននដោយចុងកន្ត្រៃ គ្រាន់តែបុរោហិតហាមាត់និយាយជាមួយនឹងព្រះរាជា ក៏ផ្ទាត់អាចម៍ពពែទៅម្តងមួយដុំ ៗ ។ បុរោហិតបានលេបអាចម៍ពពែដែលចូលទៅក្នុងមាត់នោះ ។ កាលអាចម៍ពពែអស់ហើយ បុរសខ្វិនក៏ញាំងវាំងននឱ្យញ័រ ។

ព្រះរាជា ទ្រង់ជ្រាបថា អាចម៍ពពែអស់ដោយសញ្ញានោះ ហើយក៏ត្រាស់ថា ម្នាលអាចារ្យ យើងនិយាយជាមួយនឹងលោកមិនដែលឈ្នះ, លោកសូម្បីលេបអាចម៍ពពែមួយនាឡិហើយ ក៏នៅតែមិនស្ងៀមទៀត លោកជាមនុស្សមានមាត់រឹងណាស់ ។

ព្រាហ្មណ៍មានសេចក្តីអៀនខ្មាសព្រះរាជា ចាប់តាំងពីថ្ងៃ-

នោះមក មិនហ៊ានហាមាត់ចរចាជាមួយនឹងព្រះរាជាទៀតទេ ។

ព្រះរាជាបញ្ជាឱ្យហៅបុរសខ្វិនមកហើយ ត្រាស់ថា ម្នាលអ្នកដ៏ចម្រើន យើងបានសេចក្តីសុខព្រោះអាស្រ័យអ្នក ទ្រង់ពេញព្រះទ័យទើបព្រះរាជទានពូក ៨ នៃវត្ថុទាំងពួងដល់បុរសខ្វិននោះ បានព្រះ-រាជទានស្រុកសួយ ៤ តំបន់ក្នុងទិសទាំង ៤ នៃក្រុងដល់បុរសខ្វិននោះ ។

អាមាត្យអ្នកប្រៀនប្រដៅអត្ថ និងធម៌របស់ព្រះរាជាដឹងសេចក្តីនោះហើយ ក៏ពោលគាថាដូច្នេះថា :

*ដែលឈ្មោះថាសិល្បៈ ទោះបីសិល្បៈណាមួយក៏ដោយ ក៏ញុំាំងប្រយោជន៍ឱ្យសម្រេចបានទាំងអស់ ។ អ្នកចូរមើលចុះ, ដោយការផ្ទាត់អាចម៍ពពែរបស់បុរសខ្វិន បុរសខ្វិននោះ បានស្រុកសួយដែលតាំងនៅក្នុងទិសទាំង ៤ ។*

*( ក៏អាមាត្យ ) ក្នុងសម័យនោះ គឺតថាគតនេះឯង ។*

គ្រានោះ បុរសម្នាក់ ឃើញបុរសខ្វិននោះបានលាភសក្ការៈដូច្នេះ ក៏គិតថា បុរសនេះ ជាមនុស្សខ្វិន អាស្រ័យសិល្បៈនេះ ទើបបានទទួលនូវមហាសម្បត្តិ, សូម្បីយើងក៏គួរសិក្សាសិល្បៈនេះដែរ ។ បុរសនោះក៏ចូលទៅរកបុរសខ្វិន ហើយសំពះសូមរៀនសិល្បៈ ដោយពោលថា បពិត្រអាចារ្យ សូមបង្រៀនសិល្បៈនេះដល់ខ្ញុំផងចុះ ។

បុរសខ្វិនពោលថា ម្នាលបា យើងមិនអាចបង្រៀនបានទេ ។

បុរសនោះត្រូវបុរសខ្វិននោះហាមឃាត់ហើយ ក៏គិតថា ណ្ហើយចុះ, យើងនឹងញ៉ាំងបុរសខ្វិននោះឱ្យត្រេកអរ ទើបធ្វើកិច្ចមានការច្របាច់ដៃ និងជើងជាដើមឱ្យបុរសខ្វិននោះ ញ៉ាំងបុរសខ្វិននោះឱ្យត្រេកអរហើយ អស់កាលដ៏យូរ ក៏អង្វរទៀត ។

បុរសខ្វិននោះគិតថា បុរសនេះជាអ្នកមានឧបការៈដ៏ក្រៃលែងចំពោះយើង ក៏មិនអាចហាមឃាត់បុរសនោះបាន ឱ្យបុរសនោះសិក្សា ហើយពោលថា ម្នាលបា សិល្បៈរបស់អ្នកសម្រេចហើយ, ឥឡូវនេះ អ្នកនឹងធ្វើអ្វី ?

បុរស. ខ្ញុំនឹងទៅល្បងមើលសិល្បៈខាងក្រៅ ។

បុរសខ្វិន. លោកនឹងធ្វើដូចម្តេច ?

បុរស. ខ្ញុំនឹងប្រហារមេគោ ឬមនុស្សឱ្យស្លាប់ ។

បុរសខ្វិនពោលថា ម្នាលបា កាលអ្នកសម្លាប់មេគោនឹងត្រូវពិន័យ ១០០, កាលសម្លាប់មនុស្សនឹងត្រូវពិន័យ ១.០០០, លោកព្រមទាំងបុត្រ និងភរិយាមិនអាចបង់ពិន័យនោះបានដែរ, អ្នកចូរកុំវិនាសឡើយ, អ្នកត្រូវពិចារណារកមើលនូវបុគ្គលណាមួយដែលមិនមានមាតាបិតា ទើបមិនត្រូវពិន័យ ។

បុរសនោះទទួលយល់ព្រមដោយពាក្យថា សាធុ ហើយយក

គ្រាប់ក្រួសដាក់ក្នុងថ្នក់ដើររកបុគ្គលដូច្នោះ ឃើញមេគោហើយ មិន-ហ៊ានប្រហារ ដោយគិតឃើញថា មេគោនេះមានម្ចាស់ ឃើញមនុស្ស ហើយមិនហ៊ានប្រហារ ដោយគិតថា មនុស្សនេះមានមាតាបិតា ។

ក៏ក្នុងសម័យនោះ ព្រះបច្ចេកពុទ្ធព្រះនាម **សុនេត្ត** គង់នៅក្នុងបណ្ណសាលាដែលអាស្រ័យនៅក្នុងព្រះនគរ ។

បុរសនោះ ឃើញព្រះបច្ចេកពុទ្ធនោះ ដែលជាអ្នកចូលទៅកាន់ស្រុកដើម្បីបិណ្ឌបាត ឈរនៅត្រង់ចន្លោះទ្វារនគរ ក៏គិតថា ព្រះបច្ចេកពុទ្ធនេះ ជាអ្នកមិនមានមាតាបិតា, កាលយើងផ្ទាត់គ្រាប់ក្រួសប្រហារព្រះបច្ចេកពុទ្ធនេះរមែងមិនត្រូវពិន័យ, យើងនឹងផ្ទាត់គ្រាប់ក្រួសសំដៅទៅរន្ធត្រចៀកខាងស្តាំរបស់ព្រះបច្ចេកពុទ្ធ ។

ដុំក្រួសចូលទៅតាមរន្ធត្រចៀកខាងស្តាំ ធ្លុះចេញមកតាមរន្ធត្រចៀកខាងឆ្វេង ។ ទុក្ខវេទនាក៏កើតឡើង ។

ព្រះបច្ចេកពុទ្ធ មិនអាចនឹងត្រាច់ទៅដើម្បីភិក្ខាបាន, ក៏ចូល-ទៅកាន់បណ្ណសាលាតាមអាកាស ហើយក៏បរិនិព្វានទៅ ។

ពួកមនុស្សកាលមិនឃើញព្រះបច្ចេកពុទ្ធមក ក៏គិតថា ប្រ-ហែលជាលោកម្ចាស់ដ៏ចម្រើនរបស់ពួកយើង មានអាពាធទេដឹង ក៏ទៅកាន់បណ្ណសាលានោះ ឃើញព្រះបច្ចេកពុទ្ធបរិនិព្វានហើយ សោកខ្សឹកខ្សួល យំរៀបរាប់ ។

បុរសនោះ ឃើញមហាជនទៅកាន់បណ្ណសាលា ក៏ទៅដែរ លុះទៅដល់បណ្ណសាលានោះហើយ ចាំព្រះបច្ចេកពុទ្ធបាន ក៏ពោលថា ព្រះបច្ចេកពុទ្ធអង្គនេះ កាលចូលទៅដើម្បីបិណ្ឌបាត ជួបយើងនៅត្រង់ចន្លោះទ្វារនគរ, យើងកាលនឹងល្បងមើលសិល្បៈរបស់ខ្លួន ក៏ប្រហារព្រះបច្ចេកពុទ្ធអង្គនេះ ។ មហាជនបានឮដូច្នេះ ពោលថា បានឮថា មនុស្សអាក្រក់នេះប្រហារព្រះបច្ចេកពុទ្ធ, អ្នកទាំងឡាយចូរចាប់, វាយប្រហារបុរសនោះឱ្យដល់នូវការអស់ជីវិតក្នុងទីនុ៎ះឯង ។ ក្រោយអំពីស្លាប់ទៅ បុរសនោះក៏កើតក្នុងអវីចិ ឆេះក្នុងនរកនោះរហូតមហាប្រឹថពីដុះឡើងកម្រាស់ ១ យោជន៍ ក្នុងពុទ្ធុប្បាទកាលនេះកើតជាសដ្ឋីកូដប្រេតនៅនាកំពូលភ្នំគិជ្ឈកូដ ដោយផលនៃកម្មដែលនៅសល់ ។

## ព្រះសាស្តាត្រាស់ប្រៀនប្រដៅពួកភិក្ខុ

ព្រះសាស្តា លុះត្រាស់នូវបុព្វកម្មរបស់ប្រេតនោះហើយ ក៏ត្រាស់ថា ម្នាលភិក្ខុទាំងឡាយ សិល្បៈ ឬភាពជាឥស្សរៈ កាលកើតឡើងដល់បុគ្គលពាល គ្រាន់តែដើម្បីសេចក្តីវិនាសប៉ុណ្ណោះ ត្បិតថា បុគ្គលពាលបាននូវសិល្បៈ ឬភាពជាឥស្សរៈហើយ រមែងធ្វើនូវអំពើដែលនាំមកនូវសេចក្តីវិនាសឱ្យដល់ខ្លួនតែប៉ុណ្ណោះ ដូច្នេះហើយ កាលនឹងទ្រង់បន្តអនុសន្ធិដើម្បីសម្តែងធម៌ ក៏ត្រាស់ព្រះគាថានេះថា :

**យាវទេវ អនត្ថាយ ញត្តំ ពាលស្ស ជាយតិ**
**ហន្តិ ពាលស្ស សុក្កំសំ មុទ្ធំ អស្ស[១] វិបាតយំ ។**

ការចេះដឹង កើតឡើងដល់បុគ្គលពាល គ្រាន់តែដើម្បីសេចក្ដីវិនាសប៉ុណ្ណោះ រមែងញាំងបញ្ញាឱ្យធ្លាក់ចុះ បំផ្លិចបំផ្លាញចំណែកធម៌ស គឺកុសលរបស់បុគ្គលពាលនោះ ។

## អធិប្បាយគាថា

សព្ទថា **យាវទេវ** ក្នុងគាថានេះជានិបាត ក្នុងអត្ថថា គឺការកំណត់នូវព្រំដែន ។ ការចេះដឹង ឈ្មោះថា **ញត្តំ** ។ បុគ្គលរមែងចេះដឹងនូវសិល្បៈណានីមួយ, ឬបុគ្គលតាំងនៅក្នុងភាពជាធំណាមួយ ឬដោយការដល់ព្រមដោយយសណាមួយ ដែលជនរមែងដឹង គឺប្រាកដបានដល់ជាអ្នកដឹងទូទៅ ។ ពាក្យថា **ញត្តំ** នេះ ជាឈ្មោះនៃសិល្បៈ ភាពជាធំ និងការដល់ព្រមដោយយសនោះឯង ។

ពិតណាស់ សិល្បៈ ឬភាពជាធំជាដើម កើតឡើងដល់បុគ្គលពាល គ្រាន់តែដើម្បីសេចក្ដីវិនាសប៉ុណ្ណោះ គឺបុគ្គលពាលនោះអាស្រ័យសិល្បៈជាដើមនោះហើយ រមែងធ្វើសេចក្ដីវិនាសឱ្យដល់ខ្លួនឯងតែប៉ុណ្ណោះ ។

បទថា **ហន្តិ** បានដល់ ឱ្យវិនាស ។

---

១= ម. ពុទ្ធិមស្ស ។

បទថា **សុក្កំសំ** គឺ ចំណែកនៃកុសល ។ អធិប្បាយថា សិល្បៈ ឬភាពជាធំ កាលកើតឡើងដល់បុគ្គលពាល រមែងកើតឡើងដើម្បីសម្លាប់នូវចំណែកនៃកុសលតែប៉ុណ្ណោះ ។

បទថា **មុទ្ធំ** ជាឈ្មោះនៃបញ្ញា ។

បទថា **វិបាតយំ** គឺកម្ចាត់, អធិប្បាយថា ក៏ការចេះដឹងនោះ រមែងសម្លាប់ចំណែកនៃកុសលរបស់បុគ្គលពាលនោះ ញុំាង**មុទ្ធា** ពោលគឺបញ្ញាឱ្យធ្លាក់ចុះ គឺកម្ចាត់នោះឯង ឈ្មោះថា សម្លាប់ ។

ក្នុងកាលចប់ទេសនា ជនជាច្រើន សម្រេចអរិយផលទាំង-ឡាយ មានសោតាបត្តិផលជាដើម ។

## ( ចប់រឿងសដ្ឋីកូដប្រេត )

# ៣-រឿងអជគរប្រេត

" ប្រេតមានសរីរៈដូចជាសរីរៈនៃពស់ថ្លាន់ "

( ទណ្ឌវគ្គទី ១០ គាថាទី ៨ បិដកលេខ ៥២, ទំព័រ ៥០ និងអដ្ឋកថា )

## សេចក្ដីខាងដើម

ព្រះសាស្ដា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធអជគរ-ប្រេត បានត្រាស់ព្រះធម្មទេសនានេះថា " **អថ បាបានិ កម្មានិ** " ជាដើម ។

## ( ព្រះមហាមោគ្គល្លានឃើញប្រេតត្រូវភ្លើងឆេះ )

សេចក្ដីពិស្ដារថា ក្នុងសម័យមួយ ព្រះមហាមោគ្គល្លានត្ថេរ និងព្រះលក្ខណត្ថេរចុះអំពីភ្នំគិជ្ឈកូដ បានឃើញអជគរប្រេត មាន-អត្តភាពប្រមាណ ២៥ យោជន៍ ដោយទិព្វចក្ខុ ។ អណ្ដាតភ្លើងតាំងឡើងអំពីក្បាលរបស់ប្រេតនោះ ឆេះរាលដល់កន្ទុយ, តាំងឡើងអំពីកន្ទុយ ឆេះរាលដល់ក្បាល, តាំងឡើងអំពីខាងទាំងពីរ ប្រជុំចុះនៅត្រង់កណ្ដាលខ្លួន ។

## ( តំណាលការឃើញប្រេតឱ្យព្រះលក្ខណត្ថេរស្ដាប់ )

ព្រះថេរៈ លុះឃើញប្រេតនោះហើយ ក៏បានធ្វើការញញឹម

ឱ្យប្រាកដ ព្រះលក្ខណត្ថេរបានសួរនូវហេតុការញញឹមនោះហើយ ព្រះមហាមោគ្គល្លានក៏ប្រាប់ថា ម្នាលអ្នកមានអាយុ កាលនេះ មិនមែនជាកាលសមគួរនឹងព្យាករបញ្ហានេះទេ, ចាំសួរខ្ញុំក្នុងសម្នាក់ព្រះសាស្តាចុះ ត្រាច់ទៅបិណ្ឌបាតក្នុងក្រុងរាជគ្រឹះហើយ កាលទៅកាន់សម្នាក់ព្រះសាស្តា ព្រះលក្ខណត្ថេរសួរ ក៏ឆ្លើយប្រាប់ថា ម្នាល-អ្នកមានអាយុ ខ្ញុំបានឃើញប្រេតមួយក្នុងទីនោះ, អត្តភាពរបស់វាមានសភាពបែបនេះ លុះខ្ញុំឃើញហើយ ក៏ធ្វើនូវការញញឹមឱ្យប្រាកដ ដោយគិតថា អត្តភាពបែបនេះ យើងមិនធ្លាប់បានឃើញឡើយ ។

**( ព្រះសាស្តាក៏ព្រះអង្គធ្លាប់ឃើញប្រេតនោះដែរ )**

ព្រះសាស្តា ត្រាស់ពាក្យជាដើមថា ម្នាលភិក្ខុទាំងឡាយ សាវ័ករបស់តថាគត ជាអ្នកមានចក្ខុហ្ន៎ ទ្រង់ទទួលពាក្យរបស់ព្រះថេរៈហើយ មានព្រះពុទ្ធដីកាថា ម្នាលភិក្ខុទាំងឡាយ ប្រេតនុ៎ះ សូម្បីតថាគតក៏បានឃើញដែរ តថាគតបានឃើញប្រេតនោះ តាំងពីតថាគតគង់នៅពោធិមណ្ឌលម្ល៉េះ, ប៉ុន្តែតថាគតមិនបានសម្តែង-ឡើង ព្រោះគិតថា ពួកជនណា មិនជឿពាក្យរបស់តថាគត ការមិនជឿរបស់ជនទាំងនោះ រមែងប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ ឥឡូវនេះ តថាគតបានមោគ្គល្លានជាសាក្សីហើយ ទើបពោល, ភិក្ខុទាំងឡាយ ក៏ទូលសួរបុព្វកម្មរបស់ប្រេតនោះ ព្រះសាស្តាក៏ទ្រង់-

ព្យាករ ដូចតទៅនេះថា :

## ( **បុព្វកម្មរបស់អជគរប្រេត** )

បានឮថា ក្នុងកាលនៃព្រះពុទ្ធព្រះនាមកស្សបៈ មានសេដ្ឋីម្នាក់ឈ្មោះ **សុមង្គល** ក្រាលឥដ្ឋមាសលើផែនដី ឱ្យគេសាងវិហារក្នុងទីប្រមាណ ២០ ឧសភៈ[១] ដោយទ្រព្យប៉ុណ្ណោះហើយ ក៏ឱ្យធ្វើការឆ្លងដោយទ្រព្យប៉ុណ្ណោះដែរ ។ ថ្ងៃមួយ លោកសេដ្ឋីទៅកាន់សម្នាក់ព្រះសាស្ដាអំពីព្រលឹម បានឃើញចោរម្នាក់ ដេកទទូរសំពត់កាសាយៈពីចុងជើងរហូតដល់ក្បាល ទាំងមានជើងប្រឡាក់ភក់ផង ក្នុងសាលាមួយ ជិតទ្វារព្រះនគរ បានពោលដូច្នេះថា បុគ្គលនេះមានជើងប្រឡាក់ភក់ ទំនងជាមនុស្សដើរយប់ហើយមើលទៅ ។

## ( **កម្មអាក្រក់ឱ្យផលអាក្រក់** )

ចោរបើកមុខឃើញសេដ្ឋីហើយ ក៏គិតក្នុងចិត្តថា លើកទុកសិនចុះ, យើងនឹងដឹងនូវអំពើដែលយើងគប្បីធ្វើដល់បុគ្គលនេះ ហើយក៏ចងអាឃាតទុក ក្រោយមក បានទៅដុតស្រែរបស់លោកសេដ្ឋីអស់ ៧ ដង កាត់ជើងគោទាំងឡាយក្នុងក្រោល ៧ ដង ដុតផ្ទះ ៧ ដង ។ ចោរនោះមិនអាចញុំាងសេចក្ដីក្រោធឱ្យរលត់ទៅ ដោយអំពើមាន-

**១-** ១ ឧសភៈ ស្មើនឹង ១៤០ ហត្ថ ( ៧០ ម៉ែត្រ ) ដូច្នេះ ២០ ឧសភៈ = ២,៨០០ហត្ថ ( ១៤០០ ម៉ែត្រ ), ៨០ ឧសភៈ = ១ គាវុត ( ៥,៦០០ ម៉ែត្រ ), ៤ គាវុត = ១ យោជន៍ ( **២២,៤០០ ម៉ែត្រ** ), ន័យខ្លះថា ១ យោជន៍ = ៤០០ សិន **(** ១ សិន = ២០ ព្យាម ( ៤០ ម៉ែត្រ ), **៤០០ សិន = ១៦,០០០ ម៉ែត្រ )** ។

*( ចាកវចនានុក្រមសម្ដេចព្រះសង្ឃរាជជួន ណាត* ***ជោតញ្ញាណោ*** *ទំព័រ ៦៨៣ ) ។*

ប្រមាណប៉ុណ្ណោះបាន ទើបធ្វើនូវសេចក្តីស្និទ្ធស្នាល ដោយភាវៈជាមិត្តនឹងបុរសដែលជាកូនឈ្នួលរបស់លោកសេដ្ឋី រួចសួរថា អ្វីជាទីស្រឡាញ់នៃចៅហ្វាយរបស់អ្នកឯងជាងគេ ? បានដឹងថា វត្ថុដែល-ជាទីស្រឡាញ់បំផុតនៃលោកសេដ្ឋី ក្រៅពីព្រះគន្ធកុដិមិនមាន គិតថាល្អហើយ យើងនឹងដុតព្រះគន្ធកុដិដើម្បីរំលត់កំហឹងរបស់យើង, កាលព្រះសាស្តា ស្តេចយាងចូលទៅបិណ្ឌបាត, បានវាយបំបែកក្អមទឹកឆាន់និងទឹកប្រើប្រាស់រួចហើយ ឆ្កលភ្លើងដុតព្រះគន្ធកុដិ ។

សេដ្ឋីបានឮដំណឹងថា ព្រះគន្ធកុដិត្រូវភ្លើងឆេះ ក៏ដើរទៅមើល លុះទៅដល់ភ្លើងក៏ឆេះព្រះគន្ធកុដិអស់ គាត់សម្លឹងមើលព្រះ-គន្ធកុដិ ដែលត្រូវភ្លើងឆេះនោះ ដោយមិនបានញ៉ាំងទោមនស្សឱ្យកើតឡើង សូម្បីតែប៉ុនរោមទ្រាយ បែរជាទះដៃខ្លាំង ៧ ទៅវិញ ។

ខណៈនោះ ប្រជាជនដែលឈរនៅក្បែរនោះ សួរលោក-សេដ្ឋី ហេតុអ្វីទើបលោកទះដៃ នៅពេលដែលព្រះគន្ធកុដិ ដែលលោកចំណាយទ្រព្យប៉ុណ្ណេះកសាង ត្រូវភ្លើងឆេះ ?

សេដ្ឋីឆ្លើយថា ពុកម៉ែទាំងឡាយ ខ្ញុំធ្វើកម្មប្រមាណប៉ុណ្ណេះឈ្មោះថា បានកប់ទ្រព្យក្នុងព្រះសាសនាដែលមិនជាសាធារណៈដល់អន្តរាយទាំងឡាយ មានភ្លើងជាដើម, ទើបខ្ញុំមានចិត្តរីករាយ ទះដៃដោយគិតថា យើងនឹងបានចំណាយទ្រព្យប្រមាណប៉ុណ្ណេះ សាងព្រះ-

គន្ធកុដិថ្វាយព្រះសាស្តាទៀត ។

សេដ្ឋីចំណាយទ្រព្យប្រមាណប៉ុណ្ណោះ សាងព្រះគន្ធកុដិ ថ្វាយ-ចំពោះព្រះសាស្តា ដែលមានភិក្ខុសង្ឃ ២ ម៉ឺនរូប ជាបរិវារម្តងទៀត។

ចោរឃើញកិរិយានោះហើយ គិតថា បើយើងមិនសម្លាប់សេដ្ឋីនេះទេ នឹងមិនអាចរំលត់កំហឹងបានទេ ណ្ហើយចុះ យើងនឹងសម្លាប់វា, លុះគិតដូច្នេះហើយ ក៏សៀតកូនកាំបិតទុកក្នុងជាយសំពត់ស្លៀក ដើរទៅកាន់វិហារអស់ ៧ ថ្ងៃ ប៉ុន្តែមិនបានឱកាស ។

ចំណែកមហាសេដ្ឋី ថ្វាយទានដល់ភិក្ខុសង្ឃ មានព្រះពុទ្ធជាប្រធានអស់ ៧ ថ្ងៃ ថ្វាយបង្គំព្រះសាស្តាហើយ ក្រាបទូលថា បពិត្រព្រះអង្គដ៏ចម្រើន បុរសម្នាក់ដុតស្រែរបស់ខ្ញុំព្រះអង្គ ៧ ដង កាត់ជើងគោក្នុងក្រោល ៧ ដង, ដុតផ្ទះ ៧ ដង សូម្បីព្រះគន្ធកុដិក៏ប្រហែលជាបុគ្គលនោះដុតដែរហើយមើលទៅ, ដូច្នេះ ខ្ញុំព្រះអង្គសូមឱ្យចំណែកបុណ្យដែលកើតអំពីការធ្វើទាននេះ ដល់អ្នកនោះមុន-គេ ។

## ( **អ្នកធ្វើកម្មល្អរមែងឈ្នះអ្នកធ្វើកម្មអាក្រក់** )

ចោរបានឮពាក្យនោះហើយ គិតថា យើងបានធ្វើកម្មដ៏ធ្ងន់ ប៉ុន្តែសេដ្ឋីនេះ មិនបានញ៉ាំងសេចក្តីក្រោធ សូម្បីតែបន្តិចបន្តួចចំពោះយើង ដែលជាអ្នកធ្វើនូវកំហុសយ៉ាងនេះ, ( បែរជាឱ្យ )

ចំណែកបុណ្យក្នុងទាននេះដល់យើងមុនគេទៀតផង, ការដែលយើងគិតប្រទូស្តចំពោះសេដ្ឋីនេះ មិនសមគួរឡើយ បើយើងមិនញ៉ាំងសេដ្ឋីនេះឱ្យអត់ទោសឱ្យទេ, **ទេវទណ្ឌ**ពិតជាធ្លាក់មកត្រូវក្បាលរបស់យើងមិនខាន លុះគិតដូច្នេះហើយ ក៏ចូលទៅក្រាបនៅក្បែរជើងរបស់សេដ្ឋីហើយពោលថា បពិត្រលោកសេដ្ឋី សូមលោកអត់នូវទោសនោះឱ្យខ្ញុំផងចុះ, កាលសេដ្ឋីពោលថា មានរឿងអ្វី ៗ ? ក៏ប្រាប់ថា បពិត្រសេដ្ឋីខ្ញុំបានធ្វើកម្មប៉ុណ្ណេះ ៗ, សូមលោកអត់ទោសនោះដល់ខ្ញុំផង ។

គ្រានោះ សេដ្ឋីសួរកម្មគ្រប់ ៗ ប្រការ នឹងបុរសនោះថា អ្នកធ្វើកម្មនេះផង នេះផងឬ ? កាលចោរទទួលសារភាពថា បាទលោកសេដ្ឋី ខ្ញុំបានធ្វើមែន បានសួរតទៅទៀតថា យើងមិនធ្លាប់ឃើញអ្នកឯងទេ, ហេតុអ្វីទើបអ្នកក្រោធខឹងយើង ហើយធ្វើនូវអំពើយ៉ាងនេះចំពោះយើង ?

បុរសនោះ ញ៉ាំងសេដ្ឋីឱ្យរឭកឃើញនូវពាក្យដែលសេដ្ឋីពោលក្នុងកាលដែលខ្លួនចេញអំពីព្រះនគរ ហើយបានប្រាប់សេដ្ឋីថា ខ្ញុំខឹងនឹងលោក ព្រោះហេតុនេះឯង ។

សេដ្ឋីរឭកដល់ពាក្យដែលខ្លួនពោលបានហើយ ឱ្យចោរអត់ទោសឱ្យដោយពាក្យថា ម្នាលអ្នកដ៏ចម្រើន យើងបាននិយាយពាក្យនោះពិតមែន, អ្នកចូរអត់នូវទោសនោះដល់ខ្ញុំផង, ហើយពោល-

ថា ក្រោកឡើងចុះ យើងអត់ទោសឱ្យអ្នក ចូរអ្នកទៅចុះ ។

ចោរ. បពិត្រសេដ្ឋី បើលោកអត់ទោសឱ្យខ្ញុំសោត, សូមលោកធ្វើខ្ញុំព្រមទាំងបុត្រ និងភរិយាឱ្យជាទាសៈនៅក្នុងផ្ទះរបស់លោក ផងចុះ ។

សេដ្ឋី. នែអ្នក យើងពោលពាក្យប៉ុណ្ណឹង, អ្នកបានធ្វើនូវអំពើបែបនេះ, យើងមិនអាចនឹងពោលនូវពាក្យអ្វី ៗ ជាមួយអ្នកនៅក្នុងផ្ទះរបស់យើងបានឡើយ, កិច្ចដែលអ្នកនៅក្នុងផ្ទះរបស់យើងមិនមាន, យើងអត់ទោសឱ្យអ្នកឯងហើយ អ្នកឯងទៅវិញចុះ ។

ចោរធ្វើកម្មនោះហើយ លុះអស់អាយុ កើតក្នុងអវិចីនរក ឆេះក្នុងអវិចីនោះអស់កាលដ៏យូរ ក្នុងសម័យនៃព្រះសម្មាសម្ពុទ្ធយើងនេះ កើតជា**អជគរប្រេត** ត្រូវភ្លើងឆេះនៅត្រង់ភ្នំគិជ្ឈកូដ ដោយវិបាកនៃកម្មដ៏សេស ។

ព្រះសាស្តា ត្រាស់បុព្វកម្មរបស់ប្រេតនោះហើយ មានព្រះពុទ្ធដីកាថា ម្នាលភិក្ខុទាំងឡាយ បុគ្គលពាលធ្វើកម្មអាក្រក់មិនដែលដឹងឡើយ, ប៉ុន្តែក្រោយមក រមែងក្តៅក្រហាយ ព្រោះកម្មដែលខ្លួនធ្វើហើយនោះ ដូចជាភ្លើងឆេះព្រៃ, កាលនឹងទ្រង់បន្តអនុសន្ធិដើម្បីសម្តែងធម៌ បានត្រាស់ព្រះគាថានេះថា :

**អថ បាបានិ កម្មានិ ករំ ពាលោ ន ពុជ្ឈតិ**

**សេហិ កម្មេហិ ទុម្មេធោ អគ្គិទឌ្ឍោវ តប្បតិ ។**

*បុគ្គលមិនមានប្រាជ្ញា កាលធ្វើអំពើអាក្រក់ រមែងមិនភ្ញាក់ខ្លួន លុះកាលជាខាងក្រោយ ទើបក្តៅក្រហាយ ដោយសារកម្មរបស់ខ្លួន ដូចត្រូវភ្លើងឆេះ ។*

## អធិប្បាយគាថា

បណ្តាបទទាំងនោះ បទថា **អថ ពាលោ** សេចក្តីថា ជនពាល មិនត្រឹមតែធ្វើបាបទាំងឡាយ ដោយអំណាចនៃសេចក្តីក្រោធប៉ុណ្ណោះទេ, សូម្បីកាលធ្វើក៏មិនដឹងខ្លួន, តែកាលធ្វើបាប មិនមែនមិនដឹងថា យើងធ្វើបាបទេ ព្រះមានព្រះភាគត្រាស់ថាមិនដឹង ព្រោះមិនដឹងថា ផលរបស់កម្មនេះ មានសភាពបែបនេះ ។

បទថា **សេហិ** សេចក្តីថា ព្រោះកម្មដែលខ្លួនធ្វើហើយនោះ ។

បទថា **ទុម្មេធោ** សេចក្តីថា បុគ្គលមិនមានប្រាជ្ញា កើតក្នុងនរក រមែងក្តៅក្រហាយ ដូចត្រូវភ្លើងឆេះ ។

លុះចប់ទេសនា ជនជាច្រើន បានសម្រេចអរិយផលទាំងឡាយ មានសោតាបត្តិផលជាដើម ដូច្នេះឯង ។

**( ចប់រឿងអជគរប្រេត )**

# ៤-រឿងសូករប្រេត

" ប្រេតជ្រូក "

( មគ្គវគ្គទី ២០ គាថាទី ៩ បិដកលេខ ៥២, ទំ.៧៩ និងអដ្ឋកថា )

## សេចក្ដីខាងដើម

ព្រះសាស្ដា កាលគង់នៅក្នុងវត្តវេឡុវ័ន ទ្រង់ប្រារព្ធ-សូករប្រេត ត្រាស់ព្រះធម្មទេសនានេះថា " **ទាចានុរក្ខី** " ជាដើម ។

## ( ព្រះមហាមោគ្គល្លានឃើញប្រេត )

សេចក្ដីពិស្ដារថា ថ្ងៃមួយ ព្រះមហាមោគ្គល្លានចុះអំពីភ្នំគិជ្ឈកូដជាមួយនឹងព្រះលក្ខណត្ថេរ បានធ្វើការញញឹមក្នុងប្រទេសមួយ កាលព្រះលក្ខណត្ថេរសួរថា " នែ លោកមានអាយុ អ្វីហ្ន៎ ជាហេតុនៃការធ្វើញញឹមឱ្យប្រាកដ ? " ក៏ឆ្លើយថា " នែ អ្នកមានអាយុកាលនេះមិនមែនជាកាលនៃបញ្ហានេះទេ, លោកគប្បីសួរខ្ញុំក្នុង-សម្នាក់ព្រះសាស្ដា " ដូច្នេះហើយត្រាច់បិណ្ឌបាតនៅក្នុងក្រុងរាជគ្រឹះជាមួយនឹងលក្ខណត្ថេរនោះឯង ត្រឡប់មកអំពីបិណ្ឌបាតហើយ ចូលទៅកាន់វត្តវេឡុវ័នថ្វាយបង្គំព្រះសាស្ដាហើយ គង់ក្នុងទីដ៏សមគួរ ។ គ្រានោះ ព្រះលក្ខណត្ថេរសួរសេចក្ដីនោះនឹងព្រះមហាមោគ្គល្លាន ។

ព្រះមហាមោគ្គល្លានឆ្លើយថា " នែ អ្នកមានអាយុ ខ្ញុំបានឃើញប្រេត-មួយ, សរីរៈរបស់វាប្រមាណ ៣ គាវុត, សរីរៈនោះ ស្រដៀងសរីរៈរបស់មនុស្ស ចំណែកក្បាលរបស់វាដូចក្បាលជ្រូក, កន្ទុយរបស់វាកើតក្នុងមាត់, ដង្កូវទាំងឡាយវារចេញចាកមាត់នោះ ខ្ញុំគិតថាយើងបានឃើញសត្វមានសភាពបែបនេះ លុះឃើញប្រេតនោះហើយក៏បានធ្វើការញញឹមឱ្យប្រាកដ " ។

## ( ព្រះសាស្តាត្រាស់ទទួលស្គាល់ )

ព្រះសាស្តាត្រាស់ថា " ម្នាលភិក្ខុទាំងឡាយ សាវ័ករបស់តថាគតមានចក្ខុកើតឡើងហើយហ្ន៎ " ហើយត្រាស់ថា " តថាគតឃើញសត្វនោះ ក្នុងប្រទេសជាទីផ្សំផង់នៃប្រាជ្ញា ជាគ្រឿងត្រាស់ដឹង ។ ប៉ុន្តែតថាគតមិនសម្តែង ដោយសេចក្តីអនុគ្រោះដល់ជនពួកដទៃថា ក៏ជនទាំងឡាយណា មិនជឿពាក្យរបស់តថាគត ការមិនជឿនោះជាកម្មប្រព្រឹត្តទៅដើម្បីមិនជាប្រយោជន៍ដល់ជនទាំងនោះ , ឥឡូវនេះ តថាគតបានមោគ្គល្លានជាសាក្សីទើបសម្តែង ម្នាលភិក្ខុ-ទាំងឡាយ រឿងដែលមោគ្គល្លានពោលនោះ គឺជារឿងពិត ។

ភិក្ខុទាំងឡាយ ស្តាប់រឿងនោះហើយ ទូលសួរព្រះសាស្តាថា " បពិត្រព្រះអង្គដ៏ចម្រើន ក៏បុព្វកម្មរបស់ប្រេតនោះដូចម្តេច ? " ព្រះសាស្តាត្រាស់ថា " ម្នាលភិក្ខុទាំងឡាយ បើដូច្នោះ អ្នកទាំងឡាយ

ចូរស្តាប់ដោយសេចក្តីគោរពចុះ ” ហើយទ្រង់នាំអតីតនិទានមកត្រាស់បុព្វកម្មរបស់ប្រេតនោះ ( តទៅនេះ ) ។

## ( បុព្វកម្មរបស់សូករប្រេត )

បានឮថា ក្នុងកាលនៃព្រះពុទ្ធទ្រង់ព្រះនាមកស្សបៈ , ព្រះថេរៈពីររូបព្រមព្រៀងគ្នា នៅក្នុងអាវាសជិតស្រុកតូចមួយ, បណ្តាព្រះ-ថេរៈពីររូបនោះ ព្រះថេរៈមួយរូបមានវស្សា ៦០ មួយរូបទៀតមានវស្សា ៥៩ ព្រះថេរៈដែលមានវស្សា ៥៩ នោះ កាន់បាត្រ និងចីវររបស់ព្រះថេរៈក្រៅនេះត្រាច់ទៅ, បានធ្វើកិច្ចវត្តគ្រប់យ៉ាង ដូចជាសាមណេរ ។ កាលព្រះថេរៈទាំងពីររូបនោះ នៅព្រមព្រៀងគ្នាដូចជាបងប្អូនរួមផ្ទៃជាមួយ, ព្រះថេរៈជាធម្មកថិកមួយរូបមកកាន់លំនៅ ( របស់ព្រះថេរៈទាំងពីររូបនោះ ) ។ ក៏ក្នុងកាលនោះជាថ្ងៃធម្មស្សវនៈ ។ ព្រះថេរៈទាំងពីររូបនោះសង្គ្រោះធម្មកថិក ហើយពោលថា “ នែ សប្បុរស សូមលោកពោលធម្មកថាដល់ពួកខ្ញុំចុះ ” ។ ព្រះធម្មកថិកនោះ ក៏ពោលធម្មកថា ។ ព្រះថេរៈទាំងពីររូបនោះមានចិត្តត្រេកអរថា “ ពួកយើងបានព្រះធម្មកថិកហើយ ” ស្អែកឡើងនាំព្រះធម្មកថិកនោះ ចូលទៅកាន់ស្រុកដ៏ជិត ដើម្បីបិណ្ឌបាត ធ្វើភត្តកិច្ចក្នុងស្រុកនោះហើយ ពោលថា “ នែអាវុសោ លោកចូរពោលធម្មកថាបន្តិចអំពីធម្មកថា ដែលលោកបានបញ្ឈប់ពីថ្ងៃម្សិល ” ហើយ

ញ៉ាំងព្រះធម្មកថិកនោះ ឱ្យពោលធម៌ដល់ពួកមនុស្ស ។ ពួកមនុស្ស បានស្តាប់ធម្មកថាហើយ និមន្តដើម្បី ( ឱ្យឆាន់ ) ក្នុងថ្ងៃស្អែក ។ ព្រះថេរៈទាំងពីរអង្គនាំព្រះធម្មកថិកនោះ ត្រាច់ទៅបិណ្ឌបាតក្នុងស្រុក ជាទីត្រាច់ទៅដើម្បីភិក្ខាអស់ថ្ងៃទាំងឡាយពីរ ๆ ( ក្នុងស្រុក-នីមួយ ๆ ពីរថ្ងៃ ) ដោយជុំវិញយ៉ាងនេះ ។ ព្រះធម្មកថិកនោះគិតថា " ព្រះថេរៈទាំងពីររូបនេះ ជាអ្នកទន់ភ្លន់ក្រៃលែង, កិរិយា គឺ អញញ៉ាំងព្រះថេរៈទាំងពីររូបនេះ ឱ្យចេញទៅហើយ នៅក្នុងវត្តនេះគួរ " ។ ពេលរសៀល ព្រះធម្មកថិករូបនោះចូលទៅកាន់សាលា ជាទីបម្រើព្រះថេរៈ ក្នុងវេលាដែលព្រះថេរៈទាំងពីររូបនោះ ក្រោកឡើងទៅ ហើយត្រឡប់ចូលទៅរកព្រះមហាថេរៈ ហើយនិយាយថា " បពិត្រលោកម្ចាស់ដ៏ចម្រើន រឿងបន្តិចដែលខ្ញុំគួរពោល មាន " កាលព្រះមហាថេរៈពោលថា " នែអាវុសោ ចូរពោលមកចុះ " គិតបន្តិច ហើយពោលថា " បពិត្រលោកម្ចាស់ដ៏ចម្រើន ដែលឈ្មោះថាសម្តីជារបស់មានទោសច្រើន " មិនពោលពាក្យអ្វីសោះ ហើយចៀសចេញទៅ ។ ព្រះធម្មកថិកនោះទៅកាន់សម្នាក់ព្រះអនុត្ថេរក៏បានធ្វើដោយប្រការ ដូច្នោះដែរ ។ ក្នុងថ្ងៃទី ២ លោកក៏បានធ្វើដោយប្រការ យ៉ាងនោះទៀត, ក្នុងថ្ងៃទី ៣ កាលការភ្ញាក់ផ្អើលក្រៃ-លែងកើតឡើងដល់ព្រះថេរៈទាំងពីររូបនោះហើយ, ចូលទៅរកព្រះ-

ព្រះមហាថេរៈ ហើយនិយាយថា "បពិត្រលោកម្ចាស់ដ៏ចម្រើន ពាក្យ-ខ្លះដែលខ្ញុំគប្បីពោលមាន, ប៉ុន្តែ ខ្ញុំមិនអាចពោលក្នុងសម្នាក់របស់លោកម្ចាស់បាន " ត្រូវព្រះថេរៈជំរឹតសួរថា " មិនជាអ្វីទេ អាវុសោ អ្នកចូរពោលមកចុះ " ក៏ពោលថា " បពិត្រលោកម្ចាស់ដ៏ចម្រើន ហេតុដូចម្តេច ទើបព្រះអនុត្ថេរ មិនត្រូវនឹងលោកម្ចាស់ ? " ។

ព្រះមហា. នែ អ្នកសប្បុរស អ្នកនិយាយអ្វី, យើងទាំងពីរដូចជាបុត្រដែលនៅក្នុងផ្ទៃមាតាតែមួយ បណ្តាយើងទាំងពីរនាក់ អ្នកណាបានវត្ថុអ្វីហើយ អ្នកក្រៅនេះក៏ឈ្មោះថាបានដែរ , ទោសរបស់ព្រះថេរៈនោះជាសភាពដែលយើងធ្លាប់ឃើញ រមែងមិនមាន អស់-កាលប្រមាណប៉ុណ្ណេះ ។

ព្រះធម្ម. បពិត្រលោកម្ចាស់ដ៏ចម្រើន យ៉ាងហ្នឹងឬ ?

ព្រះមហា. អើ អាវុសោ ។

ព្រះធម្ម. បពិត្រលោកម្ចាស់ដ៏ចម្រើន ព្រះអនុត្ថេរនិយាយនឹងខ្ញុំយ៉ាងនេះថា នែអ្នកសប្បុរស អ្នកជាកុលបុត្រ អ្នកគប់រកព្រះ-មហាថេរៈនោះ ដោយការធ្វើទុកក្នុងចិត្តថា ព្រះមហាថេរៈនេះជាអ្នកខ្មាសបាប ជាអ្នកមានសីលជាទីស្រឡាញ់ , គប្បីពិចារណាហើយទើបធ្វើ , តាំងអំពីថ្ងៃដែលខ្ញុំមកដល់ ព្រះអនុត្ថេរនោះបាននិយាយនឹងខ្ញុំយ៉ាងនេះ ។

ព្រះមហាថេរៈ ស្តាប់នូវពាក្យនោះភ្លាម ក៏មានចិត្តក្រោធបែក ហើយដូចភាជនៈ ដែលគេធ្វើអំពីដី ដែលបុគ្គលវាយដោយដំបង ដូច្នោះ ។ ព្រះធម្មកថិកក្រៅនេះ ក្រោកឡើងហើយទៅកាន់សម្នាក់ អនុត្ថេរ ហើយបានពោលពាក្យដូច្នេះទៀត ។ សូម្បីអនុត្ថេរក៏បែកចិត្ត ហើយដូច្នោះដែរ ។ បណ្តាព្រះថេរៈទាំងពីររូបនោះ ព្រះថេរៈសូម្បី តែមួយរូបឈ្មោះថា ជាអ្នកធ្លាប់ចូលទៅហើយដើម្បីបិណ្ឌបាតផ្សេង-គ្នា រមែងមិនមានអស់កាលប្រមាណប៉ុណ្ណេះ ក៏ពិតមែនហើយ ប៉ុន្តែ ថ្ងៃស្អែកឡើង ព្រះថេរៈទាំងពីររូបនោះចូលទៅបិណ្ឌបាតផ្សេងគ្នា , ព្រះអនុត្ថេរមកដល់មុនហើយ បានឈរនៅក្នុងសាលាជាទីបម្រើ, ព្រះមហាថេរៈមកដល់ក្រោយ ។ ព្រះអនុត្ថេរឃើញព្រះមហាថេរៈ ហើយ ក៏គិតថា " អញគួរទទួលបាត្រ និងចីវររបស់ព្រះថេរៈនេះ ឬក៏មិនគួរទទួលហ្ន៎ " សូម្បីលោកគិតថា "ឥឡូវនេះ យើងមិនទទួល" ដូច្នេះហើយ ក៏ធ្វើចិត្តឱ្យជាធម្មតាទន់បាន ដោយធ្វើទុកក្នុងចិត្តថា " ការមិនទទួលបាត្រ និងចីវររបស់ព្រះមហាថេរៈរូបនេះ ចូរលើក ទុកសិនចុះ អំពើបែបនេះអញមិនដែលធ្វើឡើយ, ការដែលអញញាំង-វត្តរបស់ខ្លួនឱ្យសាបសូន្យ មិនគួរឡើយ " លុះគិតដូច្នេះហើយ ក៏ចូល ទៅជិតព្រះថេរៈហើយពោលថា " បពិត្រលោកម្ចាស់ដ៏ចម្រើន សូម-លោកម្ចាស់ឱ្យបាត្រ និងចីវរមកខ្ញុំ " ។ ព្រះមហាថេរៈក្រៅនេះ

ចង្អុលមុខហើយ ពោលថា " នែភិក្ខុប្រដៅក្រ ចូរទៅចុះ អ្នកមិនគួរ ទទួលបាត្រ និងចីវររបស់យើងទេ " កាលអនុត្ថេរនោះពោលថា " អើ លោកម្ចាស់ សូម្បីខ្ញុំក៏បានគិតហើយថា នឹងមិនទទួលបាត្រ និងចីវររបស់លោកម្ចាស់ដែរ " ពោលថា នែ អាវុសោ ហេតុដូចម្ដេច ទើបអ្នកគិតថា ការជាប់ជំពាក់នឹងវត្ថុអ្វី ៗ ក្នុងវិហារនេះជារបស់ យើងមាន " ។ សូម្បីអនុត្ថេរក្រៅនេះក៏ពោលថា "បពិត្រលោកម្ចាស់ ដ៏ចម្រើន ហេតុដូចម្ដេចទើបលោកម្ចាស់សម្គាល់យ៉ាងនេះថា ការ-ជាប់ជំពាក់នឹងវត្ថុណា ៗ ក្នុងវិហារនេះរបស់ខ្ញុំមាន ? នេះជាវិហារ របស់លោកម្ចាស់ " លុះពោលដូច្នោះហើយ ក៏កាន់បាត្រ និងចីវរ ចៀសចេញទៅ ។ ចំណែកព្រះមហាថេរៈក្រៅនេះក៏ចៀសចេញទៅ ដែរ ។

ព្រះថេរៈទាំងពីររូបនោះ មិនបាននិមន្តទៅផ្លូវជាមួយគ្នាទេ , មួយរូបកាន់យកផ្លូវតាមទ្វារទិសបច្ឆិម , មួយរូបទៀតកាន់យកផ្លូវតាម ទ្វារទិសបុរត្ថិម ( ទិសខាងកើត ) ។ ព្រះធម្មកថិកពោលថា " បពិត្រ លោកម្ចាស់ដ៏ចម្រើន កុំធ្វើយ៉ាងនេះ កុំធ្វើយ៉ាងនេះ " កាលព្រះថេរៈ ពោលថា " នែអាវុសោ ចូរឈប់ចុះ " ក៏ត្រឡប់ទៅវិហារវិញ ។

ថ្ងៃស្អែកឡើង ព្រះធម្មកថិកនោះ ចូលទៅកាន់ស្រុកដ៏ជិត នោះ , កាលពួកមនុស្សសួរថា " បពិត្រលោកម្ចាស់ដ៏ចម្រើន លោក-

ម្ចាស់ដ៏ចម្រើនទាំងពីរអង្គនោះ និមន្តទៅណា ? " ក៏ឆ្លើយថា " នែ-អ្នកទាំងឡាយ កុំសួរឡើយ, លោកម្ចាស់អ្នកចូលកាន់ត្រកូលរបស់អ្នកទាំងឡាយ ឈ្មោះគ្នាពីថ្ងៃម្សិល ហើយចៀសចេញទៅ, សូម្បីអាត្មាភាពអង្វរយ៉ាងណាក៏ដោយ ក៏មិនព្រមស្តាប់ដែរ " ។ បណ្តា-មនុស្សទាំងនោះ អ្នកដែលល្ងង់ខ្លៅបាននៅស្ងៀម ចំណែកអ្នកមានបញ្ញា ( បណ្ឌិត ) គិតថា ការភ្លាំងភ្លាត់ណា ៗ របស់លោកដ៏ចម្រើនទាំងពីរអង្គនោះ យើងទាំងឡាយមិនដែលឃើញអស់កាលប្រមាណប៉ុណ្ណេះ, ភ័យកាលកើតឡើងដល់លោកម្ចាស់ទាំងពីរអង្គនោះ នឹងជាភ័យកើតឡើងហើយ អាស្រ័យព្រះធម្មកថិករូបនេះ " ហើយក្រោធខឹងយ៉ាងខ្លាំង ។ ព្រះមហាថេរៈនោះ មិនបាននូវសេចក្តីសុខក្នុងទីដែលខ្លួនទៅហើយ ។ ព្រះមហាថេរៈគិតថា " ឱ កម្មរបស់ភិក្ខុថ្មីនោះធ្ងន់ខ្លាំងណាស់ , ( ព្រោះ ) លោកបានពោលទៅកាន់ភិក្ខុអ្នកទើបមកថ្មី ដែលខ្លួនឃើញហើយមួយរំពេចថា អ្នកកុំសេពគប់ព្រះមហាថេរៈនោះឡើយ " ។ សូម្បីព្រះអនុត្ថេរក្រៅនេះ ក៏គិតថា " ឱ កម្មរបស់ព្រះថេរៈធ្ងន់ខ្លាំងណាស់ " ( ព្រោះ ) លោកបាននិយាយទៅកាន់ភិក្ខុអ្នកទើបមកថ្មី ដែលខ្លួនឃើញហើយមួយរំពេចថា " អ្នកកុំសេពគប់នឹងអនុត្ថេរនេះ " ។ ការស្វាធ្យាយ និងការធ្វើទុកក្នុងចិត្ត មិនបានមានដល់ព្រះថេរៈទាំងពីររូបនោះ ។ ដោយកាលកន្លងទៅ ១០០ ឆ្នាំ

ព្រះថេរៈទាំងពីររូបនោះ បានទៅកាន់វិហារមួយ ដែលនៅក្នុងបច្ឆិម-ទិស ( ទិសខាងលិច ) ។ សេនាសនៈតែមួយ បានដល់ព្រះថេរៈទាំងពីររូបនោះ ។ កាលព្រះមហាថេរៈចូលទៅគង់លើគ្រែហើយ , ព្រះអនុត្ថេរក្រៅនេះក៏បានចូលទៅដែរ ។ ព្រះមហាថេរៈឃើញព្រះ-អនុត្ថេរនោះភ្លាមក៏ចាំបាន មិនអាចទប់ទឹកភ្នែកបាន ។ ចំណែកព្រះអនុត្ថេរក្រៅនេះ ក៏ចាំព្រះមហាថេរៈបាន មានភ្នែកជោកទៅដោយទឹកភ្នែក គិតថា " អញគួរនិយាយជាមួយព្រះមហាថេរៈ ឬក៏មិនគួរនិយាយ " ហើយគិតថា " ហេតុនោះមិនគួរជឿ " ថ្វាយបង្គំព្រះថេរៈហើយ ពោលថា " បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំកាន់បាត្រនិងចីវររបស់លោកម្ចាស់ ត្រាច់ទៅអស់កាលប្រមាណប៉ុណ្ណេះ អំពើមិនសមគួរណា ៗ ក្នុងទ្វារទាំងឡាយ មានកាយទ្វារជាដើមរបស់ខ្ញុំលោកម្ចាស់ធ្លាប់ឃើញដែរឬ ?

ព្រះមហា. នែអាវុសោ អំពើមិនសមគួររបស់អ្នក ខ្ញុំមិនធ្លាប់ឃើញឡើយ ។

ព្រះអនុ. កាលបើដូច្នោះ ហេតុដូចម្តេច ទើបលោកម្ចាស់និយាយនឹងព្រះធម្មកថិកថា អ្នកកុំសេពគប់ព្រះអនុត្ថេរនោះ ។

ព្រះមហា. នែអ្នកមានអាយុ ខ្ញុំមិនបាននិយាយយ៉ាងនោះទេបានឮថា អ្នកនិយាយយ៉ាងនេះចំពោះយើង ។

ព្រះអនុ. បពិត្រលោកម្ចាស់ដ៏ចម្រើន សូម្បីខ្ញុំព្រះករុណាក៏មិនបាននិយាយដែរ ។ គ្រានោះ ព្រះថេរៈទាំងពីររូបនោះក៏បានដឹងថា " ព្រះធម្មកថិកនោះ ប្រាថ្នាញ៉ាំងយើងទាំងពីររូបឱ្យបែកគ្នាទើបនិយាយយ៉ាងនោះ " ហើយញ៉ាំងគ្នានិងគ្នាឱ្យសម្តែងទោស ។ ព្រះថេរៈទាំងពីររូបនោះមិនបានសប្បាយចិត្តអស់ ១០០ ឆ្នាំ ជាអ្នកព្រមព្រៀងគ្នាក្នុងថ្ងៃនេះ បបួលគ្នាថា " នែអាវុសោ មក , យើងនឹងបណ្តេញព្រះធម្មកថិកនោះចេញចាកវិហារនោះ " ហើយចៀសចេញទៅ បានទៅដល់វិហារនោះដោយលំដាប់ ។ ព្រះធម្មកថិកនោះឃើញព្រះថេរៈទាំងពីរនោះហើយ ចូលទៅជិតដើម្បីទទួលបាត្រ និងចីវរ ។ ព្រះថេរៈទាំងពីរនោះចង្អុលមុខហើយ ពោលថា " អ្នកមិនគួរនៅក្នុងវិហារនេះ ( តទៅទៀតទេ ) " ។ ព្រះធម្មកថិកនោះ មិនអាចទ្រាំនៅបាន ក៏ចៀសចេញទៅក្នុងថ្ងៃនោះឯង ។ គ្រានោះ សមណធម៌ដែលព្រះធម្មកថិកបំពេញហើយអស់ ២ ម៉ឺនឆ្នាំ មិនអាចទ្រទ្រង់លោកបាន ។ ព្រះធម្មកថិកនោះចុតិចាកអត្តភាពនោះហើយ កើតនៅក្នុងអវីចីអស់មួយចន្លោះព្រះពុទ្ធ មានអត្តភាពមានប្រការដូចពោលហើយសោយទុក្ខនៅនាភ្នំគិជ្ឈកូដក្នុងកាលឥឡូវនេះ ។

**( ព្រះសាស្តាត្រាស់ព្រះធម្មទេសនា )**

ព្រះសាស្តា លុះទ្រង់នាំបុព្វកម្មនេះរបស់សូករប្រេតនោះមក

ហើយ ត្រាស់ថា " ម្នាលភិក្ខុទាំងឡាយ ធម្មតាថា ភិក្ខុគប្បីជាអ្នកស្ងប់ស្ងៀមដោយទ្វារទាំងឡាយ មានកាយទ្វារជាដើម " ដូច្នេះហើយ ត្រាស់ព្រះគាថាថា :

**វាចានុរក្ខី មនសា សុសំវុតោ**
**កាយេន ច អកុសលំ ន កយិរា**
**ឯតេ តយោ កម្មបថេ វិសោធយេ**
**អារាធយេ មគ្គមិសិប្បវេទិតំ ។**

បុគ្គលគប្បីជាអ្នករក្សាវាចា សង្រួមឱ្យល្អដោយចិត្ត ទាំងមិនគប្បីធ្វើអកុសលដោយកាយ បុគ្គលគប្បីជំរះកម្មបថទាំង ៣ នេះ និងគប្បីត្រេកអរចំពោះមគ្គ ដែលលោកអ្នកស្វែងរកគុណដ៏ល្អ សម្តែងទុកហើយ ។

## អធិប្បាយគាថា

សេចក្តីនៃព្រះគាថានោះថា " បុគ្គលឈ្មោះថាជាអ្នកមានប្រក្រតីតាមរក្សាវាចា ព្រោះវៀរចាកទុច្ចរិត ៤ ។ ឈ្មោះថា សង្រួមចិត្តហើយដោយល្អ ព្រោះមិនញុំាំងមនោទុច្ចរិត មានអភិជ្ឈាជាដើមឱ្យកើតឡើង ហើយកាលលះបង់កាយទុច្ចរិត មានបាណាតិបាតជាដើម ឈ្មោះថា មិនគួរធ្វើអកុសលដោយកាយ គប្បីញុំាំងកម្មបថទាំង ៣ នោះឱ្យបរិសុទ្ធដោយអាការយ៉ាងនេះ, ក៏កាលឱ្យបរិសុទ្ធ

យ៉ាងនោះឈ្មោះថា គប្បីត្រេកអរចំពោះមគ្គមានអង្គ ៨ ដែលលោកអ្នកស្វែងរកគុណទាំងឡាយ មានព្រះពុទ្ធជាដើម អ្នកស្វែងរកគុណ គឺសីលជាដើមប្រកាសហើយ ។

ក្នុងកាលចប់ទេសនា ជនជាច្រើន បានសម្រេចអរិយផលមានសោតាបត្តិផលជាដើម ៕

## ( ចប់រឿងសូករប្រេត )

**កិច្ឆោ មនុស្សបដិលាភោ  កិច្ឆំ មច្ចាន ជីវិតំ**
**កិច្ឆំ សទ្ធម្មស្សវនំ  កិច្ឆោ ពុទ្ធានមុប្បាទោ ។**

ការត្រឡប់បានអត្តភាពជាមនុស្ស បានដោយកម្រ ការរស់របស់សត្វទាំងឡាយ បានដោយកម្រ ការស្តាប់ធម៌របស់សប្បុរស បាន-ដោយកម្រ ការកើតឡើងនៃព្រះពុទ្ធទាំងឡាយ បានដោយកម្រ ។

( បិដកលេខ ៥២, ទំព័រ ៦០ )

# ក្នុងលក្ខណសំយុត្ត

## ( មាន ២១ រឿង )

( បិដកលេខ ១, ទំព័រ ៣៥៩-៣៧១ + បិ. ៣២, ទំ. ២៣៩-២៥៤ និងអដ្ឋកថា )

## អដ្ឋិសង្ខលិកវគ្គទី ១

## ១-រឿងអដ្ឋិសង្ខលិកប្រេត

ខ្ញុំបានស្តាប់មក យ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ជិតក្រុងរាជគ្រឹះ ។ ក៏ក្នុងសម័យនោះឯង ព្រះលក្ខណៈមានអាយុនិងព្រះមហាមោគ្គល្លាន មានអាយុ គង់នៅនាភ្នំគិជ្ឈកូដ ។

គ្រានោះឯង ព្រះមហាមោគ្គល្លានមានអាយុ ស្លៀកស្បង់ ប្រដាប់បាត្រចីវរ ក្នុងបុព្វណ្ហសម័យ ហើយចូលទៅរកព្រះលក្ខណៈ មានអាយុ លុះចូលទៅដល់ហើយ បានពោលពាក្យនេះនឹងព្រះ-លក្ខណៈមានអាយុថា ម្នាលអាវុសោលក្ខណៈ អ្នកចូរមក យើងនឹងចូលទៅក្រុងរាជគ្រឹះ ដើម្បីបិណ្ឌបាត ។ ព្រះលក្ខណៈមាន

អាយុ ទទួលពាក្យព្រះមហាមោគ្គល្លានមានអាយុថា អើអាវុសោ ។ គ្រានោះឯង ព្រះមហាមោគ្គល្លានមានអាយុ កាលនិមន្តចុះអំពីភ្នំគិជ្ឈកូដ ក៏ធ្វើនូវការញញឹមឱ្យប្រាកដ ក្នុងប្រទេសមួយ ។ គ្រានោះឯង ព្រះលក្ខណៈមានអាយុ បានសួរព្រះមហាមោគ្គល្លានមានអាយុ ដូច្នេះថា ម្នាលអាវុសោមោគ្គល្លាន ហេតុដូចម្ដេច បច្ច័យដូចម្ដេច បានជាលោកធ្វើនូវការញញឹមឱ្យប្រាកដ ។ ម្នាលអាវុសោលក្ខណៈ កាលនេះជាកាលមិនគួរ ដើម្បីសួរប្រស្នានុ៎ះទេ អ្នកចូរសួរប្រស្នានុ៎ះ នឹងខ្ញុំក្នុងសម្នាក់ព្រះមានព្រះភាគចុះ ។

គ្រានោះឯង ព្រះលក្ខណៈមានអាយុ និងព្រះមហាមោគ្គល្លានមានអាយុ ចូលទៅបិណ្ឌបាតក្នុងក្រុងរាជគ្រឹះ ត្រឡប់មកអំពីបិណ្ឌបាតវិញ ក្នុងវេលាក្រោយភត្ត ក៏ចូលទៅគាល់ព្រះមានព្រះភាគ លុះចូលទៅដល់ ក៏ថ្វាយបង្គំព្រះមានព្រះភាគ ហើយអង្គុយនៅក្នុងទីដ៏សមគួរ ។ លុះព្រះលក្ខណៈមានអាយុ អង្គុយក្នុងទីដ៏សមគួរហើយ បានសួរព្រះមហាមោគ្គល្លានមានអាយុដូច្នេះថា ក្នុងទីឯណោះ មហាមោគ្គល្លានមានអាយុ កាលចុះអំពីភ្នំគិជ្ឈកូដ បានធ្វើនូវការញញឹមឱ្យប្រាកដក្នុងប្រទេសមួយ ម្នាលអាវុសោមោគ្គល្លាន ហេតុដូចម្ដេច បច្ច័យដូចម្ដេច បានជាលោកធ្វើនូវការញញឹមឱ្យប្រាកដ ។

ព្រះមហាមោគ្គល្លានតបថា ម្នាលអាវុសោ ក្នុងទីឯណោះ

កាលដែលខ្ញុំ ចុះមកអំពីភ្នំគិជ្ឈកូដ បានឃើញ**អដ្ឋិសង្ខលិក** គឺរាងឆ្អឹង កំពុងអណ្តែតទៅក្នុងអាកាស ពួកត្មាត ក្អែក រអាត ដេញតាមឆាបចោមចឹកចោះ ភើចជញ្ជែងនូវរាងឆ្អឹងនោះ រាងឆ្អឹងនោះក៏ចេះតែស្រែកថ្ងូរ ម្នាលអាវុសោ ទើបខ្ញុំនោះមានសេចក្តីបរិវិតក្កៈថា យីអើអស្ចារ្យណាស់ យីអើ មិនធ្លាប់កើតមានសោះឡើយ យីអើ សត្វបែបនេះ នឹងត្រឡប់ទៅជាមានខ្លះដែរ យក្ខបែបនេះនឹងត្រឡប់ទៅជាមានខ្លះដែរ កិរិយាបានអត្តភាពបែបនេះ នឹងត្រឡប់ទៅជាមានខ្លះដែរតើ ។

គ្រានោះឯង ព្រះមានព្រះភាគ ត្រាស់ហៅភិក្ខុទាំងឡាយថា ម្នាលភិក្ខុទាំងឡាយ ពួកសាវ័កមានចក្ខុកើតពិតហើយ ម្នាលភិក្ខុទាំង-ឡាយ ពួកសាវ័កមានញាណកើតហើយ ដ្បិតសាវ័កដឹង ឬឃើញសត្វបែបនេះ ឬថានឹងធ្វើសត្វបែបនេះឱ្យជាសាក្សី ( ដល់តថាគតបាន ) ។ ម្នាលភិក្ខុទាំងឡាយ សត្វនោះតថាគតធ្លាប់ឃើញមកអំពីមុនដែរ ប៉ុន្តែតថាគតមិនទាន់សម្តែង បើតថាគតសម្តែងអំពីរឿងសត្វនុ៎ះទៅ ជនទាំងឡាយដទៃមិនជឿពាក្យតថាគតទេ ជនទាំងឡាយណា មិនជឿពាក្យតថាគត សេចក្តីមិនជឿនោះ របស់ជនទាំងនោះ នឹងនាំឱ្យខានបានប្រយោជន៍ នាំឱ្យបានតែសេចក្តីទុក្ខ អស់កាលជាយូរអង្វែង ។ **ម្នាលភិក្ខុទាំងឡាយ សត្វនោះ** ( ពីដើម ) ជា**គោឃាតកៈ** គឺអ្នក

សម្លាប់គោ ក្នុងក្រុងរាជគ្រឹះនេះឯង ដោយវិបាករបស់កម្មនោះ គោឃាតកបុរសនោះ ក៏ទៅឆេះក្នុងនរកអស់ឆ្នាំដ៏ច្រើន អស់រយឆ្នាំដ៏ច្រើន អស់ពាន់ឆ្នាំដ៏ច្រើន អស់សែនឆ្នាំដ៏ច្រើន ដោយសេសសល់វិបាកនៃកម្មនោះឯង ទើបបានត្រឡប់មកទទួលផល គឺត្រឡប់បានអត្តភាព បែបនេះឯង ។

# រឿងអដ្ឋកថាពន្យល់ថា

ព្រះលក្ខណត្ថេរ ដែលព្រះធម្មសង្គាហកាចារ្យ ពោលទុកក្នុងលក្ខណសំយុត្តថា **អាយស្មា ច លក្ខណោ : ព្រះលក្ខណត្ថេរដ៏-មានអាយុ**ជាដើមនេះ បណ្ឌិតគប្បីជ្រាបថា មាននៅក្នុងបណ្ដាភិក្ខុជដិល ១,០០០ អង្គ ឧបសម្បទាដោយឯហិភិក្ខុឧបសម្បទា បានសម្រេចជាព្រះអរហន្តក្នុងទីបំផុតនៃអាទិត្តបរិយាយសូត្រ ជាព្រះ-មហាសាវ័កមួយអង្គ ។ ក៏ព្រោះព្រះថេរៈអង្គនេះ ប្រកបដោយអត្តភាពដូចព្រហ្ម បរិបូរណ៍ដោយលក្ខណៈពេញដោយអាការៈគ្រប់យ៉ាង, ដូច្នោះ ទើបលោកដល់ការរាប់ថា **លក្ខណៈ** ចំណែកព្រះ-មហាមោគ្គល្លានត្ថេរ ជាព្រះអគ្គសាវ័កទី ២ បានសម្រេចជាព្រះ-អរហន្ត ក្នុងថ្ងៃទី ៧ ក្រោយពីថ្ងៃដែលព្រះថេរៈ បួសហើយ ។

ពីរបទថា **សិតំ បាត្វាកាសិ** ( ធ្វើការញញឹមឱ្យប្រាកដ ) សេចក្ដីថា ព្រះមហាមោគ្គល្លានត្ថេរ បានធ្វើការញញឹមតិច ៗ ឱ្យប្រាកដ ។ មានពាក្យអធិប្បាយថា ប្រកាស គឺ សម្ដែង ។

សួរថា ក៏ព្រះថេរៈឃើញអ្វី ទើបបានធ្វើការញញឹមឱ្យប្រាកដ ?

ឆ្លើយថា ព្រះថេរៈឃើញសត្វដែលកើតនៅក្នុងបេតលោកមួយ មានតែរាងឆ្អឹងដែលមកហើយក្ដុបាលីខាងមុខ, ក៏ឯការឃើញសត្វនោះ ឃើញបានដោយទិព្វចក្ខុ មិនមែនឃើញដោយចក្ខុប្រសាទទេ ។ ពិតមែន អត្តភាពទាំងនោះ មិនបានមកកាន់គន្លងនៃចក្ខុប្រសាទទេ ។

សួរថា ក៏ព្រះថេរៈឃើញអត្តភាពមានរូបយ៉ាងនោះហើយ ព្រោះហេតុអ្វី ទើបបានធ្វើការញញឹមឱ្យប្រាកដ ក្នុងកាលគួរធ្វើសេចក្ដីករុណាហ្ន៎ ?

ឆ្លើយថា ព្រោះព្រះថេរៈរលឹកដល់សម្បត្តិរបស់ខ្លួន និងព្រះ-ញាណរបស់ព្រះពុទ្ធផង ។ ពិតមែន ព្រះថេរៈឃើញប្រេតនោះហើយ បានរលឹកដល់សម្បត្តិរបស់ខ្លួនថា " អត្តភាពបែបនេះ ដែលបុគ្គលឈ្មោះថា មិនទាន់ឃើញសច្ចៈនឹងគប្បីបាន, យើងផុតហើយចាកអត្តភាពដូច្នោះ, ជាលាភរបស់យើង យើងបានល្អហើយហ្ន៎ " និងបានរលឹកដល់សម្បត្តិនៃញាណយ៉ាងនេះថា "ញាណសម្បត្តិរបស់ព្រះមាន-ព្រះភាគ ដែលទ្រង់សម្ដែងថា ( ម្នាលភិក្ខុទាំងឡាយ វិបាករបស់កម្ម-

ជា**អចិន្តេយ្យ** ដែលបុគ្គលមិនគួរគិត[១] ) គួរអស្ចារ្យ, ព្រះពុទ្ធទាំងឡាយ ទ្រង់រមែងសម្តែងធ្វើឱ្យប្រចក្សហ្ន៎ **ធម្មធាតុ** ដែលព្រះពុទ្ធទាំងឡាយ ទ្រង់ចាក់ធ្លុះល្អហើយ " ដូច្នេះ ទើបបានធ្វើការញញឹមឱ្យប្រាកដ ។

ក៏ធម្មតាថា ព្រះខីណាស្រពទាំងឡាយ មិនធ្វើការញញឹមឱ្យប្រាកដ ព្រោះមិនមានហេតុ, ព្រោះដូច្នោះ ទើបព្រះលក្ខណត្ថេរ សួរព្រះមហាមោគ្គល្លានត្ថេរនោះថា " ម្នាលអាវុសោមោគ្គល្លាន អ្វីជា-ហេតុ អ្វីជាបច្ច័យ ចំពោះកិរិយាធ្វើនូវការញញឹមឱ្យប្រាកដ ( នេះ ) " តែព្រះថេរៈឆ្លើយតបថា " ម្នាលអាវុសោលក្ខណៈ កាលនេះ មិនមែនជាកាលគួរព្យាករប្រស្នានេះទេ លោកចូរសួរប្រស្នានេះនឹងខ្ញុំ ក្នុង-សម្នាក់ព្រះមានព្រះភាគចុះ " ។ ដោយហេតុដែលលោកមានសេចក្តីប្រាថ្នានឹងឱ្យព្រះមានព្រះភាគជាសាក្សីជាមុនសិន ទើបព្យាករ ព្រោះហេតុថា ភិក្ខុទាំងឡាយ អ្នកដែលមិនបានឃើញការឧប្បត្តិឡើងនេះដោយខ្លួនឯងហើយ នឹងបង្គាប់ឱ្យជឿបានដោយលំបាក ។ ខាងក្រោយអំពីនោះ ព្រះមហាមោគ្គល្លានត្ថេរ ត្រូវព្រះលក្ខណត្ថេរ សួរក្នុងសម្នាក់ព្រះមានព្រះភាគ ទើបបានព្យាករដោយន័យមានជាដើមថា **ឥធាហំ អាវុសោ : ម្នាលអាវុសោ ក្នុងថ្ងៃនេះខ្ញុំ** ។

បណ្តាបទទាំងនោះ បទថា **អដ្ឋិកសង្ខលិកំ** : ( ប្រេតមានឆ្អឹង-

---

១= អង្គុត្តរនិកាយ ចតុក្កនិបាត ភាគ ៤២, ទំព័រ ១៧៩ ។

ពណ៌សង្ខ ) បានដល់ ប្រេតមានតែរាងឆ្អឹងដែលមានពណ៌ស មិនមាន សាច់ និងឈាម ។

ត្បាតយក្ខ ខ្លែងយក្ខ និងរអាតយក្ខ សូម្បីទាំងនេះ គប្បីជ្រាប ថា ត្បាតខ្លះ ខ្លែងខ្លះ និងរអាតខ្លះ ។ ក៏រូបនោះ មិនមក សូម្បីកាន់គន្លង ( នៃចក្ខុ ) របស់ហ្វូងត្បាតជាដើមតាមប្រក្រតី ។

ពីរបទថា **អនុបតិត្វា អនុបតិត្វា** បានដល់ នាំគ្នាដេញតាម ទៅហើយ ៗ ។

បទថា **វិតុទេន្តិ** : ( ឆាប ) បានដល់ ចឹកហើយហើរទៅ ។ ម្យ៉ាងទៀត បាលីថា **វិតុទន្តិ** ក៏មាន, អធិប្បាយថា រមែងចឹកដោយ ចុងចំពុះលោហៈដ៏មុតដូចជាមុខដាវ ។ សព្ទថា **សុទំ** ក្នុងពាក្យថា **សា សុទំ អដ្ដស្សរំ ករោតិ** ( ប្រេតនោះ ចេះតែស្រែកថ្ងូរ ) នេះ ជានិបាត, អធិប្បាយថា អដ្ឋិកសង្ខលិកប្រេតនោះ **រមែងធ្វើសំឡេង ស្រែកថ្ងូរ គឺសំឡេងយំ** ។ បានឮថាអត្តភាពដូច្នោះ សូម្បីមាន ប្រមាណមួយយោជន៍ រមែងកើតឡើង និងមានប្រសាទដែលប៉ោង ឡើង ដូចបូសដែលទុំហើយ ដើម្បីតាមសោយផលនៃអកុសល ព្រោះដូច្នោះ អដ្ឋិកសង្ខលិកប្រេតនោះ ក្ដៅក្រហាយព្រោះវេទនា ដ៏មានកម្លាំង ទើបបានធ្វើសំឡេងដូច្នោះឯង ។

លុះព្រះមហាមោគ្គល្លានពោលយ៉ាងនេះហើយ កាលនឹង-

សម្តែងធម្មសង្វេគទៀតដែលកើតឡើង ព្រោះអាស្រ័យសេចក្តីករុណាក្នុងសត្វទាំងឡាយថា ដែលឈ្មោះថា សត្វទាំងឡាយអ្នកទៅក្នុងវដ្តៈ រមែងមិនផុតពីអត្តភាពបែបនេះទៅបាន ទើបពោលពាក្យជាដើមថា "ម្នាលអាវុសោ ទើបខ្ញុំបានបរិវិតក្កៈថា យីអើហ្ន៎ ( នេះហៅពេញ ) ជាអស្ចារ្យ យីអើហ្ន៎ មិនធ្លាប់កើតមានសោះឡើយ " ដូច្នេះ ។

ពីរបទថា **ភិក្ខូ ឧជ្ឈាយន្តិ** : ( ភិក្ខុទាំងឡាយ ទើបពោល-ទោស ) សេចក្តីថា សេចក្តីឧប្បត្តិឡើងនៃប្រេតនោះ មិនឃើញប្រចក្សដល់ភិក្ខុពួកណា, ភិក្ខុទាំងនោះ នាំគ្នាពោលទោស ។ ចំណែកព្រះមានព្រះភាគ កាលនឹងទ្រង់ប្រកាសអានុភាពរបស់ព្រះថេរៈ ទើបត្រាស់ព្រះតម្រាស់ថា " ម្នាលភិក្ខុទាំងឡាយ សាវ័កទាំងឡាយ មានចក្ខុកើតពិតហើយ ម្នាលភិក្ខុទាំងឡាយ សាវ័កទាំងឡាយ មានញាណកើតពិតហើយ ព្រោះហេតុថា សាវ័កនឹងដឹង ឬនឹងឃើញប្រេតបែបនេះ ឬថា នឹងធ្វើប្រេតបែបនេះឱ្យជាបន្ទាល់ ( របស់តថាគត ) ម្នាលភិក្ខុទាំងឡាយ សត្វនោះតថាគតបានឃើញក្នុងកាលមុនរួចមកហើយ ប៉ុន្តែតថាគតមិនបានសម្តែង ព្រោះថា តថាគតសម្តែងទៅពពួកជនដទៃមិនជឿ ( ពាក្យ ) តថាគត ពពួកជនណាដែលមិនជឿតថាគត សេចក្តីដែលមិនជឿនោះ នឹងនាំឱ្យខានបានប្រយោជន៍ នាំឱ្យបានសេចក្តីទុក្ខអស់កាលយូរអង្វែងដល់ពពួកជននោះ ម្នាលភិក្ខុ-

ទាំងឡាយ សត្វនុ៎ះ ( កាលពីដើម ) ជាអ្នកពិឃាតគោក្នុងក្រុងរាជ-គ្រឹះនេះឯង ដោយកម្មវិបាកនោះ អ្នកពិឃាតគោនោះ ទៅឆេះនៅក្នុងនរកអស់ឆ្នាំដ៏ច្រើន គឺអស់រយ ពាន់ សែនឆ្នាំដ៏ច្រើន, ដោយវិបាកនៃកម្មនោះនៅសេសសល់ ក៏ត្រឡប់មកទទួលផល គឺត្រឡប់បាននូវអត្តភាពបែបនេះឯង ។ ម្នាលភិក្ខុទាំងឡាយ មោគ្គល្លានពោលពាក្យពិត ម្នាលភិក្ខុទាំងឡាយ មោគ្គល្លាន មិនត្រូវអាបត្តិទេ ” ។

ក្នុងពាក្យទាំងនោះ ពាក្យថា **សាវ័កទាំងឡាយ មានចក្ខុកើតពិតហើយ** ព្រោះអត្ថថា សាវ័កទាំងនោះមានចក្ខុប្រាកដហើយ កើតហើយ ឧប្បត្តិហើយ ។ សេចក្ដីថា ជាអ្នកមានចក្ខុប្រាកដហើយ គឺមានចក្ខុកើតហើយ ញាំងចក្ខុឱ្យកើតឡើងហើយ ។ សូម្បីក្នុងបទទី ២ ក៏ន័យនេះដូចគ្នា ។ ពាក្យថា **យត្រ** ដែលមាននៅក្នុងពាក្យថា **យត្រ ហិ នាម** នេះ ជាពាក្យបញ្ជាក់ដល់ហេតុ ។ ក្នុងពាក្យថា **ចក្ខុភូតា** ជាដើមនោះ មានការប្រកបសេចក្ដីដូចតទៅនេះ :

ព្រោះហេតុថា សូម្បីសាវ័កនឹងដឹង ឬនឹងឃើញ ឬនឹងធ្វើអត្តភាពបែបនេះ ឱ្យជាសាក្សីបាន, ដូច្នោះ ទើបតថាគតបានពោលថា “ ម្នាលភិក្ខុទាំងឡាយ សាវ័កទាំងឡាយ មានចក្ខុកើតពិតហើយ ម្នាលភិក្ខុទាំងឡាយ សាវ័កទាំងឡាយ មានញាណកើតពិតហើយ ” ដូច្នេះ ។

ពាក្យថា **បុព្វេ ច មេ សោ ភិក្ខវេ សត្តោ ទិដ្ឋោ :** ( ម្នាលភិក្ខុទាំងឡាយ សត្វនោះ តថាគតបានឃើញពីក្នុងកាលមុនរួចមកហើយ ) មានសេចក្តីថា ( ព្រះមានព្រះភាគ ) ត្រាស់ថា តថាគតបានចាក់ធ្លុះសព្វញ្ញុតញ្ញាណទៀបពោធិមណ្ឌលធ្វើពួកសត្វនិង ភព គតិ ឋិតិ និង និវាស មិនមានប្រមាណ ក្នុងចក្កវាឡទាំងឡាយ មិនមានប្រមាណឱ្យប្រចក្ស បានឃើញសត្វនោះហើយក្នុងកាលមុន ។

បទថា **គោឃាតកោ** ( ជាអ្នកពិឃាតគោ ) សេចក្តីថា ជាអ្នកសម្លាប់គោទាំងឡាយហើយ ពន្លះសាច់ចេញពីឆ្អឹង លក់ចិញ្ចឹមជីវិត ។

ច្រើនបទថា **តស្សេវ កម្មស្ស វិបាកាវសេសេន** ( ដោយសេសសល់នៃកម្មវិបាកនោះ ) សេចក្តីថា នៃអបរាបរវេទនីយកម្ម ដែលចេតនាផ្សេង ៗ ប្រមូលមកហើយនោះឯង ។ ពិតមែន បណ្តាចេតនាទាំងនោះ បដិសន្ធិក្នុងនរកដោយចេតនាណាឱ្យកើតឡើង ហើយកាលវិបាកនៃចេតនាដួងនោះ អស់ទៅហើយ, បដិសន្ធិក្នុងប្រេតជាដើម រមែងកើតទៀត, ព្រោះធ្វើកម្មដ៏សេស ឬកម្មនិមិត្តឱ្យជាអារម្មណ៍ ព្រោះហេតុនោះ បដិសន្ធិនោះ ទើបលោកហៅថា វិបាកដ៏សេសនៃកម្មនោះឯង ព្រោះមានចំណែកស្មើដោយកម្ម ឬព្រោះមានចំណែកស្មើដោយអារម្មណ៍ ។ ក៏សត្វនេះកើតឡើងហើយយ៉ាងនេះ ។

ព្រោះហេតុនោះ ទើបព្រះមានព្រះភាគ ត្រាស់ថា " ដោយ-សេសសល់នៃកម្មវិបាកនោះ " ។ បានឮថា ក្នុងកាលរួចផុតពីនរក សត្វនោះ បានមាននិមិត្ត គឺគ្រោងឆ្អឹងនៃគោទាំងឡាយ ដែលត្រូវធ្វើមិនឱ្យមានសាច់, សត្វនោះ កាលនឹងធ្វើកម្មនោះសូម្បីដែលបិទបាំង ឱ្យដូចជាប្រាកដដល់វិញ្ញូជនទាំងឡាយ ទើបកើតជាអដ្ឋិកសង្ខលិក-ប្រេត ។

## ( ចប់រឿងអដ្ឋិសង្ខលិកប្រេតទី ១ )

**យោ ច វស្សសតំ ជីវេ ទុស្សីលោ អសមាហិតោ**
**ឯកាហំ ជីវិតំ សេយ្យោ សីលវន្តស្ស ឈាយិនោ ។**

-បុគ្គលណា រស់នៅមួយរយឆ្នាំ ជាមនុស្សទ្រុស្តសីល មានចិត្តមិនបានតម្កល់ខ្ជាប់ ការរស់នៅតែមួយថ្ងៃ របស់លោកដែលមានសីល មានការពិនិត្យពិចារណា ជាប្រក្រតី ប្រសើរជាង ។

( បិដកលេខ ៥២, ទំព័រ ៤៥ )

# ២-រឿងមំសបេសិប្រេត

ម្នាលអាវុសោ ក្នុងទីឯណោះ កាលដែលខ្ញុំចុះមកអំពីភ្នំគិជ្ឈ-កូដ បានឃើញ**មំសបេសិ** គឺចម្រៀកសាច់ កំពុងអណ្តែតទៅលើអាកាស ពួកត្មាត ក្អែក រអាត ដេញតាមឆាប ចោមចឹកចោះភើចជញ្ជែងនូវចម្រៀកសាច់នោះ ចម្រៀកសាច់នោះក៏ចេះតែស្រែកថ្ងូរ ។

**-ម្នាលភិក្ខុទាំងឡាយ** សត្វនុ៎ះជា**គោឃាតកៈ** គឺអ្នកសម្លាប់គោ ( ពីដើម ) ក្នុងក្រុងរាជគ្រឹះនេះឯង ។

**-អដ្ឋកថា :** មំសបេសិប្រេតនោះ ជាអ្នកសម្លាប់គោ ធ្វើបន្ទះសាច់ហាលឱ្យក្រៀមហើយ ចិញ្ចឹមជីវិតដោយការលក់សាច់ក្រៀមច្រើនឆ្នាំ ។ ព្រោះហេតុនោះ កាលរួចផុតពីនរក គេទើបបានមាននិមិត្ត គឺបន្ទះសាច់នុ៎ះឯង គេទើបកើតជាមំសបេសិប្រេត ។

**( ចប់រឿងមំសបេសិប្រេតទី ២ )**

# ៣-រឿងមំសបិណ្ឌប្រេត

ម្នាលអាវុសោ ក្នុងទីឯណោះ កាលដែលខ្ញុំចុះមកអំពីភ្នំគិជ្ឈ-កូដ បានឃើញ**មំសបិណ្ឌ** គឺដុំសាច់ កំពុងអណ្តែតទៅលើអាកាស ពួកត្មាត ក្អែក រអាត ដេញតាមឆាប ចោមចឹកចោះ ភើចជញ្ចែង នូវដុំសាច់នោះ ដុំសាច់នោះក៏ចេះតែស្រែកថ្ងូរ ។

**-ម្នាលភិក្ខុទាំងឡាយ** សត្វនុ៎ះជា**ព្រានបក្សី** ( អំពីដើម ) ក្នុងក្រុងរាជគ្រឹះនេះឯង ។

**-អដ្ឋកថា :** មំសបិណ្ឌប្រេតនោះ ជាព្រានសត្វ ចាប់សត្វបានហើយ វេលាលក់ បានធ្វើការដករោម ស្លាប និងស្បែកចេញអស់ ឱ្យនៅសល់ត្រឹមតែជាដុំសាច់ហើយ លក់ចិញ្ចឹមជីវិត ។ ព្រោះហេតុនោះ កាលរួចផុតពីនរក គេទើបបានមាននិមិត្ត គឺដុំសាច់ប៉ុណ្ណោះ ។ គេទើបកើតជាមំសបិណ្ឌប្រេត ។

**( ចប់រឿងមំសបិណ្ឌប្រេតទី ៣ )**

# ៤-រឿងនិច្ឆវីប្រេត

ម្នាលអាវុសោ ក្នុងទីឯណោះ កាលដែលខ្ញុំចុះមកអំពីភ្នំគិជ្ឈ-កូដ បានឃើញ**និច្ឆវិបុរស** គឺបុរសអ្នកមិនមានស្បែកក្រៅ កំពុងអណ្តែតទៅលើអាកាស ពួកត្មាត ក្អែក រអាត ដេញតាមឆាបចោមចឹកចោះ ភើចជញ្ជែងនូវនិច្ឆវិបុរសនោះ និច្ឆវិបុរសនោះក៏ចេះតែស្រែកថ្ងូរ ។

**-ម្នាលភិក្ខុទាំងឡាយ** សត្វនុ៎ះជាអ្នក**សម្លាប់ចៀម** ( អំពីដើម ) ក្នុងក្រុងរាជគ្រឹះនេះឯង ។

**-អដ្ឋកថា :** និច្ឆវីប្រេតនោះ ជាអ្នកសម្លាប់ចៀមហើយបក-ស្បែកចិញ្ចឹមជីវិត ទើបបានមាននិមិត្ត គឺរាងកាយចៀមប្រាសចាកស្បែកតាមន័យមុននុ៎ះឯង គេទើបបានកើតជានិច្ឆវីប្រេត ។

**( ចប់រឿងនិច្ឆវីប្រេតទី ៤ )**

# ៥_រឿងអសិលោមប្រេត

ម្នាលអាវុសោ ក្នុងទីឯណោះ កាលដែលខ្ញុំចុះមកអំពីភ្នំគិជ្ឈ-កូដ បានឃើញ**អសិលោមបុរស** គឺបុរសមានរោមដូចដាវ កំពុងអណ្តែតទៅលើអាកាស ដាវទាំងនោះ របស់បុរសនោះ អណ្តែតធ្លាក់ ៗ មកត្រូវកាយរបស់បុរសនោះឯង បុរសនោះក៏ចេះតែស្រែកថ្ងូរ ។

**-ម្នាលភិក្ខុទាំងឡាយ** សត្វនុ៎ះជាអ្នក**សម្លាប់ជ្រូក** ( អំពីដើម ) ក្នុងក្រុងរាជគ្រឹះនេះឯង ។

**-អដ្ឋកថា :** អសិលោមប្រេតនោះ ជាអ្នកសម្លាប់ជ្រូក ប្រើដាវសម្លាប់ជ្រូកទាំងឡាយ ដែលខ្លួនបំប៉នដោយចំណីអស់កាលយូរ ហើយចិញ្ចឹមជីវិតមករហូតអស់រាត្រីយូរ ។ គេទើបបានមាននិមិត្ត គឺភាវៈរបស់អ្នកដែលងាដាវឡើង ដូច្នោះ គេទើបកើតជាអសិលោម-ប្រេត ។

**( ចប់រឿងអសិលោមប្រេតទី ៥ )**

# ៦_រឿងសត្តិលោមប្រេត

ម្នាលអាវុសោ ក្នុងទីឯណោះ កាលដែលខ្ញុំចុះមកអំពីភ្នំគិជ្ឈ-កូដ បានឃើញ**សត្តិលោមបុរស** គឺបុរសមានរោមដូចលំពែង កំពុងអណ្តែតទៅលើអាកាស លំពែងទាំងនោះ របស់បុរសនោះ អណ្តែតធ្លាក់ ៗ មកត្រូវកាយរបស់បុរសនោះឯង បុរសនោះក៏ចេះតែស្រែកថ្ងូរ ។

**-ម្នាលភិក្ខុទាំងឡាយ** សត្វនុ៎ះជាព្រានម្រឹគ ( អំពីដើម ) ក្នុងក្រុងរាជគ្រឹះនេះឯង ។

**-អដ្ឋកថា :** សត្តិលោមប្រេតនោះ ជាអ្នកបាញ់ម្រឹគ នាំយកម្រឹគមួយ ( សម្រាប់បញ្ឆោតម្រឹគ ) និងកាន់លំពែងមួយ ទៅព្រៃ ហើយប្រើលំពែងចាក់ម្រឹគដែលនាំគ្នាមកកាន់ទីជិតម្រឹគនោះឱ្យស្លាប់, គេទើបបានមាននិមិត្ត គឺភាវៈដែលប្រើលំពែងចាក់ ។ ដូច្នោះ គេទើបកើតជាសត្តិលោមប្រេត ។

**( ចប់រឿងសត្តិលោមប្រេតទី ៦ )**

# ៧-រឿងឧសុលោមប្រេត

ម្នាលអាវុសោ ក្នុងទីឯណោះ កាលដែលខ្ញុំចុះមកអំពីភ្នំគិជ្ឈ-កូដ បានឃើញ**ឧសុលោមបុរស** គឺបុរសមានរោមដូចព្រួញ កំពុងអណ្តែតទៅលើអាកាស ព្រួញទាំងនោះ របស់បុរសនោះ អណ្តែតធ្លាក់ ៗ មកត្រូវកាយរបស់បុរសនោះឯង បុរសនោះក៏ចេះតែស្រែកថ្ងូរ ។

**-ម្នាលភិក្ខុទាំងឡាយ** សត្វនុ៎ះជា**ពេជ្ឈឃាត** ( អំពីដើម ) ក្នុងក្រុងរាជគ្រឹះនេះឯង ។

**-អដ្ឋកថា :** បទថា **ការណិកោ** ( ជាពេជ្ឈឃាត ) សេចក្តីថា ជាបុរសអ្នកបៀតបៀនពួកមនុស្ស ដែលខុសចំពោះព្រះរាជា ដោយហេតុទាំងឡាយជាច្រើន ចុងក្រោយក៏ប្រើកូនសរបាញ់ឱ្យស្លាប់ ។ បានឮថា គេជ្រាបមុនថា អ្នកត្រូវបាញ់ចំណែកឯណោះ ទើបនឹងស្លាប់ដូច្នេះ ហើយទើបបាញ់ ។ គេនុ៎ះឯង ចិញ្ចឹមជីវិតហើយកើតក្នុងនរក ក្នុងវេលាកើតក្នុងប្រេតវិស័យនេះ បានមាននិមិត្ត គឺភាវៈដែលប្រើសរបាញ់ ដោយវិបាកដ៏សេសពីនរកនោះ ។ ដូច្នោះ គេទើបកើតជា-ឧសុលោមប្រេត ៕

# ៨-រឿងសូចិលោមប្រេត

ម្នាលអាវុសោ ក្នុងទីឯណោះ កាលដែលខ្ញុំចុះមកអំពីភ្នំគិជ្ឈ-កូដ បានឃើញ**សូចិលោមបុរស** គឺបុរសមានរោមដូចដែកស្រួច កំពុងអណ្ដែតទៅលើអាកាស ដែកស្រួចទាំងនោះ របស់បុរសនោះ អណ្ដែតធ្លាក់ ៗ មកត្រូវកាយរបស់បុរសនោះវិញ បុរសនោះក៏ចេះតែស្រែកថ្ងូរ ។

**-ម្នាលភិក្ខុទាំងឡាយ** សត្វនុ៎ះជាអ្នកបរគោ ( អំពីដើម ) ក្នុងក្រុងរាជគ្រឹះនេះឯង ។

**-អដ្ឋកថា :** បទថា **សារថិ** ឬ **សូតោ** ( នាយសារថី ) គឺជាអ្នកទូន្មានសេះ ។ ក្នុងអដ្ឋកថាកុរុន្ទី លោកពោកថា ជាអ្នកបង្ហឹកគោ ដូច្នេះខ្លះ ។ គេបានមាននិមិត្ត គឺភារៈដែលចាក់ដោយជន្លួញ ។ គេទើបកើតជាសូចិលោមប្រេត ។

## ( ចប់រឿងសូចិលោមប្រេតទី ៨ )

# ៩-រឿងសូចិលោមបុរស

ម្នាលអាវុសោ ក្នុងទីឯណោះ កាលដែលខ្ញុំចុះមកអំពីភ្នំគិជ្ឈ-កូដ បានឃើញ**សូចិលោមបុរស** គឺបុរសមានរោមដូចដែកស្រួច កំពុងអណ្តែតទៅលើអាកាស ដែកស្រួចទាំងនោះ របស់បុរសនោះក៏ដោតចូលទៅក្នុងក្បាល ធ្លាយចេញមកតាមមាត់ ដោតចូលទៅក្នុងមាត់ ធ្លាយចេញមកតាមទ្រូង ដោតចូលទៅក្នុងទ្រូង ធ្លាយចេញមកតាមពោះ ដោតចូលទៅក្នុងពោះ ធ្លាយចេញមកតាមភ្លៅ ដោតចូលទៅក្នុងភ្លៅ ធ្លាយចេញមកតាមស្មង ដោតចូលទៅក្នុង-ស្មង ធ្លាយចេញមកតាមបាតជើង បុរសនោះក៏ចេះតែស្រែកថ្ងូរ ។

**-ម្នាលភិក្ខុទាំងឡាយ** សត្វនុ៎ះជាអ្នកចាក់ដោតញុះញង់គេ ( អំពីដើម ) ក្នុងក្រុងរាជគ្រឹះនេះឯង ។

**-អដ្ឋកថា :** បទថា **សូចិកោ** [(១)] ( ជាអ្នកញុះញង់គេ ) គឺជាអ្នក ធ្វើការស៊កសៀត ។ បានឮថា គេទម្លាយមនុស្សទាំងឡាយនិងពួករួមគ្នា និងញុះញង់ក្នុងរាជត្រកូលថា " អ្នកនេះមានសេចក្តី-

១= ភូមា. **សូចកោ** ។ **សុចកោ** : អ្នកពោលស៊កសៀត, **សូចិ** : ម្ជុល, ស្នៀត, គន្លឹះ, ដែកចារ ។

ខុសឈ្មោះនេះ អ្នកនេះធ្វើខុសឈ្មោះនេះ ” ដូច្នេះ, គ្រាញុះញង់ហើយ ធ្វើឱ្យដល់នូវសេចក្ដីវិនាសអស់ ។ ដូច្នោះ គេទើបកើតជាសូចិលោមប្រេត ព្រោះធ្វើនិមិត្ត គឺកម្មដើម្បីការសោយទុក្ខអំពីការទម្លាយដោយស្មៀតទាំងឡាយ ដូចដែលគេស៊កសៀតបំបែកពួកមនុស្ស ដូច្នោះ ។

## ( ចប់រឿងសូចិលោមបុរសទី ៩ )

*-មនុស្សស្លាប់រស់ព្រោះសម្ដី ដូចមនុស្សស្រីកែវកល្យាណ*
*អាចឱ្យប្រុសស្លាប់ឬរស់បាន សម្ដីប្រោសប្រាណនាំក្ដីសុខ ។*
*-សម្ដីជាឯកលេខជាទោ ចេះប្រាជ្ញចេះព្រោកកុំនាំទុក្ខ*
*សម្ដីអត់គ្រាប់គ្រោតគ្រាតគ្រុក នាំមហាទុក្ខព្រួយដល់ប្រាណ ។*

# ១០-រឿងកុម្ភណ្ឌប្រេត

## ( អណ្ឌភារប្រេត )

ម្នាលអាវុសោ ក្នុងទីឯណោះ កាលដែលខ្ញុំចុះមកអំពីភ្នំគិជ្ឈ-កូដ បានឃើញ**កុម្ភណ្ឌបុរស** គឺបុរសមានអណ្ឌៈ ( ពង ) ប៉ុនក្អម កំពុងអណ្តែតទៅលើអាកាស កាលបុរសនោះដើរទៅ លុះតែលើកអណ្ឌៈទាំងនោះដាក់ត្រង់ក ( លី ) ទើបដើរទៅបាន កាលអង្គុយក៏អង្គុយ សង្កត់លើអណ្ឌៈទាំងនោះឯង ពួកត្មាត ក្អែក រអាត ដេញតាមឆាប ចោមចឹកចោះ ភើចជញ្ជែងនូវបុរសនោះ បុរសនោះក៏ចេះតែស្រែកថ្ងូរ ។

**-ម្នាលភិក្ខុទាំងឡាយ** សត្វនុ៎ះជាអ្នក**កាន់អំពើវៀចក្នុងស្រុក** ( អំពីដើម ) ក្នុងក្រុងរាជគ្រឹះនេះឯង ។

**-អដ្ឋកថា :** បទថា **គាមកូដោ** ( ជាអាមាត្យអ្នកវិនិច្ឆ័យក្តីនៃអ្នកស្រុកដោយអំពើវៀច ) គឺជាអាមាត្យអ្នកកាត់ក្តីបណ្តឹង ។ សត្វនោះមានអណ្ឌៈប៉ុនឆ្នាំង គឺមានខ្នាតប៉ុនឆ្នាំងធំ ព្រោះមានចំណែកស្មើដោយកម្ម ។ ព្រោះថា សត្វនោះ ព្រោះហេតុដែលទទួលសំណូកក្នុងស្ថានទីកំបាំង កាលនឹងធ្វើទោសឱ្យប្រាកដ ដោយការកាត់ក្តី

បណ្ដឹងកោង បានធ្វើពួកម្ចាស់របស់ មិនឱ្យជាម្ចាស់របស់, ព្រោះដូច្នោះ អវយវៈកំបាំងរបស់សត្វនោះ ទើបកើតប្រាកដ ។ ព្រោះហេតុដែលសត្វនោះ កាលចាប់ដើមតាំងអាជ្ញា បានលើករបស់ធ្ងន់ដែលមិនគួរនឹងធ្ងន់បាន ឱ្យដល់ជនពួកដទៃ, ព្រោះហេតុដែលសត្វនោះតាំងនៅក្នុងតំណែងណា គួរនឹងជាអ្នកស្មើ, តែតាំងនៅក្នុងតំណែងនោះហើយ មិនបានជាអ្នកស្មើទេ, ដូច្នោះ សត្វនោះទើបបានមានការអង្គុយមិនរៀបរយ គឺអង្គុយលើអវយវៈកំបាំង ។

**( ចប់រឿងកុម្ភណ្ឌប្រេតទី ១០ )**

# ចប់អដ្ឋិសង្ខលិកវគ្គទី ១

-ជើងជាស្ពានរឹង ខំប្រឹងបម្រើកាម
ដល់ទៅចាស់រងេមរងាម មានកាមឯណាជាទីពឹង ។

# ឧទ្ទាននៃអដ្ឋិសង្ខលិកវគ្គនោះ គឺ :

អដ្ឋិសង្ខលិកប្រេត, មំសបេសិប្រេត ( ពីដើម ) ជាអ្នកសម្លាប់គោទាំងពីរនាក់, មំសបិណ្ឌប្រេត ( ពីដើម ) ជាព្រានបក្សី, និច្ឆវិប្រេត ( ពីដើម )ជាអ្នកសម្លាប់ចៀម, អសិលោមប្រេត ( ពីដើម) ជាអ្នកសម្លាប់ជ្រូក, សត្តិលោមប្រេត ( ពីដើម ) ជាព្រានម្រឹគ, ឧសុលោមប្រេត ( ពីដើម ) ជាពេជ្ឈឃាត, សូចិលោមប្រេត ( ពីដើម ) ជានាយសារថី, អ្នកណាញុះញង់គេ ( ពីដើម ) អ្នកនោះជាសូចិលោមប្រេតពិត, កុម្ភណ្ឌប្រេតមានអណ្ឌៈធ្ងន់ ( ពីដើម ) ជាអ្នកកាន់អំពើវៀចក្នុងស្រុក ។

# បារទារិកវគ្គទី ២

## ១-រឿងបរទារិកប្រេត

( ប្រេតលួចប្រពន្ធអ្នកដទៃ )

ខ្ញុំបានស្តាប់មក យ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តវេឡុវ័ន ជាកលន្ទកនិវាបស្ថាន ទៀបក្រុងរាជគ្រឹះ។ ម្នាលអាវុសោ ក្នុងទីឯណោះ កាលដែលខ្ញុំចុះមកអំពីភ្នំគិជ្ឈកូដ បានឃើញ**បុរសម្នាក់** កំពុងមុជក្បាលចុះទៅក្នុងរណ្តៅលាមក ។

**-ម្នាលភិក្ខុទាំងឡាយ** សត្វនុ៎ះជាអ្នកប្រព្រឹត្តបរទារិកកម្ម គឺ លួចប្រពន្ធអ្នកដទៃ ( អំពីដើម ) ក្នុងក្រុងរាជគ្រឹះនេះឯង ។

( បេយ្យាលបណ្ឌិតគប្បីធ្វើយ៉ាងនេះ )

**-អដ្ឋកថា :** សត្វនោះ កាលប៉ះពាល់សម្ផស្សដែលមានម្ចាស់ គេឃុំគ្រងរក្សាហើយរបស់អ្នកដទៃ ញុំាងចិត្តឱ្យរីករាយ ដោយសេចក្តីសុខក្នុងកាម ដែលជាសេចក្តីសុខក្នុងឧច្ចារៈ ទើបកើតក្នុងប្រេតវិស័យ នោះ ដើម្បីនឹងប៉ះពាល់សម្ផស្សជាលាមក សោយទុក្ខ ព្រោះមាន

ចំណែកស្មើដោយកម្ម ។

# ចប់រឿងបរនារីកប្រេតឬ
# ក្ងបនិម្មគ្គសូត្រ

**នត្ថិ រាគសមោ អគ្គិ នត្ថិ ទោសសមោ កលិ**
**នត្ថិ ខន្ធ សមាទុក្ខា នត្ថិ សន្តិបរំ សុខំ ។**

-ភ្លើងស្មើដោយរាគៈ មិនមាន ទោសកំហុសស្មើដោយទោសៈ មិនមាន ទុក្ខទាំងឡាយស្មើដោយខន្ធ មិនមាន សុខក្រៅពីសេចក្ដី-ស្ងប់ មិនមាន ។ ( បិដកលេខ ៥២, ទំព័រ ៦៣ )

**នត្ថិ រាគសមោ អគ្គិ នត្ថិ ទោសសមោ គហោ**
**នត្ថិ មោហសមំ ជាលំ នត្ថិ តណ្ហាសមា នទី ។**

-ភ្លើងស្មើដោយរាគៈ មិនមាន ការចាប់ស្មើដោយទោសៈ មិនមាន បណ្ដាញស្មើដោយមោហៈ មិនមាន ស្ទឹងស្មើដោយតណ្ហា មិនមាន ។

( បិដកលេខ ៥២, ទំព័រ ៧៣ )

# ២-រឿងព្រាហ្មណ៍កំណាច
# ( គូថខាទិកប្រេត )

ម្នាលអាវុសោ ក្នុងទីឯណោះ កាលដែលខ្ញុំចុះមកអំពីភ្នំ-គិជ្ឈកូដ បានឃើញ**បុរសម្នាក់** កំពុងមុជចុះក្នុងរណ្ដៅលាមក ។ ចាប់លាមកដោយដៃទាំងសងខាងស៊ី ។

-**ម្នាលភិក្ខុទាំងឡាយ** សត្វនុ៎ះពីដើមជាព្រាហ្មណ៍ ក្នុងក្រុង-រាជគ្រឹះនេះឯង ។ ព្រាហ្មណ៍នោះ កាលក្នុងសាសនាព្រះកស្សប-សម្មាសម្ពុទ្ធ បាននិមន្តភិក្ខុសង្ឃដោយភត្តាហារ ក៏ដាក់លាមកពេញក្នុងស្នូក រួចហើយប្រើគេឱ្យប្រាប់ភត្តកាល ហើយពោលដូច្នេះថា សូមលោកម្ចាស់ទាំងឡាយ និមន្តឆាន់ដរាបដល់ឆ្អែតផង សូមនិមន្តយកទៅផង ។

-**អដ្ឋកថា :** រឿងបុរសអ្នកស៊ីលាមក មានសេចក្ដីជាក់ច្បាស់ហើយ នោះឯង ។

**( ចប់រឿងព្រាហ្មណ៍កំណាចទី ២ )**

# ៣-រឿងនិច្ឆវីស្រីប្រេត

ម្នាលអាវុសោ ក្នុងទីឯណោះ កាលដែលខ្ញុំចុះមកអំពីភ្នំ-គិជ្ឈកូដ បានឃើញ**ស្រីនិច្ឆវី** គឺស្រីអ្នកមិនមានស្បែកក្រៅ កំពុងអណ្តែតទៅលើអាកាស ពួកត្មាត ក្អែក រអាត ដេញតាមឆាប ចោម-ចឹកចោះ ភើចជញ្ជែងនូវស្រីនោះ ស្រីនោះក៏ចេះតែស្រែកថ្ងូរ ។

-**ម្នាលភិក្ខុទាំងឡាយ** ស្រីនុ៎ះ ( ពីដើម ) ជា**ស្រីមេមត់**ក្នុងក្រុងរាជគ្រឹះនេះឯង ។

-**អដ្ឋកថា :** ព្រោះមាតុគ្រាម មិនជាឥស្សរៈក្នុងផស្សៈរបស់ខ្លួន ។ តែស្រីនោះលួចផស្សៈរបស់ស្វាមី ញុំាងសេចក្តីអភិរម្យឱ្យកើតដល់ពួកជនដទៃ, ដូច្នោះ ទើបបានកើតជាស្រីប្រេតប្រាសចាកសម្បុរស្បែក ដើម្បីកម្ចាត់សម្ផស្សជាសុខចេញទៅហើយ សោយសម្ផស្សជាទុក្ខ ព្រោះមានចំណែកស្មើដោយកម្ម ។

**( ចប់រឿងនិច្ឆវីស្រីប្រេតទី ៣ )**

# ៤-រឿងមង្គុឡីស្រីប្រេត

ម្នាលអាវុសោ ក្នុងទីឯណោះ កាលដែលខ្ញុំចុះមកអំពីភ្នំ-គិជ្ឈកូដ បានឃើញ**ស្រីមង្គុឡី** មានក្លិនស្អុយ កំពុងអណ្ដែតទៅលើអាកាស ពួកត្មាត ក្អែក រអាត ដេញតាមឆាប ចោមចឹកចោះភើចជញ្ជែងនូវស្រីនោះ ស្រីនោះក៏ចេះតែស្រែកថ្ងូរ ។

-**ម្នាលភិក្ខុទាំងឡាយ** ស្រីនុ៎ះ ( ពីដើម ) ជា**ស្រីប្រព្រឹត្តកន្លងចិត្តប្ដី** ក្នុងក្រុងរាជគ្រឹះនេះឯង ។

-អដ្ឋកថា : បទថា **មង្គុលី** ( ប្រេតអាក្រក់ គួរខ្ពើមឆ្អើម ) បានដល់ មានរូបខុសប្រក្រតីទៅ គឺសម្លឹងមើលគួរស្អប់ គួរខ្ពើម ។ បានឮថា ស្រីនោះធ្វើនាទីជាមេមត់ គឺជាប្រធានទាសីរបស់យក្ខពោលថា " កាលធ្វើពលីកម្មយ៉ាងនេះដោយវត្ថុនេះ និងវត្ថុនេះសេចក្ដីចម្រើនរបស់ពួកលោក ឈ្មោះនេះនឹងមាន " ដូច្នេះ ហើយកាន់យករបស់ក្រអូប និងផ្កាឈើជាដើមរបស់មហាជនដោយការបោកបញ្ឆោត ញុំាងមហាជនឱ្យប្រកាន់មិច្ឆាទិដ្ឋិ ដែលជាទិដ្ឋិអាក្រក់ ។ ព្រោះដូច្នោះ ទើបនាងកើតជាស្រីប្រេតមានក្លិនស្អុយ ព្រោះលួចរបស់ក្រអូប និងផ្កាឈើជាដើម ជាស្រីប្រេតសម្លឹងមើលគួរស្អប់ មាន

រូបអាក្រក់គួរខ្ពើម ព្រោះហេតុឱ្យមហាជនប្រកាន់សេចក្ដីអាក្រក់ ព្រោះមានចំណែកស្មើដោយកម្មនោះ ។

## ( ចប់រឿងមង្គលស្រីប្រេតទី ៤ )

**យោ ច វស្សសតំ ជីវេ ទុប្បញ្ញោ អសមាហិតោ**
**ឯកាហំ ជីវិតំ សេយ្យោ បញ្ញវន្តស្ស ឈាយិនោ ។**

បុគ្គលណា រស់នៅមួយរយឆ្នាំ ជាមនុស្សមិនមានប្រាជ្ញា មានចិត្តមិនបានតម្កល់ខ្ជាប់ ការរស់នៅតែមួយថ្ងៃ របស់លោកដែលមានប្រាជ្ញា មានការពិនិត្យពិចារណា ជាប្រក្រតី ប្រសើរជាង ។

( បិដកលេខ ៥២, ទំព័រ ៤៥ )

# ៥. រឿងឱកិលិនីប្រេត

ម្នាលអាវុសោ ក្នុងទីឯណោះ កាលដែលខ្ញុំចុះមកអំពីភ្នំ-គិជ្ឈកូដ បានឃើញ**ស្រីមានកាយឆេះរោលរាលដោយភ្លើង** មានកាយសើមជោកជាំ មានកាយដេរដាសដោយរងើកភ្លើង កំពុងអណ្តែតទៅលើអាកាស ស្រីនោះក៏ចេះតែស្រែកថ្ងូរ ។

-**ម្នាលភិក្ខុទាំងឡាយ** ស្រីនុ៎ះ ( ពីដើម ) ជា**អគ្គមហេសីនៃស្តេចក្នុងដែនកលិង្គ** ស្រីនោះ ជាអ្នកមានសេចក្តីឫស្យាគ្របសង្កត់ បានចាក់រងើកភ្លើងមួយអំបែង លើស្រីជាមហេសីចុង ។

-**អដ្ឋកថា :** ពាក្យថា **ឧប្បក្កំ ឱកិលិនី ឱកិរណី** ( ដែលកើត-ជាឱកិលិនីប្រេត ឆេះរោលដោយរងើកភ្លើង មានរងើកភ្លើងធ្លាក់ស្រោចលើខ្លួន ) ( ក្តៅអន្ទះសា ) មានសេចក្តីថា បានឮថា ស្រីប្រេតនោះ ដេកនៅលើជើងថ្ករងើកភ្លើង បម្រះនឿលត្រឡប់ទៅមកត្រូវភ្លើងឆេះ, ព្រោះដូច្នោះ នាងទើបជាអ្នកត្រូវឆេះរោលរាល មានសរីរៈឆ្អិនដោយភ្លើងក្រុត មានទឹកញើសស្រក់ មានសរីរៈសើម គឺតំណក់ទឹកញើសទាំងឡាយ រមែងហូរចេញអំពីសរីរៈរបស់ស្រីនោះ និងមានរងើកភ្លើងដេរដាស គឺពាសពេញដោយរងើកភ្លើង ។ ព្រោះ-

ថា រងើកភ្លើងទាំងឡាយ មានពណ៌ដូចផ្ការលួសផ្អុង រមែងធ្លាក់សូម្បីអំពីខាងក្រោមរបស់ស្រីប្រេតនោះ រងើកភ្លើងទាំងឡាយរមែងធ្លាក់ទាំងសងខាង សូម្បីអំពីអាកាសក្នុងខាងលើរបស់ស្រីប្រេតនោះ ។ ដោយហេតុនោះ លោកទើបពោលថា " ឆេះរោលដោយរងើកភ្លើង មានរងើកភ្លើងធ្លាក់ស្រោចលើខ្លួន ទឹកញើសស្រក់ ( ក្តៅអន្ទះសា ) " ។ នាងនោះ ជាមនុស្សប៉ុនប្រច័ណ្ឌ យកខ្ទះរងើកភ្លើងជះស្រីរួមប្តី ។ បានឮថា នាងរបាំម្នាក់របស់ព្រះរាជា-ព្រះអង្គនោះ ដាក់ខ្ទះរងើកភ្លើងទុកក្នុងទីជិត ជូតទឹកអំពីខ្លួននិងអប់ដោយបាតដៃ ។ ព្រះរាជាទ្រង់សន្ទនានឹងនាងរបាំនោះ និងទ្រង់-សម្តែងអាការប្រោសប្រាណច្រើនពេក ។ ព្រះអគ្គមហេសីទ្រង់ទ្រាំទតមើលហេតុការណ៍នោះ មិនបាន ទ្រង់ប្រច័ណ្ឌ, កាលព្រះរាជាស្តេចចេញទៅមិនយូរប៉ុន្មាន ក៏ទ្រង់ចាប់ខ្ទះរងើកភ្លើងនោះ ចាក់រងើកភ្លើង ស្រោចខាងលើនាងរបាំនោះ ។ ព្រះនាងធ្វើកម្មនោះហើយកើតក្នុងបេតលោក ដើម្បីសោយវិបាកដូច្នោះនុ៎ះឯង ។

**( ចប់រឿងឱកិលិនីប្រេតទី ៥ )**

# ៦-រឿងអសីសកពន្ធប្រេត

# ( ចោរឃាតប្រេត )

ម្នាលអាវុសោ ក្នុងទីឯណោះ កាលដែលខ្ញុំចុះមកអំពីភ្នំ-គិជ្ឈកូដ បានឃើញ**អសីសកពន្ធប្រេត** កំពុងអណ្តែតទៅលើអាកាស ពួកត្មាត ក្អែក រអាត ដេញតាមឆាប ចោមចឹកចោះ ភើចជញ្ជែង នូវប្រេតនោះ ប្រេតនោះក៏ចេះតែស្រែកថ្ងូរ ។

**-ម្នាលភិក្ខុទាំងឡាយ** សត្វនុ៎ះ ( ពីដើម ) ឈ្មោះ **ហារិកៈ ជាអ្នកពិឃាតចោរ** ក្នុងក្រុងរាជគ្រឹះ នេះឯង ។

**-អដ្ឋកថា :** ពេជ្ឈឃាតចោរនោះ កាត់ក្បាលពួកចោរអស់កាលយូរមកហើយ តាមពាក្យបង្គាប់របស់ព្រះរាជា កាលកើតក្នុងបេតលោក ទើបបានកើតជាប្រេតមានរាងកាយអត់ក្បាល ។

## ចប់រឿងអសីសកពន្ធប្រេត

## ( ចោរឃាតប្រេត ) ទី ៦

# ៧-រឿងភិក្ខុប្រេត

ម្នាលអាវុសោ ក្នុងទីឯណោះ កាលដែលខ្ញុំចុះមកអំពីភ្នំ-គិជ្ឈកូដ បានឃើញ**ភិក្ខុ** កំពុងអណ្តែតទៅលើអាកាស សង្ឃាដីរបស់ភិក្ខុនោះក្តី មានភ្លើងឆេះសន្ធោសន្ធៅ បាត្រក្តី ក៏មានភ្លើងឆេះសន្ធោសន្ធៅ វត្ថពន្ធចង្កេះក្តី ក៏មានភ្លើងឆេះសន្ធោសន្ធៅ រាងកាយក្តី ក៏មានភ្លើងឆេះសន្ធោសន្ធៅ ភិក្ខុនោះក៏ចេះតែស្រែកថ្ងូរ ។

**-ម្នាលភិក្ខុទាំងឡាយ** ភិក្ខុនុ៎ះ ( ពីដើម ) ជា**ភិក្ខុលាមក** ក្នុងសាសនាព្រះកស្សបសម្មាសម្ពុទ្ធ ។

**-អដ្ឋកថា :** បទថា **បាបភិក្ខុ** ( ជាភិក្ខុបាប ) គឺជាភិក្ខុលាមក ។ បានឮថា ភិក្ខុនោះបរិភោគបច្ច័យ ៤ ដែលគេប្រគេនដោយសទ្ធា-របស់គេ ជាអ្នកមិនសង្រួមផ្លូវកាយទ្វារ និងចីវរទ្វារ មានអាជីវៈដែលទម្លាយហើយត្រាច់លេងសប្បាយរីករាយតាមពេញចិត្ត ។ ខាងក្រោយត្រូវភ្លើងឆេះនៅក្នុងនរក រហូតដល់អស់មួយពុទ្ធន្តរ កាលកើតក្នុងបេតលោក ក៏កើតដោយអត្តភាពដូចនឹងភិក្ខុនុ៎ះឯង ៕

**-សូម្បីក្នុងរឿងភិក្ខុនី រឿងសិក្ខមានា រឿងសាមណេរ រឿងសាមណេរីប្រេត ក៏មានសេចក្តីវិនិច្ឆ័យយ៉ាងនេះដែរ** ។

# ៨-រឿងភិក្ខុនីប្រេត

ម្នាលអាវុសោ ក្នុងទីឯណោះ កាលដែលខ្ញុំចុះមកអំពីភ្នំ-គិជ្ឈកូដ បានឃើញ**ភិក្ខុនី** កំពុងអណ្តែតទៅលើអាកាស សង្ឃាដីរបស់ភិក្ខុនីនោះក្តី មានភ្លើងឆេះសន្ធោសន្ធៅ បាត្រក្តី ក៏មានភ្លើងឆេះសន្ធោសន្ធៅ វត្ថពន្ធចង្កេះក្តី ក៏មានភ្លើងឆេះសន្ធោសន្ធៅ រាងកាយក្តី ក៏មានភ្លើងឆេះសន្ធោសន្ធៅ ភិក្ខុនីនោះក៏ចេះតែស្រែកថ្ងូរ ។

-**ម្នាលភិក្ខុទាំងឡាយ** ភិក្ខុនីនុ៎ះ ( ពីដើម ) ជា**ភិក្ខុនីលាមក** ក្នុងសាសនាព្រះកស្សបសម្មាសម្ពុទ្ធ ។

## ( ចប់រឿងភិក្ខុនីប្រេតទី ៨ )

# ៩-រឿងសិក្ខមានាប្រេត

ម្នាលអាវុសោ ក្នុងទីឯណោះ កាលដែលខ្ញុំចុះមកអំពីភ្នំ-គិជ្ឈកូដ បានឃើញ**សិក្ខមានា** កំពុងអណ្តែតទៅលើអាកាស សង្ឃាដីរបស់សិក្ខមានានោះក្តី មានភ្លើងឆេះសន្ធោសន្ធៅ បាត្រក្តី ក៏មានភ្លើងឆេះសន្ធោសន្ធៅ វត្តពន្ធចង្កេះក្តី ក៏មានភ្លើងឆេះសន្ធោសន្ធៅ រាងកាយក្តី ក៏មានភ្លើងឆេះសន្ធោសន្ធៅ សិក្ខមានានោះក៏ចេះតែស្រែកថ្ងូរ ។

**-ម្នាលភិក្ខុទាំងឡាយ** សិក្ខមានានុ៎ះ ( ពីដើម ) ជា**សិក្ខមានា-លាមក** ក្នុងសាសនាព្រះកស្សបសម្មាសម្ពុទ្ធ ។

## ( ចប់រឿងសិក្ខមានាប្រេតទី ៩ )

# ១០-រឿងសាមណេរប្រេត

ម្នាលអាវុសោ ក្នុងទីឯណោះ កាលដែលខ្ញុំចុះមកអំពីភ្នំ-គិជ្ឈកូដ បានឃើញ**សាមណេរ** កំពុងអណ្តែតទៅលើអាកាស សង្ឃាដីរបស់សាមណេរនោះក្តី មានភ្លើងឆេះសន្ធោសន្ធៅ បាត្រក្តី ក៏មានភ្លើងឆេះសន្ធោសន្ធៅ វត្ថពន្ធចង្កេះក្តី ក៏មានភ្លើងឆេះសន្ធោ-សន្ធៅ រាងកាយក្តី ក៏មានភ្លើងឆេះសន្ធោសន្ធៅ សាមណេរនោះ ក៏ចេះតែស្រែកថ្ងូរ ។

**-ម្នាលភិក្ខុទាំងឡាយ** សាមណេរនុ៎ះ ( ពីដើម ) ជា**សាមណេរ លាមក** ក្នុងសាសនាព្រះកស្សបសម្មាសម្ពុទ្ធ ។

## ( ចប់រឿងសាមណេរប្រេតទី ១០ )

# ១១-រឿងសាមណេរីប្រេត

ម្នាលអាវុសោ ក្នុងទីឯណោះ កាលដែលខ្ញុំចុះមកអំពីភ្នំ-គិជ្ឈកូដ បានឃើញ**សាមណេរី** កំពុងអណ្តែតទៅលើអាកាស សង្ឃាដីរបស់សាមណេរីនោះក្តី មានភ្លើងឆេះសន្ធោសន្ធៅ បាត្រក្តី ក៏មានភ្លើងឆេះសន្ធោសន្ធៅ វត្ថពន្ធចង្កេះក្តី ក៏មានភ្លើងឆេះសន្ធោ-សន្ធៅ រាងកាយក្តី ក៏មានភ្លើងឆេះសន្ធោសន្ធៅ សាមណេរីនោះ ក៏ចេះតែស្រែកថ្ងូរ ។ ម្នាលភិក្ខុទាំងឡាយ សាមណេរីនុ៎ះ ( ពីដើម ) ជា**សាមណេរីលាមក** ក្នុងសាសនាព្រះកស្សបសម្មាសម្ពុទ្ធ ។ ម្នាល-អាវុសោ ខ្ញុំមានសេចក្តីត្រិះរិះ ដូច្នេះថា ឱអស្ចារ្យណាស់ហ្ន៎ ឱប្លែកណាស់ហ្ន៎ ឃីអើ សត្វបែបនេះនឹងមានខ្លះដែរ យក្សបែបនេះនឹងមានខ្លះដែរ ការត្រឡប់បានអត្តភាពបែបនេះ នឹងមានខ្លះដែរតើ ។

គ្រានោះ ព្រះមានព្រះភាគ ត្រាស់នឹងភិក្ខុទាំងឡាយថា ម្នាល-ភិក្ខុទាំងឡាយ ពួកសាវ័កមានចក្ខុកើតពិតហើយ ម្នាលភិក្ខុទាំងឡាយ ពួកសាវ័កមានញាណកើតពិតហើយ ដ្បិតថាសាវ័កនឹងដឹង ឬនឹងឃើញនូវសាមណេរីបែបនេះ នឹងធ្វើជាសាក្សី ( ដល់តថាគតបាន ) ។ ម្នាលភិក្ខុទាំងឡាយ សាមណេរីនោះ តថាគតធ្លាប់បានឃើញមកពី-

មុនដែរ ។ តែថា តថាគតមិនទាន់បានព្យាករ បើតថាគតព្យាករ ហេតុនោះទៅ ជនទាំងឡាយដទៃមិនជឿពាក្យតថាគត ពួកជនណា មិនជឿពាក្យតថាគត ហេតុដែលមិនជឿនោះ នឹងប្រព្រឹត្តទៅដើម្បី មិនជាប្រយោជន៍ ដើម្បីសេចក្តីទុក្ខ របស់ជនទាំងនោះ អស់កាល ដ៏យូរ ។

-**ម្នាលភិក្ខុទាំងឡាយ** សាមណេរីនោះ ( ពីដើម ) ជា-**សាមណេរីលាមក** ក្នុងសាសនាព្រះកស្សបសម្មាសម្ពុទ្ធ ដោយវិបាក នៃកម្មនោះ សាមណេរីនោះ ក៏ឆេះនៅក្នុងនរក អស់ឆ្នាំទាំងឡាយ-ដ៏ច្រើន អស់រយឆ្នាំដ៏ច្រើន អស់ពាន់ឆ្នាំដ៏ច្រើន អស់សែនឆ្នាំដ៏ច្រើន ដោយសេសសល់វិបាកនៃកម្មនោះឯង ទើបត្រឡប់បាននូវអត្តភាព បែបនេះឯង ។

## ( ចប់រឿងសាមណេរីប្រេតទី ១១ )

# ចប់ធារនារីកវគ្គទី ២

## ឧទ្ទាននៃបារាជិកវគ្គនោះ គឺ ៖

ប្រេតដែលមុជក្នុងរណ្ដៅ ប្រេតនោះ ( ពីដើម ) ជាអ្នកប្រព្រឹត្ត បរទារិកកម្ម, ប្រេតដែលទំពាស៊ីលាមក ប្រេតនោះ ( ពីដើម ) ធ្លាប់ ជាព្រាហ្មណ៍អាក្រក់, ស្រីជានិច្ឆវីប្រេត ( ពីដើម ) ជាអ្នកប្រព្រឹត្ត កន្លងចិត្តប្ដី, ស្រីជាមង្គុឡីប្រេត ( ពីដើម ) ជាស្រីមេមត់, ស្រីជា ឱកិលិនីប្រេត ( ពីដើម ) ធ្វើ ( ប្រទូស្ត ) នឹងស្រីរួមប្ដី, សីសច្ឆិន្នប្រេត ( ពីដើម ) ជាអ្នកសម្លាប់ចោរ, ភិក្ខុ, ភិក្ខុនី, សិក្ខមានា, សាមណេរ, សាមណេរី ( ពីដើម ) បួសក្នុងសាសនាព្រះកស្សបសម្មាសម្ពុទ្ធ បានធ្វើនូវកម្មដ៏លាមក ។

# ចប់ លក្ខណសំយុត្ត

# ប្រេតក្នុងរឿងព្រះសោណកុដិកណ្ណ

( បិដកលេខ ៥២, ទំព័រ ២៤៩-២៥៤ និងអដ្ឋកថា )

ខ្ញុំបានស្តាប់មកយ៉ាងនេះ ។ សម័យមួយ ព្រះមានព្រះភាគ ទ្រង់គង់នៅក្នុងវត្តជេតពន របស់អនាថបិណ្ឌិកសេដ្ឋី ទៀបក្រុង-សាវត្ថី ។ សម័យនោះឯង ព្រះមហាកច្ចានៈដ៏មានអាយុ គង់នៅលើភ្នំឈ្មោះបវត្តៈ ទៀបក្រុងឈ្មោះកុររឃរៈ ក្នុងអវន្តិជនបទ ។ សម័យនោះ ឧបាសកឈ្មោះសោណកុដិកណ្ណៈ ជាឧដ្ឋាក របស់ព្រះមហា-កច្ចានៈ ដ៏មានអាយុ ។ វេលានោះ ឧបាសកឈ្មោះសោណកុដិកណ្ណៈ នៅក្នុងទីស្ងាត់ពួនសម្ងំ កើតសេចក្តីត្រិះរិះ ក្នុងចិត្តយ៉ាងនេះថា លោកម្ចាស់មហាកច្ចានៈសម្តែងធម៌ ដោយអាការណា បុគ្គលដែលនៅគ្រប់គ្រងផ្ទះ មិនងាយនឹងប្រព្រឹត្តព្រហ្មចរិយធម៌នោះ ឱ្យបរិបូណ៌ បរិសុទ្ធពេញលេញ ដូចស័ង្ខដែលដុសខាត់ហើយ ( ដោយអាការនោះ) បានឡើយ បើដូច្នោះ មានតែអញ កោរសក់និងពុកមាត់ ហើយស្លៀកដណ្តប់សំពត់កាសាយៈចេញចាកផ្ទះចូលទៅកាន់ផ្នួស ។ គ្រានោះ ឧបាសកឈ្មោះសោណកុដិកណ្ណៈ ចូលទៅរកព្រះមហាកច្ចានៈដ៏មាន អាយុ លុះចូលទៅដល់ហើយ ថ្វាយបង្គំព្រះមហាកច្ចានៈ ដ៏មានអាយុ

ហើយអង្គុយក្នុងទីសមគួរ ។ លុះឧបាសកឈ្មោះ សោណកុដិកណ្ណៈ អង្គុយក្នុងទីសមគួរហើយ បាននិយាយពាក្យនេះ នឹងមហាកច្ចានៈដ៏-មានអាយុថា បពិត្រលោកម្ចាស់ដ៏ចម្រើន ក្នុងទីនេះ ខ្ញុំព្រះករុណា នៅក្នុងទីស្ងាត់ពួនសម្ងំ កើតសេចក្តីត្រិះរិះ ក្នុងចិត្តយ៉ាងនេះថា លោកម្ចាស់មហាកច្ចានៈ តែងសម្តែងធម៌ ដោយអាការណា បុគ្គលដែលនៅគ្រប់គ្រងផ្ទះ មិនងាយនឹងប្រព្រឹត្តព្រហ្មចរិយធម៌នេះ ឱ្យបរិបូណ៌ បរិសុទ្ធពេញលេញ ដូចជាស័ង្ខ ដែលដុសខាត់ហើយ ( ដោយអាការនោះ ) បានឡើយ បើដូច្នោះ មានតែអញកោរសក់និងពុកមាត់ ហើយស្លៀកដណ្តប់សំពត់កាសាយៈ ចេញចាកផ្ទះ ចូលទៅកាន់ផ្នួស បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់មហាកច្ចានៈ បំបួសខ្ញុំឱ្យទាន ។

លុះឧបាសក និយាយយ៉ាងនេះហើយ ទើបមហាកច្ចានៈដ៏-មានអាយុ ពោលតបនឹងឧបាសក ឈ្មោះសោណកុដិកណ្ណៈដូច្នេះថា នែសោណៈ ព្រហ្មចរិយៈ មានការបរិភោគភត្ត តែមួយពេល មានការដេកនៅម្នាក់ឯង ដរាបដល់អស់មួយជីវិត កម្របុគ្គលនឹងធ្វើបាន នែសោណៈ ណ្ហើយចុះ អ្នកនៅជាគ្រហស្ថ ក្នុងទីនោះបណ្តើរសិនចុះ ចូរប្រកបតាមពាក្យប្រៀនប្រដៅ របស់ព្រះពុទ្ធទាំងឡាយ គឺព្រហ្ម-ចរិយៈ មានការបរិភោគភត្ត តែមួយពេល មានការដេកនៅ តែម្នាក់-

ឯង សមគួរតាមកាលចុះ ។ លំដាប់នោះ ការប្រុងប្រៀបនឹងបួស របស់ឧបាសកឈ្មោះសោណកុដិកណ្ណៈ ក៏អាក់ខានទៅ ។ ឧបាសក សោណកុដិកណ្ណៈ នៅក្នុងទីស្ងាត់ ពួនសម្ងំ កើតសេចក្តីត្រិះរិះ ក្នុង ចិត្តអស់វារៈពីរដងថា លោកម្ចាស់មហាកច្ចានៈ តែងសម្តែងធម៌ ដោយអាការណា បុគ្គលដែលនៅគ្រប់គ្រងផ្ទះ មិនងាយនឹងប្រព្រឹត្ត ព្រហ្មចរិយធម៌នេះ ឱ្យបរិបូណ៌ បរិសុទ្ធពេញលេញ ដូចជាស័ង្ខ ដែលដុសខាត់ហើយ ( ដោយអាការនោះ ) បានឡើយ បើដូច្នោះ មានតែអញ កោរសក់និងពុកមាត់ ហើយស្លៀកដណ្តប់សំពត់ កាសាយៈ ចេញចាកផ្ទះ ចូលទៅកាន់ផ្នួស ។ ឧបាសកឈ្មោះសោណ-កុដិកណ្ណៈ ចូលទៅរកមហាកច្ចានៈ ដ៏មានអាយុ លុះចូលទៅដល់ ហើយ ថ្វាយបង្គំមហាកច្ចានៈ ដ៏មានអាយុ ហើយអង្គុយក្នុងទីសមគួរ អស់វារៈពីរដង ។ លុះឧបាសកឈ្មោះសោណកុដិកណ្ណៈ អង្គុយ ក្នុងទីសមគួរហើយ ពិតថេរវាចាមហាកច្ចានៈដ៏មានអាយុ ដូច្នេះថា បពិត្រលោកម្ចាស់ដ៏ចម្រើន អម្បាញ់មិញនេះ ខ្ញុំនៅក្នុងទីស្ងាត់ ពួនសម្ងំ កើតសេចក្តីត្រិះរិះក្នុងចិត្តយ៉ាងនេះថា លោកម្ចាស់មហា-កច្ចានៈ តែងសម្តែងធម៌ដោយអាការណា បុគ្គលដែលនៅគ្រប់គ្រង ផ្ទះ មិនងាយនឹងប្រព្រឹត្តព្រហ្មចរិយធម៌នេះ ឱ្យបរិបូណ៌ បរិសុទ្ធពេញ លេញ ( ដោយអាការនោះ ) បានឡើយ បើដូច្នោះ មានតែអញ

កោរសក់និងពុកមាត់ ស្លៀកដណ្ដប់សំពត់កាសាយៈ ហើយចេញចាក ផ្ទះចូលទៅកាន់ផ្នួស បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់ មហាកច្ចានៈ បំបួសខ្ញុំឱ្យទាន ។ ព្រះមហាកច្ចានៈ ដ៏មានអាយុ និយាយប្រាប់ឧបាសកឈ្មោះសោណកុដិកណ្ណៈ ធ្វើអស់វារៈពីរដងថា នែសោណៈ ព្រហ្មចរិយៈមានការបរិភោគភត្ត តែមួយពេល មានការ ដេកនៅតែម្នាក់ឯង ដរាបដល់អស់ជីវិត កម្របុគ្គលធ្វើបាន នែ សោណៈណ្ហើយចុះ អ្នកនៅជាគ្រហស្ថក្នុងទីនេះបណ្ដើរសិនចុះ ចូរ-ប្រកបតាមពាក្យប្រៀនប្រដៅរបស់ព្រះពុទ្ធទាំងឡាយ គឺព្រហ្មចរិយៈ មានការបរិភោគភត្តតែមួយពេល មានការដេកនៅម្នាក់ឯង សមគួរ ដល់កាលចុះ ។ ការប្រុងប្រៀបនឹងបួសរបស់ឧបាសកឈ្មោះសោណ-កុដិកណ្ណៈ ក៏អាក់ខានទៅអស់វារៈពីរដង ។ ឧបាសកឈ្មោះសោណ-កុដិកណ្ណៈ នៅក្នុងទីស្ងាត់ ពួនសម្ងំ កើតសេចក្ដីត្រិះរិះ ក្នុងចិត្តយ៉ាង នេះ អស់វារៈ ៣ ដងថា លោកម្ចាស់មហាកច្ចានៈ សម្ដែងធម៌ ដោយ អាការណា បុគ្គលដែលនៅគ្រប់គ្រងផ្ទះ មិនងាយនឹងប្រព្រឹត្តព្រហ្ម-ចរិយធម៌នេះ ឱ្យបរិបូណ៌ បរិសុទ្ធពេញលេញ ដូចជាស័ង្ខដែល ដុសខាត់ហើយ ( ដោយអាការនោះ ) បានឡើយ បើដូច្នោះ មានតែ អញ កោរសក់និងពុកមាត់ ស្លៀកដណ្ដប់សំពត់កាសាយៈ ចេញចាក ផ្ទះចូលទៅកាន់ផ្នួស ។ ឧបាសកឈ្មោះសោណកុដិកណ្ណៈ ចូលទៅរក

មហាកច្ចានៈដ៏មានអាយុ ហើយអង្គុយ ក្នុងទីសមគួរ ជាគម្រប់ ៣ ដង ។ លុះឧបាសកឈ្មោះសោណកុដិកណ្ណៈ អង្គុយក្នុងទីសមគួរ ហើយ ពិតថេរវាចាមហាកច្ចានៈដ៏មានអាយុដូច្នេះថា បពិត្រលោកម្ចាស់ដ៏ចម្រើន អម្បាញ់មិញនេះ ខ្ញុំនៅក្នុងទីស្ងាត់ ពួនសម្ងំ កើតសេចក្តីត្រិះរិះ ក្នុងចិត្តយ៉ាងនេះថា លោកម្ចាស់មហាកច្ចានៈសម្តែងធម៌ ដោយអាការណា បុគ្គលដែលនៅគ្រប់គ្រងផ្ទះ មិនងាយនឹងប្រព្រឹត្តព្រហ្មចរិយធម៌នេះឱ្យបរិបូណ៌ បរិសុទ្ធពេញលេញ ដូចជាស័ង្ខដែលដុសខាត់ហើយ ( ដោយអាការនោះ ) បានឡើយ បើដូច្នោះ មានតែអញ កោរសក់នឹងពុកមាត់ ស្លៀកដណ្តប់សំពត់កាសាយៈ ចេញចាកផ្ទះ ចូលទៅកាន់ផ្នួស បពិត្រលោកម្ចាស់ដ៏ចម្រើន សូមលោកម្ចាស់មហាកច្ចានៈ បំបួសខ្ញុំឱ្យទាន ។ **លំដាប់នោះ** ព្រះមហា-កច្ចានៈ បំបួសឧបាសក ឈ្មោះសោណកុដិកណ្ណៈ ( ក្នុងកាលនោះ ) ។

## សេចក្តីពន្យល់ក្នុងអដ្ឋកថាសោណសូត្រ

បទថា **អវន្តីសុ** បានដល់ ក្នុងអវន្តីរដ្ឋ ។ បទថា **កុររឃរេ** បានដល់ នគរដែលមានឈ្មោះយ៉ាងនោះ ។ បទថា **បវត្តេ បព្វតេ** បានដល់ ភ្នំដែលឈ្មោះថា **បវត្តៈ** អាចារ្យពួកខ្លះពោលថា **បបាតេ បព្វតេ** ដូច្នេះក៏មាន ។ បទថា **សោណោ ឧបាសកោ កុដិកណ្ណោ**

សេចក្តីថា ដោយនាមឈ្មោះថា **សោណៈ** ឈ្មោះថា **ឧបាសក** ព្រោះប្រកាសភាពជាឧបាសកដោយការដល់សរណៈ ៣ ព្រោះទ្រទ្រង់គ្រឿងប្រដាប់ត្រចៀកមានតម្លៃមួយកោដិ ទើបហៅថា **កោដិកណ្ណៈ** តែគេស្គាល់ច្រើនគ្នាថា **កុដិកណ្ណៈ**, អធិប្បាយថា សោណៈជាក្មេងល្អ[១] ។

ក៏សោណឧបាសកនោះ ស្តាប់ធម៌ក្នុងសម្នាក់របស់ព្រះមហាកច្ចានៈដ៏មានអាយុ ជ្រះថ្លាយ៉ាងក្រៃលែងក្នុងព្រះសាសនា តាំងនៅក្នុងសរណៈ និងសីល ទើបចាត់គេឱ្យសាងវិហារក្នុងទីដែលសម្បូរដោយម្លប់ និងទឹកជិតបវត្តបពីតៈ ហើយនិមន្តព្រះថេរៈឱ្យនៅក្នុងវិហារនោះ ទំនុកបម្រុងដោយបច្ច័យទាំង ៤ ។ ព្រោះហេតុនោះលោកទើបពោលថា ជាឧបដ្ឋាករបស់ព្រះមហាកច្ចានៈដ៏មានអាយុ ។ សោណឧបាសកនោះទៅកាន់ទីទំនុកបម្រុងរបស់ព្រះថេរៈតាមវេលាដែលសមគួរ ទាំងព្រះថេរៈក៏បានសម្តែងធម៌ដល់គាត់ ។ ព្រោះហេតុនោះ សោណៈនោះ ទើបមានសេចក្តីតក់ស្លុតយ៉ាងក្រៃលែង កើតសេចក្តីឧស្សាហ៍ក្នុងការប្រព្រឹត្តធម៌ ។ គ្រាមួយ សោណឧបាសកបានទៅក្រុងឧជ្ជេនីជាមួយនឹងពួករទេះ ដើម្បីធ្វើជំនួញ កាលសម្រាកពួករទេះទុកសោណៈនោះចោលក្នុងព្រៃ ត្រង់ចន្លោះនោះ ព្រោះភ័យពី-

១= ក្នុងអដ្ឋកថាច្បាប់ឆដ្ឋសង្គាយនាបានពោលថា សោណៈជាអ្នកមានសុខមាលមិនល្អ ។

ការបៀតបៀនរបស់ជនទាំងឡាយ ក្នុងពេលរាត្រីកន្លែងដ៏សមគួរមួយ ។ ក្នុងវេលាជិតភ្លឺ ពួកអ្នករទេះក៏ក្រោកចេញទៅ សូម្បីមួយនាក់ក៏មិនបានដាស់ឱ្យសោណឧបាសកភ្ញាក់ អ្នករទេះសូម្បីទាំងអស់មិនបាននឹកដល់សោណៈនោះ ក៏បាននាំគ្នាចេញទៅ ។ កាលរាត្រីភ្លឺហើយ សោណឧបាសកនោះភ្ញាក់ពីដេក ហើយក្រោកឡើងមិនឃើញអ្នកណាឡើយ ទើបកាន់យកផ្លូវដែលពួករទេះនុំះឯងទៅ កាលដើរទៅ ដោយប្រញាប់ប្រញាល់ ក៏ទៅដល់ដើមជ្រៃមួយដើម ។

ក្នុងទីនោះ សោណឧបាសកបានឃើញបុរសម្នាក់មានរាងកាយធំសម្បើម មានអាការប្លែក កំពុងទំពាស៊ីសាច់របស់ខ្លួនដែលជ្រុះពីឆ្អឹងដោយខ្លួនឯង ទើបសួរថា លោកជាអ្នកណា ?

ប. នែលោកដ៏ចម្រើន ខ្ញុំជាប្រេត ។

សោ. ព្រោះហេតុអ្វី លោកទើបធ្វើយ៉ាងនេះ ?

ប. ព្រោះបុព្វកម្មរបស់ខ្ញុំខ្លួនឯង ។

សោ. ក៏កម្មនោះជាកម្មអ្វី ? ប្រេតដំណាលថា កាលជាតិមុនខ្ញុំជាឈ្មួញកោងនៅក្នុង**ក្រុងភារុកច្ឆនគរ** បញ្ឆោតបន្លំយករបស់អ្នកដទៃមកទំពាស៊ី និងកាលសមណៈចូលទៅបិណ្ឌបាត ក៏ជេរថា ចូរទំពាស៊ីសាច់ខ្លួនឯងទៅ ព្រោះកម្មនោះ ខ្ញុំទើបបានសោយទុក្ខនេះក្នុងឥឡូវនេះ ។ សោណឧបាសកបានស្តាប់ដូច្នោះហើយ ទើបបាន

ចំពោះនូវសេចក្តីតក់ស្លុតយ៉ាងខ្លាំងក្លា ។

តពីនោះ កាលដើរទៅជួបក្លូនប្រេត ២ រូប ខ្លួនមានលោហិតខ្មៅហូរចេញតាមមាត់ ទើបសួរដូចមុនទៀត ។ ចំណែកប្រេត-ទាំងនោះ ក៏បានប្រាប់កម្មរបស់ខ្លួនដល់សោណៈនោះ ។ បានឮថា ក្នុងកាលនៅពីក្មេង ប្រេតទាំងនោះចិញ្ចឹមជីវិតដោយការធ្វើជំនួញវត្ថុក្នុង**ភារុកច្ឆនគរ** កាលមាតារបស់ខ្លួននិមន្តព្រះខីណាស្រពទាំងឡាយឱ្យមកឆាន់ ទើបទៅកាន់ផ្ទះ ហើយជេរថា ហេតុដូចម្តេច បានជាម៉ែទើបឱ្យវត្ថុរបស់ពួកយើងចំពោះពួកសមណៈ សូមឱ្យលោហិតខ្មៅហូរចេញតាមមាត់របស់ពួកសមណៈ អ្នកបរិភោគភោជន ដែលម៉ែឱ្យហើយចុះ ។ ព្រោះកម្មនោះ ក្មេងទាំងនោះ ទើបឆេះក្នុងនរកហើយក៏កើតក្នុងកំណើតប្រេត ដោយសេសសល់នៃវិបាករបស់កម្មនោះ ទើបសោយទុក្ខយ៉ាងនេះក្នុងកាលឥឡូវនេះ ។ សោណឧបាសកស្តាប់ពាក្យស្លូម្បីនោះ បានកើតសេចក្តីតក់ស្លុតយ៉ាងក្រៃលែង ។

សោណឧបាសកនោះ ក៏ធ្វើដំណើរទៅកាន់ក្រុងឧជ្ជេនី ត្រួតពិនិត្យដល់ការងារដែលខ្លួននឹងគប្បីធ្វើនោះហើយ ទើបត្រឡប់មកកាន់ផ្ទះប្រចាំត្រកូល ចូលទៅរកព្រះថេរៈ បានទទួលការបដិសណ្ឋារៈហើយទើបប្រាប់សេចក្តីនោះដល់ព្រះថេរៈ ។ ចំណែកព្រះថេរៈ កាលនឹងប្រកាសទោសក្នុងការកើតទុក្ខ និងអានិសង្សក្នុងការរលត់ទុក្ខ

ដល់សោណឧបាសកនោះ ទើបសម្ដែងធម៌ ។ សោណឧបាសក ថ្វាយបង្គំព្រះថេរៈ ហើយទៅផ្ទះបរិភោគអាហារពេលល្ងាច ហើយ ទើបចូលដេក គ្រាន់តែលក់ទៅមួយស្របក់ប៉ុណ្ណោះ ក៏ភ្ញាក់ឡើង អង្គុយលើទីដេក ហើយផ្ដើមពិចារណាធម៌តាមដែលខ្លួនបានស្ដាប់ មក ។ កាលលោកពិចារណាជារបស់គួរខ្លាចយ៉ាងក្រៃលែងណាស់ ។ ចិត្តក៏បង្អោនទៅក្នុងបព្វជ្ជា ។ កាលរាត្រីកន្លងទៅហើយ សោណៈ ជម្រះរាងកាយរួចហើយ ក៏ចូលទៅរកព្រះថេរៈ ប្រកាសអធ្យាស្រ័យ របស់ខ្លួនហើយសូមបព្វជ្ជា ។ ព្រោះហេតុនោះ លោកទើបពោល ថា **អថខោ សោណស្ស ឧបាសកស្ស កោដិកណ្ណស្ស រហោគតស្ស ។ ល ។ បព្វជេយ្យន្តិ បព្វាជេតុ មំ ភន្តេ អយ្យោ មហាកច្ចានោតិ** ដូច្នេះជាដើម ។

បណ្ដាបទទាំងនោះ បទមានជាអាទិថា **យថា យថា** មានសេចក្ដីសង្ខេបដូចតទៅនេះ ។ ព្រះមហាកច្ចានៈជាម្ចាស់ សម្ដែង ប្រាប់ បញ្ញត្តិ ផ្ដើមតាំង បើក ចែក ធ្វើឱ្យងាយយល់ ប្រកាសធម៌ ដោយអាការណា ៗ កាលយើង ( សោណៈ ) ពិចារណាដោយអាការ នោះ ៗ រមែងប្រាកដយ៉ាងនេះថា ព្រហ្មចរិយ គឺសិក្ខា ៣ នេះ ដែលយើងនឹងធ្វើមិនឱ្យដាច់ត្រឹមតែ ១ ថ្ងៃ ឱ្យជាព្រហ្មចរិយដ៏បរិបូណ៌ ដោយចំណែកមួយ ព្រោះគប្បីធ្វើឱ្យចាក់ផ្ទុះនូវចិត្តដួងចុងក្រោយ

( ស្លាប់ ) ។ ឱ្យបរិសុទ្ធដោយចំណែកតែមួយ ដោយធ្វើមិនឱ្យមានមន្ទិលដោយមន្ទិល គឺកិលេសត្រឹមតែមួយថ្ងៃដ៏បរិសុទ្ធដោយចំណែកមួយ គប្បីធ្វើឱ្យចាក់ផ្ទុះនូវចិត្តចុងក្រោយ ។ បទថា **សង្ខលិខិតំ** គឺដូចជាស័ង្ខដែលជម្រះដរាបស្អាត ព្រហ្មចរិយនេះ គឺបុគ្គលគ្រប់គ្រងផ្ទះ គឺអ្នកនៅផ្ទះ នឹងមិនងាយធ្វើឱ្យបរិបូណ៌ដោយចំណែកមួយបានឡើយ ។ ល ។ បើដូច្នោះ មានតែយើងគប្បីដាក់ គឺគប្បីកោរសក់និងពុកមាត់ ពុកចង្កា ហើយបិទបាំង គឺស្លៀក និងដណ្ដប់នូវសំពត់កាសាយៈ ដែលជ្រលក់ដោយទឹកអម្ចត់ ជាសំពត់ដ៏សមគួរដល់អ្នកប្រព្រឹត្តព្រហ្មចរិយ ចេញចាកផ្ទះហើយបួស ដោយភាពជាអ្នកមិនមានផ្ទះ ។ ព្រោះហេតុដែលកម្ម មានកសិកម្ម និងពាណិជ្ជកម្មជាដើម ដែលជាប្រយោជន៍ដល់ផ្ទះ លោកហៅថា **អគារិយំ** និងអគារិយៈនោះមិនមានក្នុងបព្វជ្ជា ព្រោះដូច្នោះ បព្វជ្ជាទើបឈ្មោះថា **អនគារិយៈ** ( កម្មមិនជាប្រយោជន៍ដល់ផ្ទះ ), អធិប្បាយថា យើងគប្បីចេញ គឺគប្បីចូលដល់ បានដល់ គប្បីបដិបត្តិធម៌ដែលមិនជាប្រយោជន៍ដល់ផ្ទះ គឺបព្វជ្ជានោះ ។

សោណឧបាសក ប្រាប់ដល់ហេតុដែលខ្លួនត្រិះរិះក្នុងទីកំបាំងដោយអាការយ៉ាងនេះដល់ព្រះថេរៈ ហើយមានសេចក្ដីប្រាថ្នានឹងបដិបត្តិតាមនោះ ទើបពោលថា បពិត្រលោកម្ចាស់ដ៏ចម្រើន សូម-

លោកម្ចាស់មហាកច្ចានៈ បំបួសខ្ញុំព្រះករុណាផង ចំណែកព្រះថេរៈ ពិចារណាថា ញាណរបស់លោកមិនទាន់ចាស់ក្លានៅឡើយ ទើបរង់ចាំសេចក្តីចាស់ក្លារបស់ញាណ ហាមសេចក្តីពេញចិត្តក្នុងបព្វជ្ជា ដោយន័យមានអាទិថា **ទុក្ករំខោ** ដូច្នោះ ។

បណ្តាបទទាំងនោះ ដោយបទថា **ឯកភត្តំ** នេះ លោកពោលសំដៅដល់ការវៀរចាកការបរិភោគក្នុងវេលាវិកាល ដែលពោលទុកយ៉ាងនេះថា ព្រះអរហន្តទាំងឡាយ បរិភោគតែម្តង វៀរចាកការៈបរិភោគក្នុងរាត្រី វៀរចាកការបរិភោគខុសកាល[១] ។ បទថា **ឯកសេយ្យំ** បានដល់ ដេកមិនមានបុគ្គលជាគម្រប់ពីរ ។ ក៏ក្នុងពាក្យថា **ឯកសេយ្យំ** នេះ កាលប្រាថ្នាដល់ការដេកជាប្រធាន លោកទើបសម្តែងកាយវិវេកក្នុងឥរិយាបថទាំង ៤ ដែលពោលហើយដោយន័យមានជាអាទិថា ភិក្ខុនោះដើរម្នាក់ឯង អង្គុយម្នាក់ឯង[២] ដូច្នេះ មិនមែនសម្តែងត្រឹមតែជាអ្នកដេកតែម្នាក់ឯងទេ ។ បទថា **ព្រហ្មចរិយំ** បានដល់ ព្រហ្មចរិយៈ គឺការវៀរចាកមេថុន ឬសាសនព្រហ្មចរិយៈ គឺការប្រកបរឿយ ៗ ក្នុងត្រៃសិក្ខា ។ បទថា **ឥង្ឃ** ជានិបាត ក្នុងៈចោទនត្ថៈ ។ បទថា **តត្ថេវ** បានដល់ ក្នុងផ្ទះនុ៎ះឯង ។ បទថា **ពុទ្ធានំ**

១៖ សុត្តន្តបិដក អង្គុត្តរនិកាយ តិកនិបាត លេខ ៤១ ទំព័រ ២៧៧ ។

២៖ សុត្តន្តបិដក ខុទ្ទកនិកាយ មហានិទ្ទេស លេខ ៦៤ ទំព័រ ២៤៥ ។

**សាសនំ អនុយុញ្ជ** សេចក្តីថា ចូរប្រកបរឿយ ៗ នូវសីលមានអង្គ ៥ មានអង្គ ៨ មានអង្គ ៩ និងមានអង្គ ១០ ផ្សេងដោយការកំណត់ជានិច្ចសីល និងឧបោសថសីលជាដើម និងសមាធិភាវនា និងបញ្ញាភាវនាដែលសមគួរដល់សីលនោះ ។ មែនពិត ព្រហ្មចរិយៈនេះ ដែលឧបាសកគប្បីប្រព្រឹត្តរឿយ ៗ ក្នុងចំណែកខាងដើម ឈ្មោះថា ព្រះពុទ្ធសាសនា ។ ព្រោះហេតុនោះ លោកទើបពោលថា ព្រហ្មចរិយៈមានការបរិភោគភត្តតែមួយពេល មានការដេកនៅតែម្នាក់ឯងសមគួរដល់កាលចុះ ដូច្នេះ ។

បណ្តាបទទាំងនោះ បទថា **កាលយុត្តំ** សេចក្តីថា ប្រកបដោយកាល ពោលគឺ ថ្ងៃ ១៤, ១៥, ៨ រោច និងថ្ងៃបាដិហារិយបក្ខ ។ ម្យ៉ាងទៀត យើងគប្បីអាចរហូតអស់កាលដែលគួរ គឺដែលសមរម្យដល់លោកអ្នកប្រកបរឿយ ៗ ក្នុងកាលតាមដែលពោលហើយ អធិប្បាយថា មិនមែនបួសរហូតអស់កាលទាំងពួងទេ ។ ពាក្យនោះទាំងអស់លោកពោលទុក ដើម្បីធ្វើឱ្យសមរម្យក្នុងសម្មាបដិបត្តិ ព្រោះកាមទាំងឡាយលះបានលំបាក ព្រោះហេតុដែលញាណ របស់សោណៈនោះ មិនទាន់ចាស់ក្លា មិនមែនពោលដើម្បីហាមសេចក្តីពេញចិត្តក្នុងការបព្វជ្ជា ។ បទថា **បព្វជ្ជាភិសង្ខារោ** បានដល់ **ផ្តើម** គឺឧស្សាហ៍ដើម្បីបព្វជ្ជា ។ បទថា **បដិបស្សម្ភិ** សេចក្តីថា រំងាប់ទៅ ព្រោះ-

ឥន្ទ្រិយមិនទាន់ចាស់ក្លា និងព្រោះសេចក្ដីសង្វេគមិនទាន់ខ្លាំងក្លា ។ ការបព្វជ្ជារបស់សោណៈនោះ រំងាប់ទៅក៏ពិត បើយ៉ាងនោះ សោណៈក៏នៅតែតម្រង់តាមវិថីដែលព្រះថេរៈប្រាប់ ហើយចូលទៅរកព្រះថេរៈតាមកាលដែលសមគួរ ហើយអង្គុយស្ដាប់ធម៌ ។ ចិត្តរបស់សោណៈកើតឡើងក្នុងការបព្វជ្ជាជាលើកទីពីរ ដោយន័យដូចពោលហើយនុ៎ះឯង ។ សោណៈប្រាប់ដល់ព្រះថេរៈឱ្យជ្រាប ។ សូម្បីលើកទីពីរ ព្រះថេរៈក៏នៅតែហាម ។ តែក្នុងវារៈទីបី ព្រះថេរៈដឹងថា សោណៈមានញាណចាស់ក្លាហើយ ទើបឱ្យសោណៈបព្វជ្ជាដោយគិតថា ឥឡូវនេះ ជាវេលាដែលនឹងឱ្យសោណៈបានបព្វជ្ជា ។ ល ។

( សេចក្ដីពិស្ដារគប្បីមើលក្នុងជីវប្រវត្តិរបស់ព្រះថេរៈផងចុះ )
( ដែលមាននៅក្នុងជីវប្រវត្តិអសីតិមហាសាវ័កនោះ ) ។

## ( ចប់រឿងប្រេតក្នុងរឿងព្រះសោណៈ )

# កាលកញ្ជិកអសុរ

( ខុទ្ទកនិកាយសូត្រទី៧ បិដកលេខ ៣៣, ទំព័រ ១៩២. និងអដ្ឋកថា ៣៣, ទំ. ១៣៥ )

( មានសេចក្ដីពន្យល់ទាក់ទងនឹងសេចក្ដីវិនាសព្រោះស្រេក ដូច្នេះ ) :

បានឮមកថា **កាលកញ្ជិកអសុរ**មួយ មិនអាចអត់ធន់នឹងសេចក្ដីស្រេកបាន ទើបចុះមកកាន់ទន្លេគង្គា ដែលជ្រៅ និងមានទទឹងប្រមាណ ១ យោជន៍ ( ប្រាកដថា ) ក្នុងទីដែលអសុរនោះទៅដល់ទឹកក៏រីងស្ងួតអស់ ( មានតែ ) ផ្សែងផ្សាយឡើង វេលានោះអសុរបានដើរទៅមកនៅលើទឹកនោះ ប្រៀបដូចជាដើរលើថ្មដាដែលក្ដៅគគុក ។ កាលអសុរនោះ បានឮសំឡេងទឹកហើយ ក៏រត់ទៅ រត់មកយ៉ាងនោះឯង វេលាក៏ភ្លឺ ( ល្មម ) ។ វេលានោះ ភិក្ខុដែលសមាទានការត្រាច់បិណ្ឌបាតជាវត្តប្រមាណ ៣០ រូប កំពុងដើរទៅបិណ្ឌបាតពីព្រឹកព្រលឹម ឃើញប្រេតនោះ ទើបសួរថា " ញោម ញោមជាអ្នកណា ? "

ប. ខ្ញុំជាប្រេត លោកម្ចាស់

ភិ. ញោមកំពុងរកអ្វីហ្នឹង ?

ប. រកទឹកផឹក លោកម្ចាស់

ភិ. ទន្លេគង្គានេះ ( មានទឹក ) ពេញព្រៀប ព្រោមមើលមិនឃើញឬ ?

ប. ទឹកទន្លេ មិនសម្រេច ( ប្រយោជន៍ ) ឡើយ លោកម្ចាស់

ភិ. បើដូច្នោះ ចូរព្រោមដេកចុះលើផែនដីនៃទន្លេគង្គាចុះ ពួកអាត្មានឹងដងទឹកចាក់ទៅក្នុងមាត់របស់ព្រោម ។

ប្រេតនោះ បានដេកផ្ងារចុះលើឆ្នេរខ្សាច់ ។ ភិក្ខុបាននាំបាត្រទាំង ៣០ ( ផ្លាស់គ្នា ) ដងទឹកចាក់ទៅក្នុងមាត់របស់ប្រេតនោះ ។ កាលភិក្ខុទាំងនោះធ្វើយ៉ាងនោះ វេលា ( បិណ្ឌបាត ) ក៏ជិតចូលមក ។ គ្រានោះ ភិក្ខុទាំងឡាយទើបនិយាយថា ដល់វេលាបិណ្ឌបាតរបស់ពួកអាត្មាហើយព្រោម ព្រោមល្មមបានសេចក្ដីសប្បាយចិត្តហើយមែនទេ ? ប្រេត ឆ្លើយប្រាប់ថា បពិត្រលោកម្ចាស់ដ៏ចម្រើន បើថាទឹកប្រមាណកន្លះទូកដៃ អំពីទឹកដែលលោកម្ចាស់ប្រមាណ ៣០ រូប យកបាត្រទាំង ៣០ ដួសចាក់ឱ្យព្រោមបានហូរចូលទៅក្នុង.ក ដូចចូលទៅក្នុង.ករបស់អ្នកដទៃសោត សូមឱ្យព្រោមចូរកុំរួចផុតពីអត្តភាពជាប្រេតឡើយ ។ សេចក្ដីវិនាស ព្រោះសេចក្ដីស្រេកប្រាកដ ( ច្បាស់ ) ក្នុងបេតវិស័យដោយប្រការដូចពណ៌នាមកដូច្នេះ ។

# ជាដកសូត្រទី ១

( បិដកលេខ ១៨, ទំព័រ ១-៦៩ និងអដ្ឋកថាភាគ ១៨, ទំ. ១០ )

( តទៅនេះ ខ្ញុំសូមលើកយកនូវពុទ្ធព្យាករក្នុងរឿងអចេល-កោរក្ខត្តិយៈ ត្រង់ទំព័រ ១១ លេខឃ្នាប ៤ ដែលកើតជា**កាលកញ្ជិក-អសុរ** ដូចតទៅនេះ ) :

*ម្នាលភគ្គវៈ សម័យមួយ តថាគតទៅក្នុងឧត្តរកានិគមរបស់ពួកជនថូលុ ក្នុងថូលុជនបទឯណោះ ។ ម្នាលភគ្គវៈ ក្នុងបុព្វណ្ហសម័យ តថាគតស្លៀកស្បង់ ប្រដាប់បាត្រ និងចីវរ មានសុនក្ខត្តលិច្ឆវិបុត្រជាបច្ឆាសមណៈ ដើរចូលទៅបិណ្ឌបាតក្នុងឧត្តរកានិគម ។ ក៏សម័យនោះឯង មានអចេលម្នាក់ ជាកោរក្ខត្តិយៈ[១] សមាទានកុក្កុរវត្ត គឺប្រព្រឹត្តដូចសុនខ ( ឆ្កែ ) ដើរវារជើង ៤ យកមាត់ត្របាក់ស៊ី យកមាត់ស៊ីនូវភក្សាហារដែលគេចាក់ចោលលើផែនដី ។ ម្នាលភគ្គវៈ ឯសុន-ក្ខត្តលិច្ឆវិបុត្របានឃើញអចេលកោរក្ខត្តិយៈ សមាទានកុក្កុរវត្ត ដើរវារជើង ៤ កំពុងយកមាត់ត្របាក់ស៊ី យកមាត់ស៊ីនូវភក្សាហារ ដែលគេចាក់ចោលលើផែនដី ។ លុះសុនក្ខត្តលិច្ឆវិបុត្រនោះ បានឃើញ*

*១- ជាជាតិក្សត្រមានបាទរបួសចូលក្នុង ។*

ហើយក៏មានសេចក្ដីត្រិះរិះដូច្នេះថា អើហ្ន៎ សមណៈជាព្រះអរហន្ត ល្អពេកណាស់ ដើរវារជើង ៤ យកមាត់ត្របាក់ស៊ី យកមាត់ស៊ីនូវ-ភក្សាហារ ដែលគេចាក់ចោលលើផែនដី ។ ម្នាលភគ្គវៈ លំដាប់នោះឯង តថាគតដឹងច្បាស់នូវសេចក្ដីត្រិះរិះ ក្នុងចិត្តនៃសុនក្ខត្តលិច្ឆវិបុត្រ ដោយចិត្ត ( របស់តថាគត ) ហើយបាននិយាយនឹងសុនក្ខត្តលិច្ឆវិបុត្រ យ៉ាងនេះថា ម្នាលមោឃបុរស អ្នកមិនសមបើប្ដេជ្ញាខ្លួនថាជាសក្យបុត្តិយ៍សោះឡើយ ។ សុនក្ខត្តលិច្ឆវិបុត្រនិយាយថា បពិត្រ-ព្រះអង្គដ៏ចម្រើន ព្រោះហេតុដូចម្ដេច បានជាព្រះមានព្រះភាគទ្រង់បន្ទោសខ្ញុំព្រះអង្គយ៉ាងនេះថា ម្នាលមោឃបុរស អ្នកមិនសមបើនឹងប្ដេជ្ញាខ្លួនថាជាសក្យបុត្តិយ៍សោះឡើយ ។ តថាគតក៏និយាយត្រឡប់ទៅវិញថា ម្នាលសុនក្ខត្តៈ ចុះអ្នកបានឃើញអចេល-កោរក្ខត្តិយៈនេះសមាទានកុក្កុរវត្ត ដើរវារជើង ៤ យកមាត់ត្របាក់ស៊ី យកមាត់ស៊ីនូវភក្សាហារ ដែលគេចាក់ចោលលើផែនដី ។ លុះអ្នកឃើញហើយ ក៏មានសេចក្ដីត្រិះរិះដូច្នេះថា អើហ្ន៎ សមណៈជា-ព្រះអរហន្តល្អពេកណាស់ ដើរវារជើង ៤ យកមាត់ត្របាក់ស៊ី យកមាត់ស៊ីនូវភក្សាហារ ដែលគេចាក់ចោលលើផែនដី ដូច្នេះមែនឬ ។ សុនក្ខត្តលិច្ឆវិបុត្រទូលតបថា បពិត្រព្រះអង្គដ៏ចម្រើន កាលបើហេតុយ៉ាងនេះមានហើយ ហេតុអ្វីព្រះមានព្រះភាគ កំណាញ់ព្រះអរហន្ត-

ម្ល៉េះ ។ តថាគតនិយាយតបថា ម្នាលមោឃបុរស តថាគតមិនមែន
កំណាញ់ព្រះអរហន្តទេ តែថា ទិដ្ឋិអាក្រក់យ៉ាងនេះកើតឡើងដល់អ្នក
ហើយ ចូរអ្នកលះបង់ទិដ្ឋិអាក្រក់នោះចេញ ទិដ្ឋិអាក្រក់ដែលប្រព្រឹត្ត
ទៅ ដើម្បីមិនជាប្រយោជន៍ ជាទុក្ខអស់កាលដ៏យូរ កុំបីមានដល់អ្នក
ឡើយ ម្នាលសុនក្ខត្តៈ អ្នកសម្គាល់នូវអចេលកោរក្ខត្តិយៈណា ថាជា-
ព្រះអរហន្ត ជាសមណៈល្អដូច្នេះ ឯអចេលនោះនឹងធ្វើមរណកាល
ដោយ **អលសកព្យាធិ** ក្នុងថ្ងៃទី ៧ ពុំខាន លុះដល់គាត់ធ្វើមរណកាល
ទៅហើយ នឹងទៅកើតក្នុងពួក**អសុរ**ឈ្មោះ **កាលកញ្ជិកៈ** ជាអសុរ-
កាយថោកទាបជាងគេទាំងអស់ ចំណែកខាងជនទាំងឡាយ នឹងនាំ
យកអចេលដែលធ្វើមរណកាលហើយនោះ ទៅចោលក្នុងព្រៃស្មសាន
ដែលមានដើមស្បូវរណ្តាស ។ ម្នាលសុនក្ខត្តៈ បើអ្នកចង់ដឹង គប្បី-
ចូលទៅរកអចេលកោរក្ខត្តិយៈហើយ សួរថា នែអាវុសោកោរខត្តិយៈ
អ្នកដឹងគតិរបស់ខ្លួនដែរឬទេ ម្នាលសុនក្ខត្តៈ ហេតុមានជាប្រាកដ គឺ
អចេលកោរក្ខត្តិយៈ មុខជានឹងប្រាប់អ្នកថា នែអាវុសោសុនក្ខត្តៈ ខ្ញុំដឹង
គតិរបស់ខ្ញុំថា ខ្ញុំឯងលុះធ្វើមរណកាលទៅ នឹងទៅកើតក្នុងពួកអសុរ
ឈ្មោះកាលកញ្ជិកៈ ជាអសុរកាយថោកទាបជាងគេទាំងអស់ ។
ម្នាលភគ្គវៈ សម័យនោះឯង សុនក្ខត្តលិច្ឆវិបុត្រ បានចូលទៅរកអ-
ចេលកោរក្ខត្តិយៈ លុះះចូលទៅដល់ហើយ ក៏បាននិយាយនឹងអចេល-

កោរក្ខត្តិយៈ យ៉ាងនេះថា ម្នាលអាវុសោកោរក្ខត្តិយៈ ព្រះសមណ-គោតម ទ្រង់បានព្យាករឱ្យអ្នកថា អចេលកោរក្ខត្តិយៈនឹងធ្វើមរណ-កាលដោយ**អលសកព្យាធិ**ក្នុងថ្ងៃទី ៧ លុះដល់ធ្វើមរណកាលទៅហើយ នឹងទៅកើតក្នុងកំណើតពួកអសុរឈ្មោះ**កាលកញ្ជិកៈ** ជាអសុរ-កាយថោកទាបជាងគេទាំងអស់ ជនទាំងឡាយនឹងនាំយកអចេលដែលធ្វើមរណកាលហើយនោះ ទៅចោលឯព្រៃស្មសានដែលមានដើមស្បូវរណ្តាស ម្នាលអាវុសោកោរក្ខត្តិយៈ ព្រោះហេតុនោះគួរអ្នកបរិភោគភត្តាហារឱ្យល្មម ។ គួរផឹកទឹកឱ្យល្មម ។ ពាក្យរបស់ព្រះ-សមណគោតម ត្រឡប់ទៅជាពាក្យខុសវិញយ៉ាងណា ( អ្នកគប្បីធ្វើ-យ៉ាងនោះ ) ។ ម្នាលភគ្គវៈ គ្រានោះឯង សុនក្ខត្តលិច្ឆវិបុត្រមិនជឿពាក្យតថាគត ហើយក៏រាប់តាំងអំពី ១ ថ្ងៃ ២ ថ្ងៃ រហូតដល់ ៧ យប់ ៧ ថ្ងៃ ។ ម្នាលភគ្គវៈ លំដាប់នោះឯង អចេលកោរក្ខត្តិយៈ ក៏បានធ្វើមរណកាលដោយ**អលសកព្យាធិ** ក្នុងថ្ងៃទី ៧ ( នោះមែន ) លុះធ្វើមរណកាលហើយ ក៏ទៅកើតក្នុងពួកអសុរឈ្មោះ**កាលកញ្ជិកៈ** ជាអសុរកាយ ថោកទាបជាងគេទាំងអស់ ពួកមហាជនក៏នាំគ្នាយកអចេលដែលធ្វើមរណកាលហើយនោះ ទៅចោលក្នុងព្រៃស្មសានដែលមានដើមស្បូវរណ្តាស ។ ម្នាលភគ្គវៈ សុនក្ខត្តលិច្ឆវិបុត្រ បានឮដំណឹងថា អចេលកោរក្ខត្តិយៈបានធ្វើមរណកាល ដោយ**អលសក**-

**ព្យាធិ** ពួកមនុស្សបាននាំយកទៅចោល ឯព្រៃស្មសាន ដែលមានដើម ស្បូវវណ្ណាស ។ ម្នាលភគ្គវៈ លំដាប់នោះឯង សុនក្ខត្តលិច្ឆវិបុត្រ ក៏ដើរចូលទៅរកអចេលកោរក្ខត្តិយៈ ក្នុងព្រៃស្មសាន ដែលមានដើម ស្បូវវណ្ណាស លុះចូលទៅដល់ហើយ ក៏យកដៃទះសាកសពអចេល-កោរក្ខត្តិយៈ ៣ ដង សួរថា ម្នាលអាវុសោកោរក្ខត្តិយៈ អ្នកដឹងគតិ របស់ខ្លួនឬទេ ។ ម្នាលភគ្គវៈ សម័យនោះឯង សាកសពអចេល-កោរក្ខត្តិយៈ យកដៃបោសខ្នងក្រោកឡើងប្រាប់ថា ម្នាលអាវុសោ សុនក្ខត្តៈ ខ្ញុំដឹងគតិរបស់ខ្ញុំថា ខ្ញុំបានមកកើត ក្នុងពួកអសុរឈ្មោះ កាលកញ្ជិកៈហើយ ជាអសុរកាយថោកទាបជាងគេទាំងអស់ ដូច្នេះ ហើយ ក៏ដួលដេកផ្ងារ ស្រទាងក្នុងទីនោះទៅវិញ ។ ម្នាលភគ្គវៈ គ្រានោះឯង សុនក្ខត្តលិច្ឆវិបុត្រ ក៏ចូលមករកតថាគត លុះចូលមក ដល់ហើយក៏ថ្វាយបង្គំតថាគត រួចអង្គុយក្នុងទីសមគួរ ។ ម្នាលភគ្គវៈ លុះសុនក្ខត្តលិច្ឆវិបុត្រ អង្គុយក្នុងទីសមគួរហើយ តថាគតក៏សួរ យ៉ាងនេះថា ម្នាលសុនក្ខត្តៈ អ្នកសម្គាល់សេចក្តីនោះថាដូចម្តេច តថាគតបានប្រារព្ធព្យាករ នូវអចេលកោរក្ខត្តិយៈប្រាប់អ្នកយ៉ាងណា-មិញ វិបាកនោះក៏ពិតដូច្នោះមែន មិនបានទៅជាខុសវិញទេឬ ។ សុនក្ខត្តលិច្ឆវិបុត្រ ក៏ទូលតបមកវិញថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគ ទ្រង់ប្រារព្ធព្យាករនូវអចេលកោរក្ខត្តិយៈ ប្រាប់ខ្ញុំ

ព្រះអង្គយ៉ាងណា វិបាកនោះក៏ពិតដូច្នោះមែន មិនមែនផ្សេងទេ ។ តថាគតសួរថា ម្នាលសុនក្ខត្តៈ អ្នកសម្គាល់សេចក្តីនោះថាដូចម្តេច បើហេតុយ៉ាងនេះមានហើយ តើតថាគតឈ្មោះថាបានធ្វើឥទ្ធិបាដិ-ហារិយ៍ជាធម៌ដ៏ប្រសើរ ក្រៃលែងជាងធម៌របស់មនុស្សហើយ ឬមិនមែនបានធ្វើទេ ។ សុនក្ខត្តលិច្ឆវិបុត្រទូលតបថា បពិត្រព្រះអង្គដ៏ចម្រើន កាលបើហេតុយ៉ាងនេះមានហើយ ឈ្មោះថា ព្រះអង្គបានធ្វើឥទ្ធិបាដិហារិយ៍ ជាធម៌ដ៏ប្រសើរក្រៃលែងជាងធម៌របស់មនុស្សពិតមែនហើយ មិនមែនថាព្រះអង្គមិនធ្វើទេ ។ តថាគតនិយាយតបថា ម្នាលមោឃបុរស កាលបើដូច្នោះមែន ( ចុះដូចម្តេច ) ក៏អ្នក-និយាយនឹងតថាគត ដែលជាអ្នកធ្វើឥទ្ធិបាដិហារិយ៍ ជាធម៌ដ៏ប្រសើរក្រៃលែងជាងធម៌របស់មនុស្សយ៉ាងនេះថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគ ពិតជាមិនធ្វើឥទ្ធិបាដិហារិយ៍ ជាធម៌ដ៏ប្រសើរក្រៃលែងជាងធម៌របស់មនុស្ស ដល់ខ្ញុំព្រះអង្គទេ ម្នាលមោឃបុរស អ្នកចូរមើលចុះ អំពើនេះជាកំហុសរបស់អ្នក ។ ម្នាលភគ្គវៈ ឯ-សុនក្ខត្តលិច្ឆវិបុត្រ កាលតថាគតស្តីឱ្យយ៉ាងនេះ ក៏គេចចេញចាកធម្មវិន័យនេះបាត់ទៅ ដូចជាសត្វដែលទៅកើតក្នុងអបាយ ឬទៅកើតក្នុងនរក ។

# សេចក្តីពន្យល់ក្នុងអដ្ឋកថា

បទថា **សមយំ** បានដល់ ក្នុងសម័យ ។ អធិប្បាយថា ក្នុង-កាលមួយតថាគត ។ បទថា **ថូលូសុ** អធិប្បាយថា មានជនបទមួយកន្លែង ឈ្មោះថា **ថូលូ** តថាគតនៅក្នុងជនបទនោះ ។ បទថា **ឧត្តរកា នាម** អធិប្បាយថា មាននិគមថូលូជនបទ មានឈ្មោះជាភេទស្រីថា **ឧត្តរកា** ទ្រង់អាស្រ័យនិគមនោះ ជាគោចរគ្រាម ។ បទថា **អចេលោ** បានដល់ អ្នកអាក្រាតកាយ ។ បទថា **កោរក្ខត្តិយោ** បានដល់ ក្សត្រ អ្នកមានព្រះបាទ.ងខុប ។ បទថា **កុក្កុរវត្តិកោ** បានដល់ សមាទានសុនខវត្ត ហិតក្លិនស៊ីអាហារដេកក្នុងបរិវេណផេះចង្ក្រានដូចសុនខ ធ្វើកិរិយារបស់សុនខ សូម្បី-យ៉ាងដទៃទៀត ។ បទថា **ចតុកោណ្ឌិកោ** គឺ វារជើង ៤ បានដល់ជង្គង់ពីរ និងដៃពីរច្រត់លើផែនដី ដើរទៅ ។ បទថា **ឆមានិកិណ្ណំ** បានដល់ ដែលរាត់រាយ ចាក់ទុក ដាក់ទុកលើផែនដី ។ បទថា **ភក្ខសំ** បានដល់ អាហារ គឺ របស់ទំពា របស់បរិភោគណាមួយ ។ បទថា **មុខេនេវ** គឺ មិនបានប្រើដៃចាប់អាហារ ប្រើមាត់តែម្យ៉ាងទំពាអា-

អាហារ ដែលគប្បីទំពា សូម្បីអាហារដែលគប្បីបរិភោគ ។ ក៏ប្រើមាត់តែម្យ៉ាងបរិភោគ ។ បទថា **សាធុរូបោ** បានដល់ មានរូបស្អាត ។ បទថា **អរហំ សមណោ** បានដល់ សមណៈដែលជាព្រះអរហន្តមួយអង្គ ។

សព្ទថា **ខលុ** ក្នុងបាលីនោះ ជានិបាតចុះក្នុងអត្ថនៃសេចក្ដីប្រាថ្នា ។ បានឮថា ព្រះរាជកុមារនោះ មានសេចក្ដីប្រាថ្នាយ៉ាងនេះថា អ្នកបួសដទៃដែលនឹងចាត់ថា ជាសមណៈ ដូចសមណៈរូបនេះមិនមាន ព្រោះសមណៈរូបនេះមិនស្លៀកសំពត់ ព្រោះជាអ្នកមានសេចក្ដីប្រាថ្នាតិច មានសេចក្ដីសម្គាល់ថា វត្ថុនេះ ជាហេតុឱ្យកើតសេចក្ដីយឺតយូរ ទើបមិនប្រើសូម្បីភាជនៈសម្រាប់ដាក់អាហារ ស៊ីអាហារដែលទុកនៅលើផែនដីប៉ុណ្ណោះ អ្នកបួសរូបនេះចាត់ថា ជា-សមណៈ ចំណែកពួកយើងនឹងជាសមណៈបានយ៉ាងណា ។ សាវ័កអ្នកដើរតាមក្រោយព្រះពុទ្ធជាសព្វញ្ញូ យ៉ាងនេះ ក៏មានការនឹកគិតអាក្រក់ ដូច្នេះ ។

ពាក្យថា **ឯតមត្ថំ** អធិប្បាយថា បានឮថា ព្រះមានព្រះភាគទ្រង់ត្រិះរិះថា សុនក្ខត្តៈ អ្នកមានអធ្យាស្រ័យថោកទាបនេះ ជាអ្នកបួសនេះ គិតយ៉ាងណាហ្ន៎ គ្រាទ្រង់ត្រិះរិះយ៉ាងនេះ ទ្រង់ជ្រាបអធ្យា-ស្រ័យរបស់គេ ទ្រង់ពិចារណាឃើញថា មោឃបុរសនេះ ដើរតាម

ក្រោយព្រះសព្វញ្ញូដូចតថាគត ទៅសម្គាល់អ្នកបួសដែលអាក្រាតកាយថា ជាព្រះអរហន្ត ឥឡូវនេះ ជនពាលនេះ គួរត្រូវតិះដៀលទោសក្នុងទីនេះឯង ដោយទ្រង់មិនទាន់ត្រឡប់ឡើយ បានត្រាស់ពាក្យថា **ត្វំបិ នាម** ជាដើមនេះ ។ **បិ** សព្ទ ក្នុងពាក្យថា **ត្វំបិ នាម** នោះចុះក្នុងអត្ថថា តិះដៀល ។ ព្រោះព្រះមានព្រះភាគ កាលទ្រង់-តិះដៀលសុនក្ខត្តៈ បានត្រាស់ពាក្យថា " **ត្វំបិ នាម** " ។ ក្នុងពាក្យនេះ មានពាក្យអធិប្បាយដូច្នេះថា សូម្បីខ្លួនអ្នក មានអធ្យាស្រ័យថោកទាបថ្នាក់នេះ នៅតែប្ដេជ្ញាយ៉ាងនេះថា យើងជាសមណៈ ជា-សក្យបុត្តិយ៍ទៀតឬ ។ ដោយពាក្យថា **កឹ បន មេ ភន្តេ** សុនក្ខត្តៈបានក្រាបទូលសួរថា បពិត្រព្រះអង្គដ៏ចម្រើន ព្រះមានព្រះភាគ ទ្រង់-ឃើញវត្ថុដែលគួរតិះដៀលអ្វី ក្នុងខ្លួនរបស់ខ្ញុំព្រះអង្គ ទើបបានត្រាស់យ៉ាងនេះ ។ គ្រានោះ ព្រះមានព្រះភាគ កាលត្រាស់ប្រាប់ដល់គេបានត្រាស់ពាក្យថា **ននុ តេ** ជាដើម ។ ដោយពាក្យថា **មច្ឆរាយតិ** នេះ សុនក្ខត្តៈ បានក្រាបទូលសួរថា ព្រះមានព្រះភាគ ទ្រង់ហួងហែងព្រះអរហត្ត ព្រោះទ្រង់ត្រិះរិះយ៉ាងនេះថា អ្នកដទៃចូរកុំបានជាព្រះ-អរហន្ត ឬ ។ ពាក្យថា **ន ខោ អហំ** អធិប្បាយថា ម្នាលមោឃបុរសតថាគតប្រាថ្នាឱ្យមនុស្សលោក ព្រមទាំងទេវលោកបានព្រះអរហន្តទាំងអស់គ្នា តថាគតធ្វើកម្មដែលធ្វើបានលំបាកច្រើនណាស់ បំពេញ-

បារមី ក៏ដើម្បីប្រយោជន៍យ៉ាងនេះប៉ុណ្ណោះ តថាគតមិនបាន ហួងហែងព្រះអរហន្តឡើយ ។ ពាក្យថា **ឆាបកំ ទិដ្ឋិគតំ** អធិប្បាយថា គេកើតមានការឃើញក្នុងបុគ្គលដែលមិនមែនព្រះ-អរហន្ត ។ ព្រះមានព្រះភាគត្រាស់ថា **ឆាបកំ ទិដ្ឋិគតំ** សំដៅដល់ការឃើញខុសដូចពោលមកនោះ ។ ពាក្យថា **យំ ខោ បន** បានដល់ អ្នកសម្គាល់ អ្នកបួសដែលអាក្រាតកាយរូបនោះ យ៉ាងនោះ ។

ពាក្យថា **សត្តមំ ទិវសំ** ប្រែថា ក្នុងថ្ងៃទី ៧ ។ បទថា **អលសកេន** បានដល់ ដោយព្យាធិឈ្មោះ **អលសកៈ** ។ ពាក្យថា **កាលំ ករិស្សតិ** ប្រែថា ស្លាប់ ព្រោះមានពោះហើមប៉ោង ។

ពាក្យថា **កាលកញ្ជិកា** ជាឈ្មោះរបស់អសុរទាំងនោះ ។ បានឮថា អសុរទាំងនោះ មានអត្តភាពកម្ពស់ ៣ គាវុត មានសាច់និងលោហិតតិច ដូចស្លឹកឈើចាស់ មានភ្នែកលៀនចេញមកជាប់នៅលើក្បាលដូចក្តាម មានមាត់ប៉ុនរន្ធម្ជុលជាប់នៅលើក្បាលដូចគ្នា ឱនខ្លួនចុះយកមាត់ស៊ីអាហារ ។

បទថា **វីរណត្ថម្ភកេ** អធិប្បាយថា ក្នុងព្រៃជាទីចោលសាកសពនោះ មានស្បូវរណ្តាស ព្រោះដូច្នោះ ទើបហៅព្រៃជាទី-ចោលសាកសពនោះថា **វីរណត្ថម្ភកេ** ។ ពាក្យថា **តេនុបសង្កមិ** អធិប្បាយថា កាលព្រះមានព្រះភាគត្រាស់ ដូច្នោះ ស្តេចទៅបិណ្ឌ-

បាតក្នុងស្រុកនោះ ហើយស្ដេចទៅកាន់វិហារ សុនក្ខត្តៈបានចេញពីវិហារ ចូលទៅរកអ្នកបួសស្រាតនោះ ។ ពាក្យថា **យេន ត្វំ** សេចក្ដីថា អ្នកត្រូវព្រះមានព្រះភាគទ្រង់ព្យាករទុក ព្រោះហេតុអ្វី ។ អធិប្បាយថា ព្រោះហេតុដែលលោកត្រូវព្រះមានព្រះភាគ ទ្រង់ព្យាករទុក ។ ពាក្យថា **មត្តំ មត្តំ** បានដល់ ល្មមគួរដល់ប្រមាណ ។ បាលីកន្លែងខ្លះថា **មន្តា មន្តា** ក៏មានអធិប្បាយថា ប្រើបញ្ញាពិចារណា ។ ពាក្យថា **យថា សមណស្ស** សេចក្ដីថា សុនក្ខត្តៈបានពោលថា លោកគប្បីធ្វើឱ្យពាក្យពោល របស់ព្រះសមណគោតមខុសទៅ ។ កាលសុនក្ខត្តៈពោលយ៉ាងនេះហើយ អ្នកបួសអាក្រាតដេកក្នុងបរិវេណផេះចង្ក្រានដូចសុនខ បានអើតក្បាល បើកភ្នែកក្រឡេកមើល ពោលថា ព្រះសមណគោតម ជាអ្នកចងពៀរ ជាសត្រូវ នឹងពួកយើង បាននិយាយអ្វី ចាប់តាំងពីព្រះសមណគោតមឧប្បត្តិឡើងមក ពួកយើងមានសភាពដូចជាហ្វូងអំពិលអំពែក ក្នុងយាមព្រះអាទិត្យឧទ័យ ព្រះសមណគោតម គប្បីពោលវាចាយ៉ាងនេះនឹងពួកយើង ឬពោលយ៉ាងដទៃ តែជាធម្មតាថា ពាក្យរបស់អ្នកដែលជាសត្រូវនឹងគ្នា រមែងមិនពិត លោកចូរចេញទៅចុះ យើងនឹងដឹងក្នុងរឿងនេះឯង ហើយដេកទៀតទៅ ។

បទថា **ឯកទ្វីហិកាយ** បានដល់ ពោលរាប់ថា មួយ ពីរ ។

បទថា **យថា តំ** អធិប្បាយថា រាប់ដូចអ្នកខ្លះដែលមិនជឿ គប្បីរាប់និងក្នុងមួយថ្ងៃ បានចូលទៅរកបីដង ប្រាប់ថា មួយថ្ងៃកន្លងទៅហើយ ពីថ្ងៃកន្លងទៅហើយ ។ ពាក្យថា **សត្តមំ ទិវសំ** អធិប្បាយថា បានឮថា អ្នកបួសស្រាតនោះ បានស្តាប់ពាក្យរបស់សុនក្ខត្តៈហើយ មិនបរិភោគឡើយ រហូតដល់អស់ ៧ ថ្ងៃ ។ លុះដល់ថ្ងៃទី ៧ ឧបដ្ឋាកម្នាក់របស់គេគិតថា ថ្ងៃនេះ ជាថ្ងៃទី ៧ ដែលសមណៈប្រចាំត្រកូលរបស់ពួកយើងមិនមក សម្គាល់ថា នឹងកើតសេចក្តីមិនសប្បាយ ហើយឱ្យអាំងសាច់ជ្រូក នាំអាហារទៅគេរទុកលើផែនដីខាងមុខ ។ អ្នកបួសអាក្រាត ក្រឡេកមើលហើយ គិតថា ពាក្យរបស់ព្រះសមណៈគោតមមុខជាពិត ឬកុហកក៏ដោយ តែកាលយើងបរិភោគឆ្អែតហើយ សូម្បីយើងនឹងស្លាប់ក៏សម្គាល់ថា ស្លាប់ដោយល្អ ហើយក៏ក្រាបចុះលូនស៊ីអាហារដរាបឆ្អែត ។ ក្នុងវេលាកណ្តាលយប់ គេមិនអាចនឹងឱ្យអាហាររលួយបាន ទើបអស់ជីវិតដោយរោគឈ្មោះ អលសកៈ ។ សូម្បីគេមិនទាន់គិតថា នឹងបរិភោគដូច្នោះ គេនឹងត្រូវបរិភោគក្នុងថ្ងៃនោះហើយ អស់ជីវិតដោយរោគឈ្មោះ **អលសកៈ** ។ ព្រោះព្រះតថាគតទាំងឡាយ រមែងមិនមានវាចាពាក្យពីរ ។

ពាក្យថា **វីរណត្ថម្ភកេ** អធិប្បាយថា បានឮថា ពួកក្សត្រិយជ្រាបដំណឹងថា **កោរក្ខត្តិយៈអស់ជីវិតហើយ រាប់ថ្ងៃហើយពោលថា** ពាក្យ-

ព្យាកររបស់ព្រះសមណគោតម ក៏ជាពាក្យពិតហើយ ឥឡូវនេះពួកយើងនឹងនាំសាកសពគេទៅចោលក្នុងទីដទៃ នឹងគ្រុបសង្កត់ព្រះ-សមណគោតម ដោយមុសាវាទ បាននាំគ្នាទៅនាំយកវល្លិមកចងសាកសព ហើយទាញទៅព្រមនឹងពោលថា ចោលសាកសពទុកត្រង់នេះ ៗ ។ ទីកន្លែងដែលទាញសាកសពទៅនោះ ជាទីទួលទាំងអស់ ។ ពួកគេទើបទាញសាកសពទៅកាន់ព្រៃទីចោលសាកសពឈ្មោះ **វីរណត្ថម្ភកៈ** ជ្រាបថា ជាស្មសាន ក៏បានទាញសាកសពទៅតាំងចិត្តថា នឹងនាំទៅចោលក្នុងទីដទៃ ។ ភ្លាមនោះ វល្លិទាញសាកសពក៏ដាច់ ។ ពួកគេមិនអាចនឹងឱ្យសាកសពកម្រើកបាន ទើបនាំគ្នាចៀសចេញពីទីនោះទៅ ។ ព្រោះដូច្នោះ ព្រះមានព្រះភាគទើបត្រាស់ថា **បានចោលក្នុងព្រៃស្មសានឈ្មោះ វីរណត្ថម្ភកៈ** ។

ពាក្យថា **តេនុបសង្កមិ** មានពាក្យអធិប្បាយដូច្នេះ ព្រោះហេតុអ្វី ឱរសស្តេចលិច្ឆវី ឈ្មោះសុនក្ខត្តៈ ទើបចូលទៅរក បានជ្រាបថា សុនក្ខត្តៈ ឱរសរបស់ស្តេចលិច្ឆវីនោះ គិតថា ពាក្យពោលរបស់ព្រះសមណគោតម រមែងពិតប្រាកដ ក៏ធម្មតាថា អ្នកស្លាប់នឹងក្រោកឡើងនិយាយនឹងអ្នកដទៃ រមែងមិនមាន ណ្ហើយចុះ យើងនឹងទៅសួរបើព្រះសមណគោតមត្រាស់ប្រាប់ក្តី បើមិនប្រាប់ក្តី យើងនឹងគ្រប-សង្កត់ព្រះសមណគោតមដោយមុសាវាទ ។ សុនក្ខត្តៈ ចូលទៅគាល់

ព្រោះហេតុនេះ ។ បទថា **អាកោដេសិ** ប្រែថា គោះ ( ដោយ-បាតដៃ ) ។ មានពាក្យសួរថា សាកសពរបស់អ្នកដែលស្លាប់ហើយ រមែងមិនអាចនឹងក្រោកឡើងមកនិយាយបាន អ្នកបួសអាក្រាតរូបនោះ បានពោលពាក្យថា " **ម្នាលអ្នកមានអាយុ យើងដឹង** " បានយ៉ាងណា ។ មានពាក្យឆ្លើយថា **គេនិយាយបានដោយពុទ្ធានុភាព** ។ បានជ្រាបថា ព្រះមានព្រះភាគ បាននាំកោរក្ខត្តិយៈ ពីកំណើតអសុរឱ្យចូលស្ថិតក្នុងសាកសព ហើយឱ្យនិយាយ ។ ន័យមួយទៀត ព្រះអង្គទ្រង់បានឱ្យសាកសពនោះនិយាយ ។ ព្រោះវិស័យព្រះពុទ្ធ ជាអចិ-ន្តេយ្យ ( អ្នកដទៃមិនគួរគិត ) ពាក្យថា **តថេវ តំ វិបាកំ** បានដល់ផលរបស់ពាក្យនិយាយនោះ កើតហើយយ៉ាងនោះ សព្ទថា **វិបាកំ** នោះ ចាត់ជាលិង្គវិបល្លាស ។ អត្ថន័យដ៏ត្រឹមត្រូវ ក៏គឺ **តថេវ សោ វិបាកោ** ។ ចំណែកអាចារ្យពួកខ្លះ ពោលថា **វិបក្កំ** ក៏មាន ។ អត្ថន័យ គឺ កើតហើយ ។ សូម្បីគ្រានេះ គួរនឹងបានប្រមូលបាដិ-ហារិយ៍មក ក៏ហេតុការណ៍ទាំងអស់នេះ ជាបាដិហារិយ៍ ៥ យ៉ាង គឺ ព្រះតម្រាស់ថា អ្នកបួសស្រាតនោះ នឹងស្លាប់ក្នុងថ្ងៃទី ៧ គេក៏ស្លាប់តាមព្រះតម្រាស់នោះ នេះជាបាដិហារិយ៍ប្រការទី ១, ព្រះតម្រាស់ថា គេនឹងស្លាប់ដោយរោគ " **អលសកៈ** " គេក៏ស្លាប់ដោយរោគអលសកៈពិត នេះជាបាដិហារិយ៍ប្រការទី ២, ព្រះតម្រាស់ថា អ្នកបួសស្រាត

នោះ នឹងទៅកើតក្នុងពួកអសុរឈ្មោះ **កាលកញ្ជិកា** គេក៏កើតក្នុងភពអសុរពិត នេះជាបាដិហារិយ៍ប្រការទី ៣, ព្រះតម្រាស់ថា ពួកត្រិយនឹងចោលសាកសព ទុកក្នុងព្រៃស្មសានឈ្មោះ វីរណត្ថម្ភកៈ គេក៏ត្រូវចោលក្នុងព្រៃស្មសាននោះពិត នេះជាបាដិហារិយ៍ប្រការទី ៤, ព្រះ-តម្រាស់ថា គេនឹងមកអំពីទីដែលខ្លួនកើតហើយ ពោលនឹងសុនក្ខត្តៈឱ្យសស្តេចលិច្ឆវី គេក៏ពោលពិត នេះជាបាដិហារិយ៍ប្រការទី ៥ ។

( **សូមពិនិត្យក្នុងសូត្រនេះ និងអដ្ឋកថាទាំងស្រុងផងទៀតចុះ** )

## ( ចប់រឿងកាលកញ្ជិកអសុរ )

# រឿងមិត្តវិន្ទុកៈ[(១)]

( ៣១៣ ) តាមន័យក្នុង**អដ្ឋកថាខុទ្ទកវិភង្គ** និង **អដ្ឋកថាសង្គីតិសូត្រ ថា :** « ក្នុងកាលនៃព្រះពុទ្ធទ្រង់ព្រះមានកស្សបៈ កូនរបស់សេដ្ឋីឈ្មោះ មិត្តវិន្ទុកៈ ជាអ្នកមិនមានសទ្ធា មិនជ្រះថ្លាហើយ ត្រូវមាតាប្រាប់ថា " នែកូនប្រុសសម្លាញ់ ថ្ងៃនេះ ចូរកូនរក្សានូវឧបោសថ ស្តាប់ធម៌ ក្នុងព្រះវិហារ រហូតមួយរាត្រី, ម្តាយនឹងឱ្យទ្រព្យ ១ ពាន់ ( កហាបណៈ ) ដល់អ្នក " ដូច្នេះហើយ បានសមាទាន នូវឧបោសថ ព្រោះសេចក្តីលោភក្នុងទ្រព្យ ហើយកំណត់ថា " ទីនេះ នឹងមិនមានភ័យពីណាមក " ហើយក៏បានដេកលក់ ក្រោមធម្មាសនៈ រហូតទាំងរាត្រី ដល់ព្រឹកឡើង ទើបបានទៅផ្ទះ ទទួលយកទ្រព្យ ១ ពាន់ភ្លាមហើយ ញ៉ាំបបរ ។ នាយមិត្តវិន្ទុកៈនោះ ប្រាថ្នាចង់អុំទូកឆ្លងសមុទ្រ

*១= មានសម្តែងក្នុង :* ***មង្គលត្ថទីបនីប្រែ*** *ភាគ ២ ទំព័រ ២២២, ៣៤៧, ភាគ ៣, ទំព័រ ៥១៣, ក្នុង****អដ្ឋកថាខុទ្ទកវិភង្គអភិធម្ម*** *( ប្រែដោយភិក្ខុសុន្ទរ៍_សាមៀន ភាគ ៦, ទំព័រ ៤២២ ), ក្នុងអដ្ឋកថាសង្គីតិសូត្រ ( ខ្មែរ ភាគ ១៩ ទំព័រ ២០៦ ) ក្នុង****មិត្តវិន្ទជាតក ឯកនិបាត, បញ្ចកនិបាត*** *( បិដកលេខ ៥៨, ទំព័រ ៣៦, ៤៧, បិ. ៥៩, ទំព័រ ២៤ និងអដ្ឋកថា ) ក្នុង****តិជ្ឈជាតក នវកនិបាត*** *( បិ.៥៩ ទំ. ១៣៥ និងអដ្ឋកថា ) ក្នុង****ចតុទ្វារជាតក ទសកនិបាត*** *( បិ. ៥៩, ទំ. ១៦២ និងអដ្ឋកថា ) ។* . **( សូមពិនិត្យក្នុងគម្ពីរទាំងអស់នេះថែមទៀតផងចុះ )** ។

ដោយសង្ឃឹមថា " អញនឹងរួបរួមទ្រព្យ " ។

លំដាប់នោះ មាតាបានហាមឃាត់ នាយមិត្តវិន្ទុកៈនោះថា " នែកូនសម្លាញ់ ក្នុងត្រកូលនេះ មានទ្រព្យដល់ទៅ ៤០ កោដិ[១] កូនកុំទៅឡើយ " ។ នាយមិត្តវិន្ទុកៈនោះ មិនស្តាប់ហើយ ចចេសទៅទាល់តែបាន ។ មាតានោះ បានឈររាំងហើយនៅខាងមុខ ។ នាយមិត្តវិន្ទុកៈនោះ ក្រោធហើយ គិតថា " ម្តាយ ( របស់អញ ) នេះ ឈររាំងនៅពីខាងមុខ " ដូច្នេះ បានកន្ទងមាតា ដែលខ្លួនប្រហារឱ្យដួលចុះហើយ ដោយជើង ទើបបានទៅហើយ ។ កាលបើនាយមិត្តវិន្ទុកៈនោះ ចុះទូកទៅ, ក្នុងថ្ងៃទី ៧ ទូកក៏បានកឿងហើយ ។ មនុស្សទាំងឡាយ បានចាប់ស្លាកកាឡកណ្ណីហើយ ។ ស្លាកនោះ បានធ្លាក់ដល់នាយមិត្តវិន្ទុកៈនោះឯង ដល់ទៅ ៣ ដង ។ ពួកមនុស្ស បានឱ្យក្បូន ដល់នាយមិត្តវិន្ទុកៈនោះហើយ បោះទម្លាក់ចោលទៅក្នុងសមុទ្រ ។ នាយមិត្តវិន្ទុកៈនោះ អណ្តែតទៅដល់កោះមួយហើយ សោយសម្បត្តិ ជាមួយនឹងពួកនាងវេមានិកប្រេត សូម្បីត្រូវពួកវេមានិកប្រេតទាំងនោះ ហាមប្រាមថា " សូមលោកកុំទៅខាងមុខ ។ ឡើយ " ដូច្នេះ កាល ( ដើរ ) ទស្សនាមើលនូវសម្បត្តិទ្វិគុណនោះ ៗ ក៏បានឃើញប្រេតមួយ ដែលទូលកងចក្រដ៏មុត ដោយ

១=ក្នុងអដ្ឋកថាចតុទ្វារជាតកថាមាន ៨០ កោដិ, ឯមាតាបិតាជាសោតាបន្នបុគ្គល ។

លំដាប់ ។ កងចក្រនោះបានប្រាកដហើយ ដល់នាយមិត្តវិន្ទុកៈនោះ ប្រៀបដូច ផ្កាឈូក ។ នាយមិត្តវិន្ទុកៈ អង្វរករសុំថា " ចូរអ្នកឱ្យនូវ-ផ្កាឈូកនោះដល់ខ្ញុំ " ។ ប្រេតនោះពោលថា " ម្នាលអ្នក នេះមិនមែនជាផ្កាឈូកទេ, នុ៎ះ ជាកងចក្រដ៏មុតទេតើ " ។ នាយមិត្ត-វិន្ទុកៈនោះ ពោលថា " អ្នកមិនចង់ឱ្យដល់ខ្ញុំ ទើបបញ្ឆោតខ្ញុំ, តើខ្ញុំមិនធ្លាប់ឃើញ ផ្កាឈូកឬ ? " ។ ប្រេតក្រៅនេះ គិតថា " ឯបុរសនេះ ពិតជាធ្វើកម្មដូចជាកម្មដែលអាត្មាអញបានធ្វើហើយ ទើបប្រាថ្នាចង់ទទួល នូវផលនៃកម្មនោះ " ដូច្នេះហើយ ទើបបានពាក់កងចក្រទៅលើអំបែងក្បាល របស់នាយមិត្តវិន្ទុកៈនោះ ហើយក៏បានវត់គេចចេញទៅ »។

( ៣១៤ ) **ដីកាសង្គីតិសូត្រ** « អធិប្បាយថា " ព្រោះសេចក្តីលោភក្នុងទ្រព្យ មិនមែនព្រោះការពេញចិត្ត ក្នុងធម៌ទេ " ។ ឈ្មោះថា មិនមានភ័យមកអំពីទីណា ព្រោះភាវៈជាសភាពដែលអ្នកណាមួយគប្បីឱ្យក្រោកឡើងមិនបាន ។ មាតា បានហាមប្រាមហើយ ដោយបំណងថា " ធម្មតាការធ្វើដំណើរតាមសមុទ្រ មានអន្តរាយច្រើន "។ ពីរបទថា **អន្តរំ ភត្វា** មានសេចក្តីថា បានធ្វើមាតា ត្រង់ចន្លោះនៃជើងទាំង ២ ដោយអំណាច នៃការកន្លងទៅលើ ។ ទូកបានឈប់នៅនឹងហើយ ព្រោះខ្យល់មិនបក់បោក ដោយកម្លាំងនៃកម្មដ៏-

លាមក របស់នាយមិត្តវិន្ទុកៈនោះ ។

នាយមិត្តវិន្ទុកៈនោះ សោយនូវសម្បត្តិ ដោយអានុភាពនៃ-ឧបោសថកម្ម ដែលខ្លួនបានរក្សាហើយ អស់រយៈពេល ១ ថ្ងៃ ត្រូវពួកនាងវេមានិកប្រេត ឯទៀត ៗ ហាមប្រាមហើយ ដូចជានាងវេមានិកប្រេតពួកមុន ៗ ហាមប្រាមថា " ចូរលោក កុំអញ្ជើញទៅខាងមុខ ៗ ឡើយ " យ៉ាងដូច្នេះ ព្រោះហេតុនោះ ទើបព្រះអដ្ឋកថា-ចារ្យ ពោលថា **តាហិ បរតោ បរតោ មា អគមាសីតិ ទុច្ចមានោ** ដូច្នេះ ។ បទថា **ខុរចក្កធរំ** មានសេចក្តីថា នូវបុរសម្នាក់ ដែលទូលកងចក្រដ៏មុត ដូចជាកាំបិតកោរដ៏មុត ។ កងចក្រនោះ បានប្រាកដហើយ ដោយកម្លាំងនៃកម្មដ៏លាមក » ។

( ៣១៥ ) ក្នុងគ្រានោះ **ព្រះពោធិសត្វ** សោយជាតិជាស្តេចនៃទេវតាមួយអង្គ ត្រាច់ចារិកទៅ ក្នុង**ឧស្សុទនរក** បានទៅដល់ទីនោះហើយ ។ នាយមិត្តវិន្ទុកៈ បានឃើញព្រះពោធិសត្វនោះហើយ ទើបសួរថា " បពិត្រស្តេចទេវតា ជាម្ចាស់ កងចក្រនេះ រមែងគ្រប-សង្កត់កិន ដូចជាគ្រឿងកិន ( ត្បាល់ ) កិនកំទេចនូវគ្រាប់ល្ង ដូច្នោះ, បាបអ្វីហ្ន៎ ដែលខ្ញុំបានធ្វើហើយ ? " ។

លំដាប់នោះ ព្រះពោធិសត្វ កាលសម្តែងនូវកម្មដែលគេបានធ្វើហើយដល់គេ ទើបបានពោលនូវគាថា ៣ **ក្នុងចតុទ្វារជាតក**

**ក្នុងទសកនិបាត** ( **បិដកលេខ ៥៩ ទំ. ១៦២** ) **ថា :**

*អ្នកបានទ្រព្យជាង ២០ សែន មិនធ្វើតាមពាក្យរបស់ញាតិ-ទាំងឡាយ ដែលជាអ្នកជួយអនុគ្រោះ ដោយល្អ ។ អ្នកស្ទុះលឿនទៅកាន់ទូក ដែលអណ្តែតទៅកាន់សមុទ្រសាគរជាទីសម្រេចប្រយោជន៍តិច បាននាងវេមានិកប្រេត ៤ នាក់ នាងវេមានិកប្រេត ៨ នាក់ លុះចេញអំពីវេមានិកប្រេត ៨ នាក់ ក៏បាននាងវេមានិកប្រេត ១៦ នាក់ ។ អ្នកចេញអំពីនាងវេមានិកប្រេត ១៦ នាក់ ក៏បាននាងវេមានិកប្រេត ៣២ នាក់ អ្នកជាមនុស្សមានសេចក្តីប្រាថ្នាដ៏លើសលុប បានមកប្រទះនឹងចក្រ ទាំងចក្រក៏វិលកិន នូវអំបែងក្បាលនៃបុរសដែលមានសេចក្តីប្រាថ្នាគ្របសង្កត់ ។*

( ៣១៦ ) **អដ្ឋកថាជាតក** ថា « បណ្តាបទទាំងនោះ បទថា **លទ្ធា** មានសេចក្តីថា ធ្វើឧបោសថកម្ម និង ទទួលយកទ្រព្យ ១ ពាន់ អំពីសម្នាក់នៃមាតា កាលធ្វើនូវការលក់ដូរ បានហើយនូវទ្រព្យ ១ ពាន់ និងទ្រព្យជាង ២០ សែន ( ទៀត ) ។ បទថា **នាភិរិ** មានសេចក្តីថា អ្នកមិនសន្តោសហើយ ដោយទ្រព្យនោះ ស្ទុះទៅកាន់សមុទ្រ ដោយទូក សូម្បីត្រូវមាតាសម្តែងទោស ក្នុងសមុទ្រហើយ ហាមប្រាម ក៏មិនបានធ្វើតាមពាក្យរបស់ញាតិទាំងឡាយអ្នកជួយអនុគ្រោះ ដោយ

ល្អឡើយ បានស្ទុះលឿនទៅកាន់ទូកដែលអណ្តែតកាន់សមុទ្រសាគរដ៏ធំធេង ដែលអាចធ្វើឱ្យទូកលោតផ្លោះទៅបាន ។ បទថា **អប្បសិទ្ធិយំ** គឺ ដែលមានសេចក្តីសម្រេចតិច បានដល់ មានសេចក្តីវិនាសច្រើន ។ ពីរបទថា **ចតុព្ភិ អដ្ឋ** មានសេចក្តីថា ដោយអានិសង្សនៃឧបោសថកម្ម ដែលខ្លួនបានធ្វើហើយ អស់រយៈពេល ១ ថ្ងៃ ព្រោះអាស្រ័យមាតា ទើបអ្នកបានហើយ នូវស្រី ៤ នាក់ ក្នុង-វិមានកែវផលិក, បន្ទាប់អំពីនោះមក អ្នកបានហើយ នូវស្រី ៨ នាក់ ក្នុងវិមានប្រាក់ បានស្រី ១៦ នាក់ ក្នុងវិមានកែវមណី បានស្រី ៣២ នាក់ ក្នុងវិមានមាស » ។

( ៣១៧ ) **ដីកាសង្គីតិសូត្រ** ថា « បទថា **ចតុព្ភិ** មានសេចក្តី-ថា ព្រមជាមួយនឹងនាងវេមានិកប្រេតទាំងឡាយ ៤ នាក់ ដែលដូចជានាងទេពអប្សរ ។ ពីរបទថា **សម្បត្តិំ អនុភវិត្វា** គឺ ជាពាក្យដែលនៅសល់ ( គួរនាំមកបញ្ចូល ) ។ បទថា **អដ្ឋជ្ឈគមា** មានសេចក្តីថា បាបជួបនាងវេមានិកប្រេត ៨ នាក់ ដែលប្រសើរជាងនោះ ដោយគុណមានរូបជាដើម ។ បទថា **អត្រិច្ឆំ** មានសេចក្តីថា ឈ្មោះថាប្រាថ្នាក្នុងកាមគុណនោះ ៗ ព្រោះភាវៈជាអ្នកប្រកបព្រម ដោយសេចក្តីលោភលន់ហួសហេតុ ពោលគឺប្រាថ្នាចង់បានដ៏លើសលប់ » ។

**អដ្ឋកថាជាតក** ថា « ពីរបទថា **អត្រិច្ឆំ ចក្កមាសនោ**

មានសេចក្តីថា អ្នកជាមនុស្សអាក្រក់ មិនត្រេកអរហើយ ដោយទ្រព្យតាមដែលខ្លួនបានហើយ ឈ្មោះថា ប្រាថ្នាចង់បានហួសហេតុ ព្រោះភាពជាអ្នកប្រកបព្រមហើយ ដោយសេចក្តីប្រាថ្នាដ៏លើសលប់ ពោលគឺសេចក្តីលោភលន់ ដែលកន្លងហួស នូវទ្រព្យដែលខ្លួនបានហើយ ៗ យ៉ាងដូច្នេះថា " អាត្មាអញ នឹងបានលើស គឺច្រើនឡើងទៅ ៗ " ដូច្នេះ ព្រោះភាវៈនៃឧបាសថកម្មនោះ អស់ហើយ ទើបបានកន្លងស្រីទាំងឡាយ ៣២ នាក់ហើយ បានទៅដល់ស្រុកប្រេតនេះ បានទទួលហើយ ( នូវចក្រដ៏មុត ) ដោយផលនៃអកុសល គឺការវាយប្រហារនូវមាតានោះ ។ បាឋៈថា **អតិច្ឆំ** ដូច្នេះ ក៏មានខ្លះ, អធិប្បាយថា ប្រាថ្នាចង់បានហួសហេតុ » ។

**ដីកានៃសង្គីតិសូត្រ** ថា « បទថា **ចក្កំ** បានដល់ នូវចក្រដ៏មុតដូចកាំបិតកោរ ។ បទថា **អាសទោ** មានសេចក្តីថា រមែងត្រេកអរទូទៅ ព្រោះភាវៈនៃអកុសលកម្មនោះ ជាហេតុនាំសេចក្តីវិនាសមកឱ្យ » ។

**ដីកាវិភង្គ** ថា « បទថា **ឥច្ឆាហតស្ស** គឺ ជាអ្នកត្រូវសេចក្តីប្រាថ្នាចង់បានបៀតបៀនហើយ » ។

**អដ្ឋកថាជាតក** ថា « បទថា **ភមតិ** មានសេចក្តីថា ចក្រនេះកាលកិននូវអំបែងក្បាល របស់អ្នកនោះ ដែលជាអ្នកត្រូវសេចក្តីប្រាថ្នា

ចង់បានគ្រប់សង្កត់ហើយ ក្នុងពេលឥឡូវនេះ រមែងវិលនៅលើ-អំបែងក្បាល ដូចចក្រនៃនាយស្មូនឆ្នាំង យ៉ាងដូច្នោះ » ។

(-**សូមបញ្ជាក់ថា** : មិត្តវិន្ទុកៈក្តី, កូនត្មាតក្តី ក្នុងកាលណោះ បានមកជាភិក្ខុប្រដៅក្រក្នុងកាលឥឡូវនេះ ។ ចំណែកឯស្តេចទេវតាអង្គនោះក្តី, ត្មាតដែលជាបិតាក្តី គឺបានមកជាព្រះតថាគត ដែលជា-បរមគ្រូនៃយើង ។)

## ( ចប់រឿងមិត្តវិន្ទុកៈ )

# រឿងមិត្តវិន្ទុកៈ

" ក្នុងលោសកជាតកទី ១ នៃឯកនិបាត អត្ថកាមវគ្គ "

( បិដកលេខ ៥៨, ទំព័រ ១៩ និងអដ្ឋកថា )

ព្រះសាស្តា កាលគង់ប្រថាប់នៅក្នុងវត្តជេតពនមហាវិហារ ទ្រង់ប្រារព្ធព្រះលោសកតិស្សត្ថេរ ត្រាស់ព្រះធម្មទេសនានេះ មាន-ពាក្យផ្តើមថា **យោ អត្ថកាមស្ស** ដូច្នេះ ។

ព្រះថេរៈដែលមានឈ្មោះថា លោសកៈនេះ គឺជានរណា ( មានប្រវត្តិមកយ៉ាងណា ? )

លោកជាបុត្តរបស់អ្នកនេសាទម្នាក់ ក្នុងដែនកោសល ជា-អ្នកទម្លាយវង្សត្រកូលរបស់ខ្លួន មិនមានលាភ មកបួសក្នុងសម្នាក់ពួកភិក្ខុ ។

បានឮមកថា លោកចុតិចាកទីដែលលោកកើតហើយ ចាប់បដិសន្ធិក្នុងផ្ទៃរបស់ស្ត្រីអ្នកនេសាទម្នាក់ នៅក្នុងស្រុកអ្នកនេសាទមួយ ដែលរស់នៅរួមគ្នាចំនួន ១,000 គ្រួសារ ក្នុងដែនកោសល ក្នុងថ្ងៃដែលចុះចាប់បដិសន្ធិ អ្នកនេសាទទាំង ១,000 គ្រួសារនោះ នាំគ្នាកាន់សំណាញ់ដើររកត្រី ក្នុងស្ទឹង និងទន្លេ មិនបានត្រីតូច ធំ

សូម្បីតែមួយ ចាប់ពីថ្ងៃនោះមក ពួកអ្នកនេសាទទាំងនោះ ក៏ដល់នូវ-សេចក្តីក្រីក្រលំបាក, កាលនៅក្នុងផ្ទៃមាតានោះឯង ភូមិអ្នកនេសាទនោះ ត្រូវភ្លើងឆេះរហូតដល់ ៧ ដង ត្រូវព្រះរាជាផាកពិន័យរហូត ៧ ដង ពួកអ្នកនេសាទនោះ ទើបដល់នូវសេចក្តីលំបាកដោយលំដាប់ ពួកគេគិតគ្នាថា កាលមុនរឿងបែបនេះមិនធ្លាប់មានដល់ពួកយើងឡើយ ប៉ុន្តែពេលនេះពួកយើងដល់នូវសេចក្តីទុក្ខលំបាក, ក្នុងរវាងពួកយើងប្រាកដជាមានមនុស្សកាឡកណ្ណីណាម្នាក់មិនខាន បើដូច្នេះ ពួកយើងចូរបែងចែកពួកមនុស្សជា ២ ក្រុមចុះ ដូច្នេះហើយបែងចែកមនុស្សក្នុងមួយក្រុម ៥០០ គ្រួសារ តាំងពីពេលនោះមកមាតាបិតា របស់គេនៅក្នុងក្រុមណា ក្រុមនោះក៏ដុនដាបយ៉ាកយ៉ាប់រឹតតែខ្លាំង ក្រុមក្រៅពីនោះដល់នូវសេចក្តីចម្រើន ក្រុមមនុស្សដែលយ៉ាកយ៉ាប់នោះក៏ចែកក្រុមគ្នាទៀត ដោយចែកគ្នាចេញជា ២ ក្រុមទៀត ចែកគ្នាជាក្រុមទៅដោយទំនងនេះ រហូតដល់ត្រកូលរបស់គេនោះឯងសល់នៅឯកោ ( គឺនៅតែគ្រួសារមួយនោះឯង ) ពួកអ្នកនេសាទទាំងឡាយទើបដឹងថា មនុស្សពួកនោះជាកាឡកណ្ណី ក៏នាំគ្នាចោមរោមដេញវាយដេញគប់គ្រវែងបណ្តេញចេញទៅ គ្រានោះមាតាបិតារបស់គេ ចិញ្ចឹមជីវិតមកដោយសេចក្តីខ្វះខាតយ៉ាងខ្លាំង ពេលគភ៌ចាស់ហើយក៏ប្រសូតក្នុងទីកន្លែងមួយធម្មតា លោកជាសត្វដែលកើតមកក្នុងភពចុងក្រោយ

នរណា ៗ ក៏មិនអាចសម្លាប់បាន ព្រោះបានឧបនិស្ស័យនៃអរហត្តផល រុងរឿងក្នុងហឫទ័យរបស់លោក ដូចដួងប្រទីបដែលស្ថិតនៅក្នុងក្អម ដូច្នោះ មាតាចិញ្ចឹមគេមករហូតដល់វេលា ដែលគេអាចរត់លេងទៅមកបាន ក៏យកអំបែងឆ្នាំងដីមួយ មកដាក់លើដៃរបស់កូនបណ្ដើរ និយាយបណ្ដើរដោយពាក្យថា កូនអើយ ! ឯងចូរទៅកាន់ផ្ទះនោះចុះ ដូច្នោះហើយគេចខ្លួនបាត់ទៅ ចាប់ពីពេលនោះមក គេក៏រស់នៅតែម្នាក់ឯង ដើររកអាហារទៅតាមនិស្ស័យ រួចហើយក៏ត្រឡប់មកដេកនៅក្នុងទីកន្លែងមួយ មិនបានងូតទឹក មិនបានប្រណិប័តន៍រាង-កាយ មើលទៅដូចជាបិសាច ចិញ្ចឹមជីវិតមកបានដោយលំបាក, ពេលមានអាយុ ៧ ឆ្នាំ ដោយលំដាប់ ដើររើសគ្រាប់បាយស៊ី ដូចសត្វក្អែកក្នុងទីកន្លែងសម្រាប់ចាក់ទឹកលាងឆ្នាំងជិតទ្វារផ្ទះមួយ ។

គ្រានោះ ព្រះធម្មសេនាបតី ( សារីបុត្ត ) និមន្តបិណ្ឌបាតនៅក្នុងទីក្រុងសាវត្ថី ឃើញហើយរំពឹងគិតថា ក្មេងម្នាក់នេះ គួរឱ្យអាណិតណាស់ ជាកូនអ្នកភូមិណាហ្ន៎ ! ផ្សាយមេត្តាចិត្តទៅចំពោះក្មេងនោះ រួចហើយទើបហៅមកដោយពាក្យថា មកនេះក្មេងតូចគេមកថ្វាយបង្គំព្រះថេរៈហើយឈរនៅ លំដាប់នោះ ព្រះថេរៈសួរគេថា ឯងជាអ្នកភូមិណា ឪពុកម្ដាយរបស់ឯងនៅទីណា ?

គេឆ្លើយថា បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំព្រះករុណាមិនមាន

ទីពឹងទេ ឪពុកម្ដាយរបស់ខ្ញុំនិយាយថា ព្រោះខ្ញុំធ្វើឱ្យពួកគាត់លំបាក ទើបបោះបង់ខ្ញុំចោល ហើយចៀសចេញទៅ ។

ព្រះថេរៈសួរថា ឯងចង់បួសទេ ?

គេឆ្លើយថា បពិត្រលោកម្ចាស់ដ៏ចម្រើន ខ្ញុំព្រះករុណាចង់បួសណាស់ ប៉ុន្តែមនុស្សកំព្រាដូចខ្ញុំព្រះករុណា អ្នកណានឹងឱ្យបួស ។

ព្រះថេរៈពោលថា យើងនឹងឱ្យបួស ។

គេពោលថា សាធុ ! សាធុ ! លោកម្ចាស់មេត្តាអនុគ្រោះឱ្យខ្ញុំព្រះករុណាបួសផងចុះ ព្រះថេរៈទើបឱ្យរបស់ទំពាស៊ី របស់បរិភោគដល់គេហើយនាំទៅកាន់ព្រះវិហារ ងូតទឹកឱ្យដោយខ្លួនឯង រួចហើយឱ្យបព្វជ្ជា រហូតដល់គ្រប់អាយុទើបឱ្យឧបសម្បទ ក្នុងវេលាចាស់លោកមានឈ្មោះថា **លោសកតិស្សត្ថេរ** ជាភិក្ខុមិនមានបុណ្យ មានលាភតិច បានឮថា សូម្បីក្នុងគ្រា**អសទិសទាន** លោកក៏មិនធ្លាប់បានឆាន់ឆ្អែត បានឆាន់ត្រឹមតែល្មមនឹងបន្តអាយុជីវិតឱ្យប្រព្រឹត្តទៅបានប៉ុណ្ណោះ ព្រោះពេលដែលនរណា ១ យកបបរដាក់បាត្រលោកត្រឹមតែមួយវែកប៉ុណ្ណោះ បាត្រក៏ប្រាកដដូចពេញស្មើកណ្ដាប់មាត់ កាលបើដូច្នោះមនុស្សទាំងឡាយក៏សម្គាល់ថា បាត្ររបស់ភិក្ខុរូបនេះពេញហើយ ក៏ដាក់ប្រគេនអង្គក្រោយ ១ ទៀត អាចារ្យពួកខ្លះពោលថា ក្នុងវេលាថ្វាយយាគូក្នុងបាត្ររបស់លោក យាគូក្នុងភាជនៈរបស់-

មនុស្សទាំងឡាយ ក៏វិនាសបាត់ទៅ ដូច្នេះក៏មាន សូម្បីក្នុងបច្ច័យដទៃមានរបស់គួរទំពាជាដើម ក៏មានន័យនេះដូចគ្នា, ក្នុងសម័យជាខាងក្រោយមក លោកចម្រើនវិបស្សនា រហូតបានសម្រេចអរហត្តផល ដែលជាផលដ៏កំពូល ក៏គង់នៅមានលាភតិច កាលអាយុសង្ខាររបស់លោក ទ្រុឌទ្រោមចុះទៅដោយលំដាប់ ដល់ថ្ងៃដែលត្រូវបរិនិព្វាន ។

ព្រះធម្មសេនាបតី រំពឹងគិតទៅ ក៏ដឹងដល់ការបរិនិព្វានរបស់លោក ទើបត្រិះរិះថា ថ្ងៃនេះព្រះលោសកតិស្សត្ថេរ នឹងបរិនិព្វាន, ក្នុងថ្ងៃនេះយើងគួរឱ្យអាហារដល់លោកឱ្យបានឆ្អែតម្តង ដូច្នេះហើយនាំលោកចូលទៅកាន់ទីក្រុងសាវត្ថី ដើម្បីបិណ្ឌបាត ព្រោះនាំលោកទៅផង ព្រះថេរៈមិនបានទទួលសូម្បីត្រឹមតែការលើកដៃសំពះ ក្នុងទីក្រុងសាវត្ថីដែលមានពួកមនុស្សជាច្រើន ។

ព្រះថេរៈទើបពោលថា អាវុសោ លោកចូរទៅអង្គុយរង់ចាំនៅកន្លែងរោងឆាន់ចុះ ដូច្នេះហើយឱ្យលោកត្រឡប់ទៅវត្តវិញ លុះព្រះថេរៈមកអំពីទីនោះប៉ុណ្ណោះ ពួកមនុស្សក៏និយាយគ្នាថា ព្រះធម្មសេនាបតីមកហើយ និមន្តលោកឱ្យគង់លើអាសនៈ ឱ្យឆាន់ភត្តាហារ ព្រះថេរៈក៏បញ្ជូនអាហារ ដែលបានហើយនោះទៅដោយពោលជាមួយមនុស្សពួកនោះថា ពួកអ្នកចូរឱ្យភត្តនេះដល់ព្រះលោសកតិស្ស-

ត្ថេរ មនុស្សដែលទទួលភត្តនោះទៅ ក៏ភ្លេចព្រះលោសកតិស្សត្ថេរ នាំគ្នាបរិភោគអស់ទៅ រហូតដល់វេលាដែលព្រះធម្មសេនាបតី និមន្ត ទៅដល់ព្រះវិហារ ព្រះលោសកតិស្សត្ថេរក៏ទៅនមស្ការព្រះថេរៈ, ព្រះថេរៈបែរត្រឡប់មកឈរសួរថា អាវុសោ លោកបានឆាន់ចង្ហាន់ ហើយឬ ? លោកឆ្លើយថា មិនបានឆាន់ទេលោកម្ចាស់ ព្រះថេរៈដល់ នូវសេចក្ដីស្លុតចិត្ត មើលវេលាទៅក៏ឃើញថា កាលក៏នៅមិនទាន់ កន្លងហួសឡើយ ព្រះថេរៈទើបពោលថា ណ្ហើយចុះ លោកដ៏មាន-អាយុ លោកចូរអង្គុយនៅចាំកន្លែងដើមនោះសិន គ្រាឱ្យព្រះលោ-សកតិស្សត្ថេរអង្គុយរង់ចាំក្នុងរោងឆាន់ហើយ ក៏និមន្តទៅកាន់ព្រះ-រាជវាំងរបស់ព្រះបាទកោសល ព្រះរាជាបញ្ជាឱ្យទទួលបាត្ររបស់ ព្រះថេរៈ ទ្រង់កំណត់ថា មិនមែនកាលនៃភត្ត ទើបបញ្ជាឱ្យថ្វាយ របស់ផ្អែម ៤ យ៉ាង រហូតដល់ពេញបាត្រ ។

ព្រះថេរៈទទួលបាត្រត្រឡប់ទៅដល់វត្ត ទើបហៅព្រះលោ-សកតិស្សត្ថេរថា មកចុះអ្នកមានអាយុតិស្សៈ ឆាន់របស់ផ្អែម ៤ យ៉ាង នេះចុះ ហើយកាន់បាត្រឈរនៅ ព្រះលោសកតិស្សត្ថេរកោតក្រែង ព្រះថេរៈ គិតថានឹងមិនឆាន់ លំដាប់នោះ ព្រះថេរៈពោលដល់លោក ថា និមន្តមក លោកដ៏មានអាយុតិស្សៈ ខ្ញុំនឹងឈរកាន់បាត្រទុក លោក ចូរអង្គុយឆាន់ បើខ្ញុំដាក់បាត្រចុះអំពីដៃ បាត្រត្រូវមិនមានអ្វី លំដាប់-

នោះព្រះលោសកតិស្សៈ កាលព្រះធម្មសេនាបតីដែលជាអគ្គសាវ័ក ឈរកាន់បាត្រឱ្យ ទើបអង្គុយឆាន់របស់ផ្អែម ៤ យ៉ាង, របស់ផ្អែម ៤ យ៉ាងនោះ មិនដល់នូវសេចក្ដីអស់ទៅទេ ដោយកម្លាំងនៃឫទ្ធិរបស់ព្រះថេរៈ ព្រះលោសកតិស្សៈ ឆាន់រហូតដល់ឆ្អែតតាមសេចក្ដីត្រូវការក្នុងវេលានោះក្នុងថ្ងៃនោះឯង លោកក៏បរិនិព្វានដោយអនុបាទិសេស-និព្វានធាតុ ព្រះសម្មាសម្ពុទ្ធប្រថាប់គង់ក្នុងសម្នាក់របស់លោក ទ្រង់-បញ្ជាឱ្យធ្វើការបូជាសរីរៈ កសាងព្រះចេតិយបញ្ចុះធាតុរបស់លោកទុក ។

ក្នុងវេលានោះ ភិក្ខុទាំងឡាយប្រជុំគ្នាក្នុងធម្មសភា អង្គុយសន្ទនាគ្នាថា អ្នកមានអាយុទាំងឡាយ គួរអស្ចារ្យពិតមែន ព្រះលោ-សកតិស្សៈមានបុណ្យតិច មានលាភតិច ជាបុគ្គលមានបុណ្យតិចមានលាភតិចយ៉ាងនេះ ត្រាស់ដឹងអរិយធម៌បានយ៉ាងណា ។

ព្រះបរមសាស្ដា ស្ដេចយាងទៅកាន់ធម្មសភា មានព្រះពុទ្ធ-ដីកាសួរថា ម្នាលភិក្ខុទាំងឡាយ កាលអម្បាញ់មិញ ពួកលោកប្រជុំគ្នាដោយរឿងអ្វីហ្ន៎ ? កាលភិក្ខុពួកនោះ ក្រាបទូលឱ្យទ្រង់ជ្រាបហើយទើបត្រាស់ថា ម្នាលភិក្ខុទាំងឡាយ លោសកតិស្សៈ នេះ បានប្រកបកម្ម គឺភាពជាអ្នកមានលាភតិច និងភាពជាអ្នកបាននូវអរិយធម៌របស់-ខ្លួនដោយខ្លួនឯង អាស្រ័យដោយគ្រាមុន លោកធ្វើអន្តរាយលាភ

របស់អ្នកដទៃ ទើបជាអ្នកមានលាភតិច ប៉ុន្តែជាអ្នកត្រាស់ដឹងនូវ-អរិយធម៌បាន ដោយផលដែលបំពេញវិបស្សនា គឺ **អនិច្ចំ ទុក្ខំ អនត្តា** ដូច្នេះហើយ ទ្រង់នាំយករឿងក្នុងអតីតមក**សាធក** ដូចតទៅនេះ :

ក្នុងអតីតកាល ក្នុងសាសនារបស់ព្រះសម្មាសម្ពុទ្ធ ទ្រង់ព្រះ-នាមថា **កស្សបះ** ក្នុងកាលណោះមានភិក្ខុមួយរូប អាស្រ័យកុដុម្ពិកៈម្នាក់នៅក្នុងអាវាសជាប្រចាំ ជាអ្នកសង្រួមល្អ មានសីល ព្យាយាមបំពេញវិបស្សនា គ្រានោះ មានព្រះខីណាស្រពមួយអង្គនៅក្នុង-ព្រៃហិមពាន្ត បានមកដល់ភូមិដែលជាទីនៅរបស់កុដុម្ពិកៈ ដែលជា-ឧបដ្ឋាករបស់ភិក្ខុនោះដោយលំដាប់ កុដុម្ពិកៈជ្រះថ្លាក្នុងឥរិយាបថរបស់ព្រះថេរៈ ទើបទទួលបាត្រ និមន្តចូលកាន់ផ្ទះ ឱ្យឆាន់ភត្តាហារដោយគោរព ស្តាប់ព្រះធម្មកថាបន្តិចបន្តួច ហើយថ្វាយបង្គំព្រះថេរៈពោលថា បពិត្រព្រះគុណម្ចាស់ដ៏ចម្រើន និមន្តព្រះគុណម្ចាស់ ទៅកាន់វិហារ ជិតភូមិរបស់ខ្ញុំព្រះករុណាសិនចុះ វេលាល្ងាច ពួកខ្ញុំទើបទៅសួរសុខទុក្ខ ព្រះថេរៈទើបទៅកាន់វិហារ នមស្ការព្រះភិក្ខុ-ចៅអាវាសសាកសួរសំណេះសំណាលគ្នាហើយ អង្គុយក្នុងទីដ៏សមគួរភិក្ខុដែលជាចៅអាវាស ក៏ធ្វើបដិសណ្ឋារៈជាមួយលោកហើយសួរថាអ្នកមានអាយុ លោកបានទទួលភត្តាហារហើយឬ ?

លោកឆ្លើយថា បានហើយលោកម្ចាស់ ភិក្ខុចៅអាវាសសួរថា

លោកបានក្នុងទីណា ?

ព្រះអរហន្តខីណាស្រពជាអាគន្តុកៈឆ្លើយថា បានអំពីផ្ទះរបស់កុដុម្ពិកៈ នៅជិត ៗ វិហារនេះឯង គ្រាប្រាប់យ៉ាងនេះហើយ ក៏សួរដល់សេនាសនៈរបស់ខ្លួន ចាត់ចែងបោសសំអាត រក្សាបាត្រចីវរទុករៀបរយហើយ ក៏អង្គុយនូវជាសុខដោយសេចក្តីសុខក្នុងឈាន ដោយសេចក្តីសុខក្នុងផលសមាបត្តិ វេលាល្ងាចកុដុម្ពិកៈឱ្យមនុស្សកាន់យកកម្រងផ្កា និងប្រេងអុចប្រទីបទៅវិហារ នមស្ការភិក្ខុចៅអាវាសហើយសួរថា ព្រះគុណម្ចាស់ មានព្រះថេរៈអាគន្តុកៈមកសម្រាកមួយអង្គមិនមែនឬ ? លោកឆ្លើយថា ពរ មានមកសម្រាក គហបតីសួរថា ពេលនេះលោកសម្រាកនៅទីកន្លែងណាលោកម្ចាស់ ? ឆ្លើយថា ទីសេនាសនៈឯណោះ កុដុម្ពិកៈទៅកាន់សម្នាក់របស់លោក អង្គុយក្នុងទីដ៏សមគួរ ស្តាប់ធម្មកថារហូតដល់ព្រលប់ ទើបបូជា**ព្រះចេតិយ** និង**ដើមពោធិ អុជប្រទីបបំភ្លឺ** ហើយនិមន្តភិក្ខុទាំង ២ អង្គ ឱ្យទទួលភត្តក្នុងថ្ងៃស្អែក ហើយក៏ត្រឡប់ទៅផ្ទះវិញ ។

ចំណែកភិក្ខុដែលជាចៅអាវាសគិតថា កុដុម្ពិកៈនេះ ត្រូវភិក្ខុអាគន្តុកៈញុះញង់ឱ្យបែកគ្នាជាមួយយើងហើយ បើលោកអាស្រ័យនៅក្នុងវិហារនេះសោត ពេលណាកុដុម្ពិកៈនឹងរាប់អានយើង កើតសេចក្តីមិនពេញចិត្តក្នុងព្រះថេរៈ គិតថា យើងគួរសម្តែងអាការ មិនឱ្យ-

លោកនៅក្នុងវិហារនេះ ដូច្នេះហើយ ក្នុងវេលាដែលលោកមកប្រតិបត្តិ ក៏មិននិយាយជាមួយ ព្រះថេរៈជាព្រះខីណាស្រព ជ្រាបអធ្យាស្រ័យរបស់ភិក្ខុដែលជាចៅអាវាសហើយ គិតថា ភិក្ខុនេះមិនបានជ្រាបដល់ការដែលយើង មិនមានសេចក្តីជាប់ជំពាក់ក្នុងត្រកូលក្នុងលាភ ឬ ក្នុងពួក ហើយក៏ត្រឡប់ទៅទីនៅរបស់ខ្លួន គង់នៅដោយសេចក្តីសុខក្នុងឈាន និងសេចក្តីសុខក្នុងផលសមាបត្តិ, ដល់ថ្ងៃស្អែកឡើង ភិក្ខុដែលជាចៅអាវាស ក៏វាយរគាំងដោយខ្នងក្រចក គោះទ្វារដោយក្រចក ហើយទៅកាន់ផ្ទះរបស់កុដុម្ពិកៈ កុដុម្ពិកៈទទួលបាត្រនិមន្តឱ្យគង់លើអាសនៈដែលក្រាលទុក ហើយសួរថា បពិត្រលោក-ម្ចាស់ដ៏ចម្រើន ព្រះអាគន្តុកៈទៅណា ? ភិក្ខុចៅអាវាសឆ្លើយថា អាត្មាមិនជ្រាបសេចក្តីប្រព្រឹត្តរបស់ភិក្ខុ ដែលមានសេចក្តីស្និទ្ធស្នាលជាមួយញោម អាត្មាវាយរគាំងគោះទ្វារ ក៏មិនអាចដាស់លោកឱ្យភ្ញាក់បាន កាលពីម្សិលមិញលោកទៅឆាន់ភោជនដ៏ប្រណីតក្នុងផ្ទះរបស់ញោមហើយ គង់នៅឆ្អែតរហូតមកដល់ថ្ងៃនេះ ពេលនេះក៏នៅដេកលក់នោះឯង កាលញោមជ្រះថ្លា ក៏ជ្រះថ្លាក្នុងភិក្ខុដែលមានសភាពបែបនេះ, ចំណែកព្រះថេរៈ ដែលជាព្រះខីណាស្រព កំណត់វេលាភិក្ខាចាររបស់ខ្លួនហើយ ក៏ជម្រះសរីរៈរបស់ខ្លួនហើយ ទ្រង់បាត្រចីវរហោះទៅក្នុងអាកាស ( ប៉ុន្តែ ) បានទៅកាន់ទីកន្លែងដទៃ ។

កុដុម្ពិកៈនិមន្តភិក្ខុចៅអាវាស ឆាន់បាយបាយាស ដែលផ្សំដោយទឹកដោះថ្លា ទឹកឃ្មុំ ស្ករអំពៅ ហើយអប់បាត្រដោយរបស់ក្រអូប ដាក់បាយបាយាសរហូតដល់ពេញ ហើយពោលថា បពិត្រលោកម្ចាស់ដ៏ចម្រើន ព្រះថេរៈនោះ ប្រហែលជានឿយហត់អស់កម្លាំង ព្រះគុណម្ចាស់ ចូរនាំបាយបាយាសនេះទៅប្រគេនលោកផងចុះ ហើយថ្វាយបាត្រទៅ ភិក្ខុចៅអាវាសមិនហាមអីទេពេលហ្នឹង ព្រមទទួលបាត្រមក ដើរទៅបណ្ដើរគិតទៅបណ្ដើរថា បើភិក្ខុនោះបានទទួលបាយបាយាសនេះសោត សូម្បីយើងនឹងចាប់កអូសឱ្យចេញទៅក៏នឹងមិនទៅ បើយើងនឹងឱ្យបាយបាយាសនេះដល់មនុស្ស កម្មរបស់យើងក៏នឹងប្រាកដ បើចាក់ចោលដាក់ចុះក្នុងទឹកសោត ទឹកដោះថ្លាក៏នឹងប្រាកដលើទឹកបាន បើចាក់ទៅលើផែនដី ពួកហ្វូងក្អែកនឹងចោមរោមគ្នាស៊ី កម្មរបស់យើងក៏នឹងប្រាកដ គួរចាក់ចោលបាយ-បាយាសនេះទីណាល្អហ្ន៎ ! ឃើញវាលស្រែកំពុងឆេះមួយកន្លែង ក៏កកាយធ្យូងធ្វើជារណ្ដៅ ហើយចាក់បាយបាយាសចុះទៅ លុបដោយគំនរធ្យូង ហើយទើបទៅវិហារ គ្រាមិនឃើញភិក្ខុរូបនោះ ទើបគិតថា ភិក្ខុនោះច្បាស់ជាព្រះខីណាស្រព ដឹងអធ្យាស្រ័យរបស់យើងហើយនិមន្តចេញទៅកាន់កន្លែងដទៃជាពិតប្រាកដ ។ ឱ ! ព្រោះតែផ្ទៃជាហេតុឱ្យយើងធ្វើកម្មមិនសមគួរឡើយ ពេលរំពេចនោះឯង សេចក្ដី

ខូចចិត្តយ៉ាងខ្លាំងក៏កើតឡើងដល់ភិក្ខុនោះ ចាប់ផ្ដើមពីថ្ងៃនោះទៅ លោកក៏ក្លាយទៅជាមនុស្សប្រេត តមកមិនយូរប៉ុន្មានក៏ស្លាប់ទៅ ហើយទៅកើតក្នុងនរក ។

**ភិក្ខុនោះ** ឆេះនៅក្នុងនរកច្រើនសែនឆ្នាំ ផលរបស់អកុសល ដែលនៅសេសសល់ នាំឱ្យទៅកើតជា**យក្ខ**ចំនួន ៥០០ ជាតិ មិនធ្លាប់ បានស៊ីអាហារឆ្អែតផ្ទៃ សូម្បីត្រឹមតែមួយថ្ងៃ ( រហូតដល់ថ្ងៃត្រូវស្លាប់- ទើបបានស៊ីឆ្អែត ) គឺបានស៊ីអាហារឆ្អែតផ្ទៃមួយថ្ងៃ, ( បន្ទាប់ពីកើតជា យក្ខ ) ក៏ទៅកើតជា**ឆ្កែ** ៥០០ ជាតិ សូម្បីក្នុងកាលដែលកើតជាឆ្កែ នោះ ក៏បានស៊ីអាហារឆ្អែតផ្ទៃមួយថ្ងៃប៉ុណ្ណោះ ចំណែកក្នុងកាលដែល សល់ មិនធ្លាប់បានស៊ីឆ្អែតផ្ទៃឡើយ រហូតវេលាដែលនៅជាឆ្កែ ៥០០ ជាតិ ចុតិអំពីកំណើតឆ្កែ ក៏មកកើតក្នុង**ត្រកូលអ្នកកំសត់** ក្នុង**ដែនកាសី** តាំងអំពីថ្ងៃដែលកើត ត្រកូលនោះក៏រឹងរឹតតែលំបាកទៅ ៗ សូម្បីតែ- ទឹក និងបាយកន្លះផ្ទៃក៏មិនធ្លាប់បាន គេមានឈ្មោះថា **មិត្តវិន្ទុកៈ** ឪពុក ម្ដាយរបស់គេមិនអាចនឹងទ្រាំនូវសេចក្ដីទុក្ខ ដែលកើតអំពីសេចក្ដីអត់ ឃ្លានបាន ក៏និយាយថា ទៅចុះអាកូនកាឡកណ្ណី ដេញវាយកូនឱ្យ ចេញទៅ មិត្តវិន្ទុកៈមិនមានទីពឹង ត្រាច់ចរទៅរហូតដល់ទីក្រុង- ពារាណសី គ្រានោះព្រះពោធិសត្វ សោយព្រះជាតិជាអាចារ្យទិសា- បាមោក្ខ បង្រៀនសិល្បៈដល់មាណព ៥០០ នាក់ ក្នុងវេលានោះ អ្នក

ទីក្រុងពារាណសី ឱ្យរបស់បរិភោគដល់ពួកមនុស្សក្រីក្រកំសត់ ឱ្យសិក្សាសិល្បៈ សូម្បីក្មេងមិត្តវិន្ទុកៈនោះ ក៏បានសិក្សាសិល្បៈក្នុងសម្នាក់របស់ព្រះពោធិសត្វ មិត្តវិន្ទុកៈជាក្មេងមិនសុភាពរាបសា មិនជឿស្តាប់ឱវាទ ដើរវាយដើរទាត់ធាក់រំខានគេ សូម្បីព្រះពោធិសត្វអប់រំប្រៀន-ប្រដៅក៏មិនជឿស្តាប់ឱវាទ អាស្រ័យហេតុនោះ សេចក្តីចម្រើនធំធាត់របស់គេ ទើបបានទៅជាបុគ្គលល្ងង់ខ្លៅ គ្រានោះ គេកើតមានទំនាស់ឈ្លោះប្រកែកជាមួយនឹងក្មេង ៗ ទាំងមិនជឿស្តាប់ពាក្យប្រៀនប្រដៅក៏ចៀសចេញទៅ បានទៅដល់ភូមិមួយដែលនៅឯជាយដែន ស៊ីឈ្នួលគេចិញ្ចឹមជីវិត គេបានគ្នាជាមួយនឹងស្ត្រីក្រីក្រម្នាក់ នៅក្នុងភូមិនោះនាងមានបុត្តជាមួយនឹងគេ ២ នាក់ ពួកអ្នកស្រុកបានប្រគល់ការងារប្រាប់ដំណឹងឱ្យធ្វើថា ឯងគប្បីប្រាប់ដំណឹងល្អ ដំណឹងអាក្រក់ដល់ពួកយើង ពួកយើងនឹងឱ្យថ្លៃឈ្នួលនឹងសង់កូនខ្ទមឱ្យនៅត្រង់ទ្វារស្រុក ។ ព្រោះអាស្រ័យមិត្តវិន្ទុកៈនោះ ជាដើមហេតុឱ្យពួកអ្នកភូមិជាយដែននោះ ត្រូវរាជទណ្ឌ ៧ ដង ភ្លើងឆេះភូមិ ៧ ដង ពួកគេទើបពិភាក្សាគ្នាថា ពីមុនកាលដែលមិត្តវិន្ទុកៈម្នាក់នេះ នៅមិនទាន់មក ពួកយើងមិនធ្លាប់មានរឿងយ៉ាងនេះឡើយ ឥឡូវនេះ ចាប់តាំងពីពេលដែលមិត្តវិន្ទុកៈមកនៅហើយ ពួកយើងធ្លាក់ខ្លួនក្រលំបាកតាម ៗ គ្នា ទើប-នាំគ្នាចោមរោមវាយបណ្តេញគេចេញទៅ គេក៏នាំកូន ២ នាក់ ( និង-

ភរិយា ) ទៅនៅកន្លែងដទៃ បានចូលទៅកាន់ដងព្រៃដែលអមនុស្ស គ្រប់គ្រងថែរក្សាមួយកន្លែង ពួកអមនុស្សនាំគ្នាចោមរោម ចាប់កូន និងភរិយារបស់គេសម្លាប់ស៊ីសាច់អស់ក្នុងព្រៃនោះឯង ។

ចំណែកមិត្តវិន្ទុកៈនោះ អាចរត់គេចខ្លួនរួចបាន ដើរទៅ រឿយ ៗ បានមកដល់កំពង់ផែមួយកន្លែងឈ្មោះ **គម្ភីរ** ចួនជាថ្ងៃដែល គេត្រូវចុះសំពៅទៅធ្វើជំនួញ ក៏ស្ម័គ្រខ្លួនធ្វើជាកម្មករចុះសំពៅទៅ, សំពៅទៅក្នុងសមុទ្របាន ៧ ថ្ងៃ ដល់ថ្ងៃទី ៧ ក៏កឿងនៅកណ្ដាល-សមុទ្រ ដូចជាមាននរណាមកចាប់ទាញទុក អ្នកសំពៅពួកនោះក៏ ចាប់ស្លាករកមនុស្សកាឡកណ្ណី ស្លាកនោះធ្លាក់ទៅលើមិត្តវិន្ទុកៈម្នាក់ ប៉ុណ្ណោះរហូតដល់ ៧ ដង ពួកអ្នកសំពៅ ទើបយកកំណាត់ឬស្សីធ្វើ ជាក្បូនឱ្យគេមួយ ហើយជួយគ្នាចាប់ដៃមិត្តវិន្ទុកៈ បោះចុះទៅក្នុង-សមុទ្រ លុះបោះមិត្តវិន្ទុកៈចុះទៅក្នុងសមុទ្រប៉ុណ្ណោះ សំពៅក៏ធ្វើ ដំណើរស្ទុះទៅមុខទៀតបាន ។

មិត្តវិន្ទុកៈ ដេកលើក្បូនឬស្សីអណ្ដែតទៅក្នុងសមុទ្រ ដោយ ផលដែលបានរក្សាសីលទុក ក្នុងសាសនារបស់ព្រះសម្មាសម្ពុទ្ធ-កស្សបៈ ទើបបានជួប**ទេពធីតា ៤ នាក់** ដែលនៅក្នុងវិមាន**កែវផលិក** មួយខ្នងក្នុងសមុទ្រ សោយសុខសប្បាយ នៅក្នុងសម្នាក់ទេពធីតាពួក-នោះ រហូតដល់ ៧ ថ្ងៃ ពួកនាងទាំងនោះ ក៏ជា**ប្រេតមានវិមាន**នៅ

សោយសុខបាន ៧ ថ្ងៃ សោយទុក្ខ ៧ ថ្ងៃ វិលវល់ផ្លាស់ប្តូរទៅមក កាលនាងនឹងទៅសោយទុក្ខ ៧ ថ្ងៃ ក៏បានប្រាប់មិត្តវិន្ទុកៈថា លោកចូរនៅទីនេះកុំទៅណា រហូតដល់ពេលដែលពួកខ្ញុំមក ហើយក៏នាំគ្នាទៅ គ្រាពួកនាងនាំគ្នាទៅហើយ មិត្តវិន្ទុកៈក៏ចុះទៅដេកក្នុងក្បូនឫស្សី ក្បូនឫស្សីនោះក៏អណ្តែតទៅខាងមុខ បានជួប**ទេពធីតា ៨ នាក់** ក្នុង-វិមាន**ប្រាក់** ទេពធីតាពួកនោះ ក៏ជា**ប្រេតមានវិមាន**ដូចគ្នា មិត្តវិន្ទុកៈអណ្តែតតទៅ បានជួប**ទេពធីតា ១៦ នាក់** នៅក្នុងវិមាន**កែវមណី** ហើយក៏អណ្តែតតទៅ បានជួប**ទេពធីតា ៣២ នាក់** ក្នុងវិមាន**មាស** គេមិនបានស្តាប់ពាក្យរបស់ទេពធីតាពួកនោះដូចគ្នា ទើបអណ្តែតត-ទៅខាងមុខ ក៏បានជួប**នគរយក្ខ**មួយនៅក្នុងចន្លោះកោះ ក្នុងនគរនោះ មានយក្ខិនីមួយ និម្មិតខ្លួនជាមេពពែដើររកស៊ី មិត្តវិន្ទុកៈមិនបានដឹងថា មេពពែនោះជា យក្ខិនី គិតថាយើងនឹងស៊ីសាច់ពពែ លោតទៅចាប់វាត្រង់ជើង នាងយក្ខលើកមិត្តវិន្ទុកៈឡើង បោះចោលទៅដោយអានុភាពរបស់យក្ខ មិត្តវិន្ទុកៈត្រូវនាងយក្ខបោះចោលរំលងសមុទ្រ ទៅធ្លាក់ត្រង់គុម្ពោតព្រៃ ដែលមានបន្លាមួយកន្លែង ហើយក៏រមៀលធ្លាក់ចុះទៅលើផែនដី, ក្នុងគ្រានោះ មេពពែរបស់ព្រះរាជាច្រើនក្បាល ដើររកស៊ីនៅលើខ្នងប្រឡាយត្រូវពួកចោរលួចទៅ ពួក-អ្នកឃ្វាលពពែគិតគ្នាថា ពួកយើងត្រូវចាប់ចោរឱ្យបាន នាំគ្នាពួនស្ទាក់

នៅក្នុងទីកន្លែងមួយ ។

មិត្តវិន្ទុកៈ រមៀលធ្លាក់ចុះមកឈរនៅលើផែនដីហើយ បាន ឃើញមេពពែពួកនោះក៏គិតថា យើងចាប់មេពពែមួយក្បាលក្នុងកោះ នៅកណ្តាលសមុទ្រ ត្រូវវាបោះចោលមកធ្លាក់ទីនេះ ពេលនេះបើ យើងចាប់មេពពែមួយក្បាលត្រង់ជើង វាគង់គ្រវែងយើងចោល ត្រឡប់ទៅដល់សម្នាក់ទេពធីតា ដែលមានវិមាននៅក្នុងសមុទ្រដូច មុន គេចូលចិត្តធ្វើយ៉ាងនេះ ដោយមិនត្រិះរិះឱ្យបានល្អ ដូច្នេះហើយ ក៏លោតទៅចាប់មេពពែមួយក្បាលត្រង់ជើង លុះវាត្រូវគេចាប់ជើង ប៉ុណ្ណោះ ក៏ស្រែកយំឮសូរទ្រហឹង ពួកអ្នកឃ្វាលពពែក៏នាំគ្នារត់ស្រ ចូលមកដោយជុំវិញ នាំគ្នាស្រែកថា ពួកយើងរង់ចាំមកយូរហើយ អាចោរលួចស៊ីមេពពែក្នុងរាជត្រកូលនេះ អានេះឯង ដូច្នេះហើយនាំ គ្នាចោមរោម ហើយចាប់ចង នាំទៅកាន់ព្រះរាជវាំង ក្នុងខណៈនោះ ព្រះពោធិសត្វហែហមទៅដោយមាណព ៥០០ នាក់ ចេញអំពីទីក្រុង ទៅងូតទឹក ឃើញមិត្តវិន្ទុកៈក៏ចាំបាន ទើបនិយាយប្រាប់មនុស្សពួក នោះថា អ្នកទាំងឡាយ ម្នាក់នេះជាកូនសិស្សរបស់យើង ពួកលោក ចាប់គេព្រោះហេតុអ្វី ? មនុស្សពួកនោះឆ្លើយថា បពិត្រលោក-អាចារ្យ គេជាមនុស្សអាក្រក់លួចមេពពែរបស់ស្តេច ចាប់មេពពែ មួយក្បាលត្រង់ជើង ហេតុនោះ ពួកខ្ញុំទើបចាប់គេ ព្រះពោធិសត្វសូម

អង្វរថា បើដូច្នោះចូរឱ្យគេមកជាទាសៈរបស់ពួកយើងចុះ គេនឹងបាន អាស្រ័យពួកយើងចិញ្ចឹមជីវិតតទៅ មនុស្សពួកនោះទទួលពាក្យថា ល្អ ហើយលោកអាចារ្យ រួចដោះលែងគេ ហើយក៏នាំគ្នាទៅ លំដាប់នោះ ព្រះពោធិសត្វ ទើបសាកសួរមិត្តវិន្ទុកៈថា រហូតវេលាដែលបាត់មុខ ទៅនោះ ឯងទៅរស់នៅទីណាហ្ន៎ ? មិត្តវិន្ទុកៈ ក៏ពោលរៀបរាប់រឿង ដែលខ្លួនធ្វើទាំងអស់ឱ្យស្តាប់ ព្រះពោធិសត្វទើបពោលថា អ្នកដែល មិនធ្វើតាមពាក្យរបស់បុគ្គល ដែលមានបំណងល្អ រមែងបានទទួល នូវសេចក្តីទុក្ខយ៉ាងនេះ ហើយពោលគាថានេះដោយសេចក្តីថា :

**យោ អត្ថកាមស្ស ហិតានុកម្បិនោ**
**ឱវជ្ជមានោ នករោតិ សាសនំ**
**អជិយា បាទមោលុព្ភ មិត្តកោ វិយ សោចតីតិ ។**

**បុគ្គលណា កាលលោកអ្នកប្រាថ្នាសេចក្តីចម្រើន អនុគ្រោះ ដោយប្រយោជន៍ ទូន្មាន មិនធ្វើតាមពាក្យប្រៀនប្រដៅ បុគ្គល-នោះ រមែងសោកសៅ ដូចជាមិត្តវិន្ទុកៈប្រតោងជើងនៃមេពពែ សោកសៅ ។**

បណ្តាបទទាំងនោះ បទថា **អត្ថកាមស្ស** សេចក្តីថា អ្នក-ប្រាថ្នានូវសេចក្តីចម្រើន ។ បទថា **ហិតានុកម្បិនោ** សេចក្តីថា អ្នកអនុគ្រោះដោយប្រយោជន៍ ។ បទថា **ឱវជ្ជមានោ** សេចក្តីថា

ដាស់តឿនប្រៀនប្រដៅដោយចិត្តដែលទន់ភ្លន់ ។ បទថា **ន ករោតិ សាសនំ** សេចក្តីថា មិនធ្វើតាមពាក្យប្រៀនប្រដៅ គឺជាមនុស្ស ប្រដៅលំបាក ទូន្មានមិនបាន ។ បទថា **មិត្តកោ វិយ សោចតិ** សេចក្តីថា អ្នកនោះរមែងសោកសៅ រហូតអស់កាលជានិច្ច ដូច មិត្តវិន្ទុកៈម្នាក់នេះ ចាប់ជើងពពែហើយ រមែងសោកសៅ គឺលំបាក រស់នៅដូច្នេះ ព្រះពោធិសត្វសម្តែងធម៌ ដោយគាថានេះ ដែលមាន អត្ថាធិប្បាយដូចពណ៌នាមកនេះ ។

ព្រះថេរៈនោះ ធ្លាប់បានអាហារឆ្អែតផ្អែក្នុងអត្តភាពទាំង ៣ នេះ គឺគ្រាកើតជាយក្ខបានស៊ីអាហារឆ្អែតមួយថ្ងៃ, គ្រាកើតជាឆ្កែ បានស៊ីអាហារ ( កម្អួត ) ឆ្អែតមួយថ្ងៃ, គ្រាចុងក្រោយក្នុងថ្ងៃបរិ-និព្វាន បានឆាន់របស់ផ្អែម ៤ យ៉ាង ឆ្អែតដោយអានុភាពរបស់ព្រះ-ធម្មសេនាបតីសារីបុត្ត កម្មដែលឈ្មោះថា ការធ្វើអន្តរាយដល់លាភ របស់អ្នកដទៃ គប្បីជ្រាបថា មានទោសច្រើនយ៉ាងនេះ ។

ព្រះពោធិសត្វដែលជាអាចារ្យ និងមិត្តវិន្ទុកៈក្នុងគ្រានោះ ក៏ បានទៅតាមយថាកម្ម ។

ព្រះបរមសាស្តាត្រាស់ថា ម្នាលភិក្ខុទាំងឡាយ ព្រះលោស-កតិស្សៈនោះ បានមកជាអ្នកមានលាភតិច និងសេចក្តីជាអ្នកបាន អរិយធម៌ឱ្យដល់ខ្លួន ដោយខ្លួនឯងយ៉ាងនេះឯង គ្រាទ្រង់នាំព្រះធម្ម-

ទេសនានេះមកសម្ដែងហើយ ទើបទ្រង់បន្តអនុសន្ធិប្រជុំជាតកថា មិត្តវិន្ទុកៈក្នុងកាលនោះ បានមកជាព្រះលោសកតិស្សត្ថេរ ក្នុងពេលនេះ អាចារ្យទិសាបាមោក្ខក្នុងកាលនោះ គឺបានមកជាយើងតថាគតនេះឯង ។

## ចប់រឿងមិត្តវិន្ទុកៈ

## ( ក្នុងលោសកជាតក )

**ន វេ អនរិយា ទេវលោកំ វជន្តិ**
**ពាលា ហវេ នប្បសំសន្តិ ទានំ**
**ធីរោ ច ទានំ អនុមោទមានោ**
**តេនេវ សោ ហោតិ សុខី បរត្ថ ។**

បុគ្គលកំណាញ់ស្វិតស្វាញ មិនបានទៅកាន់ទេវលោកទេ ជនពាលទាំងឡាយ មិនសរសើរទានឡើយ ចំណែកអ្នកប្រាជ្ញតែងអនុមោទនាទាន ព្រោះហេតុនោះ លោកតែងបានសេចក្ដីសុខក្នុងលោកខាងមុខ ។

# រឿងបុរោហិត

" អំណាចនៃឧបោសថសីលពាក់កណ្ដាល "

( មង្គលប្រែ ភាគ ៣, ទំព័រ ២១៨ )

ក្នុងអតីតកាល ព្រះពោធិសត្វ សោយព្រះជាតិជាព្រះរាជា ក្រុងពារាណសី ព្រះអង្គមិនទ្រង់ប្រមាទ ដោយព្រះអង្គឯង ក្នុងទាន សីល និងឧបោសថកម្ម ទ្រង់បានបបួល នូវអាមាត្យជាដើម សូម្បី-ដែលសេសសល់ ក្នុងទានជាដើម ។ ចំណែកបុរោហិត របស់ព្រះពោធិសត្វនោះ ត្រូវព្រះពោធិសត្វ តែងតាំងហើយ ក្នុងតំណែងវិនិច្ឆ័យ ជាអ្នកស៊ីសាច់ឆ្អឹងខ្នង របស់ជនដទៃ ដោយការស៊ីសំណូក ទើបមិនមានទាន ។ ក្នុងថ្ងៃឧបោសថថ្ងៃមួយ បុរោហិតនោះទទួលសំណូក កាត់ក្ដីកោង រហូតមួយថ្ងៃ ហើយបានទៅកាន់ទីឧបដ្ឋាកនៃព្រះរាជា ត្រូវព្រះរាជាត្រាស់សួរថា " ម្នាលអាចារ្យ លោករក្សាឧបោសថឬ ? " ដូច្នេះហើយ ក្រាបទូលកុហកថា " ពិតមែនហើយព្រះអង្គដ៏ចម្រើន " ហើយបានចុះអំពីប្រាសាទ ។ គ្រានោះ អាមាត្យម្នាក់ ចោទបុរោហិតនោះថា " លោកជាអ្នកមិនរក្សាឧបោសថ មិន-មែនទេឬ ? " ។ បុរោហិតនោះ ពោលថា " ខ្ញុំ បរិភោគតែក្នុងវេលា

ប៉ុណ្ណោះ ទៅផ្ទះហើយ ខ្ពុរមាត់ស្រេច នឹងអធិដ្ឋានទូវឧបោសថ មិនបរិភោគ ក្នុងវេលាល្ងាច, ខ្ញុំនឹងរក្សាសីល ក្នុងវេលារាត្រី, បើដូច្នោះ ឧបោសថកម្មពាក់កណ្ដាល នឹងមានដល់ខ្ញុំ " ដូច្នេះហើយ ក៏ទៅផ្ទះ បានធ្វើហើយ យ៉ាងដូច្នោះឯង ។ ក្នុងថ្ងៃឧបោសថថ្ងៃមួយទៀត ស្ត្រីអ្នកមានសីលម្នាក់ កំពុងកាត់សេចក្ដី កាលមិនបាន ដើម្បី-នឹងទៅផ្ទះបាន ក៏គិតថា " អាត្មាអញ នឹងមិនកន្លងឧបោសថកម្ម " ដូច្នេះ, កាលបើវេលា ចូលខិតមកជិតហើយ, ក៏បានប្រារព្ធ ដើម្បីនឹងលាងមាត់ ។ បុរោហិតនោះ ដឹងថាស្ត្រីនោះ ជាអ្នករក្សាឧបោសថ ទើបពោលថា " ចូរនាងបរិភោគផ្លែស្វាយនេះហើយ រក្សាឧបោសថចុះ " ហើយក៏បានឱ្យផ្លែស្វាយ ដល់ស្ត្រីនោះ ។ កម្មរបស់បុរោហិតមានតែប៉ុណ្ណេះ ។ ក្នុងកាលក្រោយមក បុរោហិតនោះ បានធ្វើមរណកាលហើយ បានកើតជាវេមានិកប្រេត មាននាងទេវកញ្ញា ១ ម៉ឺន ៦ ពាន់ ចោមរោមហើយ ក្នុងវិមានមាស ក្នុងព្រៃស្វាយ ប្រវែង ៣ យោជន៍ ក្បែរមាត់ទន្លេគង្គា ក្នុងព្រៃហិមវន្តប្រទេស ។ ក៏វេមានិកប្រេតនោះ សោយសម្បត្តិ តែក្នុងវេលារាត្រីប៉ុណ្ណោះ, កាលបើព្រះអរុណរះឡើង, ក៏ចូលទៅកាន់ព្រៃស្វាយ ។ ក្នុងពេលដែលវេមានិកប្រេតនោះចូលទៅនុ៎ះឯង អត្តភាពដែលជាទិព្វ ក៏អន្តរ-ធានបាត់ទៅ, អត្តភាព មានទំហំប៉ុនដើមត្នោត ប្រវែង ៨០ ហត្ថ ក៏-

កើតឡើង ។ សរីរៈទាំងអស់ ត្រូវភ្លើងឆេះ បានដូចជាផ្ការលួសផ្អុង ( ផ្កាចារ ) ដែលរីកក្រហមច្រាល ។ ក្នុងដៃទាំង ២ មានម្រាមដៃម្ខាងមួយ ៗ ប៉ុណ្ណោះ ។ លើម្រាមដៃនោះ មានក្រចកទំហំប៉ុនចបដ៏ធំ ។ វេមានិកប្រេតនោះ យកក្រចកទាំងនោះ ហែកសាច់ខ្នងរបស់ខ្លួន ខ្វេះទាញមកហើយ ៗ ទំពាស៊ី បានទទួលសេចក្ដីឈឺចាប់ស្រែកយំក្ដែង ៗ សោយនូវសេចក្ដីទុក្ខ ។ កាលបើព្រះអាទិត្យអស្ដង្គតទៅហើយ, សរីរៈនោះ ក៏អន្តរធានបាត់ទៅ, សរីរៈដែលជាទិព្វ ក៏កើតឡើង ។ ស្ត្រីអ្នករបាំដ៏ជាទិព្វទាំងឡាយ អ្នកប្រដាប់តាក់តែងហើយ ក៏នាំគ្នាកាន់តន្ត្រីផ្សេង ៗ មកចោមរោម នូវ-វេមានិកប្រេតនោះ ។ វេមានិកប្រេតនោះ សោយនូវមហាសម្បត្តិឡើងកាន់ប្រាសាទទិព្វ ក្នុងព្រៃស្វាយ ជាទីមនោរម្យ ។ វេមានិកប្រេតនោះ បានព្រៃស្វាយ ប្រវែង ៣ យោជន៍ ព្រោះផលនៃការឱ្យផ្លែស្វាយដល់ស្ត្រីអ្នករក្សាឧបោសថ, គាត់ខ្វេះហែកសាច់ខ្នងស៊ី ព្រោះផលនៃការទទួលសំណូកហើយ កាត់សេចក្ដីមិនបានយុត្តិធម៌, គាត់បានសោយនូវយសដ៏ធំ ក្នុងវេលាយប់ ព្រោះផលនៃការរក្សានូវឧបោ-សថកម្មពាក់កណ្ដាល ដោយប្រការដូច្នេះ ។

សូម្បីព្រះសាស្ដា កាលទ្រង់សម្ដែងធម៌ ដល់ពួកឧបាសកអ្នករក្សាឧបោសថ ទើបទ្រង់ត្រាស់ថា " ម្នាលឧបាសកទាំងឡាយ អ្នក-

ទាំងឡាយ រក្សាឧបោសថ ធ្វើកម្មប្រសើរហើយ, បុរាណបណ្ឌិតទាំង-ឡាយ បានសោយនូវយសដ៏ធំ ព្រោះផលនៃការរក្សានូវឧបោសថកម្មពាក់កណ្ដាល ” ដូច្នេះ ទ្រង់ញុំាងរឿងនេះ ឱ្យបានពិស្ដារហើយ ទ្រង់-ត្រាស់**កឹឆន្ទជាតក**[១] ដែលជាជាតកខាងដើម នៃជាតកទាំងពួងក្នុង**តឹសនិបាត** ទ្រង់បានប្រកាសសច្ចៈហើយ ។ ក្នុងវេលាចប់សច្ចៈ បណ្ដាឧបាសកទាំងឡាយ ឧបាសកពួកខ្លះ បានជាសោតាបន្ន, ពួកខ្លះ បានជាសកទាគាមី, ពួកខ្លះ បានជាអនាគាមី ។

## ( ចប់រឿងបុរោហិត )

១. **កឹឆន្ទជាតក** ( បិ. ៦០ ទំ. ១៤៩ )

# គម្ពីរសម្រាប់ជំនួយក្នុងការរៀបរៀងសៀវភៅនេះ

-ព្រះត្រៃបិដក និងអដ្ឋកថា

-បរមត្ថទីបនី អដ្ឋកថាខុទ្ទកនិកាយ

-បទានុក្រម

-អភិធានវណ្ណនា

-ច្បាប់ឆដ្ឋសង្គាយនា

-វចនានុក្រមខ្មែរសម្តេចព្រះសង្ឃរាជ **ជ.ណ. ជោតញ្ញាណោ** និង គម្ពីរផ្សេង ៗ ទៀត ។

# នាមពុទ្ធបរិស័ទដែលមានសទ្ធា
# បរិច្ចាគប្រាក់ក្នុងការបោះពុម្ពសៀវភៅនេះ

<u>ព្រះភិក្ខុសាមណេរវត្ត **កច្ឆបបពិត** "ភ្នំអណ្ដើក" និង បរិស័ទផ្សេងៗ</u>

| | | |
|---|---|---|
| ១. | ភិក្ខុ **សច្ចកល្យាណោ** នូវ សារឿន ( គ្រូសូត្រធ្វេង ) ......= | ១៥០ $ |
| ២. | ភិក្ខុ ញ៉ឹក ឈាង ............................................= | ២០០.០០០៛ |
| ៣. | សីលវតី ខែន សុខា ( SiyaLay Ly ) ..................= | ៥០ $ |
| ៤. | ភិក្ខុ វ៉េង លីង្វ............................................= | ១៣០.០០០៛ |
| ៥. | ភិក្ខុ **ញាណសារោ** យ៉ាវ សំអឿន ព្រមទាំងញាតិធម៌......= | ១០០.០០០៛ |
| ៦. | ឧបាសិកា ប៉ាន នួន ( ហៅយាយស្លឹកគ្រៃ ) .................= | ២០ $ |
| ៧. | ភិក្ខុ គីន សុទុំ ..............................................= | ៦០.០០០៛ |
| ៨. | ភិក្ខុ ឡាន សំណាង.........................................= | ៦០.០០០៛ |
| ៩. | លោកម្ចាស់ **យន្តធរោ** អុន សារេន ......................= | ៥០.០០០៛ |
| ១០. | ភិក្ខុ ចន កែវ................................................= | ៥០.០០០៛ |
| ១១. | ភិក្ខុ **ចិន្តកវិ** នូវ សារ៉ាន..................................= | ៥០.០០០៛ |
| ១២. | ភិក្ខុ **តិស្សត្ថេរោ** តាវ អ៊ីរ៉ុន ព្រមទាំងញោមប្រុសស្រី......= | ៥០.០០០៛ |
| ១៣. | ភិក្ខុ សេង សុជាតិ .........................................= | ៥០.០០០៛ |
| ១៤. | ភិក្ខុ គីន គីម ................................................= | ៥០.០០០៛ |
| ១៥. | សាមណេរ ណាន់ វ៉ាឃីម.....................................= | ៥០.០០០៛ |

១៦. សាមណេរ អ៊ូច ធាង ...................................= ៥០.០០០៛
១៧. ភិក្ខុ ជឹម សារ៉ុន ........................................= ៤០.០០០៛
១៨. ភិក្ខុ គួន សំឡូត........................................= ៤០.០០០៛
១៩. ភិក្ខុ អឿម វិចិត្រ........................................= ៤០.០០០៛
២០. ភិក្ខុ បេ ប៊ុនធូ.............................................= ៤០.០០០៛
២១. ភិក្ខុ សឹម សួន ............................................= ៤០.០០០៛
២២. ភិក្ខុ អ៊ួន អាន់ ...........................................= ៤០.០០០៛
២៣. សាមណេរ ហ៊ីន បញ្ញា ..................................= ៤០.០០០៛
២៤. សាមណេរ សៀង សំអូន.................................= ៤០.០០០៛
២៥. សាមណេរ វ៉ាន់ ណារីត .................................= ៤០.០០០៛
២៦. សាមណេរ វឿន វណ្ណា ..................................= ៤០.០០០៛
២៧. សាមណេរ ផន រក្សា .....................................= ៤០.០០០៛
២៧. សាមណេរ កែត សីហា....................................= ៤០.០០០៛
២៨. សាមណេរ សឿន វិស័យ.................................= ៤០.០០០៛
២៩. សាមណេរ សៀង មី .......................................= ៤០.០០០៛
៣០. សាមណេរ ជួន ដារ៉ូ .......................................= ៤០.០០០៛
៣១. សាមណេរ ភក្ត្រ័ សុផល.................................= ៤០.០០០៛
៣២. សាមណេរ អង់ កុសល....................................= ៣៥.០០០៛
៣៣. ភិក្ខុ អ៊ុម អាន់...........................................= ៣០.០០០៛
៣៤. ភិក្ខុ អ៊ុង រុំ ...............................................= ៣០.០០០៛
៣៥. ភិក្ខុ គួយ គង់ ............................................= ៣០.០០០៛
៣៦. ភិក្ខុ ញ៉ែម សុផាន .......................................= ៣០.០០០៛

៣៧. សាមណេរ សាន ថាវីន.......................................= ៣០.០០០៛
៣៨. ភិក្ខុ ឡាំ យិន.............................................= ២០.០០០៛
៣៩. ភិក្ខុ ទុយ តេង ...........................................= ២០.០០០៛
៤០. ភិក្ខុ ហួត ប៉ាវ.............................................= ២០.០០០៛
៤១. ភិក្ខុ សុមេធ ឆព្វណ្ណ......................................= ២០.០០០៛
៤២. ភិក្ខុ ឈុន ឱ ..............................................= ២០.០០០៛
៤៣. ភិក្ខុ គង់ ម៉ាញ ...........................................= ២០.០០០៛
៤៤. ភិក្ខុ ហូ ហាន.............................................= ២០.០០០៛
៤៥. ភិក្ខុ ឡាយ សុផារិទ្ធ......................................= ២០.០០០៛
៤៦. សាមណេរ ផេង សេរី........................................= ២០.០០០៛
៤៧. សាមណេរ មឿន មុន្នី ......................................= ២០.០០០៛
៤៨. សាមណេរ ជា សុជេន ......................................= ២០.០០០៛
៤៩. សាមណេរ ផន សុភា........................................= ២០.០០០៛
៥០. សាមណេរ ធី សាមុត .......................................= ២០.០០០៛
៥១. សាមណេរ ញៀប សុធិ.......................................= ២០.០០០៛
៥២. សាមណេរ ប៉ស់ រស្មី .......................................= ២០.០០០៛
៥៣. សាមណេរ ផន សុភាព.......................................= ២០.០០០៛
៥៤. សាមណេរ សុះ សុភា .......................................= ២០.០០០៛
៥៥. សាមណេរ អ៊ុង សុផា .......................................= ២០.០០០៛
៥៦. សាមណេរ ហៀវ សីហា .....................................= ២០.០០០៛
៦៧. សាមណេរ ចុល ទីណា.......................................= ២០.០០០៛
៥៨. សាមណេរ អឿន សំណាង ..................................= ២០.០០០៛

៥៩. សាមណេរ រឹម រ៉ារីត........................................= ២០.០០០៛

៦០. សាមណេរ ទី សេងហុង ...................................= ២០.០០០៛

៦១. សាមណេរ សឿង ស្រស់.....................................= ២០.០០០៛

៦២. សាមណេរ ឆោម ឆៃអ៊ី.......................................= ២០.០០០៛

៦៣. ឧបាសក សួន សឿន ព្រមទាំងភរិយា......................= ២.០០០០៛

៦៤. ភិក្ខុ សៅ ដួង..................................................= ១០.០០០៛

៦៥. ភិក្ខុ សុះ ម៉ៅ .................................................= ១០.០០០៛

៦៦. ភិក្ខុ **សារានន្ទោ** ឡាំ សុផាត ( ក្រឡាញ់ ) ................= ១០០.០០០៛

៦៧. ភិក្ខុ **យន្តធម្មោ** ង៉ែត យន ( ក្រឡាញ់ ) ...................= ៥០.០០០៛

៦៨ { ឧបាសិកា ឈឹម សាវតា និងស្វាមី លឹម ចាន់ថន<br>កូនប្រុស លឹម វុឌ្ឍី<br>កូនស្រី លឹម សុរិលីន និងស្វាមី ព្រមទាំងបុត្រ } ........= ៥០ $

៦៩. ឧបាសក គង់ ញាស់ និងឧបាសិកា អ៊ុល គឹង...............= ១០០.០០០៛

៧០. លោក អ៊ុល លីកូ និងរិន វាសនា ........................= ៥០.០០០៛

៧១. ផាន់ធារិទ្ធ និងរិន សុវណ្ណគង្គា.............................= ៥០.០០០៛

៧២. លោក ញាស់ សុគុន និងអ្នកស្រី ហុក បណ្តូល ...........= ២០.០០០៛

៧៣. កញ្ញា សុគុន ស្ទូគាំ..............................................= ២០.០០០៛

៧៤. លោក ញឹកទូច និងអ្នកស្រី ញាស់ វលក្ខណ៍..............= ២០.០០០៛

៧៥. កញ្ញា ញឹក ភាឡី..................................................= ២០.០០០៛

៧៦. កញ្ញា ញឹក ភាណា.................................................= ២០.០០០៛

៧៧. លោក គួ ធារ៉ា និងអ្នកស្រី ញាស់ ថាវរី ..................= ២០.០០០៛

៧៨. លោក ញាស់ ស៊ីដេន និងអ្នកស្រី យ៉ន គឹមលាង .........= ២០.០០០៛

៧៩- យុវជន គួ ចាន់មុនី ( ហៅ អាកៅ )......................= ២០.០០០៛

៨០- កុមារា គួ វិច្ឆិកា ( ហៅ អាកា )..........................= ១០.០០០៛

៨១- ឧបាសិកា យស់ ចុន .........................................= ១០.០០០៛

៨២- ឧបាសក ឆាំ ភ្លឹង និង ឧបាសិកា ផាង ចាក់................= ១០.០០០៛

៨៣- ឧបាសក ឆាំ ភឿន និង ឧបាសិកា រេម ...................= ១០.០០០៛

៨៤- លោកយាយ ច្រិប ..............................................= ១០.០០០៛

៨៥- ឧបាសិកា សុត គីម ស៊ាន និងកូនប្រុស យិន វីរៈ ..........= ៥០ $

៨៦- ឧបាសិកា លឹម លឿន .........................................= ១០.០០០៛

៨៧- ឧបាសិកា កាន់ នូវ............................................= ១០.០០០៛

៨៨- ឧបាសិកា អ៊ុន អោក.........................................= ១០.០០០៛

៨៩- ឧបាសិកា ព្រួញ សាខន.......................................= ១០.០០០៛

៩០- ឧបាសិកា ហ៊ុន ឈឿន .......................................= ១០.០០០៛

៩១- លោក លឹម ណារិន និង អ្នកស្រី..............................= ១០.០០០៛

៩២- លោក ម៉ៅ នាង លក្ខណ.......................................= ១០.០០០៛

៩៣- លោក រិន រ៉ាត់ និង អ្នកស្រី....................................= ១០.០០០៛

៩៤- ឧបាសិកា ស៊ីត សារេត .......................................= ២០.០០០៛

# សព្វទានំ ធម្មទានំ ជិនាតិ

## ធម្មទានឈ្នះអស់ទានទាំងពួង

# វាចារបស់ប្រេត

ឯតញ្ច  ភន្តេ  អវហាម  អញ្ញញ្ច  ចាបកំ តតោ

សន្តេសុ  ទេយ្យធម្មេសុ  ទីបំ  នាកម្ហមត្តនោ ។

*-បពិត្រលោកដ៏ចម្រើន  ពួកយើងគួរទទួល  នូវបាបកម្មនោះផង  ទទួលនូវបាបកម្មដទៃពីនោះផង  នាកាលទេយ្យធម៌ទាំងឡាយមាន  ពួកយើងមិនបានធ្វើនូវទីពឹងដល់ខ្លួនសោះ ។*

តេហិ នូន ឥតោ គន្ត្វា  យោនឹ លទ្ធាន មានុសឹ

វទញ្ញូ  សីលសម្បន្នា  កាហាម កុសលំ ពហុំ ។

*-បើដូច្នោះ  ពួកយើងលុះរដោះចាកប្រេតនេះទៅ  សូម-បានកើតជាមនុស្ស  ជាអ្នកបរិបូណ៌ដោយសីល  ធ្វើកុសលឱ្យបានច្រើន  អំពីដឹងក្តីទៅ ។*

( បិដកលេខ ៥៦, ទំព័រ ១២៩ )

ISNB-9789996331206

9 789996 331206